ឯកសារព័ត៌មាន

ផ្សាយនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម

របស់អាជ្ញាធរជាតិអប្សរា

ឆ្នាំ ២០១៧ ប្រចាំឆមាសទី១





ប្រសាសន៍លោកជំទាវប្រធានអាជ្ញាធរជាតិអប្សរា



វិញ្ញាបនប័ត្រ ISO 14001



ព័ត៌មាន និង ព្រឹត្តិការណ៍



អបអរសាទរ! ប្រាសាទអង្គរវត្តរបស់ខ្មែរជាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុតលើពិភពលោកក្នុងឆ្នាំ២០១៧

មតិស្វាគមន៍ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា



info@apsaraauthority.gov.kh

www.apsaraauthority.gov.kh

www.facebook.com/apsaraautorite

www.youtube.com/apsara authority

អារម្ភកថា

សកម្មភាពដែលបានធ្វើហើយ វាបានកន្លងទៅជាមួយនឹងពេលវេលា។ មានតែការកត់ត្រាទុកប៉ុណ្ណោះ ដែលអាចជួយឲ្យយើងនឹកឃើញសកម្មភាពទាំងនោះឡើងវិញ។ ឯកសារខ្លះមានតម្លៃត្រឹមជាឯកសារយោងសម្រាប់ការងាររក្រោយៗទៀត ប៉ុន្តែឯកសារខ្លះ គឺមានតម្លៃជាប្រវត្តិសាស្ត្រ ដែលអាចជាមេរៀនសម្រាប់ក្មេងជំនាន់ក្រោយៗទៀត។

នាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា បានកត់ត្រានិងផ្សព្វផ្សាយជាប្រចាំនូវរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំ និងសកម្មភាពការងារនៃអាជ្ញាធរជាតិអប្សរា តាមរយៈបណ្តាញទំនាក់ទំនងសង្គម គេហទំព័រ និងចែកចាយទៅតាមបណ្តាញសារព័ត៌មានជាដៃគូជាច្រើនទៀត។ ឯកសារទាំងនេះ បានជ្រួតជ្រាបដល់មហាជនទាំងក្នុងឧទ្យានអង្គរ និងមហាជនទូទៅ និងបានបង្កើនការយល់ដឹងជំរុញឲ្យមានចូលរួមអភិរក្សបេតិកភណ្ឌទៀតផង។

ដើម្បីឲ្យឯកសារទាំងនេះកាន់តែមានប្រយោជន៍សម្រាប់ជាឯកសារយោង និងជាឯកសារស្រាវជ្រាវបន្តទៀតនោះ នាយកដ្ឋានផ្សព្វផ្សាយបានរៀបចំបោះពុម្ពនូវអត្ថបទផ្សព្វផ្សាយទាំងអស់ ជាសៀវភៅទុកជាឯកសារតម្កល់ប្រចាំឆ្នាំ។ ឯកសារទាំងនេះ ត្រូវបានដាក់រៀងតាមខែនីមួយៗ ហើយនៅខាងចុងនៃសៀវភៅមានឧបសម្ព័ន្ធ ដែលអាចជួយឲ្យអ្នកអានងាយស្វែងរកអត្ថបទដែលត្រូវការ។

អត្ថបទដែលមានក្នុងសៀវភៅនេះនិយាយអំពី សកម្មភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា កិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិរក្ស និងជួសជុល ការគ្រប់គ្រងបរិស្ថាន ទឹក និងព្រៃឈើ ការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍទេសចរណ៍ ការអភិវឌ្ឍសហគមន៍ ពិធីទំនៀមទម្លាប់អ្នកស្រុកអង្គរ និងអត្ថបទផ្សេងៗទៀតដែលទាក់ទងនឹងចំណេះដឹងអំពីបេតិកភណ្ឌពិភពលោកអង្គរ។

នាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរាសង្ឃឹមថា សៀវភៅនេះនឹងបានជាប្រយោជន៍ដល់អ្នកស្រាវជ្រាវ និងសាធារណជនទូទៅដែលចង់ដឹងអំពីសកម្មភាពរបស់អាជ្ញាធរជាតិអប្សរា ក៏ដូចជាប្រពៃណីទំនៀមទម្លាប់របស់អ្នកស្រុកអង្គរ។

ទោះជាក្រុមការងារបានធ្វើការងារនេះ ដោយសម្រិតសម្រាំង និងប្រុងប្រយ័ត្នខ្ពស់យ៉ាងណាក្តី កំហុសដោយអចេតនាផ្នែកអក្ខរាវិរុទ្ធ ឬកំហុសបច្ចេកទេសណាមួយច្បាស់ជាកើតមានឡើងជាក់ជាមិនខាន។ នាយកដ្ឋានផ្សព្វផ្សាយសូមខន្តីអភ័យទោសអំពីសំណាក់អ្នកអានទាំងអស់ចំពោះកំហុសឆ្គងទាំងនោះ ហើយរង់ចាំការរិះគន់ក្នុងន័យស្ថាបនាដោយសេចក្តីសប្បាយរីករាយ។

សៀមរាប ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៧

ប្រធាននាយកដ្ឋានផ្សព្វផ្សាយ

ឡុច កុសល

មាតិកា

ចំណងជើងព័ត៌មាន **លេខទំព័រ**

អារម្ភកថា i

មាតិកា iii

ឧបសម្ព័ន្ធ..... ២៦៩

ផ្នែកទី ១
ប្រចាំខែមករា

- នៅតំបន់អង្គរមានសិលាចារឹកជាភាសាភូមាចំនួន១១កន្លែងផ្សេងគ្នា ១
- អាជ្ញាធរជាតិអប្សរានឹងបើកវគ្គបណ្តុះបណ្តាលភាសាចិនដល់មន្ត្រី-បុគ្គលិក ២
- វីដេអូ ៖ អាជ្ញាធរជាតិអប្សរានឹងបើកវគ្គបណ្តុះបណ្តាលភាសាចិនដល់មន្ត្រី-បុគ្គលិក ៣
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រឹមែកឈើងាប់ រស់
  នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ ៤
- អាជ្ញាធរជាតិអប្សរាបន្តជំរុញប្រជាពលរដ្ឋក្នុងឧទ្យានអង្គរឲ្យប្រើប្រាស់បង្គន់អនាម័យ ៥
- សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរជួសជុលបាន៦០%ហើយ ៦
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធ អតីតយុទ្ធជននៅក្នុងឱកាសរំឭកខួបលើកទី៣៨
  នៃទិវាជ័យជម្នះ៧មករា (៧.០១.១៩៧៩-៧.០១.២០១៧) ៨
- ក្រុមគ្រូពេទ្យស្ម័គ្រចិត្តជុំវិញពិភពលោកចុះពិនិត្យសុខភាពនិងព្យាបាលជំងឺ
  ជូនប្រជាជននៅភូមិតាកុះក្នុងឧទ្យានអង្គរដោយមិនគិតថ្លៃ ៩
- តំបន់រមណីយដ្ឋានអង្គរចាប់ផ្តើមបង្កើនសេវាទូរសព្ទនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ4Gសម្រាប់អ៊ីនធើណេត ១១
- ដើមស្តង់ចំណាស់មួយដើមក្នុងតំបន់អង្គរត្រូវបានជួយសង្គ្រោះដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា ១២
- អាជ្ញាធរជាតិអប្សរាបន្តដាំកូនឈើបន្ថែមទៀតនៅតាមជើងទេរទំនប់បារាយណ៍ជ័យតដាក
  ដើម្បីការពារការហូរច្រោះដីចូលក្នុងបារាយណ៍ ១៣
- រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិរដ្ឋOntarioនៃប្រទេសកាណាដា
  មកស្វែងយល់ការងារគ្រប់គ្រងរមណីយដ្ឋានអង្គរពីសំណាក់អាជ្ញាធរជាតិអប្សរា ១៤
- វីដេអូ ៖ រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិរដ្ឋ Ontario នៃប្រទេសកាណាដា
  មកស្វែងយល់ការងារគ្រប់គ្រងរមណីយដ្ឋានអង្គរពីសំណាក់អាជ្ញាធរជាតិអប្សរា ១៦
- ឆ្នាំ២០១៦កន្លងទៅនេះអាជ្ញាធរជាតិអប្សរាដាំកូនឈើបានជាង៦ម៉ឺនដើមក្នុងរមណីយដ្ឋានអង្គរ ១៦
- ក្រុមហ៊ុនសូម៉ាពាណិជ្ជឧបត្ថម្ភពូជបន្លែជូនដល់ប្រជាពលរដ្ឋនៅភូមិធម្មជាតិរុនតាឯក ១៨
- ក្នុងឆ្នាំ២០១៦កន្លងទៅនេះអាជ្ញាធរជាតិអប្សរាបានចែកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយនិងទារក
  ដល់ស្ត្រីទើបឆ្លងទន្លេរួចក្នុងតំបន់អង្គរជិត២ពាន់នាក់ ១៩
- លទ្ធផលនៃកំណាយបុរាណវិទ្យាបង្ហាញថាស្ពានហាលខាងលិចប្រាសាទអង្គរវត្ត
  ធ្លាប់បានជួសជុលនាសម័យបុរាណបន្ទាប់ពីកសាងរួច ២០
- សេចក្តីជូនដំណឹងស្តីពីការរៀបចំការដ្ឋានថ្មី និងផ្អាកការទស្សនារោងទងខាងក្រៅប្រាសាទបាយ័ន ២២

- ស្ពានអណ្តែតទឹកបណ្តោះអាសន្ននៅប្រាសាទអង្គរវត្តនឹងបង្ហាញរូបរាងនាពេលឆាប់ៗនេះហើយ! ២៤
- វីដេអូ៖ ក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរអង្គរ ក្នុងលទ្ធផលការងាររយៈពេល៣ឆ្នាំ ២៥
- អាជ្ញាធរជាតិអប្សរាចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២៥
- អ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរាបង្ហាញថាស្ពានអណ្តែតទឹកមានប្រើតាំងពីសម័យបុរាណមកម្ល៉េះ ២៧
- អាជ្ញាធជាតិអប្សរាពង្រឹងចំណេះដឹងបេតិកភណ្ឌដល់ឆ្មាំកម្មករតាមមូលដ្ឋាន ២៩
- អ្នកជំនាញការជាន់ខ្ពស់អន្តរជាតិផ្នែកបេតិកភណ្ឌរបស់អាយស៊ីស៊ី-អង្គរ
  ចុះពិនិត្យការដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ ៣០
- សេចក្តីជូនដំណឹងស្តីអំពីការបើកកំណាយស្រាវជ្រាវស្ថានីយស្លដែកបុរាណនៅក្នុងតំបន់អង្គរ ៣២
- អគ្គនាយកអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញការជាន់ខ្ពស់បេតិកភណ្ឌនៃ ICC-Angkor
  ចុះពិនិត្យការដ្ឋានកំណាយនៅ ស្ពាលហាលប្រាសាទអង្គរវត្ត ៣៣
- អាជ្ញាធរជាតិអប្សរាផ្តល់សង្កសីជូនស្ត្រីមេម៉ាយចាស់ជរាទីទ័លក្រម្នាក់នៅស្រុកបន្ទាយស្រី ៣៤
- អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសម្មភាពជួសជុលកំណាត់ផ្លូវរ៉ង់តូច ពីខាងកើតកសិន្នុអង្គរទៅដល់ស្រះស្រង់
  ដើម្បីដោះស្រាយការហុយរំខានការធ្វើដំណើរ ៣៥
- ថ្នាក់ដឹកនាំអាយស៊ីស៊ីអង្គរជួបពិភាក្សាដើម្បីកំណត់ទិសដៅសម្រាប់កិច្ចប្រជុំអន្តរជាតិស្តីពីអង្គរ ៣៦
- ឯកឧត្តម សុខ សង្ហារ និងអ្នកជំនាញការអាយស៊ីស៊ី-អង្គរ ចុះពិនិត្យការងារមួយចំនួននៅរមណីយដ្ឋានអង្គរ ៣៧
- អាជ្ញាធរជាតិអប្សរានិងស្ថាប័នអភិរក្សប្រាសាទមកពីប្រទេសចិន
  ជួបពិភាក្សាគ្នាអំពីលទ្ធភាពអនុវត្តគម្រោងអភិរក្សនាពេលអនាគត ៣៩
- កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ បានដំណើរការហើយនៅព្រឹកនេះ ៤០
- ICC-Angkor គោរពវិញ្ញាណក្ខន្ធចំពោះមរណភាពឯកឧត្តម ឃួន ឃុននាយ ៤១
- កំពែងអង្គរធំដែលជួសជុលដោយអ្នកជំនាញអប្សរាទទួលបានការសាទរគាំទ្រពីអ្នកជំនាញអាយស៊ីស៊ី-អង្គរ ៤៣
- សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៧នៃគណៈកម្មការអាយស៊ីស៊ី-អង្គរ ៤៥
- អាជ្ញាធរជាតិអប្សរាចូលរួមរំលែកមរណទុក្ខជាមួយក្រុមគ្រួសារនៃសព ឯកឧត្តម ឃួន ឃុននាយ ៤៧
- ការជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត រួមចំណែកបណ្តុះបណ្តាលធនធានមនុស្ស
  លើវិស័យបេតិកភណ្ឌ ៤៨
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងក្រុមការងារគ្រប់លំដាប់ថ្នាក់ប្រារព្ធពិធីបង្សុកូល
  ឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធឯកឧត្តម ឃួន ឃុននាយ ៤៩
- ស្វែងយល់អត្ថន័យនៃពិធីកាត់សក់បង្កក់ឆ្នុបរបស់អ្នកអង្គរ ៥០
- សេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យដំណើរការគេហទំព័រទេសចរណ៍អង្គរ (www.angkor.com.kh) ៥២
- គេហទំព័រទេសចរណ៍អង្គរថ្មី នឹងដាក់ឲ្យដំណើរការចាប់ពីថ្ងៃទី០១ ខែកុម្ភៈ នេះហើយ ៥៣
- ក្រុមគម្រោងអភិរក្សប្រាសាទព្រះពិធូរបណ្តុះបណ្តាលបុគ្គលិកជំនាញ
  នៃអាជ្ញាធរជាតិអប្សរាពីរបៀបប្រើប្រាស់ឧបករណ៍ស្នង់រចនាសម្ព័ន្ធប្រាសាទក្រោមដី ៥៤
- មគ្គុទ្ទេសក៍ទេសចរណ៍គាំទ្រចំពោះការកំណាយស្រាវជ្រាវនៅស្ថានីយ៍ស្លដែកនៅភូមិសាលាក្រ៉ាន់
  ដោយក្រុមអ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរា ៥៦

ផ្នែកទី ២
ប្រចាំខែកុម្ភៈ

- ក្រុមការងារសហគន៍អាជ្ញាធរជាតិអប្សរាបន្តចុះលើកកម្ពស់សុខុមាលភាពម្តាយ និងទារកដល់ស្ត្រីក្នុងតំបន់អង្គរ ៥៩
- អាជ្ញាធរជាតិអប្សរាបន្តសហការជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា ក្នុងកិច្ចការជួសជុលប្រាសាទតាព្រហ្ម ៦០
- អគ្គនាយកអាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជួសជុលសារមន្ទីរព្រះនរោត្តមសីហនុអង្គរជាមួយក្រុមហ៊ុនអ៊ីអុង ៦១
- ពិធីបុណ្យឡើងអ្នកតារាជ្យបង្ហាញពីការសាមគ្គីនិងស្រឡាញ់វប្បធម៌ជាតិរបស់អ្នកស្រុកអង្គរ! ៦៣
- ដំណើរទស្សនកិច្ចរបស់សមាជិកសភាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នៅការដ្ឋានអភិរក្សចម្លាក់ថ្ម របស់អាជ្ញាធរជាតិអប្សរានាប្រាសាទអង្គរវត្ត ៦៥
- សត្វទោចមុខដង្កែរដែលអាជ្ញាធរជាតិអប្សរាព្រលែងក្នុងព្រៃអង្គរកំពុងបង្កើនការបន្តពូជ ៦៦
- វីដេអូ៖សន្និសីទសារព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៧និងកិច្ចប្រជុំពេញអង្គលើកទី២៣ នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ៦៨
- ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាបន្តអនុញ្ញាតសំណើរជួសជុលនិងសាងសង់តូចតាច នៅក្នុងតំបន់ការពារឧទ្យានអង្គរ ៦៨
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តចុះចែកកញ្ចប់ទារកដល់ពលរដ្ឋឃុំខ្នាត ៦៩
- អ្នកជំនាញបេតិកភណ្ឌវប្បធម៌តំបន់ទន្លេមេគង្គចូលជួបសម្តែងការគួរសម ជាមួយឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ៧១
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តពិនិត្យ និងអនុញ្ញាតសំណើជួសជុលនិងសាងសង់សំណង់ខ្នាតតូច ដល់អ្នកភូមិនគរក្រៅ ៧២
- អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាផ្តល់បទពិសោធន៍គ្រប់គ្រងរមណីយដ្ឋានអង្គរ ដល់ក្រុមនិស្សិតមកពីប្រទេសកូរ៉េ ៧៣
- រកត្រីត្រៀមឡើងមាឃ ទំនៀមអ្នកស្រុកអង្គរដែលនៅបន្តរហូតដល់បច្ចុប្បន្ន ៧៥
- ជំនួបពិភាក្សាការងាររវាងអាជ្ញាធរជាតិអប្សរានិងនគរបាលការពារបេតិកភណ្ឌ ទទួលបានលទ្ធផលគាប់ចិត្តយ៉ាងខ្លាំង ៧៦
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តចុះអប់រំផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកភូមិថ្នល់ទទឹង ៧៧
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ រស់ នៅបរិវេណប្រាសាទបេងមាលា ៧៩
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ រស់ នៅបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ ៨០
- ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាលើកពានរដ្ឋបាលខេត្តសៀមរាបជាលើកទី២ ..... ៨១
- ប្រជាជននៅភូមិគោកកក់ ឃុំស្វាយចេក ស្រុកអង្គរធំ ប្រគល់បដិមាដែលរើសបានជូនអាជ្ញាធរជាតិអប្សរា ៨២

- កិច្ចសម្ភាសន៍ ឯកឧត្តម សុខ សង្វារ អគ្គនាយករងអាជ្ញាធរជាតិអប្សរា ស្តីពីការទាក់ទាញភ្ញៀវទេសចរតាមរយៈគេហទំព័រ www.angkor.com.kh ក្នុងកម្មវិធីពីកម្ពុជា របស់ BTVNews កាលពីថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៧ .. ៨៣
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា៣ក្រុម ចុះពិនិត្យសំណើជួសជុល និងអនុញ្ញាតបានចំនួន១២ករណី ៨៣
- អង្គរនឹងទទួលធ្វើជាទីតាំងសម្រាប់ការចាក់បញ្ចាំងភាពយន្តខ្នាតអន្តរជាតិ រឿងមុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ ៨៥
- ប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតសាងសង់ផ្ទះនៅតំបន់អង្គរ ថាមានភាពងាយស្រួលក្នុងការស្នើសុំ ៨៦
- ស្ថាប័នធានាគុណភាពជប៉ុនJQAបើកសវនកម្ម លើការងារបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ៨៧
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចុះពិនិត្យទីតាំងបញ្ចាំងខ្សែភាពយន្ត "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" ៨៨
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ទទួលស្វាគមន៍ព្រះរាជដំណើរយោងមកដល់ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនីនាថ សីហនុ ៩០
- និស្សិតសាកលវិទ្យាល័យតិចណូចុះកម្មសិក្សាស្វែងយល់ពីប្រព័ន្ធគ្រប់គ្រងទឹកនៅតំបន់អង្គរ ៩១
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមក្នុងព្រះរាជពិធីកាត់ឫសសីមានៅវត្តស្វាយដង្គំខេត្តសៀមរាប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះមហាក្សត្រ ៩៣
- លទ្ធផលសវនកម្ម៖ អាជ្ញាធរជាតិអប្សរានៅតែបន្តភាពវិជ្ជមានលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ! ៩៤
- រយៈពេលពីរសប្តាហ៍ដើមខែកុម្ភៈនេះ អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងអនុញ្ញាតសំណើសុំជួសជុលផ្ទះ និងសាងសង់សំណង់ខ្នាតតូចជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរបាន៥៩ករណី ៩៦
- សេចក្តីជូនដំណឹងស្តីពី ការបើកការដ្ឋានសាងសង់ និងរៀបចំកម្មវិធីអភិរក្សបេតិកភណ្ឌ សម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០១៧ ..... ៩៨
- សហភាពសហព័ន្ធយុវជនកម្ពុជាប្រារព្ធពិធីប្រុងពលីអង្គរសង្ក្រានលើកទី៥នាឆ្នាំ២០១៧ ..... ៩៩
- ភាពយន្តរឿងមុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំបានបញ្ចប់បេសកកម្មនៅលើទឹកដីអង្គរ ១០០
- អាជ្ញាធរជាតិអប្សរានាំយកថវិកាទៅជួយឧបត្ថម្ភលោកមេឃុំស្វាយចេកដែលរងគ្រោះដោយភ្លើងឆេះផ្ទះ ១០១
- អាជ្ញាធរជាតិអប្សរាជួយផ្នែកបច្ចេកទេសក្នុងការជួសជុលវិហារបុរាណវត្តអារញ្ញសាគរ ១០២
- កម្មវិធីបណ្តុះបណ្តាលភាសាចិនដល់មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាចាប់ដំណើរការហើយ ១០៤
- សេចក្តីជូនដំណឹងស្តីពីការធ្វើបទបង្ហាញក្រោមប្រធានបទ ការស្វែងយល់ការរស់នៅរបស់ប្រជាជននៅបុរេប្រវត្តិ តាមរយៈការសិក្សាកុលាលភាជន៍ នៅសាលសិក្សាលលៃ នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ១០៥
- ពិធីលៀងមេមត់ មរតកជំនឿរបស់អ្នកស្រុកអង្គរដែលបង្ហាញពីភាពសប្បាយរីករាយ និងជំនឿលើព្រលឹងដូនតាខ្មែរ! ១០៦
- មរតកជំនឿនៃអ្នកស្រុកអង្គរ ៖ ជម៤ ..... ១០៨
- សេចក្តីជូនដំណឹងស្តីពី ការបើកឱ្យដំណើរការឡើងវិញនូវទំព័រហ្វេសប៊ុកផ្លូវការរបស់អាជ្ញាធរជាតិអប្សរា ១១០
- អាជ្ញាធរជាតិអប្សរាបន្តសហការជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រចិន ដើម្បីជួយដល់ការងារគ្រប់គ្រងតំបន់សៀមរាប អង្គរ ១១១
- អាជ្ញាធរជាតិអប្សរាផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកភូមិថ្នល់បណ្តោយ ១១២

ផ្នែកទី ៣
ប្រចាំខែមីនា

- អាជ្ញាធរជាតិអប្សរាជួបពិភាក្សាជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា អំពីការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៧ ..... ១១៥
- អាជ្ញាធរជាតិអប្សរាបន្តអនុញ្ញាតជូនប្រជាពលរដ្ឋដើម្បីជួសជុលផ្ទះ ១១៦
- អង្គរសង្ក្រាន្តឆ្នាំ២០១៧ នឹងមកដល់ក្នុងពេលឆាប់ៗនេះ! សូមចូលរួមទាំងអស់គ្នា ថាតើអង្គរសង្ក្រាន្តឆ្នាំនេះមានអ្វីប្លែកខ្លះ? ១១៧
- ចម្លាក់បាយ័ន៖ ផ្នាំងមួយនៃសោកនាដកម្មទ័ពខ្មែរបរាជ័យក្រោមស្នាដៃចាម ១១៩
- គម្រោងជួសជុលក្រុមប្រាសាទព្រះពិធូររបស់កូរ៉េ បន្តបណ្តុះបណ្តាលមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា លើការងារវាស់ស្ទង់ស្រទាប់ដី និងកម្រិតទឹក ១២០
- អាជ្ញាធរជាតិអប្សរា ស្ថាប័នJQA និងមន្ទីរអប់រំយុវជននិងកីឡា សហការគ្នាអប់រំកុមារអង្គរអំពីបរិស្ថាន ១២១
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រឹមែកឈើងាប់ រស់នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ ១២៣
- ចម្លាក់បាយ័ន ៖ ចុះពីសំពៅឡើងសំប៉ាន ចុះពីសំប៉ានឡើងផ្សារ ១២៤
- វិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ាគ្រោងនឹងបញ្ចប់ការជួសជុលប្រាង្គខាងជើង នៃប្រាសាទតុបខាងលិចនៅពាក់កណ្តាលឆ្នាំ២០១៧នេះ ១២៥
- ក្នុងខែកុម្ភៈ អាជ្ញាធរជាតិអប្សរាចុះផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកស្រុកអង្គរបានជាង៥០០នាក់ ១២៦
- មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរាចែករំលែកបទពិសោធន៍ការគ្រប់គ្រងទេសចរណ៍អង្គរ ដល់លោកគ្រូអ្នកគ្រូមកពីវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ១២៧
- មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាប្រាប់ពលរដ្ឋកុំឲ្យបារម្ភពីបញ្ហាដង្កូវចោះដើមឈើ ១២៩
- ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ចូលជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំស្ថាប័នមួយចំនួនរបស់ជប៉ុន ដែលបានជួយលើការងារអភិរក្សនៅតំបន់អង្គរ ១៣០
- អាជ្ញាធរជាតិអប្សរាសូមជូនពរ និងអបអរសាទរចំពោះ សម្តេចវិបុលបញ្ញា សុខ អាន ១៣១
- សេចក្តីជូនដំណឹងស្តីពីការធ្វើកំណាយស្រាវជ្រាវនៅប្រាសាទតាព្រហ្ម ១៣៣
- ឯកសារដ៏មានសារៈសំខាន់សម្រាប់អ្នកចង់ដឹងពីតំបន់អង្គរដែលជាបេតិកភណ្ឌពិភពលោក ១៣៤
- ដំណឹងជ្រើសរើសបុគ្គលិកផ្នែកព័ត៌មាន ផ្នែកថតរូបភាព និងផ្នែកផលិតវីដេអូ ១៣៦
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានិងមន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់ប្រារព្ធពិធីគោរព វិញ្ញាណក្ខន្ធ សម្តេចវិបុលបញ្ញា សុខ អាន ១៣៧
- លោកជំទាវ អ៊ីរីណា បូកូវ៉ា អគ្គនាយិការអង្គការយូណេស្កូ សម្តែងគារវកិច្ចចំពោះមរណភាព របស់សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១៣៨
- មន្ត្រីជាន់ខ្ពស់២រូបរបស់គណបក្សសង្គ្រោះជាតិលោក លិម គិមយ៉ា និងលោក ហ៊ីង យឿន ធ្វើលិខិតសុំទោសដល់វិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន ទាំងយប់ថ្ងៃនេះតែម្តង ១៣៩
- រូបភាពពិធីដង្ហែសព សម្តេចវិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ ..... ១៤០

- រូបភាពពិធីបូជាសព សម្តេចវិបុលបញ្ញា សុខ អាន នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ នាមុខវត្តបុទុមវត្តី រាជធានីភ្នំពេញ ១៤១
- បន្ទាប់ពីការបូជាសពត្រូវបានបញ្ចប់, នៅល្ងាចថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧នេះ ធាតុរបស់សម្តេចវិបុលបញ្ញា សុខ អាន ត្រូវបានក្រុមគ្រួសាររៀបចំតាមពិធីសាសនាដាក់ចូលទៅក្នុងទឹកទន្លេមុខព្រះបរមរាជវាំង ១៤៣
- វីដេអូ៖ ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ សម្តេចវិបុលបញ្ញា សុខ អាន ១៤៤
- សូមថ្លែងអំណរគុណជូនដល់ ឯកឧត្តម អគ្គនាយក អគ្គនាយករង ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សា លោក លោកស្រី ឧបការី ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងមន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរាទាំងអស់ ដែលបានចូលរួម គោរពវិញ្ញាណក្ខន្ធ និងពិធីដង្ហែសព សម្តេចវិបុលបញ្ញា សុខ អាន នាថ្ងៃទី១៨ និង ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ ..... ១៤៤
- កិច្ចប្រជុំពេញអង្គលើកទី៣នៃអាយស៊ីស៊ី-ព្រះវិហារ គោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន និងកោតសរសើរពីវីរភាពរបស់សម្តេចក្នុងកិច្ចការងាររបេតិកភណ្ឌជាតិ ១៤៥
- ភ្ញៀវទេសចរជាច្រើនរង់ចាំមើលព្រឹត្តិការណ៍ថ្ងៃរះចំកណ្តាលកំពូលប្រាសាទអង្គរវត្ត ១៤៧
- អ្នកជំនាញជប៉ុន និងអាជ្ញាធរជាតិអប្សរាពិភាក្សាបញ្ហាបច្ចេកទេសសម្រាប់ការអភិរក្ស និងជួសជុលស្ពានហាលប្រាសាទអង្គរវត្ត ១៤៨
- បច្ចេកទេសរំលើងថ្មប្រាសាទនាសម័យអង្គរត្រូវបានតាំងបង្ហាញ និងសម្តែងឡើងវិញនៅសកលវិទ្យាល័យ សូហ្វីយ៉ាប្រទេសជប៉ុន ១៤៩
- អាជ្ញាធរជាតិអប្សរា និងមជ្ឈមណ្ឌល HIST របស់ចិន នឹងចុះអនុស្សរណៈយោគយល់ បន្តលើការងារ កិច្ចសហប្រតិបត្តិការរួមគ្នា ១៥០
- អាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជាមួយអ្នកជំនាញអន្តរជាតិ ដែលកំពុងអនុវត្តការងារនៅក្នុងរមណីយដ្ឋានអង្គរ ១៥២
- ដំណឹងជ្រើសរើសបុគ្គលិកផ្នែកអភិរក្ស និងមគ្គុទេសក៍ ផ្នែកអគ្គិសនី និងផ្នែករដ្ឋបាល ឱ្យបម្រើការងារនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ១៥៣
- ចម្លាក់បាយ័ន ៖ វត្តមានទ័ពចិនក្នុងជួរទ័ពខ្មែរនៃជ័យជម្នះលើកងទ័ពចាម ១៥៤
- ចម្លាក់បាយ័ន ៖ សិល្បៈទស្សនីយភាពមួយនៅសម័យអង្គរ ១៥៥
- ក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តបើកកិច្ចប្រជុំផ្ទៃក្នុងអំពីការរីកចម្រើន នៃសកម្មភាពការងារ និងការត្រៀមខ្លួនបង្ករភាពងាយស្រួលដល់ភ្ញៀវទេសចរមកកម្សាន្តថ្ងៃចូលឆ្នាំ ១៥៦
- ក្នុងត្រីមាសទី០១នេះ អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតសំណើសុំសាងសង់សំណង់តូចតាច និងជួសជុលផ្ទះ ជូនអ្នកស្រុកអង្គរជាង១២០ករណី ១៥៧
- ក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំងចុះពិនិត្យសុខភាពដោយឥតគិតថ្លៃដល់ប្រជាជននៅភូមិធម្មជាតិរុនតាឯក ១៥៨
- សេចក្តីជូនដំណឹងស្តីពី ការកាត់យកចេញមែកឈើទាល០១ដើម នៅខាងលិចប្រាសាទបាយ័ន ១៦១

ផ្នែកទី ៨
ប្រចាំខែមេសា

- ក្រុមអភិរក្សធ្វើកំណាយសង្គ្រោះនៅប្រាសាទតាព្រហ្មបន្តជួសជុលសាលរបាំ ១៦៣

- សេចក្តីជូនដំណឹងស្តីពីការដ្ឋាកយានដំនិះចូលបរិវេណទីតាំង Drop-off មុខប្រាសាទអង្គរវត្តជាបណ្តោះអាសន្ន ...១៦៤
- មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា១៤នាក់ចូលរួមកិច្ចប្រជុំផ្លាស់ប្តូរយោបល់បច្ចេកទេស
  និងបង្ហាញលទ្ធផលសិក្សាស្រាវជ្រាវសម្រាប់គម្រោងអភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិធូរ
  ក្នុងឧទ្យានអង្គរ នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ ១៦៦
- ក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តបើកកិច្ចប្រជុំផ្ទៃក្នុងអំពីវឌ្ឍនភាព
  នៃការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ១៦៧
- ថ្នាក់ដឹកនាំមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាប្រារព្ធពិធីសូត្រមន្ត អបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ១៦៨
- ក្រុមហ៊ុនវិនិយោគទេសចរណ៍ធម្មជាតិអន្តរជាតិ CaHeng របស់ចិន
  ចាប់អារម្មណ៍ខ្លាំងនឹងការបណ្តុះបណ្តាលសិល្បៈរបស់កុមារនៅភូមិធម្មជាតិរុនតាឯក ១៦៩
- គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកទទួលភ្ញៀវទេសចរធ្វើសមាធិជាលើកដំបូង ១៧០
- គណៈប្រតិភូអាជ្ញាធរជាតិអប្សរាចូលជួបសម្តែងការគួរសមថ្នាក់ដឹកនាំ KOICA និងទស្សនកិច្ច
  នៅតាមវិទ្យាស្ថានស្រាវជ្រាវជាតិកូរ៉េមួយចំនួនទាក់ទងនឹងការអភិរក្សជួសជុលមរតកវប្បធម៌មនុស្សជាតិ ១៧១
- អាជ្ញាធរអប្សរារៀបចំចំណតរ៉ឺម៉កនៅខាងលិចប្រាសាទតាព្រហ្ម ១៧៣
- ព្រះតេជគុណ ពិន សែម ៖ ភូមិមានីមានន្ទ មិនមែនភូមិគិរីមានន្ទទេ ១៧៤
- អាជ្ញាធរជាតិអប្សរា រួមជាមួយក្រសួងទេសចរណ៍ចុះសួរសុខទុក្ខ
  និងនាំយកអំណោយចែកជូនកងទ័ពនៃយោធភូមិភាគទី៤ ..... ១៧៦
- ចាប៉ីដងវែងខ្នាតយក្សនឹងត្រូវដង្ហែចូលបរិវេណព្រឹត្តិការណ៍អង្គរសង្ក្រាន្តនារសៀល១២មេសានេះ ១៧៧
- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈចុះជួបថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាជាលើកដំបូង
  ក្នុងឋានៈជាប្រធានអាជ្ញាធរជាតិអប្សរា ១៧៨
- ពិធីបួងសួងអង្គរសង្ក្រាន្តត្រូវបានរៀបចំនៅលើក្តារបែនប្រាសាទអង្គរវត្ត ១៧៩
- អាជ្ញាធរជាតិអប្សរាចែកចាយទឹកដោយឥតគិតថ្លៃក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ១៨០
- គណៈប្រតិភូអាជ្ញាធរជាតិអប្សរាបញ្ចប់ទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រង ជួសជុល
  និងអភិរក្សបេតិកកណ្ឌវប្បធម៌នៅសាធារណរដ្ឋកូរ៉េ ១៨១
- តើអ្នកទាំងអស់គ្នាដឹងទេថាចម្លាក់នៅប្រាសាទអង្គរវត្តមានទាក់ទងនឹងរឿងអ្វីខ្លះ? ១៨៣
- អង្គរសង្ក្រាន្តឆ្នាំ២០១៧បានបញ្ចប់ទៅជាមួយនឹងកំណើនអ្នកចូលរួមយ៉ាងច្រើនកុះករ ១៨៤
- អ្នកជំនាញរៀបចំកាត់ក្រី និងព្យាបាលដើមឈើទាលដែលមានអាយុកាលជាង១០០ឆ្នាំជាប់ប្រាសាទបាយ័ន ១៨៥
- ទីតាំងអភិរក្សបេតិកកណ្ឌដែលរៀបចំដោយអាជ្ញាធរជាតិអប្សរានៅមុខអង្គរវត្ត ទាក់ទាញភ្ញៀវទេសចរជាតិ-
  អន្តរជាតិជិត៥ម៉ឺននាក់ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត២០១៧ ..... ១៨៦
- ត្រីមាសទី១ដើមឆ្នាំ២០១៧ អាជ្ញាធរជាតិអប្សរាបានរកឃើញ
  និងប្រគល់សម្ភារៈជូនភ្ញៀវទេសចរវិញចំនួន៦៦ករណី ១៨៨
- អាជ្ញាធរជាតិអប្សរានឹងរៀបចំបទបង្ហាញស្តីពី ការស្វែងយល់ការរស់នៅរបស់ប្រជាជន
  សម័យបុរេប្រវត្តិតាមរយៈការសិក្សាកុលាលភាជន៍ ១៨៩
- ចម្លាក់បាយ័ន ៖ ពិធីយញ្ញក្របីនៅលើចម្លាក់នៃប្រាសាទបាយ័ន ១៩១
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ១៩២

- ប្រធានអាជ្ញាធរជាតិអប្សរាជួបប្រជុំជាមួយមន្ត្រីរាជការថ្នាក់ដឹកនាំនៃអាជ្ញាធរអប្សរា
  ដើម្បីយល់ច្បាស់អំពីដំណើរការស្តាប័ននិងការគ្រប់គ្រងរមណីយដ្ឋានអង្គរ ១៩៣
- លោកតា សុត ជុយ អ្នកស្រុកអង្គរស្រឡាញ់ការងារជួសជុលប្រាសាទ និងចង់ឲ្យកូនចៅបន្តការងារនេះ ១៩៤
- អ្នកស្រាវជ្រាវយល់ថា បំណែកកុលាលភាជន៍ ផ្តល់នូវទិន្នន័យច្រើនអំពីសង្គមមនុស្សបុរាណ ១៩៥
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានចុះអនុញ្ញាតជួសជុលផ្ទះ
  និងសាងសង់សំណង់ស្រាលចំនួន១២១ ករណីក្នុងត្រីមាសទី១ ឆ្នាំ២០១៧ ..... ១៩៦
- ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តនឹងដាក់ឲ្យដំណើរការនៅដើមខែឧសភាខាងមុខនេះ ១៩៨

ផ្នែកទី ៩
ប្រចាំខែឧសភា

- អវត្តមានរបស់យុវវ័យក្នុងពិធីទំនៀមទម្លាប់ដូនតា ប្រឈមនឹងការបាត់បង់ទំនៀមទម្លាប់ទាំងនេះទៅថ្ងៃអនាគត!. ២០១
- មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាបាននិងកំពុងរៀបចំគម្រោងអភិរក្សប្រាសាទចៅស្រីវិបុល ២០២
- អាជ្ញាធរជាតិអប្សរាបង្កើតក្រុមការងារប្រតិកម្មរហ័សសម្រាប់ដោះស្រាយបញ្ហាបន្ទាន់ៗ
  ជាមួយប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ ២០៤
- ការចូលរួមអភិវឌ្ឍសហគមន៍ប្រជាពលរដ្ឋក្នុងតំបន់បេតិកភណ្ឌនៅតែជាការងារសំខាន់
  របស់អាជ្ញាធរជាតិអប្សរា ២០៦
- ទ្វារទឹកជុំវិញកសិន្ទុប្រាសាទចៅស្រីវិបុលផ្តល់អត្ថប្រយោជន៍ទាំងការងារអភិរក្ស និងសហគមន៍ ២០៧
- សាលរបាំប្រាសាទតាព្រហ្មកំពុងជួសជុលក្នុងដំណាក់កាលទី២ ..... ២០៩
- ប្រជាពលរដ្ឋ១៣គ្រួសារនៅឃុំលាងដែទទួលបានការឧបត្ថម្ភពីការខូចខាតដំណាំស្រូវកាលពីឆ្នាំ២០១៦
  ពីអាជ្ញាធរជាតិអប្សរា ២១០
- និស្សិតបុរាណវិទ្យាជំនាន់ទី២៥ បញ្ចប់ទស្សនកិច្ចសិក្សារយៈពេល១០ថ្ងៃ
  ដើម្បីស្វែងយល់ពីអរិយធម៌ខ្មែរនៅក្នុង និងក្រៅតំបន់អង្គរ ២១១
- អាជ្ញាធរជាតិអប្សរាឧបត្ថម្ភថវិកា១២លានរៀលដល់កាកបាទក្រហមនិងអឌ្ឍចន្ទក្រហមប្រចាំខេត្តសៀមរាប
  នាឱកាសអបអរសាទរខួបលើកទី១៥៤ ..... ២១៣
- អាជ្ញាធរជាតិអប្សរានិងនគរបាលការពារបេតិកភណ្ឌជួបពិភាក្សាគ្នាដើម្បីពង្រឹងកិច្ចការពារបេតិកភណ្ឌអង្គរ ២១៤
- ប្រតិភូគណៈកម្មាធិការអោយស៊ីស៊ីអង្គរចូលគាល់ព្រះមហាក្សត្រ
  ដើម្បីទូលថ្វាយអំពីដំណើរវិវត្តនៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ ២១៥
- កំពែងប្រាសាទបន្ទាយក្តីជ្រុងពាយ័ព្យត្រូវបានអ្នកជំនាញអាជ្ញាធរជាតិអប្សរាកំពុងជួសជុល ២១៧
- ប្រតិភូនៃកិច្ចប្រជុំសេដ្ឋកិច្ចពិភពលោកមកទស្សនារមណីយដ្ឋានអង្គរ ២១៨
- អាជ្ញាធរជាតិអប្សរារួមចំណែកក្នុងការកសាងមណ្ឌលរដ្ឋបាលមន្ទីរខេត្តសៀមរាប ២១៩
- អាជ្ញាធរជាតិអប្សរាសហការជាមួយស្ថានទូតអាមេរិកប្រចាំកម្ពុជាបណ្តុះបណ្តាលមន្ត្រី
  លើជំនាញគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌ ២២០
- សារមន្ទីរវាយនកណ្ឌបើកឲ្យទស្សនាដោយឥតគិតថ្លៃក្នុងថ្ងៃទិវាសារមន្ទីរអន្តរជាតិ ២២១
- ចម្លាក់ផ្កាឈូកដ៏ធំនៅលើរានហាលព្រះលានដល់ដំរីនឹងលេចចេញរូបរាងឡើងវិញនៅខែសីហាខាងមុខនេះ ២២២

- អ្នកស្រាវជ្រាវយល់ថា ចម្លាក់នៅតាមថែវនៃប្រាសាទអង្គរវត្តមានទំនាក់ទំនងទៅនឹងយុគ
  ទាំង៤របស់ចក្រវាឡនៃសាសនាហិណ្ឌូ ២២៤
- ស្ពានអណ្តែតទឹកនៅមុខប្រាសាទអង្គរវត្តគ្រោងដាក់សម្ពោធជាផ្លូវការនៅថ្ងៃទី២៥ ឧសភា ២២៦
- សមិទ្ធផលសំខាន់ៗនៃការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា រយៈពេល៣សប្តាហ៍ដំបូងក្នុងខែឧសភានេះ .. ២២៧
- អាជ្ញាធរជាតិអប្សរាបោះបង្គោលរបងជុំវិញប្រាសាទបាយ័ន្តដើម្បីលើកកម្ពស់សោភ័ណភាព
  និងសណ្តាប់ធ្នាប់ចរាចរណ៍ ២២៨
- ប្រធានអាជ្ញាធរជាតិអប្សរាចុះទស្សនកិច្ចភូមិធម្មជាតិរុនតាឯក ២២៩
- ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តបើកជូនភ្ញៀវទេសចរធ្វើដំណើរជាផ្លូវការហើយ ២៣០
- អបអរសាទរ! ប្រាសាទអង្គរវត្តរបស់ខ្មែរជាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុត
  លើពិភពលោកក្នុងឆ្នាំ២០១៧ ..... ២៣២
- ទស្សនវិស័យវែងឆ្ងាយអំពីការគ្រប់គ្រងបេតិកភណ្ឌរបស់រាជរដ្ឋាភិបាលកម្ពុជា
  នាំឲ្យអង្គរកាន់តែល្បីល្បាញលើពិភពលោក ២៣៣
- មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរទទួលបានសៀវភៅថ្មី៧ក្បាលបន្ថែមពីដៃគូស្រាវជ្រាវ ២៣៥
- អង្គរវត្តនារដូវវស្សាស្រស់ស្អាតប្លែកម្យ៉ាងពីរដូវប្រាំង ២៣៦

ផ្នែកទី ៦
ប្រចាំខែមិថុនា

- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាជួបជុំមន្ត្រីបុគ្គលិករបស់ខ្លួនដើម្បីជំរុញ
  ការចូលរួមបោះឆ្នោតឃុំសង្កាត់ខាងមុខនេះ ២៣៧
- សម្រស់នាគព័ន្ធនារដូវដើមវស្សា ២៣៨
- ក្រុមនិស្សិតចិនហុងកុងស្វែងយល់ពីការផលិតកុលាលភាជន៍ក្នុងតំបន់អង្គរ ២៣៩
- អាជ្ញាធរជាតិអប្សរាសម្តែងការព្រួយបារម្ភចំពោះការរីករាលដាលសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ ... ២៤១
- សមិទ្ធផលសំខាន់ៗនៃការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា ក្នុងខែឧសភាកន្លងទៅនេះ ២៤២
- អាជ្ញាធរជាតិអប្សរាសហការរៀបចំពិធីដាំកូនឈើអនុស្សាវរីយ៍អបអរសាទរសន្និសីទទេសចរណ៍អន្តរជាតិ ២៤៣
- ចាប៉ីដងវែងខ្នាតយក្សត្រូវបានដង្ហែទៅរក្សាទុកនៅសាលាខេត្តបាត់ដំបង ២៤៤
- អាជ្ញាធរជាតិអប្សរាប្រជុំពិភាក្សាជាមួយនគរបាលការពារបេតិកភណ្ឌ
  លើបញ្ហាសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ ២៤៦
- ទេសភាពបៃតងបានរួមចំណែកធ្វើឲ្យអង្គរកាន់តែល្បីល្បាញលើសកលលោក ២៤៧
- សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់
  មែករស់នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ ២៤៩
- កម្ពុជាជាប្រទេសគំរូមួយដែលស្ថាប័នទេសចរណ៍និងវប្បធម៌ធ្វើការរួមគ្នាដើម្បីនិរន្តរភាពនៃតំបន់បេតិកភណ្ឌ ២៥០
- ប្រជាជនភូមិធម្មជាតិរុនតាឯកទទួលបានគ្រាក់ទំរ១គ្រឿងពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូកូរ៉ែ
  នៃមហាវិទ្យាល័យ Dong Pusan និងក្រុមហ៊ុន Dream Airline Tour ២៥១
- ប្រជាពលរដ្ឋសាងសង់សំណង់ខុសច្បាប់នៅជិតប្រាសាទបន្ទាយក្តីស្ម័គ្រចិត្តរុះរើសំណង់ដោយខ្លួនឯង ២៥៣

- អាយស៊ីស៊ី-អង្គរនឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី២៨របស់ខ្លួន នៅថ្ងៃទី២១-២២ ខែមិថុនា ២៥៤
- ប្រធានអាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជាមួយអ្នកជំនាញការជាន់ខ្ពស់
  មុនកិច្ចប្រជុំបច្ចេកទេសនៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ២៥៦
- ស្វែងយល់ពីគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ ២៥៧
- ប្រតិភូគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ចូលគោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន
  ក្នុងឱកាសបុណ្យខួបគម្រប់១០០ថ្ងៃ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ២៥៩
- អាជ្ញាធរជាតិអប្សរាចុះអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នអន្តរជាតិចំនួនពីរលើការងារអភិរក្ស ២៦០
- តំណាងអង្គការយូណេស្កូប្រចាំកម្ពុជាសម្តែងការគាំទ្រចំណាត់ការទប់ស្កាត់ការរីករាលដាល
  សំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ ២៦២
- អ្នកជំនាញនៃអង្គការយូណេស្កូ បង្ហាញភាពមហន្តរាយនៃបេតិកភណ្ឌជុំវិញពិភពលោក
  ដើម្បីរំឭកដល់ការអភិរក្សរមណីយដ្ឋានអង្គរ ២៦៣
- បើយើងជាម្ចាស់ស្រុកពិតប្រាកដ គ្មានអ្វីដែលព្រួយបារម្ភក្នុងការសាងសង់ផ្ទះនោះទេ! ២៦៥
- សំណង់ខុសច្បាប់ក្នុងតំបន់អង្គរនឹងត្រូវបន្តរុះរើក្នុងពេលឆាប់ៗនេះ ២៦៦
- ក្រុមអភិរក្សថ្មវ័យក្មេងបន្តការងារជួសជុលបង្គោលសីមានៅប្រាសាទបន្ទាយស្រី ២៦៧

ផ្នែកទី ១
ប្រចាំខែមករា

នៅតំបន់អង្គរមានសិលាចារឹកជាភាសាភូមាចំនួន១១កន្លែងផ្សេងគ្នា

ផ្សាយនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ លឹម ស្រ៊ូ

លទ្ធផលនៃការស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា បានប្រទះឃើញសិលាចារឹកជាភាសាភូមាចំនួន១១ កន្លែងផ្សេងគ្នា។ **លោក អ៊ឹម សុខរិទ្ធី** អ្នកស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា បញ្ជាក់ថាទីតាំងដែលរកឃើញ នោះមាន៩កន្លែង នៅប្រាសាទអង្គរវត្ត និង២កន្លែងទៀតក្នុងក្រុងអង្គរធំក្បែរប្រាសាទបាយ័ន។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិ អប្សរាបានបញ្ជាក់ពីវត្តមាននៃសិលាចារឹកភាសាភូមានៅក្នុងប្រាសាទរបស់ខ្មែរ។ ទីតាំងទាំងនោះមាន នៅតាមជើងសសរ នៅក្បែរក្តារបែន នៅថែវព្រះពាន់ នៅជាន់បាកាណ និងនៅតាមថែវខ្លះៗនៃប្រាសាទអង្គរវត្ត។ ចំណែកឯនៅក្នុងអង្គរធំ ក្បែរប្រាសាទបាយ័ន សិលាចារឹកភាសាភូមាមាននៅលើសន្លឹកសីមាភ្លោះ របស់ឧបោសថាគារ ព្រះអង្គងោក ដែលស្ថិតនៅខាងជើងនៃប្រាសាទមួយនេះ។

លោក អ៊ឹម សុខរិទ្ធី បានបញ្ជាក់ទៀតថា នៅអំឡុងឆ្នាំ២០១៤ និង២០១៥ អាជ្ញាធរជាតិអប្សរា តាមរយៈលោក ផ្ទាល់ គឺបានប្រាស្រ័យទាក់ទងនឹងអ្នកស្រាវជ្រាវភូមា ហើយបានជួបអនុរដ្ឋមន្ត្រីភូមា គឺ **លោក អ៊ូ ថាន់ស្វេ** (U Than Swe) តាមរយៈសាស្ត្រាចារ្យប្រទេសអង់គ្លេស **លោកស្រី** Elizabeth Moore អ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ នៃសាកលវិទ្យាល័យ SOAS នៃទីក្រុងឡុង បានស្វែងរកការសិក្សារួមគ្នាមួយ ក្នុងបំណងដើម្បីបកប្រែភាសាភូមាទាំងនោះ។ នៅឆ្នាំដដែល ការបកប្រែពីផ្នាំងសិលាចារឹកភាសាភូមា ត្រូវបានបោះពុម្ពផ្សាយជាភាសា អង់គ្លេស។

ទិន្នន័យទូទៅដែលបានពីការសិក្សាគេបានរកឃើញថា អក្សរចារឹកដែលចារចាស់ជាងគេ គឺនៅជើមសតវត្សរ៍ទី២០។ អ្នកដែលបានមកចារខ្លះមកជាលក្ខណៈគ្រួសារ និងមកតែឯង ហើយអត្ថន័យជាទូទៅ គឺបញ្ជាក់ពីឈ្មោះអ្នកសរសេរ ពេលវេលា និងតំបន់ដែលពួកគេរស់នៅ។ ចំណែកនៅប្រាសាទបាយ័ន អ្នកដែលចារគឺព្រះសង្ឃភូមា ដែលលោកបានមកគោរពព្រះនៅក្នុងប្រាសាទ ជាពិសេសព្រះអង្គងោកតែម្តង។ រូបបដិមាព្រះអង្គងោក តាមការសិក្សារបស់អ្នកស្រាវជ្រាវទំនងមិនមែនសង់ឡើងដោយជនជាតិខ្មែរនោះទេ គឺអាចជនជាតិភូមា។ នេះបើតាមការអះអាងរបស់ **លោក អ៊ឹម សុខរិទ្ធី** ដែលលោកថា តាមការពិនិត្យពីទម្រង់ រូបរាងរបស់ព្រះអង្គងោក គឺដូចទៅនឹងបដិមារបស់ភូមា។
ហេតុអ្វីបានជាមានវត្តមានជនជាតិភូមានៅកម្ពុជា? **លោក អ៊ឹម សុខរិទ្ធី** ពន្យល់ថា ពួកគេទាំងនោះមកពីតំបន់ផ្សេងៗគ្នា ខ្លះឆ្លងកាត់តាមប្រទេសម៉ាឡេស៊ី ខ្លះមកពីតំបន់ខាងជើងនៃប្រទេសភូមាសព្វថ្ងៃ ដើម្បីមកគោរពបូជាអង្គរដែលជាទីឋានព្រះពុទ្ធដ៏ល្បីល្បាញ និងសំពះព្រះនិងថ្វាយតង្វាយដល់ព្រះ។

ដោយឡែកតាមរយៈសិលាចារឹកខាងដើម បានបញ្ជាក់ថាជនជាតិភូមាទាំងនោះ ក៏មិនមែនមកត្រង់ពីភូមានោះដែរ គឺមកពីបាត់ដំបង ដែលពួកគេរស់នៅតំបន់ប៉ៃលិន។ ជនជាតិភូមាជំនាញខាងរុករកត្បូងថ្ម ហើយពួកគេចូលមកដើម្បីរុករកត្បូងថ្មមានតម្លៃ។ ប៉ៃលិន ជាភាសាភូមា ដែលប្រែថា ត្បូងកណ្តៀង ដែលក្រោយមកក្លាយជាស្រុកមួយរបស់ខេត្តបាត់ដំបង៕





ព្រះកាន់
Preah Poan

Imprint sheet no./លេខត្តិ: 120
Photograph no./រូបថតលេខ: 211

អាជ្ញាធរជាតិអប្សរានឹងបើកវគ្គបណ្តុះបណ្តាលភាសាចិនដល់មន្ត្រី-បុគ្គលិក

ផ្សាយនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧នេះ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឲ្យក្រុមប្រតិភូខេត្តជាំងស៊ី (Jiangxi) នៃសាធារណរដ្ឋប្រជាមានិតចិន ដែលដឹកនាំដោយ **លោក Yang Huiwen** អនុប្រធានមន្ទីរអប់រំ ខេត្តជាំងស៊ីចូលជួបពិភាក្សាការងារនៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។ ជំនួបពិភាក្សានេះផ្តោតសំខាន់លើការបើកវគ្គបណ្តុះបណ្តាលភាសាចិនដល់មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា។

ជាកិច្ចស្វាគមន៍ឯកឧត្តមអគ្គនាយកបានថ្លែងអំណរគុណចំពោះឯកឧត្តមអគ្គរដ្ឋទូតចិន ដែលបានជួយជ្រោមជ្រែងក្នុងការបើកវគ្គបណ្តុះបណ្តាលភាសាចិន ដល់មន្ត្រីបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា ជាពិសេសមន្ត្រីបុគ្គលិកដែលធ្វើការផ្ទាល់ជាមួយស្តាប់នមកពីប្រទេសចិន ដែលកំពុងអនុវត្តការងារអភិរក្សជួសជុលក្នុងតំបន់អង្គរ។ ឯកឧត្តមបញ្ជាក់ថា មកទល់នឹងបច្ចុប្បន្នទំនាក់ទំនងចិន និងកម្ពុជាមានភាពរឹងមាំកាន់តែខ្លាំង ហើយអាជ្ញាធរជាតិអប្សរាក៏មានកិច្ចសហការច្រើនជាមួយប្រទេសចិនទាំងលើវិស័យអភិរក្សជួសជុល វិទ្យាសាស្ត្រ និងកសិកម្ម។ ក្នុងន័យនេះអាជ្ញាធរជាតិអប្សរាបានជំរុញ មន្ត្រីបុគ្គលិក ឲ្យរៀនភាសាចិនដើម្បីជំរុញកិច្ចសហប្រតិបត្តិការឲ្យកាន់តែរលូនក្នុងទំនាក់ទំនងការងាររបស់ខ្លួន។ ជាមួយគ្នានេះដែរ ឯកឧត្តមអគ្គនាយកក៏បានបើកទូលាយចំពោះយុវជនចិន ដែលមានបំណងទទួលយកបទពិសោធន៍ការងារគ្រប់គ្រងបេតិកភណ្ឌអាចមកស្នាក់នៅ និងទទួលការបណ្តុះបណ្តាលពីមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា។

អនុប្រធានមន្ទីរអប់រំខេត្តជាំងស៊ី **លោក Yang Huiwen** បានបញ្ជាក់ថា លោកពិតជារីករាយដែលអាជ្ញាធរជាតិអប្សរាបានជំរុញឲ្យមន្ត្រីរបស់ខ្លួនសិក្សាភាសាចិន ដើម្បីសម្រួលដល់កិច្ចសហប្រតិបត្តិការណ្ណ។ លោកនឹងជំរុញឲ្យដំណើរការសិក្សានេះបានរលូនតាមរយៈវិទ្យាស្ថានខុងជឺ ហើយតាមរយៈវិទ្យាស្ថាននេះ សិក្ខាកាមក៏អាចនឹងមានឱកាសទៅសិក្សាបន្ត នៅខេត្តជាំងស៊ីផងដែរ ដើម្បីពង្រឹងភាសាចិនឲ្យកាន់តែល្អប្រសើរថែមទៀត។ លើសពីនេះ **លោក Yang Huiwen** ក៏បានសន្យាជំរុញ និងផ្សព្វផ្សាយ ដល់ភ្ញៀវទេសចរនៃខេត្តជាំងស៊ីមកកាន់រមណីយដ្ឋានអង្គរកាន់តែច្រើន ហើយលោកនឹងជំរុញយុវជនចិនឲ្យមកបោះជំរុំនៅអាជ្ញាធរជាតិអប្សរាដើម្បីសិក្សាអំពីការគ្រប់គ្រងបេតិកភណ្ឌអង្គរ ក្នុងកម្មវិធីបោះជំរុំយុវជនអាស៊ាន-ចិន។

សូមបញ្ជាក់ថា តាមរយៈសម្របសម្រួលពីស្ថានទូតចិនប្រចាំកម្ពុជា មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរានឹងទទួលបានការបណ្តុះបណ្តាលភាសាចិន ដោយវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា។ តាមគម្រោងវគ្គបណ្តុះបណ្តាលនេះអាចនឹងដំណើរការចាប់ពីពាក់កណ្តាលខែកុម្ភៈឆ្នាំ២០១៧តទៅ៕









វីដេអូ ៖ អាជ្ញាធរជាតិអប្សរានឹងបើកវគ្គបណ្តុះបណ្តាលភាសាចិនដល់មន្ត្រី-បុគ្គលិក

ផ្សាយនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៧ *អត្ថបទ ៖ ហេង ប៊ុនឡាយ*



សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រីមែកឈើងាប់ រស់ នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៧ *អត្ថបទ ៖ ន.គ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន*



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
N°.០០១/រប.សជណ
/១៧

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រីមែកឈើងាប់ រស់ នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទេសក៏ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាសុវត្ថិភាពដល់ភ្ញៀវទេសចរ និងការប៉ះពាល់ដល់ប្រាសាទជាយថាហេតុ និងដើម្បីលើកកម្ពស់សោភ័ណភាពរមណីយដ្ឋានអង្គរ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា នឹងធ្វើការកាត់ក្រី និងកាត់ដកហូតដើមឈើងាប់មួយចំនួន នៅក្នុងតំបន់រមណីយដ្ឋានអង្គរដូចខាងក្រោម៖

- កាត់ក្រីមែកឈើងាប់ពុក និងមែករស់តូចធំ សរុប១៧០មែក កាត់សម្អាតដើមឈើដួលលើគោក និងក្នុងទឹក ចំនួន៧ដើម
- កាត់ដកហូតសម្អាតដើមត្នោតងាប់១ដើម នៅមុខតូបអ្នកលក់ដូរខាងកើតឆៀងខាងត្បូងត្រពាំងសេះ ខាងលិចប្រាសាទអង្គរវត្ត។
- កាត់ក្រីមែកឈើចំនួន៨ដើម និងកាត់ដកហូតដើម ចំនួន២ដើម នៅក្នុងបរិវេណអភិរក្សដ្ឋានអង្គរសៀមរាប
- កាត់ដកហូតដើមឈើងាប់ ចំនួន២ដើម នៅផ្លូវវាងកូរ៉ ជិតផ្លូវចូលទំនប់បារាយណ៍ខាងលិច
- កាត់សម្រាលតួដើម និងកាត់ក្រីមែកឈើនៅក្នុងបរិវេណប្រាសាទតាព្រហ្ម តាមផ្លូវវង់ទស្សនា តាមកំពែងប្រាសាទ និងតាមផ្លូវខាងក្រៅបរិវេណប្រាសាទ។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទេសក៏ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាពត៌មាន។

ចម្លងជូន៖
- សាលាខេត្តសៀមរាប
- មន្ទីរបរិស្ថានខេត្តសៀមរាប
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- ស្នាក់ការតំបន់ការពារទេសភាពអង្គរ
- សមាគមមគ្គុទេសក៏ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប "ដើម្បីជូនជ្រាប និងសហការអនុវត្ត"
- គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរជាតិអប្សរា "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

សៀមរាប ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧
អគ្គនាយក



ស៊ុំ ម៉ាប់

PHNOM PENH :
#41, Russian Blvd,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 776
Fax : (855-23) 215 771

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននៃតរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
E-mail : info@apsaraauthority.gov.kh

SIEM REAP :
Bang Korng Village, Ampil Commune, Siem Reap City, Siem Reap Province
Tel: (855-63) 76 55 77 or (855-63) 76 66 76
Fax: (855-63) 76 55 76

អាជ្ញាធរជាតិអប្សរាបន្តជំរុញប្រជាពលរដ្ឋក្នុងឧទ្យានអង្គរឲ្យប្រើប្រាស់បង្គន់អនាម័យ

ផ្សាយនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សែន សែត រូបភាព ៖ សែន សែត

ការមានបង្គន់ប្រើប្រាស់ត្រឹមត្រូវ គឺជាផ្នែកមួយដ៏សំខាន់ដែលជួយឲ្យបរិស្ថានស្អាត និងទប់ស្កាត់ការចម្លងមេរោគផ្សេងៗ។ នេះជាសារដ៏សំខាន់ដែលអាជ្ញាធរជាតិអប្សរាកំពុងតែផ្សព្វផ្សាយ និងជម្រុញដល់ប្រជាពលរដ្ឋក្នុងតំបន់អង្គរដើម្បីលើកកម្ពស់សុខុមាលភាពរបស់ខ្លួន។

អាជ្ញាធរជាតិអប្សរាតាមរយៈគម្រោងសុវុឌ្ឍិកម្មនៃការសម្អាតទឹក និងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរ (PAAGERA) បានចុះអប់រំនិងក្រើនរំឭកប្រជាពលរដ្ឋក្នុងឧទ្យានអង្គរឲ្យប្រើប្រាស់បង្គន់អនាម័យ ឲ្យបានត្រឹមត្រូវ។ ជាក់ស្តែងនៅព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧នេះ ក្រុមការងារបានចុះទៅផ្សព្វផ្សាយនៅភូមិលាងដៃ ដែលជាភូមិមួយស្ថិតនៅក្នុងរមណីយដ្ឋានអង្គរ ភាគខាងលិចនៃតំបន់អង្គរធំ។

មានប្រសាសន៍ក្នុងកម្មវិធីផ្សព្វផ្សាយនេះ **អ្នកស្រី ឡុង ឆម** មេភូមិលាងដៃបញ្ជាក់ថា ក្នុងចំណោមប្រជាពលរដ្ឋភូមិលាងដៃជាង៣០០គ្រួសារ យ៉ាងហោចណាស់ក៏មានជាង១០០គ្រួសារដែរ ដែលមិនទាន់មានបង្គន់អនាម័យប្រើប្រាស់ត្រឹមត្រូវ។ អ្នកស្រីបន្តថា ការមិនមានបង្គន់ប្រើប្រាស់នេះ ដោយសារគ្រួសារទាំងនោះមិនសូវមានការយល់ដឹងអំពីផលប៉ះពាល់នៃការបន្ទោបង់ពាសវាលពាសកាល ហើយអ្នកខ្លះទៀត ចង់មានបង្គន់ប្រើប្រាស់ដែរ តែមិនមានលទ្ធភាពគ្រប់គ្រាន់។ ទោះជាយ៉ាងណា អ្នកស្រីមេភូមិសង្ឃឹមថា តាមរយៈកម្មវិធីផ្សព្វផ្សាយនេះ អ្នកភូមិភាគច្រើននឹងបានយល់ដឹងអំពីផលប៉ះពាល់ ហើយនឹងសន្សំលុយកាក់ដើម្បីសាងសង់បង្គន់អនាម័យប្រើប្រាស់។

សូមបញ្ជាក់ថា គម្រោងសុវុឌ្ឍិកម្មនៃការសម្អាតទឹក និងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរ គឺជាគម្រោងសហការ រវាងអាជ្ញាធរជាតិអប្សរា ប្រទេសបារាំង និងសាលាខេត្តសៀមរាប។ បច្ចុប្បន្ន ក្រុមអនុវត្តគម្រោងនៃអាជ្ញាធរជាតិអប្សរា កំពុងតែបន្តផ្សព្វផ្សាយនៅក្នុងភូមិចំនួន៤នៃឧទ្យានអង្គរ គឺភូមិលាងដៃនៅឃុំលាងដៃស្រុកអង្គរធំ ភូមិរហាល និងស្រះស្រង់ខាងជើងនៅសង្កាត់នគរធំ ក្រុងសៀមរាប និងភូមិស្រែចង្ហូតនៅឃុំរុនតាឯកស្រុកបន្ទាយស្រី។ មកទល់នឹងពេលនេះ ក្រុមការងារបានផ្សព្វផ្សាយក្នុងមួយភូមិ បានចំនួន៣លើករួចមកហើយ ដោយផ្តោតលើប្រធានបទ ការគ្រប់គ្រងសំរាម ការទប់ស្កាត់ការចម្លងមេរោគ និងការប្រើប្រាស់បង្គន់អនាម័យ៕









សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរជួសជុលបាន៦០%ហើយ

ផ្សាយនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ ហ៊ុំ រិទ្ធី

គិតត្រឹមដើមខែមករា ឆ្នាំ២០១៧នេះ ការដ្ឋានជួសជុលសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ទទួលបានលទ្ធផលប្រមាណ ៦០% ហើយ។ នេះបើតាមការលើកឡើងរបស់ជំនាញ ដែលគ្រប់គ្រងលើការងារនៅទីនោះ។

ការដ្ឋានជួសជុលសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ កំពុងដំណើរការដោយរលូន។ ការជួសជុល គឺធ្វើឡើងដោយយកចិត្តទុកដាក់ និងមានការគ្រប់គ្រងយ៉ាងច្បាស់លាស់ពីអ្នកជំនាញតាមផ្នែកផ្សេងៗ។

លោក យិត ចាន់ដារដ្ឋ ប្រធាននាយកដ្ឋានស្តីទី នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌរបស់អាជ្ញាធរជាតិអប្សរា បានឲ្យដឹងថា ការដ្ឋានជួសជុលសារមន្ទីរបានចាប់ផ្តើមដំណើរការនៅដើមខែវិច្ឆិកា ឆ្នាំ២០១៦ ហើយរហូតមកដល់ពេលនេះ គឺបានប្រើពេលជាង២ខែហើយ។

លោក ចាន់ដារដ្ឋ បានបន្តថា ការជួសជុលជាសំខាន់គឺផ្តោតលើដំបូលនៃអាគារទាំងមូល។ ការទ្រុឌទ្រោមនៃដំបូលអាគារធ្វើឲ្យសារមន្ទីរងាកខូចខាតជាច្រើនកន្លែង ដូចជាការហូរច្រោះទឹកចូលក្នុងអាគារទាំងមូលជាដើម។ ចំពោះការងារនេះ **លោក ចាន់ដារដ្ឋ** បញ្ជាក់ថា គេបានកោសដំបូលចាស់ចេញ ហើយជំនួសដោយប្រើបច្ចេកទេសថ្មីដើម្បីជានា ពីគុណភាពនៃអាគារទាំងមូល។

លោក ហូរី សម្បត្តិ វិស្វកគ្រប់គ្រងការងារជួសជុលនៅការដ្ឋានសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ នៃក្រុមហ៊ុនសាតូ ដែលទទួលខុសត្រូវលើការងារជួសជុលនេះ បានឲ្យដឹងដែរថា ដំបូលអាគារចាស់គេបានប្រើផ្លាស្ទិកក្រាល ដូច្នេះទើបវាមិនសូវមានគុណភាពឃ្យូរ។ បច្ចេកទេសចាស់នេះ ឃ្យូរឆ្នាំវាធ្វើឲ្យមានការពុកផុយ និងធ្វើឲ្យទឹកចូលជ្រាបចូលទៅតាមពិតាន ទើបធ្វើឲ្យមានស្នាមប្រេះនៅក្នុងអាគារ។ លោកបន្ថែមថា បច្ចេកទេសថ្មីដែលក្រុមហ៊ុនរបស់លោក យកមកធ្វើដំណោះស្រាយគឺប្រក់សន្លឹកសង្កសីពីក្រោម មុននឹងប្រក់ក្បឿងពីលើ។ លោកថា បច្ចេកទេសនេះជានាបានយូរអង្វែង មិនងាយខូចឡើយ។

ក្រៅពីការងារជួសជុលដំបូលដែលជាការងារសំខាន់ ក្នុងនោះទៀតសោត ការកែលម្អយ៉ាងនៃអាគារ ក៏ជាការងារសំខាន់ផងដែរ។ ក្រុមការងារបានជួសជុលបានរៀបចំប្រព័ន្ធហូរច្រោះថ្មី ធ្វើយ៉ាងណាឲ្យការហូរច្រោះទឹកភ្លៀងមានជម្រាលហូរកាត់។ ក្រៅពីនេះ មានការកែលម្អស្នាមប្រេះ និងលាបថ្នាំទាំងក្នុងនិងក្រៅនៃអាគារ រួមនិងដូរបង្គួចមួយចំនួនធំផងដែរ។

រហូតមកដល់ពេលនេះ ការដ្ឋានជួសជុលសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ សម្រេចបាន៦០%ហើយ។ ការដ្ឋាននេះប្រើប្រាស់បុគ្គលិកសរុបទាំងអស់ចំនួន៦៥នាក់។ តាមគម្រោង ការជួសជុលគ្រោងនឹងបញ្ចប់នៅចុងខែមីនាខាងមុខនេះ។

គួរម្លឹកថា ការងារជាក់ស្តែងដែលក្រុមហ៊ុនសាតូ ទទួលពីក្រុមហ៊ុន AEON (អ៊ីអុង) មាន១០ចំណុច រួមមាន ជួសជុលដំបូល លាបថ្នាំពណ៌ ផ្លាស់ប្តូរបង្គួចអាលុយមីញ៉ូមខាងក្រៅដែលរងការខូចខាត ទៅជាបង្គួចស្លាបព្រិល ផ្លាស់ប្តូរបង្គួចឈើដែលពុកផុយ តសំយ៉ាបនៅលំហកណ្តាលនៃអាគារ កែសម្រួលប្រព័ន្ធហូរទឹកនៅខាងក្រៅអាងទឹក កែសម្រួលទ្វារធំដែលកកិតគ្នា ជួសជុលស្នាមប្រេះនៃជញ្ជាំង និងពិតាន ជួសជុលជណ្តើរឡើងទៅលើដំបូល ធ្វើជម្រាលជនពិការនៅច្រកចូល។

តាមការបញ្ជាក់ពី **លោក ចាន់ដារដ្ឋ** ក្រៅពីចំណុចខាងលើនេះ ការងារផ្សេងៗទៀតជាបន្ទុករបស់អាជ្ញាធរជាតិអប្សរា។ ការងារទាំងនោះរួមមាន រៀបចំការតាំងពិព័រណ៌ឡើងវិញ រៀបចំផ្សព្វផ្សាយធ្វើឲ្យមានភ្ញៀវទេសចរ អគ្គិសនី ម៉ាស៊ីនត្រជាក់ រួមនឹងការដឹកជញ្ជូនរូបបដិមាក្នុងសារមន្ទីរទៅរក្សានៅកន្លែងមានសុវត្ថិភាព។ល។

សូមបញ្ជាក់ដែរថា គម្រោងជួសជុលសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ គឺជាកិច្ចសហប្រតិបត្តិការរវាងភាគី៤ស្ថាប័ន ដោយរួមមាន អាជ្ញាធរជាតិអប្សរា មូលនិធិក្លឹបអ៊ីអុង១% (AEON 1% Club Foundation) ក្រុមហ៊ុនឧស្សាហកម្មសាតូ (កម្ពុជា) និងមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សនៃសាកលវិទ្យាល័យសូហ្វីយ៉ា។ ក្រុមហ៊ុន អ៊ីអុង ជាអ្នកវ៉ាប់រងចំណាយក្នុងការងារជួសជុលទាំងនេះ ក្រោយពីស្ថាប័ននេះជាអ្នកផ្តល់មូលនិធិកសាងសារមន្ទីរនេះនៅឆ្នាំ២០០៧។ ចំណែកអាជ្ញាធរជាតិអប្សរា ជាអ្នកផ្តល់បច្ចេកទេស និងថែរក្សារូបបដិមា នៅក្នុងសារមន្ទីរទាំងមូល៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធ អតីតយុទ្ធជននៅក្នុងឱកាសរំឭកខួបលើកទី៣៨ នៃទិវាជ័យជម្នះ៧មករា (៧.០១.១៩៧៩-៧.០១.២០១៧)

ផ្សាយនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សែន សែត រូបភាព ៖ ស្បឿន ប៊ុនសារ

នាព្រឹកថ្ងៃទី៧ មករា ឆ្នាំ២០១៧នេះ ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាដឹកនាំដោយ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករង បានចូលរួមគោរពវិញ្ញាណក្ខន្ធអតីតវីរយុទ្ធជន យុទ្ធនារី នៅវិមានរំឭកគុណអតីតវីរយុទ្ធជនខេត្តសៀមរាប ដែលប្រារព្ធឡើងក្រោម អធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ឡៅ ឃាង្ស** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។

ពិធីគោរពវិញ្ញាណក្ខន្ធនេះ ត្រូវបានរៀបចំឡើងស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេសរៀបចំខួបទី៣៨ នៃទិវាជ័យជម្នះ៧មករា១៩៧៩។ ទិវាជ័យជម្នះ៧មករា ជាទិវាប្រវត្តិសាស្ត្រមិនអាចបំភ្លេចបាន ដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍។

តាមរយៈជ័យជម្នះដ៏មានន័យនេះហើយ ដែលបាននាំមកនូវសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យក្នុងប្រទេសកម្ពុជា ដោយរួមបញ្ចូលទាំងការងារអភិរក្ស ជួសជុល និងស្តារឡើងវិញនូវបេតិកភណ្ឌជាតិ និងបេតិកភណ្ឌពិភពលោកអង្គរ របស់កម្ពុជា៕









ក្រុមគ្រូពេទ្យស្ម័គ្រចិត្តជុំវិញពិភពលោកចុះពិនិត្យសុខភាពនិងព្យាបាលជំងឺ ជូនប្រជាជននៅភូមិតាកុះក្នុងឧទ្យានអង្គរដោយមិនគិតថ្លៃ

ផ្សាយនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ឹង ស្រីរ័ត្ន

ក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីបណ្តាប្រទេសផ្សេងៗជុំវិញពិភពលោក (Volunteers Around the World) និងបុគ្គលិកស្ម័គ្រចិត្តចំនួន១៥នាក់មកពីសាកលវិទ្យាល័យនៃរដ្ឋ Alaska សហរដ្ឋអាមេរិក បានសហការជាមួយក្រុមគ្រូពេទ្យខ្មែរអាជ្ញាធរជាតិអប្សរា និងអាជ្ញាធរមូលដ្ឋាន ចុះមកពិនិត្យសុខភាព និងព្យាបាលជំងឺជូនប្រជាជននៅភូមិតាកុះ ឃុំប្រដាក ស្រុកបន្ទាយស្រីដោយឥតគិតថ្លៃ នាព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ២០១៧។

ឯកឧត្តម ម៉ី ម៉ាឌី ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក បានលើកឡើងថា នេះជាថ្ងៃទី៦ហើយនៃដំណើរការពិនិត្យសុខភាព និងព្យាបាលជំងឺជូនប្រជាជនដោយឥតគិតថ្លៃនៅឃុំប្រដាក ដែលបានចាប់ផ្តើមតាំងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ លើភូមិគោលដៅចំនួន៦ មានភូមិប្រដាក ភូមិតាត្រែ ភូមិអូរទទឹង ភូមិថ្ម៉ល់ទទឹង ភូមិថ្ម៉ល់បណ្តោយ និងភូមិតាកុះ ដែលស្ថិតក្នុងស្រុកបន្ទាយស្រី។ វត្តមានរបស់គ្រូពេទ្យស្ម័គ្រចិត្តនៅពេល នេះជាឱកាសល្អសម្រាប់ប្រជាជនងាយស្រួលមកពិនិត្យជំងឺនៅជិតផ្ទះ ហើយមិនចំណាយថវិកាក្នុងការព្យាបាល។ អាជ្ញាធរជាតិអប្សរាសូមសម្តែងការអរគុណចំពោះទឹកចិត្ត និងការលះបង់ដ៏ធំធេងរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តជុំវិញពិភពលោកទាំងអស់ ហើយនឹងបន្តកិច្ចសហការយ៉ាងល្អបន្តទៀត ដើម្បីចូលរួមលើកស្ទួយសុខុមាលភាពរបស់ប្រជាជនក្នុងរមណីយដ្ឋានប្រវត្តិសាស្ត្រនេះឱ្យទទួលបានសុខភាពល្អ និងការរស់នៅដ៏ប្រសើរ។

អ្នកស្រីវេជ្ជបណ្ឌិត NICOLE Arguedas អនុប្រធានគម្រោងគ្រូពេទ្យស្ម័គ្រចិត្តជុំវិញពិភពលោក មកពីប្រទេសពេរូ បានប្រាប់ថា គោលបំណងសំខាន់របស់អង្គការអ្នកស្ម័គ្រចិត្តជុំវិញពិភពលោក គឺបង្កើតឡើងដើម្បីផ្តល់ជូនសេវាកម្មសុខភាពដល់សហគមន៍ជុំវិញពិភពលោក ដែលត្រូវការជំនួយផ្នែកសុខាភិបាល និងជូនថ្នាំសង្កូវដោយឥតគិតថ្លៃ។ អ្នកស្រីបន្តទៀតថា នេះជាលើកទី១នៅប្រទេសកម្ពុជាដែលក្រុមការងារបានផ្តល់ជូនសេវាកម្មពិនិត្យជំងឺទូទៅ ពិគ្រោះយោបល់ និងផ្តល់ថ្នាំជូនដោយឥតគិតថ្លៃដល់មនុស្សគ្រប់វ័យ ទាំងប្រុសទាំងស្រី។ ដោយឡែក ចំពោះជំងឺខ្លះដែលត្រូវព្យាបាលយូរ ក្រុមការងារអ្នកស្រីនឹងណែនាំអ្នកជំងឺទៅជួបគ្រូពេទ្យជំនាញ ឬមន្ទីរពេទ្យក្នុងស្រុកដើម្បីព្យាបាលបន្ត។ អ្នកស្រីនឹងមានគម្រោងមក កាន់កម្ពុជាលើកក្រោយៗទៀតនាពេលដ៏ឆាប់ខាងមុខ ហើយអ្នកស្រីសូមអរគុណចំពោះអាជ្ញាធរមូលដ្ឋាននិងអាជ្ញាធរជាតិអប្សរា ដែលបានផ្តល់កិច្ចសហការយ៉ាងកក់ក្តៅដើម្បីសម្រួលក្នុងការព្យាបាលជំងឺជូនប្រជាជននៅតំបន់អង្គរ។

លោក តូច ឈន់ មេឃុំប្រជាក បានបញ្ជាក់ថា រយៈពេល៦ថ្ងៃដែលក្រុមគ្រូពេទ្យស្ម័គ្រចិត្តជុំវិញពិភពលោកចុះមកពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាជនបានចំនួនជាង៦០០នាក់ ហើយប្រជាជនចូលរួមយ៉ាងសកម្ម និងលើសការកំណត់ព្រោះជាឱកាសល្អ ដែលពួកគាត់បានព្យាបាលជំងឺ និងទទួលថ្នាំពេទ្យដោយមិនចំណាយលុយ។ លោកមេឃុំក៏បានសម្តែងការអរគុណដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តទាំងអស់ ដែលបានចំណាយថវិកា និងពេលវេលាមកជួយប្រជាជននៅក្នុងឃុំប្រជាក ធ្វើឱ្យប្រជាជនសប្បាយចិត្តជាខ្លាំង។ ជាពិសេសអរគុណដល់អាជ្ញាធរជាតិអប្សរា ដែលតែងតែគិតគូរពីការរស់នៅ សុខភាព ការអប់រំដល់ ប្រជាជនក្នុងឧទ្យានអង្គរ។

លោកយាយ ឡាច វ៉ន់ អាយុ៦៩ បានសម្តែងនូវសេចក្តីរីករាយ ដែលមានគ្រូពេទ្យចុះមកជួយពិនិត្យជំងឺដល់ភូមិស្រុកមិនគិតលុយកាក់ ហើយថែមទាំងឱ្យថ្នាំលេបដើម្បីព្យាបាលជំងឺឈឺដៃទៀតផង។ លោកយាយក៏សូមអរគុណដល់អាជ្ញាធរជាតិអប្សរា ដែលបង្កើតឱ្យមានកម្មវិធីនេះឡើង ឱ្យអ្នកស្រុកអ្នកភូមិមានឱកាសបានដឹងពីអាការៈរោគដោយមិនអស់លុយ។

គួរបញ្ជាក់ផងដែរថា វត្តមានរបស់គ្រូពេទ្យស្ម័គ្រចិត្តជុំវិញពិភពលោកចុះមកពិនិត្យសុខភាព ព្យាបាលជំងឺ និងចែកថ្នាំជូនប្រជាជនដោយឥតគិតថ្លៃក្នុងឧទ្យានអង្គរមាន៣ក្រុមធំៗ គឺមកពីរដ្ឋ Alaska ចំនួន១៥នាក់ មកពីរដ្ឋ Chicago ចំនួន១២នាក់ មកពីរដ្ឋស៊ីដនីនិង Stony Brook នៃប្រទេសអូស្ត្រាលីចំនួន២២នាក់ រួមទាំងគ្រូពេទ្យខ្មែរជាច្រើនរូបទៀតដើម្បីសម្របសម្រួល។ ក្នុងនោះ ឃុំចំនួន៨ក្នុងស្រុកស្រុកបន្ទាយស្រីត្រូវបានជ្រើសរើសជាឃុំគោលដៅ គឺឃុំប្រជាក ឃុំខ្នាសណ្តាយ ឃុំរំចេក និងឃុំរុនតាឯក ស្មើនឹង១៨ភូមិ ដែលចាប់ដំណើរការពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧៕









តំបន់រមណីយដ្ឋានអង្គរចាប់ផ្តើមបង្កើនសេវាទូរសព្ទនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ4Gសម្រាប់អ៊ីនធើណេត

ផ្សាយនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីរត្ន័ រូបភាព ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ

បង្គោលអង់តែនសិប្បនិម្មិតដែលមានទម្រង់រូបរាងជាដើមឈើចំនួន៦ដើម ត្រូវបានដាក់តំឡើងរួចរាល់ជាស្ថាពរ និងដាក់ឱ្យដំណើរការហើយនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនទូរសព្ទផ្សេងៗបំពាក់អង់តែនបង្កើនសេវាទូរសព្ទនិងល្បឿនអ៊ីនធឺណេតឱ្យបានទូលំទូលាយដល់ភ្ញៀវទេសចរ ប្រជាជនក្នុងតំបន់អង្គរ អ្នកប្រកបរបរអាជីវកម្មសេវាកម្មទេសចរណ៍ និងវិស័យឯកជននានានៅក្នុងតំបន់ប្រវត្តិសាស្ត្រខ្មែរដ៏ល្បីមួយនេះ។

តាមបញ្ជាក់ពី **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងអាជ្ញាធរជាតិអប្សរាទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ បានឱ្យដឹងថា បង្គោលអង់តែន បានតំឡើងចំនួន៦ទីតាំង ដូចជា CTL1 នៅភូមិទក្សិណត្បូង សង្កាត់គោកចក CTL2 នៅភូមិក្រវ៉ាន់ សង្កាត់នគរធំ CTL3 នៅភូមិរហាល សង្កាត់នគរធំ CTL4 នៅភូមិនគរក្រៅ សង្កាត់គោកចក CTL5 នៅខ្លោងទ្វារគោការ និង CTL6 នៅតាមបណ្តោយផ្លូវកូម៉ែ។ **ឯកឧត្តម សុខ សង្ហារ** បន្តទៀតថា បើគិតមកដល់ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ ប្រព័ន្ធទូរសព្ទស្មាតជាក្រុមហ៊ុនដំបូងគេដែលបានដាក់ឱ្យដំណើរការសេវាទូរសព្ទ និងបណ្តាញអ៊ីនធឺណេត4Gយ៉ាងរលូនក្នុងតំបន់រមណីយដ្ឋានអង្គរ ហើយនាពេលឆាប់ៗខាងមុខនេះ និងមានប្រព័ន្ធទូរសព្ទផ្សេងៗទៀតក្នុងប្រទេសមកបំពាក់សេវាទូរសព្ទ និងសេវាអ៊ីនធើណិតបន្ថែមទៀតផងដែរ។

តាមរយៈការតំឡើងបង្គោលអង់តែនសិប្បនិម្មិត និងបំពាក់សេវាប្រព័ន្ធទូរសព្ទនានាក្នុងតំបន់រមណីយដ្ឋានអង្គរនេះនឹងធ្វើឱ្យភ្ញៀវទេសចរជាតិ-អន្តរជាតិដែលមកទស្សនាតំបន់អង្គរ មានភាពងាយស្រួលទាំងការហៅទូរសព្ទ ការផុសរូបក្នុងបណ្តាញសង្គមហ្វេសប៊ុក និងផ្សាយផ្ទាល់វីដេអូពីដំណើរកម្សាន្តរបស់ខ្លួនបានភ្លាមៗ ។ ជាពិសេសជាងនេះទៅទៀតវាបានជួយសម្រួល ដល់ការងាររបស់អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធក្នុងការប្រតិបត្តិការងាររបស់ខ្លួនផង។

នេះជាលើកទី១ហើយសម្រាប់ប្រទេសកម្ពុជា ដែលបានរៀបចំតំឡើងអង់តែនសិប្បនិម្មិតមានរូបរាងដូចដើមឈើ និងដាក់ឱ្យដំណើរការនៅលើទឹកដីអង្គរបេតិកភណ្ឌពិភពលោក។ អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់បំផុត ចំពោះការផ្តល់ជូននូវភាពងាយស្រួលតាមរយៈការរៀបចំសេវាកម្មទេសចរណ៍ ដើម្បីទាក់ទាញទេសចរឱ្យចូលមកទស្សនាតំបន់ប្រវត្តិសាស្ត្រដ៏ល្បីនេះឱ្យកាន់តែច្រើនឡើង។ លើសពីនោះទៀត អាជ្ញាធរជាតិអប្សរាក៏បានគិតគូរដល់ការអភិរក្ស និងការថែរក្សាសោភ័ណភាពនៅក្នុងតំបន់អង្គរផងដែរ ជាក់ស្តែងការតំឡើងអង់តែនសិប្បនិម្មិតសម្រាប់បំពាក់ប្រព័ន្ធទូរសព្ទដូច្នេះ ក៏តម្រូវឱ្យមានលក្ខណៈធម្មជាតិ ដែលអាចបន្លំនិងរក្សាបាននូវភាពស្រស់បំព្រងនៃទេសចរណ៍ធម្មជាតិ ស្របតាមបទដ្ឋានរបស់តំបន់បេតិកភណ្ឌពិភពលោកទៀតផង៕





ដើមស្គង់ចំណាស់មួយដើមក្នុងតំបន់អង្គរត្រូវបានជួយសង្គ្រោះដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ាហ៊ីនី រូបភាព ៖ ធុន ប៊ុនថុន

ក្រៅពីទស្សនាប្រាង្គប្រាសាទដ៏អស្ចារ្យ ភ្ញៀវទេសចរមួយចំនួនក៏បានចាប់អារម្មណ៍នឹងទេសភាពដ៏ស្រស់ស្អាតនៃដើមឈើធំៗ ដែលដុះចាក់ឫសនៅលើតួប្រាសាទផងដែរ ។ ដើមឈើចំណាស់ជាច្រើនបានទាក់ទាញចំណាប់អារម្មណ៍ភ្ញៀវទេសចរ ជាពិសេសដើមស្គង់នៅក្នុងប្រាសាទតាព្រហ្ម ក៏ដូចជានៅតាមបណ្តាប្រាង្គប្រាសាទមួយចំនួនទៀត។

ក្នុងបំណងអភិរក្ស និងថែរក្សាដើមឈើចំណាស់ដែលដុះក្នុងឧទ្យានអង្គរ អាជ្ញាធរជាតិអប្សរា តាមរយៈនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានចុះព្យាបាលប្រភេទដើមឈើចំណាស់ៗជាច្រើន ជាពិសេសដើមស្គង់។ ជាក់ស្តែង ដើមស្គង់ចំណាស់មួយដើមនៅជិតខ្លោងទ្វារទន្លេអុំ ត្រូវបានអភិរក្សថែទាំដោយយកចិត្តទុកដាក់ពីក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា។ ការជួយសង្គ្រោះនេះ ត្រូវបានធ្វើឡើងនៅព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ២០១៧។

លោក លឹម សៀងហួត បុគ្គលិកជំនាញតាមដានសុខភាព ផ្នែកព្យាបាលដើមឈើនៃនាយដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានឲ្យដឹងថា ដើមស្គង់ដែលចុះមកព្យាបាលនេះ មានការពុកផុយនៅត្រង់គល់ និងចុង។ ដោយសារមានទីតាំងជាប់ផ្លូវដើរជើសំខាន់សម្រាប់ភ្ញៀវទេសចរ ដូច្នេះក្រុមការងាររបស់លោកប្រញាប់ក្នុងការព្យាបាល ហើយការព្យាបាលនេះក៏មានការចាប់អារម្មណ៍ច្រើនពីសំណាក់ទេសចរដែលកំពុងទស្សនានៅទីនោះផងដែរ។ ភ្ញៀវទេសចរទាំងនោះបានសាកសួរពីការងារព្យាបាលដើមស្គង់ ដែលក្រុមការងារកំពុងជួយសង្គ្រោះនេះ ។

ដើមស្គង់ដែលក្រុមជំនាញកំពុងព្យាបាលនេះ មានបញ្ហា៣សំខាន់។ ទីមួយ ដើមអម្ពិលដែលដុះក្បែរនោះ ឫសរបស់វាចាក់ប្រជែងនឹងគល់ដើមស្គង់ ទីពីរ ការដើរជាន់ឫសស្គង់ពីសំណាក់មនុស្ស ព្រោះថាវានៅជិតផ្លូវដើរ ធ្វើឲ្យវាពិបាកស្រូបយកជីវជាតិក្នុងដី និងទីបី ដោយសារអាយុកាលរបស់វា ដោយចំណុចខ្លះនៃគល់ បានពុកផុយ និងមានសត្វកណ្តៀរឡើង។

សម្រាប់វិធីសាស្ត្រនៃការព្យាបាល **លោក សៀងហួត** បានរៀបរាប់ថា៖ « ការព្យាបាលដើមស្គង់ គឺធ្វើឡើងតាមរយៈការកោសសំបកពុកផុយចេញ លាបជ័រទឹក ដើម្បីការពារពីការជ្រាបទឹកចូលក្នុងសាច់ និងចុងក្រោយបិទដីដំបូក ដើម្បីឲ្យសាច់ឈើដុះឡើងវិញ ។ បន្ទាប់មក ក្រុមការងារនឹងបន្តតាមដានរយៈពេល៦ខែទៅមួយឆ្នាំ ដើម្បីដឹងពីការវិវត្តថ្មីរបស់ដើមស្គង់»។

យ៉ាងណាក៏ដោយ តាមបទពិសោធន៍របស់ **លោក សៀងហួត** ដែលកន្លងមកបានចុះព្យាបាលដើមស្គង់ជាច្រើនដើមនោះ បាននិយាយថា មានតែដើមស្គង់ដែលមានសាច់ខ្ចីតែប៉ុណ្ណោះ ដែលអាចលូតលាស់ល្អឡើងវិញ ចំណែកស្គង់ចាស់មានអាយុលើសពី១០០ឆ្នាំឡើង លទ្ធភាពលូតលាស់មានតិចតួចបំផុត។ ស្គង់ខ្ចី កោសិការបស់វាឆាប់លូតលាស់ជាងស្គង់ចាស់ ដែលកោសិការបស់វាមួយចំនួនបានងាប់ទៅហើយ ដោយការព្យាបាលគ្រាន់តែពន្យារអាយុកាលរបស់វាតែប៉ុណ្ណោះ។

គួរឱ្លឹកថា ស្គង់ជាប្រភេទឈើក្រៅចំណាត់ថ្នាក់មួយ ហើយភាគច្រើនមានដុះនៅតំបន់អង្គរ។ នៅតំបន់អង្គរ ដើមស្គង់មានដុះច្រើនជាងគេនៅប្រាសាទតាព្រហ្ម។ ស្គង់ជាដើមឈើទាក់ទាញ ចំណែកឫសរបស់វាមួយចំនួន ក៏មានផលប្រយោជន៍ការពារ និងទ្រប្រាសាទផងដែរ៕






អាជ្ញាធរជាតិអប្សរាបន្តដាំកូនឈើបន្ថែមទៀតនៅតាមជើងទេរទំនប់បារាយណ៍ជ័យតដាក ដើម្បីការពារការហូរច្រោះដីចូលក្នុងបារាយណ៍

ផ្សាយនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

ព្រៃឈើមិនត្រឹមតែផ្តល់ផលប្រយោជន៍ចំពោះមនុស្ស និងសត្វប៉ុណ្ណោះទេ តែព្រៃឈើក៏រឹងរឹតតែមានប្រយោជន៍ចំពោះបេតិកភណ្ឌថែមទៀត ព្រោះព្រៃឈើអាចធ្វើជារបាំងខ្យល់ ទប់ស្កាត់ការសឹករេចរឹល និង ស្រូបទឹកក្រោមដីដើម្បីផ្តល់សំណើមដល់ប្រាង្គប្រាសាទ ។

ជាក់ស្តែងនៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧នេះ កូនឈើចម្រុះចំនួន១៨០០ដើម ត្រូវបានអាជ្ញាធរជាតិអប្សរាដាំនៅតាមជើងទំនប់បារាយណ៍ជ័យតដាកខាងជើង តាមដងផ្លូវទៅប្រាសាទនាគព័ន្ធ ដែលជាទីតាំងត្រូវការពារទាំងបេតិកភណ្ឌ និងទេសភាពធម្មជាតិនៃតំបន់ទាំងមូល។

លោក វ៉ាត ប៊ុនថា បុគ្គលិកបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងទឹក នៃអាជ្ញធរជាតិអប្សរាបានបញ្ជាក់ថាកូនឈើ ដែលក្រុមការងារយកទៅដាំតាមជើងទេរទំនប់បារាយណ៍មាន៣ប្រភេទ រួមមានកូនរំដួល៦០០ដើម កូនក្របៅ៦០០ដើម និងកូនរាំង៦០០ដើម ដើម្បីការពារជើងទេររបស់ទំនប់ពីការហូរច្រោះដីនៅពេលមានភ្លៀងធ្លាក់ ។ លោកបញ្ជាក់ទៀតថាការដាំកូន ឈើតាមជើងទេរទំនប់បារាយណ៍នេះ វាមិនត្រឹមតែជួយការពារជើងទេរទំនប់ប៉ុណ្ណោះទេ ប៉ុន្តែវានៅផ្តល់សោភណភាពដល់បារាយណ៍ ជួយកាត់បន្ថយរំហួតទឹក ព្រមទាំងផ្តល់ម្លប់ដ៏ត្រជាក់ត្រជុំដល់ភ្ញៀវទេសចរនៅពេលធ្វើដំណើរទស្សនាកំសាន្តក្នុងតំបន់ឧទ្យានអង្គរទៀតផង។

គួររំឭកថា ក្នុងឆ្នាំ២០១៦កន្លងទៅ អាជ្ញធរជាតិអប្សរាក៏ធ្លាប់ដាំកូនឈើតាមជើងទេរទំនប់បារាយណ៍ជ័យតដាកនេះចំនួន ១៥០០ដើមដែរ ក្នុងន័យរួមចំណែកអភិរក្ស និងលើកតម្លៃទេសភាពវប្បធម៌ធម្មជាតិ នៃតំបន់ឧទ្យានអង្គរឲ្យកាន់តែស្រស់ស្អាតជាប្រចាំដើម្បីទាក់ទាញភ្ញៀវទេសចរឲ្យមកទស្សនាកាន់តែច្រើនឡើងថែមទៀត។









រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិរដ្ឋOntarioនៃប្រទេសកាណាដា មកស្វែងយល់ការងារគ្រប់គ្រងរមណីយដ្ឋានអង្គរពីសំណាក់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សែន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ នៃរដ្ឋ Ontario ប្រទេសកាណាដា គឺ **ឯកឧត្តម** Michael Chan បានមកបំពេញទស្សនកិច្ច និងស្វែងយល់អំពីការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ ពីសំណាក់មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។ ទទួលស្វាគមន៍ និងធ្វើបទបង្ហាញជូនឯកឧត្តមរដ្ឋមន្ត្រីនៅពេលនេះមាន **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករង និងជាតំណាងឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា រួមនឹងថ្នាក់ដឹកនាំមន្ត្រីជំនាញជាច្រើនរូបផ្សេងទៀត។

បន្ទាប់ពីកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ **ឯកឧត្តម សុខ សង្ហារ** ក៏បានបង្ហាញជូនគណៈប្រតិភូកាណាដាអំពីការវិវត្តសំខាន់ៗ ដែលពាក់ព័ន្ធនឹងការរៀបចំគ្រប់គ្រងរមណីយដ្ឋានអង្គរ។ ក្នុងនោះ ចាប់ពីអង្គរត្រូវបានដាក់ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩២មក តាមរយៈឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ការគ្រប់គ្រងអង្គរត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់បំផុត ជាក់ស្តែងការរៀបចំគណៈកម្មាធិការអន្តរជាតិ ICC-Angkor ក្នុងឆ្នាំ១៩៩៣ ការកំណត់តំបន់ការពារក្នុងឆ្នាំ១៩៩៤ ការបង្កើតអាជ្ញាធរជាតិអប្សរាក្នុងឆ្នាំ១៩៩៥ ការបង្កើតច្បាប់ស្តីពីការគ្រប់គ្រងបេតិកភណ្ឌក្នុងឆ្នាំ ១៩៩៦ គោលនយោបាយបើកលំហដើងមេឃឆ្នាំ១៩៩៧ យុទ្ធសាស្ត្រឈ្នះៗដែលបានបញ្ចប់សង្គ្រាមផ្ទៃក្នុងទាំងស្រុងក្នុងឆ្នាំ១៩៩៨ ។ កត្តាទាំងនេះហើយ ដែលជំរុញឲ្យអង្គរត្រូវបានដកចេញពីបញ្ជីបេតិកភណ្ឌប្រឈមនឹងគ្រោះថ្នាក់ឆ្នាំ ២០០៤។

ជាមួយគ្នានេះ **ឯកឧត្តម សុខ សង្ហារ** ក៏បានបញ្ជាក់ផងដែរ អំពីភាពជោគជ័យនៃការគ្រប់គ្រងរមណីយដ្ឋានអង្គរយៈពេលជាង២០ឆ្នាំកន្លងមកនេះរបស់អាជ្ញាធរជាតិអប្សរា តាមរយៈយន្តការ ICC-Angkor និងកិច្ចសហប្រតិបត្តិការយ៉ាងល្អពីសំណាក់ដៃគូជាតិ និងអន្តរជាតិជាច្រើនទៀត។ មិនត្រឹមតែជោគជ័យនៅអង្គរទេ យន្តការ ICC-Angkor ត្រូវបានបណ្តាប្រទេសជាច្រើនយកគំរូទៅអនុវត្តតាមទៀតផង។ ក្រៅពីនេះមន្ត្រីជំនាញ៤រូបផ្សេងទៀត ក៏បានធ្វើបទបង្ហាញជូនឯកឧត្តមរដ្ឋមន្ត្រីអំពីកិច្ចការអភិរក្សជួសជុលប្រាសាទក្នុងរមណីយដ្ឋានអង្គរ ការអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍អង្គរ ការអភិវឌ្ឍន៍សហគមន៍ក្នុងរមណីយដ្ឋានអង្គរ និងការគ្រប់គ្រងបរិស្ថានក្នុងរមណីយដ្ឋានអង្គរ។

ឯកឧត្តម Michael Chan បានរៀបរាប់ថា លោកពិតជាស្ងើចសរសើរចំពោះស្តាដៃដូនតាខ្មែរ ដែលបានសាងសង់ប្រាសាទយ៉ាងល្អឥតខ្ចោះ ជាពិសេសលោកពិតជាស្ងើចសរសើរចំពោះការខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរា ដែលបំពេញបេសកកម្មដ៏ធំធេងរបស់ខ្លួនបានទទួលលទ្ធផលយ៉ាងជោគជ័យ។ ឯកឧត្តមបញ្ជាក់ថា "មុនចេញដំណើរមកប្រពន្ធខ្ញុំបានស្វែងរកក្នុងប្រព័ន្ធអ៊ីនធើណិតអំពីអង្គរ ហើយបានដឹងថា អង្គរពិតជាអស្ចារ្យណាស់ យើងបានដឹងថាថ្មីៗនេះអង្គរបានក្លាយជាគោលដៅទស្សនាដ៏ល្អបំផុតលើលោកទៀតផង"។ ឯកឧត្តមបញ្ជាក់ថា "ក្រោយពីស្តាប់បង្ហាញអម្បាញ់មិញនេះទៅឃើញថាមានប្រទេសជាច្រើនមកចូលរួមជួយអង្គរ ខ្ញុំនឹងយកបញ្ហានេះទៅជម្រាបជូនថ្នាក់ដឹកនាំខ្ញុំ ហើយខ្ញុំនឹងជំរុញស្ថាប័នជាតិ និងស្ថាប័នស្ម័គ្រចិត្តនានានៅក្នុងប្រទេសកាណាដា ដើម្បីមកចូលរួមក្នុងកិច្ចការអភិរក្សអង្គរនាពេលខាងមុខ"៕









វីដេអូ ៖ រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិរដ្ឋ Ontario នៃប្រទេសកាណាដា មកស្វែងយល់ការងារគ្រប់គ្រងរមណីយដ្ឋានអង្គរពីសំណាក់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ស៊ុម សុម៉េធ



ឆ្នាំ២០១៦កន្លងទៅនេះអាជ្ញាធរជាតិអប្សរាដាំកូនឈើបានជាង៦ម៉ឺនដើមក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សែន សែត រូបភាព ៖ ន.ផ្សព្វផ្សាយ

កូនឈើចម្រុះគ្រប់ប្រភេទ ជាពិសេសប្រភេទឈើដែលមានពូជនៅតំបន់អង្គរស្រាប់ ត្រូវបានអាជ្ញាធរជាតិអប្សរាបណ្តុះ និងដាំបានចំនួន៦០៤៤៤ដើម លើផ្ទៃដីទំនេរក្នុងរមណីយដ្ឋានអង្គរទាំងមូល។ ចំនួននេះគឺបានឆ្លើយតបទៅនឹងផែនការប្រចាំឆ្នាំ ដែលអាជ្ញាធរជាតិអប្សរាបានកំណត់ដាំកូនឈើយ៉ាងតិច៦ម៉ឺនដើមក្នុងមួយឆ្នាំ។

លោក និន ចាន់សាមៀន ប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បញ្ជាក់ថា កូនឈើដែលបានដាំទាំងជាង៦ម៉ឺនដើមនេះ គឺដាំដោយក្រុមការងារព្រៃឈើផ្ទាល់ជាង៣ម៉ឺនដើម និងចែកជូនអង្គ ភាព ពាក់ព័ន្ធដាំចំនួនជាង២ម៉ឺនដើម។

លោកបន្ថែមថា "កូនឈើដែលយើងបានដាំនេះ មិនរាប់បញ្ចូលទាំងកូនឈើដែលយើងចែកជូនប្រជាពលរដ្ឋយកទៅដាំតាមផ្ទះ សម្បែងដើម្បីហូបផ្លែ ឬប្រើការផ្សេងៗទេ យើងគិតតែដីព្រៃសុទ្ធប៉ុណ្ណោះ។ យើងមានគម្រោងនិងបានជំរុញជាបណ្តើរៗឲ្យប្រជាពលរដ្ឋក្នុងតំបន់អង្គរចូលរួមដាំឈើ តាមផ្ទះរបស់គាត់ និងតាមភ្លឺស្រែ ដើម្បីបង្កើតគម្របព្រៃឈើ ក្នុងតំបន់អង្គរបានយ៉ាងតិច៦០%នាពេលអនាគត"។

តាម **លោក ចាន់សាមៀន** ព្រៃឈើក្នុងតំបន់អង្គរមានការកើនឡើងជាបន្តបន្ទាប់ដោយរាប់ចាប់ពីឆ្នាំ២០០៨ ។ លោក បញ្ជាក់ថា តាមទិន្នន័យដែលទទួលបានពីរដ្ឋបាលព្រៃឈើក្នុងឆ្នាំ២០០៦ ព្រៃឈើក្នុងឧទ្យានអង្គរមានចំនួន៤៥៨៥ ហិកតា ដែលស្មើនឹង១១,៤៣%។ ក្នុងឆ្នាំ២០១៣ក្រុមអង្កេតព្រៃឈើបានរកឃើញផ្ទៃដីព្រៃកើនឡើងដល់៥៧៣៧ហិកតា ដែលស្មើនឹង១៤,៣%នៃឧទ្យានអង្គរទាំងមូល។ ការអង្កេតដែលធ្វើឡើងក្នុងឆ្នាំ២០១៦កន្លងទៅនេះឃើញថា ព្រៃឈើក្នុងតំបន់អង្គរមានការកើនឡើងដល់៦៥០៥ហិកតា ដែលស្មើនឹង១៦,២២%នៃផ្ទៃដីឧទ្យានអង្គរទាំងមូល។

ទោះជាព្រៃឈើក្នុងតំបន់អង្គរមានការកើនឡើងជាបន្តបន្ទាប់យ៉ាងនេះក្តី **លោក សាមៀន** បញ្ជាក់ថា ដរាបណាប្រជាពលរដ្ឋមិនទាន់បានចូលរួមដាំឈើតាមផ្ទះសម្បែង និងតាមភ្លឺស្រែរបស់ពួកគាត់ទេ គម្របព្រៃឈើអង្គរ នៅតែមិនគ្រប់គ្រាន់ព្រោះថា បើមើលតាមស្ថិតិជាក់ស្តែង ផ្ទៃដីកសិកម្មរបស់ពួកគាត់មានដល់ទៅជាង៥០% ហើយបើដីទាំងនោះពុំមានដើមឈើទេនឹងទៅវាលធំធេង មិនអាចធ្វើឲ្យឧទ្យានអង្គរមានពណ៌បៃតងបានឡើយ។ "យើងជំរុញឲ្យប្រជាពលរដ្ឋចូលរួមដាំឈើតាមផ្ទះ និងតាមស្រែរបស់គាត់ដើម្បីធ្វើអុសដុត និងលក់ដូរ។ យើងបានណែនាំពួកគាត់ឲ្យដាំដើមកន្ទុំថេតតាមរបងផ្ទះតាមភ្លឺស្រែ ព្រោះប្រភេទឈើនេះមានអត្ថប្រយោជន៍ច្រើនដូចជា ធាប់ធំ ស្លឹកនិងផ្លែធ្លាក់ទៅបង្កើនជាតិអាសូត ជាជីដល់ដីស្រែគាត់ ហើយពួកគាត់ក៏អាចបេះស្លឹកនិងផ្លែធ្វើអន្លក់ឬលក់ដូរបាន។ ជាពិសេស គាត់នឹងបានអុសដុតជាប្រចាំមិនទៅកាប់ឈើក្នុងព្រៃអង្គរមកដុតទៀត"៕









ក្រុមហ៊ុនសូម៉ាពាណិជ្ជឧបត្ថម្ភពូជបន្លែជូនដល់ប្រជាពលរដ្ឋនៅភូមិធម្មជាតិរុនតាឯក

ផ្សាយនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរត្ន័ រូបភាព ៖ ហ៊ឹង ស្រីរត្ន័

ពូជបន្លែដែលនាំចូលពីប្រទេសបារាំងរួមមាន សាឡាដ ប៉េងប៉ោះ និងបន្លែផ្សេងៗទៀត ត្រូវបានក្រុមហ៊ុនសូម៉ាពាណិជ្ជ យកមកប្រគល់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិធម្មជាតិរុនតាឯក ដើម្បីជាំជុះបង្កបង្កើនផលសម្រាប់បរិភោគ និងលក់ ដូរពង្រឹងជីវភាពគ្រួសារ។

ថ្លែងក្នុងពិធីប្រគល់ពូជដំណាំកាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០១៧កន្លងមកនេះ **លោក ម៉ែន អង្គារ៉ា** តំណាងក្រុមហ៊ុនសូម៉ា ពាណិជ្ជ និងជាអ្នកជំនាញកសិកម្មនៃប្រទេសបារាំង លើកឡើងថា នេះគឺជាការរួមចំណែកជួយដល់ប្រជាជននៅក្នុងតំបន់ អង្គរដែលស្ម័គ្រចិត្តមករស់នៅភូមិធម្មជាតិរុនតាឯក ដើម្បីរួមចំណែកអភិរក្សតំបន់រមណីយដ្ឋានអង្គរ។ លោកក៏បានសម្តែង នូវសេចក្តីរីករាយដែលបានឃើញវត្តមានរបស់ប្រជាជនយ៉ាងច្រើនកុះករមកចូលរួមសំណេះសំណាលជាមួយ រួមទាំងកោត សរសើរចំពោះភាពរីកចម្រើនជាងពីមុនរបស់ភូមិក្រោមការដឹកនាំរបស់អាជ្ញាធរជាតិអប្សរា ដែលមានទាំងផ្នែកកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងភាពស្រស់ស្អាតនៃភូមិដ្ឋានរបស់ប្រជាជន។

ឯកឧត្តម ម៉ី ម៉ាឯឌី ទីប្រឹក្សាអាជ្ញាធរជាតិអប្សរានិងជាប្រធានគម្រោងភូមិធម្មជាតិរុនតាឯក បានសម្តែងនូវការអរគុណ ចំពោះទឹកចិត្ត សប្បុរសធម៌របស់ **លោក ម៉ែន អង្គារ៉ា** រួមទាំងកូនប្រុស និងមិត្តភក្តិលោក ដែលបាននាំយកគ្រាប់ពូជដំណាំ ល្អៗមកចែកជូនប្រជាជននៅទីនេះសម្រាប់ជាំជុះពង្រឹងជីវភាពគ្រួសារ រួមនឹងកេសជ្ជៈជាទឹកផ្លែឈើដើម្បីចែកជូនពិសាផង ដែរ។ ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមក៏បានជម្រាបពីប្រវត្តិនៃការកកើតភូមិធម្មជាតិរុនតាឯក ចំនួនប្រជាជន ការប្រកប របរដ៏សំខាន់របស់អ្នកភូមិ និងការកិច្ចរបស់អាជ្ញាធរជាតិអប្សរាចំពោះប្រជាជន និងធ្វើដំណើរទៅកាន់តំបន់ភូមិសាស្ត្រ ផ្សេងៗក្នុងភូមិផងដែរ៕





ក្នុងឆ្នាំ២០១៦កន្លងទៅនេះអាជ្ញាធរជាតិអប្សរាបានចែកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយនិងទារក ដល់ស្ត្រីទើបឆ្លងទន្លេចក្នុងតំបន់អង្គរជិត២ពាន់នាក់

ផ្សាយនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ ន.ផ្សព្វផ្សាយ

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា តែងតែចុះទៅតាមស្រុកគោលដៅរបស់ខ្លួនជារៀងរាល់សប្តាហ៍ ដើម្បីបង្ក្រាបចំណេះដឹងអំពីបេតិកភណ្ឌ ចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ ចុះផ្តល់សេវាកម្មនានាពាក់ព័ន្ធការសាងសង់ និងជួសជុលសំណង់ផ្សេងៗ ផ្តល់បច្ចេកទេសកសិកម្ម និងស្វែងយល់ពីតម្រូវការរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ឧទ្យានអង្គរ ព្រមទាំងលើកកម្ពស់សុខុមាលភាពស្ត្រីទើបឆ្លងទន្លេរួច។

ជាក់ស្តែងនៅក្នុងឆ្នាំ២០១៦ កន្លងទៅថ្មីៗនេះ **លោក អឿន សំអុន** អនុប្រធានក្រុមលេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានលើកឡើងថា អាជ្ញាធរជាតិអប្សរាបាននាំយកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកព្រមទាំងថវិកាមួយចំនួនទៅចែកជូនស្ត្រីទើបឆ្លងទន្លេរួចចំនួន១៨៩៩នាក់ ក្នុងបណ្តាស្រុកក្រុងទាំង៥ក្នុងខេត្តសៀមរាប រួមមានក្រុងសៀមរាប ស្រុកពួក ស្រុកប្រាសាទបាគង ស្រុកអង្គរធំ និងស្រុកបន្ទាយស្រី ។

លោកបន្តថា កញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកទាំងនោះ មានដូចជា កន្ត្រក បំពង់ទឹកក្តៅ កន្សែងពោះគោ កូនមុង ស្រោមដៃស្រោមជើង និងខោអាវទារកដែលជាអំណោយដ៏ថ្លៃថ្លារបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា និងលោកជំទាវ ។

អនុប្រធានរូបនេះបញ្ជាក់ថា រហូតមកដល់សព្វថ្ងៃប្រជាជនដែលរស់នៅក្នុងតំបន់អង្គរមានចំនួន២៩១៨គ្រួសារ ដែលមានចំនួនមនុស្សប្រហែល១២ម៉ឺនទៅ១៣ម៉ឺននាក់ ។ ប្រជាពលរដ្ឋទាំងអស់នេះតែងទទួលបានការយកចិត្តទុកដាក់ជាប្រចាំអំពីអាជ្ញាធរជាតិអប្សរា ជាពិសេសពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍សហគមន៍របស់ពួកគាត់។

ក្រៅពីចែកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារក ក្រុមការងារសហគមន៍ ក៏បានចុះពិនិត្យសំណើសុំការសាងសង់សំណង់តូចៗ និងបានអនុញ្ញាតជូនប្រជាពលរដ្ឋផ្ទាល់ដល់មូលដ្ឋានចំនួន៤៤៧គ្រួសារ និងចូលរួមឧបត្ថម្ភថវិកាមួយចំនួនជួយគ្រួសារដែលរងគ្រោះដោយឧបទ្ទវហេតុផ្សេងៗមានរន្ទះបាញ់ ខ្យល់កន្ត្រាក់រលំផ្ទះជាដើម ព្រមទាំងចូលរួមកិច្ចការងារសង្គមដទៃផងដែរ។

នេះជាការយកចិត្តទុកដាក់របស់អាជ្ញាធរជាតិអប្សរាចំពោះសុខទុក្ខ និងសុខុមាលភាពប្រជាពលរដ្ឋដើម្បី ផ្តល់ភាពកក់ក្តៅ និងជួយសម្រួលការលំបាកផ្សេងៗដល់ប្រជាពលរដ្ឋ ក៏ដូចជួយលើកកម្ពស់តម្លៃបេតិកភណ្ឌទុកសម្រាប់មនុស្សជាតិជំនាន់ក្រោយតទៅទៀត៕









លទ្ធផលនៃកំណាយបុរាណវិទ្យាបង្ហាញថាស្ពានហាលខាងលិចប្រាសាទអង្គរវត្តធ្លាប់បានជួសជុលនាសម័យបុរាណបន្ទាប់ពីកសាងរួច

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ាហ៊ីនី រូបភាព ៖ ហ៊ុំ វិទ្ធី

ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត បាននិងកំពុងចាប់ផ្តើមគម្រោងជួសជុលហើយ។ ដោយគោរពតាមអនុសាសន៍ពីគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា ICC-Angkor មុនដំណើរការជួសជុល គឺត្រូវធ្វើកំណាយស្រាវជ្រាវជាមុន ដើម្បីស្វែងយល់ពីទិន្នន័យបុរាណវិទ្យា ក៏ដូចជារចនាសម្ព័ន្ធរបស់ស្ពានហាលទាំងមូល។

ស្របតាមអនុសាសន៍នេះក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា សហការជាមួយសាកលវិទ្យាល័យស៊ូហ្វីយ៉ាបានធ្វើកំណាយស្រាវជ្រាវ និងសន្និដ្ឋានថា ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត បានស្រុត និងខូចខាតផ្នែកជញ្ជាំង ហើយក្រោយមកនៅសម័យក្រោយអង្គរ និងក្នុងសម័យបារាំងក៏ធ្លាប់បានជួសជុលមួយចំនួនដែរ។

លោក អន សុភាព មន្ត្រីបច្ចេកទេសផ្នែកបុរាណវិទ្យា ដែលបានដឹកនាំការងារធ្វើកំណាយនេះផ្តាល់បានឲ្យដឹងថា ក្រុមការងារបានបើករណ្តៅកំណាយចំនួន២កន្លែងផ្សេងគ្នានៅលើស្ពានហាល។ លទ្ធផលនៃកំណាយនេះ បានរកឃើញពីការវិវត្តលើការងារជួសជុលស្ពានហាលនេះដែលធ្លាប់បានធ្វើឡើងតាំងពីក្រោយអង្គរ។ ជារួម លទ្ធផលកំណាយ និងឯកសារដែលនៅសេសសល់ ក្រុមការងារបានរកឃើញថា ស្ពានហាលខាងលិចប្រាសាទអង្គរវត្តធ្លាប់បានជួសជុលចំនួន៤ដំណាក់កាលរួចមកហើយ។

ដំណាក់កាលទី១គឺ ការជួសជុលដែលធ្វើឡើងក្នុងសម័យក្រោយអង្គរ។ ដំណាក់កាលទី២ គឺដើមទសវត្សទី៥០ ដែលជួសជុលដោយបារាំង នៅចំហៀងខាងជើងផ្នែកខាងកើត ដែលពេលនោះ គឺការជួសជុលមានប្រើបេតុងច្រើន។ ដំណាក់ទី៣ គឺខាងដើមទសវត្សទី៦០ ដែលត្រូវបានជួសជុលដោយបារាំងដែរ នៅពាក់កណ្តាលផ្នែកខាងត្បូង។ ដំណាក់កាលទី៤ ពីឆ្នាំ១៩៩៦-២០០៧ ដែលជួសជុលដោយសាកលវិទ្យាល័យសូហ្វីយ៉ារួមនឹងអាជ្ញាធរជាតិអប្សរា ផ្នែកខាងជើងក្នុងដំណាក់កាលទី១។

ដោយឡែក គម្រោងជួសជុលដែលធ្វើឡើងដោយអាជ្ញាធរជាតិអប្សរាសហការជាមួយសាកលវិទ្យាល័យសូហ្វីយ៉ាបច្ចុប្បន្ននេះ គឺធ្វើឡើងទៅផ្នែកខាងជើងដំណាក់កាលទី២ដែលមានប្រវែង១០០ម៉ែត្រ។

តាមការបញ្ជាក់របស់ **លោក អន សុភាព** លទ្ធផលនៃកំណាយស្តានហាលក្នុងដំណើរការជួសជុលដំណាក់កាលទី២ ដែលមានការបើករណ្តៅកំណាយចំនួន២កន្លែង បានបង្ហាញថា ស្តានភាពស្តានហាលមានភាពច្របូលច្របល់ ដោយការជួសជុលក្នុងសម័យក្រោយអង្គរ មិនបានរៀបថ្ម ក៏ដូចជាការពង្រឹងគ្រឹះឲ្យបានត្រឹមត្រូវ គ្រាន់តែប្រមូលកំទេចកំទីដែលមានស្រាប់នៅទីនោះចាក់បំពេញតែប៉ុណ្ណោះ។ ចំណែកថ្មបាយក្រៀមមាន១១ស្រទាប់ ដែលជាជញ្ជាំងស្តានហាលនោះ ក៏រងការពុកផុយដោយសារអាយុកាលផងដែរ។ មានតែនៅស្រទាប់ទី៤ឡើងតែប៉ុណ្ណោះ តែស្តានភាពថ្មនៅល្អប្រសើរ។ នេះបើតាមការបញ្ជាក់របស់ **លោក អន សុភាព**។

លោក អន សុភាព ពន្យល់ទៀតថា៖« យើងបានយកលទ្ធផលនេះទៅប្រៀបធៀបទៅនឹងលទ្ធផលការងារជួសជុលក្នុងដំណាក់កាលទី១ គឺសាកលវិទ្យាល័យស៊ូហ្វីយ៉ា រកឃើញដូចគ្នា ថ្មបាយក្រៀមមានការពុកផុយស្នើរ១០០ភាគរយ ហើយការជួសជុលគឺត្រូវជំនួសដោយថ្មបាយក្រៀមថ្មីទាំងអស់តែម្តង»។ តាមរយៈលទ្ធផលកំណាយដែលទទួលបាននៅពេលនេះ ក្រុមការងារនឹងធ្វើរបាយការណ៍ដើម្បីដាក់ឆ្លងក្នុងកិច្ចប្រជុំ ICC-Angkor ដែលគ្រោងនឹងចាប់ផ្តើម នៅចុងខែមករា ឆ្នាំ២០១៧ នេះ។

គួរបញ្ជាក់ថា ក្រុមការងារនឹងរក្សារណ្តៅកំណាយសាកល្បង ដើម្បីរង់ចាំដល់ថ្ងៃកិច្ចប្រជុំ ICC-Angkor ។ ក្រុមការងារនឹងអញ្ជើញអ្នកជំនាញការ ICC-Angkor ទាំងអស់មកពិនិត្យមើលរណ្តៅកំណាយ ដើម្បីសុំយោបល់សម្រាប់ការងារជួសជុលទៅថ្ងៃអនាគត៕









សេចក្តីជូនដំណឹងស្តីពីការរៀបចំការដ្ឋានថ្មី និងផ្អាកការទស្សនារោងទងខាងក្រៅប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
N° ០៦៤ / អប.សជណ
១៧

សេចក្តីជូនដំណឹង
ស្តីពី
ការរៀបចំការដ្ឋានថ្មី និងផ្អាកការទស្សនារោងទងខាងក្រៅមួយផ្នែកនៃប្រាសាទបាយ័ន

អាជ្ញាធរអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរអប្សរា និងស្ថាប័ន JASA នៃប្រទេសជប៉ុន ក្នុងគម្រោងជួសជុល និងអភិរក្សប្រាសាទបាយ័ន ក្រុមការងារ JASA នឹងចាប់ផ្តើមដំណើរការរៀបចំបើកការដ្ឋានថ្មីដំណាក់កាលទី៥ នៅរោងទងខាងក្រៅប្រាសាទបាយ័នមួយផ្នែក។ ដើម្បីការពារសុវត្ថិភាព និងសណ្តាប់ធ្នាប់ដល់ភ្ញៀវទេសចរ ក្រុមការងារ JASA នឹងរៀបចំរបងការដ្ឋានថ្មីនេះ និងផ្អាកការទស្សនានៅរោងទងខាងក្រៅប្រាសាទបាយ័នមួយផ្នែក (ដូចមានប្លង់ជូនភ្ជាប់) ចាប់ពីខែមករា ឆ្នាំ២០១៧ រហូតដល់ចប់គម្រោងជួសជុល។

ឆ្លៀតឱកាសនេះ អាជ្ញាធរអប្សរាក៏សូមអធ្យាស្រ័យផងដែរ ពីសំណាក់សាធារណជន ក៏ដូចជាភ្ញៀវទេសចរទាំងអស់ ចំពោះការរំខានបន្តិចបន្តួច ដែលកើតចេញពីការដ្ឋាននេះ។

អាស្រ័យហេតុនេះ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័តិមាន។

ស្រៀមរាប ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧
អគ្គនាយកស្តីទី

សុខ សង្វារ

បម្លងជូន:
-សាលាខេត្តសៀមរាប
-សាលាក្រុងសៀមរាប
-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
-គ្រប់មន្ទីរពាក់ព័ន្ធ
«ដើម្បីជូនជ្រាប»
-គ្រប់នាយកដ្ឋាន-អង្គភាព «ដើម្បីជ្រាប និងមុខការ»
-ឯកសារ-កាលប្បវត្តិ

អាជ្ញាធរដើម្បីការពារមណ្ឌលអ្ឋានន៉ិងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
E-mail : info@apsaraauthority.gov.kh
PHNOM PENH :
#41, Russian Blvd,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 776
Fax : (855-23) 215 771
SIEM REAP :
Bang Korng Village, Ampil Commune, Siem Reap City, Siem Reap Province
Tel: (855-63) 76 55 77 or (855-63) 76 66 76
Fax: (855-63) 76 55 76


Safety Fence
NEW RESTORATION SITE OF JASA
Safety Fence
Safety Fence
Northern Pond
Southern Pond
T69
T70
T71
T52
T55
T56
T57
Main Entrance of Tourist
Entrance
Entrance
North
0 5 10 20M
Plan of Bayon Complex
New Circulation of Tourist
Drawing No.:
Scale: not to scale
Date: 01- December- 2016
Drawing Person: Soeur Sothy
Note: Tourist Circulation New Restoration Site
JAPAN-APSARA for Safeguarding Angkor (JASA)
JAPAN-APSARA Safeguarding Angkor
JASA Siem Reap

ស្ពានអណ្តែតទឹកបណ្តោះអាសន្ននៅប្រាសាទអង្គរវត្តនឹងបង្ហាញរូបរាងនាពេលឆាប់ៗនេះហើយ!

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ឹង ស្រីរ័ត្ន

ស្ពានអណ្តែតទឹកបណ្តោះអាសន្នធ្វើពីពោងជ័រ Polyethylene មានទីតាំងនៅក្នុងទឹកកសិន្ទខាងត្បូងស្ពានហាលប្រាសាទអង្គរវត្តនឹងដាក់ឱ្យដំណើរការប្រើប្រាស់មុនខែឧសភា ឆ្នាំ២០១៧នេះហើយ។ ស្ពាននេះសាងសង់ឡើងដើម្បីបង្វែរចរាចរណ៍និងរក្សាសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ-អន្តរជាតិពេលធ្វើដំណើរឆ្លងកាត់ទៅទស្សនាអង្គរវត្ត ខណៈស្ពានហាលអង្គរវត្តត្រូវបិទទាំងស្រុងដើម្បីទុកលទ្ធភាពឱ្យក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ាធ្វើការជួសជុលក្នុងគោលបំណងអភិរក្សស្ពានបុរាណនេះឱ្យបានល្អប្រសើរ។

លោក ហេង គឹមឡេង ប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យនៃអាជ្ញាធរជាតិអប្សរា បានប្រាប់ថា លក្ខណៈពិសេសរបស់ស្ពានអណ្តែតទឹកបណ្តោះអាសន្នគឺមានសុពលភាពប្រើការបានដល់ទៅ២០ឆ្នាំ មានកន្លែងឈរលេងចំនួន៦សម្រាប់ភ្ញៀវទេសចរឈរស្រូបយកខ្យល់អាកាសនិងថតរូបជាដើម ។ ចំណែកផ្ទៃពោងជ័រអណ្តែតទឹកសរុបគឺ ១៨៧៤ម៉ែត្រការ៉េ (បណ្តោយ១៩៧ម៉ែត្រxទទឹង១០ម៉ែត្រ) ដែលក្នុង១ម៉ែត្រការ៉េអាចទ្រទម្ងន់បានចំនួន២៧២គីឡូក្រាម ហើយបើសន្មត់មនុស្សម្នាក់មានទម្ងន់៨០គីឡូក្រាម ស្ពាននេះអាចទ្រមនុស្សសរុបចំនួន៦៣៧១នាក់ក្នុងពេលតែមួយ។ **លោក ហេង គឹមឡេង** បន្តទៀតថា ស្ពាននេះសិក្សាដោយអាជ្ញាធរជាតិអប្សរា ហើយទទួលខុសត្រូវសាងសង់ដោយក្រុមហ៊ុន កាំត្រង់ស៊ីប (KTS)។

លោក វង្ស ចាន់វិបុល ប្រធានការដ្ឋានសាងសង់ស្ពានអណ្តែតទឹករបស់ក្រុមហ៊ុនកាំត្រង់ស៊ីប បានប្រាប់ថា សម្ភារៈនិងអ្នកជំនាញបច្ចេកទេសក្នុងការធ្វើស្ពានគឺយកពីប្រទេសកាណាដាទាំងអស់។ លក្ខណៈពិសេសរបស់ពោងអណ្តែតទឹក គឺជាជ័រស្វិត ធន់ ហើយអាចទ្រទ្រង់នឹងអាកាសធាតុបានយ៉ាងល្អបំផុត មិនមានប្រតិកម្មនឹងពន្លឺថ្ងៃ ភ្លៀង និងធ្វើឱ្យទឹកប្រែពណ៌ ឬបង្កជាសារធាតុពុលផ្សេងៗដល់ទឹកឡើយ។ លើសពីនោះទៅទៀត ពោងជ័រ Polyethylene មានលក្ខណៈគ្រឹមដែលមិនធ្វើឱ្យរអិល ហើយពោងនីមួយៗមានខ្យល់នៅខាងក្នុង ពេលណាកម្តៅឡើងខ្លាំងធ្វើឱ្យឧស្ម័នក្នុងពោងសាយភាយមកក្រៅ ដែលអាចរក្សាទ្រង់ទ្រាយនិងសីតុណ្ហភាពក្នុងពោងឱ្យនៅដដែល។

លោក ចាន់វិបុល បន្ថែមទៀតថា ក្នុងការតំឡើងនិងតភ្ជាប់ពោងពីមួយទៅមួយដើម្បីធ្វើស្ពាន គឺអ្នកជំនាញនៃក្រុមហ៊ុនកាំត្រង់ស៊ីប និងអ្នកជំនាញផលិតស្ពានមកពីប្រទេសកាណា បានយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុតលើបច្ចេកទេស ដែលជានាបាននូវភាពមាំ សុវត្ថិភាពខ្ពស់មិនអាចរបូតចេញពីគ្នាឡើយ។ មកដល់ពេលនេះក្រុមការងារបានតភ្ជាប់ពោងជ័រអណ្តែតទឹករួមនឹងដាក់បង្កាន់ដៃស្ពានរួចរាល់ហើយ នៅសល់តែការភ្ជាប់ជណ្តើរឈើមកស្ពានលើទឹកតែប៉ុណ្ណោះ។ ក្នុងនោះដៃក្រុមការងារទាំងពីរ ក៏កំពុងសិក្សាពីវិធីសាស្ត្របន្ថែមទៀតក្នុងការទប់លំនឹងស្ពានកុំឱ្យយោលយោគ ឬរេចុះឡើងខណៈមានភ្ញៀវទេសចរឆ្លងកាត់ផងដែរ៕









វីដេអូ៖ ក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរអង្គរ ក្នុងលទ្ធផលការងាររយៈពេល៣ឆ្នាំ

ផ្សាយនៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហេង ប៊ុនឡាយ



អាជ្ញាធរជាតិអប្សរាចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

នៅព្រឹកថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០១៧ ក្រុមការងារសហគមន៍ទី៥ប្រចាំស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម ម៊ី ម៉ាឯ៉ឌី** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានក្រុម រួមនឹងមន្ត្រីបុគ្គលិកជាច្រើនរូបទៀត បានចុះសាកសួរសុខទុក្ខប្រជា

ពលរដ្ឋនៅភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាបដើម្បីបង្កើនភាពស្និទ្ធស្នាល និងរឹតចំណងសាមគ្គីភាព រវាងអាជ្ញាធរជាតិអប្សរា និងប្រជាពលរដ្ឋក្នុងការរួមគ្នាថែរក្សាការពារ និងអភិរក្សបេតិកភណ្ឌដ៏ល្អឯកទុកឲ្យកូនចៅជំនាន់ក្រោយបានស្គាល់ ។

ក្នុងឱកាសនោះ ក្រុមការងារបានសំណេះសំណាលជាមួយក្រុមប្រឹក្សាស្រុកឃុំ លោកមេភូមិ លោកអនុភូមិ និងបងប្អូនប្រជាពលរដ្ឋដែលបានមកចូលរួម ព្រមទាំងបាននាំនូវបណ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំរបស់អាជ្ញាធរជាតិអប្សរាដល់បងប្អូនទាំងអស់ក្នុងឃុំក៏ដូចជាប្រជាពលរដ្ឋទាំង១១២ភូមិក្នុងឧទ្យានអង្គរផងដែរ។

ក្រុមការងារបានបន្តរំឭកពីប្រវត្តិនៃការបង្កើតស្ថាប័នអាជ្ញាធរជាតិអប្សរា ក៏ដូចជាតួនាទីក្នុងការអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានអង្គរនាពេលកន្លងមក។ អាជ្ញាធរជាតិអប្សរាតែងប្រកាន់ភ្ជាប់នូវគោលការណ៍អភិរក្សដើម្បីអភិវឌ្ឍន៍ អភិវឌ្ឍន៍ដើម្បីអភិរក្សគឺធ្វើយ៉ាងណាឲ្យការអភិរក្សដើរទន្ទឹមគ្នានឹងការអភិវឌ្ឍ ហើយការអភិវឌ្ឍក៏ត្រូវដើរទន្ទឹមគ្នានឹងការអភិរក្សដែរ ។ អាជ្ញាធរជាតិអប្សរាមិនអាចគិតតែពីការងារអភិរក្សប្រាង្គប្រាសាទ ហើយភ្លេចការអភិវឌ្ឍជីវភាពប្រជាពលរដ្ឋក្នុងតំបន់អង្គរនោះទេ ។

ក្រុមការងារក៏បានស្នើសុំឲ្យប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់អង្គរ ត្រូវបន្តចូលរួម ការពារ និងថែរក្សា អភិរក្សឧទ្យានអង្គរ ដែលជាមរតកដ៏មានតម្លៃរបស់ជូនខ្មែរឲ្យបានគង់វង្សស្ថិតស្ថេរជាបន្តទៅទៀត។ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរាដោយសហការគ្នាជាមួយស្ថាប័នជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋ ទើបរមណីយដ្ឋានអង្គរមានភាពរីកចម្រើន ល្បីល្បាញក្នុងសកលលោកក្លាយជាគោលដៅទេសចរណ៍ និងបានទាក់ទាញភ្ញៀវទេសចរជាប់លាននាក់មកទស្សនារមណីយដ្ឋានប្រវត្តិសាស្ត្រមួយនេះជារៀងរាល់ឆ្នាំៗ។

សូមបញ្ជាក់ថាក្នុងឱកាសចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋនោះ ក្រុមការងារក៏នាំយកកញ្ចប់ទ្រទ្រង់សុខុមាលភាពមាតា និងទារកព្រមទាំងថវិកាមួយចំនួនទៀត ចែកជូនដល់ស្ត្រីទើបឆ្លងទន្លេរួចចំនួន១១គ្រួសារផងដែរ។ នេះ គឺជាការបង្ហាញនូវទឹកចិត្តក្នុងការយកចិត្តទុកដាក់ខ្ពស់របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ដែលមាន **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរាចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរ។









អ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរាបង្ហាញថាស្ពានអណ្តែតទឹកមានប្រើតាំងពីសម័យបុរាណមកម្ល៉េះ

ផ្សាយនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ លឹម ស្រ៊ូ

សំណង់ស្ពានអណ្តែតទឹក ដែលកំពុងសង់នៅតំបន់អង្គរក្នុងពេលបច្ចុប្បន្ននេះ ពុំមែនជាលើកដំបូងទេ។ តាមពិតទៅ តាមការស្រាវជ្រាវពីអ្នកជំនាញបុរាណវិទ្យា សំណង់ស្ពានស្រាល ឬស្ពានអណ្តែតលើទឹកនេះ មានតាំងពីសម័យបុរាណមកម្ល៉េះ គ្រាន់តែសម្ភារៈដែលយកមកសាងសង់ខុសគ្នាតាមទេសកាល និងប្រើបច្ចេកទេសមិនទំនើបដូចបច្ចុប្បន្នតែប៉ុណ្ណោះ។

វត្តមានស្ពានអណ្តែតទឹកនៅក្នុងកសិណខាងលិចអង្គរវត្ត បានទាក់ទាញចំណាប់អារម្មណ៍ភ្ញៀវទេសចរជាច្រើន។ តើជាការចៃដន្យដែរឬទេ ដែលស្ពានអណ្តែតទឹកនេះត្រូវបានស្ថាបនានៅក្នុងតំបន់បេតិកភណ្ឌពិភពលោក ដែលអ្វីៗទាមទារឲ្យមានការសិក្សាយ៉ាងច្បាស់លាស់ និងមិនប៉ះពាល់ដល់ទេសភាពវប្បធម៌?

ទម្រាំបានសាងសង់ស្ពានអណ្តែតទឹកនៅកសិណអង្គរ គឺមានការឆ្លងយោបល់ និងជជែកគ្នាយ៉ាងយូរពីអ្នកបច្ចេកទេសជាតិ និងអន្តរជាតិ។ ដោយយោងលើបុព្វហេតុដែលសម័យអង្គរធ្លាប់សង់ស្ពានអណ្តែតទឹកនេះដែរ ទើបគណៈកម្មាធិការអោយ ស៊ីស៊ី-អង្គរ (ICC-Angkor) បានគាំទ្រឲ្យមានការសង់ស្ពានអណ្តែតទឹកនេះឡើង។

សូមរម្លឹកថា ស្ពានអណ្តែតទឹកនៅប្រាសាទអង្គរវត្តត្រូវបានស្ថាបនាឡើង ក្នុងបំណងដើម្បីបញ្ចៀសចរាចរណ៍នៅលើស្ពានហាល ដែលគ្រោងបិទចរាចរមួយរយៈ ដើម្បីធ្វើការជួសជុល។ តាមគម្រោងស្ពានហាលនឹងធ្វើការជួសជុលរយៈពេល៤ឆ្នាំតទៅមុខ។

លោក អ៊ឹម សុខរិទ្ធី បុរាណវិទូ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ បានលើកឡើងថា តាមរយៈផ្នាំងគំនូរនៅប្រាសាទបន្ទាយឆ្មារ និងបាយ័ន ដែលបានបង្ហាញពីវត្តមានយ៉ាងច្បាស់ពីស្ពានអណ្តែតទឹក។ តាមរូបចម្លាក់នោះបង្ហាញថា ស្ពាននោះសង់ពីដើមឫស្សី ចងភ្ជាប់គ្នាជាបាច់ៗ ហើយក្រងប្រទាក់គ្នាជាជួរ ចងភ្ជាប់ជាមួយខ្សែពួរពីលើ និងពីខាងក្រោម រាយទទឹងទន្លេ ហើយប្រហែលមានក្រាលក្តារ ឬបន្ទះឫស្សីពីលើ ដែលអាចធ្វើចរាចរពីលើបានងាយស្រួល។

តាមចម្លាក់នោះទៀតសោត **លោក អ៊ឹម សុខរិទ្ធី** ពន្យល់ទៀតថា ស្ពានប្រភេទនេះប្រើដើម្បីចម្លងដំណើរឆ្លងកាត់របស់ទ័ពខ្មែរ ដែលយើងឃើញមានដំរី២ក្បាល និងទ័ពមួយក្រុមកំពុងចរាចរពីលើ ហើយនៅក្នុងទឹកមានហ្វូងមច្ឆាតូចធំ ក្រពើ និងសត្វទឹកមួយចំនួនទៀត ព្រមទាំងព្រៃឈើលិចទឹកតាមមាត់ច្រាំងផង ដែលតាមរយៈរូបភាពនេះបញ្ជាក់ថា ផ្លូវទឹកដែលសង់ស្ពានអណ្តែតទឹកនោះ មានទទឹងធំ ប្រហែលមានប្រវែងអាចនឹងវែងជាង១០០ម៉ែត្រ។

ចំណែកទម្ងន់ដែលផ្ទុកវិញ តាមរយៈរូបភាពនៃផ្ទាំងចម្លាក់នោះ យើងអាចគិតតាមទម្ងន់របស់ដំរី ដែលមួយក្បាលមានទម្ងន់ពី៧ទៅ១៥តោន ព្រមទាំងទ័ពមួយក្រុមទៀត នោះយើងប៉ាន់ស្មានបានថា ស្ពានអណ្តែតទឹកអាចទ្រទម្ងន់ប្រហែលពី២០តោនទៅ៣០តោន។ តើផ្លូវទឹកនោះនៅឯណា? ត្រង់នេះយើងមិនទាន់អាចកំណត់ទីតាំងច្បាស់នៅឡើយថា តើរូបភាពជាក់ស្តែងនៅលើជញ្ជាំងប្រាសាទបន្ទាយឆ្មារ និងបាយ័ន នៅកន្លែងណានៅឡើយ? អ្នកស្រាវជ្រាវបានឃើញមានទីតាំងខ្លះដែលផ្លូវបុរាណកាត់ទទឹងនឹងផ្លូវទឹកមួយចំនួនពុំមានស្លាកស្នាមស្ពានឬ មានស្នឹងធំៗ និងទន្លេមេគង្គជាដើម។

តាមប្រវត្តិនៃការសង់ស្ពានអណ្តែតនៅសម័យបុរាណ **លោក អ៊ឹម សុខរិទ្ធី** បានពន្យល់ថា ស្ពានប្រភេទនេះជាធម្មតាមានមុនកំណើតមុនស្ពានឬ។ តាមការសិក្សាស្រាវជ្រាវជាង១០ឆ្នាំមកនេះ បានប្រទះឃើញមានស្ពានឬដែលសាងអំពីឬកក់ ឬបាយក្រៀម ឬសាងរួមគ្នារវាងឬបាយក្រៀម និងឬកក់ ចំនួនជាង១០០។ ស្ពានឬដែលចាស់ជាងគេ បានសាងឡើងយ៉ាងហោចណាស់ចាប់ពីសតវត្សទី១០មក។ រីឯស្ពានឬបុរាណ ដែលបានសាងឡើងចុងក្រោយគេនៅអង្គរ បានស្ថាបនាឡើងនៅចុងសតវត្សទី១៧។ ទិន្នន័យនេះមានន័យថា ទោះជាអារ្យធម៌អង្គរបានធ្លាក់ចុះហើយក៏ដោយ ក៏ការស្ថាបនាស្ពានឬនៅតែមានមនុស្សមានចំណេះ និងមានលទ្ធភាពកសាងបន្ត៕









អាជ្ញាធរជាតិអប្សរាពង្រឹងចំណេះដឹងបេតិកភណ្ឌដល់ឆ្មាំកម្មករតាមមូលដ្ឋាន

ផ្សាយនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

នៅរសៀលថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា ប្រមាណ៨៩រូប ដែលធ្វើការផ្ទាល់នៅតាមមូលដ្ឋានទទួលបានចំណេះដឹងស្តីពីបេតិកភណ្ឌ។ ពិធីនេះប្រារព្ធធ្វើឡើងនៅសាលាស្រុកអង្គរធំ ខេត្តសៀមរាប ក្រោមអធិបតីភាព **ឯកឧត្តម ហាច់ ពៅ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និងជាប្រធានក្រុមការងារសហគមន៍ប្រចាំស្រុកអង្គរធំ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ដើម្បីពង្រឹងសមត្ថភាព និងបង្កើនការយល់ដឹងបន្ថែមទៀតអំពីកិច្ចថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌ។

ថ្លែងក្នុងឱកាសនោះ **ឯកឧត្តម ហាច់ ពៅ** បានលើកឡើងថា បន្ទាប់ពីអង្គរត្រូវបានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅទីក្រុងសាន់តាហ្វេ សហរដ្ឋអាមេរិកនាខែធ្នូ ឆ្នាំ១៩៩២ អង្គរមានការផ្លាស់ប្តូរយ៉ាងខ្លាំង ពោលគឺប្រាង្គប្រាសាទជាច្រើនត្រូវបានអភិរក្សជួសជុល ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបានល្អប្រសើរ ដែលធ្វើឲ្យមានកំណើនទេសចរជារៀងរាល់ឆ្នាំ។ ភាពផ្លាស់ប្តូរនេះ កើតឡើងដោយសារកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរាដោយសហការជាមួយស្ថាប័នជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋក្នុងតំបន់។

ឯកឧត្តមបញ្ជាក់ថា ការទទួលបានលទ្ធផលល្អប្រសើរបែបនេះគឺវាកើតឡើង ដោយការខិតខំប្រឹងប្រែង និងលះបង់ទាំងកម្លាំងកាយចិត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌ ជាពិសេស មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាតែម្តង។ ដូច្នេះ ដើម្បីឲ្យលទ្ធផលនេះនៅតែបន្តល្អប្រសើរទៅទៀត មន្ត្រីបុគ្គលិកគ្រប់រូប មិនត្រឹមតែអនុវត្តដោយខ្លួនឯងប៉ុណ្ណោះ តែត្រូវបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់អង្គរ ក៏ដូចក្រៅតំបន់អង្គរ ដើម្បីឲ្យពួកគាត់បានយល់ និងចូលរួមថែរក្សា ការពារ និង អភិរក្សបេតិកភណ្ឌ ដែលជាមរតកដ៏មានតម្លៃរបស់ជូនតាខ្មែរឲ្យបានគង់វង្សស្ថិតស្ថេរដល់កូនចៅជំនាន់ក្រោយទៀត៕









អ្នកជំនាញការជាន់ខ្ពស់អន្តរជាតិផ្នែកបេតិកភណ្ឌរបស់អាយស៊ីស៊ី-អង្គរចុះពិនិត្យការដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ុំ រិទ្ធី , ជុន ប៊ុនថុន

គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor) នឹងចាប់ដំណើរការកិច្ចប្រជុំបច្ចេកទេសលើកទី២៧ និងពេញអង្គលើកទី២៣របស់ខ្លួននាព្រឹកថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ខាងមុខនេះហើយ នៅសាលសន្និសីទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

កិច្ចប្រជុំនេះមានអ្នកជំនាញជាតិ-អន្តរជាតិជាច្រើនប្រទេសចូលរួម ព្រមទាំងពិភាក្សាជាសំខាន់លើបញ្ហាផ្សេងៗទាក់ទងនឹងកិច្ចការអភិរក្សនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានអង្គរប្រកបដោយចីរភាព។ តាមទម្លាប់ មុនពេលចាប់ផ្តើមបើកកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ អ្នកជំនាញការជាន់ខ្ពស់ ADHOC ផ្នែកអភិរក្ស និងផ្នែកអភិវឌ្ឍន៍របស់អាយស៊ីស៊ី-អង្គរ តែងតែចុះទៅពិនិត្យនៅតាមការដ្ឋានជួសជុល និងមើលការងារស្រាវជ្រាវផ្សេងៗនៅក្នុងតំបន់រមណីយដ្ឋានអង្គរមុនជាប្រចាំ ដើម្បីវាយតម្លៃ ណែនាំ និងពិនិត្យមើលការអនុវត្តនោះតើត្រឹមត្រូវ និងអនុលោមតាមអនុសាសន៍ដែលបានផ្តល់ឱ្យកន្លងមកដែរឬទេ?

ជាក់ស្តែងចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ អ្នកជំនាញការជាន់ខ្ពស់អន្តរជាតិផ្នែកបេតិកភណ្ឌ បានចុះទៅពិនិត្យមើលការដ្ឋានដែលកំពុងដំណើរនៅក្នុងតំបន់អង្គរទាំងផ្នែកជួសជុល ទល់ទ្រ និងការដ្ឋានស្រាវជ្រាវមួយចំនួន ព្រមទាំងបានស្តាប់បទបង្ហាញពីអ្នកជំនាញ រួមទាំងថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាដែលពាក់ព័ន្ធក្នុងកិច្ចការទាំងនេះផងដែរ។ ចំណែកនៅថ្ងៃទី២២ ដល់២៣ ខែមករា ឆ្នាំ២០១៧ ក្រុមអ្នកជំនាញការ ADHOC ទាំងពីរផ្នែកនឹងសរសេររបាយការណ៍បច្ចេកទេសដាក់ជូនអង្គប្រជុំអាយស៊ីស៊ី-អង្គរ ដើម្បីពិនិត្យ សម្រេច និងផ្តល់យោបល់ដល់អ្នកទទួលខុសត្រូវតាមការដ្ឋាននានារបស់ខ្លួនអនុវត្តការងារបន្តប្រកបដោយលក្ខណៈបច្ចេកទេស ជានាបាននូវស៊ុវត្ថិភាពរបស់បេតិកភណ្ឌទាំងអស់។

គួរឲ្យកត់ផងដែរថា គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor) តែងតែបើកអង្គប្រជុំរបស់ខ្លួន២ដងក្នុង១ឆ្នាំ ដើម្បីពិនិត្យមើលការដ្ឋានជួសជុល បូកសរុបលទ្ធផលការងារ ផ្តល់អនុសាសន៍ និងតាមដានការផ្តល់អនុសាសន៍ដែលអង្គប្រជុំផ្តល់ឱ្យដល់ស្ថាប័នអាជ្ញាធរជាតិអប្សរា ដើម្បីអនុវត្តផែនការរៀបចំ គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានអង្គរប្រកបដោយចីរភាព៕


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh

សេចក្តីជូនដំណឹងស្តីអំពីការបើកកំណាយស្រាវជ្រាវស្ថានីយស្លដែកបុរាណនៅក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N°. ០៤៩/ស.ជ.ត.អប្ស
១៧

សេចក្តីជូនដំណឹង
ស្តីអំពី
ការបើកកំណាយស្រាវជ្រាវស្ថានីយស្លដែកបុរាណនៅក្នុងតំបន់អង្គរ

កាលពីចុងឆ្នាំ២០១៥ ក្រុមស្រាវជ្រាវផ្លូវបុរាណនៃអាជ្ញាធរជាតិអប្សរា បានប្រទះឃើញស្ថានីយស្លដែកបុរាណមួយនៅ ភូមិសាលាក្រវ៉ាន់ ឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាបដែលស្ថិតក្នុងតំបន់ការពារទី២នៃរមណីយដ្ឋានអង្គរ។ នេះជាស្ថានីយលោហកម្មបុរាណដែលប្រទះឃើញមុនគេបង្អស់នៅក្នុងតំបន់អង្គរ។

ក្រុមស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា ដែលមានបទពិសោធន៍ស្រាវជ្រាវលើវិស័យឧស្សាហកម្មបុរាណជាង១០ឆ្នាំមកហើយ បានប្រើវិធីសាស្ត្រជាតិពន្ធុវិទ្យានិងបុរាណវិទ្យា សិក្សាស្រាវជ្រាវលើស្ថានីយនេះលើកទី១ នៅដើមឆ្នាំ២០១៦ បានរកឃើញស្លាកស្នាមទីតាំងចង្ក្រានស្លដែក សំណល់រ៉ែដែក បំណែកភាជន៍ គំនរអាចមន៍ដែកដែលកប់ក្រោមដី និងបំណែកបំពង់ខ្យល់ជាដើម។ ជាសេចក្តីសន្និដ្ឋាន ស្ថានីយនេះជាស្ថានីយផលិតលោហៈបុរាណដែលប្រទះឃើញដំបូងបង្អស់នៅក្នុងតំបន់អង្គរអស់រយៈពេល១៥០ឆ្នាំចុងក្រោយ បន្ទាប់ពីមានការស្រាវជ្រាវអំពីអង្គរ។

ក្រុមស្រាវជ្រាវអាជ្ញាធរជាតិអប្សរានឹងបើកកំណាយស្រាវជ្រាវលើកទី២ ចាប់ពីថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១៧ តទៅ ចំនួន១០ថ្ងៃ ដើម្បីសិក្សាអំពីវិសាលភាពនៃទីតាំងផលិតលោហៈ ព្រមទាំងពិនិត្យមើលរចនាសម្ព័ន្ធនៃចង្ក្រានស្លដែក ក្នុងគោលបំណងបង្ហាញអំពីសារៈសំខាន់និងតម្រូវការលោហៈដែលបានប្រើប្រាស់នៅរាជធានីអង្គរ ព្រមទាំងពិចារណាឡើងវិញអំពីប្រភពផ្គត់ផ្គង់លោហៈដល់អង្គរ ដែលកន្លងមកអ្នកស្រាវជ្រាវធ្លាប់គិតថាលោហៈបាននាំចូលមកពីតំបន់ផ្សេង។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមស្តាប់ព័ន៌ពាក់ព័ន្ធ អ្នកស្រាវជ្រាវជាតិ-អន្តរជាតិ និងសារធារណជនទាំងអស់មេត្តាជ្រាបជាដំណឹង។

សៀមរាប ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧
អគ្គនាយក

ស៊ុំ ម៉ាប់

ចម្លងជូន
- -សាលាខេត្តសៀមរាប
- -សាលាស្រុកបន្ទាយស្រី
- -ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- -អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- -អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
- -សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ប្រចាំខេត្តសៀមរាប
- -គ្រប់មន្ទីរពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប និងសហការ"
- -គ្រប់នាយកដ្ឋាន-អង្គភាព "ដើម្បីជូនជ្រាបនិងមុខការ"
- -ឯកសារកាលប្បវត្តិ

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពារមណ្ឌលនិងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

អគ្គនាយកអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញការជាន់ខ្ពស់បេតិកភណ្ឌនៃ ICC-Angkor ចុះពិនិត្យការដ្ឋានកំណាយនៅ ស្ពានហាលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ុំ រិទ្ធី

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមនឹងអ្នកជំនាញការជាន់ខ្ពស់ផ្នែកបេតិកភណ្ឌ ព្រមទាំងអ្នកជំនាញជាតិ-អន្តរជាតិរបស់ស្ថាប័នពាក់ព័ន្ធជាច្រើននាក់ បានអញ្ជើញចុះទៅពិនិត្យមើលការដ្ឋានកំណាយស្ពានហាលប្រាសាទអង្គរវត្តនាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧។

ក្នុងដំណើរចុះទស្សនកិច្ចថ្ងៃនេះដែរ អ្នកជំនាញអាជ្ញាធរជាតិអប្សរាបានធ្វើបទបង្ហាញពីការធ្វើកំណាយ និងលទ្ធផលដែលទទួលបានពីការកំណាយដើម្បីចែកជូនដល់គណៈប្រតិភូជាន់ខ្ពស់ស្តាប់ ព្រមទាំងទទួលយកនូវការផ្តល់យោបល់កែលម្អពីអ្នកជំនាញវិញផងដែរ។

ជាធម្មតា មុននឹងដំណើរការកិច្ចប្រជុំបច្ចេកទេសឬកិច្ចប្រជុំពេញអង្គរបស់ខ្លួន គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor) តែងតែឱ្យអ្នកជំនាញការជាន់ខ្ពស់ផ្នែកបេតិកភណ្ឌចុះបំពេញបេសកម្មរបស់ខ្លួនដោយផ្ទាល់នៅតាមការដ្ឋានកំពុងជួសជុល និងការដ្ឋានថ្មីដែលត្រៀមនឹងជួសជុល។ ក្នុងការចុះត្រួតពិនិត្យនេះ គឺផ្តោតលើគោលការណ៍សំខាន់៣ គឺផ្លាស់ប្តូរយោបល់បច្ចេកទេសអំពីការជួសជុល សម្ភារៈដែលយកមកធ្វើការជួសជុល និងចំណុចដែលត្រូវជួសជុល ដើម្បីឱ្យអ្នកជំនាញការបានស្វែងយល់ដោយផ្ទាល់ ហើយនឹងធ្វើការពិភាក្សា ផ្តល់យោបល់ តើការអនុវត្តកន្លងមកអនុលោម ឬមិនអនុលោមទៅតាមការឱ្យអនុសាសន៍ពីកិច្ចប្រជុំកាលពីលើកមុន។

គួរឱ្យកត់ផងដែរថា រាល់ការងារជួសជុលគឺទាមទារជាចាំបាច់ត្រូវតែស្របទៅតាមអនុសាសន៍ របស់គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ ដើម្បីធានាបាននូវនិរន្តភាពនៃបេតិកភណ្ឌ ដោយមិនអាចធ្វេសប្រហែលនៅលើចំណុចណាមួយបានឡើយ។ ចំពោះលទ្ធផលដែលទទួលបានពីការចុះទៅពិនិត្យការដ្ឋានកំណាយនៅស្ពានហាលនេះដែរ នឹងយកទៅពិភាក្សាគ្នាបន្តនៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី២៧ និងពេញអង្គលើកទី២៣ នាព្រឹកថ្ងៃទី២៤ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ខាងមុខនេះនៅសាលសន្និសីទអង្គរ នៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា៕









អាជ្ញាធរជាតិអប្សរាផ្តល់សង្កសីជូនស្ត្រីមេម៉ាយចាស់ជរាទីទ័លក្រម្នាក់នៅស្រុកបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

នៅព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧នេះ ក្រុមការងារសហគមន៍ទី៥ប្រចាំស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ាន់ឌី** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរានិងជាប្រធានក្រុម រួមនឹងមន្ត្រីបុគ្គលិកជាច្រើនរូបទៀត បាននាំយកសង្កសីចំនួន ២០សន្លឹកទៅប្រគល់ជូនស្ត្រីមេម៉ាយចាស់ជរាទីទ័លក្រម្នាក់ នៅភូមិតាត្រែ ឃុំប្រជាក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។

ឯកឧត្តម ម៉ី ម៉ាន់ឌី បានមានប្រសាសន៍ថាដោយមើលឃើញ**លោកយាយ ជួប អុល** រស់នៅតែពីរនាក់កូនស្រី មានជីវភាពក្រលំបាក ដំបូលផ្ទះឆ្លុះឆ្លាយ ទ្រុឌទ្រោម រស់នៅហាលភ្លៀង ហាលក្តៅ ហាលខ្យល់ គ្មានលទ្ធភាពទិញសង្កសីយកមកដំបូលផ្ទះបាន ។ ឯកឧត្តមបានស្នើសុំទៅថ្នាក់ដឹកនាំខាងលើ ដើម្បីឲ្យជួយសង្កសីដល់លោកយាយ។ ថ្នាក់ដឹកនាំខាងលើលោកក៏បានឯកភាព ទើបនៅព្រឹកថ្ងៃទី២០នេះ ក្រុមការងារបាននាំយកសង្កសីមកប្រគល់ជូនលោកយាយតែម្តង ដោយមានការអញ្ជើញចូលរួមពីអាជ្ញាធរមូលដ្ឋានផងដែរ។

លោកយាយ ជួប អុល ដែលមានវ័យជាង៧០ឆ្នាំប្លាយ បានសម្តែងនូវចិត្តសប្បាយរីករាយ និងអរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា ជាពិសេស **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** និងលោកជំទាវដែលតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋ និងសូមជូនពរឲ្យឯកឧត្តមមន្ត្រីបុគ្គលិកទាំងអស់ជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងសម្រេចជោគជ័យគ្រប់ភារកិច្ច៕









អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសម្មភាពជួសជុលកំណាត់ផ្លូវរង់តូច ពីខាងកើតកសិន្នុអង្គរទៅដល់ស្រះស្រង់ ដើម្បីដោះស្រាយការហុយរំខានការធ្វើដំណើរ

ផ្សាយនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីរ័ត្ន រូបភាព ៖ ហ៊ុំ រិទ្ធី

កំណាត់ផ្លូវរង់តូចចាប់ពីខាងកើតកសិន្នុអង្គរវត្ត ដល់ខាងកើតស្រះស្រង់ប្រវែង៣៧៥៨ម៉ែត្រ ដែលរងនូវការខូចខាតដោយអន្លើរ ត្រូវបានជួសជុលឡើងវិញទាំងស្រុងដោយអាជ្ញាធរជាតិអប្សរា តាមការគ្រោងទុកផ្លូវនេះនឹងរួចរាល់ទាំងស្រុងនៅដើមខែកុម្ភៈ ឆ្នាំ២០១៧នេះហើយ។

តាមការបញ្ជាក់របស់**លោក ហេង គឹមឡេង** ប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ បានឱ្យដឹងថា៖ គម្រោងកែលម្អផ្លូវរង់តូចពីខាងកើតកសិន្នុអង្គរទៅដល់ខាងកើតស្រះស្រង់ គឺត្រូវបញ្ចប់ត្រឹមចំណុចខាងត្បូងស្រះស្រង់សិន។ ពីមុនផ្លូវនេះមានទទឹងពី៥ម៉ែត្រទៅ៦ម៉ែត្រ តែពេលនេះយើងបានកែលម្អឱ្យមានទទឹងសរុប៩ម៉ែត្រ ដូចផ្លូវពីមុខអង្គរវត្តទៅក្លោងទ្វារទន្លេអុំដែរ។ លោកបន្តទៀតថា៖ ក្នុងការកែលម្អផ្លូវនេះ គឺត្រូវពង្រីកគ្រឹះរងជាប្រភេទក្រួសក្រហមកម្រាស់២០សង់ទីម៉ែត្រសងខាងឱ្យបានទទឹង៩ម៉ែត្រ បន្ទាប់មកក្រាលគ្រឹះចម្បងពីល្បាយថ្មកម្រាស់១៥សង់ទីម៉ែត្រលើផ្ទៃផ្លូវទាំងមូលដែលមានទទឹង៩ម៉ែត្រនោះ។ ជំហានបន្ត គឺក្រាលកម្រាលប្រភេទ DBST ៦ម៉ែត្រនៅកណ្តាល និង ១.៥ម៉ែត្រអមសងខាងជាប្រភេទ SBST។ បន្ថែមពីនោះ ក៏មានផ្លូវរាងដើមឈើមួយចំនួនដើម្បីរក្សាការពារដើមឈើទាំងនោះទៀតផង។

ជាការកត់សម្គាល់ក្នុងកំឡុងពេលនៃការជួសជុលនេះ ក៏បានបង្កការហុយរំខានខ្លះៗដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋក៏ដូចជាភ្ញៀវទេសចរដែលទស្សនាតំបន់ឧទ្យានអង្គរ។ ម្យ៉ាងទៀតស្ថានភាពផ្លូវនៅពេលនេះគឺកំពុងចាក់កៅស៊ូ និងរោយកម្ទេចថ្មតាមលក្ខណៈបច្ចេកទេស ដែលចៀសមិនផុតពីការហុយជីដោយអន្លើក្នុងមួយរយៈពេលខ្លី។

ត្រង់ចំណុចនេះអ្នកជំនាញបានពន្យល់ថា ក្នុងរយៈពេលនៃការចាក់បំពេញកៅស៊ូភ្លាមៗយើងមិនអាចឱ្យប៉ះទឹកបានទេ រហូតដល់កៅស៊ូឡើងជ្រាបស្មើសាច់ល្អទើបអាចប៉ះទឹកបាន។ ដូចនេះ ក្នុងនាមស្ថាប័នជំនាញ អាជ្ញាធរជាតិអប្សរាសូមការអធ្យាស្រ័យ និងការយោគយល់ពីបងប្អូនប្រជាពលរដ្ឋ ក៏ដូចជាពីសំណាក់ភ្ញៀវទេសចរទាំងអស់ ដែលបានមកទស្សនាតំបន់រមណីយដ្ឋានអង្គរ ចំពោះផលលំបាកតិចតួចដែលបង្កឡើងពីការស្ថាបនាផ្លូវនេះ។ ម្យ៉ាងទៀតក្នុងពេលឆាប់ៗបន្ទាប់ពីចាក់កៅស៊ូរួចរាល់ទាំងស្រុង ផ្លូវនេះនឹងបាត់ហុយ ហើយក្លាយជាផ្លូវមួយដ៏ល្អសម្រាប់ការធ្វើដំណើរ ងាយស្រួលក្នុងការទស្សនាប្រាង្គប្រាសាទប្រកបដោយផាសុកភាព៕









ថ្នាក់ដឹកនាំអាយស៊ីស៊ីអង្គរជួបពិភាក្សាដើម្បីកំណត់ទិសដៅសម្រាប់កិច្ចប្រជុំអន្តរជាតិស្តីពីអង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ថ្នាក់ដឹកនាំសំខាន់ៗនៃអាយស៊ីស៊ីអង្គរ រួមមាន អាជ្ញាធរជាតិអប្សរា តំណាងអង្គការយូណេស្កូ និងសហប្រធានអាយស៊ីស៊ី-អង្គរ ទាំងពីរគឺប្រទេសបារាំងនិងជប៉ុន បានជួបពិភាក្សាគ្នានៅព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ នាទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

ជំនួបចតុកាគីនេះ តែងតែប្រព្រឹត្តទៅនៅរៀងរាល់មុនកិច្ចប្រជុំពេញអង្គ និងកិច្ចប្រជុំបច្ចេកទេសនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដើម្បីកំណត់ទិសដៅ របៀបវារៈ ប្រធានបទ ជាពិសេសដើម្បីពិនិត្យវាយតម្លៃពីប្រសិទ្ធភាព ទៅលើអនុសាសន៍ដែលធ្លាប់ផ្តល់ដោយអ្នកជំនាញការជាន់ខ្ពស់កន្លងមក។

ជំនួបពិភាក្សានេះដែរ ក៏តែងតែពិនិត្យទៅលើសំណើនៃគម្រោងថ្មីៗក្នុងតំបន់អង្គរ ដែលនឹងត្រូវដាក់ជូនអង្គប្រជុំអាយស៊ីស៊ី-អង្គរនាពេលខាងមុខ ដើម្បីវាយតម្លៃពីស្ថានភាពទូទៅនៃគម្រោងផ្សេងៗថា តើគួរចាត់បញ្ចូលក្នុងរបៀបវារៈ នៃកិច្ចប្រជុំដែរឬទេ?

កិច្ចប្រជុំអាយស៊ីស៊ីអង្គរ គឺជាកិច្ចប្រជុំដ៏សំខាន់បំផុតនៃការងារអភិរក្សនិងអភិវឌ្ឍន៍តំបន់បេតិកភណ្ឌពិភពលោកអង្គរ។ ដូច្នេះហើយ មុននឹងសម្រេចប្រធានបទ ឬរបៀបវារៈនៃកិច្ចប្រជុំនេះ ភាគីទាំង៤ដែលជាថ្នាក់ដឹកនាំកិច្ចប្រជុំអាយស៊ីស៊ី-អង្គរតែងជួបពិភាក្សាគ្នាយ៉ាងមធ្យ័ត៣ទៅ៤ដងមុននឹងកិច្ចប្រជុំចូលមកដល់។

សូមបញ្ជាក់ថា គណៈកម្មាធិការអាយស៊ីស៊ីអង្គរនឹងរៀបចំកិច្ចប្រជុំបច្ចេកទេសលើកទី២៧ និងកិច្ចប្រជុំពេញអង្គលើក២៣ នៅថ្ងៃទី២៤-២៥ ខែមករា ឆ្នាំ២០១៧ខាងមុខនេះ។ កិច្ចប្រជុំនេះនឹងប្រារព្ធឡើងក្រោមអធិបតីភាពសហប្រធានទាំងពីរ គឺឯកឧត្តមឯកអគ្គរដ្ឋទូតប្រទេសបារាំង និងឯកឧត្តមឯកអគ្គរដ្ឋទូតប្រទេសជប៉ុន និងប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា៕









ឯកឧត្តម សុខ សង្ហារ និងអ្នកជំនាញការអាយស៊ីស៊ី-អង្គរ ចុះពិនិត្យការងារមួយចំនួននៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ សឿន ប៊ុនសិរ

នៅព្រឹកថ្ងៃទី២៣ មករា ឆ្នាំ២០១៧នេះ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករង ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរនៃអាជ្ញាធរអប្សរា បានដឹកនាំក្រុមការងារ និងអ្នកជំនាញការ អាយស៊ីស៊ី-អង្គរ ចុះពិនិត្យការងារមួយចំនួនក្នុងរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ។ ក្នុងនោះអ្នកជំនាញការ អាយស៊ីស៊ី-អង្គរ បានថ្លែងនូវការកោតសរសើរ និងគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នានា ដែលបាននិងកំពុងដំណើរការក្នុងរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ។

ក្នុងដំណើរទស្សនកិច្ចរយៈពេលពេញមួយព្រឹក អ្នកជំនាញការ អាយស៊ីស៊ី-អង្គរ បានចុះទៅពិនិត្យមើលការងារមួយចំនួន ដូចជានៅរង្វង់មូលចំបក់កំណប់ ការដ្ឋានស្តានអណ្តែតទឹក ភ្នំបាខែង និងខ្លោងទ្វារទន្លេអ៊ុំជាដើម។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងអាជ្ញាធរអប្សរា បានឲ្យដឹងថា អ្នកជំនាញការ អាយស៊ីស៊ី-អង្គរ បានកោតសរសើរ ចំពោះការងារកែសម្រួល ជួសជុល និងរៀបចំឡើងវិញរង្វង់មូលចំបក់កំណប់។ ការកែសម្រួលរង្វង់មូលនេះ គឺទទួលបាន ការពេញចិត្តពីអ្នកជំនាញការ អាយស៊ីស៊ី-អង្គរ និងជំរុញឲ្យគម្រោងនេះ ដំណើរការឲ្យបានឆាប់រហ័សផងដែរ។

ក្រៅពីនេះ អ្នកជំនាញការ អាយស៊ីស៊ី-អង្គរ ក៏បានទៅពិនិត្យមើលការដ្ឋានស្ពានអណ្តែតទឹកផងដែរ។ នៅទីនោះ អ្នកជំ នាញការមានការពេញចិត្ត និងអះអាងថា គម្រោងនេះដំណើរការទៅតាមគម្រោងដែលបានឆ្លងទៅកិច្ចប្រជុំ អាយស៊ីស៊ី-អង្គរ នាពេលកន្លងមក។ ក្នុងទីតាំងនេះ **ឯកឧត្តម សុខ សង្ហារ** ក៏បានបង្ហាញដល់អ្នកជំនាញការទាំងអស់ អំពីគុណភាព របស់ស្ពានអណ្តែតទឹកនេះ។ តាមការបញ្ជាក់របស់ឯកឧត្តម ស្ពាននេះអាចធានាសុវត្ថិភាពខ្ពស់ដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ហើយក៏មានភ្នាក់ងារទេសចរណ៍ប្រចាំការដោយយកចិត្តទុកដាក់ខ្ពស់ ពេលស្ពាននេះដំណើរការផងដែរ។

បន្ទាប់ពីចុះទៅរង្វង់មូលចំបក់កំណប់ ស្ពានអណ្តែតទឹក អ្នកជំនាញការក៏បានបន្តទៅត្រួតពិនិត្យគម្រោងការងារ មួយចំនួន នៅភ្នំបាខែងផងដែរ។ នៅទីនោះ **ឯកឧត្តម សុខ សង្ហារ** បានលើកឡើងពីបំណងចង់បំពាក់អគ្គិសនីបំភ្លឺតាមផ្លូវឡើងទៅ លើភ្នំបាខែង។ ឯកឧត្តមបានពន្យល់ថា វាមានការលំបាកណាស់ នៅពេលភ្ញៀវចុះពីលើភ្នំបាខែង ក្រោយពេលមើលថ្ងៃលិច គឺវាមានសភាពងងឹតខ្លាំង។ ត្រង់ចំណុចនេះ ឯកឧត្តមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា និងពិនិត្យលើលទ្ធភាពមួយចំនួននៃ ការប្រើប្រាស់ប្រព័ន្ធអគ្គិសនីណាមួយ ដែលយកទៅបំពាក់នៅទីនោះ។

ចំណុចមួយទៀតនៅភ្នំបាខែងនេះ អ្នកជំនាញការអាយស៊ីស៊ី-អង្គរ ក៏បានចុះពិនិត្យជាក់ស្តែងអំពីបញ្ហាទីតាំងចំណតយាន យន្តផងដែរ។ កន្លងមក នៅទីនេះមានការលំបាកដោយគ្មានចំណតត្រឹមត្រូវ។ ក្រុមការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍ទេស ចរណ៍នឹងរៀបចំលើបញ្ហានេះ ក៏ដូចជាបែងចែកឲ្យបានត្រឹមត្រូវចំពោះតូចលក់ដូរ និងចំណតយានយន្ត។

ចុងបញ្ចប់នៃដំណើរទស្សនកិច្ចនៃអ្នកជំនាញការអាយស៊ីស៊ី-អង្គរ គឺនៅខ្លោងទ្វារទន្លេអុំ។ បញ្ហាចំបងនៅទីនោះ គឺចន្លោះ ប្រហោងរវាងរូបចម្លាក់កូរសមុទ្រទឹកដោះ។ ចំណុចនេះធ្វើឲ្យមានភ្ញៀវទេសចរខ្លះភ្លេចខ្លួនចូលទៅឈរនៅចន្លោះនោះដើម្បី ផ្តិតរូបភាព និងជាកន្លែងដែលក្មេងៗនៅតំបន់អង្គរមួយចំនួន មកលោតទឹកកម្សាន្ត ដែលធ្វើឲ្យប៉ះពាល់ដល់សម្បត្តិបេតិក-កណ្ឌជាតិ និងអាចមានគ្រោះថ្នាក់ផ្សេងៗ។ ត្រង់ចំណុចនេះដែរ អាជ្ញាធរជាតិអប្សរា មានគម្រោងដាក់រនាំងតូចៗការពារ ត្រង់ចំណុចប្រហោងនោះ។ នេះជាមធ្យោបាយ ដែលអាជ្ញាធរជាតិអប្សរាគ្រោងនឹងរៀបចំដាក់សំណើរទៅក្នុងកិច្ចប្រជុំ អាយស៊ីស៊ី-អង្គរ។

គួរម្លឹកថា កិច្ចប្រជុំគណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ គ្រោងនឹងរៀបចំរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២៤-២៥ ខែមករា ឆ្នាំ២០១៧ នៅស្នាក់ការអាជ្ញាធរជាតិអប្សរា៕









អាជ្ញាធរជាតិអប្សរានិងស្ថាប័នអភិរក្សប្រាសាទមកពីប្រទេសចិន ជួបពិភាក្សាគ្នាអំពីលទ្ធភាពអនុវត្តគម្រោងអភិរក្សនាពេលអនាគត

ផ្សាយនៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

កិច្ចពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ និងការអភិរក្សជួសជុលប្រាសាទនាពេលអនាគត ត្រូវបានលើកយកមកពិភាក្សាក្នុងជំនួបរវាងអាជ្ញាធរជាតិអប្សរា និងស្ថាប័នរដ្ឋាភិបាលចិនសម្រាប់ការអភិរក្សអង្គរហៅកាត់ថា CSA នារសៀលថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

ជំនួបពិភាក្សានេះធ្វើឡើងក្រោមអធិបតីភាព**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាម៉ៈ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និង**លោក Chai Xiaoming** អគ្គនាយកនៃបណ្ឌិតសភាចិនសម្រាប់បេតិកភណ្ឌវប្បធម៌ ដោយមានការចូលរួមពីអ្នកជំនាញជាច្រើនរូបទៀត។

ប្រធានបទសំខាន់ៗនៃកិច្ចពិភាក្សានេះ បានផ្តោតទៅលើការជួសជុលប្រាសាទភិមានអាកាសជាគម្រោង អនាគតបន្ទាប់គម្រោងជួសជុលប្រាសាទតាកែវបានបញ្ចប់។ ក្នុងនោះដែរ ភាគីទាំងពីរក៏បានពិភាក្សាអំពីលទ្ធភាពនៃការបង្កើតកម្មវិធីបណ្តុះបណ្តាលផ្នែកអភិរក្សបន្ថែមទៀតជូនដល់មន្ត្រីនៃអាជ្ញាធរជាតិអប្សរា។

ពាក់ព័ន្ធនឹងលទ្ធភាពជួសជុលប្រាសាទបេងមាលានាពេលអនាគត ភាគីទាំងពីរឯកភាពនឹងធ្វើការសិក្សាបឋមរួមគ្នាមួយ ដើម្បីធ្វើជារបាយការណ៍បច្ចេកទេសជូនថ្នាក់ដឹកនាំមុននឹងឈានដល់ការសម្រេចដើម្បីធ្វើការជួសជុល។

លោក Chai Xiaoming បានលើកឡើងថា ការពិចារណាលើគម្រោងជួសជុលប្រាសាទបេងមាលា គឺធ្វើឡើងដោយរក្សាទង់ទ្រាយដើមនៃប្រាសាទ ក្នុងន័យលើកតម្លៃបេតិកភណ្ឌ មិនមែនផ្តោតតែលើការជួសជុលទាំងស្រុងនោះឡើយ។ មិនតែប៉ុណ្ណោះ ក្រុមការងាររបស់លោកមិនពិចារណាត្រឹមតែអ្នកជំនាញខាងជួសជុលប្រាសាទទេ តែត្រូវមានអ្នកជំនាញផ្នែកជួសជុលក្បាច់ចម្លាក់ និងបរិស្ថានដែរ។ ដូច្នេះ ក្រុមការងារចាំបាច់ត្រូវការសិក្សាលម្អិតអំពីបច្ចេកទេស មុនឈានដល់ការកំណត់ចំណុចដែលត្រូវជួសជុលដំបូងណាមួយ។

សូមបញ្ជាក់ថា ស្ថាប័ន CSA គ្រោងនឹងបញ្ចប់ការងារជួសជុលប្រាសាទតាកែវនៅចុងឆ្នាំ២០១៧ខាងមុខ ក្រោយពីបញ្ចប់ការងារជួសជុលប្រាសាទចៅសាយទេវតាពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០០៨។ ដូច្នេះហើយ ទើបអាជ្ញាធរជាតិអប្សរាកំពុងស្នើសុំរដ្ឋាភិបាលចិនដើម្បីឲ្យស្ថាប័ន CSA ជួយជួសជុលប្រាសាទបេងមាលាជាបន្តទៀត។ អាជ្ញាធរជាតិអប្សរាសង្ឃឹមថាកិច្ចពិភាក្សានេះនឹងកាន់តែចេញផ្លែផ្កា ស្របពេលដែលកិច្ចប្រជុំអាយស៊ីស៊ីអង្គរនាថ្ងៃទី២៤ ខែមករានេះ ក៏នឹងមានវត្តមាន **លោក Lui Shuguang** អនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ចិនអញ្ជើញចូលរួមផងដែរ៕









កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ បានដំណើរការហើយនៅព្រឹកនេះ

ផ្សាយនៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ាហ៊ីនី រូបភាព ៖ ហ៊ុំ រិទ្ធី

កិច្ចប្រជុំគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor) ដែលជាកិច្ចប្រជុំបច្ចេកទេសលើកទី២៧ និងកិច្ចប្រជុំពេញអង្គលើកទី២៣ បានចាប់ផ្តើមដំណើរការហើយនៅព្រឹកថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧នេះ។ កិច្ចប្រជុំនេះ នឹងដំណើរការរយៈពេលពេញ២ថ្ងៃ គឺចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ ដែលធ្វើឡើងនៅស្នាក់ការអាជ្ញាធរជាតិអប្សរា។

នៅព្រឹកថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧នេះ កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ បានដំណើរការហើយ ដែលកិច្ចប្រជុំនេះ ដឹកនាំដោយសហប្រធានរួមមានប្រទេសជប៉ុន និងប្រទេសបារាំង។

អ្នកចូលរួមក្នុងកិច្ចប្រជុំនេះ មានតំណាងមកពីបណ្តាស្ថានទូត អ្នកជំនាញការ មន្ត្រី បុគ្គលិកបច្ចេកទេសនានា ដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌។ ក្នុងពិធីបើកនៅព្រឹកនេះ គឺមានការធ្វើបទបង្ហាញខ្លីៗ ពីគម្រោងអភិរក្ស និងជួសជុលនានា ដែលកំពុងដំណើរការក្នុងតំបន់រមណីយដ្ឋានអង្គរ។

គួរបញ្ជាក់ដែរថា កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ គឺជាទូទៅធ្វើឡើងដើម្បីបូកសរុបពីលទ្ធផលការងារដែលបានអភិរក្ស និងជួសជុលក្នុងរមណីដ្ឋានអង្គរនាពេលកន្លងមក។ ក្នុងនោះដែរ កិច្ចប្រជុំនេះក៏ដើម្បីពិនិត្យ និងតាមដានរាល់អនុសាសន៍នានា ដែលគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ បានដាក់ជូនក្នុងកិច្ចប្រជុំរបស់ខ្លួននាពេលកន្លងមក៕









ICC-Angkor គោរពវិញ្ញាណក្ខន្ធចំពោះមរណភាពឯកឧត្តម ឃួន ឃុនឆាយ

ផ្សាយនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ាហ៊ីនី រូបភាព ៖ លឹម ស្រ៊ូ , ហ៊ុំ រឹទ្ធី

ក្នុងពិធីបើកកិច្ចប្រជុំពេញអង្គរ ICC-Angkor លើកទី២៣ នៅព្រឹកថ្ងៃទី២៥ មករា ឆ្នាំ២០១៧នេះ សហប្រធានដឹកនាំកិច្ចប្រជុំ បានប្រកាសពីមរណភាពរបស់ **ឯកឧត្តម ឃួន ឃុនឆាយ** អតីតអគ្គនាយករងអាជ្ញាធរជាតិអប្សរា។ ឯកឧត្តម បានទទួលមរណភាពដោយរោគាពាធកាលពីរាត្រីថ្ងៃទី២៤ មករា នៅប្រទេសកាណាដា។

អង្គប្រជុំ ICC-Angkor បានសម្តែងនូវសេចក្តីអាឡោះអាល័យចំពោះ**ឯកឧត្តម ឃួន ឃុនឆាយ** ដែលធ្លាប់ជាអតីតក្រុមការងារដ៏សកម្មក្នុងកិច្ចការអង្គរនាពេលកន្លងមក។ អង្គប្រជុំក៏បានធ្វើពិធីស្មឹងស្មាធ៍ដើម្បីសម្តែងការគោរពវិញ្ញាណក្ខន្ធរបស់**ឯកឧត្តម ឃួន ឃុនឆាយ**។

គំរូវីរៈភាព និងស្នាដៃរបស់ **ឯកឧត្តម ឃួន ឃុនឆាយ** ដែលបានរួមចំណែកក្នុងកិច្ចការអង្គរ ក៏ដូចជាការងារសង្គមផ្សេងៗទៀត គឺជាការចងចាំដែលមិនអាចបំភ្លេចបានចំពោះគុណតម្លៃដ៏ធំធេងចំពោះជាតិ និងមាតុភូមិ។

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រី បុគ្គលិក ឆ្មាំ កម្មករទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវការសោកស្តាយ និងគោរពវិញ្ញាណក្ខន្ធចំពោះ**ឯកឧត្តម ឃួន ឃុនឆាយ** និងសូមឲ្យវិញ្ញាណក្ខន្ធឯកឧត្តម បានសោយសុខក្នុងដ្ឋានសុគតិភព។

ឯកឧត្តម ឃួន ឃុនឆាយ ក៏ត្រូវបានគេស្គាល់ថាជាស្ថាបត្យករ និងនគរូបនីយកម្មដ៏ល្បីម្នាក់ដែរ។ ឯកឧត្តមទទួលបានសញ្ញាបត្រអនុបណ្ឌិត ផ្នែកស្ថាបត្យកម្មនៅសាកលវិទ្យាល័យ Kiev ប្រទេសអ៊ុយក្រែន នៅឆ្នាំ១៩៦៦ អនុបណ្ឌិតផ្នែកច្បាប់នៅទីក្រុងភ្នំពេញឆ្នាំ ១៩៧២ ផ្នែកគម្រោងអភិវឌ្ឍន៍ពីទីក្រុងឡុងដ៍នាឆ្នាំ ១៩៧២ និងផ្នែកវិទ្យាសាស្ត្រនយោបាយនៅឆ្នាំ១៩៨៧ ពីប្រទេសកាណាដា។

នៅចន្លោះឆ្នាំ១៩៦៦ដល់ឆ្នាំ១៩៧១ **ឯកឧត្តម ឃួន ឃុនឆាយ** ក៏ជាស្ថាបត្យការនៅការិយាល័យស្ថាបត្យកម្មឯកជនរបស់**លោក វណ្ណ ម៉ូលីវណ្ណ**។ នៅសម័យសង្គ្រាមឆ្នាំ១៩៧៧ ឯកឧត្តមបានចាកចេញពីប្រទេសកម្ពុជា និងត្រឡប់មកប្រទេសវិញនៅឆ្នាំ២០០៤ ដោយចូលបម្រើការងារនៅអាជ្ញាធរអប្សរា។ ចាប់តាំងពីឆ្នាំ២០០៨មក ឯកឧត្តមបានក្លាយជាអគ្គនាយករងអាជ្ញាធរអប្សរា ទទួលបន្ទុកនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ៕









កំពែងអង្គរធំដែលជួសជុលដោយអ្នកជំនាញអប្សរាទទួលបានការសាទរគាំទ្រពីអ្នកជំនាញអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ ហ៊ុំ រីទ្ធី

កំពែងអង្គរធំ ត្រូវបានជួសជុលដោយអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា។ គម្រោងនេះ បានដំណើរការជួសជុលរួចជាស្ថាពរបានប្រវែង៨៣ម៉ែត្រ រួចហើយ។ គម្រោងមួយនេះសោត ត្រូវបានសាទរ និងកោតសរសើរពីសំណាក់អ្នកជំនាញនៃគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor)។

លោក លី វណ្ណា ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ នៃអាជ្ញាធរជាតិអប្សរា បានបញ្ជាក់ប្រាប់ក្នុងឱកាសនៃកិច្ចប្រជុំ ICC-Angkor ថា របាយការណ៍បច្ចេកទេសអំពីលទ្ធផលនៃការងារជួសជុលកំពែងអង្គរធំ ត្រូវបានដាក់ជូនអ្នកជំនាញក្នុងកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ ដែលកំពុងដំណើរការនៅស្នាក់ការអាជ្ញាធរជាតិអប្សរា។ តាមការបញ្ជាក់របស់ **លោក វណ្ណា** អ្នកជំនាញការអាយស៊ីស៊ី-អង្គរ បានសាទរ និងគាំទ្រពីសមិទ្ធផល ដែលក្រុមការងារបស់លោកបានសម្រេចបានពីការជួសជុលកំពែងអង្គរធំនេះ។

កំពែងអង្គរធំ ត្រូវបានជួសជុលរួលរាល់ជាស្ថាពរបានចំនួន ៨៣ម៉ែត្រ ដោយប្រើពេល២ឆ្នាំកន្លះ។ ការជួសជុលនេះគឺប្រើប្រាស់កម្លាំងពលកម្មមនុស្សផ្ទាល់ បូករួមទាំងសម្ភារជួសជុលបែបបុរាណផងដែរ។ **លោក វណ្ណា** ពន្យល់ថា ការជួសជុលនេះ គឺក្រុមការងារបានប្រើប្រាស់សម្ភារបុរាណដែលមានស្រាប់តាមរយៈការបង្ហាប់ដី ទប់ដីកុំឲ្យច្រោះឬហូរ ក៏ដូចជាបង្កើតទីជម្រាលកុំឲ្យហូរច្រោះដីនៅលើជញ្ជាំងជាដើម។

ក្នុងដំណើរការជួសជុលនេះដែរ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ បានគោរពទៅតាមអនុសាសន៍របស់អាយស៊ីស៊ី-អង្គរ ដែល**លោក វណ្ណា** បញ្ជាក់ថា មាន១៥ចំណុច។ ហើយដំណើរការនេះទៀតសោត ក៏ស្ថិតក្រោមការតាមដានពីអ្នកជំនាញការអាយស៊ីស៊ី-អង្គរដោយយកចិត្តទុកដាក់ផងដែរ។

កំពែងអង្គរធំមានប្រវែងសរុប១២គីឡូម៉ែត្រ ក្នុងមួយជ្រុងមានប្រវែង៣គីឡូម៉ែត្រ។ កំពែងនេះមានកម្ពស់ចន្លោះ៦ម៉ែត្រទៅជាង៦ម៉ែត្រ ទៅតាមទីតាំងផ្សេងៗគ្នា គឺកន្លែងខ្លះមានជញ្ជាំងថ្មបាយក្រៀមពី១៩ ទៅ២០ស្រទាប់។

គម្រោងជួសជុលកំពែងអង្គរធំមិនទាន់រួចរាល់នោះទេ។ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ បានដាក់សំណើមួយចំនួនទៅកាន់អ្នកពាក់ព័ន្ធ ដើម្បីស្នើសុំបន្តគម្រោងជួសជុលនេះជាបន្តបន្ទាប់ទៀត៕


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh

សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៧នៃគណៈកម្មការអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ *អត្ថបទ ៖ សែន សែត*

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N°ចត្ត/នប.សសក
១៧

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៧នៃគណៈកម្មការអាយស៊ីស៊ីអង្គរ

កិច្ចប្រជុំបច្ចេកទេសលើកទី២៧នៃគណៈកម្មការអន្តរជាតិសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ីអង្គរ ដែលមានសមាជិកអចិន្ត្រៃយ៍តំណាងប្រទេសបារាំង ប្រទេសជប៉ុន អាជ្ញាធរជាតិអប្សរា និងអង្គការយូណេស្កូ បានដំណើរការនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ក្រោមអធិបតីភាពសហប្រធានទាំងពីរគឺ ប្រទេសបារាំង និងប្រទេសជប៉ុន ដោយមានការចូលរួមពីសំណាក់លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់ អគ្គនាយកអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញជាតិ-អន្តរជាតិជាច្រើនកុះករ។

លទ្ធផលនៃកិច្ចប្រជុំមានដូចតទៅ៖

១. សហប្រធានតំណាងប្រទេសបារាំង បានធ្វើការកត់សម្គាល់ជាវិជ្ជមានអំពីសារៈសំខាន់ និងលទ្ធផលនៃកិច្ចប្រជុំគណៈកម្មការអាយស៊ីស៊ីអង្គរ ដោយសង្កត់ធ្ងន់ថា ក្នុងកិច្ចខិតខំប្រឹងប្រែងនៃការងារអភិរក្សរយៈ២៥ឆ្នាំរបស់អាជ្ញាធរជាតិអប្សរា រមណីយដ្ឋានអង្គរកាន់តែមានភាពល្អប្រសើរ ហើយប្រាង្គប្រាសាទនានាបានចេញឆ្ងាយពីភាពប្រឈមនឹងគ្រោះថ្នាក់។

២. តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា បានសម្តែងនូវការអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានសម្រេចចុះបញ្ជីចាប៊ីដងវែងជាសម្បត្តិបេតិកភណ្ឌពិភពលោកអូរបី និងការដែលរាជរដ្ឋាភិបាលកម្ពុជានាឆ្នាំ២០១៦ ទទួលហាន:ជាប្រធានគណៈកម្មការអន្តរដ្ឋាភិបាលសម្របសម្រួលកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្នុងជម្លោះប្រដាប់អាវុធ។

៣. អង្គប្រជុំទាំងមូលបានធ្វើការកត់សម្គាល់នូវលទ្ធផលជាវិជ្ជមានអំពីកំណើននៃធនធានរបស់អ្នកជំនាញខ្មែរក្នុងកិច្ចការអភិរក្សបេតិកភណ្ឌ។ ជាពិសេស ក្នុងពេលបច្ចុប្បន្ន ការងារអភិរក្សជួសជុលប្រាសាទមួយចំនួនធំ កំពុងដំណើរការទាំងការដឹកនាំ និងអនុវត្តផ្ទាល់ដោយអ្នកជំនាញខ្មែរ។

៤.អង្គប្រជុំបានបន្តតាមដាននូវអនុសាសន៍របស់អ្នកជំនាញការជាន់ខ្ពស់ផ្នែកបុរាណវិទ្យា និងផ្នែកអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅតាមការដ្ឋានជួសជុលនានា សំដៅលើកកម្ពស់ភាពអនុលោមនៃអនុសាសន៍របស់អង្គប្រជុំបច្ចេកទេសលើកទី២៦។

អាជ្ញាធរដើម្បីការពារមណ្ឌលនិងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh
SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

៥. អំពីការជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្តជំហានទី២ អង្គប្រជុំបានធ្វើការពិភាក្សានិងផ្លាស់ប្តូរយោបល់ ដោយសម្រេចជ្រើសរើសយកវិធីសាស្ត្រសមស្របដើម្បីជួសជុល។ ដោយឡែក អង្គប្រជុំក៏បានសម្តែងនូវការពេញចិត្តចំពោះការសាងសង់ស្ពានអណ្តែតទឹកបណ្តោះអាសន្ននៅខាងត្បូងស្ពានហាល ដោយសារស្ពាននេះមិនមានការប៉ះពាល់ណាមួយដល់ផ្នែកបុរាណវិទ្យា និងធានាសុវត្ថិភាពទាំងស្រុងដល់ភ្ញៀវទេសចរក្នុងការធ្វើដំណើរ។

៦. អង្គប្រជុំបានសម្តែងនូវការពេញចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរាក្នុងការរៀបចំនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានាសំដៅលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ឱ្យកាន់តែល្អប្រសើរ ជាពិសេសការគិតគូរហ្មត់ចត់អំពីលំហូរទេសចរឱ្យកាន់តែមានភាពងាយស្រួលនិងសុវត្ថិភាព។

៧. អង្គប្រជុំបានជម្រុញឲ្យភ្ញៀវទេសចរបន្តគោរពយ៉ាងម៉ត់ចត់នូវក្រមប្រតិបត្តិអង្គរជាពិសេសជៀសវាងដាច់ខាតនូវសកម្មភាពដែលបង្កការប៉ះពាល់ដល់អង្គរ។

៨. អង្គប្រជុំបន្តការយកចិត្តទុកដាក់ទៅលើការវិវត្តនៃការសឹករេចរឹលនូវរូបចម្លាក់មួយចំនួននៅតាមហោជាង និងតាមកំពូលប្រាង្គនៃប្រាសាទអង្គរវត្ត ព្រោះអាយុកាលថ្មនិងអាកាសធាតុបានក្លាយជាកត្តាចំបងក្នុងការសឹករេចរឹល។ អ្នកជំនាញជាតិនិងអន្តរជាតិកំពុងរិះរកមធ្យោបាយបច្ចេកទេសសមស្របដើម្បីទប់ស្កាត់ការសឹករិចរិលនេះ។

៩. អង្គប្រជុំបានស្តាប់និងពិភាក្សាអំពីប្រធានបទមួយចំនួនផ្សេងទៀតពាក់ព័ន្ធនឹងសកម្មភាពអភិរក្ស ស្រាវជ្រាវ និងបុរាណវិទ្យា ដែលក្នុងនោះមាន លទ្ធផលនៃការជួសជុលកំពែងអង្គរធំ ការជួសជុលបណ្ណាល័យខាងជើងនៃប្រាសាទព្រះខ័ន របាយការណ៍បឋមស្តីពីការស្រាវជ្រាវនិងជួសជុលប្រាង្គខាងជើងនៃប្រាសាទតុប កិច្ចការអភិរក្សនិងជួសជុលនៅប្រាសាទតាកែវ កំណាយស្រាវជ្រាវអំពីឡដុតលិតលោហៈសម័យបុរាណនៅតំបន់អង្គរ ការជួសជុលនៅប្រាសាទតាព្រហ្មក្នុងជំហានទី៣ គម្រោងសាកល្បងលើការប្រើប្រាស់ទឹកអនាម័យនិងសំណល់រឹង និងការបង្កើតផែនការមេស្តីពីអាងស្ទឹងសៀមរាប។ល។

សៀមរាប, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧

អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរាចូលរួមរំលែកមរណទុក្ខជាមួយក្រុមគ្រួសារនៃសព ឯកឧត្តម យួន យុននាយ

ផ្សាយនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីវត្ថ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ០៦៣/ អប.ទសច
១៧

លិខិតចូលរួមមរណទុក្ខ

ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ឆ្មាំ កម្មករនៃអាជ្ញាធរជាតិអប្សរាទាំងអស់ សូមសម្តែងនូវសេចក្តីទុក្ខយ៉ាងក្រៀមក្រំបំផុត ជាមួយក្រុមគ្រួសារនៃសព **ឯកឧត្តម យួន យុននាយ** អតីតអគ្គនាយករងអាជ្ញាធរជាតិអប្សរា ដែលបានទទួលមរណភាពដោយរោគាពាធក្នុងអាយុ៧៩ឆ្នាំ កាលពីរាត្រីម៉ោង៨.១៥នាទីយប់ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ នៅប្រទេសកាណាដា។

ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ឆ្មាំ កម្មករទាំងអស់នៃអាជ្ញាធរជាតិអប្សរា ពិតជាមានការសោកស្តាយយ៉ាងខ្លាំងចំពោះការបាត់បង់នូវថ្នាក់ដឹកនាំដ៏គួរឱ្យគោរព និងមានស្នាដៃមួយរូបដែលធ្លាប់បានលះបង់កម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតី ដើម្បីបំពេញតួនាទីយ៉ាងល្អក្នុងការងារអភិរក្ស និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានអង្គរឱ្យទទួលបាននូវកេរ្តឹ៍ឈ្មោះយ៉ាងល្បីរន្ទឺជាបន្តបន្ទាប់ក្នុងរយៈកាលកន្លងមក។

ការលាចាករបស់ឯកឧត្តមពីយើងខ្ញុំទាំងអស់គ្នា គឺជាការបាត់បង់នូវធនធានមនុស្សយ៉ាងសំខាន់ និងគួរឱ្យសោកស្តាយក្រៃលែង។ អាជ្ញាធរជាតិអប្សរានឹងចងចាំក្នុងក្រអៅបេះដូងនូវគំរូវីរភាព និងការលះបង់ដ៏ធំធេងរបស់ឯកឧត្តមក្នុងវិស័យវប្បធម៌ និងបេតិកភណ្ឌជាតិដែលឯកឧត្តមបានបន្សល់ទុកដល់ប្រជាជាតិខ្មែរ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ឆ្មាំ កម្មករទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព និងសូមបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់ឯកឧត្តមបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សៀមរាប, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧

អគ្គនាយក

សុំ ម៉ាប់

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពារនិងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

ការជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត រួមចំណែកបណ្តុះបណ្តាលធនធានមនុស្ស លើវិស័យបេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីវ័ត្ន រូបភាព ៖ ហ៊ុំ រិទ្ធី

ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត បាននិងកំពុងចាប់ផ្តើមគម្រោងជួសជុលហើយ ដោយគោរពតាមអនុសាសន៍ពីគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា ICC-Angkor។ មុនដំណើរការជួសជុលស្ពានបុរាណមួយនេះ គឺត្រូវធ្វើកំណាយស្រាវជ្រាវជាមុន ដើម្បីស្វែងយល់ពីទិន្នន័យបុរាណវិទ្យា ក៏ដូចជារចនាសម្ព័ន្ធរបស់ស្ពានហាលទាំងមូល ចៀសវាងហានិភ័យផ្សេងៗ ដែលបង្កគ្រោះថ្នាក់ដល់បេតិក-ភណ្ឌទាំងផ្នែកសោភ័ណភាព និងបុរាណវិទ្យា។

លោក Satoru MIWA អ្នកជំនាញនៃសាកលវិទ្យាល័យសូហ្វីយ៉ាប្រចាំការដ្ឋានជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត បានថ្លែងក្នុងឱកាសកិច្ចប្រជុំបច្ចេកទេសលើកទី២៧នៃ ICC-Angkor ថា ក្នុងការជួសជុលយើងព្យាយាមធ្វើយ៉ាងណាដើម្បីរក្សាភាពដើមនៃស្ពានឱ្យបានច្រើនបំផុត។ ដោយឡែកចំពោះថ្មដែលពុកផុយប្រើការលែងកើត យើងបានយកថ្មថ្មីមកជំនួស ឯថ្មដែលនៅប្រើបាន យើងនឹងរក្សាទុកដដែល ដើម្បីរក្សាភាពដើមនៃរចនាសម្ព័ន្ធសំណង់មិនឱ្យប្រែប្រួល។

ជាពិសេសជាងនេះទៅទៀត គម្រោងជួសជុលនេះក៏បានផ្តោតយ៉ាងសំខាន់លើការបណ្តុះបណ្តាលធនធានមនុស្សផងដែរ ដូចជាកម្មករកាត់ថ្ម បុគ្គលិកជំនាញ អ្នកបុរាណវិទ្យា ស្ថាបត្យករនៃអាជ្ញាធរជាតិអប្សរា ដើម្បីឱ្យពួកគាត់មានជំនាញច្បាស់លាស់ និងបច្ចេកទេសខ្ពស់ក្នុងការបំពេញការងារ។ លុះបញ្ចប់ពីការងារនេះទៅ ពួកគាត់នឹងអាចធ្វើការងារផ្សេងដោយខ្លួនឯងបាន។ មួយវិញទៀត យើងក៏បានគិតគូរជាចម្បងដល់សុវត្ថិភាពសម្រាប់អ្នកធ្វើការជួសជុល កម្មករ អ្នកជំនាញដែលធ្វើការផ្ទាល់នៅក្នុងការដ្ឋាន និងសុវត្ថិភាពរបស់ភ្ញៀវទេសចរទៀតផង។

គួរបញ្ជាក់ដែរថា ការជួសជុលស្ពានហាលនេះឡើងវិញ ក្នុងគោលបំណងធំដើម្បីអភិរក្ស ព្រោះតាមរយៈកំណាយស្រាវជ្រាវអ្នកជំនាញរកឃើញថា ស្ពានហាលខាងលិចប្រាសាទអង្គរវត្តបានស្រុត និងខូចខាតផ្នែកជញ្ជាំងដោយសារថ្មបាយក្រៀមរងនូវការពុកផុយ ដែលចាំបាច់ត្រូវមានការជួសជុលជាបន្ទាន់ដើម្បីកាត់បន្ថយការទ្រុឌទ្រោមកាន់តែធ្ងន់ធ្ងរ។ ដំណើរការជួសជុលស្ពាននេះ ទទួលខុសត្រូវដោយក្រុមការងារអាជ្ញាធរជាតិអប្សរាសហការជាមួយសាកលវិទ្យាល័យសូហ្វីយ៉ា។ ក្នុងដំណាក់កាលជួសជុលនេះដែរ គឺទាមទារជាចាំបាច់នូវអ្នកជំនាញសិក្សាលម្អិតអំពីទីតាំង សម្ភារៈជួសជុល និងវិធីសាស្ត្រជួសជុលដើម្បីរក្សាឱ្យបាននូវលក្ខណៈដើមទាំងស្រុង៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងក្រុមការងារគ្រប់លំដាប់ថ្នាក់ប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធឯកឧត្តម ឃួន ឃុននាយ

ផ្សាយនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧ *អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន* *រូបភាព ៖ ហ៊ុំ រិទ្ធី , យឿន តាក់*

នាព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរាបានរៀបចំប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធសព **ឯកឧត្តម ឃួន ឃុននាយ** អតីតអគ្គនាយករងអាជ្ញាធរជាតិអប្សរា ដែលបានទទួលមរណភាពកាលពីរាត្រី ម៉ោង៨.១៥នាទីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ក្នុងអាយុ៧៩ឆ្នាំ ដោយរោគាពាធនៅប្រទេសកាណាដា។

ពិធីនេះដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមទាំងមន្ត្រីរាជការ បុគ្គលិក ឆ្មាំ កម្មករ នៃអាជ្ញាធរជាតិអប្សរាទាំងអស់ចូលរួមសម្តែងនូវសេចក្តីទុក្ខក្រៀមក្រំជាមួយនឹងគ្រួសារនៃសពពីចម្ងាយ។ យើងខ្ញុំទាំងអស់គ្នាពិតជាមានការសោកស្តាយយ៉ាងខ្លាំងចំពោះការបាត់បង់នូវថ្នាក់ដឹកនាំ ដ៏គួរឱ្យគោរពនិងមានស្នាដៃមួយរូប ដែលធ្លាប់បានលះបង់កម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតី ដើម្បីបំពេញតួនាទីយ៉ាងល្អក្នុងការងារអភិរក្ស និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានអង្គរឱ្យទទួលបាននូវកេរ្តិ៍ឈ្មោះយ៉ាងល្បីរន្ទឺជាបន្តបន្ទាប់ក្នុងរយៈកាលកន្លងមក។

ការលាចាករបស់ឯកឧត្តមពីយើងខ្ញុំទាំងអស់គ្នា គឺជាការបាត់បង់នូវធនធានមនុស្សយ៉ាងសំខាន់ និងគួរឱ្យសោកស្តាយក្រៃលែង។ អាជ្ញាធរជាតិអប្សរានឹងចងចាំក្នុងក្រអៅបេះដូងនូវគំរូវីរភាព និងការលះបង់ដ៏ធំធេងរបស់ឯកឧត្តមក្នុងវិស័យវប្បធម៌ និងបេតិកភណ្ឌជាតិដែលឯកឧត្តមបានបន្សល់ទុកដល់ប្រជាជាតិខ្មែរ។

តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ឆ្មាំ កម្មករទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព និងសូមបួងសួងឧទ្ទិសកុសលផលបុណ្យនៅថ្ងៃនេះ សូមឱ្យវិញ្ញាណក្ខន្ធរបស់ឯកឧត្តមបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ៕









ស្វែងយល់អត្ថន័យនៃពិធីកាត់សក់បង្កក់ធ្មបរបស់អ្នកអង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ យឿន តាក់

ក្រោយពេលសម្រាលកូនមួយឬពីរសប្តាហ៍អ្នកស្រុកអង្គរ តែងរៀបចំពិធីមួយសម្រាប់ទារកដែលទើបកើត។ ពិធីនោះគឺពិធីកាត់សក់ទារក។ ជាមួយគ្នានឹងពិធីកាត់សក់ គេនាំគ្នាគោរពយាយម៉ាបនិងជូនវត្ថុរបស់ផ្សេងៗ ចំពោះរូបគាត់តាមលទ្ធភាពក្នុងន័យសម្តែងនូវការអរគុណ និងខមាទោសចំពោះរូបគាត់ដែលបានជួយខ្វល់ក្នុងការសម្រាលកូនកន្លងមក។ ពិធីនេះគេហៅជាប់គ្នាថា កាត់សក់បង្កក់ធ្មប។

តាមចាស់ៗដែលបានចូលរួមពិធីពន្យល់ថា ការកាត់សក់ទារក ទោះជាកាត់មែនទែនក្តី កាត់បន្តិចជាឧបកិច្ចក្តី គឺក្នុងន័យកាត់សក់ព្រៃចេញ ដើម្បីឲ្យដុះសក់ស្រុកមកវិញ។ គេមិនត្រឹមកាត់តែសក់ទេ គេមានទាំងពិធីឈូសមាត់ ដាប់ធ្មេញជាដើមថែមទៀត ដែលក្នុងន័យឲ្យអ្វីៗគ្រប់យ៉ាងទៅជាស្រុកមិនមែនព្រៃ។ តាមវិធីនេះហើយ ដែលគេសន្មត់ថា ទារកនោះនឹងជាមនុស្សក្នុងសង្គមដូចគេដូចអ្នកផ្សេងទៀត ពោលគឺមិនមែនជាមនុស្សព្រៃ។

ចំណែកពិធីបង្កក់ធ្មបវិញ ជាពិធីជឹងគុណរបស់ឪពុកម្តាយ និងសាច់ញាតិរបស់ទារកចំពោះ យាយម៉ាប ដែលបានកាន់ឈាម កាន់ដំទារកក្នុងពេលប្រសូតមក ប្រឡាក់ប្រឡូសដោយវត្ថុមិនស្អាតផ្សេងៗ។ បច្ចុប្បន្ន បើទោះជាគេទៅសម្រាលកូននៅតាមមន្ទីរពេទ្យក៏ដោយ អ្នកអង្គរនៅរក្សាទំនៀមនេះ ដោយអញ្ជើញស្ត្រីដែលធ្លាប់ជាយាយម៉ាបពីដើមមកបំពេញកិច្ច។ គេរៀបចំស្រូវ និងគ្រឿងបរិក្ខារផ្សេងៗជាកំណល់ជមជូនគាត់ ដូចជាគាត់បានជួយបង្កើតកូនពិតៗដែរ។

លោកយាយ ខៀង នៅភូមិទក្សិណខាងត្បូង ដែលត្រូវបានអញ្ជើញជាយាយម៉ូបក្នុងពិធីកាត់សក់បង្កក់ឆ្នប នៅភូមិក្រវ៉ាន់ បញ្ជាក់ថា លោកយាយធ្លាប់ធ្វើឆ្នបកាន់ពោះឲ្យគេតាំងពីយូរមកហើយ។ សព្វថ្ងៃទោះជាលោកយាយមិនបានទៅជួយសម្រាលគេយ៉ាងណា តែអ្នកស្រុកនៅតែរក្សាទំនៀម ធ្វើពិធីដូចពីដើមដដែល។ លោកយាយបញ្ជាក់ថា "ពីដើមបើយើងទៅជួយសម្រាលគេចឹង គេត្រូវតែរៀបចំដមជូនយើងវិញ បើមិនចឹងគ្រូយើងនឹងធ្វើបាបយើង ដោយបណ្តាលឲ្យយើងជាឈឺនេះឈឺនោះមិនឈប់ ទាល់តែគេធ្វើពិធីកាត់សក់បង្កក់ឆ្នបទើបបានជា។ ចាស់ៗពីដើមជឿថា បើឪពុកម្តាយទារកមិនធ្វើជូនយាយម៉ូបទេ ទារកនោះនឹងទូលកន្ធបយាយម៉ូបរហូត។ ឥឡូវនេះ គេទៅឆ្លងទន្លេ នៅពេទ្យចឹង ខ្លះគេធ្វើ ខ្លះគេមិនធ្វើ តែភាគច្រើនគេនៅតែធ្វើតាមទំនៀម"។

ក្រៅពីកាត់សក់ទារក និងបង្កក់ជូនយាយម៉ូប ពិធីនេះក៏ជាពិធីប្រកាសសុំឲ្យជូនតាចាស់ទុំក្នុងភូមិស្រុកជួយទទួលស្គាល់សមាជិកថ្មីក្នុងគ្រួសារគឺទារកដែលទើបនឹងកើតដែរ។ ដូច្នេះហើយ ទើបមុននឹងរៀបចំពិធីកាត់សក់ទារក និងបង្កក់ឆ្នប អាចារ្យសូត្រប្រកាសសែនជូនតាមួយលើក ជាពីរលើក រហូតបីលើកឲ្យមកសេពសោយសំណែន និងសុំឲ្យជូនតាជួយរក្សាទារកដែលទើបកើតឲ្យក្តីសុខសប្បាយព្រមទាំងគ្រួសារទាំងមូលផង។

នេះជាប្រពៃណីមួយក្នុងចំណោមប្រពៃណីជាច្រើនទៀត ដែលអ្នកអង្គរបានរក្សាទុកយ៉ាងល្អ ដែលបង្ហាញថា តំបន់អង្គរជាឃ្លាំងផ្ទុកនូវមរតកជូនតាខ្មែរយ៉ាងសម្បូរបែប ធ្វើឲ្យអង្គរមានឈ្មោះថាជាសម្បត្តិបេតិកភណ្ឌមានជីវិតជារៀងរហូត៕









សេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យដំណើរការគេហទំព័រទេសចរណ៍អង្គរ (www.angkor.com.kh)

ផ្សាយនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ រូបភាព ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
N° ០៦៧/រប.សដណ
១៧

សេចក្តីជូនដំណឹង
ស្តីពី
ការដាក់ឱ្យដំណើរការគេហទំព័រទេសចរណ៍អង្គរ (www.angkor.com.kh)

អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង-ស្ថាប័ន សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ សមាគមអ្នកបើកបររថយន្ត ដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សិស្ស-និស្សិត ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីផ្សព្វផ្សាយនិងផ្តល់ព័ត៌មានឲ្យកាន់តែទូលំទូលាយ និងបង្កលក្ខណៈកាន់តែងាយស្រួលសម្រាប់ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ ក្នុងការស្វែងយល់អំពីប្រវត្តិសាស្ត្រសម័យអង្គរ តំបន់ទេសចរណ៍សំខាន់ៗ សេវាកម្មទេសចរណ៍ផ្សេងៗ និងព័ត៌មានសំខាន់ៗ ពាក់ព័ន្ធវិស័យទេសចរណ៍ជាច្រើននៅតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ អាជ្ញាធរអប្សរាបានបង្កើតគេហទំព័រថ្មីមួយ ដែលមានអាសយដ្ឋាន www.angkor.com.kh ។ គេហទំព័រនេះនឹងបើកឲ្យដំណើរការចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ នេះតទៅ។

អាស្រ័យហេតុនេះ សូមគ្រប់ក្រសួង-ស្ថាប័ន សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ សមាគមអ្នកបើកបររថយន្ត ដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សិស្ស-និស្សិត ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

សៀមរាប ថ្ងៃទី 27 ខែ មករា ឆ្នាំ២០១៧
អគ្គនាយកស្តីទី

សុខ សន្ធារ

ចម្លងជូន៖
- សាលាខេត្តសៀមរាប
- មន្ទីរទេសចរណ៍ខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌ
- អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
- គ្រឹះស្ថានអង្គរ
- សមាគមទីភ្នាក់ងារមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមអ្នកដឹកជញ្ជូនភ្ញៀវទេសចរ
- សមាគមសណ្ឋាគារ ផ្ទះសំណាក់
- គ្រប់នាយកដ្ឋាន/អង្គភាពចំណុះអាជ្ញាធរអប្សរា
- ឯកសារ-កាលប្បវត្តិ

PHNOM PENH :
#41, Russian Blvd,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 776
Fax : (855-23) 215 771

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននៃតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
E-mail : info@apsaraauthority.gov.kh

SIEM REAP :
Bang Korng Village, Ampil Commune, Siem Reap City, Siem Reap Province
Tel: (855-63) 76 55 77 or (855-63) 76 66 76
Fax: (855-63) 76 55 76





គេហទំព័រទេសចរណ៍អង្គរថ្មី នឹងដាក់ឲ្យដំណើរការចាប់ពីថ្ងៃទី០១ ខែកុម្ភៈ នេះហើយ

ផ្សាយនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ រូបភាព ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ

គេហទំព័រទេសចរណ៍អង្គរ (www.angkor.com.kh) ដែលបង្កើតឡើងដោយអាជ្ញាធរអប្សរា គឺជាប្រភពព័ត៌មានដ៏សម្បូរបែបសម្រាប់ភ្ញៀវទេសចរស្វែងរកព័ត៌មានទេសចរណ៍ផ្សេងៗ នៅតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ។

តាមការបញ្ជាក់ពីសំណាក់ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងអាជ្ញាធរអប្សរា បានឲ្យដឹងថា គេហទំព័រថ្មីនេះដើរតួនាទីចម្បងក្នុងការផ្សព្វផ្សាយពីតំបន់ទេសចរណ៍ក្នុងរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ជាពិសេសផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ដំណើរទេសចរណ៍ ប្រកបដោយបទពិសោធន៍ល្អប្រសើរ។ គេហទំព័រថ្មីនេះ ក្រុមការងារអាជ្ញាធរអប្សរា បានចំណាយពេលវេលាជិតមួយឆ្នាំមកហើយដើម្បីរៀបចំឡើង ជាពិសេសក្នុងការរចនាឲ្យមានភាពសាមញ្ញបង្កប់ដោយភាពទាក់ទាញ ដោយមានភ្ជាប់ជាមួយរូបភាពជាច្រើន និងផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិមុននឹងមកទស្សនាតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ក៏ដូចជាអំឡុងពេលទស្សនា ជាពិសេសគេហទំព័រថ្មីនេះ គឺជាមធ្យោបាយនៃការផ្សារភ្ជាប់ទំនាក់ទំនងរវាងភ្ញៀវទេសចរនិងក្រុមការងារ តាមរយៈការរៀបចំឲ្យមានតារាងបញ្ចេញមតិ ពេញចិត្តឬមិនសូវពេញចិត្ត រួមនិងសំណូមពរផ្សេងៗក្នុងន័យស្ថាបនា ដើម្បីឲ្យក្រុមការងារអាចសិក្សាកែសម្រួលលើកកម្ពស់សេវាទេសចរណ៍អង្គរឲ្យកាន់តែល្អប្រសើរ។

ឯកឧត្តម បានបញ្ជាក់បន្ថែមថា គេហទំព័រនេះ មុននឹងឈានដល់ការសម្រេចដាក់ឲ្យដំណើរការ ក្រុមការងារក៏បានពិភាក្សាគ្នាជាមួយផ្នែកឯកជន ជាពិសេសសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ដែលជាការផ្តល់ឱកាសឲ្យមានការចូលរួមមតិយោបល់ផ្សេងៗផងដែរ។ លើសពីនេះក្រុមការងារក៏បានបង្ហា ញជូនក្រុមអ្នកជំនាញចំពោះកិច្ចនៃ ICC-Angkor ដោយទទួលបានការពេញចិត្តនិងគាំទ្រយ៉ាងពេញទំហឹង និងជម្រុញអោយដំណើការកាន់តែឆាប់កាន់តែប្រសើរ។ គេហទំព័រនេះក៏នឹងមានការអភិវឌ្ឍបន្ថែមជាប្រចាំ ក៏ដូចជាការបន្ថែមភាសាបរទេសសំខាន់ៗមួយចំនួន លើភាសាអង់គ្លេសដែលមានស្រាប់។

ដោយឡែកចំពោះគេហទំព័ររបស់អាជ្ញាធរអប្សរា (www.apsaraauthority.gov.kh) និងបណ្តាញព័ត៌មាន Facebook (អាជ្ញាធរជាតិអប្សរា Apsara Authority) នៅតែដំណើរការធម្មតា ដោយដើរតួនាទីផ្សព្វផ្សាយពីសកម្មភាពប្រចាំថ្ងៃ និងធ្វើបច្ចុប្បន្នភាពព័ត៌មានផ្សេងៗ
និងជាប្រភពឯកសារសម្រាប់អ្នកស្រាវជ្រាវនិងអ្នកសិក្សានានាក្នុងការស្វែងយល់អំពីតួនាទី ភារកិច្ច និងសមិទ្ធផល របស់អាជ្ញាធរអប្សរា ក្នុងកិច្ចការអភិរក្សនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរប្រកបដោយចីរភាព។









Download Angkor map

Entrance Time

Open	7:30 AM
Close	5:30 PM

* Angkor Wat temple and Sras Srang :
Open : 5.00 AM
Close : 5.30 PM

WELCOME TO ANGKOR

With over 150 significant monuments, Angkor is the crown jewel of Khmer civilization and an outstanding cultural heritage site with the universally known temple, Angkor Wat.

It is also an ecological site with reservoirs (the famous barays), ponds, canals as well as forests and rice

ក្រុមគម្រោងអភិរក្សប្រាសាទព្រះពិធូរបណ្តុះបណ្តាលបុគ្គលិកជំនាញ នៃអាជ្ញាធរជាតិអប្សរាពីរបៀបប្រើប្រាស់ឧបករណ៍ស្ទង់រចនាសម្ព័ន្ធប្រាសាទក្រោមដី

ផ្សាយនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ យឿន តាក់

ក្រុមគម្រោងអភិរក្សប្រាសាទព្រះពិធូរ KCHF (Korean Cultural Heritage Foundation) របស់សាធារណរដ្ឋកូរ៉េនឹងប្រើប្រាស់ឧបករណ៍ទំនើបមួយចំនួន ដើម្បីវាស់ស្ទង់រចនាសម្ព័ន្ធប្រាសាទក្រោមដីក្នុងដំណើរការអភិរក្ស ជួសជុលក្រុមប្រាសាទព្រះពិធូរនាពេលខាងមុខ។ មុននឹងឈានដល់ការប្រើប្រាស់ឧបករណ៍ទាំងនេះជាផ្លូវការ KCHF បានបណ្តុះបណ្តាលមន្ត្រីជំនាញចំនួន១០រូប ដែលអាជ្ញាធរជាតិអប្សរាឲ្យចេះប្រើប្រាស់ឧបករណ៍ទាំងនេះ។

លោក Kim Jiseo អ្នកគ្រប់គ្រងគម្រោងបានបញ្ជាក់នៅព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ថា ការប្រើប្រាស់ឧបករណ៍វាស់ស្ទង់រចនាសម្ព័ន្ធប្រាសាទក្រោមដីនេះ គឺដើម្បីសិក្សាអំពីស្រទាប់ដី និងរចនាសម្ព័ន្ធក្រោមដីដែលភ្នែកធម្មតាមិនអាចមើលឃើញ។ "ឧបករណ៍នេះមានភាពសុក្រឹត្យ ហើយវាមិនបង្កបញ្ហាណាមួយដល់រចនាសម្ព័ន្ធរបស់ប្រាសាទ តែវាអាចផ្តល់ទិន្នន័យដល់យើងក្នុងការងារស្រាវជ្រាវចងក្រងឯកសារសម្រាប់ការងារជួសជុល។ បើទិន្នន័យបង្ហាញថា ចំណុចណាមួយមានបញ្ហា យើងនឹងធ្វើកំណាយ តែនឹងធ្វើទៅលើចំណុចនោះប៉ុណ្ណោះ មិនចាំបាច់ធ្វើទូទៅទេ"។

លោក Jiseo បន្ថែមថា ទីនេះជាតំបន់បេតិកភណ្ឌពិភពលោក ការស្រាវជ្រាវ អភិរក្សជួសជុល គឺត្រូវប្រាកដថា បានលើកតម្លៃបេតិកភណ្ឌ និងមិនប៉ះពាល់ដល់ផ្នែកបុរាណវិទ្យា។ ឧបករណ៍ទាំងនេះត្រូវបានអនុញ្ញាតដោយអ្នកជំនាញនៃអាយស៊ីស៊ី-អង្គរ ហើយយើងបណ្តុះបណ្តាលឲ្យអ្នកជំនាញខ្មែរអាចប្រើប្រាស់បានដោយខ្លួនឯងថែមទៀត ដើម្បីបន្ថែមជំនាញដល់មន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា។

លោក ស្រ៊ុន តិច បុរាណវិទូនៃអាជ្ញាធរជាតិអប្សរា ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះបញ្ជាក់ថា សម្ភារៈដែលប្រើប្រាស់នេះអាចជួយការងារច្រើនដល់អ្នកបុរាណវិទ្យាមុននឹងឈានដល់ការបើកកំណាយកន្លែងណាមួយ។ លោកបញ្ជាក់ថា ការធ្វើកំណាយពិតជាមានសារៈសំខាន់ សម្រាប់ការងារស្រាវជ្រាវចងក្រងឯកសារផ្នែកបុរាណវិទ្យាមុននឹងចាប់ផ្តើមជួសជុល។ ឧបករណ៍នេះនឹងជួយប្រាប់យើងនូវព័ត៌មានជាច្រើនដែលកប់ក្នុងដី តែបើចនាសម្ព័ន្ធណាមួយដែលមានបញ្ហា យើងត្រូវតែបើកកំណាយដដែល ដើម្បីពិនិត្យឲ្យច្បាស់លាស់ និងសិក្សាពីមូលហេតុផ្សេងៗដែលនាំឲ្យមានបញ្ហាជាដើម។

សូមបញ្ជាក់ថា ទន្ទឹមនឹងការងារអភិរក្សជួសជុលគម្រោង KCHF ក៏ដូចជាគម្រោងអន្តរជាតិផ្សេងៗទៀតដែរ តែងបណ្តុះបណ្តាលមន្ត្រី ជំនាញខ្មែរជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាព។ តាមរយៈសកម្មភាពនេះ អ្នកជំនាញខ្មែរបានកើនឡើងពីមួយជំនាន់ទៅមួយជំនាន់ រហូតអាចកាន់ការងារស្រាវជ្រាវ អភិរក្សជួសជុល ដោយខ្លួនឯងបានទៀតផង។ កាលពីកិច្ចប្រជុំនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរកន្លងទៅថ្មីៗនេះ សហប្រធាននៃប្រទេសបារាំង ក៏ដូចជាតំណាងអង្គការយូណេស្កូប្រចាំកម្ពុជាបានកោតសរសើរដល់មន្ត្រីជំនាញវ័យក្មេងជាច្រើនរូបនៃអាជ្ញាធរជាតិអប្សរា ដែលមានសមត្ថភាពគ្រប់គ្រាន់អាចកាន់ការងារបានដោយខ្លួនឯងទៀតផង៕









មគ្គុទ្ទេសក៍ទេសចរណ៍គាំទ្រចំពោះការកំណាយស្រាវជ្រាវនៅស្ថានីយ៍ស្លដែកនៅភូមិសាលាក្រវ៉ាន់ ដោយក្រុមអ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីវ៉ត្ថ រូបភាព ៖ ហ៊ីង ស្រីវ៉ត្ថ

នាពេលថ្មីៗនេះ សមាគមមគ្គុទ្ទេសក៍ខ្មែរអង្គរមួយក្រុមបានធ្វើដំណើរមកកាន់ការដ្ឋានកំណាយស្ថានីយ៍ស្លដែកបុរាណមួយ ដែលរកឃើញនៅភូមិសាលាក្រវ៉ាន់ ឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ស្ថិតក្នុងតំបន់ការពារទី២នៃរមណីយដ្ឋានអង្គរ។ នេះជាស្ថានីយលោហកម្មបុរាណដែលប្រទះឃើញមុនគេបង្អស់នៅក្នុងតំបន់អង្គរ។

ការមកទស្សនកិច្ចនៅទីនេះ គឺដើម្បីស្វែងយល់ពីអំពីសារៈសំខាន់នៃលោហៈសម្រាប់ការប្រើប្រាស់នៅរាជធានីអង្គរព្រមទាំងពិចារណាឡើងវិញអំពីប្រភពផ្គត់ផ្គង់លោហៈដល់អង្គរ។ តាមរយៈលទ្ធផលដែលរកឃើញក្នុងការដ្ឋានកំណាយ គឺជាភស្តុតាងដ៏សំខាន់សម្រាប់សិក្សាអំពីវិសាលភាពនៃទីតាំងផលិតលោហៈ ព្រមទាំងពិនិត្យមើលរចនាសម្ព័ន្ធនៃចង្ក្រានស្លដែកក្នុងជាស្ថានីយលោហកម្មបុរាណដែលប្រទះឃើញមុនគេបង្អស់នៅក្នុងតំបន់អង្គរ ហើយទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់មគ្គុទ្ទេសក៍លើផ្នែកអភិរក្សនិងវិស័យទេសចរណ៍។

លោក អៀង ប៉ោហេង មកពីសមាគមមគ្គុទ្ទេសក៍ខ្មែរអង្គរផ្នែកភាសាអង់គ្លេស បានលើកឡើងថា នេះជាដំណឹងដ៏គួរឱ្យភ្ញាក់ផ្អើលជាខ្លាំងដែលបានទទួលការអញ្ជើញពីអ្នកជំនាញមកកាន់ស្ថានីយ៍កំណាយនេះ ដើម្បីស្តាប់បទបង្ហាញ និងស្វែងយល់ដោយផ្ទាល់ពីរបកគំហើញថ្មីនៃការស្លដែកពីសម័យបុរាណ។ លោកចាប់អារម្មណ៍បំផុត គឺស្ថានីយនេះ ជាកន្លែងផលិតលោហៈបុរាណ ដែលប្រទះឃើញដំបូងបង្អស់នៅក្នុងតំបន់អង្គរ អស់រយៈពេល១៥០ឆ្នាំក្រោយពីការផ្តើមការស្រាវជ្រាវអំពីអង្គរ។ ភស្តុតាងដែលបានរកឃើញជាអំណះអំណាងបន្ថែមសម្រាប់ឱ្យកូនចៅជំនាន់ក្រោយ បានយល់ដឹងពីភាពអស្ចារ្យរបស់អាណាចក្រខ្មែរអង្គរ ដែលសាងសង់ប្រាសាទបានជាច្រើនដោយប្រើថ្មធំៗ ថាតើគាត់មានអ្វីកាត់ថ្ម គ្រឿងលើកដាក់ថ្ម ពិសេសគឺជំនាញ បច្ចេកទេសស្លដែក និងការផលិតសញ្ញវុធការពារក្រុងអង្គរ។ លោកបន្តទៀតថា ក្នុងនាមជាមគ្គុ-ទ្ទេសក៍ម្នាក់ យើងត្រូវដឹងឱ្យច្បាស់និងឱ្យច្រើនពីតំបន់ទេសចរណ៍របស់យើង ទាំងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វប្បធម៌ ប្រពៃណី បុរាណវិទ្យា និងរឿងផ្សេងៗទៀតដើម្បីនិយាយជូនភ្ញៀវស្តាប់។ លោកក៏សូមចូលរួមអបអរចំពោះលទ្ធផលកំណាយស្រាវជ្រាវដោយក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា និងចូលរួមចំណែកក្នុងការផ្សព្វផ្សាយពីព័ត៌មាននេះទៅកាន់ទេសចរឱ្យបានទូលំទូលាយ។ លោកក៏សំណូមពរម្ចាស់ស្រែនិងអ្នកមានសមត្ថកិច្ច សូមឱ្យរក្សាកន្លែងនេះទុកដើម្បីនាំទេសចរមកទស្សនា ដែលបង្កើតការងារដល់អ្នកស្រុកតំបន់នេះតាមរយៈការលក់ដូរផងដែរ។

លោក ជុំ ដាលីន ដែលមកពីសមាគមមគ្គុទ្ទេសក៍ខ្មែរអង្គរផ្នែកភាសាអង់គ្លេសដូចគ្នានោះ ក៏បន្ថែមទៀតថា នេះជាការរកឃើញថ្មីមួយដ៏គួរឱ្យរីករាយចំពោះភស្តុតាងនេះ។ លោកសូមគាំទ្រទាំងស្រុងចំពោះកិច្ចការស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា ដែលបានជួយលាតត្រដាងពីការរកឃើញថ្មីៗនៅក្នុងតំបន់អង្គរ ដើម្បីរួមចំណែកអភិរក្សនិងលើកស្ទួយវិស័យទេសចរណ៍។ លោកចង់ឱ្យអភិរក្សទីនេះទៅជាសារមន្ទីរ ដើម្បីក្លាយជាផលិតផលទេសចរណ៍ថ្មីមួយទៀត ដែលអាចពន្យារពេលទេសចរឱ្យស្នាក់នៅទីនេះបានយូរ នោះប្រាក់ចំណូលដល់ប្រជាជននិងប្រទេសក៏បានល្អប្រសើរដែរ។ លោកជឿជាក់ថាទីនេះនឹងមានភ្ញៀវមកទស្សនាច្រើន ព្រោះទេសចរក្រៅពីចូលចិត្តទស្សនារមណីយដ្ឋានវប្បធម៌និងប្រវត្តិសាស្ត្រហើយនោះ ពួកគេក៏ចូលចិត្តស្វែងយល់ពីតំបន់បុរាណវិទ្យា របកគំហើញថ្មីៗដែរ ណាមួយទីតាំងភូមិសាស្ត្រនេះក៏ជាប់នឹងប្រាសាទថៅស្រីវិបុល និងផ្លូវទៅភ្នំគូលែនទៀតផង។

គួរបញ្ជាក់ផងដែរថា ស្ថានីយស្លដែកបុរាណមួយនេះត្រូវបានក្រុមស្រាវជ្រាវអាជ្ញាធរជាតិអប្សរាដឹកនាំដោយ **លោក អ៊ឹម សុខរិទ្ធី** បើកកំណាយស្រាវជ្រាវជាលើកទី២រយៈពេល១០ថ្ងៃចាប់ពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ ហើយចំពោះលទ្ធផលដែលបានរកឃើញពីការកំណាយនេះនឹងត្រូវបានបង្ហាញជាសាធារណៈបន្ទាប់ពីបញ្ចប់ការកំណាយជាស្ថាពរ៕









ផ្នែកទី ២
ប្រចាំខែកុម្ភៈ

ក្រុមការងារសហគន៍អាជ្ញាធរជាតិអប្សរាបន្តចុះលើកកម្ពស់សុខុមាលភាពម្តាយ និងទារកដល់ស្ត្រីក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

នៅព្រឹកថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម តាន់ សំប៊ុន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និងមន្ត្រីបុគ្គលិកមួយចំនួនទៀតបានចុះយកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារក ទៅចែកជូនដល់ស្ត្រីទើបឆ្លងទន្លេរួច ចំនួន៣៦គ្រួសារកំពុងរស់នៅក្នុងសង្កាត់អំពិល ។ ពិធីចែកជូននេះត្រូវបានធ្វើឡើងនៅក្នុងសាលាឆទានភូមិត្រពាំងរុន សង្កាត់អំពិល ក្រុងសៀមរាប ខេត្តសៀមរាបដោយមានចូលរួមពីតំណាងអាជ្ញាធរមូលដ្ឋានរួមនិងប្រជាពលរដ្ឋប្រមាណ៥០នាក់។

មានប្រសាសន៍ក្នុងពិធីនោះ **ឯកឧត្តម តាន់ សំប៊ុន** បានណែនាំឲ្យបងប្អូនជាស្ត្រីទាំងអស់ដែលមានកូនខ្ចីត្រូវចេះយកចិត្តទុកដាក់ថែរក្សាសុខភាពខ្លួន និងកូនឲ្យបានល្អដើម្បីកុំឲ្យមានជំងឺដង្កាត់ផ្សេងៗចូលមកបៀតបៀនយាយីបាន ហើយបើក្នុងករណីខ្លួនឯង ឬកូនមានបញ្ហាសុខភាពត្រូវប្រញាប់ប្រញាល់ទៅជួបនិងពិគ្រោះយោបល់ជាមួយគ្រូពេទ្យឲ្យទាន់ពេលវេលា។

លោក ព្រៀន ប្រុប អនុប្រធានភូមិគិរីមានន្ទតំណាងស្ត្រីកូនខ្ចីបានសម្តែងនូវចិត្តសប្បាយរីករាយ និងអរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា ជាពិសេស **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** និងលោកជំទាវដែលតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋ និងសូមជូនពរឲ្យឯកឧត្តមមន្ត្រីបុគ្គលិកទាំងអស់ជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន និងសម្រេចជោគជ័យគ្រប់ភារកិច្ច។

សូមបញ្ជាក់ថា កញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយនិងទារកដែលបានផ្តល់ជូននៅពេលនេះរួមមាន កន្ត្រក បំពង់ទឹកក្តៅ កន្សែងពោះគោ កូនមុង ស្រោមដៃ ស្រោមជើង ខោអាវទារក រួមនិងថវិកាមួយចំនួនទៀតរៀល ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរានិងលោកជំទាវ៕









អាជ្ញាធរជាតិអប្សរាបន្តសហការជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា ក្នុងកិច្ចការជួសជុលប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ យឿន តាក់

គម្រោងសហប្រតិបត្តិការឥណ្ឌា-កម្ពុជា ដើម្បីអភិរក្ស និងជួសជុលប្រាសាទតាព្រហ្ម ដែលមានអាជ្ញាធរជាតិអប្សរា និងស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (Archeological Survey of India-ASI) បានធ្វើការជួសជុលផ្នែកផ្សេងៗ នៃប្រាសាទតាព្រហ្មតាំងពីឆ្នាំ២០០៤មក។ រយៈពេល១០ឆ្នាំ ដែលជាដំហានទី១នៃគម្រោង (២០០៤-២០១៤) ក្រុមការងារសម្រេចបានសមិទ្ធផលយ៉ាងច្រើនគួរឲ្យកត់សម្គាល់។ សម្រាប់ដំហានទី២ (២០១៥-២០២៥) គម្រោងកំពុងដំណើរការជួសជុលផ្តុំឡើងវិញនូវសាលរបាំ ដែលរងខូចខាតស្ទើរទាំងស្រុង តាមរយៈការប្រមូលបំណែកថ្មធ្លាក់ខូចខាត មករៀបតំឡើងនៅតាមទីតាំងឲ្យដូចពីសម័យបុរាណឡើងវិញ។

លោក D.S. Sood ទីប្រឹក្សាបច្ចេកទេសប្រចាំការដ្ឋានជួសជុលប្រាសាទតាព្រហ្មនៃស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា ASI បញ្ជាក់ថា ក្នុងដំណាក់កាលទី២នេះ ក្រុមការងារបានបន្តជួសជុលសាលរបាំ ហើយគ្រោងនឹងជួសជុលទៅលើចំណុចសំខាន់៤ ផ្សេងទៀតគឺ នៅជ្រុងខាងត្បូងសាលរបាំ ខ្លោងទ្វារចូលខាងកើត ខ្លោងទ្វារចូលខាងត្បូង និងរួតទី៣មុខផ្លូវបំបែក។ លោកបន្ថែមថា ក្រៅពីការជួសជុលតាមគម្រោងដែលគ្រោងទុក ក្រុមការងាររបស់លោកក៏បានបំពេញកិច្ចការផ្សេងៗទៀតលើការងារអភិរក្ស ទល់ទ្រ និងថែទាំជាប្រចាំនូវរាល់រចនាសម្ព័ន្ធផ្សេងៗនៃប្រាសាទតាមស្ថានភាពជាក់ស្តែង ដោយសហការជាមួយក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរជាតិអប្សរា។

ដោយឡែក សាលរបាំដែលបានរងការខូចខាតស្ទើរទាំងស្រុង ហើយភ្ញៀវទេសចរមិនអាចធ្វើដំណើរឆ្លងកាត់បាននាពេលកន្លងមកនឹងត្រូវជួសជុលរួចរាល់ក្នុងឆ្នាំ២០១៩ខាងមុខ។ **លោក Sood** បន្ថែមថា សូម្បីការជួសជុលក៏ពុំមែនធ្វើទាំងស្រុងនោះដែរ ដោយផ្នែកខ្លះនៃភាពខូចខាតនេះនឹងត្រូវអភិរក្សទុក ដើម្បីឲ្យអ្នកស្រាវជ្រាវនិងភ្ញៀវទេសចរបានឃើញថាផ្នែកណាខ្លះត្រូវបានជួសជុល និងផ្នែកណាខ្លះត្រូវបានរក្សាទុក។ ម្យ៉ាងទៀត ដោយមូលហេតុដើមឈើធំៗមានអាយុកាលរាប់រយឆ្នាំដុះពីលើផ្នែកខ្លះនៃប្រាសាទនេះ ក៏ត្រូវបានរក្សាទុកមិនធ្វើការជួសជុលដែរ ដើម្បីបញ្ជៀសការកាប់ដើមឈើប្រវត្តិសាស្ត្រទាំងនេះ។ តែទោះជាមិនបានជួសជុល ក្រុមការងារបានថែទាំនិងការពារមិនឲ្យមានការខូចខាតបន្តទៀតឡើយ។

លោក ចាន់ ឡាយ អ្នកគ្រប់គ្រងការដ្ឋានជួសជុលបញ្ជាក់ថា ដើមឈើនិងប្រាសាទតាព្រហ្មមានទំនាក់ទំនងនឹងគ្នាខ្លាំងណាស់រហូតភ្ញៀវទេសចរ និងអ្នកស្រាវជ្រាវខ្លះបានហៅប្រាសាទនេះថា ជាប្រាសាទដើមឈើ។ ភ្ញៀវទេសចរដែលមក

ទស្សនាប្រាសាទតាព្រហ្ម ភាគច្រើនគឺចង់ឃើញដើមឈើធំៗដែលដុះលើប្រាសាទ និងរួមរស់ជាមួយប្រាសាទរាប់រយឆ្នាំ។ កត្តាទាំងនេះហើយ ដែលតម្រូវឲ្យក្រុមការងារអភិរក្សជួសជុលគិតគូរទាំងប្រាសាទ ទាំងដើមឈើ។

ប្រាសាទតាព្រហ្មត្រូវបានកសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ដើម្បីថ្វាយព្រះរាជកុសលចំពោះព្រះមាតារបស់ព្រះអង្គ ដែលមានរូបបដិមាស្នងក្នុងរូបភាពជា "ប្រាជ្ញាបារមី"។ ប្រាសាទនេះមានឈ្មោះដើមថា រាជវិហារ ត្រូវបានចាត់ទុកថាជាវត្តព្រះពុទ្ធសាសនាដ៏ធំនាសម័យនោះ។ ក្រោយការស្នើសុំពីរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០២ រដ្ឋាភិបាលឥណ្ឌាតាមរយៈស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា ASI រួមសហការជាមួយអាជ្ញាធរជាតិអប្សរា និងអង្គការយូណេស្កូ បានចាប់ផ្តើមការអភិរក្សជួសជុល ទល់ទ្រជាបន្តបន្ទាប់។ ជាក់ស្តែង ក្នុងដំណាក់កាលទី១(២០០៤-២០១៤) គម្រោងនេះសម្រេចបានការជួសជុលរួចរាល់ទាំងស្រុងនូវរោងទងខាងកើតធៀងខាងត្បូង រានហាលខាងលិច ខ្លោងទ្វារច្រកចូលទី៤ ខ្លោងទ្វារខាងលិច និងជញ្ជាំងថ្មបាយក្រៀមអមសងខាង។ ក្រៅពីចំណុចជួសជុលទាំងនេះ នៅមានផ្នែកច្រើនទៀត ដែលក្រុមការងារបានធ្វើការទល់ទ្រ និងចងរឹតដោយខ្សែកាប ដើម្បីការពារការរេះរើឬធ្លាក់ឬដួលរលំបន្ថែមទៀត៕









អគ្គនាយកអាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជួសជុល សារមន្ទីរព្រះនរោត្តមសីហនុអង្គរជាមួយក្រុមហ៊ុនអ៊ីអុង

ផ្សាយនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ យឿន តាក់

នៅព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៧នេះ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុនអ៊ីអុង (AEON) សាកលវិទ្យាល័យសូហ្វីយ៉ា និងក្រុមហ៊ុនសាតូកម្ពុជា។ ជំនួបពិភាក្សានេះ ធ្វើឡើងនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរាផ្ទាល់ ដោយផ្តោតសំខាន់លើដំណើរការនៃការជួសជុលសារមន្ទីរព្រះនរោត្តមសីហនុអង្គរ និងការដាក់ឲ្យដំណើរការឡើងវិញនូវសារមន្ទីរក្រោយការជួសជុលរួចរាល់។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់ អគ្គនាយកអាជ្ញាធរជាតិអប្សរាថ្លែងអំណរគុណចំពោះក្រុមហ៊ុនអ៊ីអុង និងសាកលវិទ្យាល័យសូហ្វីយ៉ា ដែលបានជួយជ្រោមជ្រែងក្នុងកិច្ចអភិរក្សវប្បធម៌នៅអង្គរ ជាពិសេស គឺកិច្ចការជួសជុលសារមន្ទីរនៅពេលនេះ។ ឯកឧត្តមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាពិតជាពេញចិត្តចំពោះសមិទ្ធផលដ៏ល្អប្រសើរនេះ ហើយអាជ្ញាធរជាតិអប្សរានឹងពិភាក្សាជាមួយសាកលវិទ្យាល័យសូហ្វីយ៉ា ដើម្បីរិះរកវិធីសាស្ត្រយ៉ាងណាទាក់ទាញភ្ញៀវទេសចរឲ្យចូលទស្សនាសារមន្ទីរនេះកាន់តែច្រើនក្រោយពីជួសជុលរួចរាល់។ ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយកក៏បានស្នើឲ្យក្រុមហ៊ុនអ៊ីអុងពិចារណាជួយជួសជុលចំណុចមួយចំនួនទៀត ដែលមិនមានក្នុងកិច្ចព្រមព្រៀង។

ទីប្រឹក្សាជាន់ខ្ពស់នៃក្រុមហ៊ុនអ៊ីអុង **លោក ហាយ៉ាស៊ី ណាអុគី** បានសម្តែងនូវការពេញចិត្តចំពោះដំណើរការជួសជុលដែលមានការវិឌ្ឍទៅមុខជាលំដាប់។ លោកបញ្ជាក់ថា ដំណើរការជួសជុលនេះ មិនចោទជាបញ្ហាអ្វីនោះទេ តែអ្វីដែលយើងគិតគឺការទាក់ទាញភ្ញៀវទេសចរឲ្យចូលមកទស្សនាសារមន្ទីរឲ្យបានក្រោយពីការជួសជុលរួចរាល់។ ចំពោះសំណូមពរជួសជុលចំណុចផ្សេងពីកិច្ចព្រមព្រៀង លោកនឹងទៅពិនិត្យដោយផ្ទាល់ម្តងទៀត ហើយនឹងពិចារណាឡើងវិញ។

សារមន្ទីរព្រះនរោត្តមសីហនុអង្គរ បានកសាងឡើងនៅឆ្នាំ២០០៧ ក្រោមកិច្ចសហប្រតិបត្តិការរវាង អាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា ដោយ "មូលនិធិនៃក្លឹប១%" របស់ក្រុមហ៊ុនអ៊ីអុង ដើម្បីដាក់តាំង និងតម្កល់វត្ថុបុរាណដែលបានរកឃើញក្នុងពេលសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យសូហ្វីយ៉ា កាលពីឆ្នាំ២០០០ និង២០០១នៅប្រាសាទបន្ទាយក្តី។ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៦មក ក្រុមហ៊ុនអ៊ីអុង អាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ាសម្រេចធ្វើការជួសជុលកែលម្អឡើងវិញ ហើយគ្រោងនឹងបញ្ចប់នៅពាក់កណ្តាលខែមីនា ឆ្នាំ២០១៧នេះ។

យោងតាមខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីការងារជួសជុលនេះ មូលនិធិក្លឹប១%នៃក្រុមហ៊ុនអ៊ីអុងទទួលបន្ទុកចំណាយទាំងស្រុងលើការងារជួសជុលដំបូលលិចទឹក ជញ្ជាំងជ្រាបទឹក លាបថ្នាំ ជួសជុលបង្គួច និងកម្រាលឥដ្ឋសាលពិព័រណ៍។ អាជ្ញាធរជាតិអប្សរាទទួលបន្ទុកជីកជញ្ជួនចម្លាក់មុន និងក្រោយការងារជួសជុល សម្របសម្រួលការងារផ្សេងៗ និងចូលរួមជួសជុលចំណុចផ្សេងៗទៀតតាមលទ្ធភាពជាក់ស្តែង។ ចំណែកសាកលវិទ្យាល័យសូហ្វីយ៉ានឹងទទួលបន្ទុកផ្តល់ប្រឹក្សាលើការងារជួសជុល និងលើដំណើរការពិព័រណ៍សារមន្ទីរបន្ទាប់ពីជួសជុលហើយ៕









ពិធីបុណ្យឡើងអ្នកតាភ្ជាប់ពាក្យបង្ហាញពីការសាមគ្គីនិងស្រឡាញ់វប្បធម៌ជាតិរបស់អ្នកស្រុកអង្គរ!

ផ្សាយនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីរ័ត្ន រូបភាព ៖ សឿន ប៊ុនសារ

បើទោះបីជាស្រុកទេសមានការរីកចម្រើន វិទ្យាសាស្ត្រទំនើបខ្លាំង តែជំនឿនៅតែជារឿងសំខាន់បំផុតក្នុងជីវភាពរស់នៅរបស់អ្នកស្រុកអង្គរដែល។ ពួកគាត់តែងយកជំនឿជាធំមិនថាអ្នករកស៊ី អ្នកមានវិបត្តិ មុនធ្វើអ្វីមួយ ឬរៀបចំពិធីផ្សេងៗទេដើម្បីជួយដោះស្រាយជួយជាកម្លាំងចិត្ត និងធ្វើឱ្យចំពេលល្អមានសិរីសួស្តី ហើយរាល់ពិធីទាំងនេះធ្វើឡើងក្នុងគោលបំណងសុំសេចក្តីសុខសប្បាយនិងការពឹងគុណជាដើម។

ក្រៅពីនោះទៀត អ្នកស្រុកអង្គរក៏នៅរក្សាទំនៀមបុណ្យប្រពៃណីទៅតាមរដូវកាលយ៉ាងខ្ជាប់ខ្ជួនផងដែរ ដូចជាពិធីបុណ្យឡើងអ្នកតា (ឡើងមាយ) នាថ្ងៃ៣កើត ខែមាឃ ដែលអ្នកស្រុកក្នុងតំបន់អង្គរបានប្រារព្ធ ជារៀងរាល់ឆ្នាំតពីបុរាណកាលមកមិនដែលខកខាន។ ជាក់ស្តែងកាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ត្រូវនឹងថ្ងៃ៣កើតខែមាឃ ប្រជាជនដែលនៅជុំវិញប្រាសាទអង្គរវត្តបានស្រាក់ដៃគ្នារៀបចំពិធីឡើងមាយ ឬឡើងលោកតារាជ្យទៅតាមទម្លាប់ ដើម្បីសុំសេចក្តីសុខសេចក្តីចម្រើន រួមទាំងចូលរួមថែរក្សាជំនឿវប្បធម៌ខ្មែរឱ្យនៅរស់លើទឹកដីដ៏ស័ក្តិសិទ្ធិនេះ។

ចំពោះការរៀបចំគ្រឿងណ្តាប់នៅក្នុងពិធីនេះ មានស្លាធម៌ បាយសី ដម៤ គ្រឿងសំណែនមាន់ស្ងោរ ក្បាលជ្រូក បាយសម្ល បង្អែមចម្អាប ផ្លែឈើ ភ្ញីផ្កា ស្រាស ទឹកក្រូចជាដើម ពិសេសគឺនំបញ្ចុកតែម្តងដែលធ្វើសម្រាប់ចែកជូនអ្នកចូលរួមពិសារ។ ពិធីនេះកើតឡើងពីសាមគ្គីភាពរបស់អ្នកស្រុកគ្រប់គ្នាដែលស្រឡាញ់វប្បធម៌ជាតិ និងជំនឿដែលមានតាំងពីបុរាណ។

ក្នុងពិធីនេះដែរ អ្វីដែលពិសេសដើម្បីឱ្យមនុស្សនិងអ្នកតាអាចប្រាស្រ័យទាក់ទងគ្នាបានផង និងញ៉ាំងពិធីឱ្យកាន់តែអធិកអធមសប្បាយរីករាយផងនោះ គឺវង់តន្ត្រីបុរាណខ្មែរនិងអ្នកចូលរួបដែលតំណាងឱ្យអ្នកតាថែរក្សានៅទីស័ក្តិសិទ្ធិទាំងនោះដែលមិនអាចខ្វះបានឡើយ។ កិច្ចពិធីបានចាប់ផ្តើមដោយការសូត្រនមស្សការ រឭកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងឆាកហ៊ោ បួងសួងដល់វត្ថុស័ក្តសិទ្ធិ អញ្ជើញដល់អ្នកតា ម្ចាស់ទឹកម្ចាស់ដីឱ្យចូលមកកាន់ទីកន្លែង ដែលអ្នកភូមិបានរៀបចំជូន។

បន្ទាប់ពីចប់កិច្ចពិធីនេះហើយ ភ្លេងក៏ចាប់ផ្តើមប្រគំ អមទៅដោយអ្នកចូលរូប (ស្នងរូបអ្នកតាឬបារមីផ្សេងៗ) រាំវែកតាមចង្វាក់ភ្លេង។ អ្នកតាដែលចូលមកមានច្រើនរូប អត្តចរិតខុសគ្នា ចំណូលចិត្តក៏ខុសគ្នា ខ្លះស្លូតបូត ខ្លះកាច ខ្លះក្រមិច

ក្រមើម ហើយតន្ត្រីក៏ត្រូវប្រគំទៅតាមចំណង់ចំណូលចិត្តរបស់អ្នកតាដែលចូលរូបអ្នកស្នងដែរ បើមិនអ៊ីចឹងទេអ្នកតានឹងខឹង មិនរាំលេង ឬមិនចូលរូបដែលស្នង។ ពេលអ្នកតាចូលរូបហើយ អ្នកស្រុកបានអញ្ជើញឱ្យអ្នកតាសេពសោយអាហារដែលបានរៀបចំជូន ហើយសួរនាំអ្នកតាពីរឿងរ៉ាវផ្សេងៗ ពីការរៀបចំគ្រឿងសំណែន គ្រឿងរណ្តាប់តើរៀបចំត្រឹមត្រូវល្មមគ្រប់គ្រាន់ឬយ៉ាងណា ក្រែងលោមានកំហុសឆ្គងដោយប្រការណាមួយ និងសុំសេចក្តីសុខដល់ខ្លួននិងក្រុមគ្រួសារ។ ឯអ្នកស្រុកដែលមានជំនឿក៏បានសុំឱ្យជួយព្យាបាលជំងឺ សុំទឹកមន្ត និងលាភសក្ការៈផងដែរ។

បើតាមជំនឿរបស់អ្នកស្រុកដែលប្រារព្ធពិធីនេះ គឺដើម្បីឱ្យអ្នកតាដែលថែរក្សាភូមិស្រុកឬទីតាំងស័ក្តិសិទ្ធិបានរាំលេងសប្បាយ ព្រមទាំងអរគុណដល់អ្នកតាម្ចាស់ទឹកម្ចាស់ដីដែលបានផ្តល់ទឹកត្លៀង ធ្វើឱ្យដីមានជីជាតិ មិនឱ្យទឹកទន្លេឡើងខ្លាំង និងធ្វើឱ្យស្រូវគោត់បានភោគផលច្រើន។ មួយវិញទៀត ក៏ធ្វើដើម្បីសុំឱ្យកូនចៅសុខសប្បាយ និងលាបំណន់ដែលបានបែរបន់ចំពោះកសិកម្ម ឬការងារអ្វីផ្សេងក្រែងលោអ្នកតាចាំមាត់ចាំក បើមិនបានធ្វើនាំឱ្យខុសឆ្គងកើតគ្រោះភ័យដល់ខ្លួន និងភូមិស្រុក។ «អ្នកតា» ចំពោះអ្នកស្រុក គឺជាវត្ថុស័ក្តិសិទ្ធិបំផុត ព្រោះជាអ្នកថែរក្សាស្រុក អ្នកឃុំគ្រងកូនចៅឱ្យបានសុខសប្បាយ គួរឱ្យគោរពបូជា មិនអាចមើលងាយឬលេងសើចបានទេ។

តាមការលើកឡើងរបស់ **លោក សេង ធី** នៅសង្កាត់សាលាកន្សែង ខេត្តសៀមរាប ជាអ្នកផ្តួចផ្តើមពិធីឡើងមាឃនៅប្រាសាទអង្គរវត្តមុខផ្លូវចូលទៅតារាជ្យបានប្រាប់ថា ជារៀងរាល់ឆ្នាំឱ្យតែដល់ថ្ងៃ៣កើតខែមាឃ គាត់និងអ្នកភូមិជុំវិញអង្គរតែងតែជួបជុំប្រមូលថវិកាគ្នាតិចតួចដើម្បីធ្វើពិធីឡើងមាឃឬឡើងតារាជ្យមិនដែលខានទេ ព្រោះនេះជាទម្លាប់ពីបរមបុរាណ ហើយចាស់ៗក៏បានផ្តែផ្តាំកុំឱ្យបំភ្លេចទើបខំធ្វើទោះបីមានលុយឬអត់លុយក៏ដោយ។ ម្យ៉ាងពេលធ្វើហើយ កូនចៅក៏បានសុខសប្បាយ រកស៊ីមានបាន សំខាន់យើងបានថែរក្សាបុណ្យពីបុរាណយើងឱ្យនៅស្ថិតស្ថេរតកូនតចៅ។ ចំពោះលោក ប្រាសាទអង្គរមិនត្រឹមតែជាកន្លែងសម្រាប់ទេសចរទស្សនាកម្សាន្តទេ តែជាកន្លែងដ៏ស័ក្តិសិទ្ធិក្នុងការគោរពបូជារបស់ប្រជាជនខ្មែរ ហើយលោក និងអ្នកភូមិប្តេជ្ញាបន្តពិធីនេះជារៀងរហូតឱ្យរស់រវើកនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងផ្នត់គំនិតកូនខ្មែរនៅលើទឹកដីប្រវត្តិសាស្ត្រដ៏អស្ចារ្យនេះផងដែរ៕









ដំណើរទស្សនកិច្ចរបស់សមាជិកសភាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នៅការដ្ឋានអភិរក្សចម្លាក់ថ្មរបស់អាជ្ញាធរជាតិអប្សរានាប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីវ៉ែ្ត រូបភាព ៖ លី វណ្ណា

កាលពីព្រឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៧ គណៈប្រតិភូសភាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ចំនួន៥រូបមាន **លោកស្រី Dagmar Wöhrl, លោក Jürgen Klimke, លោក Waldemar Westermayer, លោក Sascha Raabe** និង**លោក Stefan Rebmann** អមដំណើរដោយ**លោក Thomas Waldraff** ប្រធានអង្គការ GIZ ប្រចាំនៅកម្ពុជា និងមន្ត្រីមួយចំនួនមកពីស្ថានទូតនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ បានបំពេញទស្សនកិច្ចផ្លូវការនៅប្រាសាទអង្គរវត្ត។

គោលបំណងនៃទស្សនកិច្ចផ្លូវការនេះដើម្បីទស្សនានិងស្វែងយល់អំពីកិច្ចការអភិរក្ស ការជួសជុលប្រាសាទ និងចម្លាក់ថ្មរបស់អាជ្ញាធរជាតិអប្សរា ជាពិសេសកិច្ចការអភិរក្សចម្លាក់ថ្មរបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ អនុវត្តដោយអ្នកជំនាញខ្មែរដែលបានទទួលការបណ្តុះបណ្តាលអស់រយៈពេលជាង២ឆ្នាំ ក្រោមជំនួយរួមគ្នារបស់អង្គការ GIZ នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងអាជ្ញាធរជាតិអប្សរា។

ក្នុងដំណើរទស្សនកិច្ចនេះ **លោក លី វណ្ណា** ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារនៃអាជ្ញាធរជាតិអប្សរា ព្រមទាំងមន្ត្រីជំនាញអភិរក្សថ្ម និងអ្នកសម្របសម្រួលបច្ចេកទេសអភិរក្សរបស់អង្គការ GIZ **លោក Sebastian Kerridge** និង **កញ្ញា Federica Grifi** បានទទួលជួបគណៈប្រតិភូ និងពន្យល់អំពីគម្រោងដំណើរការជួសជុលចម្លាក់គោថ្មនៅប្រាសាទអង្គរវត្ត និងបច្ចេកទេសអភិរក្សថ្មទូទៅនៅតំបន់អង្គរ។

លោកស្រី Dagmar Wöhrl ប្រធានដឹកនាំគណៈប្រតិភូសភាអាល្លឺម៉ង់បានមានប្រសាសន៍ថា៖ គណៈប្រតិភូសភាអាល្លឺម៉ងបានមានចំណាប់អារម្មណ៍យ៉ាងខ្លាំងអំពីកិច្ចការអភិរក្សប្រាសាទដែលធ្វើឡើងដោយអ្នកជំនាញខ្មែរផ្ទាល់ ហើយសន្យាថារដ្ឋាភិបាលអាល្លឺម៉ង់នៅតែបន្តគាំទ្រកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈអង្គការ GIZ ក្នុងការបណ្តុះបណ្តាលអ្នកជំនាញខ្មែរ បន្ថែមលើវិស័យអភិរក្ស និងជួសជុលប្រាសាទនៅតំបន់អង្គរ។

សូមរំឭកថាអង្គការ GIZ បាននិងកំពុងបន្តជួយបណ្តុះបណ្តាលអ្នកជំនាញខ្មែរលើវិស័យអភិរក្សថ្មក្នុងក្របខណ្ឌសហប្រតិបត្តិការអន្តរជាតិ និងជំនួយរួមគ្នាជាមួយអាជ្ញាធរជាតិអប្សរា ដែលគម្រោងនេះបន្តរហូតដល់ឆ្នាំ២០២០។









សត្វទោចម្ពុដដ៏កម្រដែលអាជ្ញាធរជាតិអប្សរាព្រលែងក្នុងព្រៃអង្គរកំពុងបង្កើនការបន្តពូជ

ផ្សាយនៅថ្ងៃទី ០៦ ខែ កុម្ភ: ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ Todd Anthony

សត្វទោចម្ពុដ ដែលជាប្រភេទសត្វកម្រ និងជិតផុតពូជនៅលើពិភពលោក ចំនួន០៤ក្បាលត្រូវអាជ្ញាធរជាតិអប្សរាសហការជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance) និងក្រុមហ៊ុនខ្សែយោងអេកូទេសចរណ៍ (Flight of the Gibbon Angkor) យកមកព្រលែងនៅក្នុងរមណីយដ្ឋានអង្គរ កាលពីឆ្នាំ២០១៣ និងឆ្នាំ២០១៥។

ទោចម្ពុដទាំងពីរគូនេះ មួយគូត្រូវបានព្រលែងនៅក្នុងព្រៃម្ពុំប្រាសាទតានៃ និងមួយគូទៀត ត្រូវបានព្រលែងនៅក្នុងព្រៃក្បែរខ្លោងទ្វារខ្មោច។ មកទល់នឹងពេលនេះ សត្វទោចម្ពុដទាំងពីរគូនេះ កើតកូនបានពីរក្បាលហើយ។

តាមការឲ្យដឹងរបស់ក្រុមហ៊ុនខ្សែយោងអេកូទេសចេណ៍នៅប្រាសាទតានៃ **លោក Todd Anthony** បញ្ជាក់ថា ទោចម្ពុដឈ្មោលពណ៌ខ្មៅមានឈ្មោះថា ប៉ាៗ ហើយទោចម្ពុដញីពណ៌សមានឈ្មោះថា ម៉ាៗ។ ដោយឡែកកូនទោចម្ពុដញីពណ៌សតូចជាងគេ ដែលទើបកើតនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥កន្លងទៅ មានឈ្មោះថា ស្រីពេជ្រ។ តាមការសង្កេតកន្លងមកគេអាចឃើញទោចម្ពុដទាំងនោះបាននៅពេលព្រឹកចន្លោះពីម៉ោង៦ទៅម៉ោង១០ព្រឹក។

គួររំឲ្យកថា តាមការសិក្សាជំរឿនសត្វព្រៃកន្លងមក រមណីយដ្ឋានអង្គរធ្លាប់មានសត្វព្រៃជាច្រើនប្រភេទរស់នៅ។ ដោយឡែកសត្វព្រៃប្រភេទទោចម្ពុដនេះក៏ធ្លាប់មានវត្តមានក្នុងតំបន់អង្គរផងដែរ ប៉ុន្តែក្នុងចន្លោះនៃសង្គ្រាមស៊ីវិលមកដល់ពេលបច្ចុប្បន្ននេះ ពួកទោចបានស្លាប់ផុតពូជពីព្រៃនេះទៅហើយ។ ក្នុងគម្រោងស្តារឡើងវិញនូវព្រៃឈើ និងសត្វព្រៃក្នុងឧទ្យានអង្គរ អាជ្ញាធរជាតិអប្សរាគ្រោងនឹងនាំយកប្រភេទសត្វកម្រផ្សេងៗ មកព្រលែងក្នុងព្រៃអង្គរឲ្យបានច្រើន ដើម្បីលើកតម្លៃបរិស្ថានធម្មជាតិ ក្នុងតំបន់អង្គរ ឲ្យកាន់តែវិសេសវិសាលថែមទៀត។


©Todd Anthony


©Todd Anthony


©Todd Anthony


©Todd Anthony

វីដេអូៈសន្ទិសីទសារព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៧និងកិច្ចប្រជុំពេញអង្គលើកទី២៣ នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ

ផ្សាយនៅថ្ងៃទី ០៧ ខែ កុម្ភ: ឆ្នាំ ២០១៧ អត្ថបទ ៖ ហេង ប៊ុនឡាយ



ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាបន្តអនុញ្ញាតសំណើរជួសជុលនិងសាងសង់តូចតាច នៅក្នុងតំបន់ការពារឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០៨ ខែ កុម្ភ: ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីវត្ថ៍ រូបភាព ៖ យឿន តាក់

ក្រុមការងារលេខាធិការដ្ឋានសហគមន៍ដែលបានបង្កើតឡើងដោយអាជ្ញាធរជាតិអប្សរា បានដើរតួយ៉ាងសំខាន់ និងជិតស្និទ្ធបំផុតជាមួយសហគមន៍ប្រជាពលរដ្ឋក្នុងតំបន់អង្គរដល់មូលដ្ឋានផ្ទាល់ ដោយមានតួនាទីជាអ្នកសម្របសម្រួលលើផ្នែកអប់រំ សុខភាព អនាម័យ ផ្តល់ប្រឹក្សាផ្សេងៗ ជាពិសេសគឺទទួលនិងអនុញ្ញាតសំណើរជួសជុលឬសាងសង់ខ្នាតតូចភ្លាមៗនៅនឹងកន្លែងដូចជាសង់បន្ទប់ទឹក តសំយ៉ាប ជួសជុលផ្ទះជាដើម។ លើសពីនោះទៀត ក្រុមការងារសហគមន៍ក៏ទទួលរាល់សំណូមពរពីប្រជាពលរដ្ឋដើម្បីយកមកជូនថ្នាក់លើដោះស្រាយនិងពិចារណាផងដែរ។

ជាក់ស្តែងនាព្រឹកថ្ងៃទី០៧ ខែកុម្ភ: ឆ្នាំ២០១៧ ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប បានចុះទៅពិនិត្យសំណើរសុំជួសជុលរបស់ប្រជាពលរដ្ឋចំនួន០៦ករណី នៅភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប។ សំណើរដែលប្រជាពលរដ្ឋបានស្នើសុំនោះមាន៖ ការសុំធ្វើរបង ចាក់ដី ជួសជុលផ្ទះ និងធ្វើផ្ទះថ្មី។ ក្នុងនោះមាន៣ករណីដែលអនុញ្ញាតព្រោះជាសំណើរស្រាល ឯ៣ករណីទៀតដែលមិនអនុញ្ញាត ព្រោះសំណើរនោះជាសំណង់ធំ គឺតម្រូវឱ្យម្ចាស់សំណើរទៅដាក់ពាក្យនៅច្រកចេញចូលតែមួយ របស់អាជ្ញាធរជាតិអប្សរាទើបបាន។

លោក វ៉ន បូទី ប្រជាពលរដ្ឋដែលបានទទួលការអនុញ្ញាតចំពោះសំណើរជួសជុលផ្ទះបានអំពាវនាវដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ការពារឧទ្យានអង្គរ ដែលមានបំណងចង់ជួសជុលផ្ទះឬសាងសង់ផ្ទះថ្មី គឺត្រូវទៅដាក់ពាក្យនៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ឬជម្រាបទៅអាជ្ញាធរមូលដ្ឋានដើម្បីយកសំណើរដាក់ទៅក្រុមសហគមន៍ ជាជាងការលួចធ្វើដោយខុសច្បាប់ដែលនាំឱ្យខូចខាតទាំងសងខាង ហើយចំពោះការសុំច្បាប់នេះក៏មិនមានបង់សេវាកម្មអីដែរ។

លោក យឹម ខុន សមាជិកក្រុមប្រឹក្សាសង្កាត់គោកចកបានប្រាប់ថា កន្លងមករាល់ការងារទាក់ទងនឹងសេវាកម្មផ្សេងៗរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរ ក្រុមការងារលោកតែងសហការយ៉ាងជិតស្និទ្ធិជាមួយអាជ្ញាធរជាតិអប្សរា។ លោកក៏បានសម្តែងនូវសេចក្តីរីករាយចំពោះក្រុមការងារសហគមន៍ ដែលធ្វើឱ្យប្រជាពលរដ្ឋ និងក្រុមការងារលោកកាន់តែងាយស្រួលក្នុងការសំណូមពរនិងបំពេញការងារផ្សេងដោយមិនបាច់ធ្វើដំណើរទៅឆ្ងាយ។ លោកនឹងបន្តការសហការនេះឱ្យកាន់តែល្អ ដើម្បីថែរក្សាតំបន់អង្គរឱ្យមានរបៀបរៀបរយ ពិសេសគឺទប់ស្កាត់ការកើតឡើងនៃសំណង់ថ្មីៗដែលគ្មានការអនុញ្ញាត។

គួរបញ្ជាក់ដែរថា ដើម្បីបង្កភាពងាយស្រួលដល់ប្រជាជនក្នុងតំបន់អង្គរដែលនៅឆ្ងាយពីមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា អគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរាក៏បានសម្រេចបង្កើតក្រុមការងារមួយសម្រាប់ផ្តល់សេវានៅការិយាល័យច្រកចេញ-ចូលតែមួយមាន២ទីតាំង ប្រចាំស្រុកពួក១ និងប្រចាំក្រុងសៀមរាប១។ ក្រុមការងារនេះមានតួនាទី និងភារកិច្ចសហការជាមួយមន្ត្រីប្រចាំការនៅច្រកចេញ-ចូលតែមួយ ដើម្បីពិគ្រោះយោបល់លើការស្នើសុំសេវាសាធារណៈរបស់ប្រជាជន ពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានអង្គរ ការផ្តល់ទម្រង់ពាក្យស្នើសុំ ទទួលពាក្យស្នើសុំ បញ្ជូនឯកសារមកមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរជាតិអប្សរា ដើម្បីពិនិត្យនិងជូនថ្នាក់ដឹកនាំសម្រេច ព្រមទាំងធ្វើរបាយការណ៍ជូនអភិបាលក្រុង/ស្រុកនៃច្រកចេញ-ចូលតែមួយ និងជូនមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរជាតិអប្សរា៕









ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តចុះចែកកញ្ចប់ទារកដល់ពលរដ្ឋឃុំខ្នាត

ផ្សាយនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ អ៊ីសា រ៉ហ៊ីនី

នៅព្រឹកថ្ងៃទី៨ កុម្ភៈ ឆ្នាំ២០១៧ ក្រុមការងារទី៣នៃក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា បាននាំយកកញ្ចប់ទារកទៅចែកដល់ពលរដ្ឋដែលជាស្ត្រីទើបនឹងសម្រាលកូន ដែលស្ថិតនៅឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។ កញ្ចប់ទារកដែលក្រុមការងារចុះចែកនៅព្រឹកនេះ គឺមានចំនួនជាង៥០ ដែលជាអំណោយរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា។

កញ្ចប់ទារកចំនួនជាង៥០កញ្ចប់ ត្រូវបានក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំស្រុកពួក នាំយកទៅចែកជូនដល់គ្រួសារប្រជាពលរដ្ឋនៅក្នុងឃុំខ្នាត។ ក្នុងពិធីនេះមានការចូលរួមពីតំណាងអាជ្ញាធរជាតិអប្សរា តំណាងអាជ្ញាធរស្រុកពួក មេឃុំខ្នាត រួមនិងប្រជាពលរដ្ឋផងដែរ។

មានមតិសំណេះសំណាលក្នុងពិធីនោះ **លោក និន ចាន់សាមៀន** អនុប្រធានក្រុមការងារសហគមន៍ប្រចាំស្រុកពួក បានរម្លឹកពីប្រវត្តិខ្លះៗនៃការបង្កើតស្ថាប័នអាជ្ញាធរជាតិអប្សរា ក៏ដូចជាតួនាទីក្នុងការអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានអង្គរនាពេលកន្លងមក។ លោកបន្ថែមថា ដោយសារមានអាជ្ញាធរជាតិអប្សរា ទើបរមណីយដ្ឋានអង្គរមានភាពរីកចម្រើនល្បីល្បាញជាលំដាប់ និងដែលបានទាក់ទាញភ្ញៀវទេសចរាប់លាននាក់មកទស្សនាជារៀងរាល់ឆ្នាំ។

លោក និន ចាន់សាមៀន ក៏បានបញ្ជាក់ដែរថា កញ្ចប់ទារកនេះគឺជាអំណោយរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ដោយក្នុងបំណងសង្ឃឹមថា មាតាបិតាទាំងអស់នឹងបន្តផ្តល់ដំបូន្មានល្អៗដល់កូនចៅរបស់ពួកគេ ដើម្បីចូលរួមជួយអភិរក្សរមណីយដ្ឋានអង្គរតទៅមុខទៀត ធ្វើយ៉ាងណា សំដៅឲ្យរមណីយដ្ឋានមួយនេះ នៅថែរក្សាទេសភាពវប្បធម៌ឲ្យស័ក្តសមជារមណីយដ្ឋានបេតិកភណ្ឌពិភពលោក។

គួរឲ្យដឹងផងដែរថា នេះជាលើកទី១១ហើយ ដែលក្រុមការងារសហគមន៍បានចុះចែកកញ្ចប់ទារកដល់អ្នកឃុំខ្នាត ចាប់តាំងពីខែតុលា ឆ្នាំ២០១៥មក ដែលសរុបទាំងអស់ស្មើនឹង៣២៨កញ្ចប់។ សរុបទាំង៣ឃុំ មានឃុំខ្នាត ឃុំដូនកែវ និងឃុំកែវពណ៌ នៃស្រុកពួក ដែលជាគោលដៅសម្រាប់ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា គឺការចុះចែកកញ្ចប់ទារកបានចំនួន ៦៣៧កញ្ចប់ហើយមកពេលនេះ៕









អ្នកជំនាញបេតិកភណ្ឌវប្បធម៌តំបន់ទន្លេមេគង្គចូលជួបសម្តែងការគួរសមជាមួយឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

អ្នកជំនាញបេតិកភណ្ឌវប្បធម៌ ដែលមកពីប្រទេសទាំង៥នៅតាមបណ្តោយទន្លេមេគង្គ គឺកម្ពុជា ថៃ មីយ៉ាន់ម៉ា ឡាវ វៀតណាម ព្រមទាំងប្រទេសឥណ្ឌូនេស៊ី បានមកជួបជុំគ្នាជាមួយអ្នកជំនាញជប៉ុននៃសាកលវិទ្យាល័យសូហ្វីយ៉ា និងអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ដើម្បីពិភាក្សាផ្លាស់ប្តូរបទពិសោធន៍លើកិច្ចការអភិរក្សមរតកបេតិកភណ្ឌ តាមរយៈការរៀនសូត្រទ្រឹស្តី និងការចុះអនុវត្តនៅលើទីតាំងផ្ទាល់។

ក្នុងថ្ងៃចាប់ផ្តើមនៃសិក្ខាសាលានាព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧នេះ ក្រុមសិក្ខាកាមដែលដឹកនាំដោយ **លោកសាស្ត្រាចារ្យ Yoshiaki Ishizawa** ប្រធានមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សនៃសាកលវិទ្យាសូហ្វីយ៉ា បានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរា។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាម អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលស្វាគមន៍គណៈប្រតិភូ និងសិក្ខាកាមទាំងអស់ដោយភាពស្និទ្ធស្នាល និងសម្តែងការគាំទ្រនូវសកម្មភាពរបស់សាកលវិទ្យាល័យសូហ្វីយ៉ា ដែលបានរួមចំណែកក្នុងកិច្ចអភិរក្សជួសជុលប្រាង្គប្រាសាទក្នុងឧទ្យានអង្គរនាពេលកន្លងមក ក៏ដូចជាបច្ចុប្បន្ន។ ឯកឧត្តមក៏បានជម្រាបជូនសិក្ខាកាមអំពីតួនាទីអាជ្ញាធរជាតិអប្សរា ដែលផ្តោតសំខាន់លើការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងតំបន់អង្គរ។ ឯកឧត្តមសង្ឃឹមថាសិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹង បទពិសោធន៍ល្អៗបន្ថែមទៀតពីកម្ពុជា ដើម្បីយកទៅអនុវត្តឲ្យបានជោគជ័យនៅតាមបណ្តាប្រទេសរៀងៗខ្លួនប្រកបដោយជំនាញ។

ក្នុងឱកាសនេះដែរ អ្នកជំនាញបេតិកភណ្ឌមកពីប្រទេសមីយ៉ាន់ម៉ា **លោក Aung Zaw Min** បានសម្តែងនូវការកោតសរសើរចំពោះអាជ្ញាធរជាតិអប្សរា ដែលបានទទួលជោគជ័យលើការងារគ្រប់គ្រង និងអភិរក្សតំបន់រមណីយដ្ឋានអង្គរ។ ជាមួយគ្នានេះ លោកក៏បានស្នើសុំឯកសារពាក់ព័ន្ធមួយចំនួនក្នុងការរៀបចំតំបន់ការពារឧទ្យានអង្គរ ដើម្បីធ្វើជាគំរូសម្រាប់រៀបចំតំបន់រមណីយដ្ឋានបេតិកភណ្ឌមួយចំនួននៅប្រទេសរបស់លោក។ ជាកិច្ចឆ្លើយតប ឯកឧត្តមអគ្គនាយកបានឯកភាពប្រគល់ជូននូវឯកសារពាក់ព័ន្ធមួយចំនួន ក្នុងដំណើរការគ្រប់គ្រងរមណីយដ្ឋានអង្គរ ដែលជាបេតិកភណ្ឌពិភពលោក។

សូមបញ្ជាក់ថា សិក្ខាសាលានេះរៀបចំនៅមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សនៃសាកលវិទ្យាសូហ្វីយ៉ាប្រចាំខេត្តសៀមរាប ចាប់ពីថ្ងៃទី៩ ដល់ទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧។ ក្រៅពីចែករំលែកបទពិសោធន៍លើការងារអភិរក្សជួសជុល និងគ្រប់គ្រងតំបន់បេតិកភណ្ឌ សិក្ខាកាមនឹងចុះធ្វើកម្មសិក្សានៅតាមបណ្តាប្រាង្គប្រាសាទនានាក្នុងតំបន់អង្គរ និងតំបន់ព្រះវិហារដើម្បីសិក្សាស្វែងយល់លើការអនុវត្តជាក់ស្តែង៕









ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តពិនិត្យនិងអនុញ្ញាតសំណើជួសជុលនិងសាងសង់សំណង់ខ្នាតតូចដល់អ្នកភូមិនគរក្រៅ

ផ្សាយនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ យឹម សាន់ដេ

ប្រជាពលរដ្ឋដែលរស់នៅស្របច្បាប់ក្នុងតំបន់អង្គរតាំងពីយូរណាស់មកហើយ មិនត្រូវបានហាមឃាត់ក្នុងការងារុះរើផ្ទះចាស់ដើម្បីជួសជុល ឬសាងសង់ថ្មីជំនួសនោះឡើយ។ លើសពីនេះទៀត ការសាងសង់តូចៗក៏ត្រូវបានអនុញ្ញាត ដល់មូលដ្ឋានផ្ទាល់ផងដែរ តាមរយៈក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានីមួយៗ ដែលចុះទៅជួបប្រជាពលរដ្ឋជារៀងរាល់សប្តាហ៍។

ជាក់ស្តែងនាព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧នេះ ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប បានចុះទៅពិនិត្យសំណើសុំជួសជុល និងសាងសង់របស់ប្រជាពលរដ្ឋចំនួន១១ករណី នៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ។ សំណើដែលប្រជាពលរដ្ឋបានស្នើសុំនោះមាន៖ ការសុំធ្វើរបង ចាក់ដី ធ្វើបង្គន់ ធ្វើរោងលក់ដូរ ជួសជុលផ្ទះ និងធ្វើផ្ទះថ្មី។ ក្នុងនោះមាន៣ករណីដែលអនុញ្ញាតព្រោះជាសំណង់តូច ឯ៨ករណីទៀតដែលមិនអនុញ្ញាត ព្រោះសំណើនោះជាសំណង់ធំ គឺតម្រូវឱ្យម្ចាស់សំណើទៅដាក់ពាក្យនៅច្រកចេញចូលតែមួយរបស់អាជ្ញាធរជាតិអប្សរាទើបបាន៕









អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាផ្តល់បទពិសោធន៍គ្រប់គ្រងរមណីយដ្ឋានអង្គរដល់ក្រុមនិស្សិតមកពីប្រទេសកូរ៉េ

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ សេន សែត

និស្សិតនៃសាកលវិទ្យាល័យកូរ៉េ (Korea University) ចំនួន១២នាក់ ដឹកនាំដោយ **លោកសាស្ត្រាចារ្យ Robert Rudolf** និង**លោកសាស្ត្រាចារ្យ Cuz Potter** បានមកទទួលបទពិសោធន៍លើការគ្រប់គ្រងរមណីយដ្ឋានអង្គរពីមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរា។

ដំណើរទស្សនកិច្ចមកកាន់តំបន់បេតិកភណ្ឌពិភពលោកអង្គរ នៃនិស្សិតសាកលវិទ្យាល័យកូរ៉េ នៅពេលនេះ ត្រូវបានរៀបចំឡើងដោយភ្នាក់សហប្រតិបត្តិការអន្តរជាតិ KOICA តាមរយៈកម្មវិធីអភិវឌ្ឍន៍ និងសហប្រតិបត្តិការអន្តរជាតិ នៃសាកលវិទ្យាល័យកូរ៉េ ក្នុងគោលបំណងសិក្សាស្វែងយល់ពីការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ នៃអាជ្ញាធរជាតិអប្សរាទាំងផ្នែកការងារអភិរក្ស ជួសជុល និងការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់អង្គរ។

ឯកឧត្តម ហង់ ពៅ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា បានធ្វើបទបង្ហាញយ៉ាងលម្អិតអំពីការងារទូទៅ នៃអាជ្ញាធរជាតិអប្សរាក្នុងការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ ជាពិសេស គឺការអភិរក្សជួសជុលប្រាង្គប្រាសាទ សារៈសំខាន់នៃប្រព័ន្ធគ្រប់គ្រងទឹកក្នុងតំបន់អង្គរ ការគ្រប់គ្រងបរិស្ថាន ការគ្រប់គ្រងសហគមន៍ក្នុងតំបន់អង្គរ។ល។

ជាមួយគ្នានេះ មន្ត្រីជំនាញនៃក្រុមអនុវត្តផែនការគ្រប់គ្រងទេសចរណ៍អង្គរ TMP **លោក ភួង សុភក្ត្រ** ក៏បានធ្វើបទបង្ហាញជូនក្រុមនិស្សិតអំពីដំណើរការគ្រប់គ្រងទេសចរណ៍អង្គរ។ មន្ត្រីជំនាញរូបនេះបានសង្កត់ធ្ងន់អំពីកំណើនទេសចរណ៍ជារៀងរាល់ឆ្នាំក្នុងតំបន់អង្គរ ដែលជំរុញឲ្យក្រុមការងារត្រូវយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រង ដូចជា ការរៀបចំលំហូរទេសចរណ៍ ការដាក់ចេញនូវក្រមប្រតិបត្តិអង្គរជូនភ្ញៀវទេសចរគោរព និងការរៀបចំហេដ្ឋានរចនាសម្ព័ន្ធដើម្បីបម្រើដល់វិស័យទេសចរណ៍ជាដើម។

នេះជាមិនមែនជាលើកទី១ទេ កន្លងមកមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាក៏ធ្លាប់បានធ្វើបទបង្ហាញជូននិស្សិត អ្នកជំនាញ និងអ្នកស្រាវជ្រាវជាតិ-អន្តរជាតិជាច្រើន ដែលមានបំណងចង់ស្វែងយល់ពីការងារគ្រប់គ្រងបេតិកភណ្ឌពិភពលោកអង្គរ។ នេះក៏ជាការបង្ហាញឲ្យឃើញពីធនធានមនុស្សអាជ្ញាធរជាតិអប្សរា ដែលមានសមត្ថភាពគ្រប់គ្រាន់ទាំងការងារអនុវត្តជាក់ស្តែង ក៏ដូចជាការចែករំលែកនូវបទពិសោធន៍របស់ខ្លួនទៅកាន់ឆាកអន្តរជាតិដែរ៕









រកត្រីត្រៀមឡើងមាយ ទំនៀមអ្នកស្រុកអង្គរដែលនៅបន្តរហូតដល់បច្ចុប្បន្ន

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ លឹម ស្រ៊ូ , ហ៊ឹង ស្រីរ័ត្ន

ជារៀងរាល់ឆ្នាំឱ្យតែដល់ខែមាឃ (៣កើតខែមាឃ) អ្នកភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង តែងតែនាំគ្នាប្រារព្ធពិធីរកត្រីដើម្បីត្រៀមឡើងមាយឬឡើងអ្នកតាតាមទំនៀមអ្នកស្រុកមិនដែលខកខាន។ ពិធីនេះតែងធ្វើឡើងនៅត្រពាំងបឹងដែលសហគមន៍បានអភិរក្សទុកមិនឱ្យមានការលួចនេសាទឡើយ គឺរហូតដល់មានការណាត់គ្នាពីលោកមេភូមិថាកំណត់ថ្ងៃណាមួយដើម្បីនេសាទ ទើបអ្នកភូមិនាំគ្នាទៅរកត្រីបាន។

តាមការបញ្ជាក់ពី **លោក ពេជ្រ យិន** មេភូមិបង្គោងបានប្រាប់ថា ឱ្យតែដល់ថ្ងៃ១កើតខែមាឃ គាត់តែងប្រកូកប្រកាស និងកំណត់ពេលវេលាដល់អ្នកភូមិឱ្យនាំគ្នាទៅចាប់ត្រីនៅត្រពាំងបឹង ដើម្បីយកទៅធ្វើទឹកនំបញ្ចុក និងធ្វើអាហាររួមសម្រាប់ពិធីឡើងមាយ ឬឡើងអ្នកតានៅថ្ងៃ៣កើតតាមទំនៀមបុរាណ តែឆ្នាំនេះយឺតពេលបន្តិចដោយសារសាលាឆទានមិនទាន់ធ្វើ ហើយឯទឹកត្រពាំងបឹងនេះក៏នៅច្រើន។

លោកមេភូមិបន្តទៀតថា ទិន្នផលត្រីឆ្នាំនេះមានតិចជាងឆ្នាំមុន តែប្រជាជននៅតែអាចរកបាន ហើយអ្នកដែលអាចចាប់ត្រីនៅត្រពាំងបឹងបាននៅថ្ងៃនេះក៏មានតែអ្នកភូមិបង្គោងដែរ។ ត្រពាំងបឹងត្រូវបានថែរក្សាការពារយ៉ាងល្អពីប្រជាការពារក្នុងភូមិ មិនឱ្យមានអ្នកក្រៅមកនេសាទឡើយ ហើយហាមដាច់ខាតប្រើម៉ាស៊ីនឆក់និងអូសមោង។ ចំពោះការរកត្រីដើម្បីយកទៅធ្វើពិធី ក៏អនុញ្ញាតឱ្យប្រជាជនប្រើតែឧបករណ៍បុរាណដូចគ្នា មានឈ្នាង អង្រុត សំណាញ់ជាដើម។ លោក និងអ្នកភូមិបានប្រកាន់នូវទំនៀមនេះណាស់ ទោះបីពេលខ្លះយឺតយូរក្នុងការប្រារព្ធ តែមិនដែលខកខានឆ្នាំណាឡើយ ហើយការធ្វើពិធីនេះក៏នាំមកនូវសេចក្តីសុខសប្បាយ ភាពរីករាយ ការជួបជុំគ្នា និងការរួមគ្នាថែរក្សាមរតកអរូបីមួយនេះឱ្យនៅមានជីវិតដល់បច្ចុប្បន្នទុកឱ្យកូនចៅដឹង ព្រមទាំងបន្តធ្វើតាមពេលអត់ពីពួកគាត់ទៅ។

ពាក់ព័ន្ធនឹងកិច្ចពិធីនេះ **លោក អ៊ឹម សុខរិទ្ធី** អ្នកស្រាវជ្រាវនៃអាជ្ញាធរជាតិអប្សរាបានបញ្ជាក់ថា វាជាផ្នែកមួយនៃបេតិកភណ្ឌអរូបីទាក់ទងនឹងសង្គម គឺជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនជាសំខាន់ មិនផ្តោតខ្លាំងលើជំនឿ សិល្បៈ របាំ ជាកម្មសិទ្ធិឯកជន ឬរបស់រដ្ឋនោះទេ។ វាបានបង្ហាញពីសាមគ្គីភាព និងភាពរស់រវើករបស់សហគមន៍ជនបទ ដែលបាត់បង់ទៅហើយសម្រាប់អ្នកទីក្រុង។ ពិធីនេះនៅសម្បូរព្រៃគុក ខេត្តកំពង់ធំ និងស្រុកខេត្តដទៃក៏មានធ្វើប្រហាក់ប្រហែលគ្នាដែរ ដូចជាអ្នកខ្លះរកត្រី ខ្លះរកសម្ភារៈ ខ្លះរករបស់ផ្សេងៗ ដូច្នេះវាមិនចម្លែកអីឡើយសម្រាប់កិច្ចពិធីនេះនៅសហគមន៍ភូមិបង្គោងក្នុងតំបន់ឧទ្យានអង្គរ។

តំបន់រមណីយដ្ឋានអង្គរ ជាតំបន់បេតិកភណ្ឌរស់សម្បូរទៅដោយមរតកវប្បធម៌អរូបីជាច្រើន ដែលប្រជាជនបន្តប្រតិបត្តិរហូតដល់បច្ចុប្បន្ន។ អាជ្ញាធរជាតិអប្សរាសូមគាំទ្រ និងរួមចំណែកថែរក្សាមរតកវប្បធម៌ជាច្រើនដែលនៅមានក្នុងតំបន់រមណីយដ្ឋានអង្គរតាមរយៈការផ្សព្វផ្សាយ ការចូលរួមផ្ទាល់ជាមួយអ្នកស្រុក ព្រោះវាជាអត្តសញ្ញាណជាតិដ៏ពិសេសមួយធ្វើឱ្យតំបន់អង្គរខុសប្លែកពីតំបន់ដទៃ។ ពិសេសជាងនេះទៅទៀត អាជ្ញាធរជាតិអប្សរាសូមលើកទឹកចិត្តដល់ប្រជាជនទាំងអស់ក្នុងតំបន់អង្គរ ឱ្យរួមគ្នាថែរក្សាមរតកវប្បធម៌ទាំងនេះឱ្យនៅគង់វង្សបានយូរអង្វែងតកូនតចៅគ្រប់ជំនាន់កុំឱ្យបាត់បង់៕









ជំនួបពិភាក្សាការងាររវាងអាជ្ញាធរជាតិអប្សរានិងនគរបាលការពារបេតិកភណ្ឌទទួលបានលទ្ធផលគាប់ចិត្តយ៉ាងខ្លាំង

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

នាព្រឹកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧នេះ ថ្នាក់ដឹកនាំនៃស្ថាប័នដែលពាក់ព័ន្ធនឹងកិច្ចការអភិរក្ស និងការពារបេតិកភណ្ឌអង្គរ គឺអាជ្ញាធរជាតិអប្សរា និងនគរបាលការពារបេតិកភណ្ឌ បានជួបពិភាក្សាការងារមួយចំនួន នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។ កិច្ចពិភាក្សានេះផ្តោតសំខាន់លើការផ្លាស់ប្តូរទីតាំងថ្មី នៃអង្គភាពនគរបាលការពារបេតិកភណ្ឌ នៅមុខប្រាសាទអង្គរវត្ត និងការពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងនគរបាលការពារបេតិកភណ្ឌ ប្រចាំតំបន់រមណីយដ្ឋានអង្គរ។

ជាកិច្ចស្វាគមន៍ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករង និងជាតំណាងឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានធ្វើបទបង្ហាញសង្ខេបអំពីសារវាតារនៃការចុះបញ្ជីអង្គរជាសម្បត្តិបេតិកភណ្ឌពិភពលោក ព្រមទាំងដំណាក់កាលសំខាន់ៗនៃដំណើរការគ្រប់គ្រង រមណីយដ្ឋានអង្គរ ដូចជា ការបង្កើតគណៈកម្មាធិការអោយស៊ីស៊ីអង្គរ ការកំណត់តំបន់ការពារ ការបង្កើតអាជ្ញាធរជាតិអប្សរា ការបង្កើតច្បាប់ការពារបេតិកភណ្ឌនិងនគរបាលការពារបេតិកភណ្ឌជាដើម។

ជាមួយគ្នានេះដែរ ឯកឧត្តមក៏បានសម្តែងនូវការអបអរសាទរចំពោះការឡើងកាន់តួនាទីថ្មី នៃប្រធាននាយកដ្ឋានការពារបេតិកភណ្ឌ គឺ **ឯកឧត្តមឧត្តមសេនីយ៍ ឆី ឡាយ** ។ ឯកឧត្តមបញ្ជាក់ថា ការទទួលបានតួនាទីថ្មីនៃឯកឧត្តមប្រធាននាយកដ្ឋាននៅពេលនេះ នឹងជំរុញកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងនគរបាលការពារបេតិកភណ្ឌឲ្យកាន់តែល្អប្រសើរមួយកម្រិតទៀត។

ឯកឧត្តមឧត្តមសេនីយ៍ ឈី ឆ្លាយ បានបង្ហាញនូវកាពីរការយក្នុងកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា លើការងារការពារបេតិកភណ្ឌ។ ឯកឧត្តមបញ្ជាក់ថា "យើងពិតជាមានសំណាង ដែលបានមកបម្រើព្រលឹងជាតិរបស់យើង។ ខ្ញុំនឹងជំរុញកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរាឲ្យបានកាន់តែល្អប្រសើរថែមទៀត ដើម្បីដោះស្រាយបញ្ហាតូចធំនានារួមគ្នា ក្នុងន័យការពារបេតិកភណ្ឌអង្គរឲ្យបានគង់វង្ស"។

ជាលទ្ធផលនៃកិច្ចប្រជុំ អាជ្ញាធរជាតិអប្សរានិងនគរបាលការពារបេតិកភណ្ឌរក៏ព្រមព្រៀងគ្នាកំណត់យកថ្ងៃចន្ទ ជារៀងរាល់សប្តាហ៍ទី៤នៃខែនីមួយៗ ដើម្បីជួបពិភាក្សាការងារគ្នាជាប្រចាំ ដើម្បីដោះស្រាយបញ្ហាផ្សេងៗរួមគ្នាក្នុងតំបន់អង្គរ។ ក្រៅពីនេះ អង្គប្រជុំក៏បានលើកឡើងនូវបញ្ហាផ្សេងៗមកពិភាក្សារកដំណោះស្រាយ ដូចជា ការរៀបចំសណ្តាប់ធ្នាប់លក់ដូរនៅប្រាសាទអង្គរវត្ត និងអង្គរធំ ការរៀបចំសណ្តាប់អ្នកក្រាលកន្ទេលដាក់អង្រឹងលើវាលស្មៅ មុខប្រាសាទអង្គរវត្តជាដើម៕









ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តចុះអប់រំផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកភូមិជិតទីតាំង

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

ការថែរក្សា ការពារ និងអភិរក្សប្រាង្គប្រាសាទ ទំនៀមទម្លាប់ប្រពៃណីនិងបរិស្ថានដែលជាមរតកដូនតា ដ៏ល្អឯកពីសំណាក់អាជ្ញាធរជាតិអប្សរាតែម្ខាងគឺមិនអាចទៅរួចទេ បើគ្មានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងគ្រប់គូភាគីដែលជាប់ពាក់ព័ន្ធទាំងអស់នោះទេ ។

ដោយសារហេតុផលនេះហើយ បានជាអាជ្ញាធរជាតិអប្សរាបង្កើតក្រុមការងារសហគមន៍ ដើម្បីចុះអប់រំផ្សព្វផ្សាយអំពីបេតិ-កភណ្ឌដល់ប្រជាពលរដ្ឋនៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងគ្រឹះស្ថានសិក្សានានាក្នុងខេត្តសៀមរាបទាំងមូលជាប្រចាំដើម្បីឲ្យគ្រប់គ្នាបានយល់ច្បាស់ពីតម្លៃពិតនៃបេតិកភណ្ឌ ហើយរួមគ្នាជួយថែរក្សាការពារនិងអភិរក្សនូវសម្បត្តិបេតិកភណ្ឌទាំងអស់នោះ។

ជាក់ស្តែងនៅព្រឹកថ្ងៃទី១០ ខែកុម្ភ: ឆ្នាំ២០១៧នេះ ក្រុមការងារសហគមន៍ទី៥ប្រចាំស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ាឯឌី** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរានិងជាប្រធានក្រុមរួមនឹងមន្ត្រីបុគ្គលិកជាច្រើនរូបទៀតបានចុះអប់រំផ្សព្វផ្សាយពីបេតិកភណ្ឌដល់ប្រជាពលរដ្ឋនៅភូមិថ្នល់ទទឹង ឃុំប្រដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាបដើម្បីសហការគ្នាថែរក្សាការពារ និងអភិរក្សបេតិកភណ្ឌ។

មានប្រសាសន៍ក្នុងឱកាសនោះ **ឯកឧត្តម ម៉ី ម៉ាឯឌី** បានលើកឡើងអំពីការដាក់តំបន់អង្គរចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ការបង្កើតស្ថាប័នអាជ្ញាធរជាតិអប្សរាសម្រាប់គ្រប់គ្រងតំបន់អង្គរ សិទ្ធិរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បេតិ-កភណ្ឌ។ បន្ថែមពីនោះទៀត ឯកឧត្តមក៏បានពន្យល់អំពីតួនាទីភារកិច្ច និងកិច្ចការងាររបស់អាជ្ញាធរជាតិអប្សរាក្នុងការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌ និងព្រៃឈើក្នុងតំបន់អង្គរផងដែរ។

លោក ភិន ថោង ក្រុមប្រឹក្សាឃុំ និងមេភូមិថ្នល់ទទឹង បានថ្លែងចំណាប់អារម្មណ៍ថាលោកពិតជាមានការពេញចិត្តណាស់ហើយរីករាយចូលរួមសហការជាមួយអាជ្ញាធរជាតិអប្សរាឲ្យកាន់តែជិតស្និទ្ធបន្ថែមទៀត ដើម្បីអប់រំផ្សព្វផ្សាយពីបេតិកភណ្ឌដល់ប្រជាពលរដ្ឋក្នុងដែនដីរបស់លោក ព្រោះកម្មវិធីនេះល្អ វាបានផ្តល់នូវចំណេះដឹងច្រើនដល់ប្រជាពលរដ្ឋ ធ្វើឲ្យពួកគាត់បានយល់ច្បាស់ពីតម្លៃនិងអត្ថប្រយោជន៍បេតិកភណ្ឌ ព្រមទាំងដឹងពីតួនាទីរបស់ពួកគាត់ត្រូវចូលរួមគ្នាជាមួយអាជ្ញាធរជាតិអប្សរាដើម្បីថែរក្សាបេតិកភណ្ឌដូនតាយើងទាំងអស់គ្នា។









សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ រស់ នៅបរិវេណប្រាសាទបេងមាលា

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
ន.អ.ជ.អ.លជណ
១៧

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើ ងាប់ រស់
នៅបរិវេណប្រាសាទបេងមាលា

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ និងការប៉ះពាល់ដល់ប្រាសាទជាយថាហេតុ និងដើម្បីលើកកម្ពស់សោភ័ណភាពនៅបរិវេណប្រាសាទបេងមាលា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរានឹងធ្វើការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើងាប់ រស់មួយចំនួនដូចខាងក្រោម៖

-កាត់ដកហូតដើមកំចាត់ងាប់ចំនួន ០១ដើម។
-កាត់ដើមសង្កៃចំនួន ០១ដើម (កាត់ពាក់កណ្តាលដើម)។
-កាត់ក្រឹមែកងាប់ និងមែករស់ចំនួន ០៧ដើម (ដើមជ្រៃចំនួន០៥ដើម ដើមសង្កៃចំនួន០១ដើម និងដើមខ្ចីតចំនួន០១ដើម)។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃ ១៣ ខែកុម្ភៈ ឆ្នាំ២០១៧ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាពត៌មាន។

សៀមរាប ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
អគ្គនាយក

ស៊ុំ ម៉ាប់

ចម្លងជូន
-សាលាខេត្តសៀមរាប
-សាលាស្រុកស្វាយលើ
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្មខេត្តសៀមរាប
-អង្គភាពនគរបាលការពារបតិកភណ្ឌប្រចាំខេត្តសៀមរាប
-ផ្នែករដ្ឋបាលព្រៃឈើស្រុកស្វាយលើ
-ស្ថាក់ការអ្នរក្សាងាប់ ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
-ដើម្បីជូនជ្រាប និងសហការ-
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
-ដើម្បីមុខការ-
-ឯកសារ-កាលប្បវត្តិ

អាជ្ញាធរដើម្បីការពារមេណ្ឌលដ្ឋានទីនិងតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh
SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

សេចក្តីផ្ទួនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ រស់ នៅបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភ: ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ១១៣ ប្រ.សជណ
២៧

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើ ងាប់ រស់ នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ជៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ជៀវទេសចរ សាធារណជន និងការប៉ះពាល់ដល់ប្រាសាទជាយថាហេតុ និងដើម្បីលើកកម្ពស់សោភ័ណភាពបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរានឹងធ្វើការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកងាប់ មែករស់មួយចំនួនតាមទីតាំងនានាដូចខាងក្រោម៖

-កាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើសរុបចំនួន**១៧០ដើម** ចាប់ពីផ្លូវចំបក់កំណប់ដល់បរិវេណអង្គរវត្ត ពីផ្លូវមុខអង្គរវត្តដល់ខ្លោងទ្វារទន្លអុំ ពីផ្លូវមុខអង្គរវត្តដល់ព្រលានយន្តហោះ តាមដងផ្លូវកូម៉ៃ និងតាមដងផ្លូវហ្សាដឺហ្គោល។

-កាត់ដកហូតដើមឈើ កាត់ក្រឹមែកឈើ និងកាត់ដើមងាប់ពាក់កណ្តាលសរុបចំនួន**៤៧ដើម** នៅបរិវេណប្រាសាទភិមានអាកាស។

-កាត់ដកហូតដើមឈើ កាត់ក្រឹមែកឈើ និងកាត់ពាក់កណ្តាលដើមសរុបចំនួន **៤០ដើម** នៅក្នុងបរិវេណប្រាសាទបាភួន។

-កាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើសរុបចំនួន**១០៧**ដើមពីខ្លោងទ្វារទន្លអុំរហូតដល់ប្រាសាទបាយ័ន។

-កាត់ដកហូតដើមអំពិលបារាំងងាប់ចំនួន **០២ដើម** នៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប។

-កាត់ដកហូតដើមឈើទាលងាប់ចំនួន **០១ដើម** នៅភូមិខ្ទៀន សង្កាត់គោកចក ក្រុងសៀមរាប។

-កាត់ដកហូតដើមស្ពង់ងាប់ត្រឹមពាក់កណ្តាលដើមចំនួន **០១ដើម** នៅប្រាសាទព្រះពិធូរ។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃ ០៨ ខែ កុម្ភ: ឆ្នាំ២០១៧ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ជៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាពត៌មាន។

សៀមរាប ថ្ងៃទី ០៩ ខែ កុម្ភ: ឆ្នាំ២០១៧
អត្តនាយក

ស៊ុ ម៉ាប់

ចម្លងជូន:
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
"ដើម្បីជូនជ្រាប និងសហការ"
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាលើកពានរដ្ឋបាលខេត្តសៀមរាបដាលើកទី២

ផ្សាយនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ សេន សែត

ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរា បានបន្តលើកពានជើងឯក នៃពានរង្វាន់រដ្ឋបាលខេត្តសៀមរាប ក្រោយពីបំបាក់ក្រុមសាលាក្រុងសៀមរាបក្នុងវគ្គផ្តាច់ព្រ័ត្រ ដោយលទ្ធផល៦ទល់នឹង២កាលពីរាត្រីថ្ងៃសុក្រ ទី១០ ខែកុម្ភៈ ឆ្នាំ២០១៧។

នេះជាការការពារតំណែងជើងឯកបានយ៉ាងល្អរបស់ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរា ដោយឆ្លងកាត់ការប្រកួតចំនួន១៣ប្រកួត មិនស្គាល់ពាក្យថាចាញ់ ក្នុងរដូវកាលទី២នៃពានរង្វាន់រដ្ឋបាលខេត្តសៀមរាប ឆ្នាំ២០១៦-២០១៧នេះ។

កាលពីរដូវកាលទី១ឆ្នាំ២០១៥-២០១៦ ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរា ក៏ជាម្ចាស់ជើងឯងនៃពានរង្វាន់នេះដែរ ក្រោយយកឈ្នះក្រុមមន្ទីរបរិស្ថានខេត្តសៀមរាប ដោយលទ្ធផល៣ទល់នឹង២ ក្នុងវគ្គផ្តាច់ព្រ័ត្រ។

ពានរង្វាន់រដ្ឋបាលខេត្តសៀមរាបត្រូវបានរៀបចំឡើងរយៈពេល២ឆ្នាំហើយ ដោយប្រមូលផ្តុំមន្ត្រីរាជការ និងបុគ្គលិកបម្រើការងារនៅតាមមន្ទីរ ស្ថាប័នពាក់ព័ន្ធនានាក្នុងខេត្តសៀមរាបចូលរួមប្រកួតវិលជុំសន្សំពិន្ទុ និងជ្រើសរើស៤ក្រុមដែលមានពិន្ទុខ្ពស់ប្រកួតវគ្គខ្វែង។

ក្នុងរដូវកាលនេះ មានក្រុមចំនួន១១ចូលរួមប្រកួត ដោយក្រុមលេខ១បានទៅលើអាជ្ញាធរជាតិអប្សរា ទទួលបានពាន១អមដោយទឹកប្រាក់១លានរៀល លេខ២បានទៅលើសាលាក្រុងសៀមរាបពាន១អមដោយទឹកប្រាក់៦០ម៉ឺនរៀល លេខ៣បានទៅលើមន្ទីរសង្គមកិច្ចពានតូច១អមដោយទឹកប្រាក់៤០ម៉ឺនរៀល និងចំណាត់លេខ៤បានទៅលើក្រុមហានុមានសាលាខេត្ត ទទួលបានពានតូច១អមដោយទឹកប្រាក់៣៤ម៉ឺនរៀល។

ដោយឡែកក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរា ក៏បានទទួលបានទឹកប្រាក់លើកទឹកចិត្តចំនួន២០០ដុល្លារបន្ថែមទៀតពីសំណាក់ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរា ដែលបានប្រគល់ជូនដោយ**ឯកឧត្តម ឥន ប៊ុនស៊ុយ** អគ្គនាយករង ដែលបានអញ្ជើញទៅចូលរួមទស្សនាការប្រកួតផ្ទាល់៕









ប្រជាជននៅភូមិគោកកក់ ឃុំស្វាយចេក ស្រុកអង្គរធំ ប្រគល់បដិមាដែលរើសបានជូនអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីរ័ត្ន រូបភាព ៖ សឿន ប៊ុនសារ

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ **លោក ជឿម ជឿត** រស់នៅភូមិគោកកក់ ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាបបានយកបដិមាមួយបាត់ព្រះកេស ដៃ និងជើង ដែលរើសបានក្នុងភូមិមកប្រគល់ជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក។ ការប្រគល់ជូននេះ ធ្វើឡើងនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដោយមាន**លោក យិត ចាន់ដារដ្ឋ** ប្រធានស្តីទីនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ តំណាង**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** ជាអ្នកទទួល។

លោក ជឿម ជឿត បានឱ្យដឹងថា រូបគាត់មិនមែនជាអ្នករកឃើញបដិមានេះទេ គឺអ្នកភូមិម្នាក់ទៀតបានឃើញនៅពេលដាំស្វាយក្នុងចម្ការ។ អ្នកភូមិនោះក៏យកទៅទុកនៅផ្ទះ តែរាល់យប់កូនរបស់គាត់ចេះតែដេកយំជារៀងរាល់យប់ ដូច្នេះក៏យកទៅដាក់ចោលនៅគល់ដើមគ្រាច។ ថ្ងៃមួយរូបលោក ជើរទៅប្រទះឃើញ ក៏សួរនាំដឹងរឿងរ៉ាវ គាត់ក៏សុំយកទៅរក្សាទុកនៅផ្ទះបានប្រហែលមួយអាទិត្យ ទើបបានជួបនឹងក្រុមការងារអាជ្ញាធរជាតិអប្សរា ហើយក៏សួរនាំដើម្បីយករូបនេះមកអភិរក្ស។ បងប្រុសបានបង្ហាញពីក្តីស្រឡាញ់ចំពោះមរតកវប្បធម៌នេះថា បើទោះបីជាគាត់មិនស្គាល់ថានេះជារូបអ្វី ធ្វើពីឆ្នាំណាតែគាត់ជឿជាក់ថាវាជារបស់បុរាណ ជារបស់ជាតិ មិនចង់ឱ្យបាត់បង់ ទើបយកវត្ថុនេះមកប្រគល់ដើម្បី ចៀសផុតពីការជួញដូរ។

តាងនាមឱ្យឯកឧត្តមអគ្គនាយក **លោក យិត ចាន់ដារដ្ឋ** បានថ្លែងអំណរគុណដល់**លោក ជឿម ជឿត** ប្រជាជនគំរូ និងគួរឱ្យកោតសរសើរចំពោះការយកចម្លាក់ដែលប្រទះឃើញមកប្រគល់ជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក។ លោកនឹងស្នើអ្នកជំនាញបុរាណវិទ្យាឱ្យមកពិនិត្យបដិមានេះ និងវាយតម្លៃអំពីបុរាណភាពវិនិច្ឆ័យអំពីកាលបរិច្ឆេទ និងរចនាប័ទ្ម។ អាជ្ញាធរជាតិអប្សរានឹងចេញលិខិតថ្លែងអំណរគុណនិងឧបត្ថម្ភជាកិច្ចតបស្នងដល់គាត់ ព្រោះរាល់កិច្ចការអភិរក្សវត្ថុបុរាណ និងប្រាសាទក្នុងតំបន់អង្គរ បើគ្មានការចូលរួមពីប្រជាជន អាជ្ញាធរមូលដ្ឋានដី ពិតជាលំបាកក្នុងការទប់ស្កាត់ការបំផ្លាញ និងការជួញដូរវត្ថុបុរាណទាំងនេះណាស់។

លោក ជារដ្ឋ បន្ថែមថា សកម្មភាពនេះសបញ្ជាក់ឱ្យឃើញនូវ សកម្មភាពអប់រំផ្សព្វផ្សាយបេតិកភណ្ឌកន្លងមករបស់អាជ្ញាធរជាតិអប្សរាទៅកាន់សហគមន៍ពិតជាធ្វើឱ្យប្រជាជនមានការយល់ដឹងពីតម្លៃនៃវត្ថុបុរាណ និងប្រាសាទដែលត្រូវចូលរួមការ

ពារទាំងអស់គ្នា។ លោកក៏បានសំណូមពរផងដែរ ចំពោះប្រជាជនដែលបានរកឃើញវត្ថុបុរាណ សូមប្រគល់ជូនអាជ្ញាធរជាតិអប្សរារក្សាទុក ដើម្បីស្រាវជ្រាវពីប្រភពដើមរបស់វត្ថុទាំងនោះ ចៀសវាងការយកទៅលក់ដូរ ដែលជាអំពើខុសច្បាប់ និងបំផ្លាញរតនវត្ថុរបស់ជាតិខ្លួន៕









កិច្ចសម្ភាសន៍ ឯកឧត្តម សុខ សង្ហារ អគ្គនាយករងអាជ្ញាធរជាតិអប្សរា ស្តីពីការទាក់ទាញភ្ញៀវទេសចរតាមរយៈគេហទំព័រ www.angkor.com.kh ក្នុងកម្មវិធីពីកម្ពុជា របស់ BTVNews កាលពីថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៧



ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា៣ក្រុម ចុះពិនិត្យសំណើជួសជុល និងអនុញ្ញាតបានចំនួន១២ករណី

ផ្សាយនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី , កែវ វិបុល

នាព្រឹកថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០១៧នេះ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣ក្រុម គឺក្រុមការងារប្រចាំស្រុកប្រាសាទបាគង ស្រុកអង្គរធំ និងក្រុងសៀមរាប បានចុះទៅជួបប្រជាពលរដ្ឋ និងដោះស្រាយសំណើ សុំជួសជុលផ្សេងៗ តាមការស្នើសុំរបស់ពួកគាត់។ ជាមួយគ្នានេះក៏បាននាំយកកញ្ចប់ទ្រទ្រង់សុខុមាលភាពមាតា និងទារកទៅចែកជូនស្ត្រីទើបសម្រាលកូនចំនួន១០នាក់ផងដែរ។

ក្រុមការងារបានអនុញ្ញាតសំណើសុំជួសជុលតូចៗចំនួន១២ករណី ដូចជាការផ្លាស់សសរផ្ទះ តសំយ៉ាប និងជួសជុលជញ្ជាំងផ្ទះជាដើម។ ដោយឡែក សំណើសុំចំនួន៣ករណីផ្សេងទៀតនៅក្រុងសៀមរាប ដែលស្នើសុំរុះរើផ្ទះចាស់ហើយសាងសង់ថ្មី មិនត្រូវបានអនុញ្ញាតដោយផ្ទាល់ឡើយ តែក្រុមការងារបានណែនាំឲ្យម្ចាស់ផ្ទះដាក់ពាក្យស្នើសុំទៅមជ្ឈមណ្ឌល សេវាកម្មនៃអាជ្ញាធរជាតិអប្សរា ព្រោះសំណើទាំងនោះជាសំណង់ធំ ដែលត្រូវការក្រុមជំនាញចុះពិនិត្យល្អិតល្អន់។

លោក វ៉ាន់ ចាន់ថន ពលរដ្ឋនៅភូមិប្រិយចាស់ សង្កាត់ទឹកវិល ក្រុងសៀមរាប បានបង្ហាញនូវភាពសប្បាយរីករាយ ដែលក្រុមការងារបានចុះមកពិនិត្យផ្ទះរបស់លោក និងបានអនុញ្ញាតសំណើរបស់លោកក្នុងការជួសជុលជណ្តើរ ជួសជុលជញ្ជាំង និងធ្វើរបងជុំវិញផ្ទះ។ លោកក៏បានអំពាវនាវដល់ប្រជាពលរដ្ឋដទៃទៀត ដែលរស់នៅស្របច្បាប់ក្នុងរមណីយដ្ឋានអង្គរ មានបំណងជួសជុលផ្ទះសម្បែង សូមទាក់ទងទៅអាជ្ញាធរមូលដ្ឋាន និងស្នើសុំទៅអាជ្ញាធរជាតិអប្សរាដោយផ្ទាល់ ដៀសវាងការពឹងពាក់ជនណាម្នាក់ ដែលអាចនាំឲ្យចាញ់បោកគេបាន ព្រោះការដាក់ពាក្យស្នើសុំជួសជុល ឬសាងសង់ គឺមិនមានការបង់កម្រៃឡើយ។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ត្រូវបានបង្កើតឡើងដើម្បីផ្សព្វផ្សាយអំពីបេតិកភណ្ឌ បញ្ជ្រាបចំណេះដឹងដល់ប្រជាពលរដ្ឋ ដើម្បីឲ្យពួកគាត់បានចូលរួមក្នុងកិច្ចការពារបេតិកភណ្ឌ។ ទន្ទឹមនឹងនេះ ក្រុមការងារសហគមន៍ក៏បានឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលស្នើសុំជួសជុលតិចតួច និងអនុញ្ញាតជូនភ្លាមៗនៅនឹងមូលដ្ឋាន ដើម្បីសម្រួលដល់ពេលវេលា និងការធ្វើដំណើររបស់ពួកគាត់។ លើសពីនេះទៀត ក្រុមការងារសហគមន៍ក៏ជាក្រុមជួយសង្គ្រោះបន្ទាន់ក្នុងករណីគ្រោះថ្នាក់ធម្មជាតិដែលកើតមានឡើងចំពោះប្រជាពលរដ្ឋក្នុងតំបន់អង្គរ និងនាំយកអំណោយចែកជូនស្ត្រីទើបសម្រាលកូនជាដើម៕









អង្គរនឹងទទួលឆ្នើជាទីតាំងសម្រាប់ការចាក់បញ្ចាំងភាពយន្តខ្នាតអន្តរជាតិ រឿង មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ

ផ្សាយនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត

ខ្សែភាពយន្តបែបប្រវត្តិសាស្ត្រ ដែលរឿកអំពីប្រវត្តិដ៏ជូរចត់នៃរបបវាលពិឃាត ដឹកនាំផលិតដោយ**លោកស្រី** Angelina Jolie ជាតារា និងជាផលិតករដ៏ល្បីរបស់ Hollywood នឹងត្រូវចាក់បញ្ចាំងជាលើកដំបូងបង្អស់នៅលើវាលស្មៅនៃព្រះលាន ជល់ដំរី នាថ្ងៃទី១៨-១៩ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនីនាថ សីហនុ** ។

ខ្សែភាពយន្តរឿង មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ ត្រូវបានថតនៅក្នុងទីតាំងសំខាន់ៗជាប្រវត្តិសាស្ត្រចំនួន២គឺ ខេត្តសៀមរាប និងខេត្តបាត់ដំបង ជាពិសេស តំបន់រមណីយដ្ឋានអង្គរ ក៏ជាផ្នែកមួយដ៏សំខាន់ដែលខ្សែភាពយន្តបានផ្តិតយកទិដ្ឋភាពជាប្រវត្តិសាស្ត្រមួយចំនួនធំ។ ដូចនេះហើយ បានជាផលិតករភាពយន្តសម្រេចចិត្តជ្រើសរើសយករមណីយដ្ឋានអង្គរជាទីតាំងចាក់បញ្ចាំងមុនដំបូងបំផុត ដែលជាពិធីសម្ពោធផ្លូវការមុននឹងខ្សែភាពយន្តនេះចាក់បញ្ចាំងនៅរោងភាពយន្តផ្សេងៗទៀត។

អាជ្ញាធរជាតិអប្សរា ដែលជាស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ ក្រោយពីបានទទួលការអនុញ្ញាតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសហការរៀបចំក្នុងការផលិតភាពយន្តដោយជួយសម្របសម្រួលផ្នែកឯកសារ និងទីតាំងថតជាដើម។ ក្នុងព្រឹត្តិការណ៍បញ្ចាំងនេះដែរ អាជ្ញាធរជាតិអប្សរាបានត្រៀមសហការផ្តល់ទីតាំងដើម្បីរៀបចំពិធី ការសម្អាតបរិស្ថាន ការសម្រួលលំហូរទស្សនា ក៏ដូចជារៀបចំកិច្ចការទូទៅផ្សេងៗជាច្រើនទៀត។

នេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយទៀត សម្រាប់រមណីយដ្ឋានអង្គរ ដែលកន្លងមកតែងទទួលរៀបចំនូវព្រឹត្តិការណ៍ ដែលមានការយោងចូលរួមពីសំណាក់ព្រះមហាក្សត្រ ថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាល និងឥស្សរជនល្បីៗលើពិភពលោកជាច្រើនរូបទៀត។ ព្រឹត្តិការណ៍ដ៏សំខាន់នេះ ក៏ជាផ្នែកមួយដែលជួយស្រូបទាញទេសចរឲ្យមកទស្សនាកម្ពុជា ជាពិសេសរមណីយដ្ឋានអង្គរកាន់តែច្រើនឡើងៗ៕





ប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតសាងសង់ផ្ទះនៅតំបន់អង្គរ ថាមានភាពងាយស្រួលក្នុងការស្នើសុំ

ផ្សាយនៅថ្ងៃទី ១៥ ខែ កុម្ភ: ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ លឹម ស្រ៊ូ

តំបន់ឧទ្យានអង្គរដែលមានទំហំ៤០១គីឡូម៉ែត្រក្រឡា ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីខែធ្នូ ឆ្នាំ១៩៩២។ តំបន់នេះត្រូវបានចាត់បញ្ចូលជារមណីយដ្ឋានរស់ដែលសម្បូរដោយទេសភាពធម្មជាតិ ប្រាង្គប្រាសាទ និងប្រជាពលរដ្ឋដែលបន្តរស់នៅរហូតដល់បច្ចុប្បន្ន។ ក្នុងន័យអភិរក្សមរតកបេតិកភណ្ឌជាតិ ក៏ដូចជាការគ្រប់គ្រងរមណី-យដ្ឋានទាំងមូល រាជរដ្ឋាភិបានបានប្រគល់ភារៈកិច្ចឲ្យអាជ្ញាធរជាតិអប្សរាដើម្បី បំពេញកិច្ចការសំដៅធ្វើយ៉ាងណាឲ្យគោរពបានតាមលក្ខខណ្ឌនានារបស់បេតិកភណ្ឌពិភពលោក។

ដោយឈរលើគោលការណ៍រមណីយដ្ឋានមានជីវិតរបស់អង្គរ ទើបមានការអនុញ្ញាតឲ្យប្រជាពលរដ្ឋបន្តរស់នៅលើទីតាំងដែលធ្លាប់រស់នៅពីយូរលង់មកហើយបាន។ ម្យ៉ាងទៀតការសាងសង់ជួសជុលផ្ទះសម្បែង របស់ប្រជាពលរដ្ឋក្នុងតំបន់ជាចំណុច ដែលអាជ្ញាធរជាតិអប្សរាកំពុងបន្តការយកចិត្តទុកដាក់យ៉ាងខ្លាំង។ ការជួសជុលតូចតាច សាងសង់ទ្រុងមាន់ ទ្រុងទា ឬបង្គន់អនាម័យជាដើមនោះ អាជ្ញាធរជាតិអប្សរាបានបង្កើតក្រុមការងារសហគមន៍ដើម្បីចុះពិនិត្យ និងអនុញ្ញាតឲ្យដល់ទីកន្លែងតែម្តង។ រីឯការស្នើសុំសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់ទើបតម្រូវឲ្យមកដាក់ពាក្យស្នើសុំដោយផ្ទាល់នៅអាជ្ញាធរជាតិអប្សរា។ ករណីប្រជាពលរដ្ឋបានបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ អាជ្ញាធរជាតិអប្សរាអនុញ្ញាតឲ្យសាងសង់ ព្រមទាំងគូសប្លង់បច្ចេកទេស និងជួយពិគ្រោះយោបល់សំដៅធ្វើយ៉ាងណាឲ្យការសាងសង់នោះបានប្រើប្រាស់ចំគោលដៅ សន្សំសំចៃថវិកា ព្រមទាំងគោរពបានតាមរចនាបថខ្មែរបុរាណទៀតផង។

ប្រជាពលរដ្ឋដែលមានទីលំនៅនៅភូមិស្រះស្រង់ខាងត្បូង មានផ្ទះនៅក្បែរស្រះស្រង់ផ្ទាល់តែម្តងនោះ **អ្នកមីង ធាន រ្ជន** បានបញ្ជាក់កាលពីព្រឹកថ្ងៃទី១៤ កុម្ភ: ២០១៧ នេះថា អ្នកមីងធ្លាប់ទទួលបានការអនុញ្ញាតឲ្យសាសង់ផ្ទះថ្មីតាំងពីប្រហែល១០ឆ្នាំ មុនមកម្លេះ តែចុងឆ្នាំ២០១៦កន្លងមកនេះដោយសារមានកំណើនសមាជិកក្នុងគ្រួសារបន្ថែមទៀត អ្នកមីងក៏បានស្នើសុំហើយទទួលបានការឯកភាពពីអាជ្ញាធរជាតិអប្សរា ដើម្បីតយ៉ាក ព្រមទាំងសាងសង់បង្គន់អនាម័យបន្ថែមទៀតដើម្បីប្រើប្រាស់។

ចំណែក**លោកពូ ម៉ៅ ម៉ែធ** ជាប្រជាពលដ្ឋរស់នៅភូមិរហាល ដែលកំពុងសាងសង់ផ្ទះជិតរួចរាល់ហើយនោះ ក៏បានបង្ហាញពីភាពងាយស្រួលក្នុងការស្នើសុំច្បាប់សាងសង់នេះដែរ។ **លោក ម៉ែធ** ជាអ្នកខេត្តកំពង់ឆ្នាំង ហើយលោកបានយកគ្រួសារជាអ្នកស្រុកអង្គរ និងបានមករស់នៅទីនេះរយៈពេល២០ឆ្នាំមកហើយ។ លោកអះអាងថា ការសុំច្បាប់សាងសង់នៅក្នុងឧទ្យានអង្គរពុំមានអ្វីពិបាកទេ ដោយគ្រាន់តែគោរពតាមគោលការណ៍របស់អាជ្ញាធរជាតិអប្សរា ក្នុងនោះរួមមានការសាងសង់ត្រូវគោរពទៅតាមប្លង់ដែលចេញដោយអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាជាដើម។

ដោយឡែក**លោកពូ នូ រ៉ូត** ដែលរស់នៅភូមិស្រះស្រង់ខាងជើងវិញ ផ្ទះរបស់លោកសាងសង់ជិតរួចរាល់ហើយ ក្រោយពីមានច្បាប់អនុញ្ញាតត្រឹមត្រូវ។ ដូចគ្នានឹង**អ្នកស្រី ធាន រ្ជន** និង **លោក ម៉ៅ ម៉ែធ លោក រ៉ូត** ថាពុំមានអ្វីជាពិបាកក្នុងការស្នើច្បាប់សាងសង់នោះទេ។ **លោក រ៉ូត** បានសម្តែងការងឿងឆ្ងល់ចំពោះប្រជាពលរដ្ឋខ្លះ ដែលថាការស្នើសុំច្បាប់សាងសង់ក្នុងឧទ្យានអង្គរមានការលំបាក តែសម្រាប់លោកគ្រាន់តែដាក់ពាក្យស្នើសុំត្រឹមជាង២០ថ្ងៃ ក៏ទទួលបានការអនុញ្ញាតភ្លាមៗ។

សរុបសេចក្តីមក ការស្នើសុំច្បាប់សាងសង់ក្នុងឧទ្យានអង្គរពុំមានការលំបាកដូចមហាជនមួយចំនួនលើកឡើងនោះទេ គ្រាន់តែការស្នើសុំត្រូវគោរពទៅតាមគោលការណ៍ដែលអាជ្ញាធរជាតិអប្សរា ក៏ដូចជាគោរពទៅតាមលក្ខខណ្ឌនៃច្បាប់បេតិកភណ្ឌពិភពលោកតែប៉ុណ្ណោះ។ អ្នកស្រុកអង្គរនៅតែអាចរស់នៅប្រកបរបរ និងមានកម្មសិទ្ធិគ្រប់គ្រងអ្វី ដែលជារបស់ខ្លួនតាំងដើមរហូតមក៕









ស្ថាប័នធានាគុណភាពជប៉ុនJQAបើកសវនកម្ម លើការងារបរិស្ថាននៃអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ស្ថាប័នធានាគុណភាពជប៉ុន (Japanese Quality Assurance) នឹងបើកសវនកម្មប្រចាំឆ្នាំលើការងារគ្រប់គ្រងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៥ដល់ទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧។ ពិធីបើកដំណើរការសវនកម្ម បានធ្វើឡើងនៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈនេះ ក្រោមអធិបតីភាព **ឯកឧត្តម សុខ លក្ខិណា** ប្រធានអង្គភាពគ្រប់គ្រងប្រព័ន្ធបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា និងជាតំណាងអគ្គនាយកអាជ្ញាធរជាតិអប្សរា និង**លោក Kozo Sakurada** សវនករនៃស្ថាប័នJQA។

ក្នុងបទបង្ហាញដល់អង្គប្រជុំ **លោក Kozo Sakurada** ពន្យល់ថា សវនកម្មលើកនេះជាប្រភេទសវនកម្មតាមដាន ទៅលើភាពអនុលោមនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន បន្ទាប់ពីអាជ្ញាធរជាតិអប្សរាទទួលបានវិញ្ញាបនបត្រ ISO14001 លើកទី៤ កាលឆ្នាំ២០១៥កន្លងទៅ។ តាមរយៈសវនកម្មនេះ នឹងធ្វើឲ្យក្រុមការងារគ្រប់គ្រងប្រព័ន្ធបរិស្ថាន និងក្រុមជំរុញការងារបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា កាន់តែយកចិត្តទុកដាក់និងមានស្មារតីបន្ថែមទៀត ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

មានប្រសាសន៍ក្នុងពិធីបើកនេះ **ឯកឧត្តម សុខ លក្ខិណា** លើកឡើងថា អាជ្ញាធរជាតិអប្សរាពិតជាមានមោទនភាពណាស់ ដែលអង្គទទួលបានវិញ្ញាបនបត្រ ISO14001 ពីស្ថាប័នជានាគុណភាពរបស់ជប៉ុនជាបន្តបន្ទាប់។ ក្នុងរយៈពេលជាង ១០ឆ្នាំនេះ យើងទទួលបានវិញ្ញាបនបត្រចំនួន៤លើករួចមកហើយ យើងនឹងខិតខំបន្តទៀត ដើម្បីទទួលបានវិញ្ញាបនបត្រ ក្នុងដំណាក់កាលបន្ទាប់ និងដើម្បីភាពស្រស់ស្អាតនៃបរិស្ថានអង្គររបស់យើង។

ជាមួយគ្នានេះដែរ ឯកឧត្តមក៏បានជំរុញឲ្យថ្នាក់ដឹកនាំនិងក្រុមការងារទាំងអស់ ត្រៀមលក្ខណៈ និងទទួលស្វាគមន៍សវនករ JQA ក្នុងដំណើរការធ្វើសវនកម្មពេលនេះ។ ឯកឧត្តមបញ្ជាក់ថា លទ្ធផលដែលយើងទទួលបានកន្លងមក គឺមិនមែនជាស្នាដៃរបស់បុគ្គលណាម្នាក់ឬក្រុមណាមួយឡើយ គឺទទួលបានមកដោយការខិតខំប្រឹងប្រែងរបស់ក្រុមការងារទាំងអស់គ្នា ហើយក៏មិនមែនដើម្បីសម្រាប់តែអាជ្ញាធរជាតិអប្សរាប៉ុណ្ណោះទេ គឺសម្រាប់ប្រជាជនទាំងអស់ និងជាតិរបស់យើងទាំងមូល៕






ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចុះពិនិត្យទីតាំងបញ្ចាំងខ្សែភាពយន្ត "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ"

ផ្សាយនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ យឿន តាក់

ខ្សែភាពយន្តបែបប្រវត្តិសាស្ត្រ ដែលរឿងអំពីប្រវត្តិដ៏ជូរចត់នៃរបបវាលពិឃាត ដឹកនាំផលិតដោយ **លោកស្រី** Angelina Jolie ជាតារា និងជាផលិតកររឿងល្បីរបស់ Hollywood នឹងត្រូវចាក់បញ្ចាំងជាលើកដំបូងបង្អស់នៅលើវាលស្មៅនៃព្រះលាន ជល់ដំរី នាថ្ងៃទី១៨-១៩ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃ **ព្រះករុណាព្រះបាទសម្តេច**

ព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនីនាថ សីហនុ** ។

ដើម្បីត្រៀមខ្លួនរៀបចំពិធីនេះឲ្យដំណើរការទៅដោយរលូន នៅព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧នេះ **ឯកឧត្តមបណ្ឌិត សុំ ម៉ាម៉ ** អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមនឹងថ្នាក់ដឹកនាំជាច្រើនរូបបានចុះត្រួតពិនិត្យការងារ និងពិភាក្សាការងារមួយចំនួន នៅទីលានដល់ដំរី ដែលជាទីតាំងបញ្ចាំងខ្សែភាពយន្ត។

ឯកឧត្តម ហុក ប៉េងសែ អគ្គនាយករង ដែលបានរួមដំណើរចុះត្រួតពិនិត្យទីតាំងនេះបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាបានត្រៀមខ្លួនយ៉ាងល្អ ក្នុងកិច្ចសហការរៀបចំសម្ពោធនិងបញ្ចាំងខ្សែភាពយន្តអន្តរជាតិនៅពេលនេះ។ ឯកឧត្តមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាបានចូលរួមបញ្ជូនអ្នកបច្ចេកទេសរៀបចំទីតាំង សម្រួលលំហូរចរាចរ និងថែរក្សាអនាម័យសណ្តាប់ធ្នាប់ជាដើម។

នាយកបណ្តុះបណ្តាលជំនាញនិងទទួលថតភាពយន្តនៅកម្ពុជា នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ **លោក ជៀប សុវិជ្ជា** ថ្លែងថា ការបញ្ចាំងខ្សែភាពដ៏ធំនេះគឺជាមោទនភាពបំផុតដែលត្រូវបានរៀបចំឡើងនៅតំបន់អង្គរ ជាលើកដំបូងបង្អស់ ក្រោមព្រះរាជវត្តមានរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ។ លោកបញ្ជាក់ថា អ្នកដែលត្រូវអញ្ជើញចូលរួមទស្សនាខ្សែភាពយន្តនេះ គឺក្រៅមន្ត្រីរាជការ និងមន្ត្រីទូតគ្រប់ប្រទេស គឺមានប្រជាពលរដ្ឋដែលបានចូលរួមសម្តែង និងក្រុមបច្ចេកទេស ដែលបានចូលរួមផលិតភាពយន្តកន្លងមក។ **លោក សុវិជ្ជា** ក៏បានបដិសេធនូវព័ត៌មានមួយចំនួនដែលលើកឡើងថា ប្រជាពលរដ្ឋគ្រប់គ្នាអាចចូលទស្សនាបានដោយសេរី ដោយលោកបញ្ជាក់ថា ការចូលទស្សនាគឺត្រូវបានកំណត់តាមចំនួនលិខិតដែលបានអញ្ជើញប៉ុណ្ណោះ៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ទទួលស្វាគមន៍ព្រះរាជដំណើរយាងមកដល់ របស់ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនីនាថ សីហនុ

ផ្សាយនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ លឹម ស្រ៊ូ រូបភាព ៖ ហ៊ុំ រិទ្ធី

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនីនាថ សីហនុ** បានយាងមកដល់ទឹកដីអង្គរខេត្តសៀមរាបហើយ នាព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ នេះ។

តាមគម្រោង ព្រះរាជវត្តមានរបស់ព្រះអង្គទាំងទ្វេនៅលើទឹកដីអង្គរខេត្តសៀមរាបនេះ ព្រះអង្គនឹងយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីកាត់ឫសសីមាព្រះវិហារវត្តស្វាយដង្គំ ស្ថិតក្នុងសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប និងយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីសម្ពោធខ្សែភាពយន្តខ្នាតអន្តរជាតិរឿង "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" នៅព្រះលានដល់ដំរីនៃទីក្រុងអង្គរធំដែលជាអតីតរាជធានីដ៏ឧត្តុង្គឧត្តម នាកំឡុងសតវត្សទី៩ដល់ទី១៥ ។

ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ឆ្មាំ កម្មករ នៃអាជ្ញាធរជាតិអប្សរា និងប្រជាពលរដ្ឋគ្រប់រូប សូមថ្វាយព្រះពរសូមព្រះអង្គទាំងទ្វេ មានព្រះសុវត្ថិភាពក្នុងព្រះរាជដំណើរបំពេញបេសកកម្មនៅលើទឹកដីអង្គរខេត្តសៀមរាប និងសូមប្រសិទ្ធពរ ចំពោះព្រះអង្គទាំងទ្វេ សូមមានព្រះរាជសុខភាពមាំមួន ដើម្បីគង់ជាម្លប់ដ៏ត្រជាក់សម្រាប់ប្រជានុរាស្ត្ររបស់ព្រះអង្គ ទូទាំងព្រះនគរ។









និស្សិតសាកលវិទ្យាល័យតិចណូចុះកម្មសិក្សាស្វែងយល់ពីប្រព័ន្ធគ្រប់គ្រងទឹកនៅតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ យឿន តាក់

និស្សិតមហាវិទ្យាល័យទេពកោសល្យជនបទ នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ហៅសាលាតិចណូ បានចុះកម្មសិក្សាស្វែងយល់ពីប្រព័ន្ធគ្រប់គ្រងទឹកនៅតំបន់អង្គររយៈពេល៤ថ្ងៃ។ និស្សិតទាំងនោះបានទៅស្វែងយល់នៅទីតាំងផ្សេងៗគ្នា ដោយមានការពន្យល់ និងបង្ហាញដោយអ្នកបច្ចេកទេសទឹករបស់អាជ្ញាធរជាតិអប្សរា។

នៅរសៀលថ្ងៃទី១៥ កុម្ភៈ ឆ្នាំ២០១៧ ដែលជាថ្ងៃចុងក្រោយនៃដំណើរចុះកម្មសិក្សាស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងទឹក និស្សិតសាលាតិចណូបានទៅស្វែងយល់អំពីអាងស្នាក់ខ្សាច់នៅកសិណខាងជើងប្រាសាទអង្គរវត្ត។ ពួកគេបានស្តាប់អ្នកជំនាញទឹកពន្យល់ពីដំណើរការមួយៗនៃអាងស្នាក់ខ្សាច់ ដែលដាក់ស្នាក់នៅទ្វារទឹកអូរសំពៅលូនចូលកសិន្ទុអង្គរវត្ត។

លោក ទឹម ឆោម បុគ្គលិកបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងធានទឹករបស់អាជ្ញាធរជាតិអប្សរា បានពន្យល់ពីចរន្តនៃការរៀបចំអាងស្នាក់ខ្សាច់នេះថា វាត្រូវបានបែងចែកជា៣ដំណាក់កាល។ ដំណាក់កាលទី១ គឺការរៀបចំជាជញ្ជាំងពេញដោយមានចោះប្រហោង ហើយតួនាទីរបស់វាសម្រាប់ស្នាក់សំរាមធំៗ មានដូចជាមែកឈើ ចង់ផាស្ទិក សំបកដូង។ល។ ហើយតួនាទី២ វាជួយបន្ថយល្បឿនទឹក កុំឲ្យគួចយកខ្សាច់ទៅក្រៅ។

ចំណែកដំណាក់កាលទី២ **លោក ទឹម ឆោម** រៀបរាប់បន្តថា គេបានរៀបចំជាធ្មេញណារ ឬភាសាបច្ចេកទេសហៅថាជញ្ជាំងឡាប៊ីរីន ដែលគេប្រើវានៅទីតាំងតូចតែចង់បានប្រវែងទឹកហូរវែង។ ជាក់ស្តែងនៅជញ្ជាំងនេះវាមានប្រឡោះ

១៥ម៉ែត្រតែប៉ុណ្ណោះ តែបត់ចុះបត់ឡើងមានប្រវែងសរុប ៤៥ម៉ែត្រ។ ក្នុងអាងនេះ វាធ្វើឲ្យផ្ទៃទឹកខាងលើស្ងប់ និងធ្វើឲ្យខ្សាច់មានលទ្ធភាពធ្លាក់ចុះទៅក្រោមបានលឿន។

សម្រាប់ដំណាក់កាលទី៣វិញ ក៏ទឹកមានភាពស្ងប់ដែរ វាធ្វើឲ្យខ្សាច់ធ្លាក់ចុះ ទើបទឹកហូរចូលទៅក្នុងកសិន្នុ។ តាមការបញ្ជាក់ពីអ្នកបច្ចេកទេសខាងលើ ក្នុងចំណោមអាងស្ទាក់ខ្សាច់ទាំង៣ដំណាក់កាល គឺមានតែអាងទី២ប៉ុណ្ណោះ ដែលអាចស្ទាក់ខ្សាច់បានច្រើនជាងគេ។

សាស្ត្រាចារ្យដឹកនាំកម្មសិក្សា **លោក ឈួន គង់** បានឲ្យដឹងថា និស្សិតដែលចុះកម្មសិក្សានេះ គឺជានិស្សិតដែលទទួលបានអាហារូបករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ហៅកាត់ថា ADB។ ហើយនិស្សិតទាំងនេះមានចំនួន២៩នាក់ ដែលក្នុងគោលបំណងដើម្បីយល់ដឹងពីប្រព័ន្ធគ្រប់គ្រងទឹកនៅតំបន់អង្គរ។

លោកសាស្ត្រាចារ្យបន្តទៀតថា ក្នុងរយៈពេល៤ថ្ងៃនេះ មន្ត្រីជំនាញរបស់អាជ្ញាធរជាតិអប្សរា បាននាំនិស្សិតទៅមើលការងារគ្រប់គ្រងទឹកនៅតំបន់មួយចំនួនរួមមាន នៅប្រាសាទនាគព័ន្ធ ដែលទីនោះនិស្សិតបានដឹងពីការរៀបចំប្រព័ន្ធច្រោះទឹកតាមបែបបុរាណ និងស្គាល់ទីតាំងនោះថាធ្លាប់ជាមន្ទីរពេទ្យសម័យបុរាណ ដែលលោកពុំធ្លាប់ដឹងពីមុនមក។ លោកបន្ថែមថា និស្សិតក៏បានចុះទៅបារាយណ៍ទឹកថ្លា ដើម្បីយល់ដឹងពីការរៀបចំបង្វែរទឹកឲ្យប្រជាពលរដ្ឋប្រើប្រាស់ ការបង្កើតប្រព័ន្ធជារាសាស្ត្រ ការបង្កើតប្រព័ន្ធលូទឹក និងរំដោះទឹកជំនន់។ល។

ក្នុងនោះដែរលោក សាស្ត្រាចារ្យ ក៏បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរា ជាពិសេស **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** ដែលបានផ្តល់អ្នកជំនាញដើម្បីដឹកនាំពន្យល់ក្នុងកម្មសិក្សារបស់និស្សិតទាំង៤ថ្ងៃនេះ។

និស្សិតឆ្នាំទី៥ នៃមហាវិទ្យាល័យទេពកោសល្យជនបទ **កញ្ញា ម៉េង សោភ័ណ្ឌ** បានឲ្យដឹងថា ក្នុងដំណើរចុះកម្មសិក្សាអំពីការគ្រប់គ្រងទឹកនៅតំបន់អង្គរនេះ ធ្វើឲ្យនាងបានយល់ដឹងជាច្រើនអំពីការងារទាំងនេះ។ កញ្ញាបន្ថែមថា វាពិតជាមានភាពអស្ចារ្យណាស់ ក្រោយពីដឹងអំពីការងារគ្រប់គ្រងទឹករបស់អាជ្ញាធរជាតិអប្សរា។

អ្វីដែលពិសេស និងធ្វើឲ្យ**កញ្ញា ម៉េង សោភ័ណ្ឌ** ភ្ញាក់ផ្អើលនោះ គឺការច្រោះទឹកបែបធម្មជាតិ ការវាស់កម្ពស់ទឹកនៅប្រាសាទនាគព័ន្ធ។ ក្រៅពីនេះនាងក៏បានយល់ពីប្រព័ន្ធបញ្ជៀសទឹក អាងស្ទាក់ខ្សាច់ និងបានទៅដល់ទ្វារទឹកប្រាសាទតាសោម ដែលគេសង់ឡើងដើម្បីបង្ការគ្រោះទឹកជំនន់នៅតំបន់អង្គរ ក៏ដូចជាក្រុងសៀមរាបទាំងមូល។

គួរបញ្ជាក់ថា អាងស្ទាក់ខ្សាច់នៅចំណុចទ្វារទឹកអូរសំពៅលូន ត្រូវបានសង់ឡើងនៅអំឡុងឆ្នាំ២០១៥។ អាងនេះមានសារសំខាន់ណាស់ ក្នុងការស្ទាក់ខ្សាច់មិនឲ្យហូរចូលក្នុងកសិន្នុអង្គរ ដែលតាមការព្រួយបារម្ភរបស់អ្នកជំនាញ គឺវាអាចបណ្តាលឲ្យកសិន្នុទាំងមូល រាក់ទៅថ្ងៃខាងមុខ៕






ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមក្នុងព្រះរាជពិធីកាត់ឫសសីមានៅវត្តស្វាយដង្គំខេត្តសៀមរាប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះមហាក្សត្រ

ផ្សាយនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

នាព្រឹកព្រលឹមថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧នេះ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់យាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធី កាត់ឫសីមា ព្រះវិហារនៅវត្តស្វាយដង្គំ ដែលស្ថិតនៅភូមិស្វាយដង្គំ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

ពិធីនេះក៏មានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់នៃព្រះបរមរាជវាំង ថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តសៀមរាប កងកម្លាំងប្រដាប់អាវុធ រួមនឹងពុទ្ធបរិស័ទជិតឆ្ងាយយ៉ាងច្រើនកុះករ។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប ក្នុងនាមអាជ្ញាធរជាតិអប្សរាបានដឹកនាំគណៈប្រតិភូ ដើម្បីចូលរួមដោយផ្ទាល់ក្នុងព្រះរាជពិធីដ៏ឧត្តុង្គឧត្តមនេះ៕









លទ្ធផលសវនកម្ម៖ អាជ្ញាធរជាតិអប្សរានៅតែបន្តកាពវិជ្ជមានលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ!

ផ្សាយនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីតូច្ច រូបភាព ៖ ហ៊ុំ រិទ្ធី

បន្ទាប់ពីបានធ្វើសវនកម្មផ្ទៃក្រៅរយៈពេល៣ថ្ងៃលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ដើម្បីរកភាពអនុលោមឱ្យស្របតាមស្តង់ដារ ISO14001 ពីសំណាក់ស្ថាប័នធានាគុណភាពជប៉ុន (JQA) រួចមក នៅរសៀលថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ នាសាលបេងមាលានៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរាបានប្រារព្ធពិធីបិទសវនកម្មឆ្នាំ២០១៧ហើយ ក្រោមលទ្ធផលដ៏ល្អប្រសើរ គឺអាជ្ញាធរជាតិអប្សរានៅតែបន្តកាពវិជ្ជមានលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរដដែល។

ពិធីបិទវគ្គនេះ ចូលរួមក្រោមអធិបតី**ឯកឧត្តម សុខ លក្ខិណា** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានអង្គភាពគ្រប់គ្រងបរិស្ថានអង្គរ តំណាង **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរា **លោក Kozo Sakurada** សវនករនៃស្ថាប័នធានាគុណភាពជប៉ុន (JQA) រួមទាំងថ្នាក់ដឹកនាំ និងសវនករជាច្រើនរូបនៃអាជ្ញាធរជាតិអប្សរា។

លោក Kozo Sakurada បានថ្លែងថា ការធ្វើសវនកម្មលើកនេះ គឺដើម្បីបញ្ជាក់ពីភាពអនុលោមជាប្រចាំលើប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា នៅក្នុងរយៈពេលនៃសុពលភាពបន្តពីសកម្មភាពសវនកម្មឆ្នាំមុន។ សម្រាប់ឆ្នាំនេះដែរ ក្រុមការងារមិនបានរកឃើញភាពមិនអនុលោមណាមួយចំពោះប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរានោះទេ។ ដូច្នេះ ភាពអនុលោមទៅតាមការទាមទាររបស់ស្តង់ដារបរិស្ថាន ISO 14001 របស់អាជ្ញាធរជាតិអប្សរានៅតែមានបន្តទៀត ពិសេសនឹងមានភាពងាយស្រួលក្នុងការត្រៀមខ្លួនទទួលយកប្រព័ន្ធគ្រប់គ្រងបរិស្ថានថ្មី ក៏ដូចជាទទួលវិញ្ញាបន-

បត្រនៅឆ្នាំ២០១៨ ខាងមុខនេះ។ លោករំពឹងថា តាមរយៈការបន្តសកម្មភាពដូចសព្វថ្ងៃនេះបន្តទៅទៀត ធ្វើឱ្យការកែលម្អ តែតែប្រសើរ និងដំណើរការការងារកាន់តែល្អថែមទៀត ព្រោះគ្រប់នាយកដ្ឋានទាំងអស់នៃអាជ្ញាធរជាតិអប្សរាសុទ្ធតែបាន យកចិត្តទុកដាក់អនុវត្តការងារបានសម្រេចតាមគោលបំណងនៃបេសកម្មរបស់ខ្លួន។

ឯកឧត្តម សុខ លក្ខិណា ក៏បានបញ្ជាក់តាមរយៈសុន្ទរកថារបស់ឯកឧត្តមអគ្គនាយកដែរថា ការធ្វើសវនកម្មជាថ្មីម្តងទៀត នេះ គឺដើម្បីតាមពិនិត្យលើប្រព័ន្ធគ្រប់គ្រងបរិស្ថានស្របតាមស្តង់ដារអន្តរជាតិ ISO 14001។ នេះក៏ជាឆ្នាំបញ្ចប់នូវការ អនុវត្តតាមបែបបទនៃស្តង់ដារ ISO14001 (២០០៤) ផងដែរ ហើយចាប់ពីពេលនេះទៅនឹងត្រូវបន្តអនុវត្តស្តង់ដារថ្មី ISO 14001 (២០១៥) ម្តង។

ឯកឧត្តម ក៏បានវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា តាមនាយកដ្ឋាននានា និងក្រុមការងារជំរុញផ្នែកបរិស្ថាន ដែលធ្វើការងារបានយ៉ាងល្អ។ នេះជាសក្ខីភាពបញ្ជាក់ឱ្យឃើញថា យើងទាំងអស់គ្នា កំពុងយកចិត្តទុកដាក់និងចាប់អារម្មណ៍ខ្លាំងលើការងារបរិស្ថាន។ ឯកឧត្តមសង្ឃឹមថា តាមរយៈសវនកម្មលើកនេះ ពិតជា ផ្តល់នូវគំនិត និងជាគន្លឹះដ៏សំខាន់ៗសម្រាប់ធ្វើការកែលម្អប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរាឱ្យមានភាពល្អ ប្រសើរឡើងស្របតាមចំណុចទាមទារនៃស្តង់ដារ ISO 14001។ អាជ្ញាធរជាតិអប្សរានឹងទទួលយក ហើយប្តេជ្ញាចិត្តកែលម្អ អនុវត្តការងារបរិស្ថានលើចំណុចតាមអង្កេតមួយចំនួន ឱ្យស្របតាមលក្ខខណ្ឌនៃស្តង់ដារ ISO 14001 (២០១៥) ព្រម ទាំងទទួលបានវិញ្ញាបនបត្រថ្មីនេះបន្តទៀត។

គួរបញ្ជាក់ផងដែរថា អាជ្ញាធរជាតិអប្សរាបានអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរស្របតាមស្តង់ដារអន្តរជាតិ ISO 14001 (២០០៤) រយៈពេល១២ឆ្នាំមកហើយ ចាប់ពីឆ្នាំ២០០៤ដល់២០១៦។ ក្នុងនោះដែរ អាជ្ញាធរជាតិអប្សរាបានទទួល វិញ្ញាបនបត្រ ស្តីពីការគ្រប់គ្រងប្រព័ន្ធបរិស្ថានអង្គរស្របតាមស្តង់ដារអន្តរជាតិ ISO 14001 ពីស្ថាប័នធានាគុណភាពជប៉ុន (JQA) ចំនួន៤លើកមកហើយដែរ៕









រយៈពេលពីរសប្តាហ៍ដើមខែកុម្ភៈនេះ អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងអនុញ្ញាតសំណើសុំជួសជុលផ្ទះ និងសាងសង់សំណង់ខ្នាតតូចជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរចាន៥៩ករណី

ផ្សាយនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ ន.ផ្សព្វផ្សាយ

ប្រជាពលរដ្ឋដែលរស់នៅស្របច្បាប់ក្នុងតំបន់អង្គរ មិនត្រូវបានហាមឃាត់ក្នុងការងារជុះរើផ្ទះចាស់ ដើម្បីជួសជុល ឬសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់នោះឡើយ។ មិនត្រឹមតែប៉ុណ្ណោះ ការសាងសង់តូចៗក៏ត្រូវបានអនុញ្ញាតជូនប្រជាពលរដ្ឋដល់មូលដ្ឋានផ្ទាល់ផងដែរ តាមរយៈក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាប្រចាំក្រុងស្រុកទាំង៥ក្នុងតំបន់អង្គរ ដែលចុះទៅជួបប្រជាពលរដ្ឋជារៀងរាល់សប្តាហ៍។

ការចុះប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរ និងការអនុញ្ញាតសាងសង់ផ្ទាល់នៅមូលដ្ឋានគឺជាសេវាកម្មដ៏ល្អមួយ ដែលអាជ្ញាធរជាតិអប្សរា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការជួយសម្រួលការលំបាកដល់ប្រជាជនក្នុងការធ្វើដំណើរឆ្ងាយ និងរង់ចាំពេលវេលាយូរ។

ជាក់ស្តែងនៅក្នុងសប្តាហ៍នេះ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងអនុញ្ញាតសំណើសុំជួសជុលផ្ទះ និងសាងសង់សំណង់ខ្នាតតូចដល់ប្រជាពលរដ្ឋចំនួន៥៩ករណី មានដូចជា សុំចាក់ដី តសំយ៉ាបផ្ទះ ធ្វើផ្ទះបាយ ធ្វើជង្រុក ធ្វើរបងផ្ទះ ធ្វើបង្គន់ ជួសជុលជំបូលផ្ទះ ធ្វើរោងលក់ឥវ៉ាន់ ធ្វើរោងគោ ទ្រុងមាន់ ទ្រុងជ្រូក ។ល។ ដោយសារសំណង់ទាំងនោះជាប្រភេទសំណង់ខ្នាតតូច ។ ចំណែកសំណើសុំសាងសង់សំណង់ខ្នាតធំ មានរុះរើផ្ទះចាស់ សាងសង់ផ្ទះថ្មី ឬសុំពង្រីកផ្ទះជាដើម មិនត្រូវបានអនុញ្ញាតដោយផ្ទាល់នៅនឹងកន្លែងឡើយ គឺតម្រូវឱ្យម្ចាស់សំណើត្រូវដាក់ពាក្យស្នើសុំទៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

ក្រៅពីនេះក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាក៏បានចុះជួបសួរសុខទុក្ខ និងនាំយកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកចែកជូនដល់ស្ត្រីទើបសម្រាលកូនរួចចំនួន១៧៨គ្រួសារផងដែរ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា និងលោកជំទាវ៕


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh

សេចក្តីជូនដំណឹងស្តីពី ការបើកការដ្ឋានសាងសង់ និងរៀបចំកម្មវិធីអភិរក្សបេតិកភណ្ឌ សម្រាប់ព្រឹត្តិការណ៍អង្គរសង្ត្រាន្ត ឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ១៨ ខែ កុម្ភ: ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ១៤១/ រប.លសណ
/១៧

សេចក្តីជូនដំណឹង
ស្តីពី
ការបើកការដ្ឋានសាងសង់ និងរៀបចំកម្មវិធី
"អភិរក្សបេតិកភណ្ឌ" សម្រាប់ព្រឹត្តិការណ៍អង្គរសង្ត្រាន្ត ឆ្នាំ២០១៧

អាជ្ញាធរអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរថយន្តដឹកជញ្ជូនភ្ងៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ងៀវទេសចរ ភ្ងៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីចូលរួមរៀបចំព្រឹត្តិការណ៍អង្គរសង្ត្រាន្ត អបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ព.ស ២៥៦០-២៥៦១ គ.ស ២០១៧ ដែលរៀបចំដោយសហភាពសហព័ន្ធយុវជនកម្ពុជានៅលើទឹកដីសៀមរាប-អង្គរនាពេលខាងមុខនេះ អាជ្ញាធរអប្សរានឹងរៀបចំបើកការដ្ឋានសាងសង់សំណង់ប្រភេទស្រាលមួយចំនួនក្នុងបរិវេណ "និម្មិតភូមិ" ចាស់ដែលមានទីតាំងមុខប្រាសាទអង្គរវត្ត ចាប់ពីថ្ងៃទី២០ ខែកុម្ភ: ឆ្នាំ២០១៧។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរដឹកជញ្ជូនភ្ងៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ងៀវទេសចរ ភ្ងៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

សៀមរាប ថ្ងៃទី ១៧ ខែ កុម្ភ: ឆ្នាំ២០១៧
អគ្គនាយក

ស៊ុ ម៉ាប់

ចម្លងជូន:
- សាលាខេត្តសៀមរាប
- គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជុំវិញខេត្ត
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
- គ្រឹះស្ថានអង្គរ
- សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមអ្នកបើកបរថយន្តដឹកជញ្ជូនភ្ងៀវទេសចរ
- គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះ
- ឯកសារ-កាលប្បវត្តិ

អាជ្ញាធរដើម្បីការពារមេណ៍យដ្ឋាននៃឯរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

សហភាពសហព័ន្ធយុវជនកម្ពុជាប្រារព្ធពិធីប្រុងពលីអង្គរសង្ក្រានលើកទី៥នាឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ អ៊ីសា រ៉ហ៊ីនី

នាព្រឹកថ្ងៃអាទិត្យ ទី១៩ ខែកុម្ភៈ ឆ្នាំ២០១៧ នៅមុខលានដល់ដំរីនៃបរិវេណប្រាសាទបាយ័ន សហភាពសហព័ន្ធយុវជនកម្ពុជា សាលាខេត្តសៀមរាប អាជ្ញាធរជាតិអប្សរា និងស្ថាប័នពាក់ព័ន្ធផ្សេងៗ បានរៀបចំពិធីប្រុងពលីបួងសួងសុំសេចក្តីសុខសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តលើកទី៥ ដែលនឹងប្រារព្ធធ្វើឡើងចាប់ពីថ្ងៃទី១៤ ដល់១៦ ខែមេសា ឆ្នាំ២០១៧ ខាងមុខនេះ។

កម្មវិធីនេះប្រារព្ធឡើងក្រោមអធិបតីភាព **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា **ឯកឧត្តម ឃីម ប៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងមន្ត្រីបុគ្គលិកអាជ្ញាធរខេត្ត មន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា ព្រមទាំងមន្ត្រីបុគ្គលិកនៃស្ថាប័នពាក់ព័ន្ធ យុវជន និងប្រជាពលរដ្ឋជាច្រើននាក់។

ពិធីប្រុងពលីនេះប្រារព្ធឡើងជារៀងរាល់ឆ្នាំតាមទំនៀមបុរាណ មុនចាប់ផ្តើមសាងសង់សំណង់ផ្សេងៗក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន ក្នុងគោលបំណងបួងសួងសុំម្ចាស់ទឹកម្ចាស់ដីរក្សាដែនដីអង្គរ ឱ្យការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រានឆ្នាំថ្មីទទួលបាននូវសេចក្តីសុខចម្រើនដល់ថ្នាក់ដឹកនាំ ក្រុមការងារ និងភ្ញៀវជាតិ-អន្តរជាតិទាំងអស់ដែលចូលមកទស្សនាផងដែរ។

គួរបញ្ជាក់ផងដែរថា នេះជាលើកទី៥ហើយដែលសហភាពសហព័ន្ធយុវជនកម្ពុជា សហការជាមួយមន្ត្រីអាជ្ញាធរខេត្ត អាជ្ញាធរជាតិអប្សរា មន្ត្រីអាជ្ញាធរពាក់ព័ន្ធ និងការចូលរួមពីយុវជនស្ម័គ្រចិត្តគ្រប់ទិសទីរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ដើម្បីផ្តល់ឱកាសឱ្យយុវជននិងសាធារណជនទូទៅបានចូលរួមអបអរពិធីបុណ្យចូលឆ្នាំខ្មែរក្នុងនាមជាមហាគ្រួសារខ្មែរតែមួយ។ លើសនេះទៀត ធ្វើឱ្យយុវជនខ្មែរជំនាន់ក្រោយបានស្វែងយល់នូវភាពរុងរឿង នៃព្រះរាជាណាចក្រកម្ពុជាតាំងពីសម័យមហានគរហូតដល់បច្ចុប្បន្ន ហើយនឹងបន្តរក្សារកេរមរតកវប្បធម៌ដូនតានេះរហូតតទៅ។

តាមរយៈព្រឹត្តិការណ៍អង្គរសង្ក្រាន្តនឹងជួយលើកតម្កើងកិត្តិយសជាតិ វប្បធម៌ជាតិ ឱ្យល្បីរន្ទឺលើសកលលោកផងដែរ ពិសេសគឺស្រូបទាញទេសចរជាតិ-អន្តរជាតិឱ្យចូលមកកម្សាន្តខេត្តសៀមរាបកាន់តែច្រើនកុះករ ដែលជាប្រភពចំណូលដ៏សំខាន់ ជូនប្រជាជនដែលប្រកបរបរទាក់ទងនឹងទេសចរណ៍៕









ភាពយន្តរឿងមុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំបានបញ្ចប់បេសកកម្មនៅលើទឹកដីអង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត

ពិធីសម្ពោធជាផ្លូវការ និងដាក់បញ្ចាំងរឿង មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំរយៈពេល២រាត្រី នៅលើដីអង្គរលើព្រះលានជល់ដំរីនៃក្រុងអង្គរធំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃ**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវរាជមាតាជាតខ្មែរ** បានបញ្ចប់ហើយកាលពីរាត្រីថ្ងៃអាទិត្យទី១៩ ខែកុម្ភៈ ឆ្នាំ២០១៧នេះ។

ភាពយន្តខ្នាតអន្តរជាតិ ដែលដឹកនាំផលិតដោយ**លោកស្រី** Angelina Jolie ជាតារានិងជាផលិតករដ៏ល្បីរបស់ Hollywood ជាខ្សែភាពយន្តបែបប្រវត្តិសាស្ត្រ ដែលរំឲកអំពីប្រវត្តិដ៏ជូរចត់នៃរបបវាលពិយាត ផ្អែកលើជីវិតពិតរបស់ក្មេងស្រីម្នាក់មានអាយុ៦ឆ្នាំនៅពេលនោះ ហើយបានឆ្លងកាត់នូវភាពយង់ឃ្នងយោរយៅ និងសោកនាដកម្មព្រាត់ប្រាសឪពុកម្តាយបងប្អូន ស្ទើរតែបាត់បង់ជីវិតខ្លួនឯងទៀត។

លោកជំទាវ គ្រឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានថ្លែងក្នុងពិធីសម្ពោធភាពយន្តនេះ នារាត្រីថ្ងៃទី ១៨ ខែកុម្ភៈ ថាការផលិតភាពយន្តនេះឡើងវិញ គឺពិតជាបានក្រើនរំឲកប្រជាពលរដ្ឋខ្មែរឲ្យចងចាំនូវរបបដ៏យង់ឃ្នង និងត្រូវប្រយ័ត្នកុំឲ្យព្រឹត្តិការណ៍បែបនេះកើតឡើងម្តងទៀត។ លោកជំទាវក៏បានថ្លែងអំណរគុណដល់ក្រុមផលិតករភាពយន្តនេះ ព្រោះជាសកម្មភាពមួយដែលជួយដល់វិស័យភាពយន្តកម្ពុជាឲ្យមានការរីកចម្រើន និងផ្សព្វផ្សាយទៅកាន់សកលលោក និងស្របដែលតាមគោលនយោបាយភាពយន្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងវិស័យនេះឡើងវិញ។

លោកស្រី Angelina Jolie បានថ្លែងថា លោកស្រីពិតជាអរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុញ្ញាតឲ្យលោកស្រីផលិតភាពយន្តនេះ ជាពិសេស ក្រុមតារា និងប្រជាពលរដ្ឋកម្ពុជា ដែលបានសហការយ៉ាងល្អក្នុងការផលិត។ លោកស្រីបន្តថាកម្ពុជាគឺជាប្រទេសដ៏អស្ចារ្យ គឺដោយសារកម្ពុជានេះហើយ ដែលធ្វើឲ្យលោកស្រីក្លាយជាម្តាយដ៏ល្អម្នាក់រហូតមកទល់នឹងបច្ចុប្បន្ន។ ការផលិតភាពយន្តនេះ ទុកជាសម្តែងនូវការដឹងគុណរបស់លោកស្រីចំពោះប្រទេសកម្ពុជា។



អាជ្ញាធរជាតិអប្សរានាំយកថវិកាទៅជួយឧបត្ថម្ភលោកមេឃុំស្វាយចេកដែលរងគ្រោះដោយភ្លើងឆេះផ្ទះ

ផ្សាយនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

នៅរសៀលថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ **ឯកឧត្តម ហាច់ ពៅ** អគ្គនាយករង និងជាប្រធានក្រុមការងារសហគមន៍ប្រចាំស្រុកអង្គរធំ តំណាង**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិ បានដឹកនាំមន្ត្រីបុគ្គលិកសមាជិកក្រុមការងារសហគមន៍ចុះទៅសួរសុខទុក្ខ និងនាំយកថវិកាទៅជួយឧបត្ថម្ភ **លោក ឈួន ឯម** មេឃុំស្វាយចេក និងក្រុមគ្រួសារដែលរងគ្រោះដោយភ្លើងឆេះផ្ទះស្ថិតនៅភូមិព្រះគោ ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប។

មានប្រសាសន៍ក្នុងឱកាសនោះ **ឯកឧត្តម ហាច់ ពៅ** បានលើកឡើងថា ដោយមានការណែនាំពីឯកឧត្តមអគ្គនាយក ទើបឯកឧត្តមដឹកនាំមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាចុះទៅសួរសុខទុក្ខ និងនាំយកថវិកាចំនួន២លានរៀលដែលជាអំណោយដ៏ថ្លៃថ្លារបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា និងលោកជំទាវទៅជួយឧបត្ថម្ភលោកមេឃុំស្វាយចេក និងក្រុមគ្រួសាររបស់គាត់ ដែលរងគ្រោះដោយអគ្គីភ័យភ្លើងឆេះផ្ទះនៅរសៀលថ្ងៃនេះ។

ឯកឧត្តមបន្តថាថ្វីដ្បិតថវិកានេះមានចំនួនតិចមិនអាចជួយដោះស្រាយបញ្ហាបានទាំងស្រុងពិតមែន ប៉ុន្តែនេះគឺជាទឹកចិត្តដ៏ស្មោះសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាក្នុងការជួយជនរងគ្រោះនៅពេលឧបទ្ទវហេតុអាក្រក់កើតឡើងហើយថវិកានេះវាក៏អាចជួយដោះស្រាយបញ្ហានាពេលនេះបានមួយគ្រាដែរ។ តាំងនាមឲ្យថ្នាក់ដឹកនាំមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាទាំងអស់ សូមចូលរួមសោកស្តាយជាមួយលោកមេឃុំ និងក្រុមគ្រួសារដែលបានជួបគ្រោះអគ្គីភ័យនេះផងដែរ។

លោកមេឃុំ ឈួន ឯម និងក្រុមគ្រួសារពិតជាមានត្រេកអរខ្លាំងណាស់ និងបានអរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរជាតិអប្សរា ដែលបាននាំយកថវិកាមកជួយឧបត្ថម្ភក្រុមគ្រួសារលោកចំពេលដែល កំពុងជួបគ្រោះអាសន្នបែបនេះ ហើយលោក និងក្រុមគ្រួសារ ក៏បានជូនពរថ្នាក់ដឹកនា និងមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាទាំងអស់ជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងសម្រេចជោគជ័យគ្រប់ភារកិច្ច៕









អាជ្ញាធរជាតិអប្សរាជួយផ្នែកបច្ចេកទេសក្នុងការជួសជុលវិហារបុរាណវត្តអារញ្ញសាគរ

ផ្សាយនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

វិហារវត្តអារញ្ញសាគរ គឺជាសំណង់វិហារបុរាណមួយក្នុងចំណោមវិហារជាច្រើនទៀត ដែលមានទីតាំងតាមបណ្តោយស្ទឹងសៀមរាប។ តាមការបញ្ជាក់ពីអ្នកភូមិជិតនេះ វិហារវត្តអារញ្ញសាគរមានអាយុកាលជាង១០០ឆ្នាំ ហើយ ដែលស្ថានភាពសំណង់ទាំងមូលមានសភាពចាស់ទ្រុឌទ្រោម ដែលទាមទារឲ្យមានការជួសជុលជាបន្ទាន់។ ក្នុងបុព្វហេតុអភិរក្សសំណង់វិហារបុរាណ អាជ្ញាធរជាតិអប្សរាបានជួយលើផ្នែកបច្ចេកទេស ដើម្បីជួសជុលវិហារវត្តអារញ្ញសាគរ។

លោក ស៊ឹម ប៊ុនធឿន បុគ្គលិកបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងដែនដី និងលំនៅឋានក្នុងឧទ្យានអង្គរ នៃអាជ្ញាធរជាតិអប្សរា បានថ្លែងថា វិហារវត្តអារញ្ញសាគរគឺជាសំណង់មួយដែលមានលក្ខណៈស្ថាបត្យកម្មដ៏ពិសេស ព្រោះវិហារនេះសង់ឡើងនៅលើខឿនមួយជាន់ ឯតួវិហារ និងសសរជុំវិញគឺកសាងពីឥដ្ឋតាន់។ ចំណែកសសរជុំវិញវិហារមានទម្រង់មួលហើយភាពមួលនោះ គឺធ្វើពីឥដ្ឋមួលស្រាប់ ដែលត្រូវបានរចនាដោយបុព្វបុរសខ្មែរ។ ជាងនេះទៅទៀតនោះ ភាពមួលនៃសសរនីមួយៗ គឺមានភាពខុសៗគ្នាផងដែរ។

តាម**លោក ប៊ុនធឿន** បានលម្អិតពីទម្រង់នៃវិហារអោរញ្ញទៀតថា សសរខាងក្នុង និងគ្រឿងបង្គំដំបូលនៃវត្តអារញ្ញ គឺធ្វើពីឈើទៅតាមរចនាប័ទ្មខ្មែរសុទ្ធសាធ។ លោកបន្តថា ក្នុងដំណើរការជួសជុលសំណង់វិហារនេះ គឺអាជ្ញាធរជាតិអប្សរា បានជួយ

លើផ្នែកបច្ចេកទេស ដោយបានសិក្សាចម្លងប្លង់ចាស់ទុកធ្វើជាឯកសារ ដើម្បីឲ្យប្រាកដថា ការជួសជុលត្រូវគោរពតាមរូបដើមនៃវិហារនេះ។

លោក ប៊ុនធឿន ពន្យល់ថា៖« យើងជួសជុល ដើម្បីទុកជាមរតកទៅថ្ងៃក្រោយ តែការជួសជុលនេះ គឺធ្វើយ៉ាងណារក្សាទម្រង់ដើម ហើយជួសជុលតិចបំផុតតាមតែអាចធ្វើទៅបាន...»។ លោកបន្ថែមទៀតថា ដូចជាសសរនៃវិហារនេះ គឺគ្រាន់តែបកសំបកបាយក្រៀមដែលពុកផុយចេញ ហើយបូកស៊ីម៉ង់ថ្មីតែប៉ុណ្ណោះ។ ចំណែកដំបូលវិញ គឺត្រូវរៀបតាមលំនាំរចនាប័ទ្មដើម ហើយក្បឿងត្រូវដូរថ្មី ដោយទុកក្បឿងចាស់ដែលនៅប្រើបាន សម្រាប់ប្រក់នៅកន្លែងណាមួយនៃដំបូលវិហារ។ ព្រះគ្រូចៅអធិការវត្តអារញ្ញសាគរ **ព្រះសង្ឃ ហ៊ាក់ គឹមហ៊ាត់** មានសង្ឃដីកាថា ព្រះអង្គយល់ស្របចំពោះគំនិតអាជ្ញាធរជាតិអប្សរា។ ព្រះអង្គមានបន្ទូលទៀតថា វាជារឿងដែលល្អប្រសើរបំផុតដែលយើងត្រូវគិតគូរពីការងារបគិកកណ្ឌ ដូចជាសំណង់វិហារបុរាណនេះ ដើម្បីអភិរក្សតទៅថ្ងៃមុខ ជាពិសេសទៀតនោះ ដើម្បីទាក់ទាញភ្ញៀវទេសចរឲ្យមកទស្សនាជាដើម។

តាមសង្ឃដីកាព្រះគ្រូចៅអធិការ កន្លងមកធ្លាប់មានទេសចរបរទេសមួយចំនួន បានចូលទៅទស្សនាក្នុងបរិវេណវត្តពិសេសសំណង់វិហារបុរាណដែលកំពុងជួសជុលនេះ។ លោកគ្រូពឹងថា ក្រោយវិហារនេះជួសជុលរួច នឹងមានទេសចរបន្តមកទស្សនាវត្តអារញ្ញនេះជាបន្តបន្ទាប់ទៀត។

គួរបញ្ជាក់ថា វត្តអារញ្ញមានទីតាំងនៅភូមិអារញ្ញ សង្កាត់សៀមរាប ក្រុងសៀមរាប តាមបណ្តោយស្ទឹងសៀមរាបឆ្ពោះទៅភ្នំក្រោម។ គេមិនអាចកំណត់ពីអាយុកាលច្បាស់លាស់នៃសំណង់វិហារនេះបានទេ ដោយគ្រាន់តែដឹងថា វាមានអាយុកាលជាងរយឆ្នាំមកហើយ នេះបើតាមចាស់ៗដែលពួកគាត់ដឹងឮ។ ខណៈដែលវិហារនេះកំពុងជួសជុល ព្រះគ្រូចៅអធិការវត្តនេះក៏អំពាវនាវរកសប្បុរសជន ដើម្បីជួយចំរិកក្នុងដំណើរការជួសជុលនេះឲ្យបានឆាប់រួចរាល់ផងដែរ៕









កម្មវិធីបណ្តុះបណ្តាលភាសាចិនដល់មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាចាប់ដំណើរការហើយ

ផ្សាយនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ សេន សែត

តាមរយៈកិច្ចសម្របសម្រួលពីស្ថានទូតចិនប្រចាំកម្ពុជា អាជ្ញាធរជាតិអប្សរាបានសហការជាមួយ វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា ដើម្បីបើកកម្មវិធីបណ្តុះបណ្តាលភាសាចិនដល់មន្ត្រីបុគ្គលិកជំនាញចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅ ដែលមានទីតាំងនៅក្នុងវិទ្យាល័យអង្គរ ខេត្តសៀមរាប។

មានប្រសាសន៍ក្នុងឱកាសបើកវគ្គបណ្តុះបណ្តាលដំបូង នារសៀលថ្ងៃទី២០ ខែកុម្ភៈនេះ **លោកស្រី ម៉ម វណ្ណារ័ត្ន** ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាធរជាតិអប្សរា បានសម្តែងនូវអំណរគុណចំពោះអ្នកវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិតសភាកម្ពុជា និងវិទ្យាល័យអង្គរ ក្នុងកិច្ចសហការបង្កើតកម្មវិធីបណ្តុះបណ្តាលភាសាចិនដល់មន្ត្រីបុគ្គលិកជំនាញ នៃអាជ្ញាធរអប្សរា។ លោកស្រីបញ្ជាក់ថា ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាកំពុងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែកជំនាញបច្ចេកទេស និងជំនាញភាសាបរទេស ដើម្បីជំរុញការងារអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរឲ្យមានចីរភាព។

អ្នកសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលភាសាចិននៃវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា ប្រចាំវិទ្យាល័យអង្គរ **លោក លីវ ចិន** បានអរគុណដល់អាជ្ញាធរជាតិអប្សរា ដែលបានជំរុញឲ្យមានកម្មវិធីសិក្សានេះឡើង។ លោកសន្យានឹងប្រឹងឲ្យអស់ពីសមត្ថភាព ដើម្បីជួយបណ្តុះបណ្តាលមន្ត្រីជំនាញក្នុងការរៀនភាសាចិនឲ្យបានលឿន អាចប្រើប្រាស់ក្នុងទំនាក់ទំនងការងារប្រចាំថ្ងៃបាន។ លោកបញ្ជាក់ថា ភាសាចិន មិនលំបាករៀនដូចមនុស្សមួយចំនួនធ្លាប់គិតនោះទេ។

សូមបញ្ជាក់ថា វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា បានបើកបង្ហាត់ថ្នាក់ភាសាចិនដល់សាធារណជនក្នុង វិទ្យាល័យអង្គរ ចាប់តាំងពីឆ្នាំ២០១២មក និងមានសិស្សដែលបានចូលរួមប្រមាណជាង២៣ន់មកហើយ។ ដោយឡែកថ្នាក់បណ្តុះបណ្តាលភាសាចិនដល់មន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា ត្រូវបានរៀបចំឡើង៣ថ្ងៃក្នុងមួយសប្តាហ៍ គឺចន្ទ អង្គារ ពុធ ចាប់ពីម៉ោង៥ដល់ម៉ោង៦ល្ងាច។ មន្ត្រីបុគ្គលិកដែលបានចុះឈ្មោះចូលរៀនក្នុងវគ្គនេះមានចំនួន៧០នាក់៕









សេចក្តីជូនដំណឹងស្តីពីការធ្វើបទបង្ហាញក្រោមប្រធានបទ ការស្វែងយល់ការរស់នៅរបស់ប្រជាជននៅបុរេប្រវត្តិ តាមរយៈការសិក្សាកុលាលភាជន៍ នៅសាលសិក្សាលលៃ នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ

ផ្សាយនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
N°១៤២ /តប.សជ.ណ
១៧

សេចក្តីជូនដំណឹង

អាជ្ញាធរអប្សរា មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីបុគ្គលិក នៃអាជ្ញាធរអប្សរា និងសាធារណៈជន ដែលមានចំណាប់អារម្មណ៍ក្នុងការសិក្សាស្វែងយល់ចូលរួមស្តាប់បទបង្ហាញស្តីពី៖

- ប្រធានបទ៖ "ការស្វែងយល់ការរស់នៅរបស់ប្រជាជននៅបុរេប្រវត្តិតាមរយៈការសិក្សាកុលាលភាជន៍"
- បង្ហាញដោយ ៖ លោក **TSE SIANG LIM** និស្សិតថ្នាក់បណ្ឌិត
  នៃសាកលវិទ្យាល័យ Australian National University
- កាលបរិច្ឆេទ ៖ **ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង៖**១៤:០០ រសៀល**
- ទីកន្លែង ៖ សាលសិក្សា "លលៃ" នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីបុគ្គលិក និងសាធារណៈជន ទាំងអស់ អញ្ជើញចូលរួមស្តាប់ឲ្យបានច្រើនកុះករ។

សៀមរាប ថ្ងៃទី[illegible] ខែកុម្ភៈ ឆ្នាំ២០១៧

បញ្ជាក់៖ ដោយសារកន្លែងមានកំណត់ និងដើម្បីងាយស្រួលរៀបចំ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី បញ្ជូនឈ្មោះ ឬ ចុះឈ្មោះផ្ទាល់ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ឬ តាមរយៈទូរស័ព្ទលេខ 063 765 715 / 017 658 808 ឲ្យបានមុន **ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧** ។

PHNOM PENH :
#41, Russian Blvd.,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 776
Fax : (855-23) 215 771

អាជ្ញាធរដែម្យ៉ាគារមេណ័ឌដ្ឋានទិន្នន័យនិងតំបន់អន្តរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
E-mail : info@apsaraauthority.gov.kh

SIEM REAP :
Bang Kong Village, Ampil Commune, Siem Reap City, Siem Reap Province
Tel: (855-63) 76 55 77 or (855-63) 76 66 76
Fax: (855-63) 76 55 76

ពិធីលៀងមេមត់ មរតកជំនឿរបស់អ្នកស្រុកអង្គរដែលបង្ហាញពីភាពសប្បាយរីករាយ និងជំនឿលើព្រលឹងដូនតាខ្មែរ!

ផ្សាយនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ឹង ស្រីរ័ត្ន

វាជារឿងកម្រសម្រាប់មនុស្សសម័យថ្មីដែលបានគិតគូរ និងជឿស៊ប់លើជំនឿ មូលហេតុដោយសារតែការអប់រំ និងវិទ្យាសាស្ត្រជឿនលឿនខ្លាំង។ ការមិនស្គាល់ពីតម្លៃនិងមិនយកចិត្តទុកដាក់របស់កូនខ្មែរភាគច្រើន រួមផ្សំនឹងការហូរចូលនៃវប្បធម៌បរទេសផងនោះ បានធ្វើឱ្យទំនៀមទម្លាប់ខ្មែរមួយចំនួនដែលជាកេរមរតកដូនតាបន្សល់ទុករាប់សតវត្សមកហើយ ត្រូវបាត់បង់បន្តិចម្តងៗ។

ដោយឡែកប្រជាពលរដ្ឋរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ នៅតែខិតខំរក្សា និងគោរពជំនឿជាច្រើនឱ្យនៅរស់រានរហូតដល់សព្វថ្ងៃ ជាក់ស្តែង «ពិធីលៀងមេមត់»។ ពិធីនេះជាជំនឿមួយក្នុងចំណោមជំនឿជាច្រើន ដែលអ្នកភូមិនគរក្រៅ និងភូមិដទៃទៀតក្នុងរមណីយដ្ឋានអង្គរតែងតែប្រារព្ធធ្វើមិនដែលអាក់ខាន ឱ្យតែដល់ខែមាឃទោះក្នុងថ្ងៃណាក៏បាន ហើយធ្វើពីយប់ដល់ព្រឹក។ ពួកគាត់យល់ថា លៀងមេមត់ជាទំនៀមពីបុរាណ អាចជួយឱ្យជាសះស្បើយពីជំងឺរោគា បណ្តេញខ្មោចព្រាយ បិសាច ឧបទ្រពចង្រៃចេញពីភូមិស្ថាន និងបួងសួងលួងលោមគ្រូបាអាចារ្យ អ្នកតាម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សា ទេវតាថែរក្សាភូមិស្រុក ឱ្យជួយកូនចៅបាននូវសេចក្តីសុខចម្រើន។

សម្រាប់ពិធីចូលមេមត់ឬលៀងមេមត់នៅភូមិនគរក្រៅ តែងតែរៀបចំឡើងនៅផ្ទះរបស់គ្រូធំឈ្មោះ «គង់» ជារៀងរាល់ឆ្នាំ ហើយអ្នកចូលរួមទាំងអស់ត្រូវមកជួបជុំគ្នានៅទីនេះ ដើម្បីរៀបចំគ្រឿងសក្ការៈរបស់ខ្លួនមុននឹងពិធីចាប់ផ្តើមនៅពេលយប់។ គ្រូធំមានតួនាទីមើលការខុសត្រូវអន្ទោងយោងកូនចៅទាំងអស់ដែលមកចូលរួម តែកន្លែងខ្លះទៀតគ្មានគ្រូធំទេ មានតែបុគ្គលប៉ុណ្ណោះ ហើយគេលៀងនៅតែផ្ទះអ្នកឈឺ ដើម្បីឱ្យអ្នកឈឺនោះបានជាសះស្បើយ។

អ្នកចូលរួមក្នុងពិធីមានច្រើននាក់ មានទាំងចាស់ ទាំងក្មេង ស្រីផង ប្រុសផង។ ក្នុងការរៀបគ្រឿងរណ្តាប់ម្ចាស់រូប ត្រូវធ្វើដោយខ្លួនឯងតាមការពេញចិត្តរបស់គ្រូកំណើត ឈ្មួរ និងគ្រូសណ្តិតរូបដែលបានប្រាប់ពេលដែលទៅបូលឃើញ ឬកាលចូលរូបលើកមុន។ ចំពោះគ្រឿងរណ្តាប់ទាំងនោះមាន៖ ស្លាធម៌បញ្ច្រាសនិងបណ្តោយដែលធ្វើពីដើមនិងស្លឹកចេក ជម៤ ជមម្ចាស់រូប និងជមគ្រូកំណើតធ្វើពីផ្លែដូង ដើមខ្លែងគង់ ដើមចាមរី រូបស្វា រូបតាឥសី។ល។ បាយសីប៉ាកឆាម រួមទាំងសម្លៀកបំពាក់ គ្រឿងអលង្ការ សម្ភារៈផ្សេងៗទៀត និងគ្រឿងសំណែនផង។

គ្រឿងរណ្តាប់ទាំងអស់សុទ្ធតែសំខាន់ ចំណែកតន្ត្រីក៏រឹតតែសំខាន់ក្នុងពិធីដែរ ដែលត្រូវរៀបចំឱ្យត្រូវតាមចិត្តគ្រូកំណើត ឬគ្រូសណ្តិត មានបទស្តេចយាង សំពៅថយ ប្រផាត បទប្រគំគ្រូ បទប្រជាប្រិយខ្មែរ និងបទសម័យទំនើបជាដើម។ បើតាមការរៀបរាប់របស់អ្នកស្រុកមួយចំនួនធំបានប្រាប់ថា ក្នុងការលៀងមេមត់នេះ វត្ថុបីដែលសំខាន់ជាងគេ គឺភ្លែង សម្លៀកបំពាក់ និងជម។ បើភ្លែង សម្លៀកបំពាក់ ជមមិនដូចអ្វីដែលគ្រូចង់បាន គ្រូក៏មិនចូលរូបអ្នកស្នងដែរ។ គ្រូនឹងធ្វើឱ្យរូបយំសោក ខឹង បោកកម្ទេចជមនិងគ្រឿងរណ្តាប់ដទៃទៀតគ្រវាត់ចោល ហើយធ្វើឱ្យម្ចាស់រូបនៅតែឈឺមិនជាស្រឡះពីជំងឺឡើយ។ ផ្ទុយទៅវិញបើគ្រូ ពេញចិត្ត គ្រូនឹងលើកថែរថើប បាញ់ទឹកអប់ដល់វត្ថុទាំងនោះ យកទៅបង្អួតគ្រូធំសើចសប្បាយរីករាយ ហើយធ្វើឱ្យម្ចាស់រូបជាពីជំងឺសុខកាយសប្បាយចិត្ត។

អ៊ំស្រី គង់ ជាគ្រូធំ មានស្តេចស្វាចូលសណ្តិតហៅ «ព្រះរាជគ្រូ» មានធ្នូជាសម្ភារៈសំណព្វចិត្ត បានប្រាប់ថា មកដល់ពេលនេះអ៊ំស្រីមានគ្រូកាន់ជាង៩ឆ្នាំហើយ។ ដំបូងអ៊ំមិនជឿលើព្រះអង្គ គ្រូចូលរូបអីទេ រហូតដល់អ៊ំឈឺត្រដាបត្រដួសស្ទើរស្លាប់

រកពេទ្យបីបួនមើលមិនដាក៏នៅតែមិនជឿ ហើយគេប្រាប់ថាឱ្យកាន់រូប ក៏គាត់មិនខ្វល់។ ចុងក្រោយទាំងប្តី ទាំងកូនគាត់ក៏ឈឺទៀត ទើបគាត់សម្រេចចិត្តជឿ ហើយរៀបចំគិតគូរ និងប្រតិបត្តិតាមគ្រូចង់បាន ទើបជារូបជាអង្គដល់សព្វថ្ងៃ។ អ៊ំស្រីបន្តទៀតថា ដើមឡើយអ៊ំក្រណាស់ មានកូនដល់ទៅ៨នាក់ ផ្ទះខ្នមរខេករខាក មានជំងឺមិនដាច់ តែតាំងពីជឿមកធ្វើឱ្យជីវិតប្រែប្រួលខ្លាំង ប្តីក៏ឈប់ផឹកស្រា កូនចៅក៏សុខសប្បាយ ទោះមិនមានខ្លាំង តែមានផ្ទះសម្បែងសមរម្យពេញដោយសុកមង្គល។ អ៊ំស្រីមិនត្រឹមតែអ្នកចូលរូបទេ តែជាគ្រូព្យាបាលជំងឺឈឺក្បាលវិលមុខ និងដោះអំពើយ៉ាងពូកែស័ក្តិសិទ្ធិទៀតផង មានអ្នកជិតអ្នកឆ្ងាយ ចូលមករកពឹងពាក់មិនដែលដាច់ថ្ងៃ។ ដូច្នេះហើយឱ្យតែដល់ខែមាឃ អ៊ំស្រីត្រូវលៀងមេមត់ម្តងដោយមានកូនចៅមកចូលរួមចាប់ពី២០ទៅ៣០នាក់ជាង ដើម្បីឱ្យរូបឬគ្រូបានរាំលេងសប្បាយ។ ក្នុងពេលលៀងមេមត់នេះក៏មានអ្នកជំងឺមកមើលច្រើនដែរ ព្រោះជាថ្ងៃដែលគ្រូពូកែខ្លាំង។

បន្ថែមពីនោះ អ៊ំស្រីក៏រៀបរាប់ដោយអឹមអៀននិងអស់សំណើចថា ពេលចូលរូបអត់ខ្មាសទេ ឮតែភ្លេងពិណពាទ្យ គឺចង់តែរាំទ្រាំមិនបាន ទាំងតាមធម្មតាអ៊ំស្រីជាមនុស្សអៀនច្រើន សុភាព មិនចេះរាំរែកសូម្បីបន្តិច។ អ៊ំស្រីនឹងបន្តជំនឿនេះរហូត ព្រោះជំនឿនេះធ្វើឱ្យអ៊ំ គ្រួសារអ៊ំ និងស្រុកភូមិមានក្តីសុខ ហើយមិនជឿដែរថាជំនឿនេះនឹងបាត់បង់ពីទឹកដីអង្គរដែរ ដោយសារមានកូនចៅច្រើនណាស់ចាំគោរពប្រតិបត្តិនិងជឿជាក់។ ចំណែកគ្រួសារគាត់ ពេលអត់ពីគាត់ទៅព្រះអង្គដែលកាន់រូបនឹងឱ្យកូនប្រុសពៅគាត់ស្នងបន្ត ព្រោះគេមានគ្រូកាន់តាំងពីកំណើតហើយបច្ចុប្បន្នកូនប្រុសគាត់ក៏ជាអ្នកព្យាបាលជំងឺឱ្យគេដ៏ពូកែម្នាក់ដែរ។

បងស្រី ជា អាយុ៤៥ឆ្នាំ អ្នកភូមិនគរក្រៅបានប្រាប់ថា មេមត់ពិតជាមានមែន ចំពោះគាត់និងអ្នកស្រុកនេះជឿលើមេមត់ណាស់បើអ្នកមិនជឿ ក៏មិនដែលមានអ្នកណាហ៊ានប្រមាថមើលងាយដែរ តែអាចលេងសើចរាំរែកជាមួយមេមត់បាន។ គេលៀងមេមត់ដើម្បីឱ្យអ្នកស្នងរូបជាពីជំងឺផង ឱ្យឈ្នួរ និងគ្រូកំណើតបានរាំលេងសប្បាយផង។ រាល់ឆ្នាំគេតែងលៀងនៅទីនេះឱ្យតែដល់ខែមាឃ ហើយសប្បាយណាស់ អ្នកស្រុកក៏ជុំគ្នា គ្រូកំណើត ឈ្នួរ និងព្រលឹងដូនតាដែលក៏មកជុំគ្នាដែរ ហើយកូនចៅក៏អាចទាក់ទងសួរនាំនឹងព្រលឹងទាំងនោះបាន។

បងស្រីបញ្ជាក់ថា នៅពេលគ្រូចូល រូបនោះតែងដើររកសាច់ញាតិ រកគ្រឿងណ្តាប់ បើរកមិនឃើញទេ គឺនៅតែដើររកពេញហ្នឹង។ មេមត់ស្រឡាញ់ជម សម្លៀកបំពាក់ និងភ្លេងណាស់ បើចូលបានរាំរែក គឺខ្លួនម្ចាស់នោះនឹងជាសះស្បើយ តែបើមិនចូលទេ ម្ចាស់រូបនោះនឹងនៅតែឈឺដដែល ហើយបើមេមត់ខុសជមវិញ គឺង៉ក់ខ្លាំងណាស់ ជួនកាលយំមួយយប់វាស់ព្រឹកក៏មាន ហើយបោកគ្រឿងណ្តាប់ចោលអស់។ លើសពីនោះទៀត រូបមួយមានគ្រូ៣ទៅ៤នាក់ឯណោះ គ្រូមួយចេញ គ្រូមួយចូល ឯរូបខ្លះទៀត ក៏មិនមានគ្រូចូលដែរ ព្រោះរៀបចំឱ្យគ្រូមិនត្រូវ។

បងស្រី រ៉ុង វ៉ាត់ អាយុ៣០ឆ្នាំ បានប្រាប់ថា គាត់មានគ្រូកំណើតកាន់៣ឆ្នាំហើយ ហើយនេះក៏ជាឆ្នាំទី៣ដែរដែលគាត់មកលៀងមេមត់នឹងគេ។ មុននឹងគាត់ជឿរឿងនេះ គឺគាត់ឈឺជាខ្លាំងនៅអាយុ២៤ឆ្នាំ ទៅពេទ្យក៏មិនជា ក៏ទៅបូលមើលក៏ឃើញថាមានគ្រូកំណើតកាន់ ព្រោះគាត់មានសំណុំសង្វាតាំងពីតូច។ គាត់ក៏រៀបចំគ្រឿងណ្តាប់ដែលគ្រូកំណើតត្រូវការ រួចមកចូលរូបនឹងគេ ដោយរៀបជមគ្រូកំណើត១ ស្លាធម៌១គូ និងតោក១ ហើយក៏ជារូបជាអង្គទៅ។ ពេលចូលគាត់ដឹងខ្លួនដែរ តែមិនអាចបញ្ជាខ្លួនឯងបាន ហើយហត់ណាស់ពេលចូលរូបរួច តែមានកម្លាំងនិងស្រឡះខ្លួន។

នៅចុងបញ្ចប់នៃពិធីលៀងមេមត់ គ្រូធំក៏រៀបចំពិធីបណ្តេញព្រាយ រើពិតានដើម្បីកុំឱ្យពួកសភាវៈអាក្រក់ចូលមកយាយី ហើយបើតាមការពិនិត្យសកម្មភាពជាក់ស្តែងនៅថ្ងៃចូលមេមត់ ក្រៅពីការជឿជាក់លើជំនឿនេះហើយ ប្រជាជនដែលនៅក្នុង

តំបន់នេះមានការអបអរសាទរនឹងជំនឿនេះជាខ្លាំងទាំងចាស់ទាំងក្មេងមកមើលកកកុញ បន្ទរស្រែកហ៊ោតាមភ្លេង និងរាំលេងឌឺដងជាមួយរូបដែលរៀបតាមចង្វាក់ភ្លេងមិនឈប់។ ការចូលរួម ភាពជឿជាក់ និងការយើញរឿងហេតុអស្ចារ្យទាំងនេះហើយដែលធ្វើឱ្យពួកគាត់យល់ថា វត្ថុស័ក្តិសិទ្ធិនិងបារមីនៅតែមានជីវិតរស់នៅលើដែនដីអង្គរ មិនសាបសូន្យទៅណា ទើបពេលឈឺជាអ្នកស្រុកអង្គរភាគច្រើន មិនដែលចោលការបន់ស្រន់ លៀងមេមត់ បូលរូប ទោះបីជាពួកគាត់ទៅពេទ្យដែរក៏ដោយ៕









មរតកជំនឿនៃអ្នកស្រុកអង្គរ ៖ ជម៨

ផ្សាយនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ជុន ប៊ុនជុន

កាលណាគេចូលរួមក្នុងពិធីប្រពៃណីមួយចំនួនរបស់អ្នកស្រុកអង្គរ ដូចជា ពិធីលៀងមេមត់ ចូលរូប ឡើងអ្នកតា បង្កក់កូន ជាដើម គេតែងឮចាស់ៗនិយាយគ្នាពីការរៀបចំស្លាធម៌ បាយសី និងជម ដែលជាគ្រឿងរណ្តាប់។ បើក្នុងពិធីបញ្ចូលរូប ជម៨ គឺជាគ្រឿងរណ្តាប់ដែលគេមិនអាចខកខានបានទេ។

តើអ្វីជាជម៨? គេប្រើជមនេះក្នុងពិធីអ្វីខ្លះ?

តាមការពន្យល់របស់**អ្នកស្រី គង់** ដែលជាគ្រូបញ្ចូលរូប និងព្យាបាលជំងឺនៅភូមិនគរក្រៅ ដែលជាភូមិនៅជាប់នឹងបរិវេណក្រុងអង្គរធំ ជម៨ គឺជាគ្រឿងរណ្តាប់មួយជើងពានតូច ដែលក្នុងនោះយើញមានម្ហូ៨ដុំ ហើយក្នុងមួយដុំៗមាន៨សន្លឹក

មានស្លា៤ដុំ ទៀន៤ដើមនៅគ្រប់ខាង និង១ដើមទៀតដាក់បញ្ឈរត្រង់កណ្តាលលើអង្គរមួយកូនពែង ធូប៥សរសៃ និងប្រាក់៦០០រៀល។ គេតែងឃើញជម៤នេះ ត្រូវបានរៀបចំអមជាមួយនឹងបាយសីដែលធ្វើពីដើមចេក ដែលដោតផ្កា ទៀន ធូប ស្ទើរតែគ្រប់កិច្ចពិធី។

តាមការរៀបរាប់របស់គ្រូបញ្ចូលរូបរូបនេះ បញ្ជាក់ថា គេប្រើជម៤នេះនៅក្នុងកិច្ចពិធីសំខាន់ៗទាក់ទងនឹងគ្រួកំណើត ដូចជាពិធីបញ្ចូលរូបជាដើម។ ការរៀបចំជមនេះ បើចំពោះអ្នកដែលមានគ្រួកាន់ដូចជាអ្នកស្រីជាដើម ត្រូវធ្វើតម្កល់ទុកជាប្រចាំលើអាសនៈ មួយសីល(៧ថ្ងៃឬ៨ថ្ងៃ)ទើបដូរម្តង ហើយត្រូវរក្សាជាប្រចាំ។ បើក្នុងកិច្ចពិធីផ្សេងៗ គេគ្រាន់តែរៀបចំចប់ពិធីក៏រុះរើបាន៕



រូបជមដែលគ្រូបញ្ចូលរូបរៀបចំ





រូបជមចាស់ដែលរៀបដាក់លើអាសនៈរបស់គ្រូបញ្ចូលរូប



ជមដែលគេរៀបចំនៅក្នុងពិធីកាត់សក់បង្កក់ផ្ទះបនៅភូមិក្រវ៉ាន់

សេចក្តីជូនដំណឹងស្តីពី ការបើកឱ្យដំណើរការឡើងវិញនូវទំព័រហ្វេសប៊ុកផ្លូវការរបស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ២៨ ខែ កុម្ភ: ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ១៥៨/ អ.ប.ស.ជ.ណ
១៧

សេចក្តីជូនដំណឹង
ស្តីពី
ការបើកឲ្យដំណើរការឡើងវិញ
នូវទំព័រហ្វេសប៊ុកផ្លូវការរបស់អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឲ្យបានជ្រាបថា កាលពីព្រឹកថ្ងៃទី១៨ ខែកុម្ភ: ឆ្នាំ២០១៧កន្លងទៅ ក្រុមអនាមិកបានលួចចូលគ្រប់គ្រងទំព័រហ្វេសប៊ុកផ្លូវការ និងគណនីហ្វេសប៊ុកពាក់ព័ន្ធមួយចំនួនរបស់អាជ្ញាធរជាតិអប្សរា បណ្តាលឲ្យការផ្សព្វផ្សាយពីសកម្មភាពនានារបស់អាជ្ញាធរជាតិអប្សរាតាមរយ:ទំព័រហ្វេសបុកផ្លូវការនេះត្រូវបានខកខានមួយរយ:។

ក៏ប៉ុន្តែ ដោយកិច្ចខិតខំប្រឹងប្រែងពីក្រុមបច្ចេកទេស ទំព័រហ្វេសប៊ុកផ្លូវការនេះ ត្រូវបានអាជ្ញាធរជាតិអប្សរាយកមកគ្រប់គ្រង និងបើកឲ្យដំណើរការជាធម្មតាឡើងវិញ ចាប់ពីថ្ងៃទី២៨ ខែកុម្ភ: ឆ្នាំ២០១៧នេះតទៅ។

អាស្រ័យហេតុនេះ សាធារណជនទាំងអស់មេត្តាជ្រាបជាដំណឹង។

សៀមរាប, ថ្ងៃទី ២៨ ខែកុម្ភ: ឆ្នាំ២០១៧
អាជ្ញាធរជាតិអប្សរា

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពាររមណីយដ្ឋានទិន្នរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

អាជ្ញាធរជាតិអប្សរាបន្តសហការជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រចិន ដើម្បីជួយដល់ការងារគ្រប់គ្រងតំបន់សៀមរាប អង្គរ

ផ្សាយនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

អាជ្ញាធរជាតិអប្សរាគ្រោងនឹងចុះកិច្ចព្រមព្រៀង ជាមួយមជ្ឈមណ្ឌល HIST (International Center on Space Technologies for Natural and Cultural Heritage under the auspices of UNESCO) និងវិទ្យាស្ថាន RADI (Institute of Remote Sensing and Digital Earth) នៃបណ្ឌិតសភាវិទ្យាសាស្ត្រចិន(Chinese Academy of Sciences) ដើម្បីបន្តគម្រោងសហប្រតិបត្តិការស្តីពីការប្រើប្រាស់បច្ចេកវិទ្យាអវកាសសម្រាប់ការងារអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅតំបន់សៀមរាប នៅចុងខែមីនា ឆ្នាំ២០១៧ ខាងមុខនេះ។

កិច្ចពិភាក្សាស្តីពីគម្រោងបន្តចុះអនុស្សរណៈយោគយល់គ្នានេះ ត្រូវបានរៀបចំឡើងនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា នារសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ រវាងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ក្រោមអធិបតីភាព**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងប្រតិភូនៃបណ្ឌិតសភាវិទ្យាសាស្ត្រចិន ដឹកនាំដោយ**លោកសាស្ត្រាចារ្យ Wang Enge** អនុប្រធានបណ្ឌិតសភាវិទ្យាសាស្ត្រចិន។

គោលបំណងចម្បងនៃគម្រោងសហប្រតិបត្តិការនេះគឺ បណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិករបស់អាជ្ញាធរជាតិអប្សរា ក្នុងការប្រើប្រាស់បច្ចេកវិទ្យាអវកាស (Remote Sensing) សម្រាប់ការងារអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានអង្គរ និងការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់អាងផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងសៀមរាប ស្ទឹងពួក ស្ទឹងរលួស និងភ្នំគូលែន។ ចាប់តាំងពីឆ្នាំ២០១៣មក គម្រោងនេះបានចូលរួមបណ្តុះបណ្តាលមន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរាបានចំនួន៦លើក ដោយក្នុងនោះ៥លើក នៅសាធារណរដ្ឋប្រជាមានិតចិន បណ្តុះបណ្តាលបានចំនួន១៣រូប និង១លើកទៀត រៀបចំនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរាផ្ទាល់ ដោយសាស្ត្រាចារ្យមកពីវិទ្យាស្ថាន RADI និងមជ្ឈមណ្ឌល HIST។

សូមបញ្ជាក់ថា តាមរយៈកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងបណ្ឌិតសភាវិទ្យាសាស្ត្រចិន នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ កន្លងមក អាជ្ញាធរជាតិអប្សរា បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយមជ្ឈមណ្ឌល HIST នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីបង្កើតឲ្យមានគម្រោងសហប្រតិបត្តិការស្តីពីការប្រើប្រាស់បច្ចេកវិទ្យាអវកាស សម្រាប់ការងារអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅតំបន់សៀមរាប ដែលហៅថា គម្រោងបច្ចេកវិទ្យាអវកាសសម្រាប់បរិស្ថាននៃឧទ្យានអង្គរ(REAS : Remote Sensing for Environmental of Angkor Site Project)។

គម្រោងដដែលនេះ ក៏បានចុះអនុស្សរណៈនៃការយោគយល់គ្នាមួយទៀត នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ រវាងអាជ្ញាធរជាតិអប្សរា និងវិទ្យាស្ថានRADI នៃបណ្ឌិតសភាវិទ្យាសាស្ត្រចិន និងមជ្ឈមណ្ឌល HIST សម្រាប់កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ទិន្នន័យពីផ្កាយរណបរបស់ប្រទេសចិន (China's Satellite Quicklook Data Service)។ យោងតាមអនុស្សរណៈនៃការយោគយល់គ្នាមួយទៀតនេះ វិទ្យាស្ថាន RADI បានផ្តល់មកឲ្យអាជ្ញាធរជាតិអប្សរា នូវការបង្កើតស្ថានីយផ្កាយរណបសិប្បនិម្មិតមួយ (Virtual Ground Station) ក្នុងទីស្នាក់ការអាជ្ញាធរជាតិអប្សរា និងផ្តល់ឲ្យទិន្នន័យពីផ្កាយរណបចំនួនពីររបស់ប្រទេសចិន និងបានបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា អំពីការប្រើប្រាស់ឧបករណ៍ និងកម្មវិធីទាំងនោះ ដែលស្ថានីយមួយនេះកំពុងដំណើរការមកដល់សព្វថ្ងៃ៕






អាជ្ញាធរជាតិអប្សរាផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកភូមិថ្នល់បណ្តោយ

ផ្សាយនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ នង សុវណ្ណរិទ្ធិ

នៅព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧នេះ ក្រុមការងារសហគមន៍ ទី៥ប្រចាំស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ាន់ឌី** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានក្រុមរួមនឹងមន្ត្រីបុគ្គលិកជាច្រើនរូបទៀតបានចុះ ផ្សព្វផ្សាយពីបេតិកភណ្ឌដល់ប្រជាពលរដ្ឋដែលរស់នៅភូមិថ្នល់បណ្តោយ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ គោលបំណងនៃការចុះផ្សព្វផ្សាយនេះគឺដើម្បីរួមគ្នាថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌ។

មានប្រសាសន៍ក្នុងឱកាសនោះ **ឯកឧត្តម ម៉ី ម៉ាន់ឌី** បានលើកឡើងអំពីការដាក់តំបន់អង្គរចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ការបង្កើតស្ថាប័នអាជ្ញាធរជាតិអប្សរាសម្រាប់គ្រប់គ្រងតំបន់អង្គរ តួនាទីភារកិច្ច និងកិច្ចការងាររបស់អាជ្ញាធរជាតិអប្សរាក្នុងការគ្រប់គ្រង ថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌ និងសមិទ្ធផលដែលអាជ្ញាធរជាតិអប្សរាសម្រេចបាន។ បន្ថែមពីនោះទៀត ឯកឧត្តម ក៏បានពន្យល់អំពីសិទ្ធិ និងរបៀបដាក់ពាក្យស្នើសុំសាងសង់សំណង់ផ្សេងៗរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បេតិកភណ្ឌផងដែរ។

លោកក្រុមប្រឹក្សាស្រុក លោកមេឃុំ និងមេភូមិ អនុភូមិ បានថ្លែងចំណាប់អារម្មណ៍ថាលោកពិតជាសប្បាយចិត្តណាស់និងអរគុណចំពោះអាជ្ញាធរជាតិអប្សរាដែលរយៈកាលកន្លងមកបានគិតគូរពីសុខទុក្ខប្រជាពលរដ្ឋ ហើយលោកវីកាយនឹងសហការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីអប់រំផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋបានយល់ពីបេតិកភណ្ឌកាន់ទូលំទូលាយឡើងថែមទៀត។

លោក មួន មិត្ត ប្រជាពលរដ្ឋភូមិថ្នល់បណ្តោយបានគាំទ្រចំពោះសកម្មភាព របស់អាជ្ញាធរជាតិអប្សរា ដោយលោកយល់ឃើញថាកម្មវិធីនេះល្អ ព្រោះវាបានផ្តល់នូវចំណេះដឹងច្រើនដល់ប្រជាពលរដ្ឋ ធ្វើឲ្យពួកគាត់បានយល់ច្បាស់ពីតម្លៃ និងអត្ថប្រយោជន៍បេតិកភណ្ឌ ព្រមទាំងដឹងពីតួនាទីភារកិច្ចរបស់ពួកគាត់ត្រូវចូលរួមគ្នាជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីថែរក្សាបេតិកភណ្ឌដែលជាសម្បត្តិដូនតាយើងទាំងអស់គ្នា៕









ផ្នែកទី ៣
ប្រចាំខែមីនា

អាជ្ញាធរជាតិអប្សរាជួបពិភាក្សាជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា អំពីការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ ហ៊ីង ស្រីវត្ថ៍ រូបភាព ៖ សឿន ប៊ុនស៊ីរ

នារសៀលថ្ងៃទី២ ខែមីនា អាជ្ញាធរជាតិអប្សរា និងសហភាពសហព័ន្ធយុវជនកម្ពុជា បានជួបពិភាក្សាគ្នាស្តីពីការងាររៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មី ឆ្នាំរកា អដ្ឋស័ក ពុទ្ធសករាជ២៥៦០ ឈានចូល២៥៦១។ ជំនួបពិភាក្សានេះធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា និង**ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរាខេត្តសៀមរាប។

សម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំទី៥នេះនឹងរៀបចំអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរនៅរមណីយដ្ឋានអង្គរដែលជាដួងព្រលឹងជាតិខ្មែរដូចឆ្នាំកន្លងមក។ យោងតាមបទបង្ហាញរបស់សហភាពសហព័ន្ធយុវជនកម្ពុជាឆ្នាំនេះនឹងមានរៀបចំជា២៥កម្មវិធីធំៗដូចជា ពិធីសាសនា កម្មវិធីភូមិខ្ទុំ និម្មិតភូមិ កម្មវិធីល្បែងប្រជាប្រិយ គុនល្បុក្កតោ ពិព័រណ៍សិប្បកម្ម វត្ថុអនុស្សាវរីយ៍ និងកម្មវិធីសប្បាយផ្សេងៗ។ ជាពិសេសជាងនេះទៅទៀត បង្ហាញពីប្រវត្តិមួយសតវត្ស និងការប្រែប្រួលនៃរបាំព្រះរាជទ្រព្យ ដែលជាស្ថាព្រះហស្ថរបស់ សម្តេចព្រះរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ចាប់ពីឆ្នាំ១៩០៦ ដល់២០១៦។

ឯកឧត្តម ហ៊ុន ម៉ានី បានបញ្ជាក់ថា កម្មវិធីអង្គរសង្ក្រាន្តដែលបានទទួលជោគជ័យជាបន្តបន្ទាប់មកនេះ ពិតណាស់ គឺបានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសគឺអាជ្ញាធរជាតិអប្សរា។ ឯកឧត្តមបន្ថែមថា "អង្គរសង្ក្រានជារបស់ប្រជាជនខ្មែរទាំងអស់គ្នា មិនមែនជារបស់ក្រុមការងារ ស.ស.យ.ក តែឯងនោះទេ គោលបំណងសំខាន់នៃការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តគឺ ស្នាមញញឹមនិងស្មារតីរួបរួមនៃមហាគ្រួសារខ្មែរ។ ដូច្នេះហើយ យើងពិតជាត្រូវការការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសអាជ្ញាធរជាតិអប្សរា ប្រជាពលរដ្ឋទូទៅ ធ្វើយ៉ាងណាឲ្យព្រឹត្តិការណ៍នេះប្រព្រឹត្តទៅដោយភាពសប្បាយរីករាយផង ឆ្លុះបញ្ចាំងអំពីវប្បធម៌ទំនៀមទម្លាប់ប្រពៃណីដូនតាខ្មែរផង"។

ជាការឆ្លើយតប **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** បានលើកឡើងថា "អាជ្ញាធរជាតិអប្សរារីករាយនឹងគាំទ្រ និងសហការយ៉ាងពេញទំហឹង ក្នុងការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តនេះ ព្រោះនេះជាព្រឹត្តិការណ៍មានលក្ខណៈវប្បធម៌និងប្រពៃណី ដែលស្របនឹងគោលការណ៍របស់អាជ្ញាធរជាតិអប្សរា គឺអភិរក្សដើម្បីអភិវឌ្ឍ និងអភិវឌ្ឍដើម្បីអភិរក្ស។ ម្យ៉ាងវិញទៀតនោះព្រឹត្តិការណ៍នេះ នឹងជំរុញឲ្យកិត្តិសព្ទរបស់អង្គរកាន់តែល្បីល្បាញ ដែលនេះជាយុទ្ធសាស្ត្រយ៉ាងសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរ មកទស្សនារមណីយដ្ឋានអង្គរ"។

ឯកឧត្តមអគ្គនាយកក៏បានជម្រាបជូនអង្គប្រជុំអំពីការត្រៀមខ្លួនរួចជាស្រេចរបស់អាជ្ញាធរជាតិអប្សរា ដូចជាបានបង្កើតក្រុមការងារដើម្បីសហការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តទាំងមូល ទទួលបន្ទុករ៉ាប់រងទាំងស្រុងក្នុងការរៀបចំកម្មវិធីនិម្មិតភូមិ និងភូមិខ្ទុំ ផ្តល់សេវាទឹកស្អាត កាត់ក្រីមែកឈើបង្ការគ្រោះថ្នាក់បន្ថែមធុងសំរាមតាមទីកន្លែងនានាក្នុងបរិវេណព្រឹត្តិ

ការណ៍ និងប្រាង្គប្រាសាទ ព្រមទាំងបានធ្វើការទាក់ទងជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ទន្ទឹមនេះ អាជ្ញាធរជាតិអប្សរាក៏បានស្នើសុំសហការភាពសហព័ន្ធយុវជនកម្ពុជា សហការបញ្ជ្រាបការយល់ដឹងឲ្យបានកាន់តែទូលំទូលាយ អំពីក្រមប្រតិបត្តិអង្គរ ជូនដល់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋដែលនឹងមកចូលរួមក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តនាពេលនោះផងដែរ៕






អាជ្ញាធរជាតិអប្សរាបន្តអនុញ្ញាតជូនប្រជាពលរដ្ឋដើម្បីជួសជុលផ្ទះ

ផ្សាយនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ យឹម សាន់ដេ

នៅព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ ក្រុមការងារសហគមន៍ក្រុមទី៤របស់អាជ្ញាធរជាតិអប្សរា ប្រចាំក្រុងសៀមរាប បានបន្តចុះពិនិត្យសំណើរស្នើសុំរបស់ប្រជាពលរដ្ឋ ដើម្បីជួសជុលផ្ទះសម្បែងនៅភូមិតាប៉ាង សង្កាត់អំពិល ក្រុងសៀមរាប។ ក្នុងការចុះត្រួតពិនិត្យនោះ ក្រុមការងារសហគមន៍ក្រុមទី៤ បានសម្រេចអនុញ្ញាតចំនួន១២ករណី ក្នុងចំណោម១៥ករណី។

ករណីដែលក្រុមការងារសហគមន៍បានអនុញ្ញាតដល់ប្រជាពលរដ្ឋចំនួន១២ករណី មានដូចជា សុំជួសជុលដំបូល តសំយ៉ាប ធ្វើបង្គន់ ជួសជុលជញ្ជាំងផ្ទះ ធ្វើទ្រុងជ្រូក ទ្រុងមាន់ជាដើម។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ត្រូវបានបង្កើតឡើងដើម្បីផ្សព្វផ្សាយអំពីបេតិកភណ្ឌ បញ្ជ្រាបចំណេះដឹងដល់ប្រជាពលរដ្ឋ ដើម្បីឲ្យពួកគាត់បានចូលរួមក្នុងកិច្ចការពារបេតិកភណ្ឌ។ ទន្ទឹមនឹងនេះ ក្រុមការងារសហគមន៍ ក៏បានឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលស្នើសុំជួសជុលតិចតួច និងអនុញ្ញាតជូនភ្លាមៗនៅនឹងមូលដ្ឋាន ដើម្បីសម្រួលដល់ពេលវេលា និងការធ្វើដំណើររបស់ពួកគាត់។ លើសពីនេះទៀត ក្រុមការងារសហគមន៍ក៏ជាក្រុមជួយសង្គ្រោះបន្ទាន់ ក្នុងករណីគ្រោះថ្នាក់ធម្មជាតិដែលកើតមានឡើងចំពោះប្រជាពលរដ្ឋក្នុងតំបន់អង្គរ និងនាំយកកញ្ចប់ទ្រទ្រង់សុខភាពចែកជូនស្ត្រីទើបសម្រាលកូនជាដើម៕





អង្គរសង្ក្រាន្តឆ្នាំ២០១៧ នឹងមកដល់ក្នុងពេលឆាប់ៗនេះ! សូមចូលរួមទាំងអស់គ្នា
ចាតើអង្គរសង្ក្រាន្តឆ្នាំនេះមានអ្វីប្លែកខ្លះ?

ផ្សាយនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៧




អង្គរសង្ក្រាន្ត
ANGKOR SAṄKRĀNTA
Siem Reap, Cambodia
អង្គរសង្ក្រាន្ត
មកដល់ក្នុងពេលឆាប់ៗនេះ
COMING SOON
ទំនាក់ទំនងឧបត្ថម្ភគាំទ្រ 077 366 744 / 081 74 04 05
សៀមរាប ផ្ទះខ្ញុំ

ចម្លាក់បាយ័ន៖ ឆ្នាំងមួយនៃសោកនាដកម្មទ័ពខ្មែរបរាជ័យក្រោមស្នាដៃចាម

ផ្សាយនៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

អ្នកស្រាវជ្រាវ និងទេសចរគ្រប់ជាតិសាសន៍ ដែលបានទៅដល់ប្រាសាទបាយ័ន តែងស្ងើចសរសើរនឹងចម្លាក់យ៉ាងរស់រវើក ដែលបង្ហាញពីជីវភាពរស់នៅ និងព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើងក្នុងសម័យអង្គរ។

សម្រាប់ទេសចរទូទៅ ចម្លាក់ទាំងនោះមានភាពស្អេកស្កះ ដែលមើលមិនសូវយល់ថាជារឿងរ៉ាវអ្វីឲ្យប្រាកដ។ សម្រាប់ក្រសែភ្នែកអ្នកស្រាវជ្រាវវិញ ចម្លាក់ទាំងនោះ គឺជាទិន្នន័យដ៏សំខាន់បំផុត ដែលធ្វើឲ្យគេយល់បាននូវដំណើរដើមទង និងជាសាច់រឿងដ៏ជក់ចិត្តទៀតផង។

អ្នកស្រាវជ្រាវ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរា **លោក អ៊ឹម សុខរិទ្ធី** បានពន្យល់នូវខ្លឹមសារនៃចម្លាក់មួយផ្ទាំងធំ ដែលស្ថិតនៅថែវខាងក្រៅ ភាគខាងជើងឆៀងខាងកើត។ ចម្លាក់ដ៏ធំនេះ គឺរៀបរាប់អំពីដំណើរដែលទ័ពខ្មែរបានបរាជ័យយ៉ាងធ្ងន់ធ្ងរ ក្រោមស្នាដៃការលុកលុយរបស់ទ័ពចាមក្នុងឆ្នាំ១១៧៧ រហូតគ្រប់គ្រងរាជធានីអង្គរទាំងមូល។

ដោយមើលពីលិចទៅកើត គេនឹងឃើញការសម្រុកចូលរបស់កងទ័ពចាម គំនរសាកសពខ្មែរចាមគរលើគ្នា ការសែងអ្នករបួស អ្នកស្រុកស្គាយបង្វេចរត់ មេទ័ពខ្មែរឯងរបួសហើយត្រូវលើកដាក់លើដំរី កងទ័ពខ្មែរត់ចែកផ្លូវគ្នាប្រសេចប្រសាច ។ល។

សូមទស្សនាចម្លាក់ទាំងនេះដូចខាងក្រោម ៖



ការសម្រុកចូលនៃកងទ័ពចាម



គំនរសាកសពនៃកងទ័ពខ្មែរ-ចាម



អ្នកស្រុកស្គាយបង្វេចរត់គេចខ្លួន



លើកមេទ័ពត្រូវរបួសដាក់លើដំរី

គម្រោងជួសជុលក្រុមប្រាសាទព្រះពិធូររបស់កូរ៉េ បន្តបណ្តុះបណ្តាលមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា លើការងារវាស់ស្ទង់ស្រទាប់ដី និងកម្រិតទឹក

ផ្សាយនៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ សេន សែត រូបភាព ៖ សេន សែត

ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ហៅកាត់ថា KOICA តាមរយៈមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ KCHF បានសហការជាមួយអាជ្ញាធរជាតិអប្សរា ក្នុងការជ្រើសរើសក្រុមប្រាសាទព្រះពិធូរមកធ្វើការអភិរក្សជួសជុល។ ក្នុងដំហានដំបូងគម្រោងនេះបានជ្រើសរើសយកពានហាលនៃប្រាសាទកោរសេក់ ដើម្បីធ្វើការជួសជុល ដែលនឹងត្រូវចំណាយពេលប្រមាណ៣ឆ្នាំពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។

ទន្ទឹមគ្នានឹងការងារស្រាវជ្រាវ ចងក្រងឯកសារធ្វើការអភិរក្សជួសជុល គម្រោងនេះក៏បានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការងារបណ្តុះបណ្តាលមន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែង ពីថ្ងៃទី៣ ដល់ទី៩ ខែមីនា ឆ្នាំ២០១៧នេះ វគ្គបណ្តុះបណ្តាលស្តីពីការវាស់ស្ទង់ស្រទាប់ដីដំហានទី២ ត្រូវបានរៀបចំឡើងដល់បុគ្គលិកជំនាញចំនួន១០រូបបន្តទៀត។

អ្នកគ្រប់គ្រងគម្រោងជួសជុលក្រុមប្រាសាទព្រះពិធូរ **លោក Kim Jiseo** បានបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដើម្បីបំប៉នសមត្ថភាព ដល់មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា ក្នុងន័យរួមចំណែកអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអភិរក្ស។ "យើងបានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើនប្រភេទ ទាំងរយៈពេលខ្លី និងរយៈពេលវែង។ នៅទីនេះ យើងបានបណ្តុះបណ្តាលលើការងារវាស់ស្ទង់ស្រទាប់ដី និងសិក្សាពីកម្រិតទឹក ដែលមានជុំវិញរចនាសម្ព័ន្ធប្រាសាទ។ ទៅខាងមុខទៀត យើងនឹងបណ្តុះបណ្តាលអំពីរបៀបមើលថ្ម និងបញ្ហាផ្សេងៗដែលកើតមានចំពោះថ្មប្រាសាទ។ យើងត្រូវការប្រុងប្រយ័ត្នខ្ពស់ក្នុងកិច្ចការអភិរក្សជួសជុលប្រាសាទដែលជាបេតិកភណ្ឌពិភពលោក"។

លោក Jiseo បន្ថែមថា រយៈពេល៣ឆ្នាំនៃដំហានទី១នេះ អាចនឹងត្រូវចំណាយថវិកាប្រមាណ ជា៤លានដុល្លារសហរដ្ឋអាមេរិកដោយរួមបញ្ចូលទាំងការចំណាយលើការបណ្តុះបណ្តាល ការទិញសម្ភារៈ មន្ត្រីជំនាញ និងបុគ្គលិកជាដើម។

សិក្ខាកាមមួយរូប ដែលមកពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ **កញ្ញា ហាង សុច្ឆរី** ថ្លែងថា ការបណ្តុះបណ្តាលនេះគឺមានសារៈសំខាន់ណាស់សម្រាប់អ្នកជំនាញកម្ពុជា ពីព្រោះកម្ពុជាជាប្រទេសមួយដែលមានប្រាសាទបុរាណច្រើនជាងគេជាពិសេសគឺនៅសៀមរាបនេះតែម្តង ហើយប្រាសាទបុរាណទាំងនោះមានមួយចំនួនធំមានភាពខ្ទេតខ្ទោមដែលទាមទារឲ្យមានការជួសជុលឡើងវិញ។

កញ្ញាបានបញ្ជាក់ថា នៅវគ្គបណ្តុះបណ្តាលនេះកញ្ញាទទួលបានចំណេះដឹងច្រើនពាក់ព័ន្ធនិងប្រាសាទ ហើយកញ្ញាជឿជាក់ថា តាមរយៈបច្ចេកវិជ្ជាថ្មីៗយើងនឹងធ្វើយ៉ាងណាឲ្យបានល្អប្រសើរតាមគំរូដើមរបស់បុព្វបុរសយើង និងខិតខំថែរក្សាបេតិកភណ្ឌទាំងនេះឲ្យបានល្អប្រសើរ៕









អាជ្ញាធរជាតិអប្សរា ស្ថាប័នJQA និងមន្ទីរអប់រំយុវជននិងកីឡា សហការគ្នាអប់រំកុមារអង្គរអំពីបរិស្ថាន

ផ្សាយនៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ សេន សែត រូបភាព ៖ សេន សែត

ដើម្បីជំរុញការចូលរួមថែរក្សាបរិស្ថាន ធ្វើឲ្យមានភាពស្រស់ស្អាតនៅក្នុងរមណីយដ្ឋានអង្គរជាចីរភាព អាជ្ញាធរជាតិអប្សរា បានសហការជាមួយស្ថាប័នជានាគុណភាពជប៉ុន JQA និងមន្ទីរអប់រំយុវជននិងកីឡា រៀបចំកម្មវិធីអប់រំកុមារអំពីបរិស្ថាន តាមសាលាបឋមសិក្សា និងអនុវិទ្យាល័យមួយចំនួនក្នុងតំបន់អង្គរ។

ចាប់ពីឆ្នាំ២០១១ មកទល់នឹងពេលនេះ គម្រោងអប់រំកុមារអំពីបរិស្ថានសម្រេចបានចំនួន៦សាលារួចមកហើយ ហើយគម្រោងនឹងបន្តទៅតាមបណ្តាសាលាផ្សេងៗទៀតក្នុងតំបន់អង្គរទាំងមូល ដើម្បីជំរុញឲ្យកុមារយល់ដឹងកាន់តែច្បាស់ និងមានឆន្ទៈស្រឡាញ់ការពារបរិស្ថានអង្គរ។

មានប្រសាសន៍ក្នុងពិធីចែកបណ្ណសរសើរ និងបិទវគ្គអប់រំនៅសាលាបឋមសិក្សាគោកគ្រើល នាព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ នេះ **លោក Satoru Kishino** ប្រធានការិយាល័យប្រតិបត្តិ របស់ស្ថាប័ន JQA បានបញ្ជាក់ថា គោលបំណងចម្បងនៃកម្មវិធីអប់រំនេះ គឺឱ្យកុមារចេះគិតគូរដោះស្រាយបញ្ហានិងមានស្មារតីចេះស្រឡាញ់ ថែរក្សាបរិស្ថានដោយខ្លួនឯងតាំងពីតូចមក។

លោក សាំង វិត្តនា តំណាងមន្ទីរអប់រំយុវជន និងកីឡា មានប្រសាសន៍ក្នុងពិធីនេះថា បរិស្ថានគឺជាការងាររបស់មនុស្សគ្រប់គ្នា។ អប់រំឲ្យកុមារយល់ដឹងពីបរិស្ថាន គឺដើម្បីឲ្យពួកគេចេះស្រឡាញ់ កាលណាពួកគេស្រឡាញ់ គេនឹងថែរក្សាដោយ

យកចិត្តទុកដាក់ ហើយកុមារទាំងនេះនឹងក្លាយជាគំរូល្អក្នុងការថែរក្សាបរិស្ថាន និងជួយអប់រំដល់កុមារដទៃទៀតផងនៅក្នុងតំបន់ ក៏ដូចជាប្រទេសកម្ពុជាទាំងមូល។

ឯកឧត្តម សុខ លក្ខិណា ទីប្រឹក្សា និងជាប្រធានអង្គភាពគ្រប់គ្រងប្រព័ន្ធបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណចំពោះស្ថាប័នJQA មន្ទីរអប់រំយុវជន និងកីឡា លោកគ្រូ អ្នកគ្រូ ដែលបានចូលរួមសហការយ៉ាងល្អ ក្នុងកម្មវិធីអប់រំបរិស្ថានដល់កុមារនៅក្នុងឧទ្យានអង្គរ។ ឯកឧត្តមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាមិនត្រឹមតែយកចិត្តទុកដាក់អប់រំតែកុមារទេ សូម្បីមនុស្សចាស់ក៏មានក្រុមការងារចុះជួបអប់រំអំពីបរិស្ថានជាប្រចាំដែរ តាមរយៈគម្រោងដែលឧបត្ថម្ភដោយប្រទេសញ៉ូវហ្សេឡែន។ តែកុមារជាគឺជាទិសដៅសំខាន់ ដោយហេតុថា កាលណាពួកគេចេះ ពួកគេពិតជាហ៊ានប្រាប់ឪពុកម្តាយ និងបន្តទៅមនុស្សផ្សេងទៀតឲ្យចូលរួម ជាពិសេស គឺពួកគេជាទំពាំងស្នងឫស្សី ដែលនឹងត្រូវបន្តវេនថែរក្សាមរតកដូនតារបស់យើង។

នាយកសាលាបឋមសិក្សាគោកគ្រើល **លោកគ្រូ សុង ស៊ូ** បានបង្ហាញនូវភាពរីករាយ ដែលគម្រោងអប់រំបានជ្រើសរើសសាលារបស់លោកសម្រាប់ធ្វើការអប់រំអំពីបរិស្ថាននេះ។ លោកបន្ថែមថា កុមារាកុមារីដែលបានទទួលការអប់រំ និងដាក់លំហាត់ឲ្យពួកគេអនុវត្ត ហាក់មានការកែប្រែបណ្តើរៗ។ រូបលោកផ្ទាល់ក៏តែងរំឭកដាស់តឿនពួកគេឲ្យចងចាំ និងចូលរួមអនុវត្តការងារសម្អាតបរិស្ថាន។ "ខ្ញុំតែងប្រាប់ពួកគេនៅពេលគោរពទង់ជាតិថា ខ្ញុំនឹងមនបង្រៀនប្អូនៗឲ្យចេះរើសសំរាមទេ តែខ្ញុំចង់បង្រៀនប្អូនៗឲ្យចេះទុកដាក់សំរាមត្រឹមត្រូវ។ បើប្អូនចេះទុកដាក់សំរាមបានត្រឹមត្រូវ ប្អូននឹងមិនចាំបាច់រើសសំរាមទៀតទេ"។









សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រីមែកឈើងាប់ រស់នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ១៧៣/ប.ស.សជណ
១៧

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រីមែកឈើងាប់ រស់នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណៈជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណៈជន និងផលប៉ះពាល់ដល់ប្រាសាទជាយថាហេតុ និងដើម្បីលើកកម្ពស់សោភ័ណភាពរមណីយដ្ឋានអង្គរ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរអប្សរានឹងធ្វើការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រីមែកងាប់ មែករស់មួយចំនួនតាមទីតាំងនានាដូចខាងក្រោម៖

-កាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើចំនួន ៣២ដើម នៅបរិវេណប្រាសាទបន្ទាយស្រី។

-កាត់ធាងត្នោតងាប់ និងធាងត្នោតចាស់ៗ យកចេញចំនួន ៤៩០ដើមនៅប្រាសាទអង្គរវត្ត និងអង្គរធំ។

-កាត់ត្រសសម្អាត និងកាត់ក្រីមែកឈើអមតាមផ្លូវលើខ្នងទំនប់បារាយណ៍ខាងលិច។

-កាត់ក្រីមែកឈើចំនួន ០៥ដើម នៅភូមិឱឡោក ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប (សំណើស្នើសុំរបស់ប្រជាពលរដ្ឋ)។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃ ០៦ ខែ មីនា ឆ្នាំ២០១៧ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណៈជនទាំងអស់ មេត្តាជ្រាបជាពត៌មាន។

ស្សៀមរាប ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០១៧
អត្តនាយក

ស៊ុ ម៉ាប់

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
"ដើម្បីជូនជ្រាប និងសហការ"
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពារមណីយដ្ឋាននៃតំរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

ចម្លាក់បាយ័ន ៖ ចុះពីសំពៅឡើងសំប៉ាន ចុះពីសំប៉ានឡើងផ្សារ

ផ្សាយនៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

នៅលើចម្លាក់នៃប្រាសាទបាយ័ន ត្រង់ថែវខាងក្រៅ នាទិសខាងត្បូង មានទិដ្ឋភាពមួយដែលនិយាយអំពីជំនួញផ្លូវទឹករបស់ខ្មែរបុរាណជាមួយប្រទេសជិតខាង ជាពិសេស ប្រទេសចិន។ បើគេមើលមួយភ្លែត ឬមើលដោយក្រសែភ្នែកធម្មតា ដែលមិនមែនជាអ្នកស្រាវជ្រាវ អាចនឹងមិនយល់ពីដំណើរសោច់រឿងនេះឡើយ។

អ្នកស្រាវជ្រាវ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរា **លោក អ៊ឹម សុខរិទ្ធី** បានពន្យល់នូវខ្លឹមសារនៃចម្លាក់ត្រង់ទិដ្ឋភាពនេះថា វាជាភស្តុតាងរូបភាពមួយដែលនាំឲ្យយើងដឹងថា ប្រទេសខ្មែរមានជំនួញផ្លូវទឹកជាមួយប្រទេសជិតខាងនាពេលនោះ បើទោះជាបច្ចុប្បន្ន គេមិនទាន់ដឹងថា កំពង់ផែនៅពេលនោះស្ថិតនៅកន្លែងណាច្បាស់ក៏ដោយ។

តាមការរៀបរាប់របស់អ្នកស្រាវជ្រាវរូបនេះ ចម្លាក់ដែលនៅខាងលើមើលទៅរាងធ្នូតៗកោងៗ គឺជារាងសំពៅ ដើរសមុទ្រប្រើក្តោង២ ដែលមានផ្ទុកទំនិញ និងមនុស្សជាច្រើន។ មនុស្សពីរនាក់ឡើងលើដងទង់ដ៏ខ្ពស់ ដើម្បីមើលផ្លូវជាប្រចាំជៀសវាងការវង្វែង។ នៅក្បែរសំពៅ គេឃើញកូនសំប៉ាន ដែលចូលទៅផ្ទេរទំនិញចុះ ដោយសារទឹករាក់ សំពៅចូលមិនដល់ច្រាំង។ នៅតាមមាត់ច្រាំង ចម្លាក់បង្ហាញពីផ្សារ ដែលសំប៉ានដឹកទំនិញពីសំពៅឡើងគោក ឃើញមនុស្សម្នាដើរចុះឡើងលក់ដូរយ៉ាងកុះករ។ ជាទូទៅនៅខាងក្រោយផ្សារតែងមានល្បែង។ នៅទីនេះក៏មានលេងល្បែងប្រជល់មាន់ដែរ។

សូមទស្សនាចម្លាក់នេះទាំងអស់គ្នាដូចខាងក្រោម ៖









វិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ាគ្រោងនឹងបញ្ចប់ការជួសជុលប្រាង្គខាងជើង នៃប្រាសាទតុបខាងលិចនៅពាក់កណ្តាលឆ្នាំ២០១៧នេះ

ផ្សាយនៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ សេន សែត រូបភាព ៖ ហ៊ុំ រីទ្ធី

វិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ារបស់ប្រទេសជប៉ុន ក្រោមកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមជួសជុលប្រាង្គខាងជើងនៃប្រាសាទតុបខាងលិច ក្នុងជំហានទី២របស់ខ្លួន ចាប់ពីខែកញ្ញា ឆ្នាំ២០១៥មក។ តាមគម្រោង ប្រាង្គនេះអាចនឹងបញ្ចប់ការជួសជុលនៅអំឡុងខែមិថុនា ឆ្នាំ២០១៧ ហើយនឹងចាប់ផ្តើមគម្រោងជួសជុលប្រាង្គកណ្តាលតទៅទៀត។

ក្នុងដំណើរចុះពិនិត្យការដ្ឋានអន្តរជាតិរបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី៩ មីនា ឆ្នាំ២០១៧នេះ អគ្គនាយករងនៃវិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ា **លោក Hiroshi SUGIYAMA** ដែលទទួលបន្ទុកគ្រប់គ្រងការដ្ឋាននេះពន្យល់ថា ការជួសជុលប្រាង្គខាងជើងនេះ បានដំណើរទៅយ៉ាងរលូន ក្រោមកិច្ចសហការសម្របសម្រួលយ៉ាងល្អពីអាជ្ញាធរជាតិអប្សរ ។ **លោក SUGIYAMA** ក៏បានពន្យល់ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា អំពីបច្ចេកទេសនៃការអភិរក្សជួសជុល ការចងក្រងឯកសារ និងចុះបញ្ជីសារពើភណ្ឌជាដើម។ លោកក៏បានសន្យា បន្តជួសជុលប្រាសាទនេះឲ្យបានរួចរាល់តាមគម្រោង ដោយគោរពតាមបទដ្ឋានបេតិកភណ្ឌពិភពលោក និងទទួលយកការផ្លាស់ប្តូរគំនិតជាមួយអ្នកជំនាញផ្សេងៗ ដើម្បីធ្វើយ៉ាងណាឲ្យការងារជួសជុលនេះបានជោគជ័យ និងរក្សាបាននូវតម្លៃដើមនៃបេតិកភណ្ឌ។

លោក ហាន វិត្ថា អ្នកជំនាញការប្រចាំការដ្ឋាននេះបញ្ជាក់ថា ដោយសារប្រាសាទនេះមានភាពទ្រុឌទ្រោមស្ទើរតែ៩០% ដូច្នេះការជួសជុលគឺបានធ្វើឡើងស្ទើរទាំងស្រុង។ ការជួសជុលប្រាង្គខាងជើងនេះ ក្រុមការងារបានរៀបចំគ្រឹះឡើងវិញ និងបន្តរៀបចំរចនាសម្ព័ន្ធផ្សេងៗ ដោយយកថ្មចាស់ដែលមានស្រាប់ និងជំនួសថ្មថ្មីខ្លះ ត្រង់ចំណុចណាដែលស្វែងរកមិនបានហើយមានភាពចាំបាច់ខ្លាំង។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណចំពោះវិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ា ដែលបានបំពេញការងារបានយ៉ាងល្អប្រសើរ។ ឯកឧត្តមក៏បានផ្តាំផ្ញើចំពោះប្រធានគម្រោង ដើម្បីផ្តល់ដំណឹងដល់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាឲ្យបានទាន់ពេលវេលា ករណីមានសំណូមពរ ឬសំណើណាមួយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់អាជ្ញាធរជាតិអប្សរា។

ប្រាសាទតុបខាងលិច ត្រូវបានកសាងឡើងក្នុងរវាងសតវត្សទី១០ ដែលមានរចនាប័ទ្មបន្ទាយស្រី ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា។ ចាប់ពីសតវត្សទី១៣ដល់ទី១៧ ប្រាសាទនេះ ត្រូវបានកែបន្ថែមបន្តិចបន្តួចៗ ដែលយើងឃើញដល់សព្វថ្ងៃដូចជាការកសាងប្រាង្គពីរអមសងខាង ព្រមទាំងរានហាលខាងមុខប្រាសាទបន្ថែមទៀត ជារោងឧបោសថ សម្រាប់ព្រះសង្ឃព្រះពុទ្ធសាសនាថេរវាទជាដើម។ ចាប់ពីឆ្នាំ២០១១មក វិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ា សហការជាមួយអាជ្ញាធរជាតិអប្សរា បានធ្វើការអភិរក្សជួសជុល។ ក្នុងជំហានដំបូង ក្រុមការងារបានជួសជុលប្រាង្គខាងត្បូងរួចរាល់នៅចុងឆ្នាំ២០១៥ ហើយបន្តជួសជុលប្រាង្គខាងជើងថែមទៀតក្នុងជំហានទី២។ ក្នុងជំហានទី៣ ក្រុមការងារនឹងជួសជុលប្រាង្គកណ្តាលនៃប្រាសាទដែលតាមគម្រោងនឹងបញ្ចប់នៅឆ្នាំ២០២០ខាងមុខ៕









ក្នុងខែកុម្ភៈ អាជ្ញាធរជាតិអប្សរាចុះផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកស្រុកអង្គរបានជាង៥០០នាក់

ផ្សាយនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ អោក សំអុល រូបភាព ៖ ក្រុមការងារសហគមន៍

អង្គរដោរមណីយដ្ឋានមានជីវិតដែលផ្តុំឡើងដោយសមាសធាតុសំខាន់ៗចំនួន៣គឺ ប្រាង្គប្រាសាទ បរិស្ថាននិងសហគមន៍មនុស្ស ។ ការធ្វើឲ្យមានសុខដុមនីយកម្មទៅនឹងសមាសធាតុខាងលើនេះ គឺវាកាន់តែជួយលើកតម្លៃរមណីយដ្ឋានអង្គរឲ្យលេចធ្លោជាសកលឡើងថែមទៀត និងបានក្លាយទៅជាចលករយ៉ាងសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរចម្រុះជាតិសាសន៍ ឲ្យមកទស្សនារមណីយដ្ឋានអង្គរកាន់តែច្រើនឡើងជារៀងរាល់ឆ្នាំ ។ក្នុងបរិបទនេះហើយបានជាអាជ្ញាធរជាតិអប្សរាត្រូវផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងស្តីពីបេតិកភណ្ឌដល់ប្រជាពលរដ្ឋឲ្យពួកគាត់បានយល់សំដៅ ធ្វើយ៉ាងណាដើម្បីឲ្យបេតិកភណ្ឌនេះគង់វង្សដល់កូនចៅជំនាន់ក្រោយទៀត។

ទន្ទឹមគ្នានេះដែរ អាជ្ញាធរជាតិអប្សរាក៏បានឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលស្នើសុំសាងសង់សំណង់តូចតាច និងអនុញ្ញាតជូនពួកគាត់ភ្លាមៗនៅនឹងកន្លែង ដើម្បីជួយសម្រួលដល់ពេលវេលា និងការធ្វើដំណើររបស់ពួកគាត់។ បន្ថែមពីនេះទៀត ក្រុមការងារសហគមន៍ក៏ជាក្រុមជួយសង្គ្រោះបន្ទាន់ ក្នុងករណីគ្រោះថ្នាក់ធម្មជាតិដែលកើតមានឡើងចំពោះប្រជាពលរដ្ឋក្នុងតំបន់អង្គរ និងនាំយកកញ្ចប់ទារកចែកជូនស្ត្រីទើបសម្រាលកូនជាដើម។

លោក អឿន សំអុន អនុប្រធានលេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានលើកឡើងថាក្នុងខែកុម្ភៈកន្លងទៅក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះអប់រំផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងស្តីពីបេតិកភណ្ឌដល់ប្រជាពលរដ្ឋបានចំនួន៩ភូមិ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន៥១៨នាក់ ដើម្បីឲ្យពួកគាត់ចូលរួមជួយក្នុងកិច្ចការថែរក្សា

ការពារ និងអភិរក្សសម្បត្តិបេតិកភណ្ឌ ។ ជាមួយគ្នានេះដែរ ក្រុមការងារបានពិនិត្យ និងអនុញ្ញាតសំណើសុំសាងសង់សំណង់តូចតាចដល់មូលដ្ឋានជូនប្រជាពលរដ្ឋផ្ទាល់ បានចំនួន៦០ករណីនិងចែកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកជូនដល់ស្ត្រីទើបឆ្លងទន្លេរួចចំនួន១៦៤គ្រួសារ។

ក្រៅពីនេះ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាក៏បានចុះសាកសួរសុខទុក្ខ ដោយនាំយកថវិការបស់អាជ្ញាធរជាតិអប្សរាចំនួន២លានរៀលទៅឧបត្ថម្ភ**លោក ឈួន ឯម** មេឃុំស្វាយចេកដែលរងគ្រោះដោយភ្លើងឆេះផ្ទះ និងថវិកាចំនួន១លានរៀលទៀតទៅឧបត្ថម្ភការសាងសង់សាលាឆទាននៅឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាបផងដែរ៕









មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរាចែករំលែកបទពិសោធន៍ការគ្រប់គ្រងទេសចរណ៍អង្គរ ដល់លោកគ្រូអ្នកគ្រូមកពីវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល

ផ្សាយនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ សេន សែត រូបភាព ៖ ហ៊ុំ រីទ្ធី

លោកគ្រូ អ្នកគ្រូ និងនិស្សិតដែលមកពីវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល នៃខេត្តកំពង់ធំសរុបចំនួន៧រូប បានមកទទួលយកបទពិសោធន៍នៃការងារគ្រប់គ្រងវិស័យទេសចរណ៍ ក្នុងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ នារសៀលថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរា។

លោក ភួង សុកគ្រ មន្ត្រីជំនាញនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ បានធ្វើបទបង្ហាញជូនលោកគ្រូ អ្នកគ្រូ និងនិស្សិត អំពីការរៀបចំផែនការគ្រប់គ្រងទេសចរណ៍អង្គរ និងការអនុវត្តជាក់ស្តែង។ តាមមន្ត្រីជំនាញរូបនេះ ការគ្រប់គ្រងទេសចរណ៍អង្គរ គឺផ្តោតសំខាន់លើការគ្រប់គ្រងផលប៉ះពាល់នានា ដែលអាចនឹងបង្កឡើងដោយភ្ញៀវទេសចរ ដើម្បីរក្សាគុណតម្លៃដើមនៃបេតិកភណ្ឌអង្គរ។ ជាពិសេស គឺធ្វើយ៉ាងណាឲ្យភ្ញៀវទេសចរដែលមកទស្សនាបេតិកភណ្ឌអង្គរហើយទទួលបានបទពិសោធន៍ត្រឡប់ទៅវិញ។

អ្នកគ្រូ ស៊ុន ធារី ជាគ្រូបង្រៀនផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ចនៃវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល បានបញ្ជាក់ថា ដោយយល់ឃើញថា ស្ថាប័នអាជ្ញាធរជាតិអប្សរាជាស្ថាប័នដែលធ្វើការផ្ទាល់ជាមួយនឹងបេតិកភណ្ឌ ជាពិសេស គឺការគ្រប់គ្រងវិស័យទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌ ដូច្នេះហើយ ទើបថ្នាក់ដឹកនាំនៃវិទ្យាស្ថានសម្រេចបញ្ជូនក្រុមការងារមកទទួលយកបទពិសោធន៍លើការងារនេះ។ លោកគ្រូបន្តថា អ្វីដែលអ្នកគ្រូបានទទួលពីបទបង្ហាញនៅពេលនេះ មានដូចជាវិធានការទប់ស្កាត់ផលប៉ះពាល់ដែលបង្កឡើងពីទេសចរយ៉ាងណា ការធ្វើយ៉ាងណា ឲ្យភ្ញៀវទេសចរអាចទទួលបានបទពិសោធន៍ល្អត្រឡប់ទៅកាន់ប្រទេសរបស់គេវិញជាដើម។ ជាមួយគ្នានេះ លោកគ្រូបញ្ជាក់ថា ក្រុមការងាររបស់អ្នកគ្រូនឹងនាំយកចំណេះទាំងនេះទៅបញ្ចូលក្នុងមេរៀន ចែករំលែកដល់និស្សិតដែលកំពុងសិក្សានៅក្នុងវិទ្យាស្ថាន។

នេះជាមិនមែនជាលើកទី១ទេ កន្លងមកមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាក៏ធ្លាប់បានធ្វើបទបង្ហាញជូននិស្សិត អ្នកជំនាញ និងអ្នកស្រាវជ្រាវជាតិ-អន្តរជាតិជាច្រើន ដែលមានបំណងចង់ស្វែងយល់ពីការងារគ្រប់គ្រងបេតិកភណ្ឌពិភពលោកអង្គរ។ នេះក៏ជាការបង្ហាញឲ្យឃើញពីធនធានមនុស្សអាជ្ញាធរជាតិអប្សរា ដែលមានសមត្ថភាពគ្រប់គ្រាន់ទាំងការងារអនុវត្តជាក់ស្តែង ក៏ដូចជាការចែករំលែកនូវបទពិសោធន៍របស់ខ្លួនទៅកាន់ឆាកអន្តរជាតិដែរ៕









មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាក្រាប់ពលរដ្ឋកុំឲ្យបារម្ភពីបញ្ហាដង្កូវចោះដើមឈើ

ផ្សាយនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៧ ដោយ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ សួន គង់សុភារិទ្ធ

ហ្វូងដង្កូវជាច្រើន បាននិងកំពុងបំផ្លាញដើមរុក្ខជាតិរបស់អ្នកភូមិអង្គរ ដូចជាដើមត្នោត និងដើមដូង។ អ្នកជំនាញបានហៅជំងឺនេះថា ជាជំងឺក្រាស្លើង ហើយវាតែងកើតមាននៅរដូវក្តៅ ដែលវាស៊ីមែកស្លឹកដើមត្នោត និងដូង។ យ៉ាងណា អ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា បានប្រាប់ប្រជាពលរដ្ឋកុំឲ្យបារម្ភពីបញ្ហានេះ ព្រោះថាដង្កូវនោះគ្រាន់តែស៊ីស្លឹក ហើយវាមិនបង្កឲ្យដើមរុក្ខជាតិងាប់ទេ។

ដើម្បីទប់ស្កាត់បញ្ហាទាំងនេះ អ្នកជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានប្រាប់ពីវិធីដើម្បីទប់ស្កាត់ ការរាតត្បាតជំងឺដង្កូវចោះនេះ។ **លោក សួន គង់សុភារិទ្ធ** បុគ្គលិកផ្នែកដាំឈើបានឲ្យដឹងថា ជាដំហានដំបូងគេអាចទប់ស្កាត់ជំងឺខាងលើនេះ ដោយការកាត់មែកដែលដង្កូវស៊ីចេញ និងប្រមូលដុតចោលដើម្បីបង្ការពីការរាតត្បាត ដោយសារការបង្កកំណើតរបស់ហ្វូងដង្កូវ។

តាមការបញ្ជាក់របស់**លោក គង់សុភារិទ្ធ** យើងក៏អាចប្រើថ្នាំគីមីពុលដើម្បីកំចាត់ហ្វូងដង្កូវនេះបានផងដែរ និងវិធានការមួយទៀត គឺការផ្សំថ្នាំបុរាណ ដោយយកថ្នាំជក់លាយជាមួយសំបកស្លែង រួចបាញ់ស្លឹក ឬដើមដែលដង្កូវចោះ។

តាមការចុះស្រាវជ្រាវ និងសួរប្រជាពលរដ្ឋ គេបានរកឃើញថា បញ្ហានេះបានកើតឡើងរយៈពេល២ទៅ៣ឆ្នាំហើយ ប៉ុន្តែវាមិនច្រើនដូចឆ្នាំនេះ។ តំបន់ដែលមានបញ្ហាដង្កូវចោះស៊ីស្លឹកដើមឈើនេះច្រើនជាងគេ គឺនៅភូមិក្រវ៉ាន់ និងភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប។ អ្នកជំនាញពន្យល់ថា ដង្កូវបានចោះស៊ីធាងដូងខ្លាំងជាងដើមត្នោត ហើយដោយសារមិនសូវធន់នោះ ធ្វើឲ្យដើមដូងមួយចំនួនតូច បានងាប់ដោយសារជំងឺនេះផងដែរ។

លោក គង់សុភារិទ្ធ បានបន្ថែមថា៖« ដើមត្នោតធន់ជាងដើមដូង។ តាមការចុះត្រួតពិនិត្យ យើញថាមានដើមដូងខ្លះបានងាប់ ដោយសារដង្កូវស៊ីខ្លាំងពេក។ ដំណោះស្រាយ យើងត្រូវរួសរាន់ កាត់មែកដែលដង្កូវស៊ីនោះចេញ និងប្រមូលដុតភ្លាមដៀសវាងកុំឲ្យវារាតត្បាតតទៅទៀត...»។

ប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា **លោក និន ចាន់សាមៀន** បានពន្យល់ពីបាតុភូតនេះផងដែរថា វាមិនមានអ្វីដែលគួរឲ្យបារម្ភនោះទេ។ **លោក សាមៀន** ពន្យល់យ៉ាងដូច្នេះថា៖« គេគ្រាន់តែកាត់មែកភ្លាមៗ យកទៅដុតចោល នោះពងដង្កូវនឹងងាប់អស់។ ដើមដែលដង្កូវស៊ីអស់ គឺវានឹងលាស់ស្លឹកថ្មីវិញ វាអត់ងាប់ទេ ដូច្នេះសូមប្រជាពលរដ្ឋកុំបារម្ភ នៅពេលដង្កូវវាក្លាយជាមេអំបៅ ហើយមេអំបៅនោះ នឹងហើរចេញពីកន្លែងនោះ លែងមានអ្វីកើតឡើងទៀតហើយ...»៕









ឯកឧត្តមអគ្គនាយករអាជ្ញាធរជាតិអប្សរា ចូលជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំស្ថាប័នមួយចំនួនរបស់ជប៉ុន ដែលបានជួយលើការងារអភិរក្សនៅតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ លឹម ស្រ៊ូ រូបភាព ៖ លឹម ស្រ៊ូ

ក្នុងដំណើរទស្សនកិច្ចទៅកាន់ប្រទេសជប៉ុន **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាម៉** អគ្គនាយកអាជ្ញាធរជាតិអប្សរាបានដឹកនាំមន្ត្រីបច្ចេក ទេស មួយចំនួន ដើម្បីចូលជួបសម្តែងការគួរសមដល់ថ្នាក់ដឹកនាំស្ថាប័នមួយចំនួនដែលតែងតែផ្តល់ការគាំទ្រ និងជួយជ្រោមជ្រែងយ៉ាងសំខាន់ដល់កិច្ចការអភិរក្សប្រាសាទនៅតំបន់អង្គរ។

ស្ថាប័នដែលឯកឧត្តមអគ្គនាយក និងក្រុមការងាររួមជាមួយ**លោកសាស្ត្រាចារ្យ** Yoshiaki Ishizawa ប្រធានមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សនៃសាកលវិទ្យាសូហ្វីយ៉ា បានចូលជួបពិភាក្សា និងសម្តែងការគួរសមជា បន្តបន្ទាប់នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧នេះរួមមាន:

១. ជួបជាមួយ**លោក** Toshiaki koso ប្រធានក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ សូហ្វីយ៉ា នៅសាកលវិទ្យាល័យសូហ្វីយ៉ា ក្រុងតូក្យូប្រទេសជប៉ុន។

២.ជួបពិភាក្សាជាមួយ**លោក** YAMAZAKI Hide Yasu អគ្គនាយកបេតិកភណ្ឌវប្បធម៌ រដ្ឋាភិបាលជប៉ុន។

៣.ជួបពិភាក្សា និងសម្តែងការគួរសមជាមួយ**លោកស្រី** Hiroko Tsuka អនុប្រធានស្ថាប័ន Japan Foundation។

៤. ជួបជាមួយ**លោក** Makita Shinokawa អគ្គនាយកទទួលបន្ទុកកិច្ចការវប្បធម៌ នៃក្រសួងការបរទេសជប៉ុន។

ក្នុងជំនួបជាមួយថ្នាក់ដឹកនាំស្ថាប័នសំខាន់ទាំងនោះ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណចំពោះការជួយយកចិត្តទុកដាក់លើកិច្ចការអភិរក្សជួសជុល ក៏ដូចជាការស្រាវជ្រាវក្នុងតំបន់អង្គរនារយៈកាលកន្លងមក។ ឯកឧត្តមក៏មិនភ្លេចថ្លែងអំណរគុណចំពោះរដ្ឋាភិបាលក៏ដូចជាប្រជាជនជប៉ុនដែលតែងតែជួយកម្ពុជាគ្រប់កាលៈទេសៈទោះក្នុងស្ថានភាពណាក៏ដោយ។

ថ្នាក់ដឹកនាំនៃស្ថាប័នជប៉ុនដែលឯកឧត្តមអគ្គនាយកបានជួបពិភាក្សា និងសម្តែងការគួរសមជាបន្តបន្ទាប់នោះ សុទ្ធតែបានអរគុណ និងសន្យាជួយដល់កម្ពុជាជាបន្តទៀត ជាពិសេស ផ្តោតលើកិច្ចការបណ្តុះបណ្តាលធនធានមនុស្ស ការស្រាវជ្រាវជួសជុលប្រាង្គប្រាសាទ ក៏ដូចជាការផ្តល់នូវមធ្យោបាយផ្សេងៗទៀតសម្រាប់បម្រើដល់កិច្ចការអភិរក្សជាដើម៕









អាជ្ញាធរជាតិអប្សរាសូមជូនពរ និងអបអរសាទរចំពោះ សម្តេចវិបុលបញ្ញា សុខ អាន

ផ្សាយនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៧

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លាដែល **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ប្រោសព្រះរាជទានគោរមងារជា **សម្តេចវិបុលបញ្ញា សុខ អាន** , **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាច** អគ្គនាយក អាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកក្រោមឱវាទសូមគោរពជូនពរ **សម្តេចវិបុលបញ្ញា សុខ អាន** បានប្រកបដោយសព្វសាធុការពរ ទទួលបាននូវសុខភាពបរិបូរណ៌ បញ្ញាញាណវាងវៃ អាយុយឺនយូរ ដើម្បីចូលរួមបន្តដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយជារៀងរហូត។

សូម **សម្តេចវិបុលបញ្ញា សុខ អាន** និង លោកជំទាវ ព្រមទាំង បុត្រា-បុត្រី ចៅប្រុស-ចៅស្រីជាទីស្រឡាញ់ជួបតែសេចក្តីសុខ សុភមង្គល និងប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀតឃ្លាតឡើយ។

សូមគោរពជូនពរ និងអបអរសាទរ

ដោយស្មោះអស់ពីដួងចិត្តជូនចំពោះ

ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវបាន
ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះរាជទានគោរមងារជា សម្តេចវិបុលបញ្ញា សុខ អាន



ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក និងទេវតាថែរក្សាទឹកដីនៃ ព្រះរាជាណាចក្រកម្ពុជា សូមតាមជួយអភិបាល ប្រោះព្រំសព្វសាធុការពរជ័យ គ្រប់ប្រការជូនចំពោះ **សម្តេចវិបុលបញ្ញា សុខ អាន** សូមបានប្រកប ដោយសព្វសាធុការពរ ទទួលបាននូវសុខភាពបរិបូរណ៌ បញ្ញាញាណវាងវៃ អាយុយឺនយូរ ដើម្បីចូលរួមបន្តដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយជារៀងរហូត។

សូម **សម្តេចវិបុលបញ្ញា សុខ អាន** និង **លោកជំទាវ** ព្រមទាំង បុត្រា-បុត្រី ចៅប្រុស-ចៅស្រីជាទីស្រឡាញ់ជូបតែ សេចក្តីសុខ សុភមង្គល និងប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀតឃ្លាតឡើយ។

សូមគោរពជូនពរនិងអបអរសាទរពី

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់ អគ្គនាយក អាជ្ញាធរជាតិអប្សរ
ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រី បុគ្គលិក ក្រោមឱវាទ

សេចក្តីជូនដំណឹងស្តីពីការធ្វើកំណាយស្រាវជ្រាវនៅប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ០៥៤/១០.៧៨៧
/១៧

សេចក្តីជូនដំណឹង
ស្តីពី
ការធ្វើកំណាយស្រាវជ្រាវនៅប្រាសាទតាព្រហ្ម

អគ្គនាយកអាជ្ញាធរអប្សរា មានកិត្តិយសសូមជម្រាបជូនដល់គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ និងសាធារណជនទាំងអស់ មេត្តាជ្រាបថា ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការក្នុងការជួសជុលនិងលើកតម្លៃប្រាសាទតាព្រហ្ម អាជ្ញាធរអប្សរាបានអនុញ្ញាតឱ្យស្ថាប័ន ASI (Archaeological Survey of India) ដើម្បីធ្វើការកំណាយស្រាវជ្រាវស្ថិតនៅផ្នែកខាងត្បូងនៃសាលរបាំនៃប្រាសាទតាព្រហ្មដែលមានទទឹង២ម៉ែត្រ(ដូចមានប្លង់ជូនភ្ជាប់ជាមួយ) ដែលត្រូវចាប់ផ្តើមធ្វើកំណាយចាប់ពីថ្ងៃទី១៣ ខែមីនា ដល់ថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០១៧ តទៅ។

អាជ្ញាធរអប្សរាសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទេសក៍ទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។ ./.

សៀមរាប ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៧
អគ្គនាយក

ចម្លងជូន:
-សាលាខេត្តសៀមរាប
-គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជុំវិញខេត្ត
-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
-សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
-សមាគមមគ្គុទេសក៍ទេសចរណ៍
-សមាគមអ្នកបើកបរថយន្តដឹកជញ្ជូនភ្ញៀវទេសចរ
-គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះ
-ឯកសារ-កាលប្បវត្តិ

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពារគ្រប់គ្រងរមណីយដ្ឋាននិងតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

ឯកសារដ៏មានសារៈសំខាន់សម្រាប់អ្នកចង់ដឹងពីតំបន់អង្គរដែលជាបេតិកភណ្ឌពិភពលោក

ផ្សាយនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ អោក សំអុល

សៀវភៅថ្មីដ៏មានសារៈប្រយោជន៍ចំនួន៨ក្បាល និង៨ចំណងជើងដែល មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរាទើបនឹងទទួលបាន ត្រូវបានដាក់តម្កល់ទុកក្នុងបណ្ណាល័យរបស់មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរាសម្រាប់ប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ។ នេះបើយោងតាមសេចក្តីជូនដំណឹងរបស់មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរាកាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧។

ខ្លឹមសារនៃសៀវភៅទាំងនេះមានដូចជា៖

- លទ្ធផលនៃការស្រាវជ្រាវនៅប្រទេសកម្ពុជា ថៃ ភូមា វៀតណាមនិងឡាវតាមរយៈការសិក្សាសិលាចារឹក និងកំណាយបុរាណវិទ្យាជាពិសេសលទ្ធផលស្រាវជ្រាវដ៏សន្លឹកសន្ធាប់នៅតំបន់អង្គរ របស់អ្នកស្រាវជ្រាវជាតិបារាំងដែលជារបកគំហើញថ្មីអំពីអង្គរ។
- លទ្ធផលនៃការធ្វើកំណាយសង្គ្រោះក្នុងបរិវេណព្រលានយន្តហោះខេត្តសៀមរាប
- បញ្ជីសារពើភណ្ឌសមុច្ច័យបានពីកំណាយ
- កាលបរិច្ឆេទស្តានីយ
- លទ្ធផលនៃការធ្វើកំណាយសង្គ្រោះនៅលើកន្លែងដែលមានមនុស្សតាំងទីរស់នៅនាស.វ.ទី១២-១៣ នៅក្នុងបរិវេណព្រលានយន្តហោះខេត្តសៀមរាប
- ចំនួនរមណីយដ្ឋាននៅលើភ្នំគូលែន
- ការបរិយាយនិងចំណុចនិយាមការនៃរមណីយដ្ឋាននីមួយៗ
- ការជួសជុលប្រាសាទបាពួន
- កាលបរិច្ឆេទថ្មីនៃប្រាសាទបាពួកតាមការសិក្សាស្រាវជ្រាវរបស់លោកPascal Royére
- គំនូរប្លង់
- រូបថតល្អៗបង្ហាញពីចម្លាក់រឿងទេពកថាតូចៗទាំងឡាយនៃប្រាសាទបាពួក
- វប្បធម៌គឺជាចតុស្តម្ភនៃការអភិវឌ្ឍដោយចីរភាព
- ទឹក និងមរតកនៅអង្គរ ប្រាសាទ ប្រព័ន្ធធារាសាស្ត្របុរាណនិងការជួសជុលស្តារឡើងវិញនាពេលថ្មីៗនេះ
- ការសិក្សាស្រាវជ្រាវពីប្រវត្តិព្រះវិហារវត្តប្រាសាទបាគងខេត្តសៀមរាប តាមវិធីសាស្ត្រជាតិពិន្ទុវិទ្យា និងកំណាយបុរាណ
- កិច្ចការអភិរក្សព្រះវិហារវត្តប្រាសាទបាគងផ្នែកគំនូរផៅត់ពណ៌និងសំណង់ស្ថាបត្យកម្ម
- ការងារនេះធ្វើដោយអ្នកជំនាញខ្មែរស្ទើរតែទាំងស្រុង
- សកម្មភាពស្រាវជ្រាវ ជួសជុល ថែរក្សា និងអភិរក្សមរតកវប្បធម៌រូបី និងអរូបីរបស់សាកលវិទ្យាល័យសូហ្វីយ៉ា នៃប្រទេសទាំង៥ក្នុងតំបន់អាស៊ី
- របាយការណ៍សិក្ខាសាលារបស់សាកលវិទ្យាល័យសូហ្វីយ៉ាបានធ្វើនៅឆ្នាំ២០១៥ អមដោយអត្ថបទរបស់វាគ្មិននិងបទបង្ហាញដោយសាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវល្បីៗ ក្នុងនោះមានវាគ្មិនខ្មែរដូចជាសាស្ត្រាចារ្យ អាំង ជូលាន បណ្ឌិត លី រណ្ណា បណ្ឌិត ទិន ទីណា បណ្ឌិត ឈាន រដ្ឋា និង លោក ម៉ៅ សុខនី។

សៀវភៅទាំងនេះមានប្រយោជន៍ខ្លាំងណាស់សម្រាប់ អ្នកស្រាវជ្រាវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ និង សាធារណៈជន ដែលចង់សិក្សាស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាពនិងបង្កើនចំណេះដឹងអំពីប្រវត្តិសាស្ត្រ វប្បធម៌ អរិយធម៌ ការរៀបចំរមណីយដ្ឋាន លទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីៗ និងព័ត៌មានដែលពាក់ព័ន្ធនឹងការជួសជុលប្រាសាទនានា ក្នុងតំបន់អង្គរ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក។

មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរាសូមស្វាគមន៍ រងចាំទទួលមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា អ្នកស្រាវជ្រាវជាតិអន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ និងសាធារណជនទាំងអស់ដែលមានបំណងចង់មកអាន ឬខ្ចីឯកសារទាំងនេះដោយមេត្រីភាព៕









ដំណឹងជ្រើសរើសបុគ្គលិកផ្នែកព័ត៌មាន ផ្នែកថតរូបភាព និងផ្នែកផលិតវីដេអូ

ផ្សាយនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N°១៧៩/ន.ប.ស.ជ.ល
១៧

សៀមរាប ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៧

ដំណឹងជ្រើសរើសបុគ្គលិក

អាជ្ញាធរអប្សរា "អាជ្ញាធរដើម្បីការពារមណ្ឌលដ្ឋាន និងរៀបចំតំបន់អង្គរ" (www.apsaraauthority.gov.kh) សូមជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា អាជ្ញាធរអប្សរា នឹងធ្វើការជ្រើសរើសបុគ្គលិកកម្រិតសញ្ញាបត្រទុតិយភូមិ និងបរិញ្ញាបត្រចំនួន**០៥រូប** ឲ្យបម្រើការងារនៅនាយកដ្ឋានផ្សព្វផ្សាយ។

១- បុគ្គលិកដែលត្រូវជ្រើសរើស មានដូចខាងក្រោម៖
- ផ្នែកព័ត៌មានចំនួន០២រូប
- ផ្នែកថតរូបចំនួន០២រូប
- ផ្នែកផលិតវីដេអូចំនួន០១រូប

២- លក្ខខណ្ឌនៃការជ្រើសរើស មានដូចតទៅ៖
- ត្រូវមានសញ្ញាបត្រទុតិយភូមិ
- ត្រូវមានជំនាញផ្នែកថតរូប កាត់តរូបភាព និងថតវីដេអូ
- ត្រូវមានជំនាញផ្នែកសារព័ត៌មាន
- ត្រូវមានបរិញ្ញាបត្រផ្នែកអក្សរសាស្ត្រខ្មែរ (បើចេះភាសារអង់គ្លេសកាន់តែប្រសើរ)

៣. លក្ខណៈសម្បត្តិនៃការជ្រើសរើស៖
- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- ធ្លាប់មានបទពិសោធន៍ការងារចាប់ពី១ឆ្នាំឡើងទៅ (បើមានកាន់តែប្រសើរ)
- មានអាយុចាប់ពី១៨-៣៥ឆ្នាំ
- មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ
- មានសុខភាពល្អ

៤. សំណុំឯកសារដែលត្រូវមាន៖
- ជីវប្រវត្តិរូបសង្ខេបមានបិទរូបថតទំហំ (៤x៦)
- ថតចម្លង និងបញ្ជាក់សញ្ញាបត្រ ដោយមានការទទួលស្គាល់ជាផ្លូវការពីក្រសួងចេញ-យ៉ាងតិចមួយ
- ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬ សៀវភៅស្នាក់នៅ០១ច្បាប់
- ថតចម្លងសំបុត្រកំណើត០១ច្បាប់

៥-ទីកន្លែងទទួលពាក្យ៖ ទីស្នាក់ការអាជ្ញាធរអប្សរាថ្មី "មជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា" នៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧**។

៦-ការសម្ភាសបេក្ខជន៖ បញ្ជីសម្រាំងបេក្ខជនដែលត្រូវឆ្លងកាត់ការសម្ភាសន៍ជ្រើសរើស និងកាលបរិច្ឆេទសម្ភាសន៍ នឹងបិទផ្សាយនៅស្នាក់ការអាជ្ញាធរអប្សរាខេត្តសៀមរាប និងជូនដំណឹងតាមទូរស័ព្ទ។

៧-ព័ត៌មានចាំបាច់៖ សូមទំនាក់ទំនងមកលេខទូរស័ព្ទ ០១២/០៩៣ ៩៨៦ ៨១៧

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពារមណ្ឌលដ្ឋាននិងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានិងមន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់ប្រារព្ធពិធីគោរព វិញ្ញាណក្ខន្ធ សម្តេចវិបុលបញ្ញា សុខ អាន

ផ្សាយនៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ សឿន ប៊ុនសិរ

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរាបានរៀបចំប្រារព្ធ ពិធីគោរពវិញ្ញាណក្ខន្ធ និងបំពាក់កម្រងផ្កាជូន**សម្តេចវិបុលបញ្ញា សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអាជ្ញាធរជាតិអប្សរា ដែលបានទទួលមរណភាពកាលពីថ្ងៃ៣រោជ ខែផល្គុន ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ២៥៦០ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧វេលាម៉ោង១៨:៣២នាទីដោយរោគាពាធក្នុងជន្មាយុ៦៦នៅប្រទេសចិន។

ពិធីនេះមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា រួមទាំងមន្ត្រីស្ថាប័នអន្តរជាតិមួយចំនួនទៀត បានធ្វើពិធីស្មឹងស្មាធ៍ដើម្បីសម្តែងការគោរពវិញ្ញាណក្ខន្ធ និងសម្តែងនូវសេចក្តីទុក្ខសោកយ៉ាងក្រៀមក្រំ ពោរពេញទៅដោយសេចក្តីសោកស្តាយស្រណោះអាឡោះអាល័យជាទីបំផុត ចំពោះមរណភាពរបស់**សម្តេចវិបុលបញ្ញាសុខ អាន** ។

ពិធីនេះ ត្រូវបានធ្វើឡើងដើម្បីសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះគុណូបការៈរបស់**សម្តេចវិបុលបញ្ញា សុខ អាន** ដែលបានលះបង់កម្លាំងកាយចិត្តរបស់សម្តេច ក្នុងបុព្វហេតុការពារជាតិមាតុភូមិ និងជាពិសេស គឺការលះបង់ដ៏ធំធេងក្នុងការងារគ្រប់គ្រង និងថែរក្សាបេតិកភណ្ឌពិភពលោកអង្គរ ដែលជាកេរមរតកដ៏មានតម្លៃរបស់ខ្មែរ។

តាមរយៈកិច្ចពិធីនេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា រួមទាំងមន្ត្រីស្ថាប័នអន្តរជាតិ សូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារនៃសពសម្តេច និងសូមបួងសួងវត្ថុស័ក្តិសិទ្ធិព្រមទាំងកុសលផលបុណ្យ សូមឱ្យដួងវិញ្ញាណក្ខន្ធរបស់សម្តេច បានទៅចាប់បដិសន្ធិសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូមបញ្ជាក់ថាពិធីគោរពវិញ្ញាណក្ខន្ធ**សម្តេចវិបុលបញ្ញា សុខ អាន** នេះ អាជ្ញាធរជាតិអប្សរាបានរៀបចំកន្លែងមួយនៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរាដើម្បីទុកឱកាសឲ្យថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា រួមទាំងមន្ត្រីស្ថាប័នអន្តរជាតិ ចូលទៅគោរពវិញ្ញាណក្ខន្ធ សម្តេចចាប់ពីព្រឹកថ្ងៃទី១៧ មីនារហូតថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៤:៣០នាទីល្ងាចទើបចប់ ៕









លោកដំទាវ អ៊ីរីណា បូកូវ៉ា អគ្គនាយិការអង្គការយូណេស្កូ សម្តែងគារវកិច្ចចំពោះមរណភាពរបស់ សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ឡុង កុសល រូបភាព ៖ ឡុង កុសល

លោកដំទាវបានបញ្ជាក់ថា "មរណភាពរបស់**សម្តេចឧបុលបញ្ញា សុខ អាន** គឺជាការបាត់បង់ដ៏ធំធេងសម្រាប់សហគមន៍ពិភពលោកដែលយកចិត្តទុកដាក់លើការងារបេតិកភណ្ឌ។ សម្តេចគឺជាស្ថាបនិកដ៏សំខាន់មួយរូបនៅក្នុងយុទ្ធនាការអន្តរ-ជាតិ ដើម្បីសង្គ្រោះ ស្រោចស្រង់ និងគាំពារអភិរក្សរមណីយដ្ឋានបុរាណអង្គរ ព្រមទាំងនៅក្នុងដំណើរការចុះរមណីយដ្ឋាននេះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូកាលពីឆ្នាំ១៩៩២។ អាស្រ័យដោយឆន្ទៈ ជំនាញ និងភាពប៉ិនប្រសព្វគ្មានពីរបស់សម្តេច បានធ្វើឲ្យ **សម្តេចឧបុលបញ្ញា សុខ អាន** ក្លាយជាបុគ្គលដ៏សំខាន់មួយរូបក្នុងបណ្តាឥស្សរជនដ៏កម្រកបាននៅលើសកលលោក ដែលអាចដុះឥទ្ធិពលជាវិជ្ជមាន ព្រមទាំងលើកកម្ពស់ដល់កិច្ចការពារ និងអភិរក្សរមណីយដ្ឋានធម្មជាតិ និងវប្បធម៌យ៉ាងទូលំទូលាយ គឺមិនត្រឹមតែនៅក្នុងព្រំប្រទល់ខណ្ឌសីមា នៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ»។

លោកដំទាវបន្តថា «សម្តេច គឺជាកល្យាណមិត្តដ៏សំខាន់មួយរូបរបស់អង្គការយូណេស្កូ ដោយជាបន្តបន្ទាប់សម្តេចបានទទួលតួនាទីជាប្រធានគណៈកម្មការជាតិកម្ពុជាសម្រាប់យូណេស្កូ ប្រធានអាជ្ញាធរអប្សរា និងជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ សម្តេចបានចាត់ទុកបេតិកភណ្ឌ គឺជាមូលដ្ឋានគ្រឹះ នៃសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងជាយន្តការសម្រាប់ការសន្ទនាគ្នា ដើម្បីសន្តិភាព»។





មន្ត្រីជាន់ខ្ពស់២រូបរបស់គណបក្សសង្គ្រោះជាតិលោក លិម គិមយ៉ា និងលោក ហ៊ីង យឿន ធ្វើលិខិតសុំទោសដល់វិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន ទាំងយប់ថ្ងៃនេះតែម្តង

ផ្សាយនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ឡុង កុសល រូបភាព ៖ ឡុង កុសល

(ភ្នំពេញ)៖ តំណាងរាស្ត្ររបស់គណបក្សសង្គ្រោះជាតិ លោក លិម គិមយ៉ា និងមន្ត្រីជាន់ខ្ពស់បក្សប្រឆាំងលោក ហ៊ីង យឿន បានចេញមកសុំទោសដល់វិញ្ញាណក្ខន្ធសព **សម្តេចវិបុលបញ្ញា សុខ អាន** គឺដោយមន្ត្រីគណបក្សសង្គ្រោះជាតិនាំយកលិខិតមកដល់គេហដ្ឋានតែម្តង នៅយប់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧នេះ ហើយក្មួយប្រុស**សម្តេចវិបុលបញ្ញា សុខ អាន** ឈ្មោះ សុខ ខាវ៉ាន់ ជាអ្នកទទួលនូវលិខិតសុំទោសជាសាធារណៈនេះ។

នៅក្នុងលិខិតសុំទោសរបស់មន្ត្រីជាន់ខ្ពស់ទាំងពីររូបនោះ បានសរសេរថា៖ «ខ្ញុំសុំលោកជំទាវ និងក្រុមគ្រួសារមេត្តាអធ្យាស្រ័យចំពោះកំហុសឆ្គងនៃការសន្ទនារបស់ខ្ញុំ ដែលបានធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃសព **សម្តេចវិបុលបញ្ញា សុខ អាន**»។

ខាងក្រោមនេះជាសកម្មភាពមន្ត្រី CNRP គោរពវិញ្ញាណក្ខន្ធ និងលិខិតសុំទោស៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំ **លិម គិមយ៉ា** តំណាងរាស្ត្រមណ្ឌលកំពង់ធំ

សូមគោរពជូន
លោកជំទាវ អាល្លី សុខ អាន

លោកជំទាវ,

ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងចំពោះការសន្ទនារបស់ខ្ញុំតាមទូរស័ព្ទជាមួយឯកឧត្តម **ហ៊ីង យឿន** អគ្គលេខាធិការរងព្រឹទ្ធសភាអំពីមរណៈភាព**សម្តេចវិបុលបញ្ញា សុខ អាន** ដែលត្រូវបានគេលួចថតយកមកផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងកិត្តិយសនៃសព ហើយនឹងធ្វើឱ្យក្រុមគ្រួសាររបស់លោកជំទាវមានការឈឺចាប់ ។

ខ្ញុំសុំលោកជំទាវ និងក្រុមគ្រួសារមេត្តាអធ្យាស្រ័យចំពោះកំហុសឆ្គងនៃការសន្ទនារបស់ខ្ញុំ ដែលបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃសព**សម្តេចវិបុលបញ្ញា សុខ អាន** ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារលោកជំទាវ ចំពោះមរណៈភាពរបស់**សម្តេចវិបុលបញ្ញា សុខ អាន** និងសូមបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់សម្តេចបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមលោកជំទាវ និងក្រុមគ្រួសារ បានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាត ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧

លិម គិមយ៉ា
អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំ **ហ៊ុន យឿន** អគ្គលេខាធិការរងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

សូមគោរពជូន
លោកជំទាវ អាន្លី សុខ អាន

លោកជំទាវ,

ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងចំពោះការសន្ធនារបស់ខ្ញុំតាមទូរស័ព្ទជាមួយឯកឧត្តម **លិម គិមយ៉ា** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំអំពីមរណៈភាពសម្តេចវិបុលបញ្ញា **សុខ អាន** ដែលត្រូវបានគេលួចថតយកមកផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងកិត្តិយសនៃសព ហើយនឹងធ្វើឱ្យក្រុមគ្រួសាររបស់លោកជំទាវមានការឈឺចាប់។

ខ្ញុំសុំលោកជំទាវ និងក្រុមគ្រួសារមេត្តាអធ្យាស្រ័យចំពោះកំហុសឆ្គងនៃការសន្ធនារបស់ខ្ញុំ ដែលធ្វើឱ្យប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃសពសម្តេចវិបុលបញ្ញា **សុខ អាន**។

ឆ្លៀតឱកាសនេះ ខ្ញុំសូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារលោកជំទាវ ចំពោះមរណៈភាពរបស់សម្តេចវិបុលបញ្ញា **សុខ អាន** និងសូមបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់សម្តេចបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមលោកជំទាវ និងក្រុមគ្រួសារ បានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាត។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧

ហ៊ុន យឿន
អគ្គលេខាធិការរងព្រឹទ្ធសភា

រូបភាពពិធីដង្ហែសព សម្តេចវិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ឡុង កុសល រូបភាព ៖ ឡុង កុសល

យើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងពលករ មប្រើការងារនៅអាជ្ញាធរជាតិអប្សរាទាំងអស់ មានសេចក្តីសោកសង្រេងជាទីបំផុត ចំពោះការចូលមរណភាពរបស់**សម្តេចឧបុលបញ្ញា សុខ អាន** ។ យើងខ្ញុំនឹងចងចាំនូវរាល់គំរូដឹកនាំ និងវីរភាពរបស់សម្តេច និងប្តេជ្ញាបន្តការងារជាប្រវត្តិសាស្ត្រនៃអាជ្ញាធរជាតិអប្សរាដើម្បីជម្រុញកិច្ចការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរឲ្យកាន់តែល្អប្រសើថែមទៀត។

សូមវិញ្ញាណក្ខន្ធ **សម្តេចទបុលបញ្ញា សុខ អាន** បានចាប់បដិសន្ធិក្នុងសុគតិភពកុំបីក្លាយជាប្រការអ្វីផ្សេងឡើយ។









រូបភាពពិធីបូជាសព សម្តេចវិបុលបញ្ញា សុខ អាន នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ នាមុខវត្តបុទុមវត្តី ភជធានីភ្នំពេញ

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ឡុង កុសល រូបភាព ៖ ឡុង កុសល














បន្ទាប់ពីការបូជាសពត្រូវបានបញ្ចប់, នៅល្ងាចថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧នេះ ឆាតុរបស់សម្តេចវិបុលបញ្ញា សុខ អាន ត្រូវបានក្រុមគ្រួសារ រៀបចំតាមពិធីសាសនាដាក់ចូលទៅក្នុងទឹកទន្លេ មុខព្រះបរមរាជវាំង

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ឡុង កុសល រូបភាព ៖ ឡុង កុសល













វីដេអូ៖ ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ សម្តេចវិបុលបញ្ញា សុខ អាន

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧



សូមថ្លែងអំណរគុណជូនដល់ ឯកឧត្តម អគ្គនាយក អគ្គនាយករង ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សា លោក លោកស្រី ឧបការី ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងមន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរាទាំងអស់ដែលបានចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីដង្ហែសព សម្តេចវិបុលបញ្ញា សុខ អាន នាថ្ងៃទី១៨ និង ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ឡុង កុសល រូបភាព ៖ ឡុង កុសល












កិច្ចប្រជុំពេញអង្គលើកទី៣នៃអាយស៊ីស៊ី-ព្រះវិហារ គោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន និងកោតសរសើរពីវីរភាពរបស់សម្តេចក្នុងកិច្ចការងារបេតិកភណ្ឌជាតិ

ផ្សាយនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ុំ រីទ្ធី

កិច្ចប្រជុំពេញអង្គរលើកទី៣នៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ការអភិរក្ស និងលើកតម្លៃប្រាសាទព្រះវិហារ ហៅកាត់ថា (ICC-PV) នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ នៅសាលសន្និសីទអង្គរនៃអាជ្ញាធរជាតិអប្សរា បានស្ទឹងស្មាធ៍ ដើម្បីសម្តែងការគោរពវិញ្ញាណក្ខន្ធ និងសម្តែងនូវសេចក្តីទុក្ខសោកយ៉ាងក្រៀមក្រំពោរពេញទៅដោយការសោកស្តាយស្រណោះ

អាឡោះអាល័យជាទីបំផុត ចំពោះមរណភាពរបស់ **សម្តេចឧបុលបញ្ញា សុខ អាន** វីរជននៃបេតិកភណ្ឌជាតិ ដែលបានទទួលមរណភាពនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ក្នុងជន្មាយុ៦៦ឆ្នាំ វេលាម៉ោង១៨:៣២នាទី។

ពិធីនេះក៏ធ្វើឡើងដើម្បីសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះគុណូបការៈរបស់**សម្តេចឧបុលបញ្ញា សុខ អាន** ដែលបានលះបង់កម្លាំងកាយចិត្តរបស់សម្តេច ក្នុងបុព្វហេតុការពារជាតិមាតុភូមិ ជាពិសេសគឺការលះបង់ដ៏ធំធេងក្នុងការងារគ្រប់គ្រង និងថែរក្សាបេតិកភណ្ឌពិភពលោកអង្គរ បេតិកភណ្ឌពិភពលោកព្រះវិហារ ដែលជាកេរមរតកដ៏មានតម្លៃរបស់ខ្មែរ។

សហប្រធានទាំងពីរនៃកិច្ចប្រជុំមានឥណ្ឌា និងចិន ក៏បានកោតសរសើរយ៉ាងខ្លាំងចំពោះវីរភាពរបស់ **សម្តេចឧបុលបញ្ញា សុខ អាន** ដែលបានបន្សល់ទុកស្នាដៃយ៉ាងច្រើនទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងលើកគុណតម្លៃ និងលើកកម្ពស់ការអភិរក្សរមណីយដ្ឋានបេតិកភណ្ឌអង្គរនិងព្រះវិហារ។ សហប្រធានឥណ្ឌា ក៏បានរំឭកផងដែរពីគុណសម្បត្តិក្នុងការបំពេញកិច្ចសហការល្អកន្លងមក គឺតាំងពីសម្តេចនៅជាឯកអគ្គរដ្ឋទូតឥណ្ឌានាទស្សវត្សទី៨០ និងមានការសម្របសម្រួលឱ្យឥណ្ឌាបានចូលរួមលើការងារជួសជុល អភិរក្សក្នុងតំបន់អង្គរជាថ្មីម្តងទៀតនៅឆ្នាំ២០០២។

ឯកឧត្តមបណ្ឌិត តឹម សេតារ ក្នុងនាមប្រធានអាជ្ញាធរជាតិព្រះវិហារ បានសម្តែងនូវការសោកស្តាយជាពន់ពេកចំពោះការបាត់បង់វីរជនបេតិកភណ្ឌជាតិដូចជា **សម្តេចឧបុលបញ្ញា សុខ អាន** ។ កូនខ្មែរចាំមិនភ្លេចទេនូវកិច្ចខំប្រឹងប្រែងរបស់សម្តេចទាំងកម្លាំងកាយចិត្តក្នុងការសម្តេចនូវការដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក នាឆ្នាំ២០០៨ លើជោគជ័យនៃសមរភូមិការទូតដ៏ប៉ិនប្រសប់។

ក្នុងនាមឯកឧត្តមជាអ្នកទទួលបន្ទុកមើលការខុសត្រូវប្រាសាទព្រះវិហារ នឹងចងចាំជានិច្ចនូវគុណបំណាច់ និងស្នាដៃដ៏ធំធេងរបស់សម្តេចចំពោះវិស័យវប្បធម៌ជាតិ ហើយប្តេជ្ញាខិតខំប្រឹងប្រែងថែរក្សាបេតិកភណ្ឌពិភពលោកមួយនេះឱ្យបានគង់វៀងរហូត៕









ភ្ញៀវទេសចរជាច្រើនរង់ចាំមើលព្រឹត្តិការណ៍ថ្ងៃរះចំកណ្តាលកំពូលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ាហ៊ីនី រូបភាព ៖ ស្បឿន ប៊ុនសារ

នៅព្រឹកថ្ងៃទី២១ មីនានេះ គឺជាពេលវេលាដែលព្រះអាទិត្យរះចំកំពូលប្រាង្គកណ្តាលនៃប្រាសាទអង្គរវត្ត។ គេសង្កេតឃើញថា មានភ្ញៀវទេសចរជាច្រើនបានទៅរង់ចាំមើលព្រឹត្តិការណ៍ប្រចាំឆ្នាំមួយនេះ។ បើទោះជាពពកបានរាំងស្ទះនូវព្រឹត្តិការណ៍ដ៏អច្ឆរិយៈនេះក៏ដោយ ប៉ុន្តែភ្ញៀវទេសចរទាំងនោះមានចិត្តសប្បាយ និងថាពួកគេនឹងព្យាយាមមើលព្រឹត្តិការណ៍នេះនៅលើកក្រោយទៀត។

ភ្ញៀវទេសចរជាច្រើន បានទៅរង់ចាំមើលព្រឹត្តិការណ៍សមរាត្រី ឬហៅថា ថ្ងៃរះចំកំពូលប្រាង្គកណ្តាលប្រាសាទអង្គរវត្ត។ ដោយសារអាកាសធាតុមិនអំណោយផល ធ្វើឲ្យភ្ញៀវទេសចរទាំងអស់ ខកខានមិនបានមើលព្រឹត្តិការណ៍ដ៏អស្ចារ្យនេះទេ។

មានព្រឹត្តិការណ៍ចំនួន៤សំខាន់ៗ ដែលបានកើតឡើងនៅលើសំណង់ប្រាសាទអង្គរវត្ត។ ព្រឹត្តិការណ៍ទាំងនោះ រួមមានពេលវេលាថ្ងៃនិងយប់មានរយៈពេលស្មើគ្នា ឬហៅថាសមរាត្រី គឺកើតឡើង២ដងក្នុងមួយឆ្នាំ លើកទី១នារដូវវស្សា កើតចំថ្ងៃទី២១ កញ្ញា និងលើកទី២នារដូវប្រាំង កើតចំថ្ងៃទី២១ មីនា។ សម្រាប់ព្រឹត្តិការណ៍២ទៀត គឺពេលថ្ងៃមានរយៈពេលខ្លីជាងយប់កើតឡើងចំថ្ងៃទី២១ ធ្នូ និងថ្ងៃវែងជាងយប់ កើតចំថ្ងៃទី២១ មិថុនា៕









អ្នកជំនាញជប៉ុន និងអាជ្ញាធរជាតិអប្សរាពិភាក្សាបញ្ហាបច្ចេកទេសសម្រាប់ការអភិរក្ស និងជួសជុលស្ពានហាលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ លឹម ស្រ៊ូ រូបភាព ៖ លឹម ស្រ៊ូ

ស្ពានហាលផ្លូវចូលខាងលិចប្រាសាទអង្គរវត្ត កំពុងត្រូវបានជួសជុលឡើងវិញដោយអាជ្ញាធរជាតិអប្សរា សហការជាមួយសាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន។ ដើម្បីឱ្យកិច្ចការជួសជុលនេះស្របតាមអនុសាសន៍ ណែនាំរបស់គណៈកម្មាធិការ ICC-Angkor សាកលវិទ្យាល័យសូហ្វីយ៉ា បានបើកកិច្ចពិភាក្សាជាបន្តបន្ទាប់ពី បណ្តាអ្នកជំនាញផ្សេងៗជាច្រើន។ ដោយឡែកនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ មានកិច្ចពិភាក្សាមួយបានរៀបចំឡើងនៅសាកលវិទ្យាល័យសូហ្វីយ៉ា នាទីក្រុងតូក្យូប្រទេសជប៉ុន។

កិច្ចពិភាក្សានេះមានការចូលរួមពី **លោកសាស្ត្រាចារ្យ យូស៊ីអាគី អ៊ីហ្សឺសាវ៉ា** ប្រធានមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សនៃសាកលវិទ្យាសូហ្វីយ៉ា **លោក លី វណ្ណា** ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ នៃអាជ្ញាធរជាតិអប្សរា និងមន្ត្រីជំនាញដែលជាអ្នកចូលរួមផ្ទាល់ក្នុងកិច្ចការជួសជុលស្ពានហាលនេះ។ ដោយឡែកអ្នកជំនាញជប៉ុនជាច្រើនរូប ដែលមានជំនាញពាក់ព័ន្ធផ្សេងៗត្រូវបានអញ្ជើញដោយសាកលវិទ្យាល័យសូហ្វីយ៉ា ដើម្បីចូលរួមផ្តល់យោបល់បន្ថែមទៀតលើកិច្ចការជួលជុលស្ពានហាលនេះឱ្យសម្រេចបានជោគជ័យនាពេលខាងមុខ។

លោក លី វណ្ណា ក្នុងនាមអាជ្ញាធរជាតិអប្សរាបានថ្លែងអំណរគុណចំពោះសាកលវិទ្យាល័យសូហ្វីយ៉ា និងអ្នកជំនាញទាំងអស់ដែលមកពីសាកលវិទ្យាល័យ និងស្ថាប័នពាក់ព័ន្ធផ្សេងនៅប្រទេសជប៉ុនដែលបានផ្តល់យោបល់ជាជំនួយផ្នែកបច្ចេកទេសដ៏សំខាន់ក្នុងពេលនេះ។ អាជ្ញាធរជាតិអប្សរានឹងទទួលយកយោបល់ដ៏ល្អៗ ទាំងនោះដាក់ឆ្លងទៅអ្នកជំនាញអន្តរជាតិ ដើម្បីពិនិត្យផ្តល់យោបល់បន្ថែមទៀតសំដៅធ្វើយ៉ាងណាឱ្យកិច្ចការ ជួសជុលនេះទទួលបានផ្លែផ្កាល្អ រក្សាបាននូវស្ថានភាពដើម ហើយស្របតាមលក្ខខណ្ឌផ្សេងៗដែលបានកំណត់ដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោក៕






បច្ចេកទេសរំលីងថ្មប្រាសាទនាសម័យអង្គរត្រូវបានតាំងបង្ហាញ និងសម្តែងឡើងវិញនៅសកលវិទ្យាល័យសូហ្វីយ៉ាប្រទេសជប៉ុន

ផ្សាយនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ លឹម ស្រ៊ូ រូបភាព ៖ លឹម ស្រ៊ូ

ពិព័រណ៌រូបភាព និងចម្លាក់សម័យអង្គរត្រូវបានតាំងបង្ហាញក្នុងឱកាសសម្ពោធអាគារថ្មីរបស់សកលវិទ្យាល័យសូហ្វីយ៉ា ក្រុងតូក្យូ នាថ្ងៃទី១៦ មីនា ឆ្នាំ២០១៧ កន្លងមកនេះ។ សាកលវិទ្យាល័យសូហ្វីយ៉ា បានរៀបចំទីតាំងសម្រាប់ការតាំងពិព័រណ៌ ហើយក៏បានរៀបចំឲ្យមានការសម្តែងដោយផ្ទាល់របស់កម្មករជំនាញលើកិច្ចការកាត់ និងរំលីងថ្មដើម្បីជួសជុលប្រាសាទ របស់អាជ្ញាធរជាតិអប្សរា ដែលមានបទពិសោធន៍ធ្លាប់បំពេញកិច្ចការនេះអស់រយៈកាលយូរឆ្នាំមកហើយ។

សកម្មភាពសម្តែងនាពេលនេះគឺ ការបង្ហាញពីបច្ចេកទេសរំកិលថ្ម ដាប់ថ្ម និងរំលីងថ្ម ដែលជាសកម្មភាពបង្ហាញឡើងវិញតាមរូបភាពនៃចម្លាក់ដែលបានឆ្លាក់ផ្ទាល់នាជញ្ជាំងប្រាសាទបាយ័ន។ ចំណែកអ្នកជំនាញរបស់ជប៉ុនក៏បានបង្ហាញពីបច្ចេកទេសនៃការដាប់ ចាំងថ្មតាមរបៀបជប៉ុន ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាផងដែរ។

លោក ហោ ទុយ លោក ចាម ប្រាណ និង **លោក យ៉ត់ យ៉ែង** ជាកម្មករផ្នែកជួសជុលប្រាសាទរបស់អាជ្ញាធរជាតិអប្សរា មានទីលំនៅរស់នៅក្នុងឧទ្យានអង្គរផ្ទាល់ពីយូរលង់មកហើយ។ លោកទាំងបីត្រូវបានសាកលវិទ្យាល័យសូហ្វីយ៉ា ផ្តល់ឱកាសបានមកសម្តែងបង្ហាញដោយផ្ទាល់ ពីបច្ចេកទេសខ្មែរបុរាណលើការកាត់រំលីងថ្មដើម្បីកសាងប្រាសាទ។ ក្នុងពេលដែលបានបង្ហាញដោយផ្ទាល់ពីរបៀបរំកិលថ្ម និងរំលីងថ្ម នាពេលនេះ **លោក ហោ ទុយ** ជាកម្មករជំនាញលើកិច្ចការនេះផ្ទាល់របស់អាជ្ញាធរជាតិអប្សរា បានបង្ហាញនូវក្តីរីករាយ ដែលប្រជាជនជប៉ុនបានយកចិត្តទុកដាក់ផ្តល់តម្លៃខ្ពស់លើកិច្ចការអភិរក្សមរតកបេតិកភណ្ឌជាតិ។ លោកក៏បានថ្លែងអំណរគុណចំពោះអាជ្ញាធរជាតិអប្សរា និងសកលវិទ្យាល័យសូហ្វីយ៉ា ដែលផ្តល់ឱកាសដល់រូបលោកក្នុងពេលនេះ។

លោកសាស្ត្រាចារ្យ យូស៊ីអាគី អ៊ីហ្សឺសាវ៉ា ប្រធានមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សនៃសាកលវិទ្យាសូហ្វីយ៉ា បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់កម្មករនិងអ្នកជំនាញចំពោះកិច្ចការអភិរក្សមរតកបេតិកភណ្ឌនាពេលកន្លងមក លោកក៏បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរជាតិអប្សរាចំពោះកិច្ចសហការយ៉ាងល្អ ដែលធ្វើឲ្យបេសកកម្មជួយអភិរក្សអង្គររបស់សកលវិទ្យាល័យសូហ្វីយ៉ាទទួលបានជោគជ័យជាបន្តបន្ទាប់។ ហើយសកម្មភាពក្នុងពេលនេះក៏ជាលទ្ធផលដែលទទួលបានពីកិច្ចសហការយ៉ាងល្អនាពេលកន្លងមកនោះដែរ៕






អាជ្ញាធរជាតិអប្សរា និងមជ្ឈមណ្ឌល HIST របស់ចិន នឹងចុះអនុស្សរណៈយោគយល់បន្តលើការងារកិច្ចសហប្រតិបត្តិការរួមគ្នា

ផ្សាយនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

នៅព្រឹកថ្ងៃទី២២ មីនា ឆ្នាំ២០១៧ **ឯកឧត្តម ហាច់ ពៅ** អគ្គនាយកស្តីទីអាជ្ញាធរជាតិអប្សរា បានទទួលជួបថ្នាក់ដឹកនាំមជ្ឈមណ្ឌលអន្តរជាតិខាងបច្ចេកវិទ្យាអវកាសសម្រាប់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិក្រោមអាណាព្យាបាលនៃអង្គការយូណេស្កូ (HIST : International Center on Space Technologies for Natural and Cultural Heritage under the auspices of UNESCO) របស់ប្រទេសចិន។ ប្រធានប្រតិភូមជ្ឈមណ្ឌល HIST ដឹកនាំដោយ**លោកសាស្ត្រាចារ្យ Guo Huadong** ។

ក្នុងជំនួបពិភាក្សាទ្វេភាគីនោះ ខាងមជ្ឈមណ្ឌល HIST បានរំលឹកពីការងារក្នុងកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយអាជ្ញាធរជាតិអប្សរា ក្នុងរយៈពេល៣ឆ្នាំកន្លងមក ជាពិសេសទាក់ទងនឹងការផ្តល់រូបភាពពីលើអាកាស ដែលអាចឲ្យយើងបានដឹងពីការងារគ្រប់គ្រងព្រៃឈើ ការប្រែប្រួលគម្របព្រៃឈើ ការតាំងទីរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់អង្គរ និងនៅតំបន់ជុំវិញ ដែលទិន្នន័យនេះអាចឲ្យអាជ្ញាធរជាតិអប្សរាដឹងពីព័ត៌មាននៃការប្រែប្រួលតាំងពីឆ្នាំ ១៩៨០ រហូតមកដល់ឆ្នាំ ២០១៤។

ចំណុចមួយទៀត ដែលស្ថិតក្នុងកិច្ចសហប្រតិបត្តិនេះដែរ គឺការផ្តល់ទិន្នន័យទាក់ទងទៅនឹងទឹកក្រោមដី។ ការណ៍នេះធ្វើឲ្យយើងដឹងអំពីបម្រែបម្រួលទឹកក្រោមដី និងផលប៉ះពាល់ចំពោះលំនឹង ឬគ្រឹះប្រាសាទ។ ចំណុចចុងក្រោយ គឺការអភិវឌ្ឍធនធានមនុស្ស។ ចំណុចនេះគឺមានសារសំខាន់ណាស់ ដើម្បីជំរុញឲ្យមាននិរន្តរភាពលើការងារអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរ ក៏ដូចជាជំរុញបន្ថែមឲ្យកាន់តែមានភាពជិតស្និទ្ធ ក្នុងកិច្ចសហប្រតិបត្តិរវាងភាគីទាំងពីរ។

ក្នុងជំហានទី២ ដែលស្ថិតអនុស្សរណៈយោគយល់បន្ទាប់ គឺការកំណត់ចំណុចអទិភាពនៃកិច្ចសហប្រតិបត្តិការបន្តទៀត ដែលចំណុចទាំងនោះចាំបាច់ត្រូវមានកិច្ចពិភាក្សាឲ្យបានហ្មត់ចត់។ មួយទៀត គឺខាងមជ្ឈមណ្ឌល HIST ស្នើឲ្យមានការផ្សព្វផ្សាយ ឲ្យបានទូលំទូលាយអំពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការ និងបង្កើតកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សនូវជំនាញប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅស្នាក់ការអាជ្ញាធរជាតិអប្សរា។

ឯកឧត្តម ហង់ ពៅ មានប្រសាសន៍ថា អាជ្ញាធរជាតិអប្សរាបានត្រៀមរួចរាល់ក្នុងកិច្ចសហប្រតិបត្តិការលើគ្រប់ទម្រង់។ ឯកឧត្តមបន្ថែមថា ពាក់ព័ន្ធនឹងការចុះអនុស្សរណៈយោគយល់ និងការអភិវឌ្ឍធនធានមនុស្ស គឺជាចក្ខុវិស័យចំបងរបស់អាជ្ញាធរជាតិអប្សរានាពេលអនាគត។ ការអភិវឌ្ឍធនធានមនុស្ស បានផ្តល់ផលប្រយោជន៍ជាច្រើនដល់មន្ត្រី និងបុគ្គលិករបស់អាជ្ញាធរជាតិអប្សរា៕









អាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជាមួយអ្នកជំនាញអន្តរជាតិដែលកំពុងអនុវត្តការងារនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរា នារសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧នេះ បានជួបប្រជុំជាមួយអ្នកជំនាញអន្តរជាតិ ដែលកំពុងបំពេញការងារអភិរក្សជួសជុលនៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

ជំនួបពិភាក្សានេះធ្វើឡើងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា ជាមួយនឹងស្ថាប័នអន្តរជាតិនានា ជាពិសេស គឺដើម្បីដឹងនូវបញ្ហាផ្សេងៗដែលស្ថាប័នអន្តរជាតិទាំងនោះជួបប្រទះក្នុងដំណើរបេសកកម្មរបស់ខ្លួន ក្នុងគោលដៅធ្វើយ៉ាងណា ឲ្យការងារអភិរក្សបេតិកភណ្ឌអង្គរប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ។

ក្រោយស្តាប់បទបង្ហាញ និងការលើកឡើងពីអ្នកជំនាញរួចមក **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** ក៏បានថ្លែងអំណរគុណចំពោះគ្រប់ស្ថាប័នអន្តរជាតិទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការងារអភិរក្សជួសជុលក្នុងតំបន់អង្គរ។ ឯកឧត្តមបានស្នើឲ្យគ្រប់ស្ថាប័នទាំងអស់ ដែលជួបឧបសគ្គណាមួយក្នុងដំណើរការរបស់ខ្លួន សូមផ្តល់ដំណឹងឲ្យបានទាន់ពេលវេលា ដើម្បីឲ្យអាជ្ញាធរជាតិអប្សរាអាចជួយសម្របសម្រួល។ ក្នុងនោះដែរ ក៏មានការពិភាក្សានូវការឡើងថ្លៃនៃតម្លៃឋ្មកក់ក្នុងទីផ្សារដែលនេះជាកង្វល់នៃការដ្ឋានអន្តរជាតិ ព្រោះបញ្ហានេះបានធ្វើឲ្យតម្លៃនៃការចំណាយលើការងារជួសជុលកាន់តែខ្ពស់ទៅៗ។

ឯកឧត្តមអគ្គនាយកក៏បានសំណូមពរស្ថាប័នអន្តរជាតិទាំងអស់ដើម្បីចូលរួមក្នុងកិច្ចពិភាក្សាតុមូល ដែលគ្រោងនឹងរៀបចំនៅអាជ្ញាធរជាតិអប្សរា ក្នុងគោលបំណងផ្លាស់ប្តូរយោបល់បច្ចេកទេស និងគោលការរួមក្នុងកិច្ចការអភិរក្ស ជួសជុលជាពិសេសសំដៅលើបច្ចេកទេសនៃការប្រើប្រាស់ឋ្មកក់ថ្មីជំនួសឋ្មកក់ចាស់៕









ដំណឹងជ្រើសរើសបុគ្គលិកផ្នែកអភិរក្ស និងមគ្គុទេសក៍ ផ្នែកអគ្គិសនី និងផ្នែករដ្ឋបាល ឱ្យបម្រើការងារនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ២០៧/ រប អជណ
/២៧

សៀមរាប ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៧

ដំណឹងជ្រើសរើសបុគ្គលិក

អាជ្ញាធរអប្សរា "អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ" (www.apsaraauthority.gov.kh) សូមជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា អាជ្ញាធរអប្សរា នឹងធ្វើការជ្រើសរើសបុគ្គលិកកម្រិតសញ្ញាបត្របរិញ្ញាបត្រចំនួន**០៥រូប** ឲ្យបម្រើការងារនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។

១- បុគ្គលិកដែលត្រូវជ្រើសរើស មានដូចខាងក្រោម៖

- ផ្នែកអភិរក្ស និងមគ្គុទេសក៍ចំនួន០៣រូប
- ផ្នែកអគ្គិសនីចំនួន០១រូប
- ផ្នែករដ្ឋបាលចំនួន០១រូប

២- លក្ខខណ្ឌនៃការជ្រើសរើស មានដូចតទៅ៖

- ត្រូវមានសញ្ញាបត្រទុតិយភូមិ
- ត្រូវមានបរិញ្ញាបត្រផ្នែកបុរាណវិទ្យា
- ត្រូវមានបរិញ្ញាបត្រផ្នែកអគ្គិសនី
- ត្រូវមានបរិញ្ញាបត្រផ្នែកគ្រប់គ្រង ឬបរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ

៣. លក្ខណៈសម្បត្តិនៃការជ្រើសរើស៖

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- ធ្លាប់មានបទពិសោធន៍ការងារចាប់ពី១ឆ្នាំឡើងទៅ (បើមានកាន់តែប្រសើរ)
- មានអាយុចាប់ពី១៨-៣៥ឆ្នាំ
- មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ
- ចេះភាសាអង់គ្លេសអាចប្រាស្រ័យទាក់ទងជាមួយភ្ញៀវបាន (បើចេះភាសាជប៉ុនទៀតកាន់តែល្អប្រសើរ)
- មានសុខភាពល្អ

៤. សំណុំឯកសារដែលត្រូវមាន៖

- ជីវប្រវត្តរូបសង្ខេបមានបិទរូបថតទំហំ (៤x៦)
- ថតចម្លង និងបញ្ជាក់សញ្ញាបត្រ ដោយមានការទទួលស្គាល់ជាផ្លូវការពីច្រកចេញ-ចូលតែមួយ
- ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬ សៀវភៅស្នាក់នៅ០១ច្បាប់
- ថតចម្លងសំបុត្រកំណើត០១ច្បាប់

៥-ទីកន្លែងទទួលពាក្យ៖ ទីស្នាក់ការអាជ្ញាធរអប្សរាថ្មី "មជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា" នៅនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧ ។**

៦-ការសម្ភាសបេក្ខជន៖ បញ្ជីសម្រាំងបេក្ខជនដែលត្រូវឆ្លងកាត់ការសម្ភាសន៍ជ្រើសរើស និងកាលបរិច្ឆេទសម្ភាសន៍ នឹងបិទផ្សាយនៅស្នាក់ការអាជ្ញាធរអប្សរាខេត្តសៀមរាប និងជូនដំណឹងតាមទូរស័ព្ទ។

៧-ព័ត៌មានចាំបាច់៖ សូមទំនាក់ទំនងមកលេខទូរស័ព្ទ ០១២/០៩៣ ៩៨៦ ៨១៧

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

ចម្លាក់បាយ័ន ៖ វត្តមានទ័ពចិនក្នុងជួរទ័ពខ្មែរនៃជ័យជម្នះលើកងទ័ពចាម

ផ្សាយនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

នៅលើចម្លាក់នៃប្រាសាទបាយ័ន ត្រង់ថែវខាងក្រៅ នាទិសខាងកើត មានទិដ្ឋភាពដ៏ធំពីរផ្ទាំងជាប់គ្នា ដែលរៀបរាប់អំពីជ័យជម្នះដ៏អស្ចារ្យ នៃកងទ័ពខ្មែរ លើកងទ័ពចាម ដែលបានឈ្លានពានចូលគ្រប់គ្រងនគរខ្មែរតាំងពីឆ្នាំ១១៧៧មក។

ទិដ្ឋភាពនេះ មិនថាទេសចរខ្មែរ ឬបរទេសនោះទេគឺបានដឹងបានឮជាទូទៅ ព្រោះនេះជាព្រឹត្តិការណ៍ដ៏សំខាន់បំផុតមុនការចាប់ផ្តើមឡើងគ្រងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលជាព្រះមហាក្សត្រខ្មែរដ៏ល្បីល្បាញទាំងគុណធម៌ និងស្នាព្រះហស្តបន្សល់ទុករហូតដល់សព្វថ្ងៃ។

បើមើលឲ្យលម្អិតលើសពីធម្មតាបន្តិច យើងនឹងឃើញកងទ័ព និងមេទ័ពមួយចំនួន មានឯកសណ្ឋានខុសពីកងទ័ពខ្មែរបម្រើការនៅខាងទ័ពខ្មែរ ។ កងទ័ពនោះ គឺជាកងទ័ពចិនដែលមកជួយច្បាំងខ្មែរ ក្នុងចម្បាំងនឹងនគរចាម។ ហេតុអ្វីមានវត្តមានទ័ពចិនមកជួយខ្មែរនៅពេលនោះ?

អ្នកស្រាវជ្រាវ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិវិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរា **លោក អ៊ឹម សុខរិទ្ធី** បានពន្យល់ថានាសតវត្សទី១២ រាជវង្សសុងដែលគ្រប់គ្រងនគរចិនត្រូវដួលរលំដោយកងទ័ពសេះរបស់ម៉ុងហ្គោលី។ កងទ័ពចិនដែលនៅតំបន់ធ្លាយៗបានបែកខ្ញែកគ្នា រត់គេចពីចម្បាំងចាញ់។ ទ័ពខ្លះក៏ចេញដើរច្បាំងដើម្បីបន្តជីវភាពរស់នៅបន្តទៀត។ ទេសកាលនេះហើយដែលនាំឲ្យមានជាទ័ពស៊ីឈ្នួលនៅតាមប្រទេសខ្លះ មាននៅប្រទេសខ្មែរជាដើម។ ក្រុមកងទ័ពស៊ីឈ្នួលចិនមួយក្រុមបានធ្វើចម្បាំងជួយខ្មែរតទល់នឹងទ័ពចាមផងដែរ។

អ្នកស្រាវជ្រាវរូបនេះ ក៏បានបញ្ជាក់អំពីការឆ្លងគ្នានៃទំនៀមជិះសេះធ្វើសង្គ្រាមរបស់ព្រះមហាក្សត្រខ្មែរ ដែលមានក្នុងចម្លាក់នេះ។ លោកបញ្ជាក់ថា មុនវត្តមានកងទ័ពចិនចូលមក ព្រះមហាក្សត្រពុំដែលគង់ប្រថាប់លើខ្នងសេះក្នុងការចេញច្បាំងនោះទេ គឺគង់ប្រថាប់តែលើខ្នងដំរីប៉ុណ្ណោះ។ ដូចគ្នាដែរ មេទ័ពចិនមួយចំនួនក៏រៀនជិះដំរីធ្វើសង្គ្រាមតាមខ្មែរដែរ ព្រោះនៅប្រទេសចិន ពុំមានដំរីចម្បាំងសម្រាប់ជិះធ្វើសង្គ្រាមទេ។

សូមទស្សនាទិដ្ឋភាពខាងក្រោម ...



ទ័ពខ្មែរកាប់សម្លាប់ទ័ពចាមក្នុងសមរភូមិ



វត្តមានទ័ពចិនក្នុងជួរកងទ័ពខ្មែរ





ចម្លាក់បាយ័ន ៖ សិល្បៈទស្សនីយភាពមួយនៅសម័យអង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

យើងធ្លាប់តែដឹងថា ភ្លេងតន្ត្រី និងឧបករណ៍តន្ត្រីជាច្រើន សុទ្ធតែបានបន្សល់ទុកតាំងបុរាណកាលមក។ ប៉ុន្តែមានមនុស្ស មិនច្រើនទេ ដែលដឹងថា ឧបករណ៍តន្ត្រីទាំងនោះត្រូវបានឆ្លាក់ជាប់លើផ្នាំងថ្មប្រាសាទ ហើយមានឧបករណ៍អ្វីខ្លះ ដែលនៅសល់រហូតដល់សព្វថ្ងៃ។

រហូតមកដល់ពេលនេះ គ្មានអ្នកស្រាវជ្រាវណាម្នាក់ហ៊ានអះអាងដាច់ណាត់ថា តន្ត្រីបុរាណនាសម័យអង្គរ គេបានប្រើប្រាស់ឧបករណ៍អ្វីខ្លះនោះទេ តែតាមរយៈចម្លាក់ដែលបានបន្សល់ទុក អ្នកស្រាវជ្រាវអាចប្រាប់យើងបានខ្លះ អំពីឧបករណ៍ដែលត្រូវបានប្រើប្រាស់ក្នុងពេលនោះ ហើយបានបន្សល់ទុកដល់សព្វថ្ងៃ។

នៅប្រាសាទបាយ័ន ក្នុងប្រាង្គខាងកើតឆៀងខាងត្បូង មានចម្លាក់ដែលបង្ហាញអំពីការប្រគំតន្ត្រីមួយ។ តាមការរៀបរាប់របស់ **លោក អ៊ឹម សុខរិទ្ធ** អ្នកស្រាវជ្រាវ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិវិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរាបានពន្យល់ថា វង់តន្ត្រីនេះ បានប្រើប្រាស់ឧបករណ៍បីគឺ ឆាប (ខ្លះហៅថាឆឹង) ពិណ និងសាជៀវ។

ដោយមើលពីឆ្វេងទៅស្តាំយើងនឹងឃើញ អ្នកគោះឆាប អ្នកដេញពិណ អ្នកដេញសាជៀវ អ្នកចម្រៀង អ្នករាំ និងទស្សនិកជន។ បើមើលទៅទិដ្ឋភាពខាងលើទាំងមូល គឺសាលមហោស្រព ដែលប្រកបដោយក្បាច់រចនាយ៉ាងស្រស់ស្អាត។

សូមទស្សនាទិដ្ឋភាពប្រគំតន្ត្រីដូចតទៅ ៖









ក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តបើកកិច្ចប្រជុំផ្ទៃក្នុងអំពីការរីកចម្រើននៃសកម្មភាពការងារនិងការត្រៀមខ្លួនបង្កភាពងាយស្រួលដល់ភ្ញៀវទេសចរមកកម្សាន្តថ្ងៃចូលឆ្នាំ

ផ្សាយនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ុំ រិទ្ធី

នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ក្រុមការងាររៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តនៃអាជ្ញាធរជាតិអប្សរា បានបើកអង្គប្រជុំផ្ទៃក្នុងមួយស្តីពីការរីកចម្រើននៃសកម្មភាពការងារ និងការត្រៀមខ្លួនបង្កភាពងាយស្រួលដល់ភ្ញៀវទេសចរមកកម្សាន្តនាថ្ងៃចូលឆ្នាំថ្មី។

អង្គប្រជុំនេះដឹកនាំដោយ **ឯកឧត្តម ហុក ម៉េងសៃ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និងថ្នាក់ដឹកនាំទទួលបន្ទុកការងាររៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ព្រមទាំងមានការចូលរួមពីមន្ត្រីបុគ្គលិកពាក់ព័ន្ធជាច្រើនរូបទៀត។

កិច្ចប្រជុំនេះបានផ្តោតសំខាន់ទៅលើលទ្ធផលការងារមួយចំនួនដែលអនុវត្តបានរួចរាល់ ព្រមទាំងការត្រៀមខ្លួនរបស់ក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ក្នុងការសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា និងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឲ្យដំណើរការដោយរលូននិងល្អប្រសើរ ជាពិសេសដើម្បីធ្វើយ៉ាងណាឱ្យភ្ញៀវទេសចរជាតិ-អន្តរជាតិមកកម្សាន្តក្នុងថ្ងៃសង្ក្រាន្តឆ្នាំថ្មីបានទទួលនូវភាពសប្បាយរីករាយ និងការចងចាំដ៏ល្អប្រសើរនៃព្រឹត្តិការណ៍នេះ៕









ក្នុងត្រីមាសទី០១នេះ អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតសំណើសុំសាងសង់សំណង់តូចតាចនិងជួសជុលផ្ទះជូនអ្នកស្រុកអង្គរជាង១២០ករណី

ផ្សាយនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ អោក សំអុល រូបភាព ៖ ក្រុមការងារសហគមន៍

អង្គរជាតំបន់បេតិកភណ្ឌវប្បធម៌ពិភពលោក ហើយក៏ជាតំបន់ដែលរក្សានូវទំនៀមទម្លាប់ប្រពៃណីផ្ទាល់របស់អ្នកស្រុក ព្រមទាំងជាតំបន់ដែលគ្របដណ្តប់ដោយព្រៃព្រឹក្សា ស្ទឹង បឹងបួ និងសម្បត្តិធម្មជាតិដ៏ល្អប្រពៃ។ ការធ្វើឲ្យមានសុខដុមនីយកម្មនឹងគ្នា អាជ្ញាធរជាតិអប្សរាតែងប្រកាន់ភ្ជាប់នូវគោលការណ៍អភិរក្សដើម្បីអភិវឌ្ឍន៍ អភិវឌ្ឍន៍ដើម្បីអភិរក្សដោយឈរលើមូលដ្ឋានអភិវឌ្ឍន៍ស៊ីសង្វាក់គ្នារវាងធម្មជាតិ ប្រាង្គប្រាសាទនិងអ្នកស្រុក ពោលគឺរវាង បរិស្ថាន វប្បធម៌ និងសហគមន៍ ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់អ្នកជំនាន់ក្រោយតាមរយៈសកម្មភាពអភិវឌ្ឍន៍តំបន់ ដោយសហការជិតស្និទ្ធជាមួយស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរពាក់ព័ន្ធនានា និងជាមួយប្រជាពលរដ្ឋ។

តាមរយៈសកម្មភាពខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរាទាំងអស់នេះ បានធ្វើឲ្យតំបន់អង្គរក្លាយទៅជាគំរូក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍សម្រាប់ប្រជាជាតិជំទៃទៀតលើសកលលោក ហើយជាងនេះទៅទៀត វាក៏បានជួយលើកតម្កើនតម្លៃអង្គរឲ្យកាន់តែលេចធ្លោឡើងជាសកលថែមទៀត និងបានក្លាយទៅជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរចម្រុះជាតិសាសន៍ ឲ្យមកទស្សនាវមណីយដ្ឋានអង្គរកាន់តែច្រើនឡើងជារៀងរាល់ឆ្នាំ។ ក្នុងបរិបទនេះហើយបានជាអាជ្ញាធរជាតិអប្សរាត្រូវតែឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលស្នើសុំសាងសង់សំណង់តូចតាចនិងអនុញ្ញាតជូនពួកគាត់ភ្លាមៗនៅនឹងកន្លែង ដើម្បីជួយសម្រួលដល់ពេលវេលា និងការធ្វើដំណើររបស់ពួកគាត់។

ទន្ទឹមគ្នានេះដែរ អាជ្ញាធរជាតិអប្សរាក៏បានចុះផ្សព្វផ្សាយ និងបង្ហាញបំណងដឹងស្តីពីបេតិកភណ្ឌដល់ប្រជាពលរដ្ឋឲ្យពួកគាត់បានយល់សំដៅធ្វើយ៉ាងណាដើម្បីឲ្យបេតិកភណ្ឌនេះគង់វង្សដល់កូនចៅជំនាន់ក្រោយ។ លើសពីនេះទៀត ក្រុមការងារសហគមន៍ក៏ជាក្រុមជួយសង្គ្រោះបន្ទាន់ ក្នុងករណីគ្រោះថ្នាក់ធម្មជាតិដែលកើតមានឡើងចំពោះប្រជាពលរដ្ឋក្នុងតំបន់អង្គរ កិច្ចការសង្គម កិច្ចការសាសនា និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់នេះតាមរយៈនាំយកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយនិងទារកចែកជូនដល់ស្ត្រីទើបឆ្លងទន្លេជាដើម។

លោក អឿន សំអុន អនុប្រធានលេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានលើកឡើងថាក្នុងខែមីនានេះក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងអនុញ្ញាតសំណើសុំសាងសង់សំណង់តូចតាច និងជួសជុល

ផ្ទះដូនប្រជាពលរដ្ឋដល់មូលដ្ឋានផ្តាល់បានចំនួន១២១ករណី និងចែកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកជូនដល់ស្ត្រីទើបឆ្លងទន្លេរួចចំនួន៣៩៩គ្រួសារ។ ជាមួយគ្នានេះដែរ ក្រុមការងារនេះក៏បានអប់រំផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងស្តីពីបេតិកភណ្ឌ ដល់ប្រជាពលរដ្ឋដល់ប្រជាពលរដ្ឋបានចំនួន១០ភូមិ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន៥៩៤នាក់ ដើម្បីឲ្យពួកគាត់ចូលរួមជួយក្នុងកិច្ចការថែរក្សា ការពារ និងអភិរក្សសម្បត្តិបេតិកភណ្ឌ។

ក្រៅពីនេះ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាក៏បានចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ ដោយនាំយកថវិការបស់អាជ្ញាធរជាតិអប្សរាចំនួន២លានរៀល ទៅឧបត្ថម្ភ**លោក ឈួន ឯម** មេឃុំស្វាយចេកដែលរងគ្រោះដោយភ្លើងឆេះផ្ទះ , ថវិកាចំនួន១លានរៀលទៅឧបត្ថម្ភការសាងសង់សាលាឆទាននៅឃុំបាគង, សង្កសីចំនួន២០ជួយជនក្រីក្រនិងបច្ច័យចំនួន ២ ៥៣៥ ០០០ រៀលទៀត ទៅចូលរួមពិធីបុណ្យឆ្លងកុដិថ្មីនៅវត្តរុន ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាបផងដែរ៕









ក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំងចុះពិនិត្យសុខភាពដោយឥតគិតថ្លៃដល់ប្រជាជននៅភូមិធម្មជាតិរុនតាឯក

ផ្សាយនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីវ័ត្ន រូបភាព ៖ ហ៊ឹង ស្រីវ័ត្ន

ក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំងមកពីអង្គការបេសកម្មមនុស្សធម៌នៅកម្ពុជា «Mission Humanitaier» បានសហការជាមួយក្រុមគ្រូពេទ្យខ្មែរចុះមកពិនិត្យសុខភាពដោយឥតគិតថ្លៃជូនប្រជាជននៅភូមិធម្មជាតិរុនតាឯក និងភូមិផ្សេងៗទៀត បានប្រមាណជាង២០០នាក់ ក្នុងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២៨-៣០ ខែមីនា ឆ្នាំ២០១៧។

លោកគ្រូពេទ្យ GABRIEL BOURIEZ ប្រធានក្រុមការងារបានឱ្យដឹងថា អង្គការបេសកម្មមនុស្សធម៌នៅកម្ពុជា បានធ្វើការនៅស្រុកខ្មែរជាង១០ឆ្នាំមកហើយ ហើយបំពេញការងារស្នើរពេញ២៥រាជធានី/ខេត្តនៅកម្ពុជា តែនេះជាលើកទី១ដែលក្រុមការងារបានមកដល់ភូមិធម្មជាតិរុនតាឯក ដោយមានគ្រូពេទ្យបារាំង-ខ្មែរ២១នាក់ មានជំនាញផ្នែកជំងឺទូទៅសម្រាប់កុមារ មនុស្សធំ រោគស្ត្រី សើស្បែក និងជំនាញព្យាបាលសរសៃដោយវិធីសាស្ត្រផ្សេងៗ។

លោកបន្តទៀតថា គោលបំណងពួកយើងគឺមកពិនិត្យនិងព្យាបាលជំងឺមួយចំនួន ព្រមទាំងផ្តល់ថ្នាំសង្កូវជូនដោយឥតគិតថ្លៃដល់ប្រជាជន ហើយភាគច្រើនអ្នកមកពិនិត្យសុខភាពនៅទីនេះគឺមានជំងឺលើសឈាម ទឹកនោមផ្អែម ប្រព័ន្ធរំលាយអាហារ ជំងឺសន្លាក់ ផ្តាសាយជាដើម។ លោកគ្រូពេទ្យក៏បានសម្តែងនូវក្តីសប្បាយរីកផងដែរ ដែលក្រៅពីពិនិត្យសុខភាពនិងប្រឹក្សាពីជំងឺ ហើយក៏បានចែកសម្ភារៈសិក្សាមួយចំនួនជូនដល់សិស្សានុសិស្សនៅទីនេះ រួមទាំងចូលរួមដាំដើមឈើអនុស្សាវរីយ៍ ដើម្បីលើកកម្ពស់បរិស្ថានផងដែរ។ ពិសេសអរគុណដល់កិច្ចសហការយ៉ាងល្អប្រសើរពីសំណាក់អាជ្ញាធរជាតិអប្សរា ដែលបានជួយសម្រួលដល់ការហូបចុក ស្នាក់នៅ និងបង្កបរិយាកាសរីករាយជាច្រើនដល់ក្រុមការងារ។

លោកយាយ លោត អាយុ៧៤ឆ្នាំ ប្រជាពលរដ្ឋនៅភូមិធម្មជាតិរុនតាឯក បានសម្តែងនូវការសប្បាយរីករាយ និងអរគុណជាខ្លាំងដល់ក្រុមគ្រូពេទ្យបានធ្វើឱ្យឆ្អឹងខ្នងរបស់គាត់ដែលបាក់ដោយសារធ្លាក់ពីលើផ្ទះជាង១០ឆ្នាំមកហើយ អាចងើបខ្លួនដើរត្រង់វិញបាន។ លោកយាយនឹងបន្តអនុវត្តតាមបញ្ជារបស់ពេទ្យជារៀងរាល់ថ្ងៃ ដើម្បីអាចងើបឈរ ដើរ ដេកត្រង់ខ្លួនដូចពីមុន។

មិនខុសគ្នាពីលោកយាយ **លោកតា ឈួ ឆែងួន** អាយុ៦៧ឆ្នាំ បានមកពិនិត្យជើងដែលបាក់ដោយសារដួលម៉ូតូរយៈពេលជាង៥ខែហើយ កម្រើកមិនបាន ដើរមិនរួច មូលហេតុមកពីគៀបសរសៃ។ ក្រោយពីគ្រូពេទ្យចាប់សរសៃរួច ឃើញថាអាចកម្រើក និងដើរខ្លួនឯងតិចៗបានដោយមិនបាច់មានអ្នកគ្រាហ៍ដូចមុន ពិសេសគឺគ្រូពេទ្យបានឱ្យថ្នាំ និងបង្រៀនឱ្យស្គាល់សរសៃ ដើម្បីងាយស្រួលអនុវត្តដោយខ្លួនឯង។ លោកតាសប្បាយចិត្តណាស់ដែលអាជ្ញាធរជាតិអប្សរា បានអញ្ជើញក្រុមគ្រូពេទ្យមកព្យាបាលនិងពិនិត្យជំងឺជូនអ្នកភូមិដោយមិនគិតកម្រៃដូច្នេះ។

បន្ថែមពីនោះ ក្នុងនាមជាប្រធានគ្រប់គ្រងគម្រោងភូមិធម្មជាតិរុនតាឯក **ឯកឧត្តម ម៉ី ម៉ាន់ឌី** ក៏បានអំពាវនាវឱ្យប្រជាជនជាអ្នកភូមិ បុគ្គលិក ឆ្មាំ កម្មករបានមកពិនិត្យសុខភាពឱ្យបានគ្រប់គ្នា ព្រោះនេះជាឱកាសដ៏ល្អសម្រាប់តាមដានសុខភាព។ ក្នុងនោះដែរ ដើម្បីចូលរួមលើកកម្ពស់សុខុមាលភាពប្រជាជន ឯកឧត្តមក៏តែងតែអញ្ជើញក្រុមគ្រូពេទ្យជាច្រើនឱ្យមកកាន់ទីនេះ អប់រំប្រជាជនឱ្យយល់ដឹងពីសុខភាព អនាម័យក្នុងការរស់នៅប្រចាំថ្ងៃ ទាំងកុមារនិងមនុស្សធំ ឱ្យធឹកទឹកស្អាត ហូបចុកស្អាត ពិសេសបំផុសឱ្យការចូលរួមសម្អាតបរិស្ថានទាំងអស់គ្នា ដើម្បីទទួលបានការរស់នៅប្រកបដោយសុខភាពល្អ៕


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh



សេចក្តីជូនដំណឹងស្តីពី ការកាត់យកចេញមែកឈើទាល០១ដើម នៅខាងលិចប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ៦៧៦/ឆ.សដណ
១៧

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់យកចេញមែកឈើទាល ០១ដើម
នៅខាងលិចប្រាសាទបាយ័ន

អាជ្ញាធរអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន និងការប៉ះពាល់ដល់ប្រាសាទជាយថាហេតុ និងដើម្បីលើកកម្ពស់សោភ័ណភាពប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរអប្សរា នឹងធ្វើការកាត់យកចេញមែកឈើទាល០១ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅខាងលិចប្រាសាទបាយ័ន ទាំងអស់ដែលអាចនឹងបង្ក គ្រោះថ្នាក់ជាយថាហេតុដល់អ្នកធ្វើដំណើរ ពិសេសភ្ញៀវទេសចរមកទស្សនាប្រាសាទ។

ការងារនេះនឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

សៀមរាប ថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០១៧
អគ្គនាយក

APSARA

ស៊ុ ម៉ាប់

ចម្លងជូន:
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
"ដើម្បីជូនជ្រាប និងសហការ"
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពារមណ្ឌលដ្ឋានទិដ្ឋរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

ផ្នែកទី ៤
ប្រចាំខែមេសា

ក្រុមអភិរក្សធ្វើកំណាយសង្គ្រោះនៅប្រាសាទតាព្រហ្មបន្តជួសជុលសាលរចាំ

ផ្សាយនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ីង ស្រីរ័ត្ន

ដើម្បីបន្តការងារជួសជុលសាលរចាំនៃប្រាសាទបាយ័ន គម្រោងសហប្រតិបត្តិការឥណ្ឌា-កម្ពុជា ដើម្បីអភិរក្ស និងជួសជុលប្រាសាទតាព្រហ្ម ដែលមានអាជ្ញាធរជាតិអប្សរា និងស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (Archeological Survey of India-ASI) បានធ្វើកំណាយសង្គ្រោះមួយ នៅជ្រុងខាងត្បូងនៃសាលរចាំនេះ ដោយចាប់ពីផ្តើមពីថ្ងៃទី១៣ ខែមីនា រហូតដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧។

លោក D.S. Sood ទីប្រឹក្សាបច្ចេកទេសប្រចាំការដ្ឋានជួសជុលប្រាសាទតាព្រហ្មនៃស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា ASI បញ្ជាក់ថា ការធ្វើកំណាយនេះមានគោលបំណងពីរសំខាន់គឺ ដើម្បីស្វែងរកថ្មដែលបានធ្លាក់កប់ក្នុងដីយកមកប្រើប្រាស់ក្នុងការងារជួសជុលឡើងវិញ និងដើម្បីសិក្សាអំពីរចនាសម្ព័ន្ធប្រាសាទចងក្រងឯកសារ សម្រាប់ការងារជួសជុល។

លោក Sood បន្ថែមថា "ការជួសជុលប្រាសាទ យើងចាំបាច់ត្រូវរក្សានូវអត្តសញ្ញាណដើម ពោលគឺយើងនឹងប្រើប្រាស់ថ្មចាស់ ដែលមានឲ្យអស់លទ្ធភាព មុននឹងជំនួសថ្មថ្មីដែលចាំបាច់។ យើងឃើញមានគំនរថ្មដែលបាក់ធ្លាក់ពីលើមកកប់ក្នុងដីដែលយើងចាំបាច់ធ្វើកំណាយ ដើម្បីចងក្រងឯកសារ និងយកថ្មទាំងនោះទៅប្រើប្រាស់តាមទីតាំងដើមវិញ។ រណ្តៅកំណាយនេះនឹងមានជម្រៅជ្រៅបំផុតប្រហែលកន្លះម៉ែត្រ។ ការធ្វើកំណាយ គឺជាការងារសាមញ្ញសម្រាប់ក្រុមការងារជួសជុល ព្រោះថាយើងមិនអាចជួសជុលតួប្រាសាទ ដោយមិនដឹងអំពីភាពរឹងមាំ ឬភាពទ្រុឌទ្រោមនៃគ្រឹះប្រាសាទនោះទេ"។

លោកស្រី នេត ស៊ីមន មន្ត្រីផ្នែកបុរាណវិទ្យានៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា ដែលបានចូលរួមក្នុងកំណាយនេះបញ្ជាក់ថា រាល់កំណាយស្រាវជ្រាវក្នុងតំបន់អង្គរ ដែលធ្វើឡើងដោយស្ថាប័នអន្តរជាតិ គឺតែងមានមន្ត្រីតំណាងអាជ្ញាធរជាតិអប្សរាចូលរួមជាប្រចាំ។ ជាក់ស្តែង លោកស្រីផ្ទាល់ត្រូវបានថ្នាក់ដឹកនាំចាត់តាំងជាមន្ត្រីតំណាង ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន ASI របស់ឥណ្ឌា ដោយពិនិត្យមើលផ្នែកបច្ចេកទេសនៃការធ្វើកំណាយ និងធ្វើយ៉ាងណាកុំឲ្យមានផលប៉ះពាល់ផ្នែកបុរាណវិទ្យា ព្រមទាំងចងក្រងឯកសារ ដែលទទួលបានពីការធ្វើកំណាយនេះ៕









សេចក្តីជូនដំណឹងស្តីពីការផ្អាកយានដំនិះចូលបរិវេណទីតាំង Drop-off មុខប្រាសាទអង្គរវត្តជាបណ្តោះអាសន្ន

ផ្សាយនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៧ *អត្ថបទ ៖ សេន សែត* *រូបភាព ៖ ហ៊ឹង ស្រីវត្ថ*



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
N°៤២១/ប.ស.ណ
១៧(ស្នើ)

សេចក្តីជូនដំណឹង
ស្តីពី
ការផ្អាកយានជំនិះចូលបរិវេណទីតាំង Drop-off មុខប្រាសាទអង្គរវត្ត ជាបណ្តោះអាសន្ន

អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា មានកិត្តិយសសូមជម្រាបជូនដល់គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ និងសាធារណជនទាំងអស់មេត្តាជ្រាបថា អាជ្ញាធរអប្សរា នឹងធ្វើការផ្អាកយានជំនិះគ្រប់ប្រភេទចូលជាបណ្តោះអាសន្ននៅបរិវេណទីតាំង Drop-off មុខប្រាសាទអង្គរវត្ត **ចាប់ពីថ្ងៃទី៣១ ខែមីនា រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៧** ដើម្បីអនុញ្ញាតឱ្យក្រុមការងារនៃសហភាពសហព័ន្ធយុវជនកម្ពុជា ចាប់ផ្តើមបើកការដ្ឋានរៀបចំកម្មវិធីល្បែងប្រជាប្រិយ និងកម្មវិធីផ្សេងៗទៀតនៅទីតាំងខាងលើនេះ ដើម្បីអបអរសាទរការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០១៧ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៤-១៦ ខែមេសា ឆ្នាំ២០១៧ ខាងមុខនេះ។ ចំពោះយានជំនិះគ្រប់ប្រភេទទាំងអស់ ត្រូវយកទៅចតនៅចំណតខាងលិចប៉ាវីសប្រាសាទអង្គរវត្ត (ដូចមានប្លង់ជូនភ្ជាប់) ។

អាជ្ញាធរអប្សរាសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

សៀមរាប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៧
អគ្គនាយក

ស៊ុំ ម៉ាប់

ចម្លងជូន
-សាលាខេត្តសៀមរាប
-គ្រប់ក្រសួង ស្ថាប័ន មន្ទីរ/អង្គភាពជុំវិញខេត្ត
-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
-សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
-សមាគមមគ្គុទ្ទេសក៏ទសចរណ៍
-សមាគមអ្នកបើកបរថយន្តដឹកជញ្ជូនភ្ញៀវទេសចរ
-គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះអាជ្ញាធរអប្សរា
-ឯកសារ-កាលប្បវត្តិ

អាជ្ញាធរដើម្បីការពារ រមណីយដ្ឋាននិងតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
E-mail : info@apsaraauthority.gov.kh

PHNOM PENH :
#41, Russian Blvd,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 776
Fax : (855-23) 215 771

SIEM REAP :
Bang Korng Village, Ampil Commune, Siem Reap City, Siem Reap Province
Tel: (855-63) 76 55 77 or (855-63) 76 66 76
Fax: (855-63) 76 55 76

មន្ត្រីបុគ្គលិករាជធានីអប្សរា១៨នាក់ចូលរួមកិច្ចប្រជុំផ្លាស់ប្តូរយោបល់បច្ចេកទេសនិងបង្ហាញលទ្ធផលសិក្សាស្រាវជ្រាវសម្រាប់គម្រោងអភិរក្សនិងជួសជុលក្រុមប្រាសាទព្រះពិធូរក្នុងឧទ្យានអង្គរ នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ

ផ្សាយនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីវត្ថ័ រូបភាព ៖ ហ៊ឹង ស្រីវត្ថ័

នាព្រឹកថ្ងៃទី០៤-០៥ មេសា ឆ្នាំ២០១៧ **លោកបណ្ឌិត លី វណ្ណា** ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ បានដឹកនាំមន្ត្រីបុគ្គលិកជំនាញនៃអាជ្ញាធរជាតិអប្សរាចំនួន១៤រូប ដើម្បីចូលរួមកិច្ចប្រជុំផ្លាស់ប្តូរយោបល់បច្ចេកទេស និងបង្ហាញលទ្ធផលសិក្សាស្រាវជ្រាវថ្មីសម្រាប់គម្រោងអភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិធូរក្នុងឧទ្យានអង្គរនៅសាធារណរដ្ឋកូរ៉េ។

គម្រោងអភិរក្សប្រាសាទព្រះពិធូរនិងកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់បច្ចេកទេសនេះ បានទទួលការឧបត្ថម្ភ និងគាំទ្រពីអង្គការ KOICA សហការជាមួយអាជ្ញាធរជាតិអប្សរានៃរាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធីនេះមានការចូលរួម និងធ្វើបទបង្ហាញពីសំណាក់អ្នកជំនាញបុរាណវិទ្យា អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ និងមន្ត្រីបច្ចេកទេសជាតិ-អន្តរជាតិចំនួន៥០នាក់ ពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវ ជួសជុល អភិរក្សប្រាសាទព្រះពិធូរ ក៏ដូចជាកិច្ចការអភិរក្សមរតកវប្បធម៌របស់កូរ៉េផងដែរ។

ចំពោះអ្នកជំនាញខ្មែរទាំង១៤រូបដែលចូលរួមក្នុងកិច្ចប្រជុំនេះ គឺជាមន្ត្រីបុគ្គលិកជំនាញដែលពាក់ព័ន្ធនឹងគម្រោងអភិរក្សជួសជុលក្រុមប្រាសាទព្រះពិធូរ មកពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យាននិងបុរាណវិទ្យាបង្គារ នាយកដ្ឋានគ្រប់គ្រងបុគ្គលិក និងសម្ភារៈ នាយកដ្ឋានផ្សព្វផ្សាយ នាយកដ្ឋានគ្រប់គ្រងទឹក នាយកដ្ឋានព្រៃឈើ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ និងមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ។

មន្ត្រីបុគ្គលិកជំនាញទាំង១៤នាក់ ត្រូវបានចែកចេញជា២វគ្គ គឺវគ្គខ្លីរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃទី១-១៥ ខែមេសា ឆ្នាំ២០១៧ មានគ្នា១០នាក់ ក្នុងនោះមាន៧នាក់មាននាទីធ្វើបទបង្ហាញទាក់ទងនឹងកិច្ចការក្នុងនាយកដ្ឋានរបស់ខ្លួនលើការងារពាក់ព័ន្ធនឹងគម្រោងអភិរក្សជួសជុលប្រាសាទព្រះពិធូរ។ វគ្គទី២មានរយៈពេល៣ខែ ចាប់ពីថ្ងៃទី១ មេសា ដល់៣០ មិថុនា ២០១៧ មានគ្នា៤នាក់ នឹងចូលរួមវគ្គបណ្តុះបណ្តាលដើម្បីសិក្សាបន្ថែមលើជំនាញជួសជុល និងអភិរក្សប្រាសាទបណ្តុះបណ្តាលដោយអ្នកជំនាញកូរ៉េ។

តាមរយៈកិច្ចប្រជុំផ្លាស់ប្តូរយោបល់បច្ចេកទេស និងបង្ហាញលទ្ធផលសិក្សាស្រាវជ្រាវសម្រាប់គម្រោងអភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិធូរ ព្រមទាំងវគ្គបណ្តុះបណ្តាលរយៈពេលវែងនៅសាធារណរដ្ឋកូរ៉េនេះ ជាឱកាសល្អមួយសម្រាប់អ្នកជំនាញអាជ្ញាធរជាតិអប្សរាគ្រប់នាយកដ្ឋានអភិវឌ្ឍសមត្ថភាព ចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍ការងាររបស់ខ្លួនក្នុងកិច្ចការអភិរក្ស និងជួសជុលមរតកវប្បធម៌ជាតិក្នុងតំបន់អង្គរ។

ពិសេសក៏បានរួមចំណែកពង្រឹងទំនាក់ទំនងរវាងស្ថាប័នជាតិ-អន្តរជាតិកូរ៉េ (KOICA-KCHF) កម្ពុជា (អាជ្ញាធរជាតិអប្សរា) កាន់តែល្អប្រសើរ ព្រោះកម្ពុជាត្រូវការអ្នកជំនាញជាតិ-អន្តរជាតិជាច្រើនដើម្បីរួមគ្នាសហការស្រាវជ្រាវ ជួសជុល អភិរក្សលើកតម្លៃប្រាសាទក្នុងឧទ្យានអង្គរឱ្យបានល្អប្រសើរ ហើយក៏ត្រូវការជំនាញបច្ចេកទេសពីអន្តរជាតិបន្ថែម លើជំនាញបច្ចេកទេសក្នុងស្រុករបស់ខ្លួនផងដែរ៕









ក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តបើកកិច្ចប្រជុំផ្ទៃក្នុងអំពីវឌ្ឍនភាពនៃការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត

ផ្សាយនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

នារសៀលថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧ ក្រុមការងាររៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តនៃអាជ្ញាធរជាតិអប្សរា បានបើកអង្គប្រជុំផ្ទៃក្នុងមួយស្តីពីការរីកចម្រើននៃសកម្មភាពការងារ និងការត្រៀមសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ដែលនឹងចូលមកដល់នាពេលដ៏ខ្លីខាងមុខ។

អង្គប្រជុំនេះធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម សុខ សង្វារ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និងជាអនុប្រធានក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ដោយមានការចូលរួមពីថ្នាក់ដឹកនាំទទួលបន្ទុក និងមន្ត្រីបុគ្គលិកពាក់ព័ន្ធជាច្រើនរូបទៀត។

កិច្ចប្រជុំនេះបានផ្តោតសំខាន់ទៅលើការធ្វើឱ្យផ្ទាត់លទ្ធផលការងារ ដែលអនុវត្តបានរួចរាល់ហើយ និងដោះស្រាយគម្រោងចាំបាច់នានា ដែលបម្រើការឲ្យព្រឹត្តិការណ៍នេះប្រព្រឹត្តទៅដោយភាពរលូន និងទទួលបានជោគជ័យ។

កិច្ចប្រជុំនេះដែរ ក៏បានពិភាក្សាលម្អិតទៅលើគម្រោងនៃពិធីដង្ហែចាប៉ីដងវែងយក្ស និងសំបុកមាន់យក្ស ដែលនឹងត្រូវដង្ហែមកតម្កល់ទុកនៅក្នុងបរិវេណព្រឹត្តិការណ៍អង្គរសង្ក្រាន្ត។ តាមលទ្ធផលនៃកិច្ចពិភាក្សានេះ ពិធីដង្ហែអាចនឹងធ្វើឡើងនៅថ្ងៃទី១២ ខែមេសា ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកតា គង់ ណៃ និងសិស្ស៣ជំនាន់របស់លោកតាផងដែរ៕









ថ្នាក់ដឹកនាំមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាប្រារព្ធពិធីសូត្រមន្ត អបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

ផ្សាយនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រីទ្ធី

ពិធីចូលឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ នឹងឈានចូលមកដល់នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៧វេលាម៉ោង ៣៖១២នាទីទៀបភ្លឺ ខាងមុខនេះ។ ដើម្បីអបអរសាទរ និងទទួលទេវតាឆ្នាំថ្មីនេះ ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរា បានរៀបចំប្រារព្ធពិធីនិមន្តព្រះសង្ឃចំនួន១០អង្គចម្រើនព្រះបរិត្ត និងថ្វាយទេយ្យទាន តាមទំនៀមទម្លាប់ព្រះពុទ្ធសាសនា នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

ពិធីនេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាច** អគ្គនាយកអាជ្ញាធរជាតិអប្សរា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា។ ក្នុងនេះដែរ ក៏មានកម្មវិធីគោរពវិញ្ញាណក្ខន្ធ ដាក់បាត្រ បង្សុកូលឧទ្ទិសបុណ្យកុសលដល់ **សម្តេចឧបុលបញ្ញា សុខ អាន** ដែលទើបតែទទួលមរណភាពកន្លងទៅថ្មីៗនេះ។

ក្រៅពីស្តាប់ព្រះសង្ឃសូត្រមន្ត រាប់បាត្រ និងពិធីបង្សុកូលហើយ ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកនៃអាជ្ញាធរជាតិអប្សរាក៏បានជូនទេយ្យទាន និងថវិកាមួយចំនួនចំពោះដូនជីតាជីចំនួន១០រូបផងដែរ៕






ក្រុមហ៊ុនវិនិយោគទេសចរណ៍ធម្មជាតិអន្តរជាតិ CaHeng របស់ចិន ចាប់អារម្មណ៍ខ្លាំងនឹងការបណ្តុះបណ្តាលសិល្បៈរបស់កុមារនៅភូមិធម្មជាតិរុនតាឯក

ផ្សាយនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីតូច្ច រូបភាព ៖ សឿន ប៊ុនសិរ

ក្នុងឱកាសនាំយកសម្ភារៈសិក្សា និងសម្ភារៈកីឡា ទៅឧបត្ថម្ភសិស្សានុសិស្សនៅសាលាបឋមសិក្សាជាលាធំ ដែលស្ថិតនៅក្នុងគម្រោងអភិវឌ្ឍន៍ ភូមិធម្មជាតិរុនតាឯក នារសៀលថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧នេះ ក្រុមហ៊ុនវិនិយោគទេសចរណ៍ធម្មជាតិអន្តរជាតិ CaHeng (CaHeng International Cultural Tourism Investment Co., Ltd.) បានចាប់អារម្មណ៍យ៉ាងខ្លាំងលើការសម្តែងសិល្បៈរបស់ក្រុមកុមារ ដែលត្រូវបានបណ្តុះបណ្តាលនៅក្នុងភូមិធម្មជាតិរុនតាឯកផ្ទាល់។

លោក Gan Chengmao ប្រធានគម្រោងអាណាចក្រអង្គរ នៃក្រុមហ៊ុនវិនិយោគទេសចរណ៍ធម្មជាតិអន្តរជាតិ CaHeng បញ្ជាក់ថា លោកពិតជារីករាយដែលបានរួមចំណែកក្នុងការជួយឧបត្ថម្ភក្មេងៗលើការសិក្សារបស់ពួកគេ។ ជាពិសេស លោកពិតជាពេញចិត្តលើការសម្តែងសិល្បៈប្រពៃណីរបស់កុមារ។ លោកមានគម្រោងនឹងបន្តជួយលើការបណ្តុះបណ្តាលវិស័យសិល្បៈនៅភូមិធម្មជាតិរុនតាឯកជាបន្តទៀត ដែលនឹងជំរុញឲ្យពួកគេក្លាយជាសិល្បករអាជីពនាពេលអនាគត ហើយអាចចេញទៅសម្តែងនៅក្រៅប្រទេសបានទៀតផង។

លោក កន ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ និងជាអនុប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក បញ្ជាក់ថា គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក មិនផ្តោតសំខាន់ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ អាជ្ញាធរជាតិអប្សរាបានគិតគូរផងដែរលើវិស័យអប់រំ។ បច្ចុប្បន្ន នៅភូមិនេះមានសាលាបឋមសិក្សា មួយខ្នង៦បន្ទប់ និងមានសិស្សានុសិស្សសរុប៧៦នាក់។ បន្ថែមលើការបណ្តុះបណ្តាលរបស់ក្រសួងអប់រំ ក្រុមការងារក៏បានរៀបចំបង្កើតការបង្ហាត់ផ្នែកសិល្បៈបុរាណ ដែលមកទល់នឹងសព្វថ្ងៃមានសិស្សចំនួន២០រូប និងអ្នកគ្រូស្ម័គ្រ

ចិត្តចំនួន៣រូប។ របាំសិល្បៈដែលបានហាត់អាចសម្តែង បានមាន៣មុខ គឺ របាំថ្វាយផ្កា របាំច្រូតស្រូវ និងរបាំត្រុដិ។ លោកបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា ពិតជាស្វាគមន៍រាល់ស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីចូលរួមការបណ្តុះបណ្តាលនៅទីនេះ ក្នុងន័យធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋនៅទីនេះមាន ជីវភាពរស់នៅធូរធារសម្បូរសប្បាយ៕









គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកទទួលភ្ញៀវទេសចរធ្វើសមាធិជាលើកដំបូង

ផ្សាយនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស៊ឿន ប៊ុនស៊ីរ

នារសៀលថ្ងៃទី៨ ខែមេសាឆ្នាំ២០១៧ គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកទទួលភ្ញៀវទេសចរជនជាតិអាមេរិកាំងមកកម្សាន្ត និងធ្វើសមាធិជាលើកដំបូងចំនួន៤០រូប។

ពិធីធ្វើសមាធិត្រូវបានរៀបចំនៅមាត់ត្រពាំងបុរាណឈ្មោះត្រពាំងល្បើក និងដឹកនាំដោយ **ព្រះគ្រូឥន្ទបាលី កែវ អាន** ព្រះវិន័យធរអនុគណក្រុងសៀមរាប និងជាចៅអធិការវត្តអង្គរខោងត្បូង ដើម្បីឲ្យសមស្របទៅតាមមាគ៌ាពិតប្រាកដរបស់ព្រះពុទ្ធសាសនា។

តាមធម្មទេសនាពន្យល់របស់ **ព្រះតេជគុណ កែវ អាន** ការធ្វើសមាធិ ជាវិធីសម្រាកមួយដ៏ប្រសើរ ដែលជួយឲ្យរាងកាយ និងផ្លូវចិត្តបានស្ងប់រម្ងាប់ពីកង្វល់ និងភាពចលាចលក្នុងលោក។ វិធីនេះត្រូវបានព្រះពុទ្ធជ្រើសរើសអនុវត្តដើម្បីដុសខាត់បញ្ញារហូតដល់បានត្រាស់ដឹងសច្ចធម៌ តាំងតែពីជាងពីរពាន់ឆ្នាំមុនមកម្ល៉េះ។

លោក មុត យសា ប្រធានអង្គការ PAPA និងជាមគ្គុទ្ទេសក៍ទេសចរណ៍ដែលបានដឹកនាំក្រុមសិស្សសាលាបរទេសមកធ្វើសមាធិនៅភូមិធម្មជាតិរុនតាឯកបានបញ្ជាក់ថា ការរៀបចំដំណើរកម្សាន្ត និងធ្វើសមាធិនៅទីនេះ គឺក្នុងគោលបំណងផ្សព្វ

ផ្សាយនូវវប្បធម៌អារ្យធម៌ខ្មែរ ដែលដូនតាធ្លាប់បានអនុវត្តរាប់ពាន់ឆ្នាំមកហើយ ដូចដែលមានក្នុងចម្លាក់តាមប្រាសាទជាច្រើន។ ម្យ៉ាងទៀត ការជ្រើសរើសភូមិធម្មជាតិរុនតាឯកជាទីតាំង ដោយសារទីនេះមានលក្ខណៈទេសចរណ៍ធម្មជាតិ (Eco-Tourism) និងរួមចំណែកជំរុញវិស័យទេសចរណ៍នៅទីនេះឲ្យកាន់តែទូលំទូលាយ។

ឯកឧត្តម ម៉ី ម៉ាន់ឌី ទីប្រឹក្សានៃអាជ្ញាធរជាតិអប្សរា និងជាប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកមានប្រសាសន៍ថា ទេសចរណ៍សមាធិ គឺជាគម្រោងមួយនៃទេសចរណ៍ធម្មជាតិដ៏ច្រើននៅភូមិធម្មជាតិរុនតាឯក។ កន្លងមក ភ្ញៀវទេសចរបានចាប់អារម្មណ៍លើគម្រោងផ្ទះស្នាក់ ការធ្វើស្រែ ធ្វើក្រឡាន និងបង្ហោះគោមជាដើម។ នេះជាលើកទីមួយហើយដែលភ្ញៀវទេសចរបានអារម្មណ៍លើការធ្វើសមាធិ។

ឯកឧត្តមបន្ថែមថា វិស័យទេសចរណ៍គឺជាគម្រោងធំមួយជាមួយគ្នានឹងវិស័យកសិកម្ម ដែលក្រុមគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកបានបង្កើតឡើង ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋនៅទីនេះឲ្យកាន់តែល្អប្រសើរ៕






គណៈប្រតិភូអាជ្ញាធរជាតិអប្សរាចូលជួបសម្តែងការគួរសមថ្នាក់ដឹកនាំ KOICA និងទស្សនកិច្ចនៅតាមវិទ្យាស្ថានស្រាវជ្រាវជាតិកូរ៉េមួយចំនួនទាក់ទងនឹងការអភិរក្សជួសជុលមរតកវប្បធម៌មនុស្សជាតិ

ផ្សាយនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ឹង ស្រីរ័ត្ន

ក្នុងដំណើរចូលរួមកិច្ចប្រជុំនិងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ ចាប់ពីទី១ដល់១៥ ខែមេសា ឆ្នាំ២០១៧ គណៈប្រតិភូនៃអាជ្ញាធរជាតិអប្សរាចំនួន១៤នាក់ ដឹកនាំដោយ**លោកបណ្ឌិត លី វណ្ណា** បានចូលជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំនៃអង្គការ KOICA នៅអាគារស្នាក់ការធំរបស់អង្គការផ្ទាល់ ព្រមទាំងទៅទស្សនកិច្ចនៅតាមបណ្តាវិទ្យាស្ថានស្រាវជ្រាវជាតិកូរ៉េមួយចំនួនដែលទាក់ទងនឹងការអភិរក្សជួសជុលមរតកវប្បធម៌មនុស្សជាតិ។

ក្នុងពិធីជំនួបសម្តែងការគួរសមនេះ **លោកស្រី Kang Youn Hwa** អគ្គនាយកប្រចាំតំបន់អាស៊ីអាគ្នេយ៍របស់ KOICA បានបង្ហាញអំពីការងារសំខាន់ៗរបស់ខ្លួននិងទិសដៅទៅអនាគតនៃកិច្ចសហប្រតិបត្តិការ និងជំនួយក្នុងវិស័យសុខាភិបាល អប់រំ ការអភិវឌ្ឍសង្គម ព្រមទាំងកិច្ចការអភិរក្សជួសជុលមរតកវប្បធម៌មនុស្សជាតិផងដែរ។

ប្រទេសកម្ពុជាក៏ជាប្រទេសគោលដៅមួយដែលអង្គការ KOICA បានគិតគូរដល់ការអភិរក្សប្រាសាទបុរាណនៅក្នុងតំបន់អង្គរដែរ តាមរយៈមូលនិធិមរតកវប្បធម៌កូរ៉ែ (KCHF) សហការជាមួយស្ថាប័នអាជ្ញាធរជាតិអប្សរាទាំងផ្នែកថវិកា និងអ្នកជំនាញដើម្បីធ្វើការជួសជុលអភិរក្សប្រាសាទព្រះពិធូរឱ្យបានសម្រេចតាមគម្រោង។

បន្ទាប់ពីជំនួបសម្តែងការគួរសមហើយ គណៈប្រតិភូអាជ្ញាធរជាតិអប្សរាទាំង១៤នាក់ក៏បានអញ្ជើញចូលទស្សនាការតាំងបង្ហាញពីសមិទ្ធផលនិងលទ្ធផលការងារស្តីពីជួសជុលអភិរក្សមរតកវប្បធម៌ជាតិកូរ៉ែនៅសាលពិព័រណ៌របស់ KCHF មើលការរៀបចំ ការរក្សាទុក ការតាំងបង្ហាញវត្ថុបុរាណ ពិសេសការយកចិត្តទុកដាក់លើអ្នកបន្តវេនថែរក្សាមរតកវប្បធម៌។

ក្រៅពីនោះទៀត គណៈប្រតិភូជំនាញមកពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្គារ គ្រប់គ្រងទឹក អភិរក្សព្រៃឈើ គ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍អង្គរ មជ្ឈមណ្ឌលតម្កល់ឯកសារអង្គរ គ្រប់គ្រងបុគ្គលិកនិងសម្ភារៈ ព្រមទាំងផ្សព្វផ្សាយ ក៏បានបន្តដំណើរទស្សនកិច្ចនៅវិទ្យាស្ថានស្រាវជ្រាវផ្សេងៗដូចជា វិទ្យាស្ថានតម្កល់ឯកសារ និងវិទ្យាស្ថានស្តាបត្យកម្ម ដើម្បីស្វែងយល់ពីការរៀបចំតាំងបង្ហាញលទ្ធផលការងារ ការដាក់រក្សាឯកសារចាស់ៗ និងវត្ថុបុរាណផ្សេងៗឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងរក្សាគុណភាពបានល្អដោយបច្ចេកទេសបុរាណនិងវិទ្យាសាស្ត្រទំនើប។

តាមរយៈពិធីសំណេះសំណាលនិងទស្សនកិច្ចសិក្សានៅតាមវិទ្យាស្ថានសំខាន់ៗនេះ ក្រៅពីបង្កើននូវចំណងមិត្តភាព ទំនាក់ទំនងល្អក្នុងការសហការគ្នាហើយ ក៏ជាឱកាសមួយដែលអ្នកជំនាញអាជ្ញាធរជាតិអប្សរាបានយល់ដឹង បន្ថែមពីការលើកតម្លៃមរតកវប្បធម៌កូរ៉ែ។ ចំណុចវិជ្ជមានទាំងនេះគឺជាបទពិសោធន៍ល្អសម្រាប់ស្ថាប័នអាជ្ញាធរជាតិអប្សរា យកមកអនុវត្តឱ្យបានកាន់តែប្រសើរលើជំនាញរបស់ខ្លួនក្នុងការអភិរក្ស លើកតម្លៃមរតកវប្បធម៌ជាតិ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរប្រកបដោយចីរភាព៕









អាជ្ញាធរអប្សរារៀបចំចំណតរ៉ឺម៉កនៅខាងលិចប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ និងរូបភាព ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ

ស្របពេលដែលចំនួនភ្ញៀវទេសចរបន្តកើនឡើង វិស័យទេសចរណ៍បានបង្កើតការងារជាច្រើនជូនប្រជាពលរដ្ឋខ្មែរ និងបង្កើនចំណូលចូលថវិកាជាតិ សម្រាប់ជំរុញការងារអភិវឌ្ឍន៍នៅក្នុងប្រទេស។ ទន្ទឹមនឹងនោះដែរ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមជាច្រើនទៀតនៅតំបន់អង្គរ គឺកំណើនមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ។

អាជ្ញាធរអប្សរា ត្រូវគិតគូរឲ្យមានចំណតសមស្របតាមចំនួនភ្ញៀវដែលប្រាសាទនីមួយៗអាចទទួលបាន ដោយមិនបង្កផលប៉ះពាល់អវិជ្ជមានមកលើប្រាសាទ បរិស្ថាន និងទេសភាពវប្បធម៌។ ជាក់ស្តែងកន្លងមកនៅប្រាសាទតាព្រហ្ម តែងតែមានរ៉ឺម៉កដឹកភ្ញៀវទេសចរជាច្រើនចតតាមដងផ្លូវ ដោយសារចំណតនៅមានទំហំតូច ពិសេសនៅផ្នែកខាងលិច ដែលនេះបង្កឲ្យបាត់សណ្តាប់ធ្នាប់ ស្ទះចរាចរណ៍ និង អាចប៉ះពាល់ដល់ប្រាសាទ។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៧កន្លងទៅនេះ ក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរណ៍អង្គរ ដឹកនាំដោយ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងអាជ្ញាធរអប្សរា បានចុះពិនិត្យទីតាំងផ្ទាល់ជាមួយអ្នកជំនាញ អាយស៊ីស៊ីអង្គរ ដើម្បីរៀបចំចំណតបណ្តោះអាសន្នសម្រាប់រ៉ឺម៉ក នៅលើកំណាត់ផ្លូវកៅស៊ូចាស់ ខាងជើងខ្លោងទ្វារខាងលិចប្រាសាទតាព្រហ្ម។

មានប្រសាសន៍ក្នុងឱកាសនោះ **ឯកឧត្តម សុខ សង្ហារ** បញ្ជាក់ថា "ជាការចាំបាច់ណាស់ ដែលត្រូវរៀបចំចំណតឲ្យបានប្រសើរ ដើម្បីផ្តល់សេវាជូនភ្ញៀវទេសចរកាន់តែល្អ និងថែរក្សាទេសភាពវប្បធម៌នៃតំបន់អង្គរយើង។ យើងនឹងជំរុញឲ្យមានការរៀបចំចំណតនៅតាមប្រាសាទផ្សេងៗទៀតក្នុងពេលឆាប់ៗខាងមុខ"។

គួររំលឹកផងដែរថា កន្លងមកអាជ្ញាធរអប្សរាបានរៀបចំសណ្តាប់ធ្នាប់និងគ្រប់គ្រងលំហូរភ្ញៀវ ដោយសាងសង់ចំណតនៅមុខប្រាសាទអង្គវត្ត ជួសជុលនិងរៀបចំឲ្យមានផ្លូវដិះកង់ អនុវត្តចរាចរណ៍ឯកទិសនៅខ្លោងទ្វារទន្លេអុំនាពេលព្រឹក កំណត់វង់ទស្សនានៅប្រាសាទតាព្រហ្មជាដើម។ ការរៀបចំនេះទទួលបានការសាទរជាខ្លាំងពីសំណាក់សាធារណជន ហើយពួកគាត់សំណូមពរ ឲ្យអាជ្ញាធរអប្សរាបន្តរៀបចំចំណតនៅតាមទីតាំងដទៃទៀត ដើម្បីកុំឲ្យមានការចតពាសវាលពាសកាល ដែលនាំឲ្យបាត់សណ្តាប់ធ្នាប់និងប៉ះពាល់ដល់តម្លៃអង្គរ៕









ព្រះតេជគុណ ពិន សែម ៖ ភូមិមានីមានន្ទ មិនមែនភូមិគិរីមានន្ទទេ

ផ្សាយនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ អ៊ីសា រ៉ហ៊ីនី

ភូមិគិរីមានន្ទ ជាភូមិចំណាស់មួយដែលស្ថិតនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ភាគខាងកើតសង្កាត់អំពិល ក្រុងសៀមរាប។ តាមប្រវត្តិដើមនៃឈ្មោះភូមិនេះ ដែលនិទានដោយ **ព្រះតេជគុណ ពិន សែម** ចៅអធិការវត្តព្រះរាជបូណ៌ ភូមិនេះមានឈ្មោះថា មានីមានន្ទ មិនមែន គិរីមានន្ទ ដែលអ្នកភូមិហៅសព្វថ្ងៃនេះទេ។

តាមការនិទានរបស់ **ព្រះតេជគុណ ពិន សែម** ដើមឡើយ មានបងប្អូនប្រុស២នាក់ គឺតានី និងតានន្ទ បានទៅតាំងទីមុនគេនៅក្នុងភូមិនោះ។ ម្ល៉ោះហើយ អ្នកស្រុក ក៏ដូចជាអ្នកភូមិក្បែរនោះ ក៏ហៅភូមិនោះថា មានីមានន្ទ តជាប់រហូតមក។ ព្រះតេជគុណបញ្ជាក់ថា កាលពីព្រះតេជគុណនៅពីក្មេង ចាស់ៗតែងស្គាល់ និងហៅភូមិនេះថា មានីមានន្ទរហូតមក។ ប៉ុន្តែចាប់ពីឆ្នាំ១៩៨០ ភូមិនេះបែរជាត្រូវគេដាក់ឈ្មោះថា គិរីមានន្ទទៅវិញ។

តាមការបកស្រាយរបស់ **ព្រះតេជគុណ ពិន សែម** តាមពិតទៅ ឈ្មោះគិរីមានន្ទ គឺជារឿងមួយទាក់ទងនឹងព្រះពុទ្ធសាសនា។ ក្នុងគិរីមានន្ទសូត្រ មានភិក្ខុមួយអង្គព្រះនាម គិរីមានន្ទ លោកមានអាពាធខ្លាំង ហើយព្រះអានន្ទបានទៅពិតទូលព្រះពុទ្ធ។ ព្រះពុទ្ធបានសម្តែងនូវសញ្ញា១០ប្រការឲ្យអានន្ទយកទៅសូត្រឲ្យគិរីមានន្ទស្តាប់ និងពិចារណា ក្រោយមកក៏បានជាសះស្បើយឡើងវិញ។ សាច់រឿងនេះមិនមានទំនាក់ទំនងអ្វីជាមួយនឹងភូមិហ្នឹងទេ។

ដូច្នេះហើយ ក្នុងនាមព្រះតេជគុណ ដែលបានដឹងប្រវត្តិនៃឈ្មោះភូមិខាងដើម ព្រះអង្គមានសង្ឃដីកាថា ព្រះអង្គមិនសូវចិត្តទេ និងស្នើសុំឲ្យអាជ្ញាធរ និងអ្នកស្រាវជ្រាវទាំងអស់ជួយផ្សព្វផ្សាយ លើកពីឈ្មោះដើមមកប្រើវិញ ព្រោះវាជាប្រវត្តិសាស្ត្រ ដែលកូនចៅជំនាន់ក្រោយ ចាំបាច់ត្រូវដឹង និងចងចាំ។

សូមបញ្ជាក់ថា **ព្រះតេជគុណ ព្រះមហាវិមលធម្ម ពិន សែម** ជាព្រះរាជាគណៈថ្នាក់ទោ និងជាឧត្តមទីប្រឹក្សានៃសម្តេចសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងបច្ចុប្បន្នជាចៅអធិការវត្ត ព្រះរាជបូណ៌ ខេត្តសៀមរាប។

តបនឹងបញ្ហានេះដែរ អ្នកបុរាណវិទូ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរា **លោក អ៊ឹម សុខវិទ្ធី** បានពន្យល់ថា វាមិនខុសនោះទេដែល**ព្រះតេជគុណ ពិន សែម** បកស្រាយយ៉ាងនេះ។ លោកពន្យល់ថា នៅសម័យបុរាណការដាក់ឈ្មោះភូមិ អាស្រ័យទៅលើរាជការដាក់ ឬរាជការដាក់ទៅតាមព្រះដែលតម្កល់នៅក្នុងសហគមន៍នោះ ហើយឈ្មោះខ្លះទៀតក៏ដាក់យោងតាមធម្មជាតិផងដែរ។

លោកបញ្ជាក់ថា ក្នុងរឿងភូមិមានីមានន្ទ ឈ្មោះកកើតឡើងដោយមនុស្សទីមួយដែលចូលទៅរៀបចំភូមិស្ថាននៅទីនោះ ហើយមិនដឹងដាក់ឈ្មោះអី គេក៏ដាក់ឈ្មោះមនុស្សនោះតែម្តងទៅ។ **លោក អ៊ឹម សុខវិទ្ធី** បន្ថែមទៀតថា ក្នុងសាច់រឿងនេះជារឿងទូទៅក្នុងសង្គមខ្មែរ វាតែងមានការបកស្រាយដោយយោងលើរឿងព្រេងនិទាន ខ្លះទាក់ទងនឹងប្រវត្តិសាស្ត្រ និងខ្លះទៀតទាក់ទងនឹងវប្បធម៌ ប៉ុន្តែលោកបញ្ជាក់ថា គេត្រូវបែងចែកឲ្យដាច់ចំពោះរឿងទាំងនេះ ហើយនេះជាបង្ហាញពីភាពចម្រុះនៃវប្បធម៌ខ្មែរផងដែរ៕









អាជ្ញាធរជាតិអប្សរា រួមជាមួយក្រសួងទេសចរណ៍ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនកងទ័ពនៃយោធភូមិភាគទី៤

ផ្សាយនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

នាវេលាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៧ ប្រតិភូរបស់ក្រសួងទេសចរណ៍ និងអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង **ឯកឧត្តម សឺង តង់** ទីប្រឹក្សា អាជ្ញាធរជាតិអប្សរា តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាច** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះសួរសុខទុក្ខ និងនាំយកអំណោយ ចែកជូនដល់កងទ័ពដែលឈរជើងប្រចាំការនៅបញ្ជាការដ្ឋានយោធភូមិភាគទី៤ ស្ថិតនៅក្នុងភូមិស្ពានក្អែក ឃុំកណ្តៀក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដើម្បីរួមចំណែកអបអរសាទរក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិដែលនឹងប្រព្រឹត្តទៅក្នុងពេលខាងមុខ។

ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ **ឯកឧត្តម សឺង តង់** ទីប្រឹក្សា អាជ្ញាធរជាតិអប្សរា **ឯកឧត្តមឧត្តមសេនីយ៍ ជា ម៉ន** មេបញ្ជាការយោធភូមិភាគទី៤ និងអស់លោក លោកស្រី ជាមន្ត្រីរាជការ នៃក្រសួងទេសចរណ៍ អាជ្ញាធរជាតិអប្សរា ព្រមទាំងមេបញ្ជាការ មេបញ្ជាការរង នាយទាហាន ពលទាហាន ជាច្រើនរូបទៀត ។

ឯកឧត្តម សឺង តង់ បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ ព្រមទាំងការជូនពរ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ចំពោះនាយទាហាន និងពលទាហានទាំងអស់ដែលកំពុងឈរជើង ប្រចាំការនៅសមរភូមិជួរមុខ។

មានមតិសំណេះសំណាលក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត ថោង ខុន** បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រមទាំង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ហើយ ឯកឧត្តមក៏បានកោតសរសើរ និងដឹងគុណនូវគំរូវីរភាពដ៏អង់អាចក្លាហានរបស់កងយោពលខេមរភូមិន្ទ ដែលបានធ្វើពលីកម្មដ៏ខ្ពង់ខ្ពស់សម្រាប់ប្រទេសជាតិទាំងមូល។

ចំណែកអំណោយដែលបានចែកជូនក្នុងឱកាសនោះរួមមាន មី ត្រីខ ទឹកសុីអ៊ីវ ទឹកត្រី អំបិល ប៊ីចេង ទឹកបរិសុទ្ធ ស្រាបៀអង្គរ និងថវិកា ដែលសប្បុរសជនឧបត្ថម្ភ មានចំនួនសរុបជាង៥៧លានរៀល។ ក្នុងនោះអាជ្ញាធរជាតិអប្សរាចូលរួមឧបត្ថម្ភចំនួន៨លានរៀលផងដែរ៕









ចាប៉ីដងវែងខ្នាតយក្សនឹងត្រូវដង្ហែចូលបរិវេណព្រឹត្តិការណ៍អង្គរសង្ក្រាន្តនារសៀល១២មេសានេះ

ផ្សាយនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ យិន សូភ័ត

ដើម្បីអបអរសាទរដល់ការដាក់ចាប៉ីដងវែងរបស់ខ្មែរចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅនេះ ក្រុមការងារអង្គរសង្ក្រាន្តបានរៀបចំចាប៉ីដងវែងដ៏ធំ ដើម្បីដាក់តាំងនៅក្នុងបរិវេណភូមិខ្ចីជូនភ្ញៀវទេសចរជាតិ-អន្តរជាតិ ចូលទស្សនាក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំនេះ។

ពិធីដង្ហែជាផ្លូវការនឹងប្រារព្ធឡើងនៅរសៀលថ្ងៃទី១២ ខែមេសា វេលាម៉ោង២រសៀល ចេញពីវត្តតាំងតុឆ្ពោះមកកាន់បរិវេណភូមិខ្ចីខាងជើងប្រាសាទបាយ័ន ក្រោមអធិបតីភាព **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា ដោយមានការចូលរួមពីក្រុមការងារស្ម័គ្រចិត្ត អាជ្ញាធរជាតិអប្សរា និងសាធារណជនជាច្រើន។ ជាពិសេស ពិធីដង្ហែនេះនឹងមានវត្តមាន **លោកតា គង់ ណៃ** និងសិស្សទាំងបីជំនាន់របស់លោកតាផងដែរ។

ចាប៉ីដងវែងខ្នាតធំ ដែលគ្រោងនឹងដាក់តាំងបង្ហាញក្នុងបរិវេណភូមិខ្ចីនៅថ្ងៃអង្គរសង្ក្រាន្ត មានប្រវែង១០ម៉ែត្រកន្លះ មានតួស្នូកទទឹង ប្រវែង ២,២០ម៉ែត្រ បណ្តោយប្រវែង ២,៨០ម៉ែត្រ និងកម្រាស់ ៦០សង់ទីម៉ែត្រ។ ដងចាប៉ី ដែលមានប្រវែង៧,៧០ម៉ែត្រ ធ្វើអំពីឈើខ្នុរព្រៃ ដែលជាប្រភេទឈើម៉្យាងសម្រាប់ធ្វើឧបករណ៍ភ្លេងខ្មែរ ដូចជាស្គរ តាខេ ឃឹម ជាដើម។ ចំណែកស្នូកធ្វើអំពីឈើកុំប្លាកេ និងខ្សែចាប៉ីធ្វើអំពីខ្សែដំរីទំហំ៨៥សង់ទីម៉ែត្រ។ ប្រលូតចំនួន៣ ដែលមានទំហំ ១៨សង់ទីម៉ែត្រ និងបណ្តោយប្រវែង១,០៥ម៉ែត្រ ត្រូវបានរចនាក្បួរក្បាច់យ៉ាងប្រណីត៕









រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈចុះជួបថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាជាលើកដំបូង ក្នុងឋានៈជាប្រធានអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ រឿម សុផល្លា

នាព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧នេះ **ឯកឧត្តមបណ្ឌិត ហ៊ែរ៉ឹង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចុះជួបសំណេះសំណាលថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរាផ្ទាល់។ នេះគឺជាជំនួបដំបូងបង្អស់របស់លោកជំទាវក្នុងឋានៈជាប្រធានអាជ្ញាធរជាតិអប្សរា បន្ទាប់ពីអាជ្ញាធរជាតិអប្សរាត្រូវបានរាជរដ្ឋាភិបាលផ្ទេរការគ្រប់គ្រងពីទីស្តីការគណៈរដ្ឋមន្ត្រី ឲ្យស្ថិតនៅក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ក្នុងឱកាសជួបសំណេះសំណាលនេះ លោកជំទាវរដ្ឋមន្ត្រីបានស្តាប់របាយការណ៍សង្ខេបអំពីស្ថានភាពទូទៅនៃអាជ្ញាធរជាតិអប្សរា ដែលរាយការណ៍ជូនដោយ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា។

មានប្រសាសន៍ក្នុងឱកាសនេះ លោកជំទាវបានរំឭកឡើងវិញនូវស្នាដៃសំខាន់ៗនៃអតីតប្រធានអាជ្ញាធរជាតិអប្សរា គឺ **សម្តេចឧកញ៉ាឧបទេសបណ្ឌិត សុខ អាន** ជាអាទិ៍ គឺការការពារបាននូវរមណីយដ្ឋានអង្គរ និងកេរ្តិ៍ឈ្មោះនៃអង្គរលើឆាកអន្តរជាតិក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា។

ជាអនុសាសន៍ណែនាំ លោកជំទាវបានរំឭកឲ្យថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកទាំងអស់បន្តជំរុញការទៅមុខទៀត ក្នុងបេសកកម្មបម្រើបេតិកភណ្ឌអង្គរ និងរួមគ្នាបន្តដោះស្រាយបញ្ហាដែលនៅសេសសល់ ឲ្យស្របនឹងទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរប្រកបដោយចីរភាព៕






ពិធីបួងសួងអង្គរសង្ក្រាន្តត្រូវបានរៀបចំនៅលើភ្នាររបែនប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ អ៊ីសា រ៉ហ៊ីនី

ពិធីចូលឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ នឹងឈានចូលមកដល់នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៧វេលាម៉ោង ៣:១២នាទីទៀបភ្លឺ។ កម្មវិធីសាសនា និងប្រពៃណីជាច្រើនកំពុងរៀបចំនិងប្រព្រឹត្តទៅក្នុងបរិវេណរមណីយដ្ឋានអង្គរជាបន្តបន្ទាប់ ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនេះ។

នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧ សហភាពសហព័ន្ធយុវជនកម្ពុជានិងអាជ្ញាធរជាតិអប្សរា បានរៀបចំពិធីបួងសួងសុំសេចក្តីសុខចម្រើនសិរីសួស្តី នៅលើភ្នាររបែននៃប្រាសាទអង្គរវត្ត។ ពិធីនេះរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ឯកឧត្តម ហ៊ុន ម៉ានី** និងការញើញចូលរួមពីថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា មន្ត្រីរាជការ និងក្រុមការងារជាច្រើនរូបទៀត៕









អាជ្ញាធរជាតិអប្សរាចែកចាយទឹកដោយឥតគិតថ្លៃក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត

ផ្សាយនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ សេន សែត

ដើម្បីអបអរសាទរពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ អាជ្ញាធរជាតិអប្សរាបានចែកចាយទឹកបរិសុទ្ធដោយមិនគិតថ្លៃដល់ភ្ញៀវជាតិ និងអន្តរជាតិ ដែលចូលមកទស្សនាព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ចាប់ពីថ្ងៃទី១៣ ដល់ទី១៦ ខែមេសា ឆ្នាំ២០១៧។

ទីតាំងចែកចាយទឹកបរិសុទ្ធមាន៥កន្លែង គឺជុំវិញបរិវេណប្រាសាទអង្គរវត្តចំនួន៣ទីតាំង មុខទីលានដល់ជំរី១ទីតាំង និងនៅទីលានប្រណាំងរទេះគោផ្លូវ៦០ម៉ែត្រ១ទីតាំង។

អាជ្ញាធរជាតិអប្សរាសូមគោរពអញ្ជើញសាធារណជន ភ្ញៀវជាតិ និងអន្តរជាតិដែលមកទស្សនាព្រឹត្តិការណ៍អង្គរសង្ក្រាន្តទាំងអស់ ទទួលពិសាទឹកតាមទីតាំងខាងលើដោយមេត្រីភាព៕





គណៈប្រតិភូអាជ្ញាធរជាតិអប្សរាបញ្ចប់ទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រង ជួសជុល និងអភិរក្សបេតិកកណ្ឌវប្បធម៌នៅសាធារណរដ្ឋកូរ៉េ

ផ្សាយនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីវ័ណ្ឌ រូបភាព ៖ ហ៊ឹង ស្រីវ័ណ្ឌ

ក្នុងដំណើរទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រង ជួសជុល និងអភិរក្សបេតិកកណ្ឌវប្បធម៌ ព្រមទាំងចូលរួមប្រជុំផ្លាស់ប្តូរយោបល់បច្ចេកទេស និងបង្ហាញលទ្ធផលសិក្សាស្រាវជ្រាវសម្រាប់គម្រោងអភិរក្សនិងជួសជុលក្រុមប្រាសាទព្រះពិធូក្នុងឧទ្យានអង្គរជាលើកទី២នៅសាធារណរដ្ឋកូរ៉េរយៈពេល១៤ថ្ងៃ បានបញ្ចប់ហើយនារសៀលថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៧ នៅទីស្នាក់ការមូលនិធិមរតកវប្បធម៌កូរ៉េ KCHF (Korea cultural Heritage foundation)។

ពិធីបិទវគ្គសិក្សានេះអញ្ជើញចូលរួមពីសំណាក់លោក LEE Hyang Soo ប្រធានស្តីទីមូលនិធិមរតកវប្បធម៌កូរ៉េ (KCHF) **លោកបណ្ឌិត លី វណ្ណា** ប្រធាននាយកដ្ឋានអភិរក្សក្នុងឧទ្យាននិងបុរាណវិទ្យាបង្ការ មន្ត្រី-បុគ្គលិកជំនាញនៃអាជ្ញាធរជាតិអប្សរា និងក្រុមការងាររបស់ KCHF។

ដំណើរទស្សនកិច្ចរយៈពេល១៤ថ្ងៃបានទៅកាន់រមណីយដ្ឋានប្រវត្តិសាស្ត្រ សារមន្ទីរ បូជនីយដ្ឋាន ការដ្ឋានកំណាយ ជាច្រើនដែលបានចុះបញ្ជី បេតិកកណ្ឌពិភពលោកជាសម្បត្តិវប្បធម៌មនុស្សជាតិដោយអង្គការយូណេស្កូនៅក្នុងទីក្រុងសេអ៊ូលនិងបណ្តាខេត្តផ្សេងៗរបស់សាធារណរដ្ឋកូរ៉េ។ កម្មវិធីនេះធ្វើឡើងក្នុងបំណងឱ្យអ្នកជំនាញអាជ្ញាធរជាតិអប្សរាគ្រប់ផ្នែកបានស្វែងយល់ពីប្រវត្តិសាស្ត្រកូរ៉េ ការគ្រប់គ្រងបេតិកកណ្ឌ ការស្រាវជ្រាវបុរាណវិទ្យា ការរៀបចំទេសភាពវប្បធម៌ ការរក្សាឯកសារ ការរៀបចំពិព័ណ៌ និងការលើកតម្លៃមរតកវប្បធម៌ដើម្បីជាព័ត៌មានបន្ថែមសម្រាប់យកមក បំពេញការងារជាប្រចាំនៅរមណីយដ្ឋានអង្គរ។

លោក LEE Hyang Soo បានថ្លែងអំណរគុណចំពោះការចូលរួមរបស់អ្នកជំនាញអាជ្ញាធរ ជាតិអប្សរាជាលើកទី២នៃដំណើរទស្សនកិច្ចសិក្សានេះ ក៏ដូចជាគម្រោងកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និង KCHFលើការជួសជុល និងអភិរក្សក្រុមប្រាសាទព្រះពិធូ ដែលដំណើរការបានយ៉ាងល្អប្រសើរ។

លោកបណ្ឌិត លី វណ្ណា ក៏បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ខ្ពស់របស់ស្ថាប័ន KCHF មកលើគណៈប្រតិភូអាជ្ញាធរជាតិអប្សរាកំឡុងពេលបំពេញទស្សនកិច្ចសិក្សា។ ទស្សនកិច្ចនេះជាឱកាសល្អសម្រាប់អ្នកជំនាញគ្រប់ផ្នែកបាន

ដកស្រង់បទពិសោធន៍ការងារ របៀបគ្រប់គ្រងបេតិកភណ្ឌ ការជួសជុល ការអភិរក្សសំណង់ប្រាសាទបុរាណ និងយល់កាន់តែច្បាស់ពីវប្បធម៌ ការរស់នៅ ទំនៀមទម្លាប់ ប្រពៃណី ប្រវត្តិសាស្ត្រកូរ៉េផងដែរ។ អាជ្ញាធរជាតិអប្សរានឹងបន្តជួយជំរុញកិច្ចសហការជាមួយ KCHF លើការងារអភិរក្សនិងជួសជុលក្រុមប្រាសាទព្រះពិធូក្នុងតំបន់ឧទ្យានអង្គរ ឱ្យបានសម្រេចតាមគម្រោង។

កញ្ញា ហ៊ីង ស្រីវត្ថ បុគ្គលិកផ្សព្វផ្សាយបានលើកឡើងថា អ្វីដែលគួរឱ្យចាប់អារម្មណ៍ចំពោះដំណើរទស្សនកិច្ចនេះ គឺការរៀបចំរមណីយដ្ឋានបេតិកភណ្ឌដែលលម្អទៅដោយធម្មជាតិយ៉ាងស្រស់បំព្រង សណ្តាប់ធ្នាប់ ទិសដៅទស្សនា និងភាពសម្បូរនៃកន្លែងកម្សាន្តដែលទាក់ទាញបានទាំងអ្នកស្រាវជ្រាវ និងអ្នកមកកម្សាន្តឱ្យស្រឡះចិត្តគំនិត ព្រមទាំងបានស្វែងយល់ពីប្រវត្តិនៃរមតកវប្បធម៌ទាំងនោះផង។ រឿងមួយទៀត គឺការផ្សព្វផ្សាយពីបេតិកភណ្ឌទៅកាន់សាធារណជនបានទូលំទូលាយតាមរយៈបច្ចេកវិទ្យាទំនើប ក៏ដូចជាអប់រំចិត្តគំនិតដល់មនុស្សជំនាន់ក្រោយឱ្យបានស្គាល់ និងចេះស្រឡាញ់តាំងពីតូចៗ។

លោក សយ សុការិន្ទ ប្រធានអភិរក្សប្រាសាទអង្គរវត្តនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ បានចាប់អារម្មណ៍ លើការអភិរក្ស និងជួសជុលបេតិកភណ្ឌនៅប្រទេសកូរ៉េគឺមានបច្ចេកទេសខ្ពស់ បុគ្គលិកមានជំនាញវិជ្ជាជីវៈ និងប្រើប្រាស់សម្ភារៈសមស្របទៅនឹងសំណង់ប្រាសាទ។ ម្យ៉ាងវិញទៀតគ្រប់តំបន់បេតិកភណ្ឌទាំងអស់មានការរៀបចំបានល្អពោរពេញទៅដោយធម្មជាតិគួរឱ្យចង់ទស្សនា។ នេះជាឱកាសល្អដែលបានមកទស្សនកិច្ច ក៏ដូចជាបានរៀនសូត្របន្ថែមនៅទីនេះលើកិច្ចការអភិរក្ស និងជួសជុលមរតកវប្បធម៌ បានទទួលបទពិសោធន៍ល្អៗលើការគ្រប់គ្រងបេតិក-ភណ្ឌ និងការរៀបចំទេសភាពវប្បធម៌បន្ថែមពីលើជំនាញការងារប្រចាំថ្ងៃនៅក្នុងតំបន់ឧទ្យានអង្គរ៕









តើអ្នកទាំងអស់គ្នាដឹងទេថាចម្លាក់នៅប្រាសាទអង្គរវត្តមានទាក់ទងនឹងរឿងអ្វីខ្លះ?

ផ្សាយនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា ប៉ហ៊ីនី រូបភាព ៖ ហ៊ុំ រិទ្ធី

តើអ្នកដឹងអ្វីខ្លះពីផ្ទាំងចម្លាក់នៅតាមជញ្ជាំង ឬថែវនៃប្រាសាទអង្គរវត្ត? ភ្ញៀវទេសចរមួយចំនួនធំ ទំនងមិនបានដឹងទេ អំពីដំណើររឿងនានានៅតាមចម្លាក់ទាំងនោះ។ តាមពិតទៅវាមានរឿងជាច្រើន ដែលត្រូវបានវីរបុរសខ្មែរសម័យនោះ ធ្លាក់ទុក សម្រាប់ជាប្រវត្តិសាស្ត្រដល់កូនចៅជំនាន់ក្រោយ។

តាមអ្នកបុរាណវិទូ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ **លោកបណ្ឌិត អ៊ា ជាវិទ្ធ** ចម្លាក់នៅតាមជញ្ជាំងប្រាសាទអង្គរវត្ត សរុបទាំងអស់មានចំនួន៨ផ្ទាំង និងបែងចែកទៅតាមសាច់រឿងផ្សេងៗគ្នា។

លោកបន្ថែមថា ចម្លាក់ដែលគេធ្លាក់នៅរោងទងទី៣ ខាងលិចថែវខាងជើងនិយាយរឿងរាមកេរ្តិ៍ ថែវខាងត្បូងរឿងមហាភារត ថែវខាងត្បូវចំហៀងខាងលិច ចម្លាក់វឹកពីប្រវត្តិជំនាន់ព្រះបាទសូរ្យវរ្ម័នទី២ ថែវខាងត្បូងចំហៀងខាងកើត ចម្លាក់រឿងសួគ៌ និងនរក ថែវខាងកើតចំហៀងខាងត្បូង ចម្លាក់រឿងកូរសមុទ្រទឹកដោះ ថែវខាងកើតចំហៀងខាងជើង ចម្លាក់ទាក់ទងនឹងជ័យជំនះនៃព្រះនារាយណ៍លើអសុរ។ ចំណែកពីរជ្រុងទៀតនៅទិសឦសានធ្លាក់នៅសតវត្សទី១៦ ដោយនៅថែវខាងជើងចំហៀងខាងកើត ចម្លាក់ទាក់ទងនឹងជ័យជំនះនៃព្រះក្រិស្ណលើស្តេចអសុរឈ្មោះពាន និងថែវខាងជើងចំហៀងខាងលិច ចម្លាក់ទាក់ទងនឹងចម្បាំងរវាងទេពផ្សេងៗ៕









អង្គរសង្ក្រាន្តឆ្នាំ២០១៧បានបញ្ចប់ទៅដាមួយនឹងកំណើនអ្នកចូលរួមយ៉ាងច្រើនកុះករ

ផ្សាយនៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៧ ដែលរៀបចំឡើងនៅលើទឹកដីអង្គរ ដើម្បីអបអរសាទរពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ បានបញ្ចប់ដោយសព្វគ្រប់ហើយ ជាមួយនឹងវត្តមានអ្នកចូលរួមយ៉ាងច្រើនកុះករ រហូតដល់ទៅជាង១លាន៦សែននាក់។

នេះជាឆ្នាំទី៥នៃព្រឹត្តិការណ៍ដ៏ធំនៅលើទឹកដីបេតិកកណ្ឌអង្គរ ដែលដឹកនាំរៀបចំដោយសហភាពសហព័ន្ធយុវជនកម្ពុជា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ អាជ្ញាធរជាតិអប្សរា រដ្ឋបាលខេត្តសៀមរាប និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត។

ដូចដែលបានគ្រោងទុក ពិធីអង្គរសង្ក្រាន្តបានបញ្ចប់ទៅដោយមានព្រឹត្តិការណ៍ជាច្រើន ដែលរួមបញ្ចូលទាំងពិធីសាសនាប្រពៃណី ការម្សាន្តសប្បាយ ល្បែងប្រជាប្រពៃណី-ប្រជាប្រិយ ការបង្ហាញសមត្ថភាព និងការតាំងបង្ហាញចាប៉ីដងវែងខ្នាតយក្សជាដើម។

សូមទស្សនាកម្រងរូបភាពនៃព្រឹត្តិការណ៍នេះទាំងអស់គ្នាដូចខាងក្រោម ៖

















អ្នកជំនាញរៀបចំកាត់ក្រឹ និងព្យាបាលដើមឈើទាលដែលមានអាយុកាលជាង១០០ឆ្នាំជាប់ប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ សឿន ប៊ុនស៊ីរ

ដើមឈើទាលមួយដើមធំ ដែលមានអាយុកាលប្រហែលជាង១០០មួយឆ្នាំ ដុះជាប់នឹងបរិវេណប្រាសាទបាយ័ន ជ្រុងពាយព្យ ត្រូវបានរន្ទះបាញ់កាលពីជាង១០ឆ្នាំមុន ហើយកំពុងតែស្ថិតនៅក្នុងសភាពពុកផុយដោយអន្លើ។ អ្នកជំនាញគ្រប់គ្រងព្រៃនៃអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមដំឡើងរន្ធាដៃកដើម្បីកាត់ក្រឹមែកខាងលើបញ្ជៀសការបាក់ធ្លាក់ បង្កគ្រោះថ្នាក់ដល់ភ្ញៀវទេសចរ និងព្យាបាលដើមឈើទាលនេះ តាំងពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៧មក។

លោក យិន សូរ៉ាត អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ដែលបានដឹកនាំការងារនេះបញ្ជាក់ថា ការកាត់ក្រឹ និងព្យាបាលដើមឈើក្នុងរមណីយដ្ឋានអង្គរ គឺជាការកិច្ច ដែលក្រុមការងាររបស់លោកតែងធ្វើជាប្រចាំ។ ដោយឡែក ដើមឈើទាលមួយដើមធំនេះ ក្រុមការងាររបស់លោកបានសង្កេតឃើញថា ដើមរបស់វាបានពុក និងប្រហោងខាងក្នុងដោយកន្លែង ហើយមែកមួយចំនួនក៏ងាប់ ដែលអាចនឹងបាក់ធ្លាក់បង្កគ្រោះថ្នាក់ដល់ភ្ញៀវទេសចរ។

លោក សូរ៉ាត បន្ថែមថា ក្រៅពីកាត់មែកដើម្បីសម្រាលទម្ងន់ដើម ក្រុមការងារលោកក៏នឹងព្យាបាលដើមឈើទាលមួយដើមនេះឲ្យអស់លទ្ធភាព ដើម្បីឲ្យដុះសាច់ថ្មី ព្រោះដើមឈើទាលដ៏ធំនេះ មានអាយុកាល យូរជាទីចាប់អារម្មណ៍របស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ លោកបន្តថា ដោយសារដើមឈើទាលនេះមានកម្ពស់ដល់ទៅជាង៤០ម៉ែត្រ ក្រុមការងារត្រូវចំណាយរៀបចំរន្ធាយូរ ហើយគ្រោងនឹងចាប់ផ្តើមកាត់ក្រឹនៅចុងខែមេសានេះ។

សូមបញ្ជាក់ថា ព្រៃឈើគឺជាធាតុដ៏សំខាន់មួយនៃបេតិកភណ្ឌអង្គរ ក្នុងចំណោមធាតុសំខាន់ទាំងបីគឺ ប្រាសាទ បរិស្ថាន (ព្រៃឈើនិងទឹក) និងសហគមន៍។ ព្រៃឈើក្នុងតំបន់អង្គរអោចជួយស្រូបទឹកភ្លៀងនិងផ្តល់សំណើមដល់គ្រឹះប្រាសាទ ជួយការពារខ្យល់ព្យុះមិនឲ្យបោកបក់ខ្លាំងប៉ះពាល់ប្រាសាទ និងបង្កើតបានជាទេសភាពដ៏ស្រស់ស្អាតដល់ប្រាសាទផងដែរ។ បច្ចុប្បន្ន ព្រៃឈើក្នុងរមណីយដ្ឋានអង្គរមានប្រហែល១៥%នៃផ្ទៃដីសរុប៤០១គីឡូម៉ែត្រក្រឡានៃរមណីយដ្ឋានអង្គរ។ ក្នុងឆ្នាំ២០១៦កន្លងទៅ អាជ្ញាធរជាតិអប្សរាបានដាំកូនឈើថែមក្នុងផ្ទៃដីទំនេរបានចំនួនជាង៦ម៉ឺនដើម និងកំពុងបន្តដាំថែមទៀតលើផ្ទៃដីទំនេរនៃរមណីយដ្ឋានអង្គរទាំងមូល៕









ទីតាំងអភិរក្សបេតិកភណ្ឌដែលរៀបចំដោយអាជ្ញាធរជាតិអប្សរានៅមុខអង្គរវត្ត ទាក់ទាញភ្ញៀវទេសចរជាតិ-អន្តរជាតិជិត៥ម៉ឺននាក់ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត២០១៧

ផ្សាយនៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីវ៉ែ្ន រូបភាព ៖ សឿន ប៊ុនសារ

ព្រឹត្តិការណ៍អង្គរសង្ក្រាន្តលើកទី៥ឆ្នាំ២០១៧ បានបញ្ចប់ទៅដោយជោគជ័យនិងសប្បាយរីករាយជាទីបំផុត ដែលមហាគ្រួសារខ្មែរបានមកជួបជុំគ្នាលេងល្បែងប្រជាប្រិយ ដើរកម្សាន្តសប្បាយ និងបានស្វែងយល់ពីកិច្ចការអភិរក្ស និងការជួសជុលបេតិកភណ្ឌផងនៅរមណីយដ្ឋានអង្គរ។

ក្នុងអង្គរសង្ក្រាន្តឆ្នាំ២០១៧ អាជ្ញាធរជាតិអប្សរាក៏បានរៀបចំទីតាំងអភិរក្សបេតិកភណ្ឌនៅមុខប្រាសាទអង្គរវត្ត ដែលចែកចេញជា៣ផ្នែក៖ ផ្នែកទី១ បង្ហាញពីការអភិរក្ស ជួសជុល ថែទាំងប្រាសាទក្នុងរមណីយអង្គរដោយអាជ្ញាធរជាតិអប្សរា និងប្រាសាទនៅរមណីយដ្ឋានព្រះវិហារ ដោយអាជ្ញាធរជាតិព្រះវិហារតាមរយៈរូបថត និងការកសាងប្រាសាទដោយបុព្វបុរសខ្មែរតាមរយៈរូបចម្លងតូចៗ។ ផ្នែកទី២ បង្ហាញពីប្រាសាទចម្លងរបស់ហោត្រៃខាងជើងប្រាសាទព្រះខ័នពីស្ថានភាពខូចខាត ស្ថានភាពហោត្រៃមុននិងក្រោយជួសជុល ការកាត់ថ្ម ការព្យាបាលថ្មនិងបច្ចេកទេសរៀបថ្ម ការចល័តថ្មនិងដាប់

ព្រងចុច្ចី រោងជាងជួសជុលសម្ភារៈចម្លាក់ថ្ម និងកិច្ចការកំណាយបុរាណវិទ្យា។ល។ ផ្នែកទី៣ បង្ហាញពីទីតាំងកម្សាន្ត មានរាំងស្គរដៃ លេងល្បែងប្រជាប្រិយខ្មែរ ទាញព្រ័ត្រ វាយក្តមជាដើម។

ទីតាំងនេះបានទាក់ទាញនូវចំនួនភ្ញៀវទេសចរជាតិ-អន្តរជាតិយ៉ាងច្រើនគួរឱ្យកត់សម្គាល់។ តាមការបញ្ជាក់ពី **លោក ទិន ទីណា** អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិ ស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ បានប្រាប់ថា តួលេខភ្ញៀវចូលទស្សនាយៈពេល៣ថ្ងៃនៅទីតាំងអភិរក្សបេតិកភណ្ឌ បានប្រមាណជា៤៩៦០៥នាក់ ដែលនេះជាជោគជ័យច្រើនជាងឆ្នាំណាៗទាំងអស់។

លោក ទិន ទីណា បញ្ជាក់ថា គោលបំណងនៃការរៀបចំទីតាំងអភិរក្សបេតិកភណ្ឌ គឺដើម្បីបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈអាជ្ញាធរជាតិអប្សរា សមិទ្ធផលនានាផ្នែកអភិរក្ស ជួសជុលបេតិកភណ្ឌដោយអាជ្ញាធរអប្សរានិងអាជ្ញាធរជាតិព្រះវិហារ ការយកចិត្តទុកដាក់ និងកិច្ចសហការពីស្ថាប័នអន្តរជាតិជាមួយអាជ្ញាធរជាតិអប្សរាលើកិច្ចការអភិរក្ស ជួសជុលមរតកវប្បធម៌ជាតិជាង២០ឆ្នាំ។ ក្នុងនោះក៏បង្ហាញពីការលើកតម្លៃបេតិកភណ្ឌ ព្រមទាំងផ្តល់ឱកាសឱ្យភ្ញៀវជាតិ-អន្តរជាតិដែលចូលមកទស្សនាអង្គរសង្ក្រាន្ត២០១៧ បានយល់ដឹងអំពីបច្ចេកទេសក្នុងការអភិរក្ស ជួសជុលប្រាសាទផងដែរ និងជំរុញឱ្យប្រជាជនគ្រប់តំបន់ចូលរួមចំណែកថែរក្សាបេតិកភណ្ឌរបស់ខ្លួនឱ្យបានល្អប្រសើរទាំងអស់គ្នា៕









ត្រីមាសទី១ដើមឆ្នាំ២០១៧ អាជ្ញាធរជាតិអប្សរាបានរកឃើញនិងប្រគល់សម្ភារៈជូនភ្ញៀវទេសចរវិញចំនួន៦៦ករណី

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ

យោងតាមរបាយការណ៍សកម្មភាព និងលទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ស្តីពីកិច្ចការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍បានបង្ហាញពីការយកចិត្តទុកដាក់របស់អាជ្ញាធរជាតិអប្សរា ក្នុងការលើកកម្ពស់គុណភាពសេវាកម្ម និងទំនុកចិត្តរបស់ភ្ញៀវទេសចរក្នុងពេលទស្សនាមណ្ឌលអង្គរ។ ក្នុងបរិបទនេះ មន្ត្រីជំនាញផ្នែកអភិវឌ្ឍន៍ទេសចរណ៍បានសម្រេចនូវសមិទ្ធផលសំខាន់ៗមួយចំនួនប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ដែលមានភាពលេចធ្លោគួរឲ្យកត់សម្គាល់។ ស្ថិតក្នុងចំណុចលេចធ្លោ គឺការខិតខំស្វែងរកឃើញនិងប្រគល់ជូនភ្ញៀវទេសចរ វិញនូវសម្ភារៈដែលភ្ញៀវទេសចរបានជ្រុះក្នុងពេលកំពុងទស្សនាប្រាង្គប្រាសាទ និងរមណីយដ្ឋានអង្គរ។

ទាក់ទងនឹងសកម្មភាពការងារនេះ យោងរបាយការណ៍សង្ខេបរបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ អាជ្ញាធរជាតិអប្សរា ក្នុងការងារសហការជាមួយនគរបាលទេសចរណ៍ និងនគរបាលការពារបេតិកភណ្ឌ បានជួយស្វែងរករបស់ដែលភ្ញៀវបានភ្លេច ឬជ្រុះ បានចំនួន៨១ករណី និងរកឃើញវិញបានចំនួន ៦៦ករណី។ រីឯការជួយសង្គ្រោះបឋមដល់ភ្ញៀវទេសចរ ដែលមានគ្រោះថ្នាក់អំឡុងពេលទស្សនាក្នុងតំបន់ប្រាសាទវិញ មានសរុបចំនួន ១០៣ករណីផងដែរ។

ក្នុងរបាយការណ៍ដដែលនោះក៏បានបង្ហាញអំពីតួលេខនៃការអប់រំ និងការណែនាំដល់ភ្ញៀវទេសចរអំពីឥរិយាបថអំឡុងពេលទស្សនាប្រាង្គប្រាសាទបុរាណផង។ ក្នុងនោះ ការហាមឃាត់ និងអប់រំណែនាំដល់ភ្ញៀវទេសចរដែលមានឥរិយាបថមិនសមរម្យ ក្នុងពេលទស្សនាប្រាសាទក្នុងរមណីយដ្ឋានអង្គរមានចំនួន ៧៦ករណី។ ក្នុងនោះទៀតសោត ចំណាត់ការរួមមានធ្វើការណែនាំឲ្យធ្វើលិខិតសុំទោស កិច្ចសន្យា លុបរូបភាព និងឲ្យមកសុំច្បាប់ពីអាជ្ញាធរជាតិអប្សរា និងឲ្យពួកគេបានយល់នូវខ្លឹមសារ ព្រមទាំងគោរពតាមក្រមប្រតិបត្តិអង្គរ។

សម្រាប់សកម្មភាពថតរូបវិញ ការចុះត្រួតពិនិត្យបានរកឃើញថា ករណីមានលិខិតអនុញ្ញាតចំនួន៤២ក្រុម (៤៥១នាក់) និងគ្មានលិខិតអនុញ្ញាតចំនួន ១០៧ក្រុម (១០៧០នាក់)។ ក្នុងនោះដែរ ក្រុមការងារបានចុះណែនាំដល់ ភ្ញៀវទេសចរ ដែលប្រព្រឹត្តិផ្ទុយពីក្រមប្រតិបត្តិអង្គរនៅតាមប្រាសាទមានចំនួន ២៤នាក់៕









អាជ្ញាធរជាតិអប្សរានឹងរៀបចំបទបង្ហាញស្តីពី ការស្វែងយល់ការរស់នៅរបស់ប្រជាជនសម័យបុរេប្រវត្តិតាមរយៈការសិក្សាកុលាលភាជន៍

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ ខាងមុខនេះ អាជ្ញាធរជាតិអប្សរានឹងរៀបចំធ្វើបង្ហាញមួយ ក្រោមប្រធានបទ "ការស្វែងយល់ការរស់នៅរបស់ប្រជាជនសម័យបុរេប្រវត្តិតាមរយៈការសិក្សាកុលាលភាជន៍" នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា។

វាគ្មិននៃបទបង្ហាញនេះគឺ **លោក TSE SIANG LIM** និស្សិតថ្នាក់បណ្ឌិតនៃសាកលវិទ្យាល័យ Australian National University។ បទបង្ហាញនឹងចាប់ផ្តើមពីម៉ោង២រសៀលតទៅ។

បទបង្ហាញនេះ ធ្វើឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍ ស្រាវជ្រាវ និងបន្ថែមចំណេះដឹងថ្មីដែលអ្នកស្រាវជ្រាវជាតិ និង អន្តរជាតិបានសិក្សា។ អាជ្ញាធរជាតិអប្សរា សូមគោរពអញ្ជើញ សិស្ស និស្សិត មគ្គុទ្ទេសក៍ទេសចរណ៍ អ្នកសារព័ត៌មាន និង សាធារណជនដែលមានបំណងស្វែងយល់ ចូលរួមស្តាប់ ដើម្បីជាការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ ក៏ដូចជាការទទួលយកនូវចំណេះដឹងថ្មីៗបន្ថែមទៀត៕

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
N° ១៤៤ ឆប.សដណ
១៧

សេចក្តីជូនដំណឹង

អាជ្ញាធរអប្សរា មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីបុគ្គលិក នៃអាជ្ញាធរអប្សរា និងសាធារណៈជន ដែលមានចំណាប់អារម្មណ៍ក្នុងការសិក្សាស្វែងយល់ចូលរួមស្តាប់បទបង្ហាញស្តីពី៖

- **ប្រធានបទ**៖ "**ការស្វែងយល់ការរស់នៅរបស់ប្រជាជននៅបុរេប្រវត្តិតាមរយៈការសិក្សាកុលាលតាជន៍**"
- **បង្ហាញដោយ** ៖ លោក **TSE SIANG LIM** និស្សិតថ្នាក់បណ្ឌិត
  នៃសាកលវិទ្យាល័យ Australian National University
- **កាលបរិច្ឆេទ** ៖ **ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧** ជលាម៉ោង៖**១៤:០០ រសៀល**
- **ទីកន្លែង** ៖ សាលសិក្សា "លលៃ" នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីបុគ្គលិក និងសាធារណៈជន ទាំងអស់ អញ្ជើញចូលរួមស្តាប់ឲ្យបានច្រើនកុះការ។

សៀមរាប ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧

បញ្ជាក់៖ ដោយសារកន្លែងមានកំណត់ និងដើម្បីងាយស្រួលរៀបចំ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី បញ្ជូនឈ្មោះ ឬ ចុះឈ្មោះផ្ទាល់ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ឬ តាមរយៈទូរស័ព្ទលេខ 063 765 715 / 017 658 808 ឲ្យបានមុន **ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧** ។

PHNOM PENH :
#41, Russian Blvd,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 776
Fax : (855-23) 215 771

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
E-mail : info@apsaraauthority.gov.kh

SIEM REAP :
Bang Korng Village, Ampil Commune, Siem Reap City, Siem Reap Province
Tel: (855-63) 76 55 77 or (855-63) 76 66 76
Fax: (855-63) 76 55 76

ចម្លាក់ចាយ័ន ៖ ពិធីយញ្ញក្របីនៅលើចម្លាក់នៃប្រាសាទចាយ័ន

ផ្សាយនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

ចម្លាក់រឿងនេះបង្ហាញនៅលើជញ្ជាំងថែវខាងក្រៅ នាទិសខាងកើត ជ្រុងអាគ្នេយ៍។ ជាទិដ្ឋភាពធំបីផ្ទាំងតជាប់គ្នាពីលើមកក្រោមរៀបរាប់អំពីពិធីទាក់ទងនឹងក្របី។ ចម្លាក់នៅថ្នាក់ខាងលើបង្ហស់បាត់ពាក់កណ្តាល ដែលយើងមើលយល់ថាមានបង្ហាញអំពីការនាំក្របីទៅថ្វាយព្រះរាជាទតនិងកិច្ចពិធីផ្សេងៗ។ ចម្លាក់នៅថ្នាក់កណ្តាលមានបង្ហាញអំពីក្របី ដែលយកមកចងនឹងបង្គោលឈើ នៅក្បែរនោះមានព្រាហ្មណ៍ពីរនាក់អង្គុយលើដំរីកំពុងសូត្រយញ្ញបូជា។ កងទ័ពរេហ៍ពលទាំងគ្រប់ហានានុក្រមរំកិលដំណើរចូលកាន់ក្របី រួចចាក់ក្របីនឹងអាវុធរបស់ខ្លួនជាបន្តបន្ទាប់ ទើបបន្តដំណើរឆ្ពោះទៅទីវាលចម្បាំង។

អ្នកស្រាវជ្រាវ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរា **លោក អ៊ឹម សុខរិទ្ធី** បានពន្យល់ថា ចម្លាក់នេះជាការបង្ហាញឲ្យឃើញអំពីកិច្ចពិធីលើកទឹកចិត្តទ័ពមុននឹងចេញច្បាំងនៅសម័យបុរាណ ដើម្បីធ្វើឲ្យកងទ័ពមានសេចក្តីក្លាហានអង់អាចក្នុងចម្បាំង តាមរយៈកិច្ចពិធីពិសេស ដែលទាក់ទងនឹងការបូជាឈាមស្រស់ ដើម្បីឲ្យអំពាវនាវសុំឲ្យកម្លាំងទេពមកសណ្ឋិតនៅហ្នឹងអ្នកចម្បាំង។

អ្នកស្រាវជ្រាវរូបនេះបញ្ជាក់ថា ចម្លាក់នេះ អ្នកខ្លះយល់ច្រឡំថា ជាចម្លាក់បង្ហាញអំពីសម្លាប់សត្វក្របីដើម្បីប្រារព្ធពិធីជ័យជំនះ។ តាមពិតជាកិច្ចបូជាដ៏ធំរបស់ជនជាតិភាគតិចនៅក្នុងអាស៊ីអាគ្នេយ៍។ ខ្មែរបានយកទំនៀមជនជាតិមកផ្សំនឹងទំនៀមព្រាហ្មណ៍ ដើម្បីសុំឲ្យទេពស្ថិតនៅជាកម្លាំងក្នុងរេហ៍ពលរបស់ខ្លួន។

សូមទស្សនាកម្រងរូបភាពនៃចម្លាក់នេះដូចតទៅ ៖









អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច

ផ្សាយនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាច** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា និងតំណាងស្ថានទូតបារាំង ក្នុងនាមសហប្រធានគណៈកម្មការដឹកនាំ និងតាមដានគម្រោងជួសជុលប្រាសាទមេបុណ្យខាងលិច បានដឹកនាំក្រុមការងារចម្រុះនៃអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញសាលាបារាំងចុងបូព៌ាចុះទៅពិនិត្យការងារជួសជុលប្រាសាទមេបុណ្យខាងលិច។

ប្រាសាទមេបុណ្យខាងលិចត្រូវបានអភិរក្សជួសជុល និងស្តារឡើងវិញដោយគម្រោងសហការរវាងអាជ្ញាធរជាតិអប្សរា និងរដ្ឋាភិបាលបារាំង តាមរយៈសាលាបារាំងចុងបូព៌ា ចាប់ផ្តើមពីឆ្នាំ២០១២មក ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០១៩។ សហប្រធាននៃគណៈកម្មការដឹកនាំ និងតាមដានគម្រោងជួសជុលនេះ តែងជួបជុំគ្នាពីរដងក្នុងមួយឆ្នាំ ដើម្បីតាមដានវឌ្ឍនភាពនៃការងារ និងរួមគ្នាដោះស្រាយនូវឧបសគ្គផ្សេងៗ ដែលក្រុមការងារបច្ចេកទេសជួបប្រទះក្នុងដំណើរការរបស់ខ្លួន។

ឯកឧត្តម ហង់ ពៅ អគ្គនាយករង និងជាសហប្រធាននៃគម្រោងជួសជុលនេះបញ្ជាក់ថា ជំនួបពិភាក្សារវាងសហប្រធានគណៈកម្មការព្រឹកនេះ ផ្តោតសំខាន់លើការវិវត្តនៃការជួសជុល និងរួមគ្នាដោះស្រាយការលំបាកផ្សេងៗ ដូចជាការដឹកជញ្ជូនថ្មទៅកាន់ការដ្ឋានជាដើម។ ជាការកត់សម្គាល់ សហប្រធានគណៈកម្មការមានការពេញចិត្តនឹងដំណើរការជួសជុល ដែលប្រព្រឹត្តទៅដោយរលូនតាមការគ្រោងទុក។

ប្រាសាទមេបុណ្យខាងលិចជាប្រាសាទបុរាណខ្មែរ មានទីតាំងស្ថិតនៅលើដីទួលមួយកន្លែងចំកណ្តាលបារាយណ៍ខាងលិច។ ប្រាសាទនេះត្រូវបានស្ថាបនាឡើងនៅអំឡុងពាក់កណ្តាលសតវត្សរ៍ទី១១នៃគ្រិស្តសករាជ ក្នុងរាជ្យព្រះបាទឧទយាទិត្យវរ្ម័នទី២ ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា។ ប្រាសាទនេះមានលក្ខណៈប្លែកពិសេស ដោយហេតុថា សំណង់ប្រាសាទផ្សំឡើងដោយកំពែងមួយជាន់ធ្វើអំពីឥដ្ឋក់ ហ៊ុមព័ទ្ធស្រះទឹកធំមួយដែលគេជីកនៅលើដីទួលនោះ។ តាមរយៈការធ្វើកំណាយនៅឆ្នាំ១៩៣៩ គេបានរកឃើញរូបបដិមាជាព្រះវិស្ណុ ក្នុងឥរិយាបថផ្ទំមួយអង្គ ដែលសព្វថ្ងៃតម្កល់ទុកនៅសារមន្ទីរជាតិភ្នំពេញ៕









ប្រធានអាជ្ញាធរជាតិអប្សរាជួបប្រជុំជាមួយមន្ត្រីរាជការថ្នាក់ដឹកនាំនៃអាជ្ញាធរអប្សរា ដើម្បីយល់ច្បាស់អំពីដំណើរការស្ថាប័ននិងការគ្រប់គ្រងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប: និងជាប្រធានថ្មីនៃអាជ្ញាធរជាតិអប្សរា **លោកជំទាវ គ្រឿង សកុណា** នារសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧នេះ បានជួបប្រជុំជាមួយមន្ត្រីរាជការ ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា ដើម្បីស្វែងយល់បន្ថែមនូវការងារអនុវត្តជាក់ស្តែងនៃស្ថាប័ន និងការគ្រប់គ្រងនៅរមណីយដ្ឋានអង្គរ។

ជំនួបប្រជុំនេះ ត្រូវបានរៀបចំឡើងនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា និងក៏ជាលើកទី២ផងដែរ បន្ទាប់ពីអាជ្ញាធរជាតិអប្សរា ត្រូវបានរាជរដ្ឋាភិបាលផ្ទេរការគ្រប់គ្រងពីទីស្តីការគណៈរដ្ឋមន្ត្រី ឲ្យស្ថិតនៅក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្ប:។

តាមគម្រោងកិច្ចប្រជុំនេះនឹងដំណើរការរយៈពេល២ថ្ងៃ គឺរសៀលថ្ងៃទី២៥ និងព្រឹកថ្ងៃទី២៦ ខែមសា ដែលគ្រប់នាយកដ្ឋាន និងអង្គភាពចំណុះរបស់អាជ្ញាធរជាតិអប្សរាទាំងអស់នឹងលើកឡើងនូវសកម្មភាពការងាររបស់ខ្លួន និងសំណូមពររាល់បញ្ហាលំបាកផ្សេងៗ ដើម្បីដាក់ជូនប្រធានអាជ្ញាធរជាតិអប្សរាដោះស្រាយ។









លោកតា សុត ជុយ អ្នកស្រុកអង្គរស្រឡាញ់ការងារជួសជុលប្រាសាទ និងចង់ឲ្យកូនចៅបន្តការងារនេះ

ផ្សាយនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ ហ៊ុំ រិទ្ធី

ទោះនឿយហត់ដោយសារកម្តៅថ្ងៃយ៉ាងណាក្តី ក៏មិនអាចរារាំងទឹកចិត្តរបស់ **លោកតា សុត ជុយ** លើការងារជួសជុល និងអភិរក្សប្រាសាទបានឡើយ។ លោកតា គឺជាកម្មករជួសជុលនៅប្រាសាទមេបុណ្យខាងលិច ដែលនៅចំកណ្តាលបារាយណ៍ទឹកថ្លា។

មានសម្បុរស្រអែម សក់លាយសច្រើនសរសៃ **លោកតា សុត ជុយ** បច្ចុប្បន្នគឺជាកម្មករជួសជុលនៅប្រាសាទមេបុណ្យខាងលិច។ រយៈពេល៥ឆ្នាំមកហើយ ដែលលោកតាបានមកបំពេញការងារនៅប្រាសាទមេបុណ្យខាងលិច ក្រោយគម្រោងជួសជុលប្រាសាទបាពួនត្រូវបានបញ្ចប់។

មានវ័យ៦១ឆ្នាំទៅហើយ តែ**លោកតា សុត ជុយ** នៅតែមានកម្លាំងដាប់ឋ និងដោយភាពរហ័ស។ កំពុងដាប់ឋបណ្តើរ លោកតាបានរម្លឹកថា លោកធ្លាប់ធ្វើការក្នុងគម្រោងជួសជុលប្រាសាទបាពួនរយៈពេល១០ឆ្នាំ មុននឹងមកបំពេញការងារដូចគ្នានៅប្រាសាទមេបុណ្យខាងលិច។ លោកបន្ថែមថា ក្នុងរយៈពេលជាច្រើនឆ្នាំក្នុងការងារជាកម្មករជួសជុលប្រាសាទនេះ លោកបានចេះជំនាញមួយចំនួន ដូចជា ដាប់ឋ ជាត់ដី និងរៀបសាបជាដើម។

មានកូន៨នាក់ក្នុងបន្ទុក **លោកតា សុត ជុយ** ជាអ្នកស្រុកនៅភូមិគោកចក សង្កាត់គោកចក ក្រុងសៀមរាប។ លោកបានឲ្យដឹងទៀតថា លោកស្រឡាញ់ការងារដែលលោកកំពុងធ្វើសព្វថ្ងៃនេះណាស់។ លោកបន្តថា ទៅថ្ងៃខាងមុខក្រោយពេលលោកសម្រាកទៅ លោកចង់ឲ្យកូនចៅបន្តធ្វើការងារនេះពីលោក ព្រោះការងារជួសជុលប្រាសាទធ្វើឲ្យលោកមានអារម្មណ៍ថា ហាក់កំពុងជួយខ្មែរសាងសង់ប្រាសាទឡើងយ៉ាងដូច្នេះដែរ៕









អ្នកស្រាវជ្រាវយល់ថា បំណែកកុលាលភាជន៍ ផ្តល់នូវទិន្នន័យច្រើនអំពីសង្គមមនុស្សបុរាណ

ផ្សាយនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រីទ្ធី

តាំងពីយូរមកហើយ ការស្រាវជ្រាវស្តីពីអារ្យធម៌អង្គរ ភាគច្រើនផ្តោតតែទៅលើការសិក្សាពីសិលាចារឹក ប្រាង្គប្រាសាទ និងសិល្បៈតែប៉ុណ្ណោះ។ ចំណែកឯការសិក្សាស្រាវជ្រាវស្តីពីកុលាលភាជន៍ គេពុំសូវយកចិត្តទុកដាក់ទេ។ ទើបតែថ្មីៗនេះ ការសិក្សាស្រាវជ្រាវអំពីកុលាលភាជន៍ ត្រូវបានទទួលបានការចាប់អារម្មណ៍ច្រើន បន្ទាប់ពីក្រុមអ្នកស្រាវជ្រាវបានរកឃើញទីតាំងនៃឡបុរាណខ្មែរមួយចំនួន។

បេក្ខជនបណ្ឌិតនៃសាកលវិទ្យាល័យ Australian National University **លោក TSE SIANG LIM** ដែលបានចុះធ្វើការស្រាវជ្រាវដើម្បីបញ្ចប់ថ្នាក់បណ្ឌិតរបស់ខ្លួន ក៏បានចាប់អារម្មណ៍និងផ្តោតការស្រាវជ្រាវលើបញ្ហាកុលាលភាជន៍នេះដែរ។ កិច្ចការស្រាវជ្រាវរបស់លោកបានធ្វើឡើងតាមរយៈគម្រោងស្រាវជ្រាវមួយដែលមានឈ្មោះថា គម្រោងស្រាវជ្រាវអំពីវិសាលភាពអង្គរ (The Greater Angkor Project) ដែលជាគម្រោងសហការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យស៊ីដនីនៃប្រទេសអូស្ត្រាលី។

ក្នុងបទបង្ហាញនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាធរជាតិអប្សរា នារសៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧នេះ **លោក TSE SIANG LIM** បញ្ជាក់ថា ទិន្នន័យដែលលោកទទួលបានពីការសិក្សាកុលាលភាជន៍ ដែលបានពីកំណាយនៅស្ថានីយព្រៃក្មេង និងភូមិល្វា នៅក្នុងស្រុកពួកខេត្តសៀមរាប និងភូមិសូគីដែលស្ថិតនៅក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យជាដើម អាចជួយឲ្យលោកយល់ដឹងអំពីការប្រែប្រួលនៃសង្គមមនុស្សក្នុងសម័យបុរេប្រវត្តិបានច្រើន។

ជាក់ស្តែង លទ្ធផលកំណាយលើផ្នូរដែលស្ថិតនៅក្នុងយុគសម័យលង្ហិន (Bronze Age: 1000-500BC) បង្ហាញថាមានកុលាលភាជន៍តិចតួចជាងផ្នូរក្នុងយុគសម័យដែក (Iron Age: 500BC-1000AD)។ នេះបញ្ជាក់ថា សង្គមមនុស្សក្នុងយុគសម័យដែកមានការរីកចម្រើនកាន់តែច្រើន។ **លោក TSE SIANG LIM** ក៏បញ្ជាក់ដែរ វត្តមានកុលាលភាជន៍ក្នុងផ្នូរថែមទាំងជួយប្រាប់យើងអំពីការបែងចែកសង្គមអ្នកធូរធារ និងអ្នកក្រីក្រផងដែរ ដូចជា ក្នុងផ្នូរខ្លះមានកុលាលភាជន៍ច្រើនប្រណីតៗ ជាងផ្នូរខ្លះទៀត ដែលស្ថិតនៅក្នុងសម័យកាលដូចគ្នា តែមានចំនួនកុលាលភាជន៍កប់ជាមួយតិចតួច និងមិនសូវល្អប្រណីត។

បទបង្ហាញនេះ ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកចូលរួម។ **លោកគ្រូ នាង សុភាព** ជាគ្រូបង្ហាត់នៅសាលាគរុកោលស្ស និងវិក្រឹត្យការខេត្តសៀមរាប ដែលបានដឹកនាំគរុសិស្សប្រមាណជាង៣០រូបមកចូលរួមស្តាប់ បាន

បង្ហាញអារម្មណ៍រីករាយ និងគាំទ្រចំពោះបទបង្ហាញនេះ។ លោកគ្រូជឿជាក់ថា គុរុសិស្សរបស់លោកនឹងបានទទួលចំណេះដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ និងបន្តផ្ទេរចំណេះដឹងដល់សិស្សានុសិស្សក្រោយៗទៀត។ ជាមួយគ្នានេះ លោកគ្រូក៏បានសំណូមពរឲ្យអាជ្ញាធរជាតិអប្សរាបន្តរៀបចំបទបង្ហាញអំពីលទ្ធផលស្រាវជ្រាវផ្សេងៗទៀត
ដើម្បីបន្ថែមចំណេះដឹងដល់មហាជនទូទៅ។

ឯកឧត្តម ឥន ប៊ុនស៊ុយ អគ្គនាយករងទទួលបន្ទុកមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ មានប្រសាសន៍ថា រាល់អ្នកស្រាវជ្រាវក្នុងរមណីយដ្ឋានអង្គរតែងតែត្រូវឲ្យមានការផ្តល់ជូនរបាយការណ៍ ស្តីពីលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន និងធ្វើបទបង្ហាញជាសាធារណៈចំពោះប្រធានបទណាដែលយល់ថា មានអត្ថប្រយោជន៍ច្រើនដល់អ្នកស្រាវជ្រាវ និងសាធារណជនជាប្រជាពលរដ្ឋខ្មែរ។ នេះជាកិច្ចសហការមួយដែលបានផ្តល់ប្រយោជន៍ដល់អ្នកស្រាវជ្រាវផងដល់ប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់ទឹកដីផង៕









ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានចុះអនុញ្ញាតជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១២១ករណីក្នុងត្រីមាសទី១ ឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ក្រុមការងារសហគមន៍

ក្រៅពីការងារអភិរក្ស រៀបចំ គ្រប់គ្រង និងអភិវឌ្ឍន៍តំបន់អង្គរប្រកបដោយចីរភាព អាជ្ញាធរជាតិអប្សរាតាមរយៈក្រុមការងារសហគមន៍ បានចុះសួរសុខទុក្ខ អប់រំ ស្តាប់សំណូមពរ ផលលំបាក និងជួយដោះស្រាយបញ្ហាជូនបងប្អូនប្រជាជនដោយផ្ទាល់ដល់មូលដ្ឋាន។

យោងតាមរបាយការណ៍រយៈពេល៣ខែនៃឆ្នាំ២០១៧នេះ អាជ្ញាធរជាតិអប្សរាបានចុះទៅផ្សព្វផ្សាយ និងសួរសុខទុក្ខប្រជាជនក្នុងតំបន់អង្គរបានចំនួន១០ភូមិដែលមានប្រជាជនចូលរួម៥៩៤នាក់។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យនិងអនុញ្ញាត សំណើសុំសាង សង់សំណង់តូចតាច និងជួសជុលផ្ទះជូនប្រជាពលរដ្ឋដល់មូលដ្ឋានផ្ទាល់បានចំនួន ១២១ ករណី ដូចជា ជួសជុលផ្ទះ ជួសជុលដំបូលផ្ទះ ជួសជុលជញ្ជាំងផ្ទះ ប្តូរសសរផ្ទះ កឥដ្ឋក្រោមផ្ទះ សាងសង់ បង្គន់ ចាក់ជី និងសាងសង់តូបលក់ដូរ ដោយមិនបាច់ធ្វើលិខិតស្នាមសុំបែបបទសាងសង់ ឬជួសជុលមកទីស្នាក់ការអាជ្ញាធរជាតិ អប្សរា។

ក្រៅពីនោះ ការងារស្នូលរបស់ក្រុមការងារសហគមន៍ ចុះផ្សព្វផ្សាយអំពីភារកិច្ចរបស់ អាជ្ញាធរជាតិអប្សរា និងអប់រំ បេតិក-ភណ្ឌដល់ប្រជាជនក្នុងតំបន់អង្គរបានយល់ច្បាស់ពីតម្លៃនៃ មរតកវប្បធម៌ ដូនតារបស់ខ្លួនមានតាំងពីប្រាង្គប្រាសាទទំនៀមទម្លាប់ការរស់នៅ ការគោរពបូជា នូវជំនឿ ផ្សេងៗដែលធ្វើជាប្រចាំថ្ងៃតពីដូនតាមក។

ជាមួយគ្នានោះអាជ្ញាធរជាតិអប្សរាបានចុះសួរសុខទុក្ខ និងពាំនាំនូវកញ្ចប់សុខុមាលភាពម្តាយ និងទារកទៅឧបត្ថម្ភជូនស្ត្រីទើបសម្រាលកូនរួចក្នុងឧទ្យានអង្គរបានចំនួន៣៩៩។ បន្ថែមលើការ ងារសង្គមអាជ្ញាធរជាតិអប្សរាក៏បាននាំយកនូវថវិកាចំនួន ១ លានរៀលទៅជូនអាជ្ញាធរមូលដ្ឋាន ភូមិថ្នល់ត្រង់ ឃុំរលួស ដើម្បីជួសជុលសាលាឆទានឡើងវិញ និងថវិកាចំនួន ២ លានរៀល ទៀតទៅឧបត្ថម្ភមេឃុំស្វាយចេក ដែលរងគ្រោះដោយភ្លើងឆេះផ្ទះ នៅភូមិគោកថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ព្រមទាំងថវិកាចំនួន១,២៩០,០០០រៀល ដើម្បីចូលរួមក្នុងពិធីបុណ្យឆ្លងកុដិថ្មី នៅវត្តរុន ឃុំរុនតាឯក ស្រុកបន្ទាយស្រី។ ក្នុងនោះដែរ អាជ្ញាធរជាតិអប្សរាក៏បាននាំយកអំណោយជាស័ង្កសី ចំនួន២០សន្លឹកទៅឧបត្ថម្ភដែលមានជីវភាពខ្វះខាតនៅភូមតាត្រែ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ដើម្បីប្រក់ដំបូងផ្ទះ។

ស្តែងចេញពីសកម្មភាពទាំងនេះ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាតែងតែចុះទៅ តាមគោលដៅរបស់ខ្លួនដល់ខ្នងផ្ទះប្រជាពលរដ្ឋជារៀងរាល់ ដើម្បីដោះស្រាយបញ្ហាមួយចំនួនជូន ដល់ពួកគាត់។ អាជ្ញាធរជាតិអប្សរា តែងតែនៅក្បែរ និងយកចិត្តទុកដាក់គ្រប់បញ្ហាចំពោះប្រជាពលរដ្ឋទាំងសុខទុក្ខ ទាំងជីវភាពរស់នៅ សុខភាព ការសាងសង់ និងការអប់រំ ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋក្នុងតំបន់អង្គរមានសេដ្ឋកិច្ចល្អប្រសើរចំណេះដឹងទូលំទូលាយ និងមានភាពសុខសាន្តក្នុងសង្គមគ្រួសារ៕









ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តនឹងដាក់ឲ្យដំណើរការនៅដើមខែឧសភាខាងមុខនេះ

ផ្សាយនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តបណ្តោះអាសន្ន ដែលត្រូវបានសាងសង់ឡើង ដើម្បីជូនភ្ញៀវជាតិ និងអន្តរជាតិប្រើប្រាស់ជំនួសឲ្យស្ពានហាល ដែលកំពុងដំណើរការជួសជុលនោះ បានរួចរាល់ស្ទើរ១០០% ហើយគ្រោងនឹងដាក់ឲ្យដំណើរការនៅដើមខែឧសភា ឆ្នាំ២០១៧ខាងមុខនេះ។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរាបានបញ្ជាក់ថា ដំណើរការសាងសង់ស្ពានអណ្តែតទឹកបានរួចរាល់ស្ទើរទាំងស្រុងហើយនៅសល់តែការសម្អាត និងការត្រួតពិនិត្យបន្តែមប៉ុណ្ណោះ។ ស្ពានអណ្តែតទឹកនេះមានសមត្ថភាពគ្រប់គ្រាន់ជានាសុវត្ថិភាពដល់ភ្ញៀវទេសចរ ព្រោះវាអាចទ្រទ្រង់ទម្ងន់ដល់ទៅជាង៤០០តោនក្នុងពេលតែមួយបាន។ លើសពីនេះ នៅពេលស្ពាននេះដំណើរការ នឹងមានពោងសុវត្ថិភាព ដោយមានភ្នាក់ងារទេសចរណ៍នៅយាមសងខាងស្ពានជាប្រចាំផងដែរ។

ឯកឧត្តមបញ្ជាក់ថា ការសាងសង់ស្ពានអណ្តែតទឹកជំនួសស្ពានហាលមុខប្រាសាទអង្គរវត្តនេះ គឺដើម្បីសម្រួលដល់ដំណើរការជួសជុល និងបញ្ចៀសគ្រោះថ្នាក់ជាយថាហេតុ ក្នុងពេលដែលស្ពានហាលនេះកំពុងជួសជុលដោយកិច្ចសហការនៃអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ានៃប្រទេសជប៉ុន។ តាមគម្រោងស្ពានហាលនេះនឹងត្រូវបិទបណ្តោះអាសន្នរហូតដល់ការជួសជុលរួចរាល់ក្នុងឆ្នាំ២០២០ ទើបបើកឲ្យសាធារណជនធ្វើដំណើរឆ្លងកាត់ឡើងវិញ។

សូមបញ្ជាក់ថា គិតចាប់ពីទសវត្សឆ្នាំ១៩៥០មក ស្ពានហាលមុខប្រាសាទអង្គរវត្តត្រូវបានជួសជុលឡើងវិញ៣ដំណាក់កាលហើយ។ ដំណាក់កាលទី១ គឺនៅឆ្នាំ១៩៥៣ ជួសជុលដោយប្រទេសបារាំងតាមរយៈសាលាបារាំងចុងបូព៌ា EFEO នៅចំហៀងខាងជើងផ្នែកខាងកើត និងខាងជើងទសវត្សទី៦០ នៅពាក់កណ្តាលផ្នែកខាងត្បូងទាំងស្រុង។ ដំណាក់កាលទី២ ពីឆ្នាំ១៩៩៦-២០០៧ ជួសជុលដោយសាកលវិទ្យាល័យសូហ្វីយ៉ានៃប្រទេសជប៉ុន រួមនឹងអាជ្ញាធរជាតិអប្សរាផ្នែកខាងជើងក្នុងជំហានទី១។

ដំណាក់កាលទី៣ គឺអាជ្ញាធរជាតិអប្សរាសហការនឹងសាកលវិទ្យាល័យសូហ្វីយ៉ា បន្តជំហានទី២ ជួសជុលផ្នែកខាងជើង ចំហៀងខាងលិច មានប្រវែង៩០ម៉ែត្រ ដែលបានបើកឲ្យដំណើរការជាផ្លូវការតាំងពីខែឧសភា ឆ្នាំ២០១៦មក ហើយគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២០ខាងមុខ។









ផ្នែកទី ៥
ប្រចាំខែឧសភា

អរគុណរបស់យុវវ័យក្នុងពិធីទំនៀមទម្លាប់ដូនតា ប្រឈមនឹងការបាត់បង់ទំនៀមទម្លាប់ទាំងនេះទៅថ្ងៃអនាគត!

ផ្សាយនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីវ័ត្ន រូបភាព ៖ ហ៊ីង ស្រីវ័ត្ន

មិនខុសពីឆ្នាំមុន ឱ្យតែដល់ថ្ងៃ៣កើត ខែពិសាខ អ្នកភូមិចំណុះជើងវត្តអធ្យាតែងតែនាំគ្នាប្រារព្ធពិធីឡើងអ្នកតាមទំនៀមពីបុរាណមិនដែលខកខាន។ ពួកគាត់បានសាមគ្គីគ្នាក្នុងការរៀបចំ ដោយអ្នកខ្លះចេញលុយចេញកាក់ ខ្លះយកម្ហូបអាហារបង្អែមចម្ការប គ្រឿងសំណែនម្នាក់បន្តិចៗមកជួបជុំគ្នាធ្វើពិធីនៅប្រាសាទអធ្យា ដើម្បីបន្តមរតកវប្បធម៌នេះឱ្យនៅរស់រាន។

ពិធីនេះត្រូវបានធ្វើឡើងក្នុងបំណងឱ្យអ្នកតា ម្ចាស់ទឹកម្ចាស់ដីរាំលេងសប្បាយតាមរយៈអ្នកស្នងរូប ដើម្បីសុំសេចក្តីសុខចម្រើនដល់ស្រុកភូមិផង ប្រជាជនទូទាំងប្រទេសផង ឱ្យចៀសផុតពីរោគាព្យាធិ គ្រោះកាចឧបទ្រពចង្រៃ កូនចៅសុខកាយសប្បាយចិត្ត។ ពិសេសគឺអរគុណដល់អ្នកតា ម្ចាស់ទឹកម្ចាស់ដីដែលផ្តល់ទឹកភ្លៀងបានគ្រប់គ្រាន់ ដីមានជីជាតិ កុំឱ្យរាំងស្ងួតហួតហែង ធ្វើឱ្យកសិកម្មរបស់គាត់បានទទួលផលល្អ។

ដោយឡែកចំពោះការចូលរួមវិញ ហាក់មិនសូវឃើញវត្តមានយុវវ័យនៅក្នុងពិធីឡើងអ្នកតានៅប្រាសាទអធ្យានេះប៉ុន្មានទេ ភាគច្រើនគឺស្ត្រីវ័យចំណាស់ៗដែលនៅប្រឹងត្រដរទាំងឈឺ ទាំងជាមករៀបចំ ព្រោះខ្លាចក្រែងពិធីនេះបាត់បង់ និងខុសទំនៀមពីដូនតានាំឱ្យកូនចៅក្តៅក្រហាយ ធ្វើស្រែ ធ្វើស្រូវមិនកើតជាផល។

អ្នកស្រី ធីតា អាយុ៥២ឆ្នាំ រស់នៅភូមិកក្រាញ់បានលើកឡើងថា ពិធីឡើងអ្នកតា គឺសំខាន់ណាស់សម្រាប់គាត់ឱ្យតែដល់ពេលគាត់តែងចូលរួមមិនដែលខាន សុខចិត្តចោលការលក់ដូរ តែមិនហ៊ានចោលពិធីនេះទេ។ គាត់តែងរៀបចំម្ហូបអាហារ និងក្បាលជ្រូក ដើម្បីយកមកថ្វាយលោកតារាជ្យ និងលោកតាមហាជម្ពូ លោកតាទាំងពីរនេះស័ក្តិសិទ្ធិណាស់។ អ្នកមីងបន្តទៀតថា ក្រៅពីបានរួមចំណែកក្នុងការថែរក្សាពិធីនេះ ក៏ទទួលបានភាពសប្បាយរីករាយស្រឡះចិត្តគំនិតពីពិធីនេះដែរតាមរយៈអ្នកចូលរួមរាំរែក។ អ្នកមីងក៏តែងណែនាំកូនចៅឱ្យមកចូលរួមពិធីនេះដែរ ឱ្យពួកគេចេះថែរក្សាទំនៀមទម្លាប់ពីដូនតា តែពួកគេរវល់ធ្វើការ ទើបខកខាន។ គាត់សង្ឃឹមថាបើនៅក្មេងគេមិនបានធ្វើ តែពេលចាស់ទៅគេអាចបានធ្វើទៅចុះ តែបើពួកគេនៅតែមិនចាប់អារម្មណ៍ មិនឱ្យតម្លៃ មិនធ្វើក៏មិនដឹងថាម៉េច មានតែបាត់បង់តាមពេលវេលា ដោយសារមិនបានចូលរួម ទើបមិនយល់ពីសារៈសំខាន់ និងរបៀបនៃការធ្វើពិធី។

លោកយាយ ទឹម អ្នកស្នងរូបមហារាជ៧ឆ្នាំមកហើយបានប្រាប់ថា រាល់ពេលឡើងអ្នកតា គាត់ជាតួបារមីម្នាក់ក្នុងចំណោមបារមីទាំង៤។ ពិធីនេះមានសារៈសំខាន់ណាស់សម្រាប់កូនចៅ វាជាការគោរពដឹងគុណដល់លោកតាម្ចាស់ស្រុក ដែលបានថែរក្សាភូមិករឱ្យបានសុខសាន្ត ហើយពិធីនេះមិនដែលចោលការបញ្ចូលរូបទេរាល់ៗឆ្នាំ។ ខណៈវ័យកាន់តែចាស់ទៅហើយ លោកយាយក៏បានសម្តែងការព្រួយបារម្ភខ្លាចបាត់បង់ទំនៀមទម្លាប់នេះដែរ ព្រោះក្មេងៗជំនាន់ក្រោយមិនសូវមានអ្នកណាគេចង់ធ្វើជាអ្នកចូលរូបទេ ខ្លាចខ្មាសគេ ហើយអ្នកស្នងរូបទៀតសោត ក៏ទាល់តែជាមនុស្សល្អ មាននិស្ស័យនឹងរូបដូចគ្នាទើបនៅបាន។ លោកយាយបន្ថែមថា ពេលធ្វើពិធីម្តងៗ ចង់ឱ្យក្មេងៗមកចូលរួមឱ្យបានច្រើន តែអ្នកខ្លះគេមិនសូវចាប់អារម្មណ៍ អ្នកខ្លះគេរវល់ធ្វើការ បើទោះបីពួកគេដឹងថាឱ្យតែដល់ថ្ងៃ៣កើតខែមាឃ និង៣កើតខែពិសាខ តែងតែធ្វើពិធីឡើងអ្នកតាក៏ដោយ ក៏ពួកគេមិនអាចឈប់សម្រាកមកចូលរួមដែរ។ ក្មេងៗគឺសំខាន់ណាស់ ព្រោះជាអ្នកស្នង អ្នកថែរប្បធម៌ដូន

តាទាំងនេះបន្តពីមនុស្សចាស់ តែបើពួកគេមិនចូលរួម ពួកគេមិនដឹង មិនស្គាល់ ហើយទំនៀមទម្លាប់នេះ ក៏នឹងបាត់បង់នៅថ្ងៃណាមួយមិនខាន។






មន្ត្រីដំនាញនៃអាជ្ញាធរជាតិអប្សរាបានកំពុងរៀបចំគម្រោងអភិរក្សប្រាសាទចៅស្រីវិបុល

ផ្សាយនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រីទ្ធី

ប្រាសាទចៅស្រីវិបុលមានទីតាំងនៅក្នុងភូមិត្រាច ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ អ្នកស្រាវជ្រាវយល់ថា តាមរយៈរចនាបថឃ្លាំង និងបច្ចេកទេសសំណង់គឺដូចគ្នាទៅនឹងចំណុចមួយចំនួននៃប្រាសាទភ្នំជីសូរ វត្តបាសែត វត្តឯកភ្នំ និងព្រះវិហារ ដែលកសាងឡើងក្នុងអំឡុងសតវត្សទី១១ ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១។ បច្ចុប្បន្នប្រាសាទនេះទទួលរងនូវការខូចខាតស្ទើរទាំងស្រុង ប៉ុន្តែក៏នៅទទួលបានការចាប់អារម្មណ៍ពីភ្ញៀវទេសចរមួយចំនួនផងដែរ។

ប្រធានស្តីទីនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ **លោកបណ្ឌិត ឈាន រដ្ឋា** បានរៀបរាប់ថា ស្ថានភាពខូចខាតនៃប្រាសាទចៅស្រីវិបុលនេះកើតឡើងដោយកត្តាសំខាន់ៗ៣យ៉ាងគឺ កត្តាសង្គ្រាម ដែលប្រើប្រាស់ប្រាសាទជាទីតាំងសមរភូមិ កត្តាមនុស្ស តាមរយៈការលួចគាស់កកាយរកវត្ថុមានតម្លៃជាដើម និងកត្តាធម្មជាតិ តាមរយៈអាយុកាលរបស់ប្រាសាទ និងដើមឈើធំៗដុះឫសជ្រែកថ្មប្រាសាទបណ្តាលឲ្យប្រាសាទដួលរលំ។

ចាប់ពីឆ្នាំ២០០៧មក នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានចុះធ្វើការអភិរក្ស ដោយផ្តោតសំខាន់លើការងារទល់ទ្រ និងទប់ស្កាត់ការដួលរលំបន្ត។ មកទល់នឹងពេលនេះ ក្រុមអ្នកជំនាញបានធ្វើការទល់ទ្របានចំនួន១៧ចំណុចសំខាន់ៗ និងកំពុងរៀបចំផែនការទល់ទ្រចំនួន៥ទីតាំងបន្ថែមទៀត។ ក្រៅពីនេះ ក្រុមការងារបានរៀបចំធ្វើផែនទីហានិភ័យ ដើម្បីតាមដានស្ថានភាពគ្រោះថ្នាក់នៃប្រាសាទនេះជាប្រចាំ ដោយមានបុគ្គលិកប្រចាំការម្នាក់ ភ្នាក់ងារ៧នាក់ និងកម្មករ១៩នាក់។

លោក រដ្ឋា បន្ថែមថា ចំពោះកិច្ចការអភិរក្សទល់ទ្រប្រាសាទនេះ គឺត្រូវបានធ្វើឡើងដោយអ្នកជំនាញខ្មែរ និងប្រើប្រាស់ថវិកាជាតិ ពុំទាន់មានស្ថាប័នអន្តរជាតិណាមួយចូលរួមនៅឡើយ។ ទោះជាយ៉ាងនេះក្តី អ្នកជំនាញបរទេសក៏តែងផ្តល់អនុសាសន៍ខ្លះៗតាមរយៈកិច្ចប្រជុំគណៈកម្មាធិការអាយស៊ីស៊ីជាដើម។ បច្ចុប្បន្ន អ្នកជំនាញកំពុងព្យាយាមរៀបចំគម្រោងតូចៗដើម្បីធ្វើការអភិរក្សជួសជុល ទៅតាមលទ្ធភាពនៃថវិកាជាតិ។

ប្រធាននាយកដ្ឋានស្តីទីរូបនេះបន្ថែមថា ការងារអភិរក្សនៅប្រាសាទចៅស្រីវិបុល មិនត្រឹមតែគិតគូរទៅលើសំណង់ប្រាសាទប៉ុណ្ណោះទេ តែអ្នកជំនាញបានគិតគូរដល់តំបន់ជុំវិញប្រាសាទដូចជា កសិន្ទ និងព្រៃឈើជាដើម។ បញ្ហាប្រឈមនៃការងារអភិរក្សនេះ គឺប្រជាពលរដ្ឋមួយចំនួនដែលមិនបានយល់ដល់តម្លៃនៃបេតិកភណ្ឌ បានព្យាយាមជីកដីលក់ក្នុងតំបន់ការពារ កាប់ឆ្ការព្រៃ និងសាងសង់សំណង់ក្នុងតំបន់ការពារជាដើម។ លោកក៏បានអំពាវនាវឲ្យប្រជាពលរដ្ឋគ្រប់រូបចូលរួមក្នុងកិច្ចការអភិរក្សនេះឲ្យបានគ្រប់គ្នា ដើម្បីភាពគង់វង្សយូរអង្វែងនៃបេតិកភណ្ឌជាតិ៕









អាជ្ញាធរជាតិអប្សរាបង្កើតក្រុមការងារប្រតិកម្មរហ័សសម្រាប់ដោះស្រាយបញ្ហាបន្ទាន់ៗ ជាមួយប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត

ដើម្បីដោះស្រាយបញ្ហា និងធ្លើយតបបានទាន់ពេលចំពោះតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានបង្កើតក្រុមការងារប្រតិកម្មរហ័សមួយ ដើម្បីធ្វើការជាមួយរដ្ឋបាលខេត្តសៀមរាប។

ក្រុមការងារនេះមានតួនាទីសំខាន់ក្នុងការដោះស្រាយបញ្ហាបន្ទាន់របស់ប្រជាពលរដ្ឋដូចជា ការសាងសង់សំណង់ផ្សេងៗ សុខទុក្ខរបស់ប្រជាពលរដ្ឋ ឬពេលដែលប្រជាពលរដ្ឋមានតម្រូវការជាក់ស្តែងណាមួយជាដើម។ ជាមួយគ្នានេះដែរ ក្រុមការ-ងារនេះនឹងធ្វើការដោយផ្ទាល់ជាមួយអាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋានដើម្បីដោះស្រាយបញ្ហា ផ្តល់ប្រឹក្សាយោបល់ និងទទួលបណ្តឹងផ្សេងៗពីប្រជាលរដ្ឋ។

ក្រុមការងារប្រតិកម្មរហ័សរបស់អាជ្ញាធរជាតិអប្សរា

ល.រ	គោត្តនាម នាម	មុខងារ	តួនាទី	ទទួលបន្ទុក	លេខទូរសព្ទ
១	ឯកឧត្តម សុំ ម៉ាប់	អគ្គនាយក	ប្រធាន	ទទួលបន្ទុករួម	012 55 11 33
២	ឯកឧត្តម សុខ សង្វារ	អគ្គនាយករង	អនុប្រធាន	ទទួលបន្ទុករួម	016 89 99 99
៣	ឯកឧត្តម ហង់ ពៅ	អគ្គនាយករង	សមាជិក	ស្រុកអង្គរធំ	077 88 78 36
៤	ឯកឧត្តម ខូយ គឹមទូ	ទីប្រឹក្សា	សមាជិក	ក្រុងសៀមរាប	012 77 73 99
៥	ឯកឧត្តម សុខ លក្ខិណា	ទីប្រឹក្សា	សមាជិក	ស្រុកប្រាសាទបាគង	012 77 77 56
៦	ឯកឧត្តម មុី ម៉ារ៉ាឌី	ទីប្រឹក្សា	សមាជិក	ស្រុកបន្ទាយស្រី	012 90 19 01
៧	លោក និន ចាន់សាមៀន	ប្រធាននាយកដ្ឋាន	សមាជិក	ស្រុកពួក	012 98 15 56
៨	លោក គង់ មរកត	ប្រធាននាយកដ្ឋានស្តីទី	សមាជិក	ដោះស្រាយការងារសាងសង់	012 85 02 26
៩	លោក ទស្ស សុមនាថ	ប្រធាននាយកដ្ឋានស្តីទី	សមាជិក	ដោះស្រាយការងារសាងសង់	012 32 54 19
១០	លោក ង៉ាន់ ដានី	ប្រធាននាយកដ្ឋាន	សមាជិក		012 30 30 30

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ៣៧៤/ ៦៧ ៦ប.ឯ

គោរពជូន
ឯកឧត្តមបណ្ឌិតអភិបាល នៃគណៈអភិបាល ខេត្តសៀមរាប

កម្មវត្ថុ: ស្តីពីក្រុមការងារប្រតិកម្មរហ័សសម្រាប់ដោះស្រាយបញ្ហាបន្ទាន់ៗជាមួយប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ ១ និងតំបន់ ២ ក្នុងរមណីយដ្ឋានអង្គរ។

យោង : អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអភិបាលខេត្ត ជ្រាបថាផ្អែកតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៧ បានសម្រេចឱ្យអាជ្ញាធរអប្សរាមានក្រុមការងារប្រតិកម្មរហ័សមួយសម្រាប់ដោះស្រាយនូវរាល់បញ្ហាបន្ទាន់ៗ (ការសាងសង់សំណង់ផ្សេងៗ សុខទុក្ខ និងតម្រូវការរបស់ប្រជាពលរដ្ឋ ។ល។) ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ១ និងតំបន់ ២ ក្នុងរមណីយដ្ឋានអង្គរ។ ដើម្បីអនុវត្តឲ្យបានប្រសិទ្ធភាពខ្ពស់អាជ្ញាធរអប្សរាបានបង្កើតក្រុមការងារមួយសម្រាប់ធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយអាជ្ញាធរខេត្ត ឬអាជ្ញាធរដែនដីពាក់ព័ន្ធស្ថិតនៅក្នុងតំបន់ ១ និងតំបន់ ២ ក្នុងរមណីយដ្ឋានអង្គរ និងផ្តល់យោបល់ជូនជាបន្ទាន់ៗ ដែលមានសមាសភាពដូចខាងក្រោម ៖

ល.រ	នាម និងគោត្តនាម	មុខងារ	តួនាទី	លេខទូរស័ព្ទ
១	ឯកឧត្តម ស៊ុំ ម៉ាប់	អគ្គនាយក	ប្រធាន	012 55 11 33
២	ឯកឧត្តម សុខ សង្ធារ	អគ្គនាយករង	អនុប្រធាន	016 89 99 99
៣	ឯកឧត្តម ហង់ ពៅ	អគ្គនាយករង	សមាជិក	077 88 78 36
៤	ឯកឧត្តម ខូយ គឹមទូ	ទីប្រឹក្សាអាជ្ញាធរអប្សរា	សមាជិក	012 77 73 99
៥	ឯកឧត្តម សុខ លក្ខិណា	ទីប្រឹក្សាអាជ្ញាធរអប្សរា	សមាជិក	012 77 77 56
៦	ឯកឧត្តម ម៉ី ម៉ាវ៉ាឌី	ទីប្រឹក្សាអាជ្ញាធរអប្សរា	សមាជិក	012 90 19 01
៧	លោក ង៉ាន់ ដានី	ប្រធាននាយកដ្ឋាន	សមាជិក	012 30 30 30
៨	លោក និន ចាន់សាម៉ៀន	ប្រធាននាយកដ្ឋាន	សមាជិក	012 98 15 56

អាជ្ញាធរដើម្បីការពារមណីយដ្ឋាននៃតំរៀបចំតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

PHNOM PENH :
#41, Russian Blvd,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 776
Fax : (855-23) 215 771

SIEM REAP :
Phum Bang Korng Sangkat Ampil Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

៩	លោក គង់ មរកត	ប្រធាននាយកដ្ឋានស្តីទី	សមាជិក	012 85 02 26
១០	លោក ទស្ស សុមនាថ	ប្រធាននាយកដ្ឋានស្តីទី	សមាជិក	012 32 54 19

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលខេត្តមេត្តាជ្រាប និងជួយសហការតាមការគួរ។
សូមឯកឧត្តមអភិបាលខេត្ត មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

ចម្លងជូន ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

សៀមរាប ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧
អគ្គនាយក
ស៊ុំ ម៉ាប់

ការចូលរួមអភិវឌ្ឍសហគមន៍ប្រជាពលរដ្ឋក្នុងតំបន់បេតិកភណ្ឌនៅតែជាការងារសំខាន់ របស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ចិន ស៊ីយ៉ាង រូបភាព ៖ ក្រុមការងារសហគមន៍

ក្រៅពីការងារថែរក្សា គ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរក៏ដូចជាការលើកតម្លៃ បេតិកភណ្ឌរូបី និងអរូបី ប្រកបដោយចីរភាព អាជ្ញាធរជាតិអប្សរាតាមរយៈក្រុមការងារ សហគមន៍តែងចុះសួរសុខទុក្ខ អប់រំ ស្តាប់សំណូមពរ ដោះស្រាយផលលំបាក និងបញ្ជាជូនបងប្អូនប្រជាពលរដ្ឋដោយផ្ទាល់ តាមមូលដ្ឋានដែលស្ថិតនៅក្នុងរមណីយដ្ឋានអង្គរ។

នៅខែមេសាដើមឆ្នាំ២០១៧កន្លងទៅនេះ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា បានចុះសួរសុខទុក្ខ និងធ្វើកិច្ចការងារមនុស្សធម៌ដោយបានពាំនាំនូវកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកទៅឧបត្ថម្ភដល់ស្ត្រី ដែលទើបតែសម្រាលកូនរួចថ្មីៗ ក្នុងតំបន់រមណីយដ្ឋានអង្គរបានចំនួន ២០៦ កញ្ចប់។ បន្ថែមពីលើកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារក ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានធ្វើការងារសង្គមកិច្ច ដូចជាបាននាំយកនូវស៊ីម៉ង់ត៍ចំនួន ១តោន ទៅឧបត្ថម្ភដល់មណ្ឌលសុខភាពរលួស ឃុំរលួស ស្រុកប្រាសាទបាគង ដើម្បីចូលរួមក្នុងការកសាងសមិទ្ធផលនានានៅក្នុងទីនោះ។ អាជ្ញាធរជាតិអប្សរាក៏បានចូលរួមចរិកា ដើម្បីកសាងនូវសមិទ្ធផលក្នុងវិស័យសាសនា ដោយបានឧបត្ថម្ភចរិកាចំនួន ៤០ម៉ឺនរៀល ដើម្បីចូលរួមបុណ្យឆ្លងសាលា នៅភូមិពាម ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។

ដោយឡែក ពាក់ព័ន្ធនឹងការងារអនុញ្ញាតការសាងសង់ប្រភេទសំណង់ស្រាល ដូចជា ជួសជុលផ្ទះ ជួសជុលជំបូល ជួសជុលជញ្ជាំង ប្តូរសសរ កឥដ្ឋក្រោមផ្ទះ សាងសង់បង្គន់ ចាក់ដី និងសាងសង់តូបលក់ដូរ ដែលមានចំនួន៥៣ករណី នៅស្រុកប្រាសាទបាគងចំនួន ៧ករណី, ស្រុកពួកចំនួន២ករណី, ក្រុងសៀមរាបចំនួន៣៥ករណី, ស្រុកបន្ទាយស្រីចំនួន ៩ករណី។

ស្តែងចេញពីសកម្មភាពទាំងនេះ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាតែងតែនៅក្បែរ និងយកចិត្តទុកដាក់គ្រប់បញ្ហាចំពោះប្រជាពលរដ្ឋទាំងសុខទុក្ខ ទាំងជីវភាពរស់នៅ សុខភាព ការសាងសង់ និងការអប់រំ ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋក្នុងតំបន់អង្គរមានសេដ្ឋកិច្ចល្អប្រសើរចំណេះដឹងទូលំទូលាយ និងមានភាពសុខសាន្តក្នុងសង្គមគ្រួសារ៕









ទ្វារទឹកជុំវិញកសិន្នុប្រាសាទចៅស្រីវិបុលផ្តល់អត្ថប្រយោជន៍ទាំងការងារអភិរក្ស និងសហគមន៍

ផ្សាយនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ឆ្លើយតបនឹងសំណើរបស់ប្រជាពលរដ្ឋ អាជ្ញាធរជាតិអប្សរាបានសហការជាមួយប្រទេសញ៉ូវហ្សេឡែន តាមរយៈគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍និងបេតិកភណ្ឌអង្គរហៅកាត់ថា ACHA បានកសាងទ្វារគ្រប់គ្រងទឹកចេញចូលកសិន្នុនៃប្រាសាទចៅស្រីវិបុល តាំងពីចុងឆ្នាំ២០១៦មក ហើយគ្រោងនឹងបញ្ចប់នៅចុងខែឧសភានេះ។

ទ្វារទឹកនេះត្រូវបានសាងសង់ឡើង៤ទីតាំងជុំវិញប្រាសាទចៅស្រីវិបុល គឺទ្វារខាងជើងមានតួនាទីបញ្ចូលទឹកក្នុងកសិន្នុ ទ្វារខាងកើតសម្រាប់បញ្ចេញ និងបញ្ចូលទឹក ទ្វារខាងត្បូងសម្រាប់បញ្ចេញទឹកជូនប្រជាពលរដ្ឋប្រើប្រាស់ និងទ្វារខាងលិចមានតួនាទីភ្ជាប់ប្រព័ន្ធទឹកជុំវិញកសិន្នុ។

ឯកឧត្តម ហង់ ពៅ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងទឹក មានប្រសាសន៍កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៧ថា ទ្វារទឹកទាំង៤នេះពិតជាផ្តល់អត្ថប្រយោជន៍ច្រើន ទាំងផ្នែកការងារអភិរក្ស និងអត្ថប្រយោជន៍ដល់សហគមន៍ប្រជាពលរដ្ឋដែលរស់នៅជុំវិញប្រាសាទចៅស្រីវិបុល។

អត្ថប្រយោជន៍ចំពោះការងារអភិរក្ស គឺដោយសារតែទ្វារទឹកនេះនឹងជួយប្រមូលទឹកពីតំបន់ផ្សេងៗមកបំពេញ ក្នុងកសិន្នុនៃប្រាសាទចៅស្រីវិបុល ស្របនឹងអត្ថន័យដើមនៃកសិន្នុដែលតែងមានទឹកជុំវិញប្រាសាទ ជានិមិត្តរូបនៃជំនឿខ្មែរក្នុងការប្រដូចប្រាសាទទៅនឹងភ្នំព្រះសុមេរុ ព័ទ្ធជុំវិញដោយមហាសមុទ្រ។

ចំពោះអត្ថប្រយោជន៍សម្រាប់សហគមន៍វិញ គឺទ្វារទឹកទាំង៤នេះនឹងមានតួនាទីសំខាន់សម្រាប់រំដោះទឹកកុំឲ្យមានជំនន់ រក្សាទឹកក្នុងកសិន្នុ និងបង្ហូរចេញទៅស្រោចស្រពស្រូវ ដំណាំរបស់ប្រជាពលរដ្ឋបានតាមតម្រូវការ ដែលតាមការប៉ាន់ប្រមាណនឹងមានប្រជាពលរដ្ឋជាង៤០០គ្រួសារនឹងទទួលបានទឹកស្រោចស្រពពីកសិន្នុនេះ។

អ្នកស្រី ហ៊ឹប ស៊ាន សមាជិកក្រុមប្រឹក្សាឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង បានបង្ហាញអារម្មណ៍រីករាយដែលទទួលបានសំណង់ទ្វារទឹកពីអាជ្ញាធរជាតិអប្សរា។ អ្នកស្រីបញ្ជាក់ថា សំណង់ទ្វារទឹកនេះនឹងជួយឲ្យប្រជាពលរដ្ឋរាប់រយគ្រួសារអាចធ្វើស្រែ និងដាំដំណាំបន្ថែលក់ដូរពង្រឹងសេដ្ឋកិច្ចគ្រួសារ កាត់បន្ថយចំណាកស្រុក។ ជាពិសេស អ្នកស្រីសង្ឃឹមថា នៅពេលមានទឹកពេញកសិន្នុ គួបផ្សំនឹងធម្មជាតិជុំវិញស្អាតស្រាប់ផងនោះ នឹងនាំឲ្យភ្ញៀវទេសចរមកកម្សាន្តច្រើន ហើយប្រជាពលរដ្ឋអាចលក់ដូរបានចំណូលបន្ថែមទៀតជាមិនខាន៕









សាលរបាំប្រាសាទតាព្រហ្មកំពុងជួសជុលក្នុងដំណាក់កាលទី២

ផ្សាយនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ អ៊ីសា រ៉ហ៊ីនី

សាលរបាំ ដែលស្ថិតក្នុងប្រាសាទតាព្រហ្ម បាននិងកំពុងជួសជុលដោយក្រុមអ្នកជំនាញពីប្រទេសឥណ្ឌា ដែលមានកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា។ គម្រោងជួសជុលសាលរបាំនេះ គឺស្ថិតក្នុងដំណាក់កាលទី២ ដែលត្រូវជួសជុលដំបូលកណ្តាល។

លោក ចាន់ ឡាយ អ្នកគ្រប់គ្រងការដ្ឋានជួសជុលប្រាសាទតាព្រហ្ម បានរៀបរាប់ពីការងារជួសជុលដែលលោកពន្យល់ថា ការជួសជុលនេះ គឺស្ថិតក្នុងគម្រោងដំណាក់កាលទី២ ដែលចាប់ផ្តើមនៅក្នុងឆ្នាំ២០១៧នេះ។ តាមគម្រោង ការជួសជុលនេះគ្រោងនឹងបញ្ចប់នៅរយៈពេល២ឆ្នាំបន្ទាប់។

តាមអ្នកគ្រប់គ្រងលើការងារជួសជុល សាលរបាំត្រូវបានជួសជុលក្នុងដំណាក់កាលទី១ គឺនៅក្នុងឆ្នាំ២០១០។ អ្នកជំនាញបានប្រើពេលជាង២ឆ្នាំ សម្រាប់ការធ្វើកំណាយ មុននឹងចាប់ផ្តើមការងារជួសជុលនៅចុងឆ្នាំ២០១២។ តាមការបញ្ជាក់របស់**លោក ចាន់ ឡាយ** ក្នុងការងារជួសជុលដំណាក់កាលទី១ គឺចាប់ផ្តើមពីជ្រុងខាងជើង ដោយជួសជុលពីគ្រឹះដល់ដំបូល ដោយបញ្ចប់នៅឆ្នាំ២០១៤។ ចំណែកក្នុងដំណាក់ទី២នេះ គឺបន្តជួសជុលភ្ជាប់ទៅដំបូលកណ្តាល។ ក្រៅពីនេះ តាមការពន្យល់របស់**លោក ចាន់ ឡាយ** ក្រុមការងារក៏បានកំពុងធ្វើកំណាយទៅជ្រុងខាងត្បូងផងដែរ ដើម្បីពិនិត្យមើលគ្រឹះរបស់វា ហើយបើអ្នកជំនាញឃើញថា គ្រឹះវាខ្សោយ គេនឹងចាប់ផ្តើមពង្រឹងគ្រឹះវាឡើងវិញ។

យ៉ាងណាក្តី បើទោះជាការងារជួសជុលសាលរបាំប្រព្រឹត្តទៅដោយរលូន និងមានសោភ័ណស្រស់ស្អាតក៏ពិតមែន តែតាមគម្រោងនេះ អ្នកជំនាញនឹងទុកផ្នែកខ្លះដែលបាក់បែកឲ្យនៅសភាពដើម។ ដោយសារក្រុមអ្នកជំនាញយល់ថា វាអាចជាចំណែកមួយទាក់ទាញភ្ញៀវទេសចរ ដើម្បីប្រៀបធៀបចំណុចដែលបានជួសជុល និងចំណុលដែលគ្រាន់ជាគំនរថ្ម ដែលពុំមានការជួសជុលនោះ។ នេះបើតាមការបញ្ជាក់របស់**លោក ចាន់ ឡាយ**។

សាលរបាំ បើតាមការរម្លឹកពីក្រុមការងារជួសជុលនៅទីនោះ គឺមុនពេលមានការជួសជុល សាលនេះគ្រាន់តែជាគំនរថ្មតែប៉ុណ្ណោះ។ ដំបូលនៃសាលនេះ ជ្រុះធ្លាក់ស្ទើរទាំងស្រុង ចំណែកសសរដួលរាបដល់ដីគ្មានសល់។ ក្រុមការងារជួសជុលបានចាប់ផ្តើមរើថ្មចេញ និងបង់លេខ ដើម្បីងាយស្រួលក្នុងការរៀប និងជួសជុលឡើងវិញ។

បច្ចុប្បន្នគម្រោងជួសជុលសាលរបាំ ស្ថិតក្នុងគម្រោងសហប្រតិបត្តិការឥណ្ឌា-កម្ពុជា ដើម្បីអភិរក្ស និងជួសជុលប្រាសាទតាព្រហ្ម។ គម្រោងនេះប្រើប្រាស់កម្មករចំនួន ១១៨នាក់ ដោយក្នុងនោះអាជ្ញាធរជាតិអប្សរាបានបញ្ជូនកម្មករចំនួន ២៥នាក់ សម្រាប់ការងារសហប្រតិបត្តិការនេះផងដែរ៕









ប្រជាពលរដ្ឋ១៣គ្រួសារនៅឃុំលាងដែនទទួលបានការឧបត្ថម្ភពីការខូចខាតដំណាំស្រូវកាលពីឆ្នាំ២០១៦ ពីអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ចិន ស៊ីយ៉ាំង រូបភាព ៖ ហ៊ុំ រិទ្ធី

កាលពីថ្ងៃ៥ ខែឧសភា ឆ្នាំ២០១៧ កន្លងទៅនេះ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាដឹកនាំដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរាបានចុះសួរសុខទុក្ខ និងឧបត្ថម្ភការខូចខាតដំណាំស្រូវកាលពីឆ្នាំ២០១៦ ដោយឧបត្ថម្ភជាប្រាក់យ៉ាងតិច ចាប់ពី២០ម៉ឺនរៀល និងយ៉ាងច្រើន២ លានរៀលទៅតាមទំហំដីស្រែ និងបរិមាណស្រូវត្រូវបានខូចខាត។

ក្នុងនាមអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** បានលើកឡើងថាអាជ្ញាធរជាតិអប្សរាតែងយកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋ ដូចជាពេលនេះគឺការខូចខាតដំណាំស្រូវរបស់ប្រជាពលរដ្ឋ និងការបញ្ជៀសជំនន់ក្រុងសៀមរាប និងប្រាង្គប្រាសាទនានានៅក្នុងតំបន់រមណីយដ្ឋានអង្គរ។ ម្យ៉ាងទៀត ការការពារតំបន់រមណីយដ្ឋានអង្គរ គឺស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យមន្ត្រីអាជ្ញាធរជាតិអប្សរាប្រឹងប្រែងធ្វើតាមតួនាទីរបស់ខ្លួនក្នុងការអភិរក្ស និងអភិវឌ្ឍដើម្បីជួយលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

ក្នុងពិធីនោះដែរ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាក៏បាននាំយកនូវកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកចែកជូនដល់ស្ត្រីដែលទើបតែឆ្លងទន្លេហើយថ្មីៗ ចំនួន២២ គ្រួសារ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ តាមការណែនាំរបស់ **លោកជំទាវ ឡើង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ដែលលោកជំទាវតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខបងប្អូនប្រជាពលរដ្ឋដែលរស់នៅទីនោះ។

ទាំងនេះជាការយកចិត្តទុកដាក់របស់អាជ្ញាធរជាតិអប្សរាចំពោះសុខទុក្ខ និងសុខុមាលភាពប្រជាពលរដ្ឋដើម្បី ផ្តល់កាពកក់ក្តៅ និងជួយសម្រួលការលំបាកផ្សេងៗដល់ប្រជាពលរដ្ឋ ក៏ដូចជួយលើកកម្ពស់តម្លៃបេតិកភណ្ឌទុកសម្រាប់មនុស្សជាតិជំនាន់ក្រោយតទៅទៀត៕






និស្សិតបុរាណវិទ្យាជំនាន់ទី២៩ បញ្ចប់ទស្សនកិច្ចសិក្សារយៈពេល១០ថ្ងៃដើម្បីស្វែងយល់ពីអរិយធម៌ខ្មែរនៅក្នុង និងក្រៅតំបន់អង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ឹង ស្រីរ័ត្ន

និស្សិតបុរាណវិទ្យាជំនាន់ទី២៥នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ចំនួន១៤នាក់ បានបំពេញទស្សនកិច្ចសិក្សាដើម្បីស្វែងយល់ពីអរិយធម៌ខ្មែរនៅក្នុងនិងក្រៅតំបន់រមណីយដ្ឋានអង្គររយៈពេល១០ថ្ងៃ ហើយបានបញ្ចប់កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៧។ ដំណើរទស្សនកិច្ចសិក្សានេះ ទទួលបន្ទុកទាំងស្រុងដោយអាជ្ញាធរជាតិអប្សរា ដើម្បីឱ្យនិស្សិតបុរាណវិទ្យាឆ្នាំទី៤នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានសិក្សាដោយផ្ទាល់នៅតាមទីតាំងជាក់ស្តែងបន្ទាប់ពីរៀនទ្រឹស្តី ហើយក៏ជាជំនួយស្មារតីក្នុងការសរសេរបញ្ចប់សារណាដល់និស្សិតផងដែរ។

លោក ខៀវ ចន្ន មន្ត្រីបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរាបានមានប្រសាសន៍ថា នេះជាវគ្គគរុកោសល្យមួយដែលអាជ្ញាធរជាតិអប្សរាចែករំលែកចំណេះដឹងដល់និស្សិតបុរាណវិទ្យាច្រើនជំនាន់ ច្រើនឆ្នាំមកហើយក្នុងនាមជាអ្នកមានសមត្ថភាពក្នុងការផ្តល់ចំណេះដឹង ជំនាញ និងសមត្ថកិច្ចក្នុងការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរ។ លោកបន្តទៀតថា ក្រៅពីទទួលខុសត្រូវទាំងស្រុងលើផ្នែកថវិកា អាជ្ញាធរជាតិអប្សរាក៏មានអ្នកជំនាញជាច្រើនរូបធ្វើបទបង្ហាញ និងនាំនិស្សិតទៅសិក្សាតាមគោលដៅជាក់ស្តែងទាក់ទងនឹងប្រវត្តិសាស្ត្រ បុរាណវិទ្យា ការដ្ឋានកំណាយ ស្ថានីយបុរេប្រវត្តិ និងស្វែងយល់ពីវប្បធម៌អរិយធម៌ខ្មែរជាដើម ដើម្បីបំពេញបន្ថែមលើទ្រឹស្តីដែលសិក្សានៅសាលា និងពង្រីកចំណេះដឹងក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់ខ្លួន។

លោកសាស្ត្រាចារ្យ ព្រាប ចាន់ម៉ារ៉ា បង្រៀនផ្នែកទ្រឹស្តីសំណង់ប្រពៃណីខ្មែរ និងជាមន្ត្រីសម្របសម្រួលក្នុងកម្មសិក្សានេះ បានលើកឡើងថា កម្មសិក្សានេះធ្វើឡើងជាទៀងទាត់សម្រាប់និស្សិតបុរាណវិទ្យាឆ្នាំទី៤គ្រប់ជំនាន់ ដែលត្រូវមកសិក្សាដោយផ្ទាល់អំពីអរិយធម៌អង្គរ ក្រោមការឧបត្ថម្ភពីអាជ្ញាធរជាតិអប្សរាទាំងថវិកា និងគ្រូបង្គោល។ ការមករៀនសូត្រនៅទីនេះគឺល្អ ណាស់ ព្រោះវាបានផ្សារភ្ជាប់ទ្រឹស្តីនិងការមើលឃើញជាក់ស្តែងអំពីកស្តុតាង នានាដែលនៅសេសសល់ ពីបុរាណកាល ដែលក្នុងនាមអ្នកបុរាណវិទ្យាត្រូវតែធ្វើ ត្រូវតែចេះ ត្រូវតែដឹង។

និស្សិតបុរាណវិទ្យា អ៊ុន សុផានិត បានមានមតិថា ការចុះទស្សនកិច្ចសិក្សានេះគឺដើម្បីស្វែងយល់ពីអរិយធម៌អង្គរ ទាំងវិសាលភាព កស្តុតាង និងបុរាណដ្ឋាននានាក្នុងតំបន់អង្គរនិងក្រៅតំបន់អង្គរដែលអ្នកសិក្សា និងទេសចរមួយចំនួនទៅមិនដល់។ តាមរយៈកម្មសិក្សានេះ វាពិតជាប្លែកភ្នែកដែលបានដឹងច្រើនពីការតាំងទីរស់នៅរបស់បុព្វបុរសខ្មែរ សមិទ្ធផលដែលដូនតាបន្សល់ទុក ហើយពួកយើងបានរៀនសូត្រពីប្រវត្តិប្រាសាទ ទំនៀមទម្លាប់ ការរៀបចំក្រុង ទំនាក់ទំនងផ្លូវបុរាណមកក្រុងអង្គរជាដើម។ ចំពោះ **សុផានិត** ការជ្រើសរើសជំនាញបុរាណវិទ្យា ជាការស្រឡាញ់ពេញចិត្តបំផុត បើទោះមិនសូវមានអ្នកចាប់អារម្មណ៍ តែវាពិតជាសំខាន់ណាស់សម្រាប់ប្រទេសខ្មែរដែលសម្បូរទៅដោយបុរាណដ្ឋាន ដែលសព្វថ្ងៃនៅខ្វះធនធានមនុស្សខាងផ្នែកវប្បធម៌នេះច្រើនណាស់។ ក្នុងនោះដែរដើម្បីអភិរក្សបេតិកភណ្ឌឱ្យបានល្អប្រសើរ គឺត្រូវការអ្នកស្រឡាញ់ និងមានជំនាញពិតប្រាកដ បើយើងខ្វះធនធានមនុស្ស ខ្វះចិត្តស្រឡាញ់ ជំនាញពិតប្រាកដ ខ្វះបច្ចេកទេសនោះយើងនឹងមិនដឹងថាគេធ្វើយ៉ាងម៉េច ត្រូវឬខុស ល្អឬអាក្រក់មកលើការជួសជុលមរតកវប្បធម៌ទាំងនោះទេ។

និស្សិត ជាន ធី ក៏បានចាប់អារម្មណ៍នឹងដំណើរទស្សនកិច្ចសិក្សានេះផងថា ក្នុងរយៈពេល១០ថ្ងៃពិតជាបានផ្តល់ចំណេះដឹងថ្មីបន្ថែមលើទ្រឹស្តីដែលរៀននៅសាលា ហើយវាក៏ជួយជាគំនិតដល់និស្សិតទាំងអស់ដើម្បីបញ្ចប់សារណាបានល្អ ព្រោះយើងបានមកសិក្សាដោយផ្ទាល់ ជួបគ្រូល្អៗដើម្បីស្វែងយល់ពីអរិយធម៌អង្គរ។ ការសិក្សានេះ គឺមានទាំងនៅក្នុងឧទ្យាន និងក្រៅឧទ្យានអង្គរ ដើម្បីស្វែងយល់ពីទីតាំងភូមិសាស្ត្រ រចនាសម្ពន្ធប្រាសាទ ការជួសជុល អភិរក្សប្រាសាទ ទំនៀមទម្លាប់អ្នកស្រុកជាដើម។ ជួសមុខឱ្យនិស្សិតទាំងអស់ **ជាន ធី** ក៏បានសម្តែងការអរគុណដល់អាជ្ញាធរជាតិអប្សរា ដែលបានឧបត្ថម្ភចំពោះ ដំណើរទស្សនកិច្ច ផ្តល់ចំណេះដឹងល្អៗ រួមទាំងជាកន្លែងផ្តល់ការងារដល់និស្សិតបុរាណវិទ្យាយ៉ាងច្រើនទៀតផង៕









អាជ្ញាធរជាតិអប្សរាឧបត្ថម្ភថវិកា១២លានរៀលដល់កាកបាទក្រហមនិងអង្គចន្ទក្រហមប្រចាំខេត្តសៀមរាប នាឱកាសអបអរសាទរខួបលើកទី១៥៤

ផ្សាយនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីវ័ន្ត រូបភាព ៖ ហ៊ឹង ស្រីវ័ន្ត

នាព្រឹកថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៧ **ឯកឧត្តម ហាច់ ពៅ** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងទឹក និង **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ តំណាងដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ឡឿង សកុណា** ប្រធានអាជ្ញាធរជាតិអប្សរា បានយកថវិកាចំនួន១២លានរៀលឧបត្ថម្ភដល់កាកបាទក្រហមខេត្តសៀមរាប ដើម្បីរួមចំណែកការងារមនុស្សធម៌ក្នុងសង្គម។

កម្មវិធីប្រគល់ថវិកានេះ បានធ្វើឡើងក្នុងឱកាសកាកបាទក្រហមខេត្ត ប្រារព្ធពិធីអបអរសាទរខួបទី១៥៤ ទិវាពិភពលោកកាកបាទក្រហម អង្គចន្ទក្រហម ៨ឧសភា ក្រោមប្រធានបទ «កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា» នាព្រឹកថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលកម្សាន្តរ៉ូហ្សាណា ប្រជុំវែរ។

កម្មវិធីនេះប្រារព្ធឡើងក្រោមអធិបតីភាព**ឯកឧត្តម ឡៅ ឆាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ **ឯកឧត្តម ឃីម ប៊ុនសុង** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ព្រះសង្ឃ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ថ្នាក់ដឹកនាំគ្រប់ស្ថាប័នពាក់ព័ន្ធ អ្នកជំនួញជាតិ-អន្តរជាតិ អាជីវករ សិស្សានុសិស្សជាច្រើនផងដែរ។

កម្មវិធីនេះ ក៏បានបង្ហាញរបាយការណ៍លទ្ធផលការងារឆ្នាំចាស់ និងការប្តេជ្ញាចិត្តបន្តអនុវត្តផែនការការងារឆ្នាំថ្មី សំដៅធ្វើយ៉ាងណាជួយឱ្យបានច្រើនជាងមុន និងបានឆាប់ជាងមុន ដោយស្មើភាព មិនប្រកាន់ហានៈ ឬបក្សនយោបាយអ្វីទាំងអស់ចំពោះជនរងគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត គ្រោះថ្នាក់ដោយធម្មជាតិ អ្នកផ្ទុកមេរោគអេដស៍ ស្ត្រីមេម៉ាយ ក្មេងកំព្រា ជនពិការ។ល។

បន្ថែមពីនោះ អង្គពិធីទាំងមូលក៏បានថ្លែងអំណរគុណដល់សប្បុរសជនជាតិ-អន្តរជាតិទាំងអស់ ដែលបានចូលរួមបរិច្ចាគធនធាន តាមសទ្ធានិងលទ្ធភាពដល់កាកក្រហមកម្ពុជាប្រចាំខេត្តសៀមរាប ដើម្បីជួយដល់ជនរងគ្រោះដែលត្រូវការការ

សង្គ្រោះជាបន្ទាន់។ តាមរយៈការចូលរួមចំណែកទាំងនេះ គឺបង្ហាញពីការបណ្តុះស្មារតីសាមគ្គីភាព ចែករំលែកការអាណិតអាសូរ និងទឹកចិត្តស្រឡាញ់ដល់អ្នកទន់ខ្សោយ ដែលក្នុងនាមជនរួមជាតិត្រូវធ្វើដើម្បីគ្នាទៅវិញទៅមក៕









អាជ្ញាធរជាតិអប្សរានិងនគរបាលការពារបេតិកភណ្ឌជួបពិភាក្សាគ្នាដើម្បីពង្រឹងកិច្ចការពារបេតិកភណ្ឌអង្គរ

ផ្សាយនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ

អាជ្ញាធរជាតិអប្សរា និងនគរបាលការពារបេតិកភណ្ឌ សុទ្ធតែមានតួនាទីសំខាន់ក្នុងកិច្ចការពារបេតិកភណ្ឌអង្គរ។ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើកិច្ចការពារបេតិកភណ្ឌអង្គរឲ្យបានកាន់តែល្អប្រសើរ នាព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៧ នេះ ថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរបានជួបពិភាក្សាគ្នានៅទីស្នាក់ការនគរបាលការពារបេតិកភណ្ឌទល់មុខប្រាសាទអង្គរវត្ត។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាព**ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និង ប្រធាននាយកដ្ឋានការពារបេតិកភណ្ឌ **ឯកឧត្តមឧត្តមសេនីយ៍ ថី ឡាយ** ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសជាច្រើនរូបទៀត។ គោលបំណងចម្បងនៃកិច្ចប្រជុំនេះគឺដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់គ្នា លើការងារពង្រឹងសណ្តាប់ធ្នាប់ សុវត្ថិភាព និងការងារអភិរក្សរមណីយដ្ឋានអង្គរឲ្យបានកាន់តែល្អប្រសើរឡើងថែមទៀត។

នេះជាកិច្ចប្រជុំលើកទី១ នៃក្រុមការងារទាំងពីរ ដែលបានកំណត់យករៀងរាល់ថ្ងៃចន្ទដើមខែនីមួយៗ ដើម្បីពិភាក្សាគ្នាលើចំណុចខ្វះខាត និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងនគរបាលការពារបេតិកភណ្ឌ លើការងារប្រតិបត្តិក្នុងកិច្ចការពារបេតិកភណ្ឌអង្គរ៕






ប្រតិភូគណៈកម្មាធិការអាយស៊ីស៊ីអង្គរចូលគាល់ព្រះមហាក្សត្រ ដើម្បីទូលថ្វាយអំពីដំណើរវិវត្តនៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត

ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧កន្លងទៅនេះ ប្រតិភូនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលការគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ីអង្គរ បានចូលគាល់ **ព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះប្រធានកិត្តិយសនៃ គណៈកម្មាធិការអាយស៊ីស៊ីអង្គរ ដើម្បីទូលថ្វាយអំពីវឌ្ឍនភាពនៃការងារអភិរក្សរមណីយដ្ឋានអង្គរ។

ក្នុងដំណើរចូលគាល់ព្រះមហាក្សត្រនៅពេលនេះ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានទូលថ្វាយព្រះមហាក្សត្រអំពីដំណើរការគ្រប់គ្រងរបស់រមណីយដ្ឋានអង្គរ ដែលផ្តោត

សំខាន់លើការអភិរក្ស ជួសជុលស្តារឡើងវិញនូវប្រាង្គប្រាសាទ ការងារស្រាវជ្រាវ និងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបន្តវេនការងារអភិរក្សជាដើម។

ក្រៅពីនេះ ព្រះមហាក្សត្រក៏បានទ្រង់ព្រះសណ្តាប់នូវរបាយការណ៍អំពីការរីកចម្រើនយ៉ាងខ្លាំង នៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ដែលទូលថ្វាយដោយសហប្រធាននៃគណៈកម្មការអន្តរជាតិមួយនេះ គឺ **ឯកឧត្តម** Jean-Claude POIMBàUF អគ្គរដ្ឋទូតនៃប្រទេសបារាំងប្រចាំកម្ពុជា និង**ឯកឧត្តម** Hidehisa HORINOUCHI អគ្គរាជទូតនៃប្រទេសជប៉ុនប្រចាំកម្ពុជា រួមនឹងតំណាងអង្គការ UNESCO ប្រចាំកម្ពុជាគឺ **លោកស្រី** Anne LEMAISTRE។

គណៈប្រតិភូនេះក៏បានទូលថ្វាយអំពីភាពជោគជ័យជាបន្តបន្ទាប់ នៃការយន្តការអាយស៊ីស៊ីអង្គរ ក្នុងការគ្រប់គ្រងរមណីយដ្ឋានអង្គរ។ ជាក់ស្តែង កិត្តិសព្ទយន្តការនេះត្រូវបានប្រទេសជាច្រើនក្នុងពិភពលោកកោតសរសើរ និងយកគំរូតាម ដើម្បីអនុវត្តនៅក្នុងរមណីយដ្ឋានបេតិកភណ្ឌរបស់គេទៀតផង។

មានព្រះរាជឱង្ការក្នុងឱកាសនោះ ព្រះមហាក្សត្រជីវិតតម្កល់លើត្បូងទ្រង់សព្វព្រះរាជហឫទ័យ និងបានថ្លែងអំណរគុណចំពោះអាជ្ញាធរជាតិអប្សរា គណៈកម្មាធិការអាយស៊ីស៊ីអង្គរ និងស្ថាប័នអន្តរជាតិទាំងអស់ ដែលបានចូលរួមអភិរក្ស ជួសជុលប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ និងបានអនុវត្តតាមគោលការដ៏ល្អប្រពៃរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចការថែរក្សាការពារបេតិកភណ្ឌដ៏ល្អបវររបស់កម្ពុជា៕









កំពែងប្រាសាទបន្ទាយក្តីជ្រុងពាយ័ព្យត្រូវបានអ្នកជំនាញអាជ្ញាធរជាតិអប្សរាកំពុងជួសជុល

ផ្សាយនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ អ៊ីសា រ៉ហ៊ីនី

កំពែងថ្មបាយក្រៀមប្រាសាទបន្ទាយក្តីនាជ្រុងពាយ័ព្យ បណ្តោយប្រវែង៥.៥០ម៉ែត្រ កម្ពស់៣.៧០ម៉ែត្រ ត្រូវបានជួសជុលឡើងវិញដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកដោយនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ។ ការជួសជុលនេះធ្វើឡើងក្នុងបំណងលើកតម្លៃមរតកវប្បធម៌ជាតិ រក្សាសោភ័ណភាព និងអភិរក្សសំណង់ឱ្យនៅគង់វង្សយូរអង្វែងសម្រាប់អ្នកជំនាន់ក្រោយ។

លោក ម៉ៅ សុខនី អ្នកជំនាញអភិរក្សប្រាសាទក្នុងឧទ្យានអង្គរបានឱ្យដឹងថា កំពែងប្រាសាទបន្ទាយក្តីត្រង់ជ្រុងពាយ័ព្យនេះចាប់ផ្តើមជួសជុលពីខែមករា ឆ្នាំ២០១៧ បន្ទាប់ពីធ្វើកំណាយរកឃើញថាបាតគ្រឹះក្រោមពុកផុយ មិនអាចទ្រទម្ងន់ថ្មពីលើបាន។ មួយទៀត ជញ្ជាំងកំពែងនេះក៏ទ្រេតដួលទៅខាងជើងមួយផ្នែកទៀតផង ដែលអាចបង្កហានិភ័យបាក់រលំជញ្ជាំងកំពែងកាន់តែខ្លាំង និងបង្កគ្រោះថ្នាក់ដល់អ្នកធ្វើដំណើរជាយថាហេតុ។ ដូច្នេះហើយទើបនាយកដ្ឋានសម្រេចចិត្តជួសជុលជាបន្ទាន់។

លោក សុខនី បន្តទៀតថា ការជួសជុលកំពែងប្រាសាទបន្ទាយក្តីនេះគ្រោងនឹងបញ្ចប់នៅខែមិថុនា ឆ្នាំ២០១៧នេះហើយ ដែលនេះជាការជួសជុលលើកទី២ បន្ទាប់ពីបារាំងជួសជុលនាទសវត្សឆ្នាំ១៩៥០ ដោយប្រើស៊ីម៉ង់ត៍ដើម្បីបិទភ្ជិតថ្មបាយក្រៀមឱ្យជាប់គ្នា។ រីឯការជួសជុលដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា គឺអនុវត្តតាមបច្ចេកទេសនិងវត្ថុធាតុដើមពីបុរាណដែលមានក្នុងស្រុក ដោយចាប់ផ្តើមពង្រឹងបាតគ្រឹះស្រទាប់ទី១ ទី២ ទី៣ឱ្យមាំតាមរយៈការយកថ្មថ្មីមកប្រើជំនួសថ្មពុកផុយ ឯថ្មចាស់ខ្លះដែលនៅប្រើការបាន ក៏ត្រូវបានយកមកប្រើវិញដែរ។ ក្រុមការងារបានរៀបថ្មទៅវិញដោយបិទភ្ជិតបាតក្រោមឱ្យជិតល្អ មិនឱ្យទឹកជ្រាបចូល ដោយប្រើបាយអដែលផ្សំពីកម្ទេចថ្មបាយក្រៀម ខ្សាច់ ដីដំបូក និងការសម្រាប់ប្រើក្នុងការអភិរក្ស ដែលជានាបានមិនបង្កផលប៉ះពាល់ដល់សំណង់។ ក្រៅពីនោះថ្មនីមួយៗ ក៏មានធ្នាក់សម្រាប់ទាក់គ្នាទៅវិញទៅមក ធានាបាននូវភាពរឹងមាំ ជាប់ល្អ ហើយថ្មទាំងនោះក៏រៀបត្រូវតាមលំដាប់ និងទីតាំងដោយអ្នកជំនាញមានបទពិសោធន៍យូរឆ្នាំ។

អ្នកជំនាញរូបនេះជឿជាក់ខ្ពស់ថា ការជួសជុលតាមរបៀបបុរាណ ទាំងបច្ចេកទេសនិងសម្ភារៈ នឹងទទួលបានលទ្ធផលនិងគុណភាពល្អជាប់បានយូរដូចបុរាណដែរ ហើយក្រោយពីបញ្ចប់ការជួសជុលនៅកំពែងប្រាសាទបន្ទាយក្តី ជ្រុងពាយ័ព្យ នាយកដ្ឋានអភិរក្សក្នុងឧទ្យាន ក៏មានគម្រោងជួសជុលនៅទីតាំងផ្សេងៗនៃកំពែងនិងតួប្រាសាទផងដែរ ព្រោះវាមានសភាពទ្រុឌទ្រោមខ្លាំងច្រើនកន្លែង ដែលទាមទារឱ្យមានការសង្គ្រោះបន្ទាន់៕









ប្រតិភូនៃកិច្ចប្រជុំសេដ្ឋកិច្ចពិភពលោកមកទស្សនាអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

ក្រោយបញ្ចប់កិច្ចប្រជុំសេដ្ឋកិច្ចពិភពលោក នាទីក្រុងភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧នេះ គណៈប្រតិភូនៃកិច្ចប្រជុំនេះដែលមានសមាជិកជាង១០០រូប បានមកទស្សនាប្រាង្គប្រាសាទបុរាណនានាក្នុងរមណីយដ្ឋានអង្គរ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក។

អាជ្ញាធរជាតិអប្សរា ក្នុងឋានៈជាស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ បានទទួលស្វាគមន៍គណៈប្រតិភូយ៉ាងកក់ក្តៅ និងបញ្ជូនមន្ត្រីជំនាញផ្នែកប្រវត្តិសាស្ត្រ និងបុរាណវិទ្យាដើម្បីអមដំណើរជាមគ្គុទ្ទេសក៍ដល់គណៈប្រតិភូ ដោយធ្វើដំណើរទស្សនាបានចំនួន៣ប្រាសាទធំៗគឺ ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទតាព្រហ្ម។

មានប្រសាសន៍ស្វាគមន៍ក្នុងឱកាសទទួលដំណើរមកដល់របស់គណៈប្រតិភូនេះ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា បានពន្យល់ដល់គណៈប្រតិភូអំពីដំណាក់កាលវិវត្តន៍សំខាន់ៗបន្ទាប់ពីការបញ្ចូលអង្គរជាសម្បត្តិបេតិកភណ្ឌពិភពលោករួចមក ដូចជា ការបង្កើតគណៈកម្មាធិការអន្តរជាតិ ICC-Angkor ការបង្កើតអាជ្ញាធរជាតិអប្សរា ការបង្កើតច្បាប់ការពារបេតិកភណ្ឌ និងការទទួលបានសន្តិភាពពេញលេញលើផ្ទៃប្រទេស តាមរយៈគោលនយោបាយឈ្នះៗ របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រហូតធ្វើឲ្យអង្គរលែងជាបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ចាប់ពីឆ្នាំ២០០៤មក។ ចាប់ពីពេលនោះហើយ ដែលកិត្តិសព្ទអង្គរបានល្បីល្បាញទៅកាន់ពិភពលោកកាន់តែខ្លាំងឡើងៗ រហូតទទួលបានការបោះឆ្នោតគាំទ្រថាជាគោលដៅទេសចរណ៍ស្រស់ស្អាតបំផុតលើពិភពលោក ពីសំណាក់គេហទំព័រដ៏ធំរបស់ពិភពលោកដូចជា Trip Advisor និង Lonely planet ជាដើម។

ជាមួយគ្នានេះដែរ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះក្រុមប្រតិភូដែលបានចំណាយពេលមកទស្សនារមណីយដ្ឋានអង្គរ ហើយសង្ឃឹមថា ក្រុមប្រតិភូនឹងវិលមកទស្សនាអង្គរលើកក្រោយៗទៀត ដោយសារតែកម្មវិធីទស្សនានៅពេលនេះមានរយៈពេលខ្លី មិនអាចទស្សនាបានច្រើនទីតាំងសំខាន់ៗក្នុងរមណីយអង្គរទាំងមូល៕

អាជ្ញាធរជាតិអប្សរារួមចំណែកក្នុងការកសាងមណ្ឌលរដ្ឋបាលមន្ទីរខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីរ័ត្ន រូបភាព ៖ ហ៊ីង ស្រីរ័ត្ន

មណ្ឌលរដ្ឋបាលខេត្តសៀមរាបដ៏ប្រណីត ដែលមានទីតាំងនៅតាមបណ្តោយផ្លូវ៦០ម៉ែត្រ (ផ្លូវអង្គរយ្យុងយូ) បានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការកាលពីព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៧ ក្រោមអធិបតីភាព **ឯកឧត្តម ឧៀ ឃុញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការពារជាតិ ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងព្រះសង្ឃ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់។

យោងតាមរបាយការណ៍ **ឯកឧត្តម យីម ប៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាបបានឱ្យដឹងថា ដំណើរការសាងសង់មណ្ឌលរដ្ឋបាលមន្ទីរខេត្តចាប់ផ្តើមពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ ដោយក្រុមហ៊ុន កាំត្រង់ស៊ីប លើផ្ទៃដីទំហំ៦ ហិកតា មានអគារមន្ទីរជំនាញសរុបចំនួន២៦ មន្ទីរជាប្រភេទអគារភ្លោះចំនួន១២អគារ និងអគារទោលចំនួន២អគារ ហើយអគារនីមួយៗមានទំហំ២០.៥០ម៉ែត្រX២៣.៨០ម៉ែត្រ មានចំនួន២ជាន់ ១៥បន្ទប់ មានសាលប្រជុំមួយ ឃ្លាំងទុកដាក់សម្ភារៈ និងបន្ទប់សម្រាប់ទុកដាក់ឯកសារចំនួន៣បន្ទប់។ បន្ថែមពីនេះក៏មានផ្ទៃដីចំនួន២,៥០ហិកតា សម្រាប់ធ្វើទីលានសាធារណៈ និងដីបម្រុងចំនួន០,៦៣ ហិកតាផងដែរ។

ទាក់ទងនឹងការសាងសង់នេះដែរ អាជ្ញាធរជាតិអប្សរាក៏បានរួមចំណែកក្នុងការផ្តល់ដីចំនួន៩ហិកតាតាមការស្នើសុំរបស់សាលាខេត្តសៀមរាប ដែលស្ថិតក្នុងអតីតដីបុរីវប្បធម៌ និងទេសចរណ៍ដើម្បីសាងសង់មណ្ឌលមន្ទីរខេត្ត។ បន្ថែមពីនោះ អាជ្ញាធរជាតិអប្សរាក៏បានជួយសិក្សាប្លង់ស្ថាបត្យកម្មនៃសំណង់ផងដែរ ហើយចំពោះមូលហេតុនៃការអនុញ្ញាតឱ្យសាលាខេត្ត សាងសង់មណ្ឌលមន្ទីរ គឺយោងទៅលើលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ១៥០៤ សជណ រាជធានីភ្នំពេញ, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ បាននិយាយពីការដោះដូរបុរីរដ្ឋបាលខេត្តសៀមរាបមកកាន់ទីតាំងនៃអាជ្ញាធរជាតិអប្សរា ហើយអាជ្ញាធរជាតិអប្សរាប្តូរទៅកាន់ទីតាំងបុរីរដ្ឋបាលខេត្តសៀមរាបវិញ។









អាជ្ញាធរជាតិអប្សរាសហការជាមួយស្ថានទូតអាមេរិកប្រចាំកម្ពុជាបណ្តុះបណ្តាលមន្ត្រីលើជំនាញគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

មន្ត្រីជំនាញផ្នែកគ្រប់គ្រងទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា ទទួលបានវគ្គបណ្តុះបណ្តាលបន្ថែមជំនាញលើការងារគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌ។ កម្មវិធីនេះរៀបចំឡើងដោយអាជ្ញាធរជាតិអប្សរា ក្រោមជំនួយឧបត្ថម្ភរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជាក្នុងក្របខណ្ឌ Fulbright Specialist Program។

មន្ត្រីជំនាញ រួមទាំងប្រធាន និងអនុប្រធានភ្នាក់ងារទេសចរណ៍ប្រចាំនៅតាមប្រាសាទសរុបចំនួន៦៥រូប បានចូលរួមវគ្គបណ្តុះបណ្តាលនេះ ចំនួន២វគ្គ ដោយវគ្គទី១ ចាប់ផ្តើមពីថ្ងៃទី១៥ ដល់ទី២៨ ខែឧសភា ឆ្នាំ២០១៧ និងវគ្គទី២ ចាប់ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ សីហា ឆ្នាំ២០១៧។

ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនារសៀលថ្ងៃទី១៦ ខែឧសភានេះ **លោកស្រីបណ្ឌិត** Claudia G.Green ដែលមានបទ-ពិសោធន៍ ការងារបង្រៀនលើវិស័យទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌក្នុងបណ្តាប្រទេសជាច្រើន និងជាគ្រូបង្គោលក្នុងកម្មវិធីនេះបញ្ជាក់ថា "ខ្ញុំពិតជារីករាយដែលទទួលបានឱកាសនេះ។ ក្នុងវគ្គនេះ ខ្ញុំនឹងមិនព្យាយាមនិយាយច្រើនទេ តែខ្ញុំចង់ស្តាប់បញ្ហារបស់អ្នករាល់គ្នា ហើយខ្ញុំនឹងចែករំលែកបទពិសោធន៍របស់ខ្ញុំដើម្បីរួមចំណែកបន្ថែមលើចំណុចខ្វះខាត"។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ថា មន្ត្រី និងភ្នាក់ងាររបស់អាជ្ញាធរជាតិអប្សរាគឺជាភ្នាក់ងារបម្រើសេវាកម្មទេសចរណ៍ ដែលត្រូវគិតគូរទាំងគុណភាពនៃសេវាកម្មទេសចរណ៍ និងគិតគូរពីផលប៉ះពាល់នៃភ្ញៀវទេសចរមកលើប្រាសាទរបស់យើង។ ដូច្នេះ យើងត្រូវតែសិក្សាបន្ថែមសមត្ថភាពរបស់យើង ក្នុងន័យធ្វើយ៉ាងណាឲ្យភ្ញៀវទេសចរដែលមកទស្សនាអង្គរទទួលបានបទពិសោធន៍ដ៏ល្អបំផុត តែផ្តល់ផលប៉ះពាល់ដ៏តិចបំផុតដល់តំបន់រមណីយដ្ឋានអង្គរ។

វគ្គសិក្សានេះបែងចែកជាពីរក្រុមគឺ មន្ត្រីជំនាញនឹងសិក្សាអំពីការងារគ្រប់គ្រងទេសចរណ៍ ស្ថិតិ និងវិធីសាស្ត្រវិភាគទិន្នន័យ និងសិក្សាអំពីបទពិសោធន៍នៃការគ្រប់គ្រងទេសចរណ៍ពិភពលោក ដោយប្រៀបជាមួយនឹងការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់អង្គរ។ ចំណែកភ្នាក់ងារទេសចរណ៍សិក្សាបង្កើនចំណេះដឹងផ្នែកភាសាអង់គ្លេស និងសិក្សាអំពីសេវាកម្ម និងការងារគ្រប់គ្រងលំហូរភ្ញៀវទេសចរ៕









សារមន្ទីរវាយនកណ្ដាលបើកឲ្យទស្សនាដោយឥតគិតថ្លៃក្នុងថ្ងៃទិវាសារមន្ទីរអន្តរជាតិ

ផ្សាយនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី

អាជ្ញាធរជាតិអប្សរា សហការជាមួយសារមន្ទីរវាយនកណ្ដាប្រពៃណីអាស៊ី អិម ជី ស៊ី នឹងបង្កើតឲ្យមានការចូលទស្សនាដោយឥតគិតថ្លៃ នៅសារមន្ទីរវាយនកណ្ដាប្រពៃណីអាស៊ី ដើម្បីចូលរួមអបអរទិវាសារមន្ទីរអន្តរជាតិ ១៨ ឧសភា។

កម្មវិធីអបអរសាទរ បើកទស្សនាដោយសេរីនៅក្នុងសារមន្ទីរវាយនកណ្ដាប្រពៃណីអាស៊ី នឹងធ្វើឡើងនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧នេះ ចាប់ពីម៉ោង៨កន្លះព្រឹកតទៅ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាសារមន្ទីរអន្តរជាតិ និងក្រុមប្រឹក្សាសារមន្ទីរជាតិ។ សូមសាធារណជនទាំងអស់ មកចូលរួមទស្សនាការដាក់បង្ហាញនូវផលិតផលប្រពៃណីដ៏សម្បូរបែបនៅក្នុងសារមន្ទីរវាយនកណ្ដាប្រពៃណីអាស៊ី ដែលមានទីតាំងនៅផ្លូវ៦០ម៉ែត្រ ខាងត្បូងរង្វង់មូល ក្នុងភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប។

គួរម្លឹកថា សារមន្ទីរវាយនកណ្ដាប្រពៃណីអាស៊ី ជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលឥណ្ឌាជាមួយបណ្ដាប្រទេសតំបន់ទន្លេមេគង្គរួមមានរដ្ឋាភិបាលកម្ពុជា វៀតណាម ថៃ មីយ៉ាន់ម៉ា និងឡាវ៕



ចម្លាក់ផ្កាឈូកដ៏ធំនៅលើរានហាលព្រះលានដល់ដំរីនឹងលេចចេញរូបរាងឡើងវិញនៅខែសីហាខាងមុខនេះ

ផ្សាយនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនសិរ

នៅលើរានហាលនៃព្រះលានដល់ដំរីផ្នែកខាងជើង ក្បែរចម្លាក់ស្តេចគម្លង់ ដែលអ្នកស្រុកទម្លាប់ហៅថា កន្លែងដំរីក្បាលពីរ សេះក្បាលប្រាំ មានចម្លាក់ផ្កាឈូកក្រពុំដ៏ធំ ដែលត្រូវបានកសាងឡើងក្នុងសម័យក្រោយបាយ័ន។ ចម្លាក់ផ្កាឈូកនេះមានកម្ពស់១ម៉ែត្រកន្លះ និងអង្កត់ផ្ចិត៣ម៉ែត្រកន្លះ ផ្គុំឡើងពីដុំថ្មកក់តូចធំចំនួន៦៩ដុំ និងទ្រដោយទម្រថ្មបាយក្រៀម។

នៅអំឡុងពាក់កណ្តាលឆ្នាំ២០១៥ នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ទឹកហូរច្រោះគ្រឹះ ធ្វើឲ្យចម្លាក់ផ្កាឈូកនេះ បានរបេះធ្លាក់ថ្មដែលជាត្របកផ្កាឈូកអស់មួយចំនួននៅជ្រុងនិរតី។ ជាការបន្ទាន់ ក្រុមជំនាញនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរាបានរៀបចំទល់ទ្របណ្តោះអាសន្នបង្ការការធ្លាក់របេះបន្ថែម ព្រមទាំងរៀបចំផែនការដើម្បីជួសជុលឡើងវិញ។

ចាប់ពីពាក់កណ្តាលឆ្នាំ២០១៦មក ក្រុមការងារអភិរក្សបានចាប់ផ្តើមជួសជុលចម្លាក់ផ្តាំឈូកនេះ ហើយតាមគម្រោងការងារជួសជុលនេះនឹង បញ្ចប់នៅរវាងខែសីហា ឆ្នាំ២០១៧ខាងមុខ។ ក្រោយការជួសជុលរៀបចំឡើងវិញហើយ ភ្ញៀវទេសចរគ្រប់ជាតិសាសន៍នឹងបានឃើញនូវផ្តាំឈូកដ៏ធំនេះឡើងវិញ។

លោក ម៉ៅ សុខនី ស្ថាបត្យករ ដែលដឹកនាំការងារជួសជុលនេះ បញ្ជាក់ថា នៅឆ្នាំ១៩៩៥ សាលាបារាំងចុងបូព៌ាធ្លាប់បានជួសជុលចម្លាក់ផ្តាំឈូកនេះម្តងរួចមកហើយ។ ដោយឡែក ការជួសជុលនៅពេលនេះ ថ្វីត្បិតតែអ្នកជំនាញផ្នែកជាអ្នកកាន់ការងារជួសជុល តែក៏មានការត្រួតពិនិត្យ និងផ្តល់អនុសាសន៍ពីអ្នកជំនាញនៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរផងដែរ។

ចំពោះបច្ចេកទេសនៃការជួសជុល **លោក សុខនី** រៀបរាប់ថា "យើងបានរៀបចំបាតគ្រឹះឡើងវិញ ជួសជុលត្របកផ្តាំឈូកដែលធ្លាក់បាក់ ប្រើបច្ចេកទេសដែកទាមដូចសម័យបុរាណដែរ ដើម្បីទាមថ្មពីមួយដុំទៅមួយដុំឲ្យជាប់គ្នានិងរឹងមាំ។ ជាមួយគ្នានេះ ក្រុមការងារបានប្រើប្រាស់ថ្មចាស់ៗដែលមានស្រាប់ និងប្រើប្រាស់ថ្មថ្មីក្នុងកម្រិតអប្បបរមាដើម្បីជំនួសថ្មចាស់បាត់ឬមានគុណភាពមិនអាចយកមកប្រើប្រាស់ឡើងវិញបាន។ ជាក់ស្តែង ការជួសជុលផ្តាំឈូកនេះ ក្រុមការងារបានប្រើប្រាស់ថ្មថ្មីចំនួន៤ដុំបំពេញបន្ថែមជំនួសថ្មចាស់ដែលបាត់រកមិនឃើញ ដើម្បីឲ្យមានលំនឹងជាប់បានយូរ។

រហូតមកដល់ពេលនេះ ការងារជួសជុលសម្រេចបានប្រហែល៧០%ហើយ ដោយបានរៀបគ្រឹះ និងស្រទាប់ត្របកឈូកទី១ក៏បានរួចរាល់ ហើយកំពុងបន្តរៀបត្របកទី២ និងកំពូលបន្តិចប៉ុណ្ណោះ។

សូមបញ្ជាក់ថា ការជួសជុលប្រាង្គប្រាសាទ គឺជាការងារអាទិភាពនៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ។ ដើម្បីឲ្យការងារនេះបានជោគជ័យរាជរដ្ឋាភិបាលកម្ពុជា ដែលមានអាជ្ញាធរជាតិអប្សរាជាសេនាធិការ បានសម្របសម្រួលជាមួយស្ថាប័នអន្តរជាតិជាច្រើនដើម្បីមកចូលរួមការងារអភិរក្សជួសជុល។

ជាក់ស្តែង ចាប់ពីឆ្នាំ១៩៩២មក មានស្ថាប័នអន្តរជាតិចំនួន២១ មកពី១៣ប្រទេស បានអនុវត្តគម្រោងអភិរក្ស និងជួសជុលប្រាសាទចំនួន៣១គម្រោង។ ប្រទេសទាំង១៣នោះរួមមាន ចិន សាធារណរដ្ឋឆែក បារាំង អាឡឺម៉ង់ ឥណ្ឌា ឥណ្ឌូណេស៊ី អ៊ីតាលី ជប៉ុន ស្វីស អាមេរិក អូស្ត្រាលី ហុងគ្រី និងសាធារណរដ្ឋកូរ៉េ។

ទន្ទឹមនឹងការចូលរួមរបស់ស្ថាប័នអន្តរជាតិ អាជ្ញាធរជាតិអប្សរាក៏មានក្រុមការងារអភិរក្សជួសជុលដោយផ្ទាល់ផងដែរ។ ក្រុមការងារទាំងនេះកំពុងអនុវត្តការងាររបស់ខ្លួននៅលើការដ្ឋានជាច្រើនដូចជា នៅកំពែងអង្គរធំ ព្រះលានដល់ដំរី ច្រាំងកសិន្ទ ប្រាសាទអង្គរវត្ត ជួសជុលចម្លាក់តោនៅប្រាសាទក្រវ៉ាន់ ជួសជុលចម្លាក់នាគនៅប្រាសាទប្រែរូប ជួសជុលចង្រឹងបង្អួចនៅប្រាសាទអង្គរវត្ត ជួសជុលប្រាសាទឥដ្ឋនៅប្រាសាទព្រះគោ និងប្រាសាទលលៃ ជួសជុលប្រាសាទ និងរចនាសម្ព័ន្ធនៅប្រាសាទគោកចក។ល។









អ្នកស្រាវជ្រាវយល់ថា ចម្លាក់នៅតាមថែវនៃប្រាសាទអង្គរវត្តមានទំនាក់ទំនងទៅនឹងយុគទាំង៨របស់ចក្រវាឡនៃសាសនាហិណ្ឌូ

ផ្សាយនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ដោយសារតែប្រាសាទអង្គរវត្តត្រូវបានកសាងឡើងឧទ្ទិសដល់ព្រះនារាយណ៍នៃព្រហ្មញ្ញសាសនា ដូច្នេះហើយ ទើបចម្លាក់ជាច្រើនពិព័ណ៌នាអំពីរឿងរ៉ាវក្នុងព្រហ្មញ្ញសាសនា ជាពិសេសទាក់ទងរឿងរ៉ាងនៃព្រះនារាយណ៍។ ហើយអ្វីដែលកាន់តែអស្ចារ្យទៅទៀតនោះ គឺចម្លាក់ទាំងនេះបានបង្ហាញអំពីការវិវត្តនៃចក្រវាឡថែមទៀតផង។

នៅលើថែវទី៣នៃប្រាសាទអង្គរវត្ត ដែលមានប្រវែងជិត ៦០០ ម៉ែត្រ និងកម្ពស់ ២ម៉ែត្រ មានចម្លាក់ចំនួន៨ផ្ទាំង ដែលពណ៌នានូវរឿងរ៉ាវ ផ្សេងៗពាក់ព័ន្ធនឹងទេវកថានៃព្រហ្មញ្ញសាសនា អមនឹងរឿងរ៉ាវមួយចំនួនដែលកើតមានឡើងនៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ ដែលព្រះអង្គជាក្សត្របានកសាងប្រាសាទនេះឡើង។

អ្នកស្រាវជ្រាវ និងជាអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា **លោក បណ្ឌិត អ៊ា ដារិទ្ធ** ជឿជាក់ថា ចម្លាក់ទាំង៨ផ្ទាំងលើថែវទី៣នៃប្រាសាទអង្គរវត្ត គឺមានការពាក់ព័ន្ធទៅនឹងដំណើរវិវត្តរបស់ចក្រវាឡ តាមរយៈការបែងចែកយុគក្នុងជំនឿនៃសាសនានេះ។

លោកបណ្ឌិតបញ្ជាក់ថា តាមទស្សនៈរបស់ព្រហ្មញ្ញសាសនា ចក្រវាឡទាំងមូលត្រូវបានបែងចែកជា៤យុគគឺ៖

១. ក្រឹតយុគ ឬ យុគមាស (១.៧២៨.០០០ឆ្នាំមនុស្ស=៤.៨០០ឆ្នាំទេព) គឺសម័យកាលដែលសត្វលោកមានគុណធម៌ពេញលេញ ១០០% ហើយមនុស្សលោកមានអាយុវែង និងមានសេចក្តីសុខច្រើន។

២. ត្រេតយុគ ឬ យុគប្រាក់ (១.២៩៦.០០០ឆ្នាំមនុស្ស=៣.៦០០ឆ្នាំទេព) គឺសម័យកាលដែលសត្វលោកមានគុណធម៌បង្គួរ ថយចុះនៅសល់៧៥%, ហើយមនុស្សលោកមានអាយុវែងល្មម និងមានសេចក្តីសុខល្មម។

៣. ទ្វាបរយុគ (៨៦៤.០០០ឆ្នាំមនុស្ស=២.៤០០ឆ្នាំទេព) គឺយុគដែលមានលេខគត់គូ គឺសម័យកាលដែលសត្វលោកមានគុណធម៌អន់ថយនៅសល់តែ៥០%។

៤. កលិយុគ (៤៣២.០០០ឆ្នាំមនុស្ស=១.២០០ឆ្នាំទេព)ជាយុគប្រកបដោយទោស ជម្លោះ ហើយសត្វលោកមានគុណធម៌នៅសល់តែ២៥%ប៉ុណ្ណោះ។ មនុស្សលោកសព្វថ្ងៃកំពុងរស់នៅក្នុងយុគនេះឯង ហើយមានសេចក្តីសុខតិចតួចណាស់។

ចម្លាក់ប្រាសាទអង្គរវត្តត្រូវបានឆ្លាក់ឡើង ដើម្បីបង្ហាញពីយុគទាំង៤នេះគឺ ចម្លាក់ពីរផ្នាំងនៅទិសខាងកើតតំណាងឲ្យក្រឹតយុគ ដែលបង្ហាញនូវភាពស្អាត ភាពបរិសុទ្ធ មនុស្សនៅមានសច្ចភាពពេញលេញ។ ចម្លាក់ទាំងនោះជារឿងរ៉ាវនៃទេពសុទ្ធសាធ ដោយមានរឿងកូរសមុទ្រទឹកដោះ និងជ័យជម្នះព្រះនារាយណ៍ លើពួកអសុរទាំងឡាយ។

ចម្លាក់ពីរផ្នាំងបន្ទាប់នៅទិសខាងជើង តំណាងឲ្យត្រេតយុគ ជាយុគដែលមនុស្សមានគុណធម៌ថមថយចុះខ្លះ តែក៏នៅក្នុងភាពល្អប្រសើរគ្រាន់ជាងពាក់កណ្តាល។ ចម្លាក់ទាំងនោះបង្ហាញពីរឿងរ៉ាវចម្បាំងគ្នារវាងទេពនិងពួកអសុរ ដោយមានរឿងជ័យជម្នះនៃព្រះក្រឹស្ណៈលើស្តេចអសុរឈ្មោះពាន និងចម្បាំងរវាងទេពផ្សេងៗជាមួយនឹងពួកអសុរ។

ចម្លាក់ពីរផ្នាំងនៅទិសខាងលិច តំណាងឲ្យទ្វាបរយុគ ជាយុគដែលមនុស្សលោកនៅសល់គុណធម៌តែពាក់កណ្តាល ដោយឆ្លាក់នូវរឿងរាមកេរ្តិ៍និងរឿងមហាភារត ដែលមានសាច់រឿងលំនាំជាទេពពាក់កណ្តាល និងមនុស្សពាក់កណ្តាល។

ចម្លាក់ពីរផ្នាំងចុងក្រោយគេ គឺនៅទិសខាងត្បូង ដែលតំណាងឲ្យកលិយុគ ជាយុគដែលយើងកំពុងរស់នៅសព្វថ្ងៃ។ ចម្លាក់ទាំងពីរផ្នាំងនេះឆ្លាក់នូវរឿងរ៉ាវនានាដែលកើតមានក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ និងបញ្ចប់ទៅដោយចម្លាក់នរកសួគ៌ ដែលបង្ហាញអំពីទីបញ្ចប់នៃចក្រវាឡ ដែលមានមនុស្សខ្លះឡើងទៅស្ថានសួគ៌ និងមនុស្សខ្លះធ្លាក់ចុះនរក៕



រឿងមហាភារត ៖ មរណភាពរបស់ គិស្ន បងប្អូនប្រុស៥នាក់របស់បណ្ដាពអង្គុយខាងលើ និងគោរពអង្គុយខាងក្រោម (ថ្ងៃខាងលិចស្ថាបខាងត្បូង)



រឿងមហាភារត ៖ ព្រះក្រឹស្ណបរាជ័យអជុន (ថ្ងៃខាងលិច ស្ថាបខាងត្បូង)



ក្រឹស្ត្រៈលើកភ្នំគោវឌ្ឍនៈការពារក្មេងគង្វាល និងសត្វពាហនៈ (ព្រះពន្លាជ្រុងនិរតី)



រឿងរាមកេរ្តិ៍ ៖ព្រះរាមសម្លាប់ស្តេចស្វាពាលី (ព្រះពន្លាជ្រុងនិរតី)

ស្ពានអណ្តែតទឹកនៅមុខប្រាសាទអង្គរវត្តគ្រោងដាក់សម្ពោធជាផ្លូវការនៅថ្ងៃទី២៥ ឧសភា

ផ្សាយនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ ហ៊ុំ រឹទ្ធី

ស្ពានអណ្តែតទឹក ដែលជាសំណង់ដែលសង់កាត់កសិន្ទុប្រាសាទអង្គរវត្ត គ្រោងនឹងដាក់សម្ពោធជាផ្លូវការនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ខាងមុខនេះ។ ពិធីនេះធ្វើឡើងក្រោមអធិបតីភាព **លោកជំទាវ គ្រឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា។

ស្ពានអណ្តែតទឹកដែលត្រូវបានបើកការដ្ឋានសង់តាំងពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦នោះ នឹងដាក់សម្ពោធជាផ្លូវការហើយនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧។ ស្ពានហាលខាងលិចមុខប្រាសាទអង្គរវត្តនឹងផ្អាកលែងឱ្យភ្ញៀវទេសចរធ្វើដំណើរការឆ្លងកាត់ទាំងស្រុង ក្នុងអំឡុងពេលដែលស្ពាននេះកំពុងដំណើរការជួសជុលដោយសាកលវិទ្យាល័យសូហ្វីយ៉ា នៃប្រទេសជប៉ុន សហការជាមួយអាជ្ញាធរជាតិអប្សរា។ ការផ្អាកលែងឲ្យភ្ញៀវទេសចរឆ្លងកាត់ គឺដើម្បីបញ្ជៀសគ្រោះថ្នាក់ និងទុកលទ្ធភាពឲ្យក្រុមការងារជួសជុលស្ពានហាលនេះបានល្អប្រសើរ។

ក្នុងដំណាក់កាលកំពុងសាងសង់នេះ អាជ្ញាធរជាតិអប្សរាសម្រេចសាងសង់ស្ពានអណ្តែតទឹកបណ្តោះអាសន្នមួយដែលមានទទឹង១០ម៉ែត្រ និងបណ្តោយ២២០ម៉ែត្រ សម្រាប់ឲ្យភ្ញៀវទេសចរអាចចូលទៅទស្សនាប្រាសាទអង្គរបានតាមធម្មតា។ ស្ពាននេះសង់ពីពោងទឹកដែលនាំយកមកពីប្រទេសកាណាដា ដែលមានការធានាគុណភាព និងសុវត្ថិភាពត្រឹមត្រូវពីក្រុមហ៊ុនរយៈពេល៥ឆ្នាំ។









សមិទ្ធផលសំខាន់ៗនៃការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា រយៈពេល៣សប្តាហ៍ដំបូងក្នុងខែឧសភានេះ

ផ្សាយនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ក្រុមការងារសហគមន៍

ដើម្បីផ្សព្វផ្សាយអំពីការងារអភិរក្សបេតិកភណ្ឌអង្គរឲ្យប្រជាពលរដ្ឋបានយល់ដឹង និងចូលរួមថែរក្សាការពារក្នុងនាមជាអ្នករស់នៅផ្ទាល់ជាមួយបេតិកភណ្ឌអង្គរ អាជ្ញាធរជាតិអប្សរាបានបង្កើតក្រុមការងារសហគមន៍មួយ ដើម្បីចុះទៅជួបប្រជាពលរដ្ឋជាប្រចាំរៀងរាល់ថ្ងៃទាំង១១២ភូមិក្នុងរមណីយដ្ឋានអង្គរ។

ដំណាលគ្នានឹងការបញ្ជ្រាបចំណេះដឹងដល់ពួកគាត់ ក្រុមការងារសហគមន៍ក៏បានដោះស្រាយសំណើ និងបញ្ហានានាដែលប្រជាពលរដ្ឋក្នុងតំបន់អង្គរជួបប្រទះផងដែរ។ ជាក់ស្តែង សម្រាប់ខែឧសភា ឆ្នាំ២០១៧នេះ ដោយគិតត្រឹម៣សប្តាហ៍ដំបូង ក្រុមការងារសហគមន៍បានចុះពិនិត្យសំណើសុំជួសជុលផ្ទះសម្បែង និងសាងសង់សំណង់តូចៗបានចំនួន១៤៤ករណី និងអនុញ្ញាតបានចំនួន១០៣ករណីនៅទីតាំងផ្ទាល់។

ក្រៅពីដោះស្រាយបញ្ហាសាងសង់ ក្រុមការងារក៏បាននាំយកអំណោយកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារកបស់អាជ្ញាធរជាតិអប្សរា ទៅចែកជូនស្ត្រីទើបសម្រាលបុត្រក្នុងតំបន់អង្គរបានចំនួន១០៥នាក់ ដោះស្រាយថវិកាគោលនយោបាយជីផ្លី២គ្រួសារ និងឧបត្ថម្ភថវិកាដល់ប្រជាពលរដ្ឋចំនួន១៣គ្រួសារ ដែលរងការខូចខាតដោយសារស្រូវលិចទឹកក្នុងឆ្នាំ២០១៦កន្លងទៅ។

មិនត្រឹមតែប៉ុណ្ណោះ ក្រុមការងារសហគមន៍ក៏បានចូលរួមឧបត្ថម្ភថវិកាកាត់សម្លៀកបំពាក់ជូនប្រជាការពារភូមិលាងដៃ ចូលរួមឧបត្ថម្ភបុណ្យសព និងចូលរួមក្នុងវេទិកាសាធារណៈ ដើម្បីឆ្លើយតបនឹងសំណួរនានាដែលលើកឡើងដោយប្រជាពលរដ្ឋផងដែរ៕









អាជ្ញាធរជាតិអប្សរាចោះបង្គោលរបងជុំវិញប្រាសាទបាយ័ន្តដើម្បីលើកកម្ពស់សោភ័ណភាព និងសណ្តាប់ធ្នាប់ចរាចរណ៍

ផ្សាយនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីវ័ត្ន រូបភាព ៖ ហ៊ុំ រិទ្ធី

ក្រុមការងារអាជ្ញាធរជាតិអប្សរានៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានចាប់ដំណើរការចោះបង្គោលរបងជុំវិញប្រាសាទបាយ័ន្តកាលពីព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧។

លោក យិន សូរ៉ាត អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថានបានឱ្យដឹងថា ការចោះបង្គោលរបងនេះ ធ្វើឡើងក្នុងគោលបំណងលើកកម្ពស់សោភ័ណភាព និងសណ្តាប់ធ្នាប់ចរាចរណ៍ឱ្យបានល្អប្រសើរផងដែរនៅប្រាសាទបាយ័ន្ត។

លោក សូរ៉ាត បន្តទៀតថា បង្គោលរបងទាំងនោះ ជាក្រាក់រឹងមាំ កាត់តម្រឹមស្មើស្អាត មានប្រវែង១.២០ម៉ែត្រ ដឹកកប់ក្នុងដីជម្រៅកន្លះមែត្រ។ បង្គោលក្រាក់ដែលត្រូវប្រើទាំងអស់មានទាំងថ្មីនិងចាស់ ចំនួន៨០០ដើម រួមនឹងប្រើខ្សែកាបចំនួន ៦០០ម៉ែត្រជាងដើម្បីចងភ្ជាប់ ហើយការងារនេះគ្រោងនឹងបញ្ចប់ត្រឹមរយៈពេល២សប្តាហ៍៕






ប្រធានអាជ្ញាធរជាតិអប្សរាចុះទស្សនកិច្ចភូមិធម្មជាតិរុនតាឯក

ផ្សាយនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

នៅរសៀលថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានចុះទស្សនកិច្ចជាលើកដំបូងនៅភូមិធម្មជាតិរុនតាឯក។ ក្នុងទស្សនកិច្ចនេះ លោកជំទាវបានជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ សិស្សានុសិស្ស ព្រមទាំងពិនិត្យគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិធម្មជាតិរុនតាឯក ដែលស្ថិតក្រោមផែនការអភិវឌ្ឍន៍គម្រោងរបស់អាជ្ញាធរជាតិអប្សរា។

លោកជំទាវ ភឿង សកុណា បានសម្តែងអារម្មណ៍សប្បាយរីករាយ ពេលបំពេញទស្សនកិច្ចត្រួតពិនិត្យពីគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ដោយលោកជំទាវបានឃើញការរីកចម្រើនយ៉ាងពិតប្រាកដលើការងារអភិវឌ្ឍន៍កសិកម្ម។ ជាពិសេស លោកជំទាវប្រធានអាជ្ញាធរជាតិអប្សរា ក៏បានចុះទៅពិនិត្យដល់ទីកន្លែងនៃសកម្មភាពអនុវត្តគម្រោងអភិវឌ្ឍន៍នានា ដែលកំពុងដំណើរការក្នុងភូមិធម្មជាតិរុនតាឯកដូចជាគម្រោងអភិវឌ្ឍលើវិស័យកសិកម្ម នៃមជ្ឈមណ្ឌលលើកកម្ពស់កសិកម្មចិន-កម្ពុជា ហៅកាត់ថា CAPROC (China-Cambodia Agriculture Promotion Center) របស់ចិន និងការផលិតម្សៅម្រុំ ដែលកំពុងដំណើរការយ៉ាងល្អ ក្នុងភូមិអភិវឌ្ឍន៍មួយនេះជាដើម។ ក្នុងនោះ លោកជំទាវក៏បានផ្តល់នូវអនុសាសន៍មួយចំនួន ដើម្បីជាប្រយោជន៍សម្រាប់ការអភិវឌ្ឍភូមិគំរូនេះទៅអនាគត សំដៅធ្វើយ៉ាងណាឲ្យជីវភាពប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងភូមិរុនតាឯកទាំងអស់ មានភាពល្អប្រសើរ។ ទន្ទឹមនោះដែរ លោកជំទាវបានចែកសម្ភារសិក្សាមួយចំនួនដល់សិស្សានុសិស្ស និងសួរសុខទុក្ខដល់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងភូមិរុនតាឯកទាំងមូលផង។

នៅរសៀលថ្ងៃដដែលនោះ ក្រោយពីបញ្ចប់ទស្សនកិច្ចនៅភូមិរុនតាឯកហើយ លោកជំទាវប្រធានអាជ្ញាធរជាតិអប្សរា ក៏បន្តចុះត្រួតពិនិត្យទីតាំងបុរាណដ្ឋានមួយចំនួន រួមមានប្រាសាទភ្នំបូក និងប្រាសាទចៅស្រីវិបុល ដើម្បីស្វែងយល់ពីស្ថានភាពអភិរក្សនៃប្រាសាទទាំងនោះ ក៏ដូចជាដំណើរការនៃការអភិរក្សរបស់អាជ្ញាធរជាតិអប្សរា៕









ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តបើកជូនភ្ញៀវទេសចរធ្វើដំណើរជាផ្លូវការហើយ

ផ្សាយនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ស្ពានអណ្តែតទឹក ដែលត្រូវបានកសាងឡើងសម្រាប់ភ្ញៀវទេសចរធ្វើដំណើរជាបណ្តោះអាសន្នចូលទស្សនាប្រាសាទអង្គរវត្ត ក្នុងអំឡុងពេលដែលស្ពានហាលកំពុងទទួលការជួសជុលនោះ ត្រូវបានដាក់សម្ពោធបើកជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិប្រើប្រាស់ជាផ្លូវការហើយ នៅព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧នេះ។ ដោយឡែក ស្ពានហាលនៃប្រាសាទអង្គរវត្តនឹងត្រូវបិទផ្អាកការធ្វើដំណើរចាប់ពីពេលនេះ រហូតដល់ឆ្នាំ២០២០ បញ្ជៀសគ្រោះថ្នាក់ជាយថាហេតុដល់ភ្ញៀវទេសចរ និងដើម្បីបង្កលទ្ធភាពងាយស្រួលដល់ក្រុមការងារជួសជុល។

ពិធីសម្ពោធជាផ្លូវការត្រូវបានរៀបចំឡើងក្រោមអធិបតីភាព **ឧកញ៉ាឧត្តមសេនីយ៍ភ្លឿង សក្ដិណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ដោយមានការនិមន្តនិងអញ្ជើញចូលរួមពីព្រះសង្ឃ មន្ត្រីរាជការ ស្ថាប័នអន្តរជាតិ និងប្រជាពលរដ្ឋរាប់ពាន់នាក់។

ស្ពាននេះមានប្រវែងបណ្តោយ១៧០ម៉ែត្រ ទទឹង៨ម៉ែត្រ ស្មើនឹង១៣៦០ម៉ែត្រការ៉េ ប្រើប្រាស់ផ្ទៃពោងជ័រអណ្តែតទឹកសរុប ៦៧២០ដុំ អាចផ្ទុកចំនួនមនុស្សឈរលើស្ពានក្នុងពេលតែមួយបាន១៣៦០នាក់ ដោយគិតមួយម៉ែត្រការ៉េសម្រាប់មនុស្ស ម្នាក់។ ស្ពាននេះអាចផ្ទុកទម្ងន់សរុបបាន៤៥៧តោន ដោយក្នុងពោងជ័រមួយដុំអាចផ្ទុកបានទម្ងន់៦៨គីឡូក្រាម។ លក្ខណៈ ពិសេសរបស់ពោងអណ្តែតទឹកនេះ គឺជាប្រភេទជ័រ ស្វិត ធន់ ហើយអាចទទ្រង់នឹងអាកាសធាតុបានយ៉ាងល្អបំផុត មិនមាន ប្រតិកម្មនឹងពន្លឺថ្ងៃ និងភ្លៀង ថែមទាំងមិនធ្វើឲ្យទឹកប្រែពណ៌ ឬបង្កជាសារធាតុពុលផ្សេងៗដល់ទឹកឡើយ។

ថ្លែងក្នុងរបាយការណ៍ក្នុងឱកាសនេះ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរាបញ្ជាក់ថា ការកសាងស្ពាន អណ្តែតទឹកបណ្តោះអាសន្ននេះ បានឆ្លងយោបល់របស់ក្រុមជំនាញនៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ និងបានជ្រើសរើស ប្រភេទស្ពាននេះឡើង ដោយផ្តោតទៅលើតម្លៃ ពេលវេលានៃការសាងសង់ ការថែទាំ ភាពមិនប៉ះពាល់ដល់បុរាណដ្ឋាន ក្រោមទឹក និងភាពស៊ីសង្វាក់គ្នាទៅលើទេសភាពវប្បធម៌តំបន់អង្គរ។

មានប្រសាសន៍ក្នុងឱកាសនេះដែរ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធាន អាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណដល់ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា និងស្ថាប័នអន្តរជាតិនានាដែលបានខិត ខំបំពេញការងារអភិរក្សបេតិកភណ្ឌបានយ៉ាងល្អប្រសើរ។ ជាមួយគ្នានេះដែរ លោកជំទាវក៏បានរំឭកដល់គុណូបការៈដ៏ ធំធេងរបស់ **សម្តេចឧបុលបញ្ញា សុខ អាន** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជា ប្រធានអាជ្ញាធរជាតិអប្សរា ដែលបានបូជាអស់កម្លាំងកាយចិត្តប្រាជ្ញាស្មារតីដើម្បីដឹកនាំការងារអភិរក្ស និងអភិវឌ្ឍសម្បត្តិ បេតិកភណ្ឌវប្បធម៌ដែលជាមរតកដ៏ថ្លៃថ្លានៃដូនតាយើងឲ្យទទួលបានជោគជ័យជាបន្តបន្ទាប់។

លោកជំទាវបន្ថែមថា ស្ពានអណ្តែតទឹកនេះគឺជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលដ៏ធំធេងជាច្រើនទៀត នៃការងារ អភិរក្សរមណីយដ្ឋានអង្គរ។ សមិទ្ធផលទាំងអស់នេះ គឺសម្រេចបានដោយសារប្រទេសរួចផុតពីសង្គ្រាម មានសន្តិភាព បរិបូណ៌ពេញផ្ទៃប្រទេស ដែលកើតឡើងតាមរយៈគោលនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លោកជំទាវបញ្ជាក់ថា សង្គ្រាមមិនត្រឹមតែបំផ្លាញជីវិតមនុស្ស និងទ្រព្យសម្បត្តិប៉ុណ្ណោះទេ តែវាក៏បានបំផ្លិចបំផ្លាញនូវបេតិកភណ្ឌវប្បធម៌របស់ជាតិយ៉ាងច្រើនផងដែរ។ ដោយសារ សង្គ្រាម មរតកដ៏ថ្លៃថ្លារបស់ដូនតាយើងត្រូវទទួលរងនូវផលប៉ះពាល់ជាបន្តបន្ទាប់ ដោយសារកង្វះការថែរក្សា ព្រោះការរត់ គៀសសង្គ្រាមនៃប្រជាជនកម្ពុជាយើង។ ក៏ប៉ុន្តែ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនៃប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានបញ្ចប់សង្គ្រាមទាំងស្រុង នាំមកនូវសន្តិភាពជូនប្រជាជាតិកម្ពុជាទាំងមូល ក្នុងនោះរួមទាំងសុខុដុមភាពនៃសម្បត្តិ បេតិកភណ្ឌវប្បធម៌ជាតិផងដែរ៕









អបអរសាទរ! ប្រាសាទអង្គរវត្តរបស់ខ្មែរដាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុតលើពិភពលោកក្នុងឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ក្រោយការចូលរួមបោះឆ្នោតពីភ្ញៀវទេសចរជាប់លាននាក់ជុំវិញពិភពលោក គេហទំព័រដ៏ល្បីល្បាញ TripAdvisor បានផ្តល់ចំណាត់ថ្នាក់លេខ១ដល់ប្រាសាទអង្គរវត្តរបស់កម្ពុជា ជាសំណង់ដ៏មានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រអស្ចារ្យបំផុតរបស់ពិភពលោកសម្រាប់ឆ្នាំ២០១៧នេះ។

នេះគឺជាឆ្នាំទី៤ហើយ ដែលអង្គរត្រូវបានភ្ញៀវទេសចរលើពិភពលោកបោះឆ្នោតគាំទ្រ ហើយទទួលបានចំណាត់លេខ១ជាប់ៗគ្នាតាមរយៈគេហទំព័រដ៏ល្បីល្បាញផ្សេងៗគ្នា គឺ កាលពីឆ្នាំ២០១៤ អង្គរបានជាប់ចំណាត់ថ្នាក់លេខ១ នៅលើគេហទំព័រមួយដែលតែងតែយកតំបន់បុរាណវិទ្យា និងប្រវត្តិសាស្ត្រទាំងអស់លើពិភពលោកមកប្រៀបធៀបគ្នា នោះគឺគេហទំព័រ ArchaeoMadness។ បន្ទាប់មកទៀត នៅដើមឆ្នាំ២០១៥ អង្គរទទួលបានចំណាត់ថ្នាក់លេខ១ម្តងទៀតនៅលើគេហទំព័រអន្តរជាតិមួយ ដែលជាគេហទំព័រផ្សព្វផ្សាយតំបន់ទេសចរណ៍ល្បីៗលើពិភពលោក នោះគឺគេហទំព័រ TripAdvisor។ នៅឆ្នាំ២០១៦កន្លងទៅ អង្គរបានបន្តជាប់លេខ១បន្ថែមទៀត នៅលើគេហទំព័ររបស់ក្រុមហ៊ុន Lonely Planet ដែលជាគេហទំព័រផ្សព្វផ្សាយ និងជាប្រភពព័ត៌មានទេសចរណ៍ដ៏ល្បីមួយលើពិភពលោក មានទាំងព័ត៌មានតាមរយៈវីដេសាយ ទស្សនាវដ្តី និងសៀវភៅ ជាដើម។

នេះជាមោទនភាពមួយរបស់ជាតិខ្មែរយើងទាំងមូល ដែលអង្គរវត្តរបស់កម្ពុជាទទួលបានការគាំទ្រពីបណ្តាប្រជាជនជុំវិញពិភពលោក។ ក្នុងនាមស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរា សូមចូលរួមអបអរសាទរ និងសូមអំពាវនាវដល់សាធារណជនទាំងអស់បន្តចូលរួមថែរក្សា ការពារនូវបេតិកភណ្ឌរបស់ជូនតាយើងឲ្យបានខ្លាំងក្លាដើម្បីភាពគង់វង្សយូរអង្វែងតទៅ៕









ទស្សនវិស័យវែងឆ្ងាយអំពីការគ្រប់គ្រងបេតិកភណ្ឌរបស់រាជរដ្ឋាភិបាលកម្ពុជា នាំឲ្យអង្គរកាន់តែល្បីល្បាញលើពិភពលោក

ផ្សាយនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ុំ រិទ្ធី

នេះជាមោទនភាពថ្មីមួយទៀតសម្រាប់ប្រាសាទអង្គរវត្ត ដែលគេហទំព័រដ៏ល្បីល្បាញ TripAdvisor បានផ្តល់ចំណាត់ថ្នាក់លេខ១ ជាសំណង់ដ៏មានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រអស្ចារ្យបំផុតរបស់ពិភពលោកសម្រាប់ឆ្នាំ២០១៧នេះ ក្រោយការចូលរួមបោះឆ្នោតពីភ្ញៀវទេសចរជាច្រើនលាននាក់ជុំវិញពិភពលោក។

មោទនភាពនេះ យើងពិតជាមិនអាចបំភ្លេចបានចំពោះកិច្ចខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបាននាំមកនូវសុខសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ និងការអភិវឌ្ឍលើគ្រប់វិស័យពេញផ្ទៃប្រទេស។ ស្របតាមគោលនយោបាល ឈ្នះ-ឈ្នះ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន ព្រះរាជាណាចក្រកម្ពុជាបានផ្សារភ្ជាប់បណ្តាញគមនាគមន៍ផ្ទៃក្នុងបានយ៉ាងប្រសើរ ដែលចំណុចនេះបានជំរុញ និងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឲ្យធ្វើដំណើរបានគ្រប់ទីកន្លែងដោយគ្មានការព្រួយបារម្ភឡើយ។ បន្ថែមលើនេះ អ្នកវិនិយោគទុនបរទេសជាច្រើនបានមកបណ្តាក់ទុនវិនិយោគនៅកម្ពុជាលើគ្រប់វិស័យ ដែលធ្វើឱ្យពិភពលោកស្គាល់កម្ពុជាកាន់តែច្រើន។

ក្នុងនាមស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ ដែលចូលរួមលើកតម្លៃបេតិកភណ្ឌពិភពលោកឱ្យមានការទទួលស្គាល់ជាសកល អាជ្ញាធរជាតិអប្សរាក៏បានគិតគូរយ៉ាងខ្លាំងចំពោះការងារអភិរក្ស ការអភិវឌ្ឍទេសចរ សហគមន៍មនុស្ស និងការថែរក្សាបរិស្ថាន ព្រោះកត្តាទាំងនេះជាសមាសធាតុយ៉ាងសំខាន់ក្នុងការលើកតម្លៃអង្គរ ដោយប្រកាន់ខ្ជាប់តាមពាក្យស្លោក អភិវឌ្ឍន៍ដើម្បីអភិរក្ស អភិរក្សដើម្បីអភិវឌ្ឍន៍។ អាជ្ញាធរជាតិអប្សរា ក៏សូមចូលរួមអបអរសាទរ និងសូមអំពាវនាវដល់សាធារណជន ទាំងអស់បន្តចូលរួមថែរក្សា ការពារនូវបេតិកភណ្ឌរបស់ជូនតាយើងឱ្យបានខ្លាំងក្លាដើម្បីភាពគង់វង្សយូរអង្វែងតទៅ។

គួរឮកផងដែរថា នេះគឺជាឆ្នាំទី៤ហើយ ដែលអង្គរត្រូវបានភ្ញៀវទេសចរលើពិភពលោកបោះឆ្នោតគាំទ្រ ហើយទទួលបានចំណាត់លេខ១ជាប់ៗគ្នាតាមរយៈគេហទំព័រដ៏ល្បីល្បាញផ្សេងៗគ្នា គឺ កាលពីឆ្នាំ២០១៤ អង្គរបានជាប់ចំណាត់ថ្នាក់លេខ១ នៅលើគេហទំព័រមួយដែលតែងតែយកតំបន់បុរាណវិទ្យា និងប្រវត្តិសាស្ត្រទាំងអស់លើពិភពលោកមកប្រៀបធៀបគ្នា នោះគឺគេហទំព័រ ArchaeoMadness។ បន្ទាប់មកទៀត នៅដើមឆ្នាំ២០១៥ អង្គរទទួលបានចំណាត់ថ្នាក់លេខ១ម្តងទៀត នៅលើគេហទំព័រអន្តរជាតិមួយ ដែលជាគេហទំព័រផ្សព្វផ្សាយតំបន់ទេសចរណ៍ល្បីៗលើពិភពលោក នោះគឺគេហទំព័រ TripAdvisor។ នៅឆ្នាំ២០១៦កន្លងទៅ អង្គរបានបន្តជាប់លេខ១បន្ថែមទៀត នៅលើគេហទំព័ររបស់ក្រុមហ៊ុន Lonely Planet ដែលជាគេហទំព័រផ្សព្វផ្សាយ និងជាប្រភពព័ត៌មានទេសចរណ៍ដ៏ល្បីមួយលើពិភពលោក មានទាំងព័ត៌មានតាមរយៈវីដេសាយ ទស្សនាវដ្តី និងសៀវភៅជាដើម៕









មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរទទួលបានសៀវភៅថ្មី៧ក្បាលបន្ថែមពីដៃគូស្រាវជ្រាវ

ផ្សាយនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា ប៉ហ៊ីនី រូបភាព ៖ សេន សែត

ថ្មីៗនេះ មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា បានទទួលសៀវភៅថ្មីចំនួន៧ក្បាល ពីដៃគូស្រាវជ្រាវមួយចំនួន។ សៀវភៅទាំងនោះ និយាយពីការស្រាវជ្រាវផ្នែកបុរាណវិទ្យា ស្ថាបត្យកម្ម ។ល។

សៀវភៅទាំង៧ក្បាល ដែលអាជ្ញាធរជាតិអប្សរាទើបនឹងទទួលបាន ទី១ សៀវភៅ Art and Archaeology of South-East Asia ស្តីពីទំនាក់ទំនងរវាងប្រទេសឥណ្ឌា និងអាស៊ីអាគ្នេយ៍តាំងពីមុនមានសិលាចារឹក។ ទី២ សៀវភៅ Theory and practice of temple architecture in medieval India ដែលបង្ហាញពីការសាងសង់ប្រាសាទតាមគម្ពីរ Vastusastra។ ទី៣ សៀវភៅ Rama- Legends and Rama-reliefs in Indonesia ស្តីពីព្រះរាមក្នុងទស្សនៈ ឥណ្ឌូនេស៊ី។

ចំណែកសៀវភៅទី៤ មានឈ្មោះថា Research Report on Preah Vihear Temple ដែលជាការសរុបទិន្នន័យស្តីពីស្ថាបត្យកម្ម សិលាវិទ្យា បុរាណវិទ្យា-ល- របស់ប្រាសាទព្រះវិហារ។ ទី៥ សៀវភៅ IGNCA- A Retrospect ដែលជាលទ្ធផល២៥ឆ្នាំរបស់ Indira Gandhi National Center for the Art។ ទី៦ សៀវភៅ The Iconography of Avalokitesvara in Mainland South East Asia ដែលបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវអំពីព្រះពោធិសត្វ។ និងសៀវភៅទី៧ ឈ្មោះថា Pilgrimage បង្ហាញពីឥទ្ធិពលនៃធម្មយាត្រាទៅលើវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន...។

មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ ចាត់ទុកសៀវភៅទាំងអស់ជា សមិទ្ធផលថ្មី និងស្វាគមន៍ចំពោះការស្រាវជ្រាវបន្តពីសំណាក់សិស្សនិស្សិត នៅបណ្ណាល័យរបស់មជ្ឈមណ្ឌល។

គួរបញ្ជាក់ថា សៀវភៅ និងឯកសារស្រាវជ្រាវជាង២៥០០ច្បាប់ ដែលជាឯកសារកម្រ ផ្នែកបុរាណវិទ្យា នរវិទ្យា ប្រវត្តិសាស្ត្រ សាសនា សិល្បៈវប្បធម៌ សំណង់ស្ថាបត្យកម្មបុរាណ ភាសាវិទ្យា និងឯកសារជាច្រើនទៀតដែលស្តីពីទំនៀមទម្លាប់ប្រពៃណីខ្មែរ ជាពិសេសទំនៀមទម្លាប់ដែលកំពុងបន្តប្រតិបត្តិរបស់អ្នកស្រុកអង្គរ ត្រូវបានរក្សាទុកក្នុងបណ្ណាល័យអាជ្ញាធរ ជាតិអប្សរា៕





អង្គរវត្តនារដូវវស្សាស្រស់ស្អាតប្លែកម្យ៉ាងពីរដូវប្រាំង

ផ្សាយនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា ប៉ហ៊ីនី រូបភាព ៖ ហ៊ុំ រឹទ្ធី

ប្រាសាទអង្គរវត្ត ត្រូវបានចាត់ទុកថាជាដួងព្រលឹងនៃជាតិខ្មែរ។ ជារៀងរាល់ឆ្នាំ មានទេសចរជាតិ និងអន្តរជាតិច្រើនលាននាក់ដែលមកកម្សាន្តប្រាសាទអង្គរវត្ត។ នារដូវវស្សា ដែលមានភ្លៀងធ្លាក់ ធ្វើឲ្យទេសភាពនៅបរិវេណប្រាសាទអង្គរវត្ត មានភាពស្រស់បំព្រង និងគ្របដណ្តប់ដោយពណ៌ខៀវ និងបៃតង។

ចង់ដឹងថា តើទិដ្ឋភាពប្រាសាទអង្គរវត្តនារដូវវស្សានេះ មានភាពស្រស់ស្អាតកម្រិតណា សូមអញ្ជើញទស្សនារូបភាពមួយចំនួនខាងក្រោមនេះ ៖













ផ្នែកទី ៦
ប្រចាំខែមិថុនា

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាជួបជុំមន្ត្រីបុគ្គលិករបស់ខ្លួនដើម្បីដំរុញការចូលរួមបោះឆ្នោតឃុំសង្កាត់ខាងមុខនេះ

ផ្សាយនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី , សឿន ប៊ុនសីរ

នារសៀលថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧កន្លងទៅនេះ អាជ្ញាធរជាតិអប្សរាបានប្រារព្ធពិធីជួបជុំសំណេះសំណាលរវាងថ្នាក់ដឹកនាំជាមួយនឹងមន្ត្រីបុគ្គលិក ឆ្មាំ កម្មករប្រមាណជិត១ពាន់នាក់ នៅសាលសន្និសីទអង្គរ។

ពិធីជួបជុំនេះ ធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករង និងជាតំណាងឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ក្នុងគោលបំណងជំរុញឲ្យមន្ត្រីបុគ្គលិកទាំងអស់ចូលរួមបំពេញកាតព្វកិច្ចជាពលរដ្ឋក្នុងការបោះឆ្នោតឃុំសង្កាត់ដែលនឹងចូលមកដល់នៅថ្ងៃទី៤ ខែមិថុនាខាងមុខ។

មានប្រសាសន៍សំណេះសំណាលក្នុងឱកាសនេះ **ឯកឧត្តម សុខ សង្ហារ** បានរំឭកឲ្យមន្ត្រីបុគ្គលិកទាំងអស់ត្រៀមឯកសារឲ្យបានគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងការបោះឆ្នោតជ្រើសរើសមេឃុំចៅសង្កាត់តាមទីតាំងដែលខ្លួនបានចុះឈ្មោះរៀងៗខ្លួន។ ជាពិសេស ឯកឧត្តម ក៏បានអំពាវនាវឲ្យចូលរួមជ្រើសរើសមេឃុំចៅសង្កាត់នៃគណបក្សណាដែលអាចរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍជាក់ស្តែង។

ជាមួយគ្នានេះ ឯកឧត្តមក៏បានរំឭកឡើងវិញនូវសមិទ្ធផលសំខាន់ៗ នៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ និងដំណាក់កាលវិវត្តន៍សំខាន់ៗបន្ទាប់ពីការបញ្ចូលអង្គរជាសម្បត្តិបេតិកភណ្ឌពិភពលោករួចមក ដូចជា ការបង្កើតគណៈកម្មាធិការអន្តរជាតិ ICC-Angkor ការបង្កើតអាជ្ញាធរជាតិអប្សរា ការបង្កើតច្បាប់ការពារបេតិកភណ្ឌ និងការទទួលបានសន្តិភាពពេញលេញលើផ្ទៃប្រទេសតាមរយៈគោលនយោបាយឈ្នះ-ឈ្នះ របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រហូតធ្វើឲ្យអង្គរលែងជាបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ចាប់ពីឆ្នាំ២០០៤មក។ ចាប់ពីពេលនោះហើយ ដែលកិត្តិសព្ទអង្គរបានល្បីល្បាញទៅកាន់ពិភពលោកកាន់តែខ្លាំងឡើងៗ រហូតទទួលបានការបោះឆ្នោតគាំទ្រថាជាគោលដៅទេសចរណ៍ស្រស់ស្អាតបំផុតលើពិភពលោក ពីសំណាក់គេហទំព័រដ៏ធំរបស់ពិភពលោកដូចជា Trip Advisor និង Lonely planet ជាដើម។

ឯកឧត្តមបន្ថែមថា ភាពជោគជ័យទាំងអស់នេះ គឺកើតចេញពីកម្លាំងសាមគ្គីនៃថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកទាំងអស់របស់អាជ្ញាធរជាតិអប្សរា ដោយមានការចូលរួមជ្រោមជ្រែងពីស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិជាច្រើនទៀត៕






សម្រស់នាគព័ន្ធនារដូវដើមវស្សា

ផ្សាយនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

ប្រាសាទនាគព័ន្ធត្រូវបានសាងសង់ឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ជាប្រាសាទកោះ ស្ថិតនៅក្នុងបារាយណ៍ជ័យតដាក (បារាយណ៍ខាងជើង) ដូចជាប្រាសាទមេបុណ្យក្នុងបារាយណ៍ដទៃទៀតដែរ។ នៅសម័យបុរាណប្រាសាទនាគព័ន្ធមានតួនាទីមួយផ្សេងទៀត គឺជាមន្ទីរពេទ្យដែលប្រើប្រាស់រុក្ខជាតិជាឱសថបុរាណ។

នៅជុំវិញប្រាសាទនេះ មានកូនអាងតូចៗចំនួន៥ ដែលស្ថិតនៅទិសខាងលិច កើត ជើង ត្បូង និងចំកណ្តាលជុំវិញតួប្រាសាទ។ អាងទាំង៥នេះធ្លាប់ត្រូវបានរីងស្ងួតលែងមានទឹក លើកលែងតែអាងកណ្តាលដែលមានទឹកតែក្នុងរដូវវស្សាប៉ុន្មានខែប៉ុណ្ណោះ។ ចាប់ពីឆ្នាំ២០០៧មក ក្រោយពេលដែលអ្នកស្រាវជ្រាវបានរកឃើញប្រព័ន្ធទឹកបុរាណ និងបានជួសជុលព្រមទាំងបានបង្ហូរទឹកចូលបារាយណ៍ជ័យតដាក ធ្វើឲ្យអាងទាំង៥មានទឹកជាប្រចាំឡើងវិញ។

នារដូវដើមវស្សានេះ ភ្លៀងចាប់ផ្តើមធ្លាក់ រុក្ខជាតិជុំវិញចាប់ផ្តើមបញ្ចេញពណ៌បៃតងស្រស់ស្អាត ដែលរឹងតែធ្វើឲ្យអ្នកទស្សនាកាន់តែទាក់ភ្នែកថែមទៀត។

សូមទស្សនាកម្រងរូបភាពនៃប្រាសាទនាគព័ន្ធនារដូវដើមវស្សានេះ ៖









ក្រុមនិស្សិតចិនហុងកុងស្វែងយល់ពីការផលិតកុលាលភាជន៍ក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ ហ៊ីង ស្រីវត្ថ

ក្រុមនិស្សិតនៃសាកលវិទ្យាចិនហុងកុង (The Chinese University of Hong Kong) ផ្នែកនរវិទ្យាចំនួន១៤នាក់ បានចុះកម្មសិក្សា ស្វែងយល់ពីការងាររបស់អាជ្ញាធរជាតិអប្សរា ពិសេសគឺការសិក្សាពីកុលាលភាជន៍ ដែលអ្នកស្រាវជ្រាវបានរកឃើញថាកុលាលភាជន៍របស់ប្រទេសចិន និងខ្មែរ មានភាពប្រហាក់ប្រហែលគ្នា។

លោកបណ្ឌិត អ៊ា ដារិទ្ធ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ និងជាគ្រូដឹកនាំកម្មសិក្សា បានឲ្យដឹងថា នេះជាគម្រោងកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាចិនហុងកុង ដែលបានបណ្តុះបណ្តាលនិស្សិតកម្ពុជា និងចិន អំពីកុលាលភាជន៍ខ្មែរ និងចិន នាសម័យអង្គរ។

ក្នុងបទបង្ហាញនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៅព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៧ **លោកបណ្ឌិត អ៊ា ដារិទ្ធ** បានធ្វើបទបង្ហាញអំពីតួនាទីរបស់អាជ្ញាធរជាតិអប្សរា និងការងារគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដែលសហការជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗ។ បន្ថែមពីនេះ **លោក ដារិទ្ធ** ក៏បង្ហាញដល់ក្រុមនិស្សិតអំពីប្រវត្តិសាស្ត្រខ្មែរ និងចិន ដែលមានទំនាក់ទំនងគ្នាតាំងពី សម័យហ្វូណន ហើយដែលជនជាតិចិនបានកត់ត្រាឈ្មោះកម្ពុជាមុនគេ។

ទាក់ទងនឹងកុលាលភាជន៍ **លោកបណ្ឌិត អ៊ា ដារិទ្ធ** បានបង្ហាញទៅនិស្សិតចិន អំពីការវិវត្តកុលាលភាជន៍ខ្មែរ ក្នុង២ដំណាក់កាលដាច់ពីគ្នា ដែលដំណាក់កាលទីមួយពីសតវត្សរ៍ទី៩ ដល់ទី១១ និងដំណាក់កាលទីពីរ ពីសតវត្សរ៍ទី១១ ដល់ទី១៥។

ចំណែកខាងសាកលវិទ្យាល័យចិនហុងកុង បាននាំកុលាលភាជន៍បុរាណពីស្រុកចិន ដែលបានមកពីការធ្វើកំណាយនៃឡដុតកុលាលភាជន៍ចំនួន១០ទីតាំងផ្សេងគ្នា មកបង្ហាញដល់និស្សិតខ្មែរ និងអ្នកស្រាវជ្រាវខ្មែរ ឲ្យបានយល់ដឹងពីកុលាល-ភាជន៍ ពួកគេ ផងដែរ។ **លោក ជាវិទ្ធ** ពន្យល់ថា៖« ទំនាក់ទំនងកុលាលភាជន៍របស់ចិន និងខ្មែរ ខ្លះមានរូបរាងស្រដៀងគ្នា ពិសេសដើមសម័យអង្គរ មានរូបសត្វ ហើយពណ៌ក៏ស្រដៀងគ្នា...តាមការស្មាន ប្រហែល ប្រទេសទាំងពីរមានឥទ្ធិពលពីគ្នាទៅវិញទៅមក»។

លោក ជាវិទ្ធ មើលឃើញពីដំណើរទស្សនកិច្ចរបស់ក្រុមនិស្សិតផ្នែកនរវិទ្យានៅពេលនេះថា ជាការផ្លាស់ប្តូរវប្បធម៌គ្នាយ៉ាងល្អតាមរយៈការផលិតកុលាលភាជន៍ និងដើម្បីធ្វើការប្រៀបធៀបគ្នា។ ជាងនេះទៅទៀត កន្លងមកអ្នកស្រាវជ្រាវខ្មែរពិបាកក្នុងការសិក្សាស្រាវជ្រាវកុលាលភាជន៍នៅប្រទេសចិន ហើយដែលក្រុមនិស្សិតបានយកមកជាមួយ ធ្វើឲ្យអ្នកសិក្សាបានស្គាល់ច្បាស់ពីកុលាលភាជន៍ទាំងនេះ៕









អាជ្ញាធរជាតិអប្សរាសម្តែងការព្រួយបារម្ភចំពោះការរីករាលដាលសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ឹម សីហា

ក្នុងកំឡុងពេលពីរសប្តាហ៍ចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៧ កន្លងមកនេះ សកម្មភាពរំលោភសាងសង់ ចាក់ដីបំពេញខុសច្បាប់ក្នុងតំបន់១ និងតំបន់២នៃរមណីយដ្ឋានអង្គរមានការកើនឡើងយ៉ាងគំហុកបង្កឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់តម្លៃលេចធ្លោជាសកលនៃបេតិកភណ្ឌ ក៏ដូចជាកិច្ចការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ដោយចីរភាពនៃរមណីយដ្ឋានអង្គរ ដែលជាបេតិកភណ្ឌពិភពលោកនិងជាអត្តសញ្ញាណជាតិដ៏ថ្លៃថ្លានៃកម្ពុជា។ តំបន់១ និងតំបន់២នៃរមណីយដ្ឋានអង្គរត្រូវបានកំណត់ដោយព្រះរាជក្រឹត្យលេខ០០១នស ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ជាតំបន់គ្របដណ្តប់យ៉ាងច្រើនដោយប្រាសាទបុរាណ និងសំណល់បុរាណវិទ្យាដែលចាំបាច់ត្រូវការពារក្នុងកម្រិតខ្ពស់បំផុត។ គួរកត់សម្គាល់ថា ព្រះរាជក្រឹត្យលេខ០០១នស គឺជាព្រះរាជក្រឹត្យដំបូងបង្អស់ដែលចុះព្រះហស្តលេខាដោយព្រះមហាក្សត្រព្រះបរមរតនកោដ្ឋ បន្ទាប់ពីព្រះអង្គបានឡើងគ្រងរាជសម្បត្តិជាថ្មីម្តងទៀតនៅឆ្នាំ១៩៩៣។

យោងតាមរបាយការណ៍របស់ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា ដែលបានតាមដាននិងធ្វើរបាយការណ៍ពីសកម្មភាពសាងសង់ ចាក់ដីបំពេញសំណង់ខុសច្បាប់ក្នុងតំបន់អង្គរ បានបញ្ជាក់ថារយៈពេលពីរសប្តាហ៍ខាងលើមានសកម្មភាពសាងសង់ ចាក់បំពេញដីខុសច្បាប់សរុបមាន៥២៣ករណី ដែលក្នុងនោះមានការរំលោភសាងសង់កៀកនឹងកំផែងប្រាសាទបន្ទាយក្តីដែរ។ សកម្មភាពរំលោភសាងសង់ ចាក់ដីបំពេញខុសច្បាប់ទាំងនេះ បានក្លាយជាសកម្មភាពអវិជ្ជមានដ៏ធ្ងន់ធ្ងរក្នុងការងារថែរក្សា ការពារ និងអភិរក្សរមណីយដ្ឋានអង្គរដែលសហគមន៍អន្តរជាតិ និងអង្គការយូណេស្កូតែងតែចាត់ទុកជាគំរូត្រូវយកតម្រាប់តាមជាលក្ខណៈអន្តរជាតិ ក៏ដូចជាធ្វើឲ្យអាប់អោនដល់កិត្យានុភាពរបស់កម្ពុជាក្នុងឆាកអន្តរជាតិលើវិស័យថែរក្សា ការពារបេតិកភណ្ឌ។ លើសពីនេះ សកម្មភាពខុសច្បាប់ទាំងនេះ អាចរំខានដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការព្យាយាមបញ្ចូលប្រាសាទបុរាណខ្មែរមួយចំនួនទៀតជារមណីយដ្ឋានបេតិកភណ្ឌពិភពលោកផងដែរ។

ក្នុងស្មារតីមោទនភាព ស្រឡាញ់ ថែរក្សា និងចូលរួមលើកតម្លៃមរតកដូនតាដែលមានតម្លៃមិនអាចកាត់ថ្លៃបាន អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់ម្ចាស់សំណង់ ម្ចាស់ដីចាក់បំពេញខុសច្បាប់ទាំងអស់ មេត្តារុះរើសំណង់ទាំងនោះវិញដោយស្ម័គ្រចិត្ត និងសហការខ្ពស់។ ក្នុងករណីម្ចាស់សំណង់ ម្ចាស់ដីចាក់បំពេញខុសច្បាប់បន្តល្មើស និងមិនព្រមរុះរើ អាជ្ញាធរជាតិអប្សរា ដោយស្របតាមស្មារតីអង្គប្រជុំនៅសាលាខេត្តសៀមរាបរវាងសាលាខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ នឹងសហការជាមួយកម្លាំងចម្រុះនៃរដ្ឋបាលសាលាខេត្តសៀមរាប អាជ្ញាធរដែនដី ចុះរុះរើនាពេលខាងមុខដ៏ខ្លី។

អាជ្ញាធរជាតិអប្សរាសង្ឃឹមថា ម្ចាស់សំណង់ ម្ចាស់ដីចាក់បំពេញខុសច្បាប់ទាំងអស់នឹងសហការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីថែរក្សាតំបន់ប្រវត្តិសាស្ត្រអង្គរប្រកបដោយស្មារតីគោរពស្រឡាញ់បេតិកភណ្ឌដូនតា ដើម្បីបន្តការពារទុកឲ្យបានគង់វង្សតកូនតចៅគ្រប់ជំនាន់ខាងក្រោយៗទៀត៕









សមិទ្ធផលសំខាន់ៗនៃការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា ក្នុងខែឧសភាកន្លងទៅនេះ

ផ្សាយនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ក្រុមការងារសហគមន៍

ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ដឹង និងចូលរួមថែរក្សាការពារក្នុងនាមជាអ្នករស់នៅផ្ទាល់ជាមួយបេតិកភណ្ឌអង្គរ អាជ្ញាធរជាតិអប្សរាបានបង្កើតក្រុមការងារសហគមន៍ចុះផ្សព្វផ្សាយអំពីការងារអភិរក្សបេតិកភណ្ឌអង្គរ ជូនប្រជាពលរដ្ឋជាប្រចាំរៀងរាល់ថ្ងៃទាំង១១២ភូមិក្នុងរមណីយដ្ឋានអង្គរ។

ជាមួយគ្នានឹងការបង្ក្រាបចំណេះដឹងដល់ពួកគាត់ ក្រុមការងារសហគមន៍ក៏បានដោះស្រាយសំណើ និងបញ្ហានានា ដែលប្រជាពលរដ្ឋក្នុងតំបន់អង្គរជួបប្រទះផងដែរ។ ជាក់ស្តែង សម្រាប់ខែឧសភា ឆ្នាំ២០១៧នេះ ក្រុមការងារសហគមន៍បានចុះពិនិត្យ និងអនុញ្ញាតផ្ទាល់នៅហ្នឹងកន្លែងនូវសំណើសុំជួសជុលផ្ទះសម្បែង និងសាងសង់សំណង់តូចៗបានចំនួន ១៣១ករណី។

ក្រៅពីដោះស្រាយបញ្ហាសាងសង់ ក្រុមការងារក៏បាននាំយកអំណោយកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារករបស់អាជ្ញាធរជាតិអប្សរា ទៅចែកជូនស្ត្រីទើបសម្រាលបុត្រក្នុងតំបន់អង្គរបានចំនួន១១៣នាក់ និងឧបត្ថម្ភថវិកាដល់ប្រជាពលរដ្ឋចំនួន១៣គ្រួសារ ដែលរងការខូចខាតដោយសារស្រូវលិចទឹកក្នុងឆ្នាំ២០១៦កន្លងទៅ។

មិនត្រឹមតែប៉ុណ្ណោះ ក្រុមការងារសហគមន៍ក៏បានចូលរួមឧបត្ថម្ភថវិកាកាត់សម្លៀកបំពាក់ជូនប្រជាការពារភូមិលាងដៃ ចូលរួមឧបត្ថម្ភបុណ្យសព និងចូលរួមក្នុងវេទិកាសាធារណៈ ដើម្បីឆ្លើយតបនឹងសំណួរនានាដែលលើកឡើងដោយប្រជាពលរដ្ឋផងដែរ៕









អាជ្ញាធរជាតិអប្សរាសហការរៀបចំពិធីដាំកូនឈើអនុស្សាវរីយ៍អបអរសាទរសន្និសីទទេសចរណ៍អន្តរជាតិ

ផ្សាយនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ៃ៉ានី រូបភាព ៖ ហ៊ុំ រិទ្ធី

ដើម្បីជំរុញការយល់ដឹងជាសាធារណៈ និងបង្កើតអនុស្សាវរីយ៍ក្នុងឱកាសសន្និសីទលើកទី១ ស្តីពីទេសចរណ៍ប្រកបដោយចីរភាព និងទីក្រុងបេតិកភណ្ឌ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍នៃកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ ប្រព្រឹត្តនាថ្ងៃទី១១-១៦ ខែមិថុនា ឆ្នាំ២០១៧ ខេត្តសៀមរាប អាជ្ញាធរជាតិអប្សរាសហការជាមួយក្រសួងទេសចរណ៍រៀបចំពិធីដាំកូនឈើអនុស្សាវរីយ៍ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧។

ពិធីដាំកូនឈើអនុស្សាវរីយ៍នេះរៀបចំនៅបរិវេណស្រះស្រង់ទល់មុខប្រាសាទបន្ទាយក្តី នឹងប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ **ឧកញ៉ាចំនាង ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ឃីម ច៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និង ប្រតិភូទេសចរណ៍២២ប្រទេស ដែលកំពុងចូលរួមប្រជុំនៅខេត្តសៀមរាប។

គួរបញ្ជាក់ថា កម្ពុជាកំពុងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំសន្និសីទលើកទី១ ស្តីពីទេសចរណ៍ប្រកបដោយចីរភាព និងទីក្រុងបេតិកភណ្ឌ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍នៃកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧។ កិច្ចប្រជុំនេះ ត្រូវបានប្រារព្ធបើកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧៕









ចាប៉ីដងវែងខ្នាតយក្សត្រូវបានដង្ហែទៅរក្សាទុកនៅសាលាខេត្តបាត់ដំបង

ផ្សាយនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ស្បឿន ប៊ុនស៊ីរ

ចាប៉ីដងវែងខ្នាតយក្ស ដែលផលិតឡើងដោយអាជ្ញាធរជាតិអប្សរា ក្រោមការជ្រោមជ្រែងរបស់សហភាពសហព័ន្ធយុវជនកម្ពុជា ក្នុងឱកាសព្រឹត្តិការណ៍អង្គរសង្ក្រាន្តកន្លងទៅនេះ ត្រូវបានដង្ហែទៅរក្សាទុកក្នុងបរិវេណសាលាខេត្តបាត់ដំបងក្នុងផ្ទះបុរាណសម័យលោកម្ចាស់ ឈុំ អភ័យវង្ស (កថាថន) និងបានធ្វើពិធីប្រគល់ជូនដោយជោគជ័យនៅព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧នេះ។

ការសម្រេចដង្ហែចាប៉ីដងវែងខ្នាតយក្ស ដែលបានបំបែកឯតទគ្គកម្មថ្នាក់ជាតិកាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៧ ទៅរក្សាទុកនៅក្នុងខេត្តបាត់ដំបងនៅពេលនេះ ធ្វើឡើងក្រោមគំនិតផ្តួចផ្តើមរបស់ **ឧកញ៉ាឧត្តមសេនីយ៍ ស្បឿន សភ័ក្តិ** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា និងមានការឯកភាពពីសំណាក់ **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាស្របពេលដែលខេត្តបាត់ដំបង ក៏ជាខេត្តមួយដែលសម្បូណ៌ទៅដោយបេតិកភណ្ឌជាតិជាច្រើនផងដែរ។

លោកស្រី កែវ សុភាព ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបងមានប្រសាសន៍ថា ការទទួលបានចាប៉ីដងវែងខ្នាតយក្សនៅពេលនេះ គឺជាកិត្តិយសមួយដ៏ធំធេងរបស់ខេត្តបាត់ដំបង។ "ខ្ញុំពិតជារីករាយដែលខេត្តបាត់ដំបងបានទទួលចាប៉ីដងវែងដ៏ធំនេះ។ ចាប៉ីនឹងត្រូវដាក់ជូនបងប្អូនប្រជាពលរដ្ឋទូទៅចូលទស្សនា ដើម្បីឲ្យពួកគាត់កាន់តែស្រឡាញ់កេរមរតករបស់ជូនតាយើង ហើយចូលរួមថែរក្សាឲ្យបានគង់វង្សតទៅ"។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា និងជាប្រធានគម្រោងភូមិខ្ញុំនៃព្រឹត្តិការណ៍អង្គរសង្ក្រាន្ត មានប្រសាសន៍ក្នុងឱកាសបង្ហាញចាប៉ីដងវែងដល់ថ្នាក់ដឹកនាំខេត្តបាត់ដំបង និងប្រតិភូនៃកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍នៃកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ថា ការកសាងចាប៉ីដងវែងខ្នាតយក្សដាក់តាំងក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តកន្លងទៅនេះ គឺដើម្បីអបអរសាទរដែលចាប៉ីដងវែងរបស់កម្ពុជា ត្រូវបានអង្គការយូណេស្កូ សម្រេចដាក់បញ្ចូលបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី នៅក្នុងកិច្ចប្រជុំរបស់អង្គការយូណេស្កូនាទីក្រុង Addis Ababa ប្រទេសអេត្យូពី នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

ឯកឧត្តមបន្ថែមថា ការដង្ហែចាប៉ីដងវែងខ្នាតធំមករក្សាទុកក្នុងខេត្តបាត់ដំបងនេះ នឹងធ្វើឲ្យធ្វើប្រជាពលរដ្ឋកាន់តែច្រើនមានការចាប់អារម្មណ៍ ស្រឡាញ់ និងរួមចំណែកថែរក្សាបេតិកភណ្ឌនេះបានគង់វង្សយូរអង្វែង។ ជាមួយគ្នានេះ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំខេត្តបាត់ដំបង ក្រោមអធិបតីភាព **ឯកឧត្តម ច័ន្ទ សុផល** និងប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា **ឯកឧត្តម ស រដ្ឋា** ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងទទួលរក្សាទុកចាប៉ីដងវែងខ្នាតធំនេះក្នុងអាគារបុរាណដែលមានអាយុកាលជាង១០០ឆ្នាំ។

សូមបញ្ជាក់ថា ចាប៉ីដងវែងខ្នាតធំ ដែលបានដាក់តាំងបង្ហាញក្នុងបរិវេណភូមិខ្ញុំនៅថ្ងៃអង្គរសង្ក្រាន្ត និងបានដង្ហែមករក្សាទុកក្នុងខេត្តបាត់ដំបងនេះ មានប្រវែង១០ម៉ែត្រកន្លះ មានតួស្នូកទទឹងប្រវែង ២,២០ម៉ែត្រ បណ្តោយប្រវែង ២,៨០ម៉ែត្រ និងកម្រាស់ ៦០សង់ទីម៉ែត្រ។ ដងចាប៉ីដែលមានប្រវែង៧,៧០ម៉ែត្រ។ ចំណែកស្នូកធ្វើអំពីឈើកុំប្លាកេ និងខ្សែចាប៉ីធ្វើអំពីខ្សែដំរីទំហំ៨៥សង់ទីម៉ែត្រ។ ប្រលួតចំនួន៣ ដែលមានទំហំ ១៨សង់ទីម៉ែត្រ និងបណ្តោយប្រវែង១,០៥ម៉ែត្រ ត្រូវបានរចនាក្បូរក្បាច់យ៉ាងប្រណីត៕









អាជ្ញាធរជាតិអប្សរាប្រជុំពិភាក្សាជាមួយនគរបាលការពារបេតិកភណ្ឌ លើបញ្ហាសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ សឿន ប៊ុនសារ

នារសៀលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧នេះ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាច** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា និង **ឯកឧត្តម ឧត្តមសេនីយ៍ឆោ លី ឡាយ** ប្រធាននាយកដ្ឋានការពារបេតិកភណ្ឌនៃក្រសួងមហាផ្ទៃ បានជួបប្រជុំពិភាក្សាអំពីសកម្មភាពសាងសង់សំណង់ ដីចាក់បំពេញខុសច្បាប់នានាដែលកើតមានក្នុងរមណីយដ្ឋានអង្គរនាពេលថ្មីៗនេះ និងវិធានការរុះរើនាពេលខាងមុខដ៏ខ្លី។

មានប្រសាសន៍ក្នុងជំនួបនេះ ឯកឧត្តមអគ្គនាយកបានរំឭកឡើងវិញអំពីសកម្មភាពសាងសង់ខុសច្បាប់ និងរបាយការណ៍សំខាន់ៗដោយរួមទាំងទិន្នន័យដែលក្រុមការងារប្រមូលបានកន្លងមកទាក់ទិននឹងម្ចាស់សំណង់ទាំងនោះ។ ជាពិសេស ឯកឧត្តម បានបញ្ជាក់ថាក៏មានអ្នកឆ្លៀតឱកាសដើម្បីសាងសង់បើទោះបីជាអ្នកទាំងនោះភាគច្រើនពុំមែនជាអ្នកស្រុកអង្គរ និងពុំមានតម្រូវការសាងសង់ដើម្បីស្នាក់នៅនោះទេ។ ម្យ៉ាងទៀតសំណង់មួយចំនួនស្ថិតនៅកៀកនឹងប្រាសាទបន្ទាយក្តី តែប្រម៉ាណ៥០ម៉ែត្រប៉ុណ្ណោះ ដែលធ្វើឲ្យប៉ះពាល់អវិជ្ជមានដ៏ធ្ងន់ធ្ងរដល់បេតិកភណ្ឌ។ ដោយក្នុងហេតុផលនេះហើយទើបរាល់សំណង់ និងដីចាក់បំពេញខុសច្បាប់ទាំងនោះ ត្រូវតែមានវិធានការរុះរើជាចាំបាច់ ដើម្បីការពារឲ្យបាននូវបេតិកភណ្ឌដូនតាឲ្យបានយូរអង្វែង។

ឯកឧត្តម លី ឡាយ បានលើកឡើងថា រមណីយដ្ឋានអង្គរពិតជាអស្ចារ្យ និងល្បីល្បាញណាស់ ដែលសព្វថ្ងៃកម្ពុជាត្រូវអន្តរជាតិទទួលស្គាល់យ៉ាងច្បាស់ ដូច្នេះកិច្ចការពារត្រូវតែម៉ឺងម៉ាត់។ ឯកឧត្តមក៏បានឯកភាពតាមគោលការណ៍របស់អាជ្ញាធរជាតិអប្សរា ពោលគឺវិធានការរុះរើចាំបាច់ត្រូវតែធ្វើ ដើម្បីការពារបេតិកភណ្ឌ។ ឯកឧត្តមក៏បានជំរុញឲ្យមានការអនុវត្តការងារនេះដោយមានកិច្ចសហការពីគ្រប់ភាគីទាំងអស់ដោយរួមទាំងកម្លាំងនគរបាលខេត្ត នគរបាលការពារបេតិកភណ្ឌ ស្ថាប័នតុលាការ និងកម្លាំងសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា៕






ទេសភាពបៃតងបានរួមចំណែកធ្វើឲ្យអង្គរកាន់តែល្បីល្បាញលើសកលលោក

ផ្សាយនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

តំបន់រមណីយដ្ឋានអង្គរ ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមានផ្ទៃដី៤០១គីឡូម៉ែត្រក្រឡា។ ទំហំដីនេះមានទាំងប្រាង្គប្រាសាទ បារាយណ៍ ត្រពាំងបុរាណ ស្ថានីយបុរាណវិទ្យា ភូមិករ ដីស្រែចម្ការរបស់សហគមន៍ប្រជាពលរដ្ឋ និងព្រៃឈើតូចធំផ្សេងទៀត។

តាមស្ថិតិរបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរាក្នុងឆ្នាំ២០១៦បញ្ជាក់ថា បច្ចុប្បន្ន ព្រៃឈើក្នុងតំបន់អង្គរទាំងមូលមានចំនួន៦៥០៥ហិកតា ដែលស្មើនឹង១៦,២២%នៃផ្ទៃដីឧទ្យានអង្គរទាំងមូល។

ចំនួននេះមិនទាន់គ្រប់គ្រាន់ដើម្បីធ្វើឲ្យតំបន់អង្គរ គ្របដណ្តប់ដោយទេសភាពបៃតងបានឡើយ។ តាមការប៉ាន់ប្រមាណយ៉ាងហោចណាស់ ព្រៃឈើក្នុងតំបន់អង្គរទាំងមូលត្រូវបង្កើនរហូតដល់៦០%នៃផ្ទៃដីសរុបទើបអាចធ្វើឲ្យអង្គរមានតុល្យភាព និងគ្របដណ្តប់ដោយទេសភាពបៃតងបាន។

ឈរលើគោលការណ៍នេះ អាជ្ញាធរជាតិអប្សរាបានបង្កើនការដាំកូនឈើជាប្រចាំក្នុងតំបន់រមណីយដ្ឋានអង្គរ តាមរយៈការជ្រើសរើសដីទំនេរ ទីកន្លែងសាធារណៈ វត្តអារាម ការដាំជំនួសឈើងាប់ និងជំរុញឲ្យប្រជាពលរដ្ឋចូលរួមដាំតាមផ្ទះសម្បែង និងតាមភ្លឺស្រែជាដើម។

ទន្ទឹមនេះ អាជ្ញាធរជាតិអប្សរាក៏តែងសហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ ដូចជា ក្រសួងទេសចរណ៍ ក្រសួងបរិស្ថានជាដើម ដើម្បីជំរុញការដាំកូនឈើក្នុងតំបន់អង្គរតាមរយៈកម្មវិធីរុក្ខទិវា និងកម្មវិធីបរិស្ថានជាដើម។ ជាក់ស្តែង នៅព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧នេះ អាជ្ញាធរជាតិអប្សរាបានសហការរៀបចំពិធីដាំកូនឈើអនុស្សាវរីយ៍អបអរសាទរសន្ទិសីទលើកទី១ស្តីពីទេសចរណ៍ប្រកបដោយចីរភាព និងទីក្រុងបេតិកភណ្ឌ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍នៃកិច្ចសន្ទនាសហ-ប្រតិបត្តិការអាស៊ីលើកទី២ ជាមួយក្រសួងទេសចរណ៍។

ពិធីដាំកូនឈើអនុស្សាវរីយ៍នេះរៀបចំនៅបរិវេណស្រះស្រង់ទល់មុខប្រាសាទបន្ទាយក្តី ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរអប្សរា **ឯកឧត្តមតឹម ឆៃហ្សៀង** អភិបាលរងខេត្តសៀមរាប និង ប្រតិភូទេសចរណ៍២២ប្រទេស ដែលអញ្ជើញចូលរួមប្រជុំនៅខេត្តសៀម-រាប។

មានប្រសាសន៍ក្នុងពិធីដាំកូនឈើនេះ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** ដែលជាតំណាង **លោកជំទាវ ត្រៀង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរាបញ្ជាក់ថា ភាពល្បីល្បាញនៃអង្គរទៅកាន់ពិភពលោកសព្វថ្ងៃ មិនអាស្រ័យតែប្រាង្គប្រាសាទបុរាណប៉ុណ្ណោះទេ តែទេសភាពវប្បធម៌ និងបរិស្ថានជុំវិញរមណីយដ្ឋានអង្គរ ក៏ជាកត្តារួមចំណែកដ៏សំខាន់ផងដែរ។ អាជ្ញាធរជាតិអប្សរាបានទទួលយកស្តង់ដារ ISO14001 នៃប្រទេសជប៉ុនមកអនុវត្តលើការងារគ្រប់គ្រងបរិស្ថានបរិស្ថានអង្គរតាំងពីឆ្នាំ២០០៤មក ហើយបានទទួលជោគជ័យ ដោយទទួលបានវិញ្ញាបនបត្រនេះចំនួន៤លើករួចមកហើយ។









សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ មែករស់នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ ន.គ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
APSARA
N° ...អ.ប.ស.ជ.ណ
...(ស្តួច)

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ មែករស់ នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន និងការប៉ះពាល់ដល់ប្រាសាទដោយចាហោតុ និងដើម្បីលើកកម្ពស់សោភ័ណភាពបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរអប្សរានឹងធ្វើការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកងាប់ មែករស់មួយចំនួនតាមទីតាំងនានាដូចខាងក្រោម៖

-កាត់ក្រឹមែកឈើចំនួន ០២ដើម នៅបរិវេណប្រាសាទនាគព័ន្ធ។
-កាត់ក្រឹមែកឈើចំនួន ០៣ដើម នៅបរិវេណប្រាសាទបន្ទាយប្រីយ។
-កាត់ដកហូតដើមឈើយកចេញ និងកាត់ក្រឹមែកឈើនៅបរិវេណប្រាសាទក្រាលគោ។
-កាត់ក្រឹមែកឈើចំនួន ០៥ដើម នៅបរិវេណប្រាសាទតាសោម។
-កាត់ដកហូតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើនៅបរិវេណប្រាសាទព្រះខ័ន។
-កាត់ដកហូតដើមឈើយកចេញ និងកាត់ក្រឹមែកឈើចំនួន ០៣ដើមនៅបរិវេណប្រាសាទបន្ទាយអំពិល។
-កាត់ដកហូតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើនៅបរិវេណប្រាសាទតាព្រហ្ម។
-កាត់ក្រឹមែកឈើចំនួន ០៣ដើម នៅភូមិស្រះស្រង់ខាងជើង។
-កាត់ដកហូតដើមឈើយកចេញចំនួន ០៧ដើមនៅរមណីយដ្ឋានក្បាលស្ពាន។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៧ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាពត៌មាន។

សៀមរាម, ថ្ងៃទី ...ខែ...ឆ្នាំ២០១៧
អគ្គនាយក

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
"ដើម្បីជូនជ្រាប និងសហការ"
-ប៉ូលីសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង:លោក គង់ សុវណ្ណារិទ្ធ 012-354-630,លោក ខៀន សុធី 010-304-089,088-9522-5059

អាជ្ញាធរដើម្បីការពារមណ្ឌលអង្គរនិងតំបន់អនុវត្តន៍
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP

PHNOM PENH :
#41, Russian Blvd, Sangkhat Meatapheap, Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Phum Bang Korng, Sangkhat Ampil, Krong Siem Reap
Tel : (855-63) 765 577, 766 676
Fax : (855-63) 765 576

កម្ពុជាជាប្រទេសគំរូមួយដែលស្ថាបន៍ទេសចរណ៍និងវប្បធម៌ធ្វើការរួមគ្នាដើម្បីនិរន្តរភាពនៃតំបន់បេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

សន្និសីទអន្តរជាតិនៃអង្គការយូណេស្កូស្តីពីទេសចរណ៍ប្រកបដោយចីរភាព និងទីក្រុងបេតិកភណ្ឌ ដែលបានរៀបចំនៅលើទឹកដីអង្គរនៃខេត្តសៀមរាប បានបិទបញ្ចប់ហើយនៅរសៀលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧នេះ។ តំណាងអង្គការយូណេ-ស្កូប្រចាំកម្ពុជាបានវាយតម្លៃខ្ពស់ថា ប្រទេសកម្ពុជាជាប្រទេសគំរូមួយដែលស្ថាបន៍ទេសចរណ៍ និងវប្បធម៌រួមសហការគ្នាយ៉ាងល្អ ដើម្បីធ្វើឲ្យវិស័យទេសចរណ៍ និងតំបន់បេតិកភណ្ឌមាននិរន្តរភាពយូរអង្វែង។

លោកស្រី អាន ឡឺម៉ែស៍ (Anne Lemaistre) តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា បានហៅសន្និសីទនាពេលនេះថាវាជាការចាប់ផ្តើមមួយដ៏ល្អ ដែលនឹងនាំឲ្យថ្នាក់ដឹកនាំប្រទេសនានាគិតគូរលើការអភិវឌ្ឍទីក្រុងដែលជាបេតិកភណ្ឌ។ លោកស្រីបញ្ជាក់ថា បេតិកភណ្ឌ គឺជាបេតិកភណ្ឌ វាមានតម្លៃផ្ទាល់ខ្លួន ដែលបង្ហាញនូវអត្តសញ្ញាណរបស់សហគមន៍ណាមួយមិនថាវាជាបេតិកភណ្ឌជាតិ ឬជាបេតិកភណ្ឌពិភពលោកនោះទេ គឺយើងត្រូវយកចិត្តទុកដាក់ថែរក្សាឲ្យបានល្អ ដើម្បីរក្សានូវអត្តសញ្ញាណនៃតំបន់នោះឲ្យមានចីរភាព។

លោកជំទាវ ឆ្លើង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប:និងជាប្រធានអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ក្នុងពិធីបិទសន្និសីទនេះថា សន្និសីទនេះពិតជាបានសម្រេចលទ្ធផលយ៉ាងជោគជ័យ ដោយហេតុថា សមាជិកចូលរួមដែលមកពីជុំវិញពិភពលោកមិនត្រឹមតែបង្ហាញនូវបញ្ហាប្រឈមប៉ុណ្ណោះទេ ប៉ុន្តែពួកគេបានបង្ហាញនូវដំណោះស្រាយតាមរយ:បទពិសោធន៍នៃតំបន់រៀងៗខ្លួន ដែលជួយឲ្យយើងអាចយកមកដោះស្រាយកង្វល់នានាដែលកំពុងកើតមានឡើងក្នុងទីក្រុងបេតិកភណ្ឌរបស់កម្ពុជាយើង។

លោកជំទាវបន្តថា ក្នុងដំណាក់កាលនៃចរន្តសាកលភាវូបនីយកម្ម ទំនើបកម្ម ការរីកសាយភាយយ៉ាងឆាប់រហ័សនៃនគរូបនីយកម្ម នាពេលបច្ចុប្បន្ននេះ បានក្លាយជាក្តីកង្វល់យ៉ាងខ្លាំង ដែលនាំទៅរកការបាត់បង់ទីក្រុងចាស់ៗ ដែលមានតម្លៃជាប្រវត្តិសាស្ត្រ និងជាបេតិកភណ្ឌនៃមនុស្សជាតិ។ ហេតុនេះហើយ ការពិភាក្សាផ្លាស់ប្តូរមតិយោបល់គ្នា ដើម្បីរៀបចំបង្កើតនូវវិធានផ្សេងៗ ស្តីពីការអភិរក្ស និងថែរក្សាសំណង់បេតិកភណ្ឌ ដើម្បីបន្សុីជាមួយច្បាប់រៀបចំក្រុងថ្មី ប្រកបដោយសង្គតិភាព ដែលមានរចនាសម្ព័ន្ធនៃលំហសាធារណ: លំហធម្មជាតិ គឺជាចំណុចសំខាន់ដែលអង្គសន្និសីទ ត្រូវយកចិត្តទុកដាក់បង្កើតឡើង។

លោកជំទាវជឿជាក់ថា ឆ្លងកាត់ការធ្វើបទបង្ហាញ ការពិភាក្សា និងការធ្វើដំណើរទស្សនកិច្ចសិក្សាស្វែងយល់នៅទីក្រុងបាត់ដំបង ដែលជាទីក្រុងចាស់មួយពោរពេញដោយសំណង់ស្ថាបត្យកម្មយ៉ាងប្រណីត ដែលបន្សល់ទុកតាំងពីសម័យអាណាព្យាបាលបារាំងមក ហើយជាភស្តុតាងបង្ហាញអំពីប្រវត្តិសាស្ត្រ និងលក្ខណ:ដោយឡែកនៃស្ថាបត្យកម្មនៅកម្ពុជាជាមួយនឹងដំណើរទស្សនកិច្ចតំបន់បេតិកភណ្ឌពិភពលោកក្នុងខេត្តសៀមរាបនេះ អង្គសន្និសីទទាំងមូលពិតជាបានដកបទពិសោធន៍ និងរៀនសូត្រជាច្រើនថែមទៀត ដើម្បីរៀបចំទេសចរណ៍និងទីក្រុងបេតិកភណ្ឌឲ្យបានល្អប្រសើរ ដើម្បីឲ្យមានភាពទាក់ទាញនិងប្រកបដោយនិរន្តរភាព។

មានប្រសាសន៍ក្នុងពិធីនេះដែរ លោកជំទាវរដ្ឋមន្ត្រីក៏បានបញ្ជាក់ថា កម្ពុជាមានគម្រោងនឹងរៀបចំឯកសារដើម្បីបញ្ចូលផ្នែកខ្លះនៃទីក្រុងចំនួន៣ចូល ក្នុងសម្បត្តិបេតិកភណ្ឌពិភពលោកគឺ បាត់ដំបង កំពត និងក្រចេះ។ ទោះជាយ៉ាង ដំណើរការនេះនៅមានភាពវែងឆ្ងាយតទៅទៀត ដោយហេតុថា ការចងក្រងឯកសារដើម្បីបញ្ចូលបេតិកភណ្ឌជាតិមួយទៅជាសម្បត្តិបេតិកភណ្ឌពិភពលោកជារឿងស្មុគស្មាញណាស់៕









ប្រជាជនកូមិធម្មជាតិរុនតាងកទទួលបានគ្រាក់ទ័រ១គ្រឿងពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូកូរ៉េនៃមហាវិទ្យាល័យ Dong Pusan និងក្រុមហ៊ុន Dream Airline Tour

ផ្សាយនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ីង ស្រីវ៉ែ្ត រូបភាព ៖ សឿន ប៊ុនសិរ

នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ក្រុមគណៈប្រតិភូកូរ៉េ ដឹកនាំដោយ**លោក CHOI HWANEON** នាយកមហាវិទ្យាល័យ Dong Pusan បានប្រគល់ត្រាក់ទ័រមួយគ្រឿងជូនប្រជាជនកូមិធម្មជាតិរុនតាងក ដើម្បីសម្រួលដល់ការប្រកបកសិកម្ម។

ពិធីប្រគល់-ទទួលនេះបានរៀបចំឡើងនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សុំ ម៉ាប** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងថ្នាក់ដឹកនាំនៃមហាវិទ្យាល័យ Dong Pusan។ បន្តពីនោះ ក្រុមគណៈប្រតិភូ ក៏បានធ្វើបទបង្ហាញមួយចំនួននៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ហើយបន្តដំណើរទៅទស្សនកិច្ចដោយផ្ទាល់នៅ កូមិធម្មជាតិរុនតា-ងក និងសារមន្ទីរកុលាលភាជន៍ឡតានី។

ថ្លែងក្នុងឱកាសនោះដែរ **ឯកឧត្តម ម៉ី ម៉ាន់ឌី** ប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ជួសមុខឱ្យប្រជាពលរដ្ឋទាំងអស់បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈប្រតិភូកូរ៉េ ដែលបានផ្តល់នូវគ្រាក់ទ័រមួយគ្រឿងដើម្បីបង្កភាពងាយស្រួល និងភាពឆាប់រហ័សក្នុងការបង្កបង្កើនផលដល់ប្រជាជនក្នុងភូមិធម្មជាតិរុនតាឯក។

ឯកឧត្តមបន្តទៀតថា ការផ្តល់ជូននេះគឺយោងតាមអនុស្សារណៈយោគយល់គ្នារវាងអាជ្ញាធរជាតិអប្សរាជាមួយមហាវិទ្យាល័យ Dong Busan និងក្រុមហ៊ុន Dream Airline Tour ដែលមានបំណងពង្រឹងចំណងមិត្តភាពនៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំតាមរយៈវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងការអភិវឌ្ឍទេសចរណ៍។ តាមរយៈអនុស្សារណៈយោគយល់គ្នានេះដែរ ភាគីកូរ៉េនឹងបើកសាលាបណ្តុះបណ្តាលជំនាញជួសជុលនិងផលិតកុលាភាជន៍ផង។ ក្រៅពីនេះក៏នឹងចាប់ផ្តើមបណ្តុះបណ្តាលជំនាញខ្លីៗ ផ្នែកសំអាងនិងធ្វើម្ហូប ដោយភាគីកូរ៉េបានផ្តល់ទាំងអ្នកជំនាញ ថវិកា និងសម្ភារៈក្នុងការសិក្សា។ បន្ទាប់មកទៀត នឹងបង្រៀនជួសជុលឡាន ជាងឈើ និងផ្នែកទេសចរណ៍ជាបន្តបន្ទាប់ទៀតតាមអនុស្សារណៈដែលបានសម្រេចរួចមកហើយ៕









ប្រជាពលរដ្ឋសាងសង់សំណង់ខុសច្បាប់នៅជិតប្រាសាទបន្ទាយក្តីស្ម័គ្រចិត្តរុះរើសំណង់ដោយខ្លួនឯង

ផ្សាយនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ អ៊ីសា រ៉ហ៊ីនី រូបភាព ៖ រឿម សុផល្លា

បន្ទាប់ពីអាជ្ញាធរជាតិអប្សរាចេញលិខិតជូនដំណឹងឲ្យធ្វើការរុះរើសំណង់ខុសច្បាប់ ដែលបានសាងសង់ក្នុងកំឡុងពេលថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៧ ប្រជាពលរដ្ឋរស់នៅភូមិរហាល សង្កាត់នគរធំ ក្រុងសៀមរាប បានសម្រេចធ្វើការរុះរើសំណង់ខុសច្បាប់របស់ខ្លួនដោយស្ម័គ្រចិត្តនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧។ ការរុះរើដោយស្ម័គ្រចិត្តនេះ បានធ្វើឡើងបន្ទាប់ពីក្រុមការងារចម្រុះដែលមានសមាសភាពមកពីអាជ្ញាធរជាតិអប្សរា រដ្ឋបាលខេត្តសៀមរាប នគរបាលការពារបេតិកភណ្ឌ រដ្ឋបាលក្រុងសៀមរាប និងអាជ្ញាធរភូមិឃុំ បានចុះមករំលឹកអំពីការរុះរើសំណង់ខុសច្បាប់ទាំងនោះ និងពន្យល់ប្រជាពលរដ្ឋពីផលប៉ះពាល់អវិជ្ជមានដ៏ធ្ងន់ធ្ងរដល់បេតិកភណ្ឌ។

ជម្រាបជូនបងប្អូនប្រជាពលរដ្ឋនាពេលនោះ **ឯកឧត្តម ហុក ម៉េងសៃ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានបញ្ជាក់ថា សំណង់ដែលត្រូវរុះរើពេលនេះសុទ្ធតែជាសំណង់ដែលពុំមានច្បាប់អនុញ្ញាត ហើយប៉ះពាល់អវិជ្ជមានខ្លាំងដល់បេតិកភណ្ឌផ្ទាល់តែម្តង ជាពិសេសសំណង់ទាំងនេះស្ថិតនៅចំងាយប្រម៉ាណតែ៥០ម៉ែត្រពីកំពែងប្រាសាទប៉ុណ្ណោះ។ ហើយកន្លងមកអាជ្ញាធរជាតិអប្សរាបានធ្វើសេចក្តីជូនដំណឹងស្តីពីការរុះរើនេះរួចហើយដល់ម្ចាស់សំណង់ទាំងអស់ ដូច្នេះសូមឲ្យបងប្អូនប្រជាពលរដ្ឋសហការជាមួយកំលាំងចម្រុះដើម្បីចូលរួមថែរក្សាសម្បត្តិវប្បធម៌ដែលជាបេតិកភណ្ឌពិភពលោក។

លោក កែវ រុទ្ធី និង **លោកស្រី អ៊ឹង សាវ៉ាយ** ជាម្ចាស់សំណង់ផ្ទះឬ ស្ថិតនៅចំងាយត្រឹមតែប្រមាណ៥០ម៉ែត្រពីកំពែងប្រាសាទបន្ទាយក្តី ដែលស្ម័គ្រចិត្តរុះរើដោយខ្លួនឯងបានទទួលស្គាល់ថាសំណង់របស់គាត់ពិតជា បានសាងសង់ខុសច្បាប់ពិតប្រាកដមែន ហើយយល់ព្រមរុះរើដោយគ្មានលក្ខខណ្ឌព្រោះថានេះជាកំហុសឆ្គងរបស់គាត់ ដែលពុំបានសុំការអនុញ្ញាតច្បាប់សាងសង់ជាមុនពីអាជ្ញាធរអប្សរា។ ម្ចាស់សំណង់ក៏បញ្ជាក់ថាពិតជាបានបង្កហានិភ័យដល់ប្រាសាទពិតប្រាកដមែន ហើយបានស្នើសុំឲ្យក្រុមការងារដឹកយកសម្ភារៈសំណង់របស់ពួកគាត់ យកទៅរក្សាទុកនៅផ្ទះរបស់ម្តាយក្មេកដែលមានទីតាំងនៅភូមិតាត្រៃ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។

លោក មាស សាង និង**លោកស្រី នន់ ប៊ុននី** ជាម្ចាស់សំណង់ខុសច្បាប់មួយកន្លែងទៀតដែលបានរុះរើដោយស្ម័គ្រចិត្តដៃរនោះបានបញ្ជាក់ពីការទទួលស្គាល់កំហុសរបស់ខ្លួនដោយបានធ្វើការរុះរើ និងយកចេញនូវសម្ភារៈរើរុះទាំងនោះពីទីតាំងសំណង់។ **លោកស្រី នន់ ប៊ុននី** បានបញ្ជាក់បន្ថែមថាគាត់បានត្រៀមខ្លួនរួចរាល់ហើយក្នុងការរុះរើនេះ ហើយគាត់បានចាប់ផ្តើមការរុះរើនេះតាំងពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧មកម្ល៉េះ។ ដោយឡែកម្ចាស់គូបប្រក់សង្កសីឈ្មោះ **ជឿន ចន្ទ្រា** ដែលស្ថិតនៅក្បែគ្នាដៃរនោះ ក៏ព្រមរុះរើចេញទៅវិញដៃរ។

ថ្លែងក្នុងកំឡុងពេលប្រតិបត្តិការរុះរើ **លោក សរ សម្បត្តិ** អភិបាលរងក្រុងសៀមរាប បានលើកឡើងថាសកម្មភាពរបស់បងប្អូនដែលរុះរើដោយស្ម័គ្រចិត្តនាពេលនេះស្តែងឲ្យឃើញការភ្ញាក់រលឹក ដោយចូលរួមសហការជាមួយអាជ្ញាធរជាតិអប្សរាក្នុងការលើកតម្លៃបេតិកភណ្ឌដែលជាមរតកជូនតា និងជាអត្តសញ្ញាណជាតិដ៏ថ្លៃថ្លា។

សូមបញ្ជាក់ថា នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧ បន្ទាប់ពីសង្កេតឃើញថាសំណង់ និងដីចាក់បំពេញខុសច្បាប់ចំនួន ៥២១ករណីបានសាងសង់និងចាក់ដីបំពេញក្នុងតំបន់រមណីយដ្ឋានអង្គរក្នុងចន្លោះថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧កន្លងមក អាជ្ញាធរជាតិអប្សរាបានចេញសេចក្តីជូនដំណឹងដល់គ្រប់ម្ចាស់សំណង់ទាំងអស់ឲ្យរុះរើនូវ

សំណង់ ដីចាក់បំពេញនោះចេញវិញក្នុងរយៈពេលមួយសប្តាហ៍ ហើយប្រតិបត្តិការនេះនឹងបន្តទៅទីតាំងផ្សេងៗទៀត។ ក្នុងករណីពុំរុះរើចេញដោយខ្លួនឯងនោះទេ កំលាំងចម្រុះនឹងធ្វើការរុះរើដោយពុំទទួលស្គាល់នូវការខូចខាតនោះទេ។









អាយស៊ីស៊ី-អង្គរនឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី២៨របស់ខ្លួន នៅថ្ងៃទី២១-២២ ខែមិថុនា

ផ្សាយនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (International Coordination Committee for the Safeguarding and Development of Historic Site of Angkor : ICC-Angkor) នឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី២៨របស់ខ្លួន នៅថ្ងៃទី២១-២២ ខែមិថុនា ឆ្នាំ២០១៧ នាសាលសន្និសីទអង្គរ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ នឹងប្រារព្ធឡើងក្រោមអធិបតីភាព **លោកជំទាវ គឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា រួមនឹងសហប្រធានគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ **លោក Takahisa TSUGAWA** អនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុន និង **លោក Guillaume NARJOLLET** ទីប្រឹក្សាផ្នែកសហ-ប្រតិបត្តិការនិងកិច្ចការវប្បធម៌នៃស្ថានទូតបារាំង។

របៀបវារៈនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៨៦នេះ នឹងផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចជា តាមដានការអនុវត្តអនុសាសន៍កិច្ចប្រជុំបច្ចេកទេសលើកទី២៧ អំពីកិច្ចការអភិរក្ស ជួសជុល ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងរមណីយដ្ឋាន

អង្គរ និងរបាយការណ៍សកម្មភាពស្តីអំពីការងារអភិរក្សផ្សេងៗ។ ជាមួយគ្នានេះ អង្គប្រជុំក៏នឹងតាមដានសេវាកម្មនៃការលក់សំបុត្រចូលទស្សនាអង្គរ ការងារស្រាវជ្រាវអំពីឡផលិតលោហៈសម័យបុរាណ និង ការសង្ខេបឡើងវិញនូវលទ្ធផលស្រាវជ្រាវចុងក្រោយនៃប្រព័ន្ធបច្ចេកវិទ្យាLiDAR ជាដើម។

គណៈកម្មាធិការអាយស៊ីស៊ីអង្គរ(ICC-Angkor) បានបង្កើតឡើងនៅឆ្នាំ១៩៩៣ ក្រោយសន្និសីទអន្តរជាតិលើកទី១ ស្តីពីអង្គរនៅទីក្រុងតូក្យូ ប្រទេសជប៉ុន តាមសំណូមពររបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ពេលទទួលចុះអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ការបង្កើតយន្តការអន្តរជាតិ ICC សម្រាប់អង្គរ ជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំង៥ ដែលតម្រូវឲ្យអាជ្ញាធរកម្ពុជាបំពេញក្នុងរយៈពេល៣ឆ្នាំ(១៩៩៣-១៩៩៦)។ សមាជិកនៃអាយស៊ីស៊ី(ICC) មានចំនួន៣៧ប្រទេស មកពីទ្វីប៥ និងមានអង្គការអន្តរជាតិចំនួន១៣ទៀតចូលរួម ជាសមាជិកដែរ។

អាយស៊ីស៊ី-អង្គររៀបចំកិច្ចប្រជុំរបស់ខ្លួនពីរដងក្នុង១ឆ្នាំម្តងជាមួយសមាជិក គឺកិច្ចប្រជុំពេញអង្គ និងម្តងទៀតគឺកិច្ចប្រជុំបច្ចេកទេស។ កិច្ចប្រជុំពេញអង្គផ្តោតទៅលើគោលនយោបាយគ្រប់គ្រង អំពាវនាវសុំជំនួយថវិកា សុពលភាពនៃគម្រោងថ្មី និងការប្រកាសពីគម្រោងថ្មីនៅអង្គរ។ ចំណែកកិច្ចប្រជុំបច្ចេកទេស តែងធ្វើឡើងដើម្បីតាមដានការងារ អនុវត្តអនុសាសន៍មុនៗ និងតាមដានរបាយការណ៍របស់ក្រុមជំនាញដែលកំពុងប្រតិបត្តិការលើការងារអភិរក្ស ជួសជុលក្នុងតំបន់អង្គរទាំងមូល៕









ប្រធានអាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជាមួយអ្នកជំនាញការជាន់ខ្ពស់ មុនកិច្ចប្រជុំបច្ចេកទេសនៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ

ផ្សាយនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ សេន សែត

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាក្រោមអធិបតីភាព**ឯកឧត្តម ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា នារសៀលថ្ងៃទី២០ ខែមិថុនា នេះ បានជួបពិភាក្សាការងារជាមួយអ្នកជំនាញការជាន់ខ្ពស់នៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។ កិច្ចពិភាក្សានេះរៀបចំឡើងមួយថ្ងៃមុនកិច្ចប្រជុំបច្ចេកទេសលើកទី២៨នៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ដែលនឹងចាប់ផ្តើមពីថ្ងៃទី២១ដល់ទី២២ ខែមិថុនា ឆ្នាំ២០១៧។

គោលបំណងនៃជំនួបពិភាក្សានាពេលនេះគឺសំដៅផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមកនៃផលប៉ះពាល់ ដែលកើតចេញពីការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចសង្គម និងកំណើនប្រជាជននៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោកក្នុងប្រទេសនានា និងជំរុញតុល្យភាពរវាងការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលចំណុចនេះបានក្លាយជាចំណុចស្នូលយ៉ាងសំខាន់របស់អាជ្ញាធរជាតិអប្សរា ក៏ដូចជាគណៈកម្មាធិការអាយស៊ីស៊ីអង្គរដែរ។

កិច្ចពិភាក្សាក៏បានលើកឡើងនូវស្ថានភាពនៃការងារអភិរក្សរមណីយដ្ឋានអង្គរ លទ្ធភាពផ្សេងៗដែលបានជំរុញភាពជោគជ័យជាបន្តបន្ទាប់ និងការបណ្តុះបណ្តាលធនធានមនុស្សនាពេលអនាគត។ ទន្ទឹមនឹងនោះ ការប្រឈមមួយចំនួនដែលជាកង្វល់ប៉ះពាល់ដល់ដំណើរការនៃកិច្ចគាំពាររមណីយដ្ឋានអង្គរ ជាពិសេសការរីករាលដាលនៃសំណង់ខុសច្បាប់ ដែលបានកើតឡើងយ៉ាងគំហុកក្នុងរយៈពេលចុងក្រោយនេះ ក៏បានលើកយកមកពិភាក្សាផងដែរ។

ក្រៅពីផ្តល់អនុសាសន៍ និងបទពិសោធន៍ដល់ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ អ្នកជំនាញការជាន់ខ្ពស់មួយចំនួនដែលបានមកបំពេញការងារនៅកម្ពុជារយៈពេលជាង២០ឆ្នាំ តាំងពីការចុះបញ្ជីអង្គរជាបេតិកភណ្ឌពិភពលោក និងជាសាក្សីរស់ បានសម្តែងនូវការកោតសរសើរដល់កិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យវប្បធម៌ និងបេតិកភណ្ឌ និងការអភិវឌ្ឍរីកចម្រើនដ៏អស្ចារ្យលើគ្រប់វិស័យរបស់កម្ពុជាក្នុងរយៈពេលកន្លងមកនេះ ជាពិសេសការដឹកនាំប្រកបដោយទស្សនវិស័យវែងឆ្ងាយនិងបញ្ញាញាណរបស់**សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រ និងផ្តល់លទ្ធភាពគ្រប់បែបយ៉ាងលើវិស័យវប្បធម៌ និងបេតិកភណ្ឌ។

សូមបញ្ជាក់ថា អ្នកជំនាញការជាន់ខ្ពស់ទាំងនោះមានចំនួន៦រូប ក្នុងនោះមាន៣រូប ជាអ្នកជំនាញផ្នែកខាងអភិរក្សជួសជុល និង៣រូបទៀត ជាអ្នកជំនាញខាងការងារអភិវឌ្ឍប្រកបដោយចីរភាព៕









ស្វែងយល់ពីគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

អាយស៊ីស៊ី (ICC) ជាពាក្យកាត់មកពីភាសាអង់គ្លេស International Coordination Committee for the Safeguarding and Development of Historic Site of Angkor ដែលមានន័យជាភាសាខ្មែរថា គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ។

គណៈកម្មាធិការអាយស៊ីស៊ី (ICC) បានបង្កើតឡើងនៅឆ្នាំ១៩៩៣ ក្រោយសន្និសីទអន្តរជាតិលើកទី១ស្តីពីអង្គរនៅទីក្រុងតូក្យូ ប្រទេសជប៉ុន តាមសំណូមពររបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ពេលទទួលចុះអង្គរទៅក្នុងបញ្ជីបេតិក-ភណ្ឌពិភពលោក។ ការបង្កើតយន្តការអន្តរជាតិ ICC សម្រាប់អង្គរ ជាលក្ខខណ្ឌមួយ ក្នុងចំណោមលក្ខខណ្ឌទាំង៥ ដែលតម្រូវឲ្យអាជ្ញាធរកម្ពុជាបំពេញក្នុងរយៈពេល៣ឆ្នាំ(១៩៩៣-១៩៩៦)។ លក្ខខណ្ឌទាំង៥នោះគឺ ៖

១. រៀបចំបង្កើតនីតិក្រមសម្រាប់ការពាររបេតិកភណ្ឌឲ្យបានសមស្រប
២. បង្កើតស្ថាប័នជាតិទទួលបន្ទុកការពាររមណីយដ្ឋានអង្គរ ដោយមានបុគ្គលិកគ្រប់គ្រាន់
៣. បង្កើតព្រំការពាររមណីយដ្ឋានអង្គរជាអចិន្ត្រៃយ៍
៤. បង្កើតតំបន់ទ្រនាប់ឲ្យបានសមស្រប
៥. បង្កើតយន្តការត្រួតពិនិត្យ និងសម្របសម្រួលកិច្ចខិតខំរបស់អន្តរជាតិ ក្នុងការអភិរក្សរមណីយដ្ឋានអង្គរ។

ក្នុងរយៈពេល ៣ឆ្នាំ ពីឆ្នាំ១៩៩៣ ដល់១៩៩៦ ប្រទេសកម្ពុជាបានបំពេញលក្ខខណ្ឌទាំងអស់ ទោះបីជាសង្គ្រាមផ្ទៃក្នុងនៅពុំទាន់បញ្ចប់នៅឡើយក្តី:

១. នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ច្បាប់ស្តីពីកិច្ចការពាររបេតិកភណ្ឌពិភពលោក ត្រូវបានប្រកាសឲ្យប្រើជាការឆ្លើយតបនឹងលក្ខខណ្ឌទី១

២. ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់សៀមរាប-អង្គរ ហៅថា អាជ្ញាធរ «អប្សរា» ត្រូវបានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ០០១ នស/រកត/០២៩៥/១២ ជាការបំពេញលក្ខខណ្ឌទី២

៣. ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ព្រះរាជក្រឹត្យលេខ ០០១.នស ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ ត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ជាការបំពេញលក្ខខណ្ឌទី៣ និងទី៤។

៤. បង្កើតនូវគណៈកម្មាធិការ ICC បំពេញលក្ខខណ្ឌទី៥។

សមាជិកនៃអាយស៊ីស៊ី (ICC) មានចំនួន៣៧ប្រទេស មកពីទ្វីប៥ និងមានអង្គការអន្តរជាតិចំនួន១៣ ទៀត ចូលរួមជាសមាជិកដែរ។ បណ្តាប្រទេសទាំងនោះមាន៖ បារាំង អាល្លឺម៉ង់ អូស្ត្រាលី បែលហ្សិក ប្រ៊ុយណេ កម្ពុជា កាណាដា ជាណឺម៉ាក អេហ្ស៊ីប អេស្ប៉ាញ អាមេរិក រ៉ូស្ស៊ី ក្រិច ហុងគ្រី ឥណ្ឌា ឥណ្ឌូណេស៊ី អ៊ីតាលី ជប៉ុន ឡាវ លុចហ្សំបួរ ម៉ាឡេស៊ី មុិចស៊ិច ន័រវែស នូវែលហ្សេឡង់ ហូឡង់ ហ្វីលីពីន ប៉ូឡូញ ចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើង សាធារណរដ្ឋកូរ៉េ ចិន សិង្ហបុរី សិរីលង្កា ស៊ុយអែត ស្វីស ថៃ ទុយណេស៊ី និងវៀតណាម។

ចំណែកអង្គការអន្តរជាតិមានដូចជា៖ សហភាពអឺរ៉ុប ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការស្បៀងអាហារនិងកសិកម្ម អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ អង្គការអ៊ីក្រូម អង្គការអ៊ីកូម អង្គការអ៊ីកូម៉ូស អង្គការទេសចរណ៍អន្តរជាតិ អង្គការ SEAMEO/SPAFA អង្គការយូណេស្កូ អង្គការយូអិនឌីភី អង្គការយូអិនវី និងមូលនិធិប្រាង្គប្រាសាទពិភពលោក (WMF) ។

អាយស៊ីស៊ី (ICC) គឺជាយន្តការអន្តរជាតិសម្របសម្រួលដល់បណ្តាប្រទេស និងអង្គការផ្សេងៗចូលរួមអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិអង្គរ។ អាយស៊ីស៊ី (ICC) ជាវេទិកាមួយដែលស្ថាបត្យករ វិស្វករ បុរាណវិទូ អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេសជំនាញផ្សេងៗគ្នាអាចផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈរបស់ពួកគេសម្រាប់ការអភិរក្ស និងការអភិវឌ្ឍនៃឧទ្យានអង្គរ។

ភារកិច្ចសំខាន់របស់អាយស៊ីស៊ី (ICC) គឺ ស្រោចស្រង់ អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពនៅតំបន់រមណីយដ្ឋានសៀមរាប-អង្គរ។ អាយស៊ីស៊ី (ICC) រៀបចំកិច្ចប្រជុំរបស់ខ្លួនពីរដង ក្នុង១ឆ្នាំម្តងជាមួយសមាជិក គឺកិច្ចប្រជុំពេញអង្គ និងម្តងទៀតគឺកិច្ចប្រជុំបច្ចេកទេស។ កិច្ចប្រជុំពេញអង្គផ្តោតលើការតម្រង់ទិសគោលនយោបាយគ្រប់គ្រង អំពាវនាវស្វែងរកជំនួយថវិកា សុពលភាពនៃគម្រោងថ្មី និងការប្រកាសពីគម្រោងថ្មីៗនៅអង្គរ។ ជាធម្មតាសម័យប្រជុំពេញអង្គនេះតែងរៀបចំនៅចុងឆ្នាំ។

ចំណែកឯសម័យប្រជុំបច្ចេកទេសតែងធ្វើឡើងនៅពាក់កណ្តាលឆ្នាំ ហើយអនុញ្ញាតឲ្យអ្នកជំនាញបច្ចេកទេសផ្លាស់ប្តូរបទពិសោធន៍ របស់ពួកគេ ពិភាក្សាអំពីបញ្ហាបច្ចេកទេស និងដំណោះស្រាយសម្រាប់បញ្ហាជាក់លាក់។ រាល់សម័យប្រជុំទាំងអស់របស់អាយស៊ីស៊ី (ICC) ឯកអគ្គរដ្ឋទូតនៃប្រទេសបារាំង និងជប៉ុននៅកម្ពុជាធ្វើជាសហប្រធាននៃកិច្ចប្រជុំនេះ និងផ្តល់ជំនួយហិរញ្ញវត្ថុដែលចាំបាច់ផ្សេងៗ រីឯអង្គការយូណេស្កូធ្វើជាលេខាធិការដ្ឋាន និងផ្តល់ចំណាយពាក់ព័ន្ធនឹង

បេសកកម្មរបស់ក្រុមអ្នកជំនាញ អាដហុកសម្រាប់ការអភិរក្ស។ ចំណែកអាជ្ញាធរជាតិអប្សរាបានរួមចំណែកតាំងពីឆ្នាំ២០០៦ ផ្តល់ជាជំនួយហិរញ្ញវត្ថុក្នុងដំណើរការរបស់គណៈកម្មាធិការ ការចំណាយលើបេសកកម្មក្រុមអ្នកជំនាញអាដហុក និងចំណាយពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំ។









ប្រតិភូគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ចូលគោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន ក្នុងឱកាសបុណ្យខួបគម្រប់១០០ថ្ងៃ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី , សឿន ប៊ុនសីរ

ព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ ក្នុងឱកាសប្រជុំបច្ចេកទេសលើកទី២៨ នៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ប្រតិភូមកពីស្ថាប័នជាតិ ស្ថានទូត ស្ថាប័នផ្សេងៗដែលកំពុងមានសកម្មភាពជួសជុល ថែរក្សា និងអភិរក្សនៅរមណីយដ្ឋានអង្គរ បានចូលសម្តែងការគោរពដល់វិញ្ញាណក្ខន្ធ **សម្តេចវិបុលបញ្ញា សុខ អាន** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា។

ពិធីគោរពវិញ្ញាណក្ខន្ធនេះ ធ្វើឡើងស្របពេលដែលថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរាកំពុងរៀបចំពិធីបុណ្យខួបគម្រប់១០០ថ្ងៃនៃមរណភាពរបស់ **សម្តេចវិបុលបញ្ញា** នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

ការចូលរួមគោរពវិញ្ញាណក្ខន្ធដល់**សម្តេចឧបុលបញ្ញា សុខ អាន** របស់ប្រតិភូនៃអង្គប្រជុំនាពេលនេះ គឺជាការសម្តែងនូវការគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត និងស្រណោះអាលោះអាល័យជាទីបំផុតចំពោះ **សម្តេចឧបុលបញ្ញា សុខ អាន** ដែលធ្លាប់បានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាញាណដើម្បីបុព្វហេតុនៃការងារអភិរក្សថែរក្សារមណីយដ្ឋានអង្គរ ជាពិសេសគឺការដឹកនាំអង្គប្រជុំនៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរឲ្យដំណើរការយ៉ាងជោគជ័យគ្រប់ពេលទាំងអស់។

សូមបញ្ជាក់ថា **សម្តេចឧបុលបញ្ញា សុខ អាន** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអាជ្ញាធរជាតិអប្សរា បានទទួលមរណភាពកាលពីថ្ងៃ៣រោជ ខែផល្គុន ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ២៥៦០ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧វេលាម៉ោង១៨:៣២នាទីដោយរោគាពាធក្នុងជន្មាយុ៦៦ឆ្នាំ។









អាជ្ញាធរជាតិអប្សរាចុះអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នអន្តរជាតិចំនួនពីរលើការងាររអភិរក្ស

ផ្សាយនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

នៅព្រឹកថ្ងៃទី២២ មិថុនា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំបច្ចេកទេសគណៈកម្មាធិការអាយស៊ីស៊ី-អង្គរលើកទី២៨ អនុស្សរណៈយោគយល់គ្នាចំនួនពីរត្រូវបានចុះហត្ថលេខារវាងអាជ្ញាធរជាតិអប្សរា និងបណ្ឌិតសភាបេតិកភណ្ឌចិន នៃសាធារណរដ្ឋប្រជាមានិតចិន និងរវាងអាជ្ញាធរជាតិអប្សរា និងមជ្ឈមណ្ឌលសិល្បៈជាតិអ៊ិនឌីរ៉ាហ្គិនធី (Indira Gandhi National Center for the Arts) ហៅកាត់ថា IGNCA នៃប្រទេសឥណ្ឌា។ ពិធីចុះហត្ថលេខានាពេលនេះស្ថិតក្រោមអធិបតីភាព **ឧកញ៉ាឧត្តមសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា និងចុះហត្ថលេខា

ដោយ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា **លោក** Xu Yan នាយករងតំណាងបណ្ឌិតសភាបេតិក-កណ្ឌវប្បធម៌ចិន **លោកស្រី** Vinita SRISVASTAVA លេខាធិការរួមនៃមជ្ឈមណ្ឌលសិល្បៈជាតិអ៊ិនឌីរ៉ាហ្គិនធី។

អនុស្សរណៈយោគយល់ជាមួយបណ្ឌិតសភាបេតិកភណ្ឌចិន គឺធ្វើឡើងក្នុងបំណងដើម្បីស្រាវជ្រាវ និងប្រមូលទិន្នន័យនានាសម្រាប់ការអភិរក្ស និងជួសជុលប្រាសាទបេងមាលា។ ការចុះហត្ថលេខានេះ គឺជំហានដំបូងនៃការខិតខំរបស់អាជ្ញា-ធរជាតិអប្សរា ក្នុងការស្វែងរកកិច្ចសហការអន្តរជាតិលើការងារជួសជុលប្រាសាទបេងមាលា។ អនុស្សរណៈនេះធ្វើឡើងបន្ទាប់ពីមានការខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរា ក្នុងន័យស្វែងរកកិច្ចសហការជាមួយដៃគូ អន្តរជាតិ សម្រាប់ការជួសជុលប្រាសាទក្រៅឧទ្យានអង្គរ ដែលកន្លងមកមានភាពលំបាកខ្លះ។ នេះមានន័យថា ដៃគូសហប្រតិបត្តិការអន្តរជាតិអាចនឹងងាយស្រួលយល់ព្រមជួសជុលប្រាសាទក្នុងតំបន់បេតិកភណ្ឌពិភពលោក ព្រោះឆាប់ទទួលបានការចាប់អារម្មណ៍ពីអង្គការយូណេស្កូ។ ត្រង់ចំណុចនេះហើយ ការចុះបញ្ជីប្រាសាទបុរាណខ្មែរក្នុងបញ្ជីបេតិកភណ្ឌពិភពលោកគឺជាកត្តាចាំបាច់ក្នុងការទទួលបានកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីជួសជុល។

សូមបញ្ជាក់ថា កន្លងមកភាគីចិន បានជួយជួសជុលប្រាសាទចៅសាយទេវតា និងកំពុងបន្តជួសជុលប្រាសាទតាកែវ ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០១៨ ហើយនឹងបន្តជួសជុលលើគម្រោងមួយទៀតក្នុងឧទ្យានអង្គរបន្ទាប់ពីប្រាសាទតាកែវ។

ដោយឡែកសម្រាប់អនុស្សរណៈជាមួយ មជ្ឈមណ្ឌលសិល្បៈជាតិអ៊ិនឌីរ៉ាហ្គិនធី វិញ គឺក្នុងបំណងដើម្បី ប្រមូលទិន្នន័យចងក្រងឯកសារ ជារូបភាព និងវីដេអូ រក្សាទុកក្នុងប្រព័ន្ធបច្ចេកវិទ្យា។ គម្រោងនេះ ដើម្បីរក្សាទុក និងជាភស្តុតាងសម្រាប់ជួយដល់ការងារជួសជុលទៅពេលខាងមុខ។ ឧទាហរណ៍ ការចងក្រងរូបភាពនេះអាចឲ្យអ្នកអភិរក្សជំនាន់ក្រោយដឹងអំពីស្ថានភាពដើម និងការវិវត្តនៃផ្នែកមួយរបស់ប្រាសាទនាពេល១០ឆ្នាំ ឬ២០ឆ្នាំខាងមុខ។ ដូចនេះការរក្សាបាននូវរូបភាពទាំងនោះគឺជាចំណុចស្នូល និងជាឯកសារគោលដែលអាចឲ្យអ្នកអភិរក្សជំនាន់ក្រោយយកមកសិក្សាមុនសម្រេចចិត្តធ្វើការជួសជុល៕









តំណាងអង្គការយូណេស្កូប្រចាំកម្ពុជាសម្តែងការគាំទ្រចំណាត់ការទប់ស្កាត់ការរីករាលដាល សំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ស្របពេលដែលសំណង់ខុសច្បាប់បានរីករាលដាលយ៉ាងគំហុកក្នុងរយៈពេលចុងក្រោយនេះ បានធ្វើឲ្យរមណីយដ្ឋានអង្គរ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកអាចនឹងប្រឈមនឹងបញ្ហា បើទប់ស្កាត់មិនបានទាន់ពេលទេនោះ។

ឆ្លើយតបនឹងបញ្ហានេះ អាជ្ញាធរជាតិអប្សរាក្នុងឋានៈជាស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ បានព្យាយាមសម្របសម្រួលជាមួយប្រជាពលរដ្ឋដែលបានលួចសាងសង់សំណង់ខុសច្បាប់ ដោយសុំឲ្យពួកគាត់រុះរើសំណង់ខុសច្បាប់ទាំងនោះដោយខ្លួនឯងវិញ។ ចំពោះករណីដែលប្រជាពលរដ្ឋមួយចំនួនទៀតមិនបានរុះរើដោយស្ម័គ្រចិត្តទេ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការថែរក្សាឲ្យបាននូវបេតិកភណ្ឌពិភពលោកអង្គរ អាជ្ញាធរជាតិអប្សរាមានភាពចាំបាច់ដើម្បីប្រើប្រាស់គោលការណ៍រដ្ឋបាលចុះរុះរើសំណង់ខុសច្បាប់ទាំងនោះចេញ។

លោកស្រី Anne Lemaistre តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា បានថ្លែងក្នុងសន្និសីទសារព័ត៌មានក្រោយកិច្ចប្រជុំបច្ចេកទេសលើកទី២៨ នៃគណៈកម្មាធិការ ICC-Angkor ថា "និយាយអំពីសំណង់ថ្មីៗនៅក្នុងតំបន់១ និង តំបន់២ តាមពិតទៅសំនួរមួយនេះត្រូវបានអគ្គនាយកអាជ្ញាធរជាតិអប្សរា ឆ្លើយយ៉ាងក្បោះក្បាយល្អរួចហើយ តែយើងគ្រាន់តែចង់បន្តែមបន្តិច ពួកយើងសូមសំដែងការសោទរដល់អាជ្ញាធរជាតិអប្សរាដែលបានចាត់វិធានការទប់ស្កាត់ និងធ្វើការរុះរើសំណង់ថ្មីៗ ខុសច្បាប់ នៅក្នុងតំបន់១ និង តំបន់២។ នេះគឺជាការងារដែលមានក្នុងកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងអង្គការ UNESCO"។

លោកស្រីបន្ថែមថា "ដូច្នេះយើង សូមលើកទឹកចិត្តដល់អាជ្ញាធរអប្សរាឲ្យបន្តក្នុងកិច្ចការពារតំបន់១ និងតំបន់២ និងការពារច្បាប់ ឲ្យបានខ្លាំងតាមដែលអាចធ្វើទៅបាន។ អ្វីដែលយើងត្រូវនិយាយ និងសម្រេចចិត្តគឺនៅខែធ្នូ ក្នុងកិច្ចប្រជុំ ICC-Angkor លើកក្រោយ ពួកយើងអាចនឹងមានរៀបចំសិក្ខាសិលាមួយស្តីអំពីកិច្ចការអភិរក្ស ហើយខ្ញុំគិតថាសម្រាប់ពេលនេះ យើងកំពុងមានដំណើរការល្អប្រសើរហើយ ដូច្នេះយើងពិតជាពេញចិត្តចំពោះដំណើរការនេះ"៕









អ្នកជំនាញនៃអង្គការយូណេស្កូ បង្ហាញភាពមហន្តរាយនៃបេតិកភណ្ឌជុំវិញពិភពលោក ដើម្បីរុញកដល់ការអភិរក្សរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រឹទ្ធី

នៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី២៨ នៃគណៈកម្មាធិការ ICC-Angkor កន្លងទៅថ្មីៗនេះ អ្នកជំនាញ Ad Hoc នៃអង្គការយូណេស្កូ បានធ្វើបទបង្ហាញមួយចំនួន ដោយបានលើកករណីការបំផ្លិចបំផ្លាញបេតិកភណ្ឌតាមរយៈសង្គ្រាមស៊ីវិល។ ការលើកករណីនេះមកបង្ហាញក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការ ICC-Angkor ជាការរុញកដល់ស្ថាប័នពាក់ព័ន្ធឲ្យយកចិត្តទុកដាក់ខ្ពស់លើការអភិរក្សបេតិកភណ្ឌអង្គរ។

ឯកឧត្តម ឆឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរាបាន ថ្លែងក្នុងសន្និសីទសារព័ត៌មាន ក្រោយកិច្ចប្រជុំនេះកាលពីថ្ងៃទី២២ ខែមិថុនា ថា អ្នកជំនាញជាន់ខ្ពស់បានធ្វើបទបង្ហាញនូវផលវិបាករបស់សង្គ្រាម ចំពោះសំណង់បេតិកភណ្ឌ ដោយបានបង្ហាញពីការបំផ្លាញបេតិកភណ្ឌជាច្រើននៅលើពិភពលោក តាមរយៈរូបភាពនានានៅក្នុងសង្គ្រាម។

លោកជំទាវបន្ថែមថា "ក៏ប៉ុន្តែ យើងដឹងហើយប្រទេសរបស់យើងមិនមានសង្គ្រាមទេ ដូច្នេះការណ៍មួយចំនួនដែលអ្នកជំនាញ ឬក៏អ្នកចូលរួមក្នុងកិច្ចប្រជុំអាយស៊ីស៊ី លើកឡើងគឺគេមានការបារម្ភចំពោះសំណង់អនាធិបតេយ្យមួយចំនួន ដែលកើតឡើងនៅក្នុងតំបន់អង្គរយើងនេះទេ ព្រោះហេតុអ្វី? យើងត្រូវយល់ថា តំបន់អង្គរ បានចុះបញ្ជីទៅក្នុងបេតិកភណ្ឌពិភពលោកហើយ នៅពេលដែលយើងចុះបញ្ជីបេតិកភណ្ឌពិភពលោក កម្ពុជាមានកាតព្វកិច្ចត្រូវគោរពនូវស្តង់ដារអន្តរជាតិ

មួយចំនួន អញ្ចឹងនៅពេលដែលស្តង់ដារអន្តរជាតិមួយចំនួនត្រូវបានរំលោភ យើងនឹងមានការព្រួយបារម្ភ មិត្តភក្តិរបស់យើងទាំងក្នុង និងក្រៅប្រទេស តែងតែយកចិត្តទុកដាក់ ដូចជាជួយណែនាំ ជួយរឭកថា មានកិច្ចការដែលត្រូវត្រួតពិនិត្យមើលកុំឱ្យរឿងហ្នឹងហួសពេល"។

លោកជំទាវប្រធានអាជ្ញាធរបន្ថែមថា "បាតុភាពខ្លះ តែកើតឡើងហើយមិនអាចត្រឡប់មកវិញបានទេ អញ្ចឹងកិច្ចការដែលខិតខំប្រឹងប្រែងការពារទាំងអស់គ្នានេះ វាអាចជាឧទាហរណ៍មួយដែរ ដែលយើងត្រូវខិតខំកុំឱ្យវាហួសពេលទាន់។ ម្យ៉ាងទៀតត្រូវដឹងថា កម្ពុជាមិនមែនមានតែតំបន់អង្គរមួយទេ យើងបានចុះបញ្ជីតំបន់អង្គរ ប្រាសាទព្រះវិហារ យើងនៅមានតំបន់ផ្សេងៗទៀតដូចជា សម្បូណ៌ព្រៃគុក បន្ទាយឆ្មារ ព្រះខ័ន ឬក៏តំបន់បេតិកភណ្ឌមួយចំនួននៅភ្នំគូលែនដែរ។ ដូច្នេះបើការថែរក្សាតំបន់ដែលចុះក្នុងបញ្ជីហើយ យើងគ្រប់គ្រងមិនបានជិតដល់វាអាចផ្តល់ការលំបាកដល់ការចុះបញ្ជីថ្ងៃក្រោយទៀត។ បើយើងចង់ចុះ បញ្ជីសម្បូណ៌ព្រៃគុក បន្ទាយឆ្មារ គេអាចនិយាយថា ឥឡូវគ្រាន់តែតំបន់អង្គរគ្រប់គ្រង មិនបានផងទៅចុះបញ្ជីអីផ្សេងទៀត។ អានេះមួយគឺជារឿងដែលយើងបារម្ភពីបេតិកភណ្ឌជាតិនានា ដែលនឹងត្រូវចុះបញ្ជីនៅថ្ងៃខាងមុខ ក៏ដូចជាបារម្ភនឹងចំណាត់ថ្នាក់អង្គរទៅក្នុងតំបន់ដែលងាយរងគ្រោះ ពីព្រោះនៅពេលដែលសំណង់ ឬការរៀបចំខ្វះសណ្តាប់ធ្នាប់ វាអាចធ្វើឱ្យយើងមានភាពងាយរងគ្រោះ ប៉ុន្តែយើងត្រូវដឹងថា រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរជាតិអប្សរាគឺថាយើងមានឆន្ទៈខ្ពស់ក្នុងការថែរក្សា"៕



UNESCO Mission to Lebanon September 2006 after Israeli Airstrike







បើយើងជាម្ចាស់ស្រុកពិតប្រាកដ គ្មានអ្វីដែលព្រួយបារម្ភក្នុងការសាងសង់ផ្ទះនោះទេ!

ផ្សាយនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ ហ៊ឹង ស្រីរ័ត្ន រូបភាព ៖ ហ៊ឹង ស្រីរ័ត្ន

ទាក់ទងនឹងការសាងសង់ផ្ទះនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ជារឿងស្មុគ្រស្មាញនិងចម្រូងចម្រាស់បំផុតសម្រាប់ប្រជាជនដែលមិនគោរពទៅតាមបទដ្ឋានដែលកំណត់ដោយអង្គការយូណេស្កូ ហើយប្រាសចាកពីលក្ខខណ្ឌដែលត្រូវអនុគ្រោះ។ ផ្ទុយទៅវិញ បើប្រជាជនអនុវត្តទៅតាមអ្វីដែលបានកំណត់ ហើយមានលិខិតបញ្ជាក់ច្បាស់លាស់ថាខ្លួនជាប្រជាជនចាស់រស់នៅលើទឹកដីអង្គរ នោះមិនមានអ្វីចោទជាបញ្ហាសម្រាប់ការស្នើសុំពាក្យសាងសង់នោះទេ។

តាមការបញ្ជាក់ពី**លោកពូ ស៊ុយ យឿង** រស់នៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ដែលទើបសង់ផ្ទះហើយបានប្រាប់ថា ការស្នើសុំលិខិតសង់ផ្ទះមិនជារឿងពិបាកទេ បើយើងពិតជាម្ចាស់ស្រុករស់នៅក្នុងតំបន់អង្គរយូរយោរមកមែន ហើយមានខ្នងផ្ទះចាស់ស្រាប់ ពេលសុំច្បាប់គេ គឺដឹងតែអាជ្ញាធរជាតិអប្សរាអនុញ្ញាត លើកលែងតែយើងអ្នកចំណូលថ្មី គ្មានខ្នងផ្ទះចាស់ ហើយលួចសង់ខុសច្បាប់នោះគេមិនអនុញ្ញាតទេ ថែមទាំងរុះរើទៀតផង។ ការស្នើសុំសង់ផ្ទះថ្មីជំនួសផ្ទះចាស់ក៏មិនស្មុគស្មាញអ្វីដែរ គឺដំបូងគាត់បានយកបណ្ណគ្រួសារទៅឱ្យមេភូមិស៊ីញ៉ែ ហើយឱ្យមេឃុំបោះត្រាឱ្យ ដើម្បីបញ្ជាក់ថាគាត់ជាអ្នកស្រុកភូមិចាស់ មានទីលំនៅ និងមានខ្នងផ្ទះចាស់នៅក្នុងតំបន់អង្គរពិតប្រាកដមែន រួចយកពាក្យស្នើសុំទៅដាក់ដោយផ្ទាល់នៅទីស្នាក់ការកណ្តាលរបស់អាជ្ញាធរជាតិអប្សរា។ គាត់រង់ចាំរយៈពេល១ខែលិខិតក៏ចេញមក រីឯការស្នើសុំវិញក៏មិនមានតម្រូវឱ្យបង់ប្រាក់អ្វីឡើយ ហើយពេលធ្វើផ្ទះ ក៏គ្មានអ្នកណាមកសុំប្រាក់កាក់បន្តែមដែរ។

លោកពូ យឿង បន្តទៀតថា អាជ្ញាធរជាតិអប្សរាបានចុះមកវាស់និងសិក្សាពីប្លង់ផ្ទះដោយក្រុមការងារផ្ទាល់ ហើយក្នុងលិខិតបានអនុញ្ញាតឱ្យលោកពូសង់ផ្ទះថ្មីជំនួសផ្ទះចាស់នៅលើទំហំដីដដែល ជួសជុលផ្ទះបាយ ចាក់ដី ធ្វើរបង និងដឹកជញ្ជូនគ្រឿងសំណង់សម្រាប់ធ្វើផ្ទះដោយគ្មានអាជ្ញាធរណាហាមឃាត់ទេ។ ចំពោះសុពលភាពនៃការសាងសង់ គឺមានរយៈពេល១ឆ្នាំ តែបើ១ឆ្នាំមិនទាន់ហើយអាជ្ញាធរជាតិអប្សរាបានឱ្យគាត់ស្នើសុំបន្តសុពលភាពដើម្បីបញ្ចប់កិច្ចការទាំងនោះឱ្យរួចរាល់។

លោកពូ ក៏បានសម្តែងនូវការអរគុណចំពោះក្រុមការងារអាជ្ញាធរជាតិអប្សរាដែលបានជួយសម្របសម្រួល ហើយក៏ផ្តាំផ្ញើផងដែរឱ្យប្រជាជនដែលរស់នៅលើទឹកដីអង្គរទាំងអស់ គួរស្វែងយល់ពីសិទ្ធិរបស់ខ្លួនដែលមានតាមរយៈការចូលរួមប្រជុំនានា ចៀសវាងការជឿតែពីមាត់មួយទៅមាត់មួយ និងចូលរួមថែរក្សាសម្បត្តិដូនតារបស់ខ្លួនឱ្យបានល្អ ដោយអនុវត្តទៅតាមគោលការណ៍ ដែលបានកំណត់។ បើចង់សាងសង់ផ្ទះ គួរសុំច្បាប់ឱ្យបានត្រឹមត្រូវ ចៀសវាងការលួចធ្វើ ដែលជាទង្វើខុសច្បាប់ ដល់ពេលគេមករុះរើនាំតែខូចប្រយោជន៍ ទ្រព្យធន ពេលវេលារបស់ខ្លួនតែប៉ុណ្ណោះ៕









សំណង់ខុសច្បាប់ក្នុងតំបន់អង្គរនឹងត្រូវបន្តរុះរើក្នុងពេលឆាប់ៗនេះ

ផ្សាយនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ រ៉ុង អង្គវិល

សំណង់ខុសច្បាប់ដែលសាងសង់ឡើងក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ ក្នុងរយៈពេលចុងក្រោយនេះ នឹងត្រូវបន្តការរុះរើ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។ នេះជាជំហររបស់រាជរដ្ឋាភិបាល ក្នុងការការពារឲ្យបានដាច់ខាតនូវតំបន់បេតិកភណ្ឌពិភពលោកអង្គរ ដែលកំពុងរងហានិភ័យដោយសារកំណើននៃសំណង់អនាធិបតេយ្យទាំងនេះ។

មានប្រសាសន៍ក្នុងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិនារសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ នៅសាលាខេត្តសៀមរាប **ឯកឧត្តម ឆៀ ចាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង ជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តសៀមរាប បានគាំទ្រនូវរាល់វិធានការរបស់អាជ្ញាធរជាតិអប្សរា រាល់ការអនុវត្តតាមគោលការណ៍ច្បាប់របស់អង្គការយូណេស្កូ ក្នុងការថែរក្សាអភិរក្ស តំបន់រមណីយដ្ឋានអង្គរ សំខាន់បញ្ហាសំណង់អនាធិបតេយ្យនៅក្នុងតំបន់អង្គរ តំបន់១ និង តំបន់២ ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំង ចំពោះសោភណភាពប្រាសាទបុរាណ។

ឯកឧត្តមបញ្ជាក់ថា "តំបន់បេតិកភណ្ឌត្រូវការពារឲ្យបានដាច់ខាត បើទោះជាត្រូវលះបង់អ្វីៗក៏ដោយ ព្រោះយើងជាប្រជា-ជាតិមួយ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញដោយសារបេតិកភណ្ឌ។ កុំថាឡើយ១០០ម៉ែត្រពីប្រាសាទ ទោះជា១គីឡូម៉ែត្រក៏ដោយ ត្រូវតែចាត់វិធានការ ប្រសិនបើមានហានិភ័យខ្លាំង តែយើងក៏ត្រូវគិតគូរដែរ ពីកន្លែងដែលមិនប៉ះពាល់ខ្លាំង យើងត្រូវរួមកម្លាំងគ្នាដើម្បីដោះស្រាយបញ្ហានេះ....″។

ជាមួយគ្នានេះ ឯកឧត្តមក៏បានជំរុញឲ្យអាជ្ញាធរជាតិអប្សរា អាជ្ញាធរខេត្ត ក្រុង ស្រុក និងកម្លាំងសមត្ថកិច្ច ទាំងអស់ត្រូវសហការគ្នា ក្នុងការអនុវត្តគោលការណ៍ច្បាប់របស់អង្គការយូណេស្កូ ទៅតាមគ្រប់រូបភាព និងវិធានការក្នុងការរុះរើសំណង់អនាធិបតេយ្យក្នុងតំបន់អង្គរ ដែលនឹងចាប់ផ្តើមអនុវត្តជាដំហានដំបូងលើសំណង់ខុសច្បាប់ទាំងឡាយណាដែលស្ថិតនៅកៀកនឹងប្រាសាទ ព្រមទាំងសំណង់ខុសច្បាប់នានាដែលបង្កហានិភ័យជាក់ស្តែងដល់បេតិកភណ្ឌ។

យោងលើវិធានការចំពោះមុខនេះ សូមម្ចាស់សំណង់ខុសច្បាប់ទាំងអស់ត្រូវប្រញាប់រុះរើសំណង់ដោយខ្លួនឯង ដូចដែលអាជ្ញាធរអប្សរាបានជូនដំណឹង និងបានទុកពេលវេលាជូនក្នុងការរុះរើ ជៀសវាងការខូចខាតដែលអាចកើតមានជាយថា-ហេតុ ក្នុងអំឡុងយុទ្ធនាការរុះរើរបស់សមត្ថកិច្ច៕









ក្រុមអភិរក្សថ្មវ័យក្មេងបន្តការងារជួសជុលបង្គោលសីមានៅប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ អត្ថបទ ៖ សេន សែត រូបភាព ៖ ហ៊ុំ រិទ្ធី

ក្រុមអភិរក្សថ្មវ័យក្មេងប្រមាណ២០រូប ដែលធ្លាប់ទទួលការបណ្តុះបណ្តាលដោយអ្នកជំនាញនៃប្រទេសអាឡឺម៉ង់ និងដែលដឹកនាំអនុវត្តការងារផ្ទាល់ដោយ **លោក ឡុង ណារី** មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា កំពុងបន្តការងារជួសជុលថ្ម និងចម្លាក់ផ្សេងៗក្នុងតំបន់អង្គរ។

ក្រុមអភិរក្សថ្មវ័យក្មេងទាំងនេះបានចែកគ្នាជាក្រុមៗ ដើម្បីធ្វើការជួសជុលព្យាបាលថ្ម ឬចម្លាក់ផ្សេងៗ ដែលរងការខូចខាតដើម្បីឲ្យរឹងមាំឡើងវិញ។ ជាក់ស្តែង ក្រុមការងារនេះបានជួសជុលបង្គាន់ជៃនាគនៅប្រាសាទបន្ទាយសំរែ ជួសជុលចម្លាក់តោនៅប្រាសាទក្រវ៉ាន់ ជួសជុលសសរពេជ្រ និងផ្ដែរនៅសារមន្ទីរព្រះនរោត្តមសីហនុអង្គរ និងកំពុងបន្តការងារជួសជុលបង្គោលសីមានៅប្រាសាទបន្ទាយស្រី។

ក្រុមអភិរក្សថ្មវ័យក្មេង៣នាក់ដែលកំពុងតែជួសជុលបង្គោលសីមានៅប្រាសាទបន្ទាយស្រី **លោក ស៊ុយ ប៊ុនថន លោក អៀន ធី** និង **លោក មឿត ដា** ។ លោកបានរៀបរាប់ថា បង្គោលសីមាដែលក្រុមការងាររបស់លោកកំពុងជួសជុលនេះមានបញ្ហាដោយសារការជួសជុលកាលពីសម័យបារាំងគេបានដាក់ស៊ីម៉ង់ត៍ និងដាក់ដែកទាមពីខាងក្រៅ តែពេលនេះវាបានរង្គើរបេះ

ស៊ីម៉ង់ត៍ធ្លាក់ហើយអាចនឹងរលំដួល ឬធ្លាក់បាក់ បើមានភ្ញៀវមកប៉ះពាល់ខ្លាំងបន្តិច។ ការជួសជុលរបស់ក្រុមការងារលោកគឺដកស៊ីម៉ង់ត៍និងដែកទាមចេញ ដាក់ជំនួសវិញដោយស្នូលភ្ជាប់ប្រភេទ Fiberglass និងដាក់ថ្មថ្មីជំនួសស៊ីម៉ង់ត៍ចាស់។ បច្ចុប្បន្នក្រុមការងារលោកកំពុងជួសជុលបង្គោលសីមាចំនួន៣ដើម និងសសរមួយដើមនៅប្រាសាទបន្ទាយស្រីនេះ។

នេះជាមោទនភាពមួយដែលធនធានមនុស្សនៃអាជ្ញាធរជាតិអប្សរា មានសមត្ថភាពអាចកាន់ការងារជួសជុលថ្មប្រាសាទដូនតាខ្មែរបានដោយខ្លួនឯង ដែលជាគោលដៅធំបំផុតនៃបេសកកម្មរបស់អាជ្ញាធរជាតិអប្សរា ក្នុងកិច្ចការគ្រប់គ្រងដោយឈរលើទស្សនៈថា ប្រាសាទខ្មែរ ធ្វើដោយកូនខ្មែរ និងដើម្បីកូនខ្មែរ។ តាមរយៈការសិក្សារៀនសូត្រពីអ្នកជំនាញ និងការអនុវត្តផ្ទាល់លើការងារប្រចាំថ្ងៃ អ្នកជំនាញវ័យក្មេងទាំងនេះនឹងកាន់តែមានសមត្ថភាពល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយអនាគតពួកគេនឹងអាចបន្តជំនាញទាំងនេះដល់អ្នកជំនាន់ក្រោយៗទៀត
ដែលធ្វើឲ្យកិច្ចការអភិរក្សមរតកដូនតាមាននិរន្តរភាពបាន៕









ឧបសម្ព័ន្ធ

ចំណងជើងព័ត៌មាន **លេខទំព័រ**

ផ្នែកទី ១
សកម្មភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា

- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធ អតីតយុទ្ធជននៅក្នុងឱកាសរំឭកខួបលើកទី៣៨ នៃទិវាជ័យជម្នះ៧មករា (៧.០១.១៩៧៩-៧.០១.២០១៧) ៨
- រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិរដ្ឋOntarioនៃប្រទេសកាណាដា មកស្វែងយល់ការងារគ្រប់គ្រងរមណីយដ្ឋានអង្គរពីសំណាក់អាជ្ញាធរជាតិអប្សរា ១៤
- រីដៅអូរដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិរដ្ឋOntarioនៃប្រទេសកាណាដា មកស្វែងយល់ការងារគ្រប់គ្រងរមណីយដ្ឋានអង្គរពីសំណាក់អាជ្ញាធរជាតិអប្សរា ១៦
- ថ្នាក់ដឹកនាំអាយស៊ីស៊ីអង្គរជួបពិភាក្សាដើម្បីកំណត់ទិសដៅសម្រាប់កិច្ចប្រជុំអន្តរជាតិស្តីពីអង្គរ ៣៦
- អាជ្ញាធរជាតិអប្សរាចូលរួមរំលែកមរណទុក្ខជាមួយក្រុមគ្រួសារនៃសព ឯកឧត្តម ឃួន ឃុននាយ ៤៧
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងក្រុមការងារគ្រប់លំដាប់ថ្នាក់ប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធឯកឧត្តម ឃួន ឃុននាយ ៥៩
- ដំណើរទស្សនកិច្ចរបស់សមាជិកសភាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នៅការដ្ឋានអភិរក្សចម្លាក់ថ្ម របស់អាជ្ញាធរជាតិអប្សរានាប្រាសាទអង្គរវត្ត ៦៥
- អ្នកជំនាញបេតិកភណ្ឌវប្បធម៌តំបន់ទន្លេមេគង្គចូលជួបសម្តែងការគួរសម ជាមួយឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ៧១
- ជំនួបពិភាក្សាការងាររវាងអាជ្ញាធរជាតិអប្សរានិងនគរបាលការពារបេតិកភណ្ឌ ទទួលបានលទ្ធផលគាប់ចិត្តយ៉ាងខ្លាំង ៧៦
- ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាលើកពានរដ្ឋបាលខេត្តសៀមរាបជាលើកទី២ ..... ៨១
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចុះពិនិត្យទីតាំងបញ្ចាំងខ្សែភាពយន្ត "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" ៨៨
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ទទួលស្វាគមន៍ព្រះរាជដំណើរយាងមកដល់ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនីនាថ សីហនុ ៩០
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមក្នុងព្រះរាជពិធីកាត់ឫសសីមានៅវត្តស្វាយដង្គំខេត្តសៀមរាប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះមហាក្សត្រ ៩៣
- សហភាពសហព័ន្ធយុវជនកម្ពុជាប្រារព្ធពិធីប្រុងពលីអង្គរសង្រ្កានលើកទី៥នាឆ្នាំ២០១៧ ..... ៩៩
- អាជ្ញាធរជាតិអប្សរាជួបពិភាក្សាជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា អំពីការរៀបចំព្រឹត្តិការណ៍អង្គរសង្រ្កានត្តាំ២០១៧ ..... ១១៥
- ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ចូលជួបសម្តែងការគួរសមជាមួយ ថ្នាក់ដឹកនាំស្ថាប័នមួយចំនួនរបស់ជប៉ុន ដែលបានជួយលើការងារអភិរក្សនៅតំបន់អង្គរ ១៣០
- អាជ្ញាធរជាតិអប្សរាសូមជូនពរ និងអបអរសាទរចំពោះ សម្តេចវិបុលបញ្ញា សុខ អាន ១៣១

- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានិងមន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់ប្រារព្ធពិធីគោរព វិញ្ញាណក្ខន្ធ សម្តេចវិបុលបញ្ញា សុខ អាន ១៣៧
- លោកជំទាវ អ៊ីរីណា បូកូវ៉ា អគ្គនាយិការអង្គការយូណេស្កូ សម្តែងគារវកិច្ចចំពោះមរណភាព របស់សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១៣៨
- មន្ត្រីជាន់ខ្ពស់២រូបរបស់គណបក្សសង្គ្រោះជាតិលោក លិម គិមយ៉ា និងលោក ហ៊ីង យឿន ធ្វើលិខិតសុំទោសដល់វិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន ទាំងយប់ថ្ងៃនេះតែម្តង ១៣៩
- រូបភាពពិធីដង្ហែសព សម្តេចវិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ ..... ១៤០
- រូបភាពពិធីបូជាសព សម្តេចវិបុលបញ្ញា សុខ អាន នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ នាមុខវត្តបុទុមវត្តី រាជធានីភ្នំពេញ ១៤១
- បន្ទាប់ពីការបូជាសពត្រូវបានបញ្ចប់, នៅល្ងាចថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧នេះ ធាតុរបស់សម្តេចវិបុលបញ្ញា សុខ អាន ត្រូវបានក្រុមគ្រួសាររៀបចំតាមពិធីសាសនាដាក់ចូលទៅក្នុងទឹកទន្លេមុខព្រះបរមរាជវាំង ១៤៣
- វីដេអូ៖ ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ សម្តេចវិបុលបញ្ញា សុខ អាន ១៤៤
- សូមថ្លែងអំណរគុណជូនដល់ ឯកឧត្តម អគ្គនាយក អគ្គនាយករង ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សា លោក លោកស្រី ឧបការី ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងមន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរាទាំងអស់ ដែលបានចូលរួម គោរពវិញ្ញាណក្ខន្ធ និងពិធីដង្ហែសព សម្តេចវិបុលបញ្ញា សុខ អាន នាថ្ងៃទី១៨ និង ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ ..... ១៤៤
- អាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជាមួយអ្នកជំនាញអន្តរជាតិ ដែលកំពុងអនុវត្តការងារនៅក្នុងរមណីយដ្ឋានអង្គរ ១៥២
- ក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តបើកកិច្ចប្រជុំផ្ទៃក្នុងអំពីវឌ្ឍនភាព នៃការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ១៦៧
- ថ្នាក់ដឹកនាំមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាប្រារព្ធពិធីសូត្រមន្ត អបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ១៦៨
- គណៈប្រតិភូអាជ្ញាធរជាតិអប្សរាចូលជួបសម្តែងការគួរសមថ្នាក់ដឹកនាំ KOICA និងទស្សនកិច្ច នៅតាមវិទ្យាស្ថានស្រាវជ្រាវជាតិកូរ៉េមួយចំនួនទាក់ទងនឹងការអភិរក្សជួសជុលមរតកវប្បធម៌មនុស្សជាតិ ១៧១
- អាជ្ញាធរជាតិអប្សរា រួមជាមួយក្រសួងទេសចរណ៍ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនកងទ័ពនៃយោធភូមិភាគទី៤ ..... ១៧៦
- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈចុះជួបថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាជាលើកដំបូង ក្នុងឋានៈជាប្រធានអាជ្ញាធរជាតិអប្សរា ១៧៨
- ពិធីបួងសួងអង្គរសង្ក្រាន្តត្រូវបានរៀបចំនៅលើភ្នាររបែនប្រាសាទអង្គរវត្ត ១៧៩
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ១៩២
- ប្រធានអាជ្ញាធរជាតិអប្សរាជួបប្រជុំជាមួយមន្ត្រីរាជការថ្នាក់ដឹកនាំនៃអាជ្ញាធរអប្សរា ដើម្បីយល់ច្បាស់អំពីដំណើរការស្ថាបនានិងការគ្រប់គ្រងរមណីយដ្ឋានអង្គរ ១៩៣

- អាជ្ញាធរជាតិអប្សរាបង្កើតក្រុមការងារប្រតិកម្មរហ័សសម្រាប់ដោះស្រាយបញ្ហាបន្ទាន់ៗ ជាមួយប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ ២០៤
- អាជ្ញាធរជាតិអប្សរាឧបត្ថម្ភថវិកា១២លានរៀលដល់កាកបាទក្រហមនិងអឌ្ឍចន្ទក្រហមប្រចាំខេត្តសៀមរាប នាឱកាសអបអរសាទរខួបលើកទី១៥៤ ..... ២១៣
- ប្រធានអាជ្ញាធរជាតិអប្សរាចុះទស្សនកិច្ចភូមិធម្មជាតិរុនតាឯក ២២៩
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាជួបជុំមន្ត្រីបុគ្គលិករបស់ខ្លួនដើម្បីជំរុញការចូលរួមបោះឆ្នោតឃុំសង្កាត់ខាងមុខនេះ ២៣៧
- ប្រធានអាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជាមួយអ្នកជំនាញការជាន់ខ្ពស់មុនកិច្ចប្រជុំបច្ចេកទេសនៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ២៥៦
- ប្រតិភូគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ចូលគោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន ក្នុងឱកាសបុណ្យខួបគម្រប់១០០ថ្ងៃ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ២៥៩

ផ្នែកទី ២
កិច្ចសហប្រតិបត្តិការអន្តរជាតិ

- កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ បានដំណើរការហើយនៅព្រឹកនេះ ៨០
- ICC-Angkor គោរពវិញ្ញាណក្ខន្ធចំពោះមរណភាពឯកឧត្តម ឃួន ឃុននាយ ៨១
- សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៧នៃគណៈកម្មការអាយស៊ីស៊ី-អង្គរ ៨៥
- វីដេអូះសន្និសីទសារព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំបច្ចេកទេសលើកទី២៧និងកិច្ចប្រជុំពេញអង្គលើកទី២៣ នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ៦៨
- កិច្ចប្រជុំពេញអង្គលើកទី៣នៃអាយស៊ីស៊ី-ព្រះវិហារ គោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន និងកោតសរសើរពីវីរភាពរបស់សម្តេចក្នុងកិច្ចការងារបេតិកភណ្ឌជាតិ ១៤៥
- ប្រតិភូគណៈកម្មាធិការអាយស៊ីស៊ីអង្គរចូលគាល់ព្រះមហាក្សត្រ ដើម្បីទូលថ្វាយអំពីដំណើរវិវត្តនៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ ២១៥
- ប្រតិភូនៃកិច្ចប្រជុំសេដ្ឋកិច្ចពិភពលោកមកទស្សនារមណីយដ្ឋានអង្គរ ២១៨
- អាយស៊ីស៊ី-អង្គរនឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី២៨របស់ខ្លួន នៅថ្ងៃទី២១-២២ ខែមិថុនា ២៥៤
- ស្វែងយល់ពីគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ ២៥៧
- ប្រតិភូគណៈកម្មាធិការអាយស៊ីស៊ីអង្គរ ចូលគោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន ក្នុងឱកាសបុណ្យខួបគម្រប់១០០ថ្ងៃ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ២៥៩
- អាជ្ញាធរជាតិអប្សរាចុះអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នអន្តរជាតិចំនួនពីរលើការងារអភិរក្ស ២៦០

ផ្នែកទី ៣
ការអភិរក្ស និងជួសជុល

- សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរជួសជុលបាន៦០%ហើយ ៦
- ស្ពានអណ្តែតទឹកបណ្តោះអាសន្ននៅប្រាសាទអង្គរវត្តនឹងបង្ហាញរូបរាងនាពេលឆាប់ៗនេះហើយ! ២៨
- អ្នកជំនាញការជាន់ខ្ពស់អន្តរជាតិផ្នែកបេតិកភណ្ឌរបស់អាយស៊ីស៊ី-អង្គរ
  ចុះពិនិត្យការដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ ៣០
- អគ្គនាយកអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញការជាន់ខ្ពស់បេតិកភណ្ឌនៃ ICC-Angkor
  ចុះពិនិត្យការដ្ឋានកំណាយនៅ ស្ពានហាលប្រាសាទអង្គរវត្ត ៣៣
- អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសម្មភាពជួសជុលកំណាត់ផ្លូវរ៉ង់តូច ពីខាងកើតកសិន្នុអង្គរទៅដល់ស្រះស្រង់
  ដើម្បីដោះស្រាយការហុយរំខានការធ្វើដំណើរ ៣៥
- ឯកឧត្តម សុខ សង្វារ និងអ្នកជំនាញការអាយស៊ីស៊ី-អង្គរ ចុះពិនិត្យការងារមួយចំនួននៅរមណីយដ្ឋានអង្គរ ៣៧
- អាជ្ញាធរជាតិអប្សរានិងស្ថាប័នអភិរក្សប្រាសាទមកពីប្រទេសចិន
  ជួបពិភាក្សាគ្នាអំពីលទ្ធភាពអនុវត្តគម្រោងអភិរក្សនាពេលអនាគត ៣៩
- កំពែងអង្គរធំដែលជួសជុលដោយអ្នកជំនាញអប្សរាទទួលបានការសាទរគាំទ្រពីអ្នកជំនាញអាយស៊ីស៊ី-អង្គរ ៤៣
- ការជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត រួមចំណែកបណ្តុះបណ្តាលធនធានមនុស្ស
  លើវិស័យបេតិកភណ្ឌ ៤៨
- អាជ្ញាធរជាតិអប្សរាបន្តសហការជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា ក្នុងកិច្ចការជួសជុលប្រាសាទតាព្រហ្ម ..៦០
- អគ្គនាយកអាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជួសជុល
  សារមន្ទីរព្រះនរោត្តមសីហនុអង្គរជាមួយក្រុមហ៊ុនអ៊ីអុង ៦២
- ប្រជាជននៅភូមិគោកកក់ ឃុំស្វាយចេក ស្រុកអង្គរធំ ប្រគល់បដិមាដែលរើសបានជូនអាជ្ញាធរជាតិអប្សរា ៨២
- សេចក្តីជូនដំណឹងស្តីពី ការបើកការដ្ឋានសាងសង់ និងរៀបចំកម្មវិធីអភិរក្សបេតិកភណ្ឌ
  សម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០១៧ ..... ៩៨
- អាជ្ញាធរជាតិអប្សរាជួយផ្នែកបច្ចេកទេសក្នុងការជួសជុលវិហារបុរាណវត្តអារញ្ញសាគរ ១០២
- អាជ្ញាធរជាតិអប្សរាបន្តសហការជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រចិន
  ដើម្បីជួយដល់ការងារគ្រប់គ្រងតំបន់សៀមរាប អង្គរ ១១១
- វិទ្យាស្ថានស្រាវជ្រាវជាតិណាវ៉ាគ្រោងនឹងបញ្ចប់ការជួសជុលប្រាង្គខាងជើង
  នៃប្រាសាទតុបខាងលិចនៅពាក់កណ្តាលឆ្នាំ២០១៧នេះ ១២៥
- អ្នកជំនាញជប៉ុន និងអាជ្ញាធរជាតិអប្សរាពិភាក្សាបញ្ហាបច្ចេកទេសសម្រាប់ការអភិរក្ស
  និងជួសជុលស្ពានហាលប្រាសាទអង្គរវត្ត ១៤៨
- បច្ចេកទេសរំលើងថ្មប្រាសាទនាសម័យអង្គរត្រូវបានតាំងបង្ហាញ
  និងសម្តែងឡើងវិញនៅសកលវិទ្យាល័យ សូហ្វីយ៉ាប្រទេសជប៉ុន ១៤៩
- ក្រុមអភិរក្សធ្វើកំណាយសង្គ្រោះនៅប្រាសាទតាព្រហ្មបន្តជួសជុលសាលរបាំ ១៦៣
- លោកតា សុត ជុយ អ្នកស្រុកអង្គរស្រឡាញ់ការងារជួសជុលប្រាសាទ និងចង់ឲ្យកូនចៅបន្តការងារនេះ ១៩៤

- ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តនឹងដាក់ឲ្យដំណើរការនៅដើមខែឧសភាខាងមុខនេះ ១៩៨
- មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាបាននិងកំពុងរៀបចំគម្រោងអភិរក្សប្រាសាទថៅស្រីវិបុល ២០២
- សាលរបាំប្រាសាទតាព្រហ្មកំពុងជួសជុលក្នុងដំណាក់កាលទី២ ..... ២០៩
- អាជ្ញាធរជាតិអប្សរានិងនគរបាលការពារបេតិកភណ្ឌជួបពិភាក្សាគ្នាដើម្បីពង្រឹងកិច្ចការពារបេតិកភណ្ឌអង្គរ ២១៤
- កំពែងប្រាសាទបន្ទាយក្តីជ្រុងពាយ័ព្យត្រូវបានអ្នកជំនាញអាជ្ញាធរជាតិអប្សរាកំពុងជួសជុល ២១៧
- ចម្លាក់ផ្កាឈូកដ៏ធំនៅលើរានហាលព្រះលានជល់ដំរីនឹងលេចចេញរូបរាងឡើងវិញនៅខែសីហាខាងមុខនេះ ២២២
- អាជ្ញាធរជាតិអប្សរាបោះបង្គោលរបងជុំវិញប្រាសាទបាយ័ន្តដើម្បីលើកកម្ពស់សោភ័ណភាព និងសណ្តាប់ធ្នាប់ចរាចរណ៍ ២២៨
- អាជ្ញាធរជាតិអប្សរាសម្តែងការព្រួយបារម្ភចំពោះការរីករាលដាលសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ ២៤១
- អាជ្ញាធរជាតិអប្សរាប្រជុំពិភាក្សាជាមួយនគរបាលការពារបេតិកភណ្ឌ លើបញ្ហាសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ ២៤៦
- កម្ពុជាជាប្រទេសគំរូមួយដែលស្ថាប័នទេសចរណ៍និងវប្បធម៌ធ្វើការរួមគ្នាដើម្បីនិរន្តរភាពនៃតំបន់បេតិកភណ្ឌ ២៥០
- ប្រជាពលរដ្ឋសាងសង់សំណង់ខុសច្បាប់នៅជិតប្រាសាទបន្ទាយក្តីស្ទុះគ្រចិត្តរុះរើសំណង់ដោយខ្លួនឯង ២៥៣
- តំណាងអង្គការយូណេស្កូប្រចាំកម្ពុជាសម្តែងការគាំទ្រចំណាត់ការទប់ស្កាត់ការរីករាលដាលសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ ២៦២
- អ្នកជំនាញនៃអង្គការយូណេស្កូ បង្ហាញភាពមហន្តរាយនៃបេតិកភណ្ឌជុំវិញពិភពលោក ដើម្បីរំឭកដល់ការអភិរក្សរមណីយដ្ឋានអង្គរ ២៦៣
- បើយើងជាម្ចាស់ស្រុកពិតប្រាកដ គ្មានអ្វីដែលព្រួយបារម្ភក្នុងការសាងសង់ផ្ទះនោះទេ! ២៦៥
- សំណង់ខុសច្បាប់ក្នុងតំបន់អង្គរនឹងត្រូវបន្តរុះរើក្នុងពេលឆាប់ៗនេះ ២៦៦
- ក្រុមអភិរក្សថ្មើរជើងបន្តការងារជួសជុលបង្គោលសីមានៅប្រាសាទបន្ទាយស្រី ២៦៧

ផ្នែកទី ៨
ការគ្រប់គ្រងបរិស្ថាន ទឹក និងព្រៃឈើ

- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រឹមែកឈើងាប់ រស់ នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ ៨
- ដើមស្គង់ចំណាស់មួយដើមក្នុងតំបន់អង្គរត្រូវបានជួយសង្គ្រោះដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា ១២
- អាជ្ញាធរជាតិអប្សរាបន្តដាំកូនឈើបន្ថែមទៀតនៅតាមជើងទេរទំនប់បារាយណ៍ជ័យតដាក ដើម្បីការពារការហូរច្រោះដីចូលក្នុងបារាយណ៍ ១៣
- ឆ្នាំ២០១៦កន្លងទៅនេះអាជ្ញាធរជាតិអប្សរាដាំកូនឈើបានជាង៦ម៉ឺនដើមក្នុងរមណីយដ្ឋានអង្គរ ១៦
- សត្វទោចមុដដ៏កម្រដែលអាជ្ញាធរជាតិអប្សរាព្រលែងក្នុងព្រៃអង្គរកំពុងបង្កើនការបន្តពូជ ៦៦
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ រស់ នៅបរិវេណប្រាសាទបេងមាលា ៧៩

- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ រស់ នៅបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ ៨០
- ស្តាប់ធានាគុណភាពជប៉ុនJQAបើកសវនកម្ម លើការងារបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ៨៧
- លទ្ធផលសវនកម្ម៖ អាជ្ញាធរជាតិអប្សរានៅតែបន្តភាពវិជ្ជមានលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ! ៩៤
- អាជ្ញាធរជាតិអប្សរា ស្តាប់ធនJQA និងមន្ទីរអប់រំយុវជននិងកីឡា សហការគ្នាអប់រំកុមារអង្គរអំពីបរិស្ថាន ១២១
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើងាប់ និងកាត់ក្រឹមែកឈើងាប់ រស់នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ ១២៣
- មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាប្រាប់ពលរដ្ឋកុំឲ្យបារម្ភពីបញ្ហាដង្កូវចោះដើមឈើ ១២៩
- អាជ្ញាធរជាតិអប្សរា និងមជ្ឈមណ្ឌល HIST របស់ចិន នឹងចុះអនុស្សរណៈយោគយល់ បន្តលើការងារ កិច្ចសហប្រតិបត្តិការរួមគ្នា ១៥០
- សេចក្តីជូនដំណឹងស្តីពី ការកាត់យកចេញមែកឈើទាល០១ដើម នៅខាងលិចប្រាសាទបាយ័ន ១៦១
- អ្នកជំនាញរៀបចំកាត់ក្រឹ និងព្យាបាលដើមឈើទាលដែលមានអាយុកាលជាង១០០ឆ្នាំជាប់ប្រាសាទបាយ័ន ១៨៥
- ទ្វារទឹកជុំវិញកសិន្ទុប្រាសាទចៅស្រីវិបុលផ្តល់អត្ថប្រយោជន៍ទាំងការងារអភិរក្ស និងសហគមន៍ ២០៧
- អាជ្ញាធរជាតិអប្សរាសហការរៀបចំពិធីដាំកូនឈើអនុស្សាវរីយ៍អបអរសាទរសន្និសីទទេសចរណ៍អន្តរជាតិ ២៤៣
- ទេសភាពបៃតងបានរួមចំណែកធ្វើឲ្យអង្គរកាន់តែល្បីល្បាញលើសកលលោក ២៤៧
- សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើងាប់ កាត់ពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើងាប់ មែករស់នៅតាមបរិវេណប្រាសាទ និងតាមទីតាំងនានាក្នុងរមណីយដ្ឋានអង្គរ ២៤៩

ផ្នែកទី ៥
ការបណ្តុះបណ្តាល

- អាជ្ញាធរជាតិអប្សរានឹងបើកវគ្គបណ្តុះបណ្តាលភាសាចិនដល់មន្ត្រី-បុគ្គលិក ២
- វីដេអូ ៖ អាជ្ញាធរជាតិអប្សរានឹងបើកវគ្គបណ្តុះបណ្តាលភាសាចិនដល់មន្ត្រី-បុគ្គលិក ៣
- អាជ្ញាធជាតិអប្សរាពង្រឹងចំណេះដឹងបេតិកភណ្ឌដល់ឆ្មាំកម្មករតាមមូលដ្ឋាន ២៩
- ក្រុមគម្រោងអភិរក្សប្រាសាទព្រះពិធូរបណ្តុះបណ្តាលបុគ្គលិកជំនាញ នៃអាជ្ញាធរជាតិអប្សរាពីរបៀបប្រើប្រាស់ឧបករណ៍ស្ទង់រចនាសម្ព័ន្ធប្រាសាទក្រោមដី ៥៤
- អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាផ្តល់បទពិសោធន៍គ្រប់គ្រងរមណីយដ្ឋានអង្គរ ដល់ក្រុមនិស្សិតមកពីប្រទេសកូរ៉ ៧៣
- និស្សិតសាកលវិទ្យាល័យតិចណូចុះកម្មសិក្សាស្វែងយល់ពីប្រព័ន្ធគ្រប់គ្រងទឹកនៅតំបន់អង្គរ ៩១
- កម្មវិធីបណ្តុះបណ្តាលភាសាចិនដល់មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាចាប់ដំណើរការហើយ ១០៤
- គម្រោងជួសជុលក្រុមប្រាសាទព្រះពិធូររបស់កូរ៉ បន្តបណ្តុះបណ្តាលមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា លើការងារវាស់ស្ទង់ស្រទាប់ដី និងកម្រិតទឹក ១២០
- អាជ្ញាធរជាតិអប្សរា ស្តាប់ធនJQA និងមន្ទីរអប់រំយុវជននិងកីឡា សហការគ្នាអប់រំកុមារអង្គរអំពីបរិស្ថាន ១២១

- មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា១៤នាក់ចូលរួមកិច្ចប្រជុំផ្លាស់ប្តូរយោបល់បច្ចេកទេស និងបង្ហាញលទ្ធផលសិក្សាស្រាវជ្រាវសម្រាប់គម្រោងអភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិធូរ ក្នុងឧទ្យានអង្គរ នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉ៃ ១៦៦
- គណៈប្រតិភូអាជ្ញាធរជាតិអប្សរាបញ្ចប់ទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រង ជួសជុល និងអភិរក្សបេតិកភណ្ឌវប្បធម៌នៅសាធារណរដ្ឋកូរ៉ៃ ១៨១
- និស្សិតបុរាណវិទ្យាជំនាន់ទី២៥ បញ្ចប់ទស្សនកិច្ចសិក្សារយៈពេល១០ថ្ងៃ ដើម្បីស្វែងយល់ពីអរិយធម៌ខ្មែរនៅក្នុង និងក្រៅតំបន់អង្គរ ២១១
- អាជ្ញាធរជាតិអប្សរាសហការជាមួយស្ថានទូតអាមេរិកប្រចាំកម្ពុជាបណ្តុះបណ្តាលមន្ត្រី លើជំនាញគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌ ២២០
- ក្រុមនិស្សិតចិនហុងកុងស្វែងយល់ពីការផលិតកុលាលភាជន៍ក្នុងតំបន់អង្គរ ២៣៩

ផ្នែកទី ៦
ការសិក្សាស្រាវជ្រាវ

- លទ្ធផលនៃកំណាយបុរាណវិទ្យាបង្ហាញថាស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ធ្លាប់បានជួសជុលនាសម័យបុរាណបន្ទាប់ពីកសាងរួច ២០
- អ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរាបង្ហាញថាស្ពានអណ្តែតទឹកមានប្រើតាំងពីសម័យបុរាណមកម្ល៉េះ ២៧
- សេចក្តីជូនដំណឹងស្តីអំពីការបើកកំណាយស្រាវជ្រាវស្ថានីយស្លដែកបុរាណនៅក្នុងតំបន់អង្គរ ៣២
- មគ្គុទ្ទេសក៍ទេសចរណ៍គាំទ្រចំពោះការកំណាយស្រាវជ្រាវនៅស្ថានីយ៍ស្លដែកនៅភូមិសាលាក្រ៉ាន់ ដោយក្រុមអ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរា ៥៦
- សេចក្តីជូនដំណឹងស្តីពីការធ្វើបទបង្ហាញក្រោមប្រធានបទ ការស្វែងយល់ការរស់នៅរបស់ប្រជាជននៅបុរេប្រវត្តិ តាមរយៈការសិក្សាកុលាលភាជន៍ នៅសាលសិក្សាលលៃ នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ១០៥
- សេចក្តីជូនដំណឹងស្តីពីការធ្វើកំណាយស្រាវជ្រាវនៅប្រាសាទតាព្រហ្ម ១៣៣
- អ្នកស្រាវជ្រាវយល់ថា បំណែកកុលាលភាជន៍ ផ្តល់នូវទិន្នន័យច្រើនអំពីសង្គមមនុស្សបុរាណ ១៩៥
- អ្នកស្រាវជ្រាវយល់ថា ចម្លាក់នៅតាមថែវនៃប្រាសាទអង្គរវត្តមានទំនាក់ទំនងទៅនឹងយុគទាំង៤របស់ចក្រវាឡនៃសាសនាហិណ្ឌូ ២២៤
- មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរទទួលបានសៀវភៅថ្មី៧ក្បាលបន្ថែមពីដៃគូស្រាវជ្រាវ ២៣៥

ផ្នែកទី ៧
ការអភិវឌ្ឍទេសចរណ៍

- តំបន់រមណីយដ្ឋានអង្គរចាប់ផ្តើមបង្កើនសេវាទូរសព្ទនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ4Gសម្រាប់អ៊ីនធើណេត ១១
- សេចក្តីជូនដំណឹងស្តីពីការរៀបចំការដ្ឋានថ្មី និងផ្អាកការទស្សនារោងទងខាងក្រៅប្រាសាទបាយ័ន ២២
- ស្ពានអណ្តែតទឹកបណ្តោះអាសន្ននៅប្រាសាទអង្គរវត្តនឹងបង្ហាញរូបរាងនាពេលឆាប់ៗនេះហើយ! ២៤
- វីដេអូ៖ ក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរអង្គរ ក្នុងលទ្ធផលការងាររយៈពេល៣ឆ្នាំ ២៥

- សេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យដំណើរការគេហទំព័រទេសចរណ៍អង្គរ (www.angkor.com.kh) ៥២
- គេហទំព័រទេសចរណ៍អង្គរថ្មី នឹងដាក់ឲ្យដំណើរការចាប់ពីថ្ងៃទី០១ ខែកុម្ភៈ នេះហើយ ៥៣
- កិច្ចសម្ភាសន៍ ឯកឧត្តម សុខ សង្វារ អគ្គនាយករងអាជ្ញាធរជាតិអប្សរា ស្តីពីការទាក់ទាញភ្ញៀវទេសចរតាមរយៈគេហទំព័រ www.angkor.com.kh ក្នុងកម្មវិធីពីកម្ពុជា របស់ BTVNews កាលពីថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៧ .. ៨៣
- មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរាចែករំលែកបទពិសោធន៍ការគ្រប់គ្រងទេសចរណ៍អង្គរដល់លោកគ្រូអ្នកគ្រូមកពីវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ១២៧
- ភ្ញៀវទេសចរជាច្រើនរង់ចាំមើលព្រឹត្តិការណ៍ថ្ងៃរះចំកណ្តាលកំពូលប្រាសាទអង្គរវត្ត ១៤៧
- ក្រុមប្រតិបត្តិអាជ្ញាធរជាតិអប្សរាសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តបើកកិច្ចប្រជុំផ្ទៃក្នុងអំពីការកែចម្រើននៃសកម្មភាពការងារ និងការត្រៀមខ្លួនបង្ករភាពងាយស្រួលដល់ភ្ញៀវទេសចរមកកម្សាន្តថ្ងៃចូលឆ្នាំ ១៥៦
- អាជ្ញាធរអប្សរារៀបចំចំណតរ៉ឺម៉កនៅខាងលិចប្រាសាទតាព្រហ្ម ១៧៣
- ចាប៉ីដងវែងខ្នាតយក្សនឹងត្រូវដង្ហែចូលបរិវេណព្រឹត្តិការណ៍អង្គរសង្ក្រាន្តនារសៀល១២មេសានេះ ១៧៧
- អាជ្ញាធរជាតិអប្សរាចែកចាយទឹកដោយឥតគិតថ្លៃក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ១៨០
- អង្គរសង្ក្រាន្តឆ្នាំ២០១៧បានបញ្ចប់ទៅជាមួយនឹងកំណើនអ្នកចូលរួមយ៉ាងច្រើនកុះករ ១៨៤
- ទីតាំងអភិរក្សបេតិកភណ្ឌដែលរៀបចំដោយអាជ្ញាធរជាតិអប្សរានៅមុខអង្គរវត្ត ទាក់ទាញភ្ញៀវទេសចរជាតិ-អន្តរជាតិជិត៥ម៉ឺននាក់ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត២០១៧ ..... ១៨៦
- ត្រីមាសទី១ដើមឆ្នាំ២០១៧ អាជ្ញាធរជាតិអប្សរាបានរកឃើញ និងប្រគល់សម្ភារៈជូនភ្ញៀវទេសចរវិញចំនួន៦៦ករណី ១៨៨
- ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តនឹងដាក់ឲ្យដំណើរការនៅដើមខែឧសភាខាងមុខនេះ ១៩៨
- សារមន្ទីរវាយនកណ្ឌបើកឲ្យទស្សនាដោយឥតគិតថ្លៃក្នុងថ្ងៃទិវាសារមន្ទីរអន្តរជាតិ ២២១
- ស្ពានអណ្តែតទឹកនៅមុខប្រាសាទអង្គរវត្តគ្រោងដាក់សម្ពោធជាផ្លូវការនៅថ្ងៃទី២៥ ឧសភា ២២៦
- ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្តបើកជូនភ្ញៀវទេសចរធ្វើដំណើរជាផ្លូវការហើយ ២៣០
- អង្គរវត្តនារដូវវស្សាស្រស់ស្អាតប្លែកម្យ៉ាងពីរដូវប្រាំង ២៣៦
- សម្រស់នាគព័ន្ធនារដូវដើមវស្សា ២៣៨
- ចាប៉ីដងវែងខ្នាតយក្សត្រូវបានដង្ហែទៅរក្សាទុកនៅសាលាខេត្តបាត់ដំបង ២៤៤
- កម្ពុជាជាប្រទេសគំរូមួយដែលស្ថាប័នទេសចរណ៍និងវប្បធម៌ធ្វើការរួមគ្នាដើម្បីនិរន្តរភាពនៃតំបន់បេតិកភណ្ឌ ២៥០

ផ្នែកទី ៨
ការអភិវឌ្ឍសហគមន៍

- អាជ្ញាធរជាតិអប្សរាបន្តជំរុញប្រជាពលរដ្ឋក្នុងឧទ្យានអង្គរឲ្យប្រើប្រាស់បង្គន់អនាម័យ ៥
- ក្រុមគ្រូពេទ្យស្ម័គ្រចិត្តជុំវិញពិភពលោកចុះពិនិត្យសុខភាពនិងព្យាបាលជំងឺជូនប្រជាជននៅភូមិតាកុះក្នុងឧទ្យានអង្គរដោយមិនគិតថ្លៃ ៩
- ក្រុមហ៊ុនសូម៉ាពាណិជ្ជឧបត្ថម្ភពូជបន្លែជូនដល់ប្រជាពលរដ្ឋនៅភូមិធម្មជាតិរុនតាឯក ១៨

- ក្នុងឆ្នាំ២០១៦កន្លងទៅនេះអាជ្ញាធរជាតិអប្សរាបានចែកកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយនិងទារក ដល់ស្ត្រីទើបឆ្លងទន្លេរួចក្នុងតំបន់អង្គរជិត២ពាន់នាក់ ១៩
- អាជ្ញាធរជាតិអប្សរាចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២៥
- អាជ្ញាធរជាតិអប្សរាផ្តល់សង្កសីជូនស្ត្រីមេម៉ាយចាស់ជរាទីទ័លក្រម្នាក់នៅស្រុកបន្ទាយស្រី ៣៤
- អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសម្មភាពជួសជុលកំណាត់ផ្លូវរ៉ង់តូច ពីខាងកើតកសិន្ទុអង្គរទៅដល់ស្រះស្រង់ ដើម្បីដោះស្រាយការហុយរំខានការធ្វើដំណើរ ៣៥
- ក្រុមការងារសហគន៍អាជ្ញាធរជាតិអប្សរាបន្តចុះលើកកម្ពស់សុខុមាលភាពម្តាយ និងទារកដល់ស្ត្រីក្នុងតំបន់អង្គរ ៥៩
- ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាបន្តអនុញ្ញាតសំណើរជួសជុលនិងសាងសង់តូចតាច នៅក្នុងតំបន់ការពារឧទ្យានអង្គរ ៦៨
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តចុះចែកកញ្ចប់ទារកដល់ពលរដ្ឋឃុំខ្នាត ៦៩
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តពិនិត្យ និងអនុញ្ញាតសំណើជួសជុលនិងសាងសង់សំណង់ខ្នាតតូច ដល់អ្នកភូមិនគរក្រៅ ៧២
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបន្តចុះអប់រំផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកភូមិថ្នល់ទទឹង ៧៧
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា៣ក្រុម ចុះពិនិត្យសំណើជួសជុល និងអនុញ្ញាតបានចំនួន១២ករណី ៨៣
- ប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតសាងសង់ផ្ទះនៅតំបន់អង្គរ ថាមានភាពងាយស្រួលក្នុងការស្នើសុំ ៨៦
- រយៈពេលពីរសប្តាហ៍ដើមខែកុម្ភៈនេះ អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងអនុញ្ញាតសំណើសុំជួសជុលផ្ទះ និងសាងសង់សំណង់ខ្នាតតូចជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរបាន៥៩ករណី ៩៦
- អាជ្ញាធរជាតិអប្សរានាំយកថវិកាទៅជួយឧបត្ថម្ភលោកមេឃុំស្វាយចេកដែលរងគ្រោះដោយភ្លើងឆេះផ្ទះ ១០១
- អាជ្ញាធរជាតិអប្សរាផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកភូមិថ្នល់បណ្តោយ ១១២
- អាជ្ញាធរជាតិអប្សរាបន្តអនុញ្ញាតជូនប្រជាពលរដ្ឋដើម្បីជួសជុលផ្ទះ ១១៦
- ក្នុងខែកុម្ភៈ អាជ្ញាធរជាតិអប្សរាចុះផ្សព្វផ្សាយពីបេតិកភណ្ឌដល់អ្នកស្រុកអង្គរបានជាង៥០០នាក់ ១២៦
- ក្នុងត្រីមាសទី០១នេះ អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតសំណើសុំសាងសង់សំណង់តូចតាច និងជួសជុលផ្ទះ ជូនអ្នកស្រុកអង្គរជាង១២០ករណី ១៥៧
- ក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំងចុះពិនិត្យសុខភាពដោយឥតគិតថ្លៃដល់ប្រជាជននៅភូមិធម្មជាតិរុនតាឯក ១៥៨
- ក្រុមហ៊ុនវិនិយោគទេសចរណ៍ធម្មជាតិអន្តរជាតិ CaHeng របស់ចិន ចាប់អារម្មណ៍ខ្លាំងនឹងការបណ្តុះបណ្តាលសិល្បៈរបស់កុមារនៅភូមិធម្មជាតិរុនតាឯក ១៦៩
- គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកទទួលភ្ញៀវទេសចរធ្វើសមាធិជាលើកដំបូង ១៧០
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានចុះអនុញ្ញាតជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១២១ ករណីក្នុងត្រីមាសទី១ ឆ្នាំ២០១៧ ..... ១៩៦
- ការចូលរួមអភិវឌ្ឍសហគមន៍ប្រជាពលរដ្ឋក្នុងតំបន់បេតិកភណ្ឌនៅតែជាការងារសំខាន់ របស់អាជ្ញាធរជាតិអប្សរា ២០៦

- ប្រជាពលរដ្ឋ១៣គ្រួសារនៅឃុំលាងដៃទទួលបានការឧបត្ថម្ភពីការខូចខាតដំណាំស្រូវកាលពីឆ្នាំ២០១៦ ពីអាជ្ញាធរជាតិអប្សរា ២១០
- អាជ្ញាធរជាតិអប្សរារួមចំណែកក្នុងការកសាងមណ្ឌលរដ្ឋបាលមន្ទីរខេត្តសៀមរាប ២១៩
- សមិទ្ធផលសំខាន់ៗនៃការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា រយៈពេល៣សប្តាហ៍ដំបូងក្នុងខែឧសភានេះ ... ២២៧
- សមិទ្ធផលសំខាន់ៗនៃការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា ក្នុងខែឧសភាកន្លងទៅនេះ ២៤២
- ប្រជាជនភូមិធម្មជាតិរុនតាឯកទទួលបានត្រាក់ទ័រ១គ្រឿងពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូកូរ៉េ នៃមហាវិទ្យាល័យ Dong Pusan និងក្រុមហ៊ុន Dream Airline Tour ២៥១

ផ្នែកទី ៩
ទំនៀមទម្លាប់អ្នកស្រុកអង្គរ

- ស្វែងយល់អត្ថន័យនៃពិធីកាត់សក់បង្កក់ឆ្នូបរបស់អ្នកអង្គរ ៥០
- ពិធីបុណ្យឡើងអ្នកតារាជ្យបង្ហាញពីការសាមគ្គីនិងស្រឡាញ់វប្បធម៌ជាតិរបស់អ្នកស្រុកអង្គរ! ៦៣
- រកត្រីត្រៀមឡើងមាឃ ទំនៀមអ្នកស្រុកអង្គរដែលនៅបន្តរហូតដល់បច្ចុប្បន្ន ៧៥
- ពិធីលៀងមេមត់ មរតកជំនឿរបស់អ្នកស្រុកអង្គរដែលបង្ហាញពីភាពសប្បាយរីករាយ និងជំនឿលើព្រលឹងដូនតាខ្មែរ! ១០៦
- មរតកជំនឿនៃអ្នកស្រុកអង្គរ ៖ ជម៤ ..... ១០៨
- អវត្តមានរបស់យុវវ័យក្នុងពិធីទំនៀមទម្លាប់ដូនតា ប្រឈមនឹងការបាត់បង់ទំនៀមទម្លាប់ទាំងនេះទៅថ្ងៃអនាគត!. ២០១

ផ្នែកទី ១០
ចំណេះដឹងទូទៅអំពីបេតិកភណ្ឌ

- នៅតំបន់អង្គរមានសិលាចារឹកជាភាសាភូមាចំនួន១១កន្លែងផ្សេងគ្នា ១
- អង្គរនឹងទទួលធ្វើជាទីតាំងសម្រាប់ការចាក់បញ្ចាំងភាពយន្តខ្នាតអន្តរជាតិ រឿងមុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ ៨៥
- ភាពយន្តរឿងមុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំបានបញ្ចប់បេសកកម្មនៅលើទឹកដីអង្គរ ១០០
- សេចក្តីជូនដំណឹងស្តីពី ការបើកឱ្យដំណើរការឡើងវិញនូវទំព័រហ្វេសប៊ុកផ្លូវការរបស់អាជ្ញាធរជាតិអប្សរា ១១០
- អង្គរសង្ក្រាន្តឆ្នាំ២០១៧ នឹងមកដល់ក្នុងពេលឆាប់ៗនេះ! សូមចូលរួមទាំងអស់គ្នា ថាតើអង្គរសង្ក្រាន្តឆ្នាំនេះមានអ្វីប្លែកខ្លះ? ១១៧
- ចម្លាក់បាយ័ន៖ ផ្នាំងមួយនៃសោកនាដកម្មទ័ពខ្មែរបរាជ័យក្រោមស្នាដៃចាម ១១៩
- ចម្លាក់បាយ័ន ៖ ចុះពីសំពៅឡើងសំប៉ាន ចុះពីសំប៉ានឡើងផ្សារ ១២៤
- ឯកសារដ៏មានសារៈសំខាន់សម្រាប់អ្នកចង់ដឹងពីតំបន់អង្គរដែលជាបេតិកភណ្ឌពិភពលោក ១៣៤
- ដំណឹងជ្រើសរើសបុគ្គលិកផ្នែកព័ត៌មាន ផ្នែកថតរូបភាព និងផ្នែកផលិតវីដេអូ ១៣៦

- ដំណឹងជ្រើសរើសបុគ្គលិកផ្នែកអភិរក្ស និងមគ្គុទេសក៍ ផ្នែកអគ្គិសនី និងផ្នែករដ្ឋបាល ឱ្យបម្រើការងារនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ១៥៣
- ចម្លាក់បាយ័ន ៖ វត្តមានទ័ពចិនក្នុងជួរទ័ពខ្មែរនៃជ័យជម្នះលើកងទ័ពចាម ១៥៤
- ចម្លាក់បាយ័ន ៖ សិល្បៈទស្សនីយភាពមួយនៅសម័យអង្គរ ១៥៥
- សេចក្តីជូនដំណឹងស្តីពីការផ្អាកយានជំនិះចូលបរិវេណទីតាំង Drop-off មុខប្រាសាទអង្គរវត្តជាបណ្តោះអាសន្ន .. ១៦៤
- ព្រះតេជគុណ ពិន សែម ៖ ភូមិមានីមានន្ទ មិនមែនភូមិគិរីមានន្ទទេ ១៧៤
- តើអ្នកទាំងអស់គ្នាដឹងទេថាចម្លាក់នៅប្រាសាទអង្គរវត្តមានទាក់ទងនឹងរឿងអ្វីខ្លះ? ១៨៣
- អាជ្ញាធរជាតិអប្សរានឹងរៀបចំបទបង្ហាញស្តីពី ការស្វែងយល់ការរស់នៅរបស់ប្រជាជន សម័យបុរេប្រវត្តិតាមរយៈការសិក្សាកុលាលភាជន៍ ១៨៩
- ចម្លាក់បាយ័ន ៖ ពិធីយញ្ញក្របីនៅលើចម្លាក់នៃប្រាសាទបាយ័ន ១៩១
- អបអរសាទរ! ប្រាសាទអង្គរវត្តរបស់ខ្មែរជាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុត លើពិភពលោកក្នុងឆ្នាំ២០១៧ ..... ២៣២
- ទស្សនវិស័យវែងឆ្ងាយអំពីការគ្រប់គ្រងបេតិកភណ្ឌរបស់រាជរដ្ឋាភិបាលកម្ពុជា នាំឲ្យអង្គរកាន់តែល្បីល្បាញលើពិភពលោក ២៣៣



ផលិតដោយនាយកដ្ឋានផ្សព្វផ្សាយ
ឆ្នាំ២០១៧

តើប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរមានសិទ្ធិអ្វីខ្លះលើដីធ្លីរបស់ខ្លួន?

១ ប្រជាពលរដ្ឋដែលមានលំនៅដ្ឋាន និងរស់នៅយូរលង់មកហើយ អាចបន្តរស់នៅតទៅទៀតបាន ដោយមិនមានការដេញឱ្យចាកចេញពីភូមិដ្ឋានឡើយ ។

២ ប្រជាពលរដ្ឋអាចរុះរើផ្ទះចាស់ទ្រុឌទ្រោម ឬសាងសង់ថ្មីជំនួសផ្ទះចាស់បាន ដោយមានការសុំអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរជាតិអប្សរា ។

៣ ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រង និងចាត់ចែងដីធ្លីតាមរូបភាពដូចជា ផ្ទេរមរតក ទៅឱ្យញាតិសន្តានពីឪពុកម្តាយទៅកូនក្មួយ ឬលក់ដូរឱ្យអ្នកភូមិផងជាមួយគ្នា ដើម្បីដោះស្រាយជីវភាព ប៉ុន្តែហាមឃាត់លើសកម្មភាពទិញ-លក់ដីរបស់ឈ្មួញក្នុងគោលដៅធ្វើអាជីវកម្មយកចំណេញសម្រាប់ក្រុមហ៊ុន ឬបុគ្គល ឬការទិញ-លក់ដី សម្រាប់យកទៅសាងសង់សណ្ឋាគារ ភោជនីដ្ឋាន ខាវ៉ាអូខេ ជាដើម។ល។